# សុត្តន្តបិដក





៧១

# SUTTANTA PITAKA

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ
# តតិយភាគ
# ៧១



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

# KHUDDAKANIKĀYA

# PAṬISAMBHIDĀMAGGA

# TATIYABHĀGA

# 71

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី

សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមឌ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

ទំព័រទទេ

# សេចក្តីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរ: **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (ជួន-ណាត) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សន្ទឹកច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

## តតិយភាគ

៧១

ព. ស. ២៤៨៦

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស បដិសម្ភិទាមគ្គោ

# តតិយោ ភាគោ

---

## មហាវគ្គេ មណ្ឌបេយ្យកថា

[១] មណ្ឌបេយ្យមិទំ ភិក្ខវេ ព្រហ្មចរិយំ សត្ថរិ សម្មុខីភូតេ តិវិធោ មណ្ឌោ សត្ថរិ សម្មុខីភូតេ ទេសនាមណ្ឌោ បដិគ្គហមណ្ឌោ ព្រហ្មចរិយមណ្ឌោ ។

កតមោ ទេសនាមណ្ឌោ ។ ចតុន្នំ អរិយសច្ចានំ អាចិក្ខណា ទេសនា បញ្ញបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ ចតុន្នំ សតិប្បដ្ឋានានំ ។ បេ ។ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស អាចិក្ខណា ទេសនា បញ្ញបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ អយំ ទេសនាមណ្ឌោ ។

កតមោ បដិគ្គហមណ្ឌោ ។ ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ ទេវា មនុស្សា យេ វា បនញ្ញេបិ កេចិ វិញ្ញាតារោ អយំ បដិគ្គហមណ្ឌោ ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

# តតិយភាគ

---

## មហាវគ្គ មណ្ឌបេយ្យកថា

[១] ម្នាលភិក្ខុទាំងឡាយ កាលព្រះសាស្តាគង់នៅក្នុងទីចំពោះមុខ ព្រហ្មចរិយៈនេះ ថាគួរក្រេបផឹក កាលព្រះសាស្តាគង់នៅក្នុងទីចំពោះមុខ សភាពថាមាន ៣ យ៉ាង គឺទេសនាថា ១ អ្នកទទួលថា ១ ព្រហ្មចរិយៈថា ១ ។

ទេសនាថា តើដូចម្តេច ។ ការប្រាប់ ការសម្តែង ការបញ្ញត្ត ការតាំងទុក ការបើក ការវែកញែក ការធ្វើឲ្យរាក់ នូវអរិយសច្ច ៤ ការប្រាប់ ការសម្តែង ការបញ្ញត្ត ការតាំងទុក ការបើក ការវែកញែក ការធ្វើឲ្យរាក់ នូវសតិប្បដ្ឋាន ៤ ។ បេ ។ នូវសម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ នេះទេសនាថា ។

អ្នកទទួលថា តើដូចម្តេច ។ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតានិងមនុស្ស ឬពួកជនដទៃណាមួយជាអ្នកដឹង នេះអ្នកទទួលថា ។

កតមោ ព្រហ្មចរិយមណ្ឌោ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ អយំ ព្រហ្មចរិយមណ្ឌោ ។

[២] អធិមោក្ខមណ្ឌោ សទ្ធិន្ទ្រិយំ អស្សទ្ធិយំ កសដោ អស្សទ្ធិយំ កសដំ ឆឌ្ឌេត្វា សទ្ធិន្ទ្រិយស្ស អធិមោក្ខមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ បគ្គហមណ្ឌោ វីរិយិន្ទ្រិយំ កោសជ្ជំ កសដោ កោសជ្ជំ កសដំ ឆឌ្ឌេត្វា វីរិយិន្ទ្រិយស្ស បគ្គហមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ ឧបដ្ឋានមណ្ឌោ សតិន្ទ្រិយំ បមាទោ កសដោ បមាទំ កសដំ ឆឌ្ឌេត្វា សតិន្ទ្រិយស្ស ឧបដ្ឋានមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ អវិក្ខេបមណ្ឌោ សមាធិន្ទ្រិយំ ឧទ្ធច្ចំ កសដោ ឧទ្ធច្ចំ កសដំ ឆឌ្ឌេត្វា សមាធិន្ទ្រិយស្ស អវិក្ខេបមណ្ឌំ បិវតីតិ

ព្រហ្មចរិយៈថ្វា តើដូចម្តេច ។ អរិយមគ្គមានអង្គ ៨ នេះឯង ។ ដូចម្តេចខ្លះ ។ គឺសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ នេះព្រហ្មចរិយៈថ្វា ។

[២] សទ្ធិន្ទ្រិយ ថ្វាដោយការជឿស៊ប់ អស្សទ្ធិយៈ (ការមិនជឿ) ជាកករល្អក់ បុគ្គលលះបោល នូវអស្សទ្ធិយៈ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វាដោយការជឿស៊ប់ របស់សទ្ធិន្ទ្រិយ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក វិរិយិន្ទ្រិយ ថ្វាដោយការផ្គងឡើង កោសជ្ជៈ ជាកករល្អក់ បុគ្គលលះបោល នូវកោសជ្ជៈជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វាដោយការផ្គងឡើង របស់វិរិយិន្ទ្រិយ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក សតិន្ទ្រិយ ថ្វាដោយការប្រុង បមាទៈ ជាកករល្អក់ បុគ្គលលះបោល នូវបមាទៈ ជាកករល្អក់ ហើយក្រេបផឹក នូវធម្មជាតដ៏ថ្វាដោយការប្រុង របស់សតិន្ទ្រិយ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក សមាធិន្ទ្រិយ ថ្វាដោយការមិនរាយមាយ ឧទ្ធច្ចៈ ជាកករល្អក់ បុគ្គលលះបោល នូវឧទ្ធច្ចៈជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វាដោយការមិនរាយមាយ របស់សមាធិន្ទ្រិយ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក

៣

មហាវគ្គេ មណ្ឌបេយ្យកថា

មណ្ឌបេយ្យំ ទស្សនមណ្ឌោ បញ្ញិន្ទ្រិយំ អវិជ្ជា កសដោ អវិជ្ជំ កសដំ ឆឌ្ឌេត្វា បញ្ញិន្ទ្រិយស្ស ទស្សនមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ អស្សទ្ធិយេ អកម្មិយមណ្ឌោ សទ្ធាពលំ អស្សទ្ធិយំ កសដោ អស្សទ្ធិយំ កសដំ ឆឌ្ឌេត្វា សទ្ធាពលស្ស អស្សទ្ធិយេ អកម្មិយមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ កោសជ្ជេ អកម្មិយមណ្ឌោ វីរិយពលំ កោសជ្ជំ កសដោ កោសជ្ជំ កសដំ ឆឌ្ឌេត្វា វីរិយពលស្ស កោសជ្ជេ អកម្មិយមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ បមាទេ អកម្មិយមណ្ឌោ សតិពលំ បមាទោ កសដោ បមាទំ កសដំ ឆឌ្ឌេត្វា សតិពលស្ស បមាទេ អកម្មិយមណ្ឌំ បិវតីតិ

បញ្ញិន្ទ្រិយ ថាដោយការឃើញ អវិជ្ជាជាកករល្អក់ បុគ្គលលះបោលនូវអវិជ្ជាជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លាដោយការឃើញ របស់បញ្ញិន្ទ្រិយ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក សទ្ធាពលៈ ថាដោយការមិនញាប់ញ័រ ព្រោះការមិនជឿ ការមិនជឿ ជាកករល្អក់ បុគ្គលលះបោល នូវការមិនជឿជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការមិនញាប់ញ័រព្រោះធម្មជាតមិនជឿ របស់សទ្ធាពលៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក វីរិយពលៈ ថាដោយការមិនញាប់ញ័រ ព្រោះសេចក្តីខ្ជិល សេចក្តីខ្ជិល ជាកករល្អក់ បុគ្គលលះបោល នូវសេចក្តីខ្ជិលជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លាដោយការមិនញាប់ញ័រ ព្រោះសេចក្តីខ្ជិល របស់វីរិយពលៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក សតិពលៈ ថាដោយការមិនញាប់ញ័រ ព្រោះបមាទៈ បមាទៈ ជាកករល្អក់ បុគ្គលលះបោលនូវបមាទៈជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លាដោយការមិនញាប់ញ័រព្រោះបមាទៈ របស់សតិពលៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក

មណ្ឌបេយ្យំ ឧទ្ធច្ចេ អកម្បិយមណ្ឌោ សមាធិពលំ
ឧទ្ធច្ចំ កសដោ ឧទ្ធច្ចំ កសដំ ឆឌ្ឌេត្វា សមាធិ-
ពលស្ស ឧទ្ធច្ចេ អកម្បិយមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ
អវិជ្ជាយ អកម្បិយមណ្ឌោ បញ្ញាពលំ អវិជ្ជា កស-
ដោ អវិជ្ជំ កសដំ ឆឌ្ឌេត្វា បញ្ញាពលស្ស អវិជ្ជាយ
អកម្បិយមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ ឧបដ្ឋានមណ្ឌោ
សតិសម្ពោជ្ឈង្គោ បមាទោ កសដោ បមាទំ កសដំ
ឆឌ្ឌេត្វា សតិសម្ពោជ្ឈង្គស្ស ឧបដ្ឋានមណ្ឌំ បិវ-
តីតិ មណ្ឌបេយ្យំ បវិចយមណ្ឌោ ធម្មវិចយសម្ពោ-
ជ្ឈង្គោ អវិជ្ជា កសដោ អវិជ្ជំ កសដំ ឆឌ្ឌេត្វា
ធម្មវិចយសម្ពោជ្ឈង្គស្ស បវិចយមណ្ឌំ បិវតីតិ

សមាធិពលៈ ថាដោយការមិនញាប់ញ័រ ព្រោះឧទ្ធច្ចៈ ឧទ្ធច្ចៈ ជាកករល្អក់ បុគ្គលលះចោល នូវឧទ្ធច្ចៈជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការមិនញាប់ញ័រព្រោះឧទ្ធច្ចៈ របស់សមាធិពលៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក បញ្ញាពលៈ ថាដោយការមិនញាប់ញ័រព្រោះអវិជ្ជា អវិជ្ជាជាកករល្អក់ បុគ្គលលះចោលនូវអវិជ្ជាជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការមិនញាប់ញ័រ ព្រោះអវិជ្ជា របស់បញ្ញាពលៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក សតិសម្ពោជ្ឈង្គ ថាដោយការប្រុង បមាទៈ ជាកករល្អក់ បុគ្គលលះចោល នូវបមាទៈ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការប្រុង របស់សតិសម្ពោជ្ឈង្គ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក ធម្មវិចយសម្ពោជ្ឈង្គ ថាដោយការជ្រើសរើសធម៌ អវិជ្ជា ជាកករល្អក់ បុគ្គលលះចោល នូវអវិជ្ជា ជាកករល្អក់ ហើយក្រេបផឹក នូវធម្មជាតដ៏ថ្លា ដោយការជ្រើសរើស របស់ធម្មវិចយសម្ពោជ្ឈង្គ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថា ថ្លាគួរក្រេបផឹក

៤

### មហាវគ្គេ មណ្ឌបេយ្យកថា

មណ្ឌបេយ្យំ បគ្គហមណ្ឌោ វីរិយសម្ពោជ្ឈង្គោ កោសជ្ជំ កសដោ កោសជ្ជំ កសដំ ឆឌ្ឌេត្វា វីរិយសម្ពោជ្ឈង្គស្ស បគ្គហមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ ផរណមណ្ឌោ បីតិសម្ពោជ្ឈង្គោ បរិឡាហោ កសដោ បរិឡាហំ កសដំ ឆឌ្ឌេត្វា បីតិសម្ពោជ្ឈង្គស្ស ផរណមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ ឧបសមមណ្ឌោ បស្សទ្ធិសម្ពោជ្ឈង្គោ ទុដ្ឋុល្លំ កសដោ ទុដ្ឋុល្លំ កសដំ ឆឌ្ឌេត្វា បស្សទ្ធិសម្ពោជ្ឈង្គស្ស ឧបសម-មណ្ឌំ បិវតីតិ មណ្ឌបេយ្យំ អវិក្ខេបមណ្ឌោ សមា-ធិសម្ពោជ្ឈង្គោ ឧទ្ធច្ចំ កសដោ ឧទ្ធច្ចំ កសដំ ឆឌ្ឌេត្វា សមាធិសម្ពោជ្ឈង្គស្ស អវិក្ខេបមណ្ឌំ បិវតីតិ

វីរិយសម្ពោជ្ឈង្គ ថាដោយការផ្គងឡើង សេចក្ដីខ្ជិលជាកករល្អក់ បុគ្គលលះចោល នូវសេចក្ដីខ្ជិល ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លាដោយការផ្គងឡើង របស់វីរិយសម្ពោជ្ឈង្គ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក បីតិសម្ពោជ្ឈង្គថាដោយការផ្សាយ សេចក្ដីក្ដៅក្រហាយជាកករល្អក់ បុគ្គលលះចោលនូវសេចក្ដីក្ដៅក្រហាយ ជាកករល្អក់ ហើយក្រេបផឹក នូវធម្មជាតដ៏ថ្លាដោយការផ្សាយ របស់បីតិសម្ពោជ្ឈង្គ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក បស្សទ្ធិសម្ពោជ្ឈង្គថាដោយការស្ងប់រម្ងាប់ ធម្មជាតជាទីតាំងនៃសេចក្ដីអាក្រក់ ជាកករល្អក់ បុគ្គលលះចោល នូវធម្មជាតជាទីតាំង នៃសេចក្ដីអាក្រក់ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការស្ងប់ របស់បស្សទ្ធិសម្ពោជ្ឈង្គ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក សមាធិសម្ពោជ្ឈង្គ ថាដោយការមិនរាយមាយ ឧទ្ធច្ចៈ ជាកករល្អក់ បុគ្គលលះចោលនូវឧទ្ធច្ចៈជាកករល្អក់ ហើយក្រេបផឹកនូវធម្ម-ជាតដ៏ថ្លាដោយការមិនរាយមាយ របស់សមាធិសម្ពោជ្ឈង្គ (ដោយព្រហ្ម-ចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក

៦



មណ្ឌបេយ្យំ បដិសង្ខានមណ្ឌោ ឧបេក្ខាសម្ពោជ្ឈង្គោ អប្បដិសង្ខានំ កសដោ អប្បដិសង្ខានំ កសដំ ឆឌ្ឌេត្វា ឧបេក្ខាសម្ពោជ្ឈង្គស្ស បដិសង្ខានមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ ទស្សនមណ្ឌោ សម្មាទិដ្ឋិ មិច្ឆាទិដ្ឋិ កសដោ មិច្ឆាទិដ្ឋឹ កសដំ ឆឌ្ឌេត្វា សម្មាទិដ្ឋិយា ទស្សនមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ អភិរោបនមណ្ឌោ សម្មាសង្កប្បោ មិច្ឆាសង្កប្បោ កសដោ មិច្ឆាសង្កប្បំ កសដំ ឆឌ្ឌេត្វា សម្មាសង្ក-ប្បស្ស អភិរោបនមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ បរិគ្គ-ហមណ្ឌោ សម្មាវាចា មិច្ឆាវាចា កសដោ មិច្ឆាវាចំ កសដំ ឆឌ្ឌេត្វា សម្មាវាចាយ បរិគ្គហមណ្ឌំ បិវតីតិ

ឧបេក្ខាសម្ពោជ្ឈង្គ ថ្វាដោយការរំពឹង ការមិនរំពឹង ជាកករល្អក់ បុគ្គលលះចោល នូវការមិនរំពឹងជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វា ដោយការរំពឹង របស់ឧបេក្ខាសម្ពោជ្ឈង្គ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថា ថ្វាគួរក្រេបផឹក សម្មាទិដ្ឋិ ថ្វាដោយការឃើញ មិច្ឆាទិដ្ឋិ ជាកករល្អក់ បុគ្គលលះចោល នូវមិច្ឆាទិដ្ឋិជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វា ដោយការឃើញ របស់សម្មាទិដ្ឋិ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក សម្មាសង្កប្បៈ ថ្វាដោយការលើកចិត្តឡើង (កាន់អារម្មណ៍) មិច្ឆាសង្កប្បៈ ជាកករល្អក់ បុគ្គលលះចោលនូវមិច្ឆាសង្កប្បៈជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វា ដោយការលើកចិត្តឡើង របស់សម្មាសង្កប្បៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក សម្មាវាចា ថ្វាដោយការកំណត់ មិច្ឆាវាចាជាកករល្អក់ បុគ្គលលះចោល នូវមិច្ឆាវាចាជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វាដោយការកំណត់ របស់សម្មាវាចា (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក

៧

### មហាវគ្គេ មណ្ឌបេយ្យកថា

មណ្ឌបេយ្យំ សមុដ្ឋានមណ្ឌោ សម្មាកម្មន្តោ មិច្ឆាកម្ម-
ន្តោ កសដោ មិច្ឆាកម្មន្តំ កសដំ ឆឌ្ឌេត្វា សម្មាកម្ម-
ន្តស្ស សមុដ្ឋានមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ វោទាន-
មណ្ឌោ សម្មាអាជីវោ មិច្ឆាអាជីវោ កសដោ មិច្ឆា-
អាជីវំ កសដំ ឆឌ្ឌេត្វា សម្មាអាជីវស្ស វោទានមណ្ឌំ
បិវតីតិ មណ្ឌបេយ្យំ បគ្គហមណ្ឌោ សម្មាវាយាមោ
មិច្ឆាវាយាមោ កសដោ មិច្ឆាវាយាមំ កសដំ ឆឌ្ឌេត្វា
សម្មាវាយាមស្ស បគ្គហមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ ឧប-
ដ្ឋានមណ្ឌោ សម្មាសតិ មិច្ឆាសតិ កសដោ មិច្ឆាសតឹ
កសដំ ឆឌ្ឌេត្វា សម្មាសតិយា ឧបដ្ឋានមណ្ឌំ បិវតីតិ

សម្មាកម្មន្តៈ ថ្វាដោយការខ្នះខ្នែង មិច្ឆាកម្មន្តៈ ជាកករល្អក់ បុគ្គល លះចោល នូវមិច្ឆាកម្មន្តៈ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វា ដោយការខ្នះខ្នែង របស់សម្មាកម្មន្តៈ (ដោយព្រហ្មចរិយៈណា) ហេតុ នោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក សម្មាអាជីវៈថ្វាដោយ សេចក្តីផូរផង់ មិច្ឆាអាជីវៈ ជាកករល្អក់ បុគ្គលលះចោលនូវមិច្ឆាអាជីវៈ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វា ដោយសេចក្តីផូរផង់ របស់ សម្មាអាជីវៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក សម្មាវាយាមៈ ថ្វាដោយការផ្គងឡើង មិច្ឆា-វាយាមៈ ជាកករល្អក់ បុគ្គលលះចោលនូវមិច្ឆាវាយាមៈ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វា ដោយការផ្គងឡើង របស់សម្មាវាយាមៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថា ថ្វាគួរក្រេបផឹក សម្មាសតិ ថ្វាដោយការប្រុង មិច្ឆាសតិ ជាកករ ល្អក់ បុគ្គលលះចោល នូវមិច្ឆាសតិជាកករល្អក់ ហើយក្រេបផឹក នូវ ធម្មជាតដ៏ថ្វា ដោយការប្រុង របស់សម្មាសតិ (ដោយព្រហ្មចរិយៈ ណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថា ថ្វាគួរក្រេបផឹក

មណ្ឌាបេយ្យំ អវិក្ខេបមណ្ឌោ សម្មាសមាធិ មិច្ឆាសមាធិ កសដោ មិច្ឆាសមាធឹ កសដំ ឆឌ្ឌេត្វា សម្មាសមាធិស្ស អវិក្ខេបមណ្ឌំ បិវតីតិ មណ្ឌាបេយ្យំ ។

[៣] អត្ថិ មណ្ឌោ អត្ថិ បេយ្យំ អត្ថិ កសដោ អធិមោក្ខមណ្ឌោ សទ្ធិន្ទ្រិយំ អស្សទ្ធិយំ កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ បគ្គហមណ្ឌោ វីរិយិន្ទ្រិយំ កោសជ្ជំ កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ ឧបដ្ឋានមណ្ឌោ សតិន្ទ្រិយំ បមាទោ កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ អវិក្ខេបមណ្ឌោ សមាធិន្ទ្រិយំ ឧទ្ធច្ចំ កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ ទស្សនមណ្ឌោ បញ្ញិន្ទ្រិយំ អវិជ្ជា កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ

សម្មាសមាធិ ថ្វាដោយការមិនរាយមាយ មិច្ឆាសមាធិ ជាកករល្អក់ បុគ្គលលះបោលនូវមិច្ឆាសមាធិ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វាដោយការមិនរាយមាយ របស់សម្មាសមាធិ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក ។

[៣] សេចក្តីថ្វាក៏មាន ធម្មជាតគួរក្រេបផឹកក៏មាន សភាពកករល្អក់ក៏មាន សទ្ធិន្ទ្រិយ ថ្វាដោយការជឿ ការមិនជឿ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសទ្ធិន្ទ្រិយនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក វីរិយិន្ទ្រិយ ថ្វាដោយការផ្គងឡើង សេចក្តីខ្ជិល ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងវីរិយិន្ទ្រិយនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សតិន្ទ្រិយថ្វាដោយការប្រុងបមាទៈ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសតិន្ទ្រិយនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សមាធិន្ទ្រិយ ថ្វាដោយការមិនរាយមាយ ឧទ្ធច្ចៈ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសមាធិន្ទ្រិយនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក បញ្ញិន្ទ្រិយ ថ្វាដោយការឃើញ អវិជ្ជា ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងបញ្ញិន្ទ្រិយនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក

៩

## មហាវគ្គេ  មណ្ឌបេយ្យកថា

ឥទំ បេយ្យំ អស្សទ្ធិយេ អកម្បិយមណ្ឌោ សទ្ធាពលំ អស្សទ្ធិយំ កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ កោសជ្ជេ អកម្បិយមណ្ឌោ វីរិយពលំ កោសជ្ជំ កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ បមាទេ អកម្បិយម-ណ្ឌោ សតិពលំ បមាទោ កសដោ យោ តត្ថ អត្ថ-រសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ ឧទ្ធច្ចេ អ-កម្បិយមណ្ឌោ សមាធិពលំ ឧទ្ធច្ចំ កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ អវិជ្ជាយ អកម្បិយមណ្ឌោ បញ្ញាពលំ អវិជ្ជា កស-ដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ ឧបដ្ឋានមណ្ឌោ សតិសម្ពោជ្ឈង្គោ បមាទោ ក-សដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ បវិចយមណ្ឌោ ធម្មវិចយសម្ពោជ្ឈង្គោ អវិជ្ជា កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ

សទ្ធាពលៈ ថាដោយការមិនញាប់ញ័រព្រោះការមិនជឿ ការមិនជឿ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសទ្ធាពលៈនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក វិរិយពលៈ ថាដោយការមិនញាប់ញ័រព្រោះសេចក្ដីខ្ជិល សេចក្ដីខ្ជិលជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងវិរិយពលៈនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សតិពលៈ ថាដោយការមិនញាប់ញ័រ ព្រោះបមាទៈ បមាទៈជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសតិពលៈនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សមាធិពលៈ ថាដោយការមិនញាប់ញ័រ ព្រោះឧទ្ធច្ចៈ ឧទ្ធច្ចៈ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសមាធិពលៈនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក បញ្ញាពលៈ ថាដោយការមិនញាប់ញ័រ ព្រោះអវិជ្ជា អវិជ្ជា ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងបញ្ញាពលៈនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សតិសម្ពោជ្ឈង្គ ថាដោយការប្រុង បមាទៈជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសតិសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក ធម្មវិចយសម្ពោជ្ឈង្គ ថាដោយការជ្រើសរើសធម៌ អវិជ្ជា ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងធម្មវិចយសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក

ឥទំ បេយ្យំ បគ្គហាមណ្ឌោ វីរិយសម្ពោជ្ឈង្គោ កោសជ្ជំ កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ ផរណាមណ្ឌោ បីតិសម្ពោជ្ឈង្គោ បរិឡាហោ កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ ឧបសមមណ្ឌោ បស្សទ្ធិសម្ពោជ្ឈង្គោ ទុដ្ឋុល្លំ កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ អវិក្ខេបមណ្ឌោ សមាធិសម្ពោជ្ឈង្គោ ឧទ្ធច្ចំ កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ បដិសង្ខានមណ្ឌោ ឧបេក្ខាសម្ពោជ្ឈង្គោ អប្បដិសង្ខានំ[១] កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ ។

[៤] ទស្សនមណ្ឌោ សម្មាទិដ្ឋិ មិច្ឆាទិដ្ឋិ កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ បេយ្យំ អភិរោបនមណ្ឌោ សម្មាសង្កប្បោ មិច្ឆាសង្កប្បោ កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ

---

១ ម. អប្បដិសង្ខា ។

វីរិយសម្ពោជ្ឈង្គ ថា ដោយការផ្គងឡើង សេចក្តីខ្ជិលជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងវីរិយសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក បីតិសម្ពោជ្ឈង្គ ថាដោយការផ្សាយទៅ សេចក្តីក្តៅក្រហាយជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងបីតិសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក បស្សទ្ធិសម្ពោជ្ឈង្គ ថាដោយការស្ងប់ធម្មជាតជាទីតាំងនៃសេចក្តីអាក្រក់ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងបស្សទ្ធិសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សមាធិសម្ពោជ្ឈង្គ ថាដោយការមិនរាយមាយ ឧទ្ធច្ចៈជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសមាធិសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក ឧបេក្ខាសម្ពោជ្ឈង្គ ថាដោយការទឹករំពឹង ការមិនទឹករំពឹង ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងឧបេក្ខាសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក ។

[៤] សម្មាទិដ្ឋិ ថាដោយការឃើញ មិច្ឆាទិដ្ឋិ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសម្មាទិដ្ឋិនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាសង្កប្បៈ ថាដោយការលើកចិត្តឡើង (កាន់អារម្មណ៍) មិច្ឆាសង្កប្បៈ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសម្មាសង្កប្បៈនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក

១១

មហាវគ្គេ មណ្ឌបេយ្យកថា

ឥទំ បេយ្យំ បរិគ្គហមណ្ឌោ សម្មាវាចា មិច្ឆាវាចា កស-
ដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ
បេយ្យំ សមុដ្ឋានមណ្ឌោ សម្មាកម្មន្តោ មិច្ឆាកម្មន្តោ
កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ
ឥទំ បេយ្យំ វោទានមណ្ឌោ សម្មាអាជីវោ មិច្ឆាអាជីវោ
កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ ឥទំ
បេយ្យំ បគ្គហមណ្ឌោ សម្មាវាយាមោ មិច្ឆាវាយាមោ
កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិរសោ
ឥទំ បេយ្យំ ឧបដ្ឋានមណ្ឌោ សម្មាសតិ មិច្ឆាសតិ
កសដោ យោ តត្ថ អត្ថរសោ ធម្មរសោ វិមុត្តិ-
រសោ ឥទំ បេយ្យំ អវិក្ខេបមណ្ឌោ សម្មាសមាធិ
មិច្ឆាសមាធិ កសដោ យោ តត្ថ អត្ថរសោ ធម្ម-
រសោ វិមុត្តិរសោ ឥទំ បេយ្យំ ទស្សនមណ្ឌោ
សម្មាទិដ្ឋិ អភិរោបនមណ្ឌោ សម្មាសង្កប្បោ បរិគ្គ-
ហមណ្ឌោ សម្មាវាចា សមុដ្ឋានមណ្ឌោ សម្មាក-
ម្មន្តោ វោទានមណ្ឌោ សម្មាអាជីវោ បគ្គហមណ្ឌោ

សម្មាវាចា ថ្វាដោយការកំណត់ទុក មិច្ឆាវាចា ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសម្មាវាចានោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាកម្មន្តៈ ថ្វាដោយការខ្នះខ្នែង មិច្ឆាកម្មន្តៈ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសម្មាកម្មន្តៈនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាអាជីវៈ ថ្វាដោយសេចក្តីបរិសុទ្ធ មិច្ឆាអាជីវៈ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសម្មាអាជីវៈនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាវាយាមៈ ថ្វាដោយការផ្គងឡើង មិច្ឆាវាយាមៈ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសម្មា-វាយាមៈនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាសតិ ថ្វាដោយការប្រុង មិច្ឆាសតិ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសម្មាសតិនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាសមាធិ ថ្វាដោយការមិនរាយមាយ មិច្ឆាសមាធិ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសម្មាសមាធិនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាទិដ្ឋិ ថ្វាដោយការឃើញ សម្មាសង្កប្បៈ ថ្វាដោយការលើកចិត្តឡើង (កាន់អារម្មណ៍) សម្មាវាចា ថ្វាដោយការកំណត់ សម្មាកម្ម-ន្តៈ ថ្វាដោយការខ្នះខ្នែង សម្មាអាជីវៈ ថ្វាដោយសេចក្តីបរិសុទ្ធ

សម្មាវាយាមោ ឧបដ្ឋានមគ្គោ សម្មាសតិ អវិក្ខេបមគ្គោ សម្មាសមាធិ ឧបដ្ឋានមគ្គោ សតិសម្ពោជ្ឈង្គោ បវិចយមគ្គោ ធម្មវិចយសម្ពោជ្ឈង្គោ បគ្គហមគ្គោ វីរិយសម្ពោជ្ឈង្គោ ផរណមគ្គោ បីតិសម្ពោជ្ឈង្គោ ឧបសមមគ្គោ បស្សទ្ធិសម្ពោជ្ឈង្គោ អវិក្ខេបមគ្គោ សមាធិសម្ពោជ្ឈង្គោ បដិសង្ខានមគ្គោ ឧបេក្ខាសម្ពោជ្ឈង្គោ អស្សទ្ធិយេ អកម្បិយមគ្គោ សទ្ធាពលំ កោសជ្ជេ អកម្បិយមគ្គោ វីរិយពលំ បមាទេ អកម្បិយមគ្គោ សតិពលំ ឧទ្ធច្ចេ អកម្បិយមគ្គោ សមាធិពលំ អវិជ្ជាយ អកម្បិយមគ្គោ បញ្ញាពលំ អធិមោក្ខមគ្គោ សទ្ធិន្ទ្រិយំ បគ្គហមគ្គោ វីរិយិន្ទ្រិយំ ឧបដ្ឋានមគ្គោ សតិន្ទ្រិយំ អវិក្ខេបមគ្គោ សមាធិន្ទ្រិយំ ទស្សនមគ្គោ បញ្ញិន្ទ្រិយំ អាធិបតេយ្យដ្ឋេន ឥន្ទ្រិយំ[១] មគ្គោ អកម្បិយដ្ឋេន ពលំ[២] មគ្គោ និយ្យានដ្ឋេន ពោជ្ឈង្គោ មគ្គោ ហេតដ្ឋេន មគ្គោ មគ្គោ ឧបដ្ឋានដ្ឋេន សតិប្បដ្ឋានា មគ្គោ បទហានដ្ឋេន

១ ម. ឥន្ទ្រិយា ។ ២ ម. ពលា ។

សម្មាវាយាមៈ ថាដោយការផ្គងឡើង សម្មាសតិ ថាដោយការប្រុង សម្មាសមាធិ ថាដោយការមិនរាយមាយ សតិសម្ពោជ្ឈង្គ ថាដោយការប្រុង ធម្មវិចយសម្ពោជ្ឈង្គ ថាដោយការជ្រើសរើសធម៌ វិរិយសម្ពោជ្ឈង្គ ថាដោយការផ្គងឡើង បីតិសម្ពោជ្ឈង្គ ថាដោយការផ្សាយទៅ បស្សទ្ធិសម្ពោជ្ឈង្គ ថាដោយការស្ងប់ សមាធិសម្ពោជ្ឈង្គ ថាដោយការមិនរាយមាយ ឧបេក្ខាសម្ពោជ្ឈង្គ ថាដោយការនឹករំពឹង សទ្ធាពលៈ ថាដោយការមិនញាប់ញ័រ ព្រោះការមិនជឿ វិរិយពលៈ ថាដោយការមិនញាប់ញ័រ ព្រោះសេចក្ដីខ្ជិល សតិពលៈ ថាដោយការមិនញាប់ញ័រ ព្រោះបមាទៈ សមាធិពលៈ ថាដោយការមិនញាប់ញ័រ ព្រោះឧទ្ធច្ចៈ បញ្ញាពលៈ ថាដោយការមិនញាប់ញ័រ ព្រោះអវិជ្ជា សទ្ធិន្ទ្រិយ ថាដោយការជឿស៊ប់ វិរិយិន្ទ្រិយ ថាដោយការផ្គងឡើង សតិន្ទ្រិយ ថាដោយការប្រុង សមាធិន្ទ្រិយ ថាដោយការមិនរាយមាយ បញ្ញិន្ទ្រិយ ថាដោយការឃើញ ឥន្ទ្រិយ ថាដោយអត្ថថាជាអធិបតី ពលៈ ថាដោយអត្ថថាមិនញាប់ញ័រ ពោជ្ឈង្គ ថាដោយអត្ថថាចេញចាក (វដ្ដៈ) មគ្គ ថាដោយអត្ថថាជាហេតុ សតិប្បដ្ឋាន ថាដោយអត្ថថាប្រុង

១៣

## មហាវគ្គេ មណ្ឌបេយ្យកថា

សម្មប្បធានា មណ្ឌោ ឥជ្ឈនដ្ឋេន ឥទ្ធិបាទា មណ្ឌោ អវិក្ខេបដ្ឋេន សមថោ មណ្ឌោ អនុបស្សនដ្ឋេន វិបស្សនា មណ្ឌោ ឯករសដ្ឋេន សមថវិបស្សនា មណ្ឌោ អនតិវត្តនដ្ឋេន យុគនទ្ធា មណ្ឌោ សំវរដ្ឋេន សីលវិសុទ្ធិ មណ្ឌោ អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ មណ្ឌោ ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ មណ្ឌោ មុត្តដ្ឋេន វិមោក្ខោ មណ្ឌោ បដិវេធដ្ឋេន វិជ្ជា មណ្ឌោ បរិច្ចាគដ្ឋេន វិមុត្តិ មណ្ឌោ សមុច្ឆេទដ្ឋេន ខយេ ញាណំ មណ្ឌោ បដិប្បស្សទ្ធដ្ឋេន អនុប្បាទេ ញាណំ មណ្ឌោ ឆន្ទោ មូលដ្ឋេន មណ្ឌោ មនសិការោ សមុដ្ឋានដ្ឋេន មណ្ឌោ ផស្សោ សមោធានដ្ឋេន មណ្ឌោ វេទនា សមោសរណដ្ឋេន មណ្ឌោ សមាធិ បមុខដ្ឋេន មណ្ឌោ សតិ អាធិបតេយ្យដ្ឋេន មណ្ឌោ បញ្ញា តទុត្តរដ្ឋេន មណ្ឌោ វិមុត្តិ សារដ្ឋេន មណ្ឌោ អមតោគធំ និព្វានំ បរិយោសានដ្ឋេន មណ្ឌោតិ ។

មណ្ឌបេយ្យកថា ។

ភាណវារំ ។

មហាវគ្គោ បឋមោ ។

សម្មប្បធាន ថាដោយអត្ថថាតម្កល់ទុក ឥទ្ធិបាទ ថាដោយអត្ថថាសម្រេច សមថៈ ថាដោយអត្ថថាមិនរាយមាយ វិបស្សនា ថាដោយអត្ថថាឃើញរឿយ ៗ សមថៈនិងវិបស្សនា ថាដោយអត្ថថាមានរសតែមួយ ធម៌ដែលជាប់គ្នាជាគូ ថាដោយអត្ថថាមិនកន្លង (នូវគ្នានិងគ្នា) សីលវិសុទ្ធិ ថាដោយអត្ថថាសង្រួម ចិត្តវិសុទ្ធិ ថាដោយអត្ថថាមិនរាយមាយ ទិដ្ឋិវិសុទ្ធិ ថាដោយអត្ថថាឃើញ វិមោក្ខ ថាដោយអត្ថថារួច វិជ្ជា ថាដោយអត្ថថាត្រាស់ដឹង វិមុត្តិ ថាដោយអត្ថថាលះចេញស្រឡះ ខយញ្ញាណ ថាដោយអត្ថថាផ្តាច់បង់ស្រឡះ អនុប្បាទញ្ញាណ ថាដោយអត្ថថារម្ងាប់ ឆន្ទៈ ថាដោយអត្ថថាឫសគល់ មនសិការៈ ថាដោយអត្ថថាតាំងឡើងព្រម ផស្សៈ ថាដោយអត្ថថាប្រមូល វេទនា ថាដោយអត្ថថាប្រជុំចុះ សមាធិ ថាដោយអត្ថថាជាប្រធាន សតិ ថាដោយអត្ថថាជាអធិបតី បញ្ញា ថាដោយអត្ថថាក្រៃលែងជាងធម៌ទាំងនោះ វិមុត្តិ ថាដោយអត្ថថាជាខ្លឹម និព្វាន ដែលជាពួកអមតៈ ថាដោយអត្ថថា ចប់ស្រេច (នៃកិច្ចក្នុងសាសនា) ។

ចប់ មណ្ឌបេយ្យកថា ។

ចប់ ភាណវារៈ ។

ចប់ មហាវគ្គ ទី ១ ។

## តស្ស វគ្គស្ស ឧទ្ទានំ ភវតិ

ញាណទិដ្ឋិ ច អស្សាសា ឥន្ទ្រិយំ វិមោក្ខបញ្ចមា
គតិកម្មវិបល្លាសា មគ្គោ មណ្ឌោ តេ ទសាតិ ។

ឯស និកាយវរោ ឋបិតោ អស្សមោ បឋមោ ច បវរោ វរមគ្គោតិ ។

# ឧទ្ទាននៃវគ្គនោះគឺ

*ក្នុងវគ្គនោះមាន ញាណ ១ ទិដ្ឋិ ១ ការដកដង្ហើមចេញ ១ ឥន្ទ្រិយ ១ វិមោក្ខជាគម្រប់ប្រាំ ១ គតិ ១ កម្ម ១ វិបល្លាស ១ មគ្គ ១ ដប់នឹងសភាពថ្វា ។*

*និកាយដ៏ប្រសើរនេះ លោកតម្កល់ទុកហើយ មិនមានធម៌ដទៃស្មើផង ជាដំបូងផង សំខាន់ផង ជាមគ្គដ៏ប្រសើរផង ។*

# យុគនទ្ធវគ្គេ យុគនទ្ធកថា

[៨] ឯវម្មេ សុតំ ឯកំ សមយំ អាយស្មា អានន្ទោ កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តត្រ ខោ អាយស្មា អានន្ទោ ភិក្ខូ អាមន្តេសិ អាវុសោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស បច្ចស្សោសុំ ។ អាយស្មា អានន្ទោ ឯតទវោច យោ ហិ កោចិ អាវុសោ ភិក្ខុ វា ភិក្ខុនី វា មម សន្តិកេ អរហត្តំ ព្យាករោតិ សព្វសោ ចតូហិ មគ្គេហិ ឯតេសំ វា អញ្ញតរេន កតមេហិ ចតូហិ ។

ឥធាវុសោ ភិក្ខុ សមថបុព្វង្គមំ វិបស្សនំ ភាវេតិ តស្ស សមថបុព្វង្គមំ វិបស្សនំ ភាវយតោ មគ្គោ សញ្ជាយតិ សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។

# យុគនទ្ធវគ្គ យុគនទ្ធកថា

[៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ សម័យមួយ ព្រះអានន្ទមានអាយុ គង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ ក្នុងទីនោះឯង ព្រះអានន្ទមានអាយុ បានហៅពួកភិក្ខុថា ម្នាលអាវុសោទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះអានន្ទមានអាយុថា ករុណា អាវុសោ ។ ព្រះអានន្ទមានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ បព្វជិតណាមួយ ទោះភិក្ខុក្តី ភិក្ខុនីក្តី ព្យាករអរហត្តក្នុងសម្នាក់ខ្ញុំ ដោយមគ្គ ៤ សព្វគ្រប់ ឬដោយមគ្គទាំងនុ៎ះ មគ្គណាមួយ តើមគ្គទាំង ៤ ដូចម្តេចខ្លះ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនវិបស្សនាមានសមថៈជាប្រធាន កាលភិក្ខុនោះ ចម្រើនវិបស្សនាមានសមថៈជាប្រធាន មគ្គរមែងកើតឡើង ភិក្ខុនោះ ឈ្មោះថាសេព ចម្រើន ធ្វើឲ្យច្រើន នូវមគ្គនោះ កាលភិក្ខុនោះ សេព ចម្រើន ធ្វើឲ្យច្រើន នូវមគ្គនោះ ភិក្ខុនោះក៏លះបង់សញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស ។

បុន ចបរំ អាវុសោ ភិក្ខុ វិបស្សនាបុព្វង្គមំ សមថំ ភាវេតិ តស្ស វិបស្សនាបុព្វង្គមំ សមថំ ភាវ-យតោ មគ្គោ សញ្ជាយតិ ។ សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។

បុន ចបរំ អាវុសោ ភិក្ខុ សមថវិបស្សនំ យុគនទ្ធំ[១] ភាវេតិ តស្ស តំ សមថវិបស្សនំ យុគ-នទ្ធំ ភាវយតោ មគ្គោ សញ្ជាយតិ សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោ-ជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។

បុន ចបរំ អាវុសោ ភិក្ខុនោ ធម្មុទ្ធច្ចវិគ្គហិ-តមានសំ[២] ហោតិ សោ អាវុសោ សមយោ យន្តំ ចិត្តំ អជ្ឈត្តញ្ញេវ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិ ហោតិ សមាធិយតិ តស្ស មគ្គោ សញ្ជាយតិ

១ ឱ. ម. យុគនន្ធំ ។ ២ ឱ. ម. ធម្មុទ្ធច្ចវិគ្គហិតំ មានសំ ។

ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុចម្រើនសមថៈ មានវិបស្សនាជាប្រធាន កាលភិក្ខុនោះ ចម្រើនសមថៈមានវិបស្សនាជាប្រធាន មគ្គក៏កើតឡើង ភិក្ខុនោះ ឈ្មោះថាសេព ចម្រើន ធ្វើឲ្យច្រើន នូវមគ្គនោះ កាលភិក្ខុនោះ សេព ចម្រើន ធ្វើឲ្យច្រើន នូវមគ្គនោះ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស ។

ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូគឺសមថៈនិងវិបស្សនា កាលភិក្ខុនោះចម្រើនធម៌ ដែលជាប់គ្នាជាគូគឺសមថៈ និងវិបស្សនានោះ មគ្គក៏កើតឡើង ភិក្ខុនោះ ឈ្មោះថាសេព ចម្រើន ធ្វើឲ្យច្រើន នូវមគ្គនោះ កាលភិក្ខុនោះសេព ចម្រើន ធ្វើឲ្យច្រើន នូវមគ្គនោះ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំង-ឡាយក៏វិនាស ។

ម្នាលអាវុសោទាំងឡាយ មួយវិញទៀត ភិក្ខុមានចិត្តមិនច្រួលច្រាល់ដោយឧទ្ធច្ចៈក្នុងធម៌ ម្នាលអាវុសោទាំងឡាយ មានសម័យ ដែលចិត្តបិតល្អ តាំងនៅស៊ប់ ជាចិត្តខ្ពស់ឯក តាំងនៅមាំ មគ្គរបស់ភិក្ខុនោះ ក៏កើតឡើង

សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។ យោ ហិ កោចិ អាវុសោ ភិក្ខុ វា ភិក្ខុនី វា មម សន្តិកេ អរហត្តំ ព្យាករោតិ សព្វសោ ឥមេហិ ចតូហិ មគ្គេហិ ឯតេសំ វា អញ្ញតរេនាតិ ។

[៦] កថំ សមថបុព្វង្គមំ វិបស្សនំ ភាវេតិ ។ នេក្ខម្មវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ តត្ថ ជាតេ ធម្មេ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា ទុក្ខតោ អនុបស្សនដ្ឋេន វិបស្សនា អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា ។ ឥតិ បឋមំ សមថោ បច្ឆា វិបស្សនា តេន វុច្ចតិ សមថបុព្វង្គមំ វិបស្សនំ ភាវេតិ[១] ។

ភាវេតីតិ ចតស្សោ ភាវនា តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា តទុបគវីរិយវាហនដ្ឋេន ភាវនា អាសេវនដ្ឋេន ភាវនា ។

---
១ ម. ភាវេតីតិ ។

ភិក្ខុនោះ ឈ្មោះថាសេព ចម្រើន ធ្វើឲ្យច្រើន នូវមគ្គនោះ កាលភិក្ខុនោះ សេព ចម្រើន ធ្វើឲ្យច្រើន នូវមគ្គនោះ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស ។ ម្នាលអាវុសោទាំងឡាយ បព្វជិតណាមួយ ទោះភិក្ខុក្តី ភិក្ខុនីក្តី តែងព្យាករអរហត្តក្នុងសម្នាក់ខ្ញុំ ដោយមគ្គទាំង ៤ នេះ សព្វគ្រប់ ឬដោយមគ្គៈទាំងនុ៎ះ មគ្គណាមួយ ។

[៦] ភិក្ខុចម្រើនវិបស្សនា មានសមថៈជាប្រធាន តើដូចម្តេច ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃនេក្ខម្មៈ ឈ្មោះថាសមាធិ ឈ្មោះថាវិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ថាមិនទៀង ឈ្មោះថាវិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ថាជាទុក្ខ ឈ្មោះថាវិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ថាមិនមែនខ្លួន នូវធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ ។ សមថៈ (កើត) មុន វិបស្សនា (កើត) ក្រោយ ហេតុនោះ លោកពោលថា ភិក្ខុចម្រើនវិបស្សនា មានសមថៈជាប្រធាន ដោយប្រការដូច្នេះ ។

ពាក្យថា ចម្រើន បានដល់ ការចម្រើន (ភាវនា) ៤ យ៉ាង គឺ ការចម្រើន ដោយអត្ថថាមិនកន្លង នូវធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ ១ ការចម្រើន ដោយអត្ថថាមានរសតែមួយ នៃឥន្ទ្រិយទាំងឡាយ ១ ការចម្រើន ដោយអត្ថថានាំទៅដោយវិរិយៈ ដ៏សមគួរដល់ឥន្ទ្រិយនោះ ១ ការចម្រើន ដោយអត្ថថាឧស្សាហ៍សេព ១ ។

មគ្គោ សញ្ជាយតីតិ កថំ មគ្គោ សញ្ជាយតិ ទស្សនដ្ឋេន សម្មាទិដ្ឋិ មគ្គោ សញ្ជាយតិ អភិរោប-នដ្ឋេន សម្មាសង្កប្បោ មគ្គោ សញ្ជាយតិ បរិគ្គហ-ដ្ឋេន សម្មាវាចា មគ្គោ សញ្ជាយតិ សមុដ្ឋានដ្ឋេន សម្មាកម្មន្តោ មគ្គោ សញ្ជាយតិ វោទានដ្ឋេន សម្មាអាជីវោ មគ្គោ សញ្ជាយតិ បគ្គហដ្ឋេន សម្មាវាយាមោ មគ្គោ សញ្ជាយតិ ឧបដ្ឋានដ្ឋេន សម្មាសតិ មគ្គោ សញ្ជាយតិ អវិក្ខេបដ្ឋេន សម្មា-សមាធិ មគ្គោ សញ្ជាយតិ ឯវំ មគ្គោ សញ្ជាយតិ ។

សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីក-រោតីតិ អាសេវតីតិ កថំ អាសេវតិ ។ អាវជ្ជន្តោ អាសេវតិ ជានន្តោ អាសេវតិ បស្សន្តោ អាសេវតិ បច្ចវេក្ខន្តោ អាសេវតិ ចិត្តំ អធិដ្ឋហន្តោ អាសេវតិ សទ្ធាយ អធិមុច្ចន្តោ អាសេវតិ វីរិយំ បគ្គណ្ហន្តោ អាសេវតិ សតឹ ឧបដ្ឋាបេន្តោ អាសេវតិ ចិត្តំ សមាទហន្តោ អាសេវតិ បញ្ញាយ បជានន្តោ

សំណួរត្រង់ពាក្យថា មគ្គក៏កើតឡើង តើមគ្គកើតឡើង ដូចម្តេច មគ្គគឺសម្មាទិដ្ឋិ ដោយអត្ថថាឃើញ កើតឡើង មគ្គគឺសម្មាសង្កប្បៈ ដោយអត្ថថា លើកចិត្តឡើង (កាន់អារម្មណ៍) កើតឡើង មគ្គគឺសម្មាវាចា ដោយអត្ថថាកំណត់ កើតឡើង មគ្គគឺសម្មាកម្មន្តៈ ដោយអត្ថថាខ្ជះខ្ជែង កើតឡើង មគ្គគឺសម្មាអាជីវៈ ដោយអត្ថថាផូរផង់ កើតឡើង មគ្គគឺសម្មាវាយាមៈ ដោយអត្ថថាផ្គងទុក កើតឡើង មគ្គគឺសម្មាសតិ ដោយអត្ថថាប្រុង កើតឡើង មគ្គគឺសម្មាសមាធិ ដោយអត្ថថាមិនរាយមាយ កើតឡើង មគ្គកើតឡើង យ៉ាងនេះឯង ។

អធិប្បាយពាក្យថា ភិក្ខុនោះ ឈ្មោះថាសេព ចម្រើន ធ្វើឲ្យច្រើន នូវមគ្គនោះ ត្រង់ពាក្យថា សេព តើសេពដូចម្តេច ។ ភិក្ខុកាលនឹករំពឹងរក (នូវមគ្គ) ឈ្មោះថាសេព កាលដឹង ឈ្មោះថាសេព កាលឃើញ ឈ្មោះថាសេព កាលពិចារណា ឈ្មោះថាសេព កាលអធិដ្ឋាននូវចិត្ត ឈ្មោះថាសេព កាលជឿស៊ប់ដោយសទ្ធា ឈ្មោះថាសេព កាលផ្គងនូវព្យាយាម ឈ្មោះថាសេព កាលប្រុងនូវស្មារតី ឈ្មោះថាសេព កាលតម្កល់ទុកនូវចិត្ត ឈ្មោះថាសេព កាលដឹងច្បាស់ដោយបញ្ញា ឈ្មោះថាសេព

១៩

យុគនទ្ធវគ្គេ យុគនទ្ធកថា

អាសេវតិ អភិញ្ញេយ្យំ អភិជានន្តោ អាសេវតិ បរិ-ញ្ញេយ្យំ បរិជានន្តោ អាសេវតិ បហាតព្វំ បជហន្តោ អាសេវតិ ភាវេតព្វំ ភាវេន្តោ អាសេវតិ សច្ឆិកាតព្វំ សច្ឆិករោន្តោ អាសេវតិ ឯវំ អាសេវតិ ។

ភាវេតីតិ កថំ ភាវេតិ ។ អាវជ្ជន្តោ ភាវេតិ ជានន្តោ ភាវេតិ បស្សន្តោ ភាវេតិ បច្ចវេក្ខន្តោ ភាវេតិ ចិត្តំ អធិដ្ឋហន្តោ ភាវេតិ សទ្ធាយ អធិមុច្ច-ន្តោ ភាវេតិ វិរិយំ បគ្គណ្ហន្តោ ភាវេតិ សតឹ ឧបដ្ឋា-បេន្តោ ភាវេតិ ចិត្តំ សមាទហន្តោ ភាវេតិ បញ្ញាយ បជានន្តោ ភាវេតិ អភិញ្ញេយ្យំ អភិជានន្តោ ភាវេតិ បរិញ្ញេយ្យំ បរិជានន្តោ ភាវេតិ បហាតព្វំ បជហន្តោ ភាវេតិ ភាវេតព្វំ ភាវេន្តោ ភាវេតិ សច្ឆិកាតព្វំ សច្ឆិករោន្តោ ភាវេតិ ឯវំ ភាវេតិ ។

យុគនទ្ធវគ្គ យុគនទ្ធកថា

កាលដឹងចំពោះនូវធម៌ដែលគួរដឹង ឈ្មោះថាសេព កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង ឈ្មោះថាសេព កាលលះនូវធម៌ដែលគួរលះ ឈ្មោះថាសេព កាលចម្រើននូវធម៌ដែលគួរចម្រើន ឈ្មោះថាសេព ភិក្ខុកាលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាសេព ភិក្ខុសេព យ៉ាងនេះឯង ។

សំណួរត្រង់ពាក្យថា ចម្រើន តើចម្រើនដូចម្តេច ។ ភិក្ខុកាលនឹករំពឹងរក ឈ្មោះថាចម្រើន កាលដឹង ឈ្មោះថាចម្រើន កាលឃើញ ឈ្មោះថាចម្រើន កាលពិចារណា ឈ្មោះថាចម្រើន កាលអធិដ្ឋាននូវចិត្ត ឈ្មោះថាចម្រើន កាលជឿស៊ប់ដោយសទ្ធា ឈ្មោះថាចម្រើន កាលផ្គងព្យាយាម ឈ្មោះថាចម្រើន កាលប្រុងស្មារតី ឈ្មោះថាចម្រើន កាលតម្កល់ទុកនូវចិត្ត ឈ្មោះថាចម្រើន កាលដឹងច្បាស់ដោយបញ្ញា ឈ្មោះថាចម្រើន កាលដឹងចំពោះនូវធម៌ដែលគួរដឹង ឈ្មោះថាចម្រើន កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង ឈ្មោះថាចម្រើន កាលលះនូវធម៌ដែលគួរលះ ឈ្មោះថាចម្រើន កាលចម្រើននូវធម៌ដែលគួរចម្រើន ឈ្មោះថាចម្រើន កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាចម្រើន ភិក្ខុចម្រើន យ៉ាងនេះឯង ។

ពហុលីកាេតីតិ កថំ ពហុលីករោតិ ។ អាវជ្ជន្តោ ពហុលីករោតិ ជានន្តោ ពហុលីករោតិ បស្សន្តោ ពហុលីករោតិ បច្ចវេក្ខន្តោ ពហុលីករោតិ ចិត្តំ អធិដ្ឋហន្តោ ពហុលីករោតិ សទ្ធាយ អធិមុច្ចន្តោ ពហុលីករោតិ វីរិយំ បគ្គណ្ហន្តោ ពហុលីករោតិ សតឹ ឧបដ្ឋាបេន្តោ ពហុលីករោតិ ចិត្តំ សមាទហន្តោ ពហុលីករោតិ បញ្ញាយ បជានន្តោ ពហុលីករោតិ អភិញ្ញេយ្យំ អភិជានន្តោ ពហុលីករោតិ បរិញ្ញេយ្យំ បរិជានន្តោ ពហុលីករោតិ បហាតព្វំ បជហន្តោ ពហុលីករោតិ ភាវេតព្វំ ភាវេន្តោ ពហុលីករោតិ សច្ឆិកាតព្វំ សច្ឆិករោន្តោ ពហុលីករោតិ ឯវំ ពហុលីករោតិ ។

តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តីតិ កថំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។

សំណួរត្រង់ពាក្យថា ធ្វើឲ្យច្រើន តើធ្វើឲ្យច្រើនដូចម្តេច ។ ភិក្ខុ កាលនឹករំពឹងរក ឈ្មោះថាធ្វើឲ្យច្រើន កាលដឹង ឈ្មោះថាធ្វើឲ្យច្រើន កាលឃើញ ឈ្មោះថាធ្វើឲ្យច្រើន កាលពិចារណា ឈ្មោះថាធ្វើឲ្យច្រើន កាលអធិដ្ឋាននូវចិត្ត ឈ្មោះថាធ្វើឲ្យច្រើន កាលជឿស៊ប់ដោយសទ្ធា ឈ្មោះថាធ្វើឲ្យច្រើន កាលផ្គងព្យាយាម ឈ្មោះថាធ្វើឲ្យច្រើន កាលប្រុងស្មារតី ឈ្មោះថាធ្វើឲ្យច្រើន កាលតម្កល់ទុកនូវចិត្ត ឈ្មោះថាធ្វើឲ្យច្រើន កាលដឹងច្បាស់ដោយបញ្ញា ឈ្មោះថាធ្វើឲ្យច្រើន កាលដឹងចំពោះនូវធម៌ដែលគួរដឹង ឈ្មោះថាធ្វើឲ្យច្រើន កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង ឈ្មោះថាធ្វើឲ្យច្រើន កាលលះនូវធម៌ដែលគួរលះ ឈ្មោះថាធ្វើច្រើន កាលចម្រើននូវធម៌ដែលគួរចម្រើន ឈ្មោះថាធ្វើឲ្យច្រើន កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាធ្វើឲ្យច្រើន ភិក្ខុធ្វើឲ្យច្រើន យ៉ាងនេះឯង ។

សំណួរត្រង់ពាក្យថា កាលភិក្ខុនោះ សេព ចម្រើន ធ្វើឲ្យច្រើន នូវមគ្គនោះ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស តើភិក្ខុលះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស ដូចម្តេច ។

យុគនទ្ធវគ្គេ យុគនទ្ធកថា

សោតាបត្តិមគ្គេន សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ ឥមានិ តីណិ សញ្ញោជនានិ បហីយន្តិ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ ឥមេ ទ្វេ អនុសយា ព្យន្តីហោន្តិ ។

សកទាគាមិមគ្គេន ឱឡារិកំ កាមរាគសញ្ញោជនំ បដិឃសញ្ញោជនំ ឥមានិ ទ្វេ សញ្ញោជនានិ បហីយន្តិ ឱឡារិកោ កាមរាគានុសយោ បដិឃានុសយោ ឥមេ ទ្វេ អនុសយា ព្យន្តីហោន្តិ ។

អនាគាមិមគ្គេន អណុសហគតំ កាមរាគសញ្ញោជនំ បដិឃសញ្ញោជនំ ឥមានិ ទ្វេ សញ្ញោជនានិ បហីយន្តិ អណុសហគតោ កាមរាគានុសយោ បដិឃានុសយោ ឥមេ ទ្វេ អនុសយា ព្យន្តីហោន្តិ ។

អរហត្តមគ្គេន រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ឥមានិ បញ្ច សញ្ញោជនានិ បហីយន្តិ មានានុសយោ ភវរាគានុសយោ អវិជ្ជានុសយោ ឥមេ តយោ អនុសយា ព្យន្តីហោន្តិ ឯវំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។

យុគនទ្ធវគ្គ យុគនទ្ធកថា

ភិក្ខុលះសញ្ញោជនៈ ៣ នេះ គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស អនុស័យ ២ នេះ គឺទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ក៏វិនាស ដោយសោតាបត្តិមគ្គ ។

លះសញ្ញោជនៈ ២ នេះ គឺកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈ ដ៏គ្រោតគ្រាត អនុស័យ ២ នេះ គឺកាមរាគានុស័យ បដិឃានុស័យ ដ៏គ្រោតគ្រាត ក៏វិនាស ដោយសកទាគាមិមគ្គ ។

លះសញ្ញោជនៈ ២ នេះ គឺកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈ ដ៏ល្អិត អនុស័យ ២ នេះ គឺកាមរាគានុស័យ បដិឃានុស័យ ដ៏ល្អិត ក៏វិនាស ដោយអនាគាមិមគ្គ ។

លះសញ្ញោជនៈ ៥ នេះ គឺរូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា អនុស័យ ៣ នេះ គឺមានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ក៏វិនាស ដោយអរហត្តមគ្គ ភិក្ខុលះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយ ក៏វិនាស យ៉ាងនេះឯង ។

[៧] អព្យាបាទវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ អាលោកសញ្ញាវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ។ បេ ។ បដិនិស្សគ្គានុបស្សី អស្សាសវសេន... បដិនិស្សគ្គានុបស្សី បស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ តត្ថ ជាតេ ធម្មេ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា ទុក្ខតោ អនុបស្សនដ្ឋេន វិបស្សនា អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា ។ ឥតិ បឋមំ សមថោ បច្ឆា វិបស្សនា តេន វុច្ចតិ សមថបុព្វង្គមំ វិបស្សនំ ភាវេតិ ។

ភាវេតីតិ ចតស្សោ ភាវនា តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា តទុបគវីរិយវាហនដ្ឋេន ភាវនា អាសេវនដ្ឋេន ភាវនា ។

[៧] ភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចឥតព្យាបាទ ឈ្មោះថាសមាធិ ភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃការសម្គាល់ពន្លឺ ឈ្មោះថាសមាធិ ។ បេ ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃដង្ហើមចេញរបស់បុគ្គលអ្នកឃើញរឿយ ៗ ក្នុងការរលាស់ខ្លួនចេញ... ដោយអំណាចនៃដង្ហើមចូល របស់បុគ្គលអ្នកឃើញរឿយ ៗ ក្នុងការរលាស់ខ្លួនចេញ ឈ្មោះថាសមាធិ ឈ្មោះថាវិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ថាមិនទៀង ឈ្មោះថាវិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ថាជាទុក្ខ ឈ្មោះថាវិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ថាមិនមែនខ្លួន នូវធម៌ទាំងឡាយដែលកើតក្នុងសមាធិនោះ សមថៈ (កើត) មុន វិបស្សនា (កើត) ក្រោយ ហេតុនោះ លោកពោលថា ភិក្ខុចម្រើនវិបស្សនាមានសមថៈជាប្រធានដោយប្រការដូច្នេះ ។

ពាក្យថា ចម្រើន បានដល់ការចម្រើន (ភាវនា) ៤ យ៉ាង គឺការចម្រើនដោយអត្ថថាមិនកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ ១ ការចម្រើន ដោយអត្ថថាមានរសតែមួយនៃឥន្ទ្រិយទាំងឡាយ ១ ការចម្រើនដោយអត្ថថានាំទៅដោយវីរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ ១ ការចម្រើនដោយអត្ថថាឧស្សាហ៍សេព ១ ។

៤៣



មគ្គោ សញ្ជាយតីតិ កថំ មគ្គោ សញ្ជាយតិ ។ ឧស្សុនដ្ឋេន សម្មាទិដ្ឋិ មគ្គោ សញ្ជាយតិ អភិ-រោបនដ្ឋេន សម្មាសង្កប្បោ មគ្គោ សញ្ជាយតិ ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធិ មគ្គោ សញ្ជាយតិ ឯវំ មគ្គោ សញ្ជាយតិ ។

សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតីតិ អាសេវតីតិ កថំ អាសេវតិ ។ អាវជ្ជន្តោ អាសេវតិ ជានន្តោ អាសេវតិ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិករោ-ន្តោ អាសេវតិ ឯវំ អាសេវតិ ។

ភាវេតីតិ កថំ ភាវេតិ ។ អាវជ្ជន្តោ ភាវេតិ ជានន្តោ ភាវេតិ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិករោន្តោ ភាវេតិ ឯវំ ភាវេតិ ។

ពហុលីករោតីតិ កថំ ពហុលីករោតិ ។ អាវជ្ជន្តោ ពហុលីករោតិ ជានន្តោ ពហុលីករោតិ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិករោន្តោ ពហុលីករោតិ ឯវំ ពហុលីករោតិ ។

យុគនទ្ធវគ្គ យុគនទ្ធកថា

សំណួរត្រង់ពាក្យថា មគ្គក៏កើតឡើង តើមគ្គកើតឡើង ដូចម្ដេច ។ មគ្គគឺសម្មាទិដ្ឋិ ដោយអត្ថថាឃើញ កើតឡើង មគ្គគឺសម្មាសង្កប្បៈ ដោយអត្ថថាលើកចិត្តឡើង (កាន់អារម្មណ៍) កើតឡើង ។ បេ ។ មគ្គគឺសម្មាសមាធិ ដោយអត្ថថាមិនរាយមាយ កើតឡើង មគ្គកើតឡើង យ៉ាងនេះឯង ។

អធិប្បាយពាក្យថា ភិក្ខុនោះឈ្មោះថាសេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ ត្រង់ពាក្យថា សេព តើសេពដូចម្ដេច ។ ភិក្ខុកាលនឹករំពឹងរក ឈ្មោះថាសេព កាលដឹង ឈ្មោះថាសេព ។ បេ ។ កាលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាសេព ភិក្ខុសេព យ៉ាងនេះឯង ។

សំណួរត្រង់ពាក្យថា ចម្រើន តើចម្រើន ដូចម្ដេច ។ ភិក្ខុកាលនឹករំពឹងរក (នូវមគ្គ) ឈ្មោះថាចម្រើន កាលដឹង ឈ្មោះថាចម្រើន ។ បេ ។ កាលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាចម្រើន ភិក្ខុចម្រើន យ៉ាងនេះឯង ។

សំណួរត្រង់ពាក្យថា ធ្វើឲ្យច្រើន តើធ្វើឲ្យច្រើនដូចម្ដេច ។ ភិក្ខុកាលនឹករំពឹង (នូវមគ្គ) ឈ្មោះថាធ្វើឲ្យច្រើន កាលដឹង ឈ្មោះថាធ្វើឲ្យច្រើន ។ បេ ។ កាលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាធ្វើឲ្យច្រើន ភិក្ខុធ្វើឲ្យច្រើន យ៉ាងនេះឯង ។

តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តីតិ កថំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។

សោតាបត្តិមគ្គេន សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ ឥមានិ តីណិ សញ្ញោជនានិ បហីយន្តិ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ ឥមេ ទ្វេ អនុសយា ព្យន្តីហោន្តិ ។

សកទាគាមិមគ្គេន ឱឡារិកំ កាមរាគសញ្ញោជនំ បដិឃសញ្ញោជនំ ឥមានិ ទ្វេ សញ្ញោជនានិ បហីយន្តិ ឱឡារិកោ កាមរាគានុសយោ បដិឃានុសយោ ឥមេ ទ្វេ អនុសយា ព្យន្តីហោន្តិ ។

អនាគាមិមគ្គេន អណុសហគតំ កាមរាគសញ្ញោជនំ បដិឃសញ្ញោជនំ ឥមានិ ទ្វេ សញ្ញោជនានិ បហីយន្តិ អណុសហគតោ កាមរាគានុសយោ បដិឃានុសយោ ឥមេ ទ្វេ អនុសយា ព្យន្តីហោន្តិ ។

សំណួរត្រង់ពាក្យថា កាលភិក្ខុនោះ សេព ចម្រើន ធ្វើឲ្យច្រើន នូវមគ្គនោះ ភិក្ខុនោះ ក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស តើភិក្ខុលះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាសដូចម្តេចខ្លះ ។

ភិក្ខុលះសញ្ញោជនៈ ៣ នេះ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ដោយសោតាបត្តិមគ្គ អនុស័យ ២ នេះ គឺ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ក៏វិនាស ។

ភិក្ខុលះសញ្ញោជនៈ ២ នេះ គឺកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈ ដ៏គ្រោតគ្រាត ដោយសកទាគាមិមគ្គ អនុស័យ ២ នេះ គឺ កាមរាគានុស័យ បដិឃានុស័យ ដ៏គ្រោតគ្រាត ក៏វិនាស ។

ភិក្ខុលះសញ្ញោជនៈ ២ នេះ គឺ កាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈ ដ៏ល្អិត ដោយអនាគាមិមគ្គ អនុស័យ ២ នេះ គឺ កាមរាគានុស័យ បដិឃានុស័យ ដ៏ល្អិត ក៏វិនាស ។

អរហត្តមគ្គេន រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ឥមានិ បញ្ច សញ្ញោជនានិ បហីយន្តិ មានានុ-សយោ ភវរាគានុសយោ អវិជ្ជានុសយោ ឥមេ តយោ អនុសយា ព្យន្តីហោន្តិ ឯវំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ឯវំ សមថបុព្វង្គមំ វិបស្សនំ ភាវេតិ ។

[៨] កថំ វិបស្សនាបុព្វង្គមំ សមថំ ភាវេតិ ។ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា ទុក្ខតោ អ-នុបស្សនដ្ឋេន វិបស្សនា អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា តត្ថ ជាតានំ ធម្មានំ ច វោស្សគ្គារម្មណតា ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ឥតិ បឋមំ វិបស្សនា បច្ឆា សមថោ តេន វុច្ចតិ វិបស្សនាបុព្វង្គមំ សមថំ ភាវេតិ ។

ភាវេតីតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ បេ ។ មគ្គោ សញ្ជាយតីតិ កថំ មគ្គោ សញ្ជាយតិ ។ បេ ។ ឯវំ មគ្គោ សញ្ជាយតិ ។ បេ ។

ភិក្ខុលះសញ្ញោជនៈ ៥ នេះ គឺ រូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា ដោយអរហត្តមគ្គ អនុស័យ ៣ នេះ គឺ មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ក៏វិនាស ភិក្ខុ លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយ ក៏វិនាស យ៉ាងនេះ ភិក្ខុចម្រើនវិបស្សនា មានសមថៈជាប្រធាន យ៉ាងនេះឯង ។

[៨] ភិក្ខុចម្រើនសមថៈ មានវិបស្សនាជាប្រធាន តើដូចម្ដេច ។ វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ថាមិនទៀង វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ថាជាទុក្ខ វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ថាមិនមែនខ្លួន មួយទៀត ភាពនៃធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ មានអារម្មណ៍គួរលះ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ ឈ្មោះថាសមាធិ វិបស្សនា (កើត) មុន សមថៈ (កើត) ក្រោយ ហេតុនោះ លោកពោលថា ភិក្ខុចម្រើនសមថៈ មានវិបស្សនាជាប្រធាន ដោយប្រការដូច្នេះ ។

ពាក្យថា ចម្រើន បានដល់ការចម្រើន ៤ យ៉ាង ។ បេ ។ ការចម្រើនដោយអត្ថថាឧស្សាហ៍សេព ។ បេ ។ សំណួរត្រង់ពាក្យថា មគ្គកើតឡើង តើមគ្គកើតឡើង ដូចម្ដេច ។ បេ ។ មគ្គកើតឡើង យ៉ាងនេះ ។ បេ ។

ឯវំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។ រូបំ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា រូបំ ទុក្ខ-តោ អនុបស្សនដ្ឋេន វិបស្សនា រូបំ អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា តត្ថ ជាតានំ ធម្មានំ ច វោស្សគ្គារម្មណតា ចិត្តស្ស ឯកគ្គតា អវិក្ខេ-បោ សមាធិ ឥតិ បឋមំ វិបស្សនា បច្ឆា សមថោ តេន វុច្ចតិ វិបស្សនាបុព្វង្គមំ សមថំ ភាវេតិ ។

ភាវេតីតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ បេ ។ មគ្គោ សញ្ជាយតីតិ ។ បេ ។ ឯវំ មគ្គោ សញ្ជាយតិ ។ បេ ។ ឯវំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។ វេទនំ សញ្ញំ សង្ខារេ វិញ្ញា-ណំ ចក្ខុំ ។ បេ ។ ជរាមរណំ អនិច្ចតោ អនុបស្ស-នដ្ឋេន វិបស្សនា ជរាមរណំ ទុក្ខតោ ។ បេ ។ អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា តត្ថ ជាតានំ ធម្មានំ ច វោស្សគ្គារម្មណតា ចិត្តស្ស ឯកគ្គតា

ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស យ៉ាងនេះ ។ វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ នូវរូប ថាមិនទៀង វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ នូវរូប ថាជាទុក្ខ វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ នូវរូប ថាមិនមែនខ្លួន មួយទៀត ភាពនៃធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ មានអារម្មណ៍គួរលះ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ ឈ្មោះថាសមាធិ វិបស្សនា (កើត) មុន សមថៈ (កើត) ក្រោយ ហេតុនោះ លោកពោលថា ភិក្ខុចម្រើនសមថៈ មានវិបស្សនាជាប្រធាន ដោយប្រការដូច្នេះ ។

ពាក្យថា ចម្រើន បានដល់ការចម្រើន ៤ យ៉ាង ។ បេ ។ ការចម្រើនដោយអត្ថថាឧស្សាហ៍សេព ។ បេ ។ សំណួរត្រង់ពាក្យថា មគ្គ កើតឡើង ។ បេ ។ មគ្គកើតឡើងយ៉ាងនេះ ។ បេ ។ ភិក្ខុនោះក៏លះសញ្ញោជនៈទាំង-ឡាយ អនុស័យទាំងឡាយ ក៏វិនាស ។ វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ នូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ នូវជរាមរណៈ ថាមិនទៀង វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ នូវជរាមរណៈ ថាជាទុក្ខ ។ បេ ។ ថាមិនមែនខ្លួន មួយទៀត ភាពនៃធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ មានអារម្មណ៍គួរលះ ភាពនៃចិត្តមានអារម្មណ៍តែមួយ

២៧

យុគនទ្ធវគ្គេ យុគនទ្ធកថា

អវិក្ខេបោ សមាធិ ឥតិ បឋមំ វិបស្សនា បច្ឆា ស-
មថោ តេន វុច្ចតិ វិបស្សនាបុព្វង្គមំ សមថំ ភាវេតិ ។

ភាវេតីតិ ចតស្សោ ភាវនា ។ បេ ។ សញ្ជាយ-
តីតិ កថំ មគ្គោ សញ្ជាយតិ ។ បេ ។ ឯវំ មគ្គោ
សញ្ជាយតិ ។ បេ ។ ឯវំ សញ្ញោជនានិ បហីយន្តិ
អនុសយា ព្យន្តីហោន្តិ ឯវំ វិបស្សនាបុព្វង្គមំ សមថំ
ភាវេតិ ។

[៩] កថំ សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។
សោឡសហិ អាការេហិ សមថវិបស្សនំ យុគនទ្ធំ
ភាវេតិ អារម្មណដ្ឋេន គោចរដ្ឋេន បហានដ្ឋេន
បរិច្ចាគដ្ឋេន វុដ្ឋានដ្ឋេន វិវដ្តនដ្ឋេន សន្តដ្ឋេន
បណីតដ្ឋេន វិមុត្តដ្ឋេន អនាសវដ្ឋេន តរណដ្ឋេន
អនិមិត្តដ្ឋេន អប្បណិហិតដ្ឋេន សុញ្ញដ្ឋេន ឯករ-
សដ្ឋេន អនតិវត្តនដ្ឋេន យុគនទ្ធដ្ឋេន ។

ការមិនរាយមាយ ឈ្មោះថាសមាធិ វិបស្សនា (កើត) មុន សមថៈ (កើត) ក្រោយ ហេតុនោះ លោកពោលថា ភិក្ខុចម្រើនសមថៈ មានវិបស្សនាជាប្រធាន ដោយប្រការដូច្នេះ ។

ពាក្យថា ចម្រើន បានដល់ការចម្រើន ៤ យ៉ាង ។ បេ ។ សំណួរត្រង់ពាក្យថា មគ្គកើតឡើង តើមគ្គកើតឡើងដូចម្ដេច ។ បេ ។ មគ្គកើតឡើងយ៉ាងនេះ ។ បេ ។ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយ ក៏វិនាសយ៉ាងនេះ ភិក្ខុចម្រើនសមថៈមានវិបស្សនាជាប្រធាន យ៉ាងនេះឯង ។

[៩] ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា តើដូចម្ដេច ។ ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអាការ ១៦ គឺដោយអត្ថថាជាអារម្មណ៍ ១ ដោយអត្ថថាជាគោចរ ១ ដោយអត្ថថាលះបង់ ១ ដោយអត្ថថាលះស្រឡះ ១ ដោយអត្ថថាចេញ ១ ដោយអត្ថថាប្រែត្រឡប់ ១ ដោយអត្ថថាស្ងប់ ១ ដោយអត្ថថាឧត្តម ១ ដោយអត្ថថារួចស្រឡះ ១ ដោយអត្ថថាមិនមានអាសវៈ ១ ដោយអត្ថថាឆ្លង ១ ដោយអត្ថថាមិនមាននិមិត្ត ១ ដោយអត្ថថាមិនមានទីតម្កល់ ១ ដោយអត្ថថាសូន្យ ១ ដោយអត្ថថាមានរសតែមួយ ១ ដោយអត្ថថាមិនកន្លងជាប់គ្នាជាគូនឹងគ្នា១។

កថំ អារម្មណដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ឧទ្ធច្ចំ បជហតោ ចិត្តស្ស ឯកគ្គតា អវិ-ក្ខេបោ សមាធិ និរោធារម្មណោ អវិជ្ជំ បជហតោ អនុបស្សនដ្ឋេន វិបស្សនា និរោធារម្មណា ឥតិ អារម្មណដ្ឋេន សមថវិបស្សនា ឯករសា ហោន្តិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ អារម្មណដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

ភាវេតីតិ ចតស្សោ ភាវនា ។ បេ ។ អាសេវ-នដ្ឋេន ភាវនា ។ បេ ។ មគ្គោ សញ្ជាយតីតិ កថំ មគ្គោ សញ្ជាយតិ ។ បេ ។ ឯវំ មគ្គោ សញ្ជាយតិ ឯវំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោ-ន្តិ ឯវំ អារម្មណដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

កថំ គោចរដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ឧទ្ធច្ចំ បជហតោ ចិត្តស្ស ឯកគ្គតា អវិក្ខេ-បោ សមាធិ និរោធគោចរោ អវិជ្ជំ បជហតោ អនុប-ស្សនដ្ឋេន វិបស្សនា និរោធគោចរា ឥតិ គោចរដ្ឋេន

ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថជាអារម្មណ៍ តើដូចម្តេច ។ កាលបុគ្គលលះឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធជាអារម្មណ៍ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ក៏មាននិរោធជាអារម្មណ៍ដែរ សមថៈនិងវិបស្សនា ដោយអត្ថថាជាអារម្មណ៍ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាជាអារម្មណ៍ ។

ពាក្យថា ចម្រើន បានដល់ការចម្រើន ៤ យ៉ាង ។ បេ ។ ការចម្រើន ដោយអត្ថថា ឧស្សាហ៍សេព ។ បេ ។ សំណួរត្រង់ពាក្យថា មគ្គកើតឡើង តើមគ្គកើតឡើង ដូចម្តេច ។ បេ ។ មគ្គកើតឡើង យ៉ាងនេះ ភិក្ខុនោះលះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស យ៉ាងនេះ ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាជាអារម្មណ៍ យ៉ាងនេះឯង ។

ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាជាគោចរ តើដូចម្តេច ។ កាលបុគ្គលលះឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធជាគោចរ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ក៏មាននិរោធជាគោចរដែរ

សមថវិបស្សនា ឯករសា ហោន្តិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ គោចរដ្ឋេន សមថ-វិបស្សនំ យុគនទ្ធំ ភាវេតិ ។

[១០] កថំ បហានដ្ឋេន សមថវិបស្សនំ យុគន-ទ្ធំ ភាវេតិ ។ ឧទ្ធច្ចសហគតកិលេសេ ច ខន្ធេ ច បជហតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ និរោធគោចរោ អវិជ្ជាសហគតកិលេសេ ច ខន្ធេ ច បជហតោ អនុបស្សនដ្ឋេន វិបស្សនា និរោធគោចរា ឥតិ បហានដ្ឋេន សមថវិបស្សនា ឯករសា ហោន្តិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ បហានដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

កថំ បរិច្ចាគដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភា-វេតិ ។ ឧទ្ធច្ចសហគតកិលេសេ ច ខន្ធេ ច បរិច្ចជតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ និរោធគោចរោ អវិជ្ជាសហគតកិលេសេ ច ខន្ធេ ច បរិច្ចជតោ អនុ-បស្សនដ្ឋេន វិបស្សនា និរោធគោចរា ឥតិ បរិច្ចាគដ្ឋេន

*សមថៈនិងវិបស្សនា ដោយអត្ថថាជាគោចរ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាជាគោចរ ។*

[១០] *ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាលះបង់ តើដូចម្តេច ។ កាលបុគ្គលលះនូវកិលេសដែលច្រឡំដោយឧទ្ធច្ចៈផង នូវខន្ធផង ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធជាគោចរ កាលបុគ្គលលះនូវកិលេសដែលច្រឡំដោយអវិជ្ជាផង នូវខន្ធផង វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ក៏មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថាលះបង់ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាលះបង់ ។*

*ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាលះស្រឡះ តើដូចម្តេច ។ កាលបុគ្គលលះស្រឡះ នូវកិលេសដែលច្រឡំដោយឧទ្ធច្ចៈផង នូវខន្ធផង ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធជាគោចរ កាលបុគ្គលលះស្រឡះ នូវកិលេសដែលច្រឡំ ដោយអវិជ្ជាផង នូវខន្ធផង វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ក៏មាននិរោធជាគោចរដែរ*

សមថវិបស្សនា ឯករសា ហោន្តិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ បរិច្ចាគដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

កថំ វុដ្ឋានដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ឧទ្ធច្ចសហគតកិលេសេហិ ច ខន្ធេហិ ច វុដ្ឋហតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ និរោធគោចរោ អវិជ្ជាសហគតកិលេសេហិ ច ខន្ធេហិ ច វុដ្ឋហតោ អនុបស្សនដ្ឋេន វិបស្សនា និរោធគោចរា ឥតិ វុដ្ឋានដ្ឋេន សមថវិបស្សនា ឯករសា ហោន្តិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ វុដ្ឋានដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

កថំ វិវដ្ដនដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ឧទ្ធច្ចសហគតកិលេសេហិ ច ខន្ធេហិ ច វិវដ្ដតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ និរោធគោចរោ អវិជ្ជាសហគតកិលេសេហិ ច ខន្ធេហិ ច វិវដ្ដតោ អនុបស្សនដ្ឋេន វិបស្សនា និរោធគោចរា ឥតិ វិវដ្ដនដ្ឋេន

សមថៈនិងវិបស្សនា ដោយអត្ថថាលះស្រឡះ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាលះស្រឡះ ។

ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាចេញ តើដូចម្តេច ។ កាលបុគ្គលចេញចាកកិលេសដែលប្រកបដោយឧទ្ធច្ចៈផង ចាកខន្ធផង ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធជាគោចរ កាលបុគ្គលចេញចាកកិលេសដែលប្រកបដោយអវិជ្ជាផង ចាកខន្ធផង វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ក៏មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថាចេញ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាចេញ ។

ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាប្រែត្រឡប់ តើដូចម្តេច ។ កាលបុគ្គលប្រែត្រឡប់ចាកកិលេសដែលប្រកប ដោយឧទ្ធច្ចៈផង ចាកខន្ធផង ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធជាគោចរ កាលបុគ្គលប្រែត្រឡប់ ចាកកិលេសដែលប្រកប ដោយអវិជ្ជាផង ចាកខន្ធផង វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ក៏មាននិរោធជាគោចរដែរ

៣១

យុគនទ្ធវគ្គេ យុគនទ្ធកថា

សមថវិបស្សនា ឯករសា ហោន្តិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ វិវដ្ដនដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

[១១] កថំ សន្តដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ឧទ្ធច្ចំ បជហតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ សន្តោ ហោតិ និរោធគោចរោ អវិជ្ជំ បជហតោ អនុបស្សនដ្ឋេន វិបស្សនា សន្តា ហោតិ និរោធគោចរា ឥតិ សន្តដ្ឋេន សមថវិបស្សនា ឯករសា ហោន្តិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ សន្តដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

កថំ បណីតដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ឧទ្ធច្ចំ បជហតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ បណីតោ ហោតិ និរោធគោចរោ អវិជ្ជំ បជហតោ អនុបស្សនដ្ឋេន វិបស្សនា បណីតា ហោតិ និរោធគោចរា ឥតិ បណីតដ្ឋេន

សមថៈនិងវិបស្សនា ដោយអត្ថថាប្រែត្រឡប់ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាប្រែត្រឡប់ ។

[១១] ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាល្អិត តើដូចម្ដេច ។ កាលបុគ្គលលះឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ ជាធម៌ដ៏ល្អិត មាននិរោធជាគោចរ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ក៏ជាគុណជាតិដ៏ល្អិត មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថាល្អិត ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាល្អិត ។

ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាឧត្តម តើដូចម្ដេច ។ កាលបុគ្គលលះឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ ជាធម៌ដ៏ឧត្តម មាននិរោធជាគោចរ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ក៏ជាគុណជាតិ ដ៏ឧត្តម មាននិរោធជាគោចរដែរ

សមថវិបស្សនា ឯករសា ហោន្តិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ បណីតដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

កថំ វិមុត្តដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ឧទ្ធច្ចំ បជហតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ វិមុត្តោ ហោតិ និរោធគោចរោ អវិជ្ជំ បជហតោ អនុបស្សនដ្ឋេន វិបស្សនា វិមុត្តា ហោតិ និរោធគោចរា ឥតិ រាគវិរាគា ចេតោវិមុត្តិ អវិជ្ជាវិរាគា បញ្ញាវិមុត្តិ ឥតិ វិមុត្តដ្ឋេន សមថវិបស្សនា ឯករសា ហោន្តិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ វិមុត្តដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

សមថៈនិងវិបស្សនា ដោយអត្ថថាឧត្តម ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាឧត្តម ។

ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថារួចស្រឡះ តើដូចម្តេច ។ កាលបុគ្គលលះនូវឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ ជាធម៌រួចស្រឡះ មាននិរោធជាគោចរ កាលបុគ្គលលះនូវអវិជ្ជា វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ក៏ជាគុណជាតិរួចស្រឡះ មាននិរោធជាគោចរដែរ បន្ទាប់មក ចេតោវិមុត្តិ ព្រោះការរសាយចេញចាករាគៈ បញ្ញាវិមុត្តិ ព្រោះការរសាយចេញចាកអវិជ្ជា (ក៏កើតមាន) សមថៈនិងវិបស្សនា ដោយអត្ថថារួចស្រឡះ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថារួចស្រឡះ ។

៣៣

យុគនទ្ធវគ្គេ យុគនទ្ធកថា

[១២] កថំ អនាសវដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ឧទ្ធច្ចំ បជហតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ កាមាសវេន អនាសវោ ហោតិ និរោធគោចរោ អវិជ្ជំ បជហតោ អនុបស្សនដ្ឋេន វិបស្សនា អវិជ្ជាសវេន អនាសវា ហោតិ និរោធគោចរា ឥតិ អនាសវដ្ឋេន សមថវិបស្សនា ឯករសា ហោន្តិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ អនាសវដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

កថំ តរណដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ឧទ្ធច្ចសហគតកិលេសេហិ ច ខន្ធេហិ ច តរតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ និរោធគោចរោ អវិជ្ជាសហគតកិលេសេហិ ច ខន្ធេហិ ច តរតោ អនុបស្សនដ្ឋេន វិបស្សនា និរោធគោចរា ឥតិ តរណដ្ឋេន សមថវិបស្សនា ឯករសា ហោតិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ តរណដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

[១២] ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាមិនមានអាសវៈ តើដូចម្តេច ។ កាលបុគ្គលលះនូវឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ ជាធម៌មិនមានអាសវៈដោយកាមាសវៈ មាននិរោធជាគោចរ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថា ឃើញរឿយ ៗ ក៏ជាគុណជាតិមិនមានអាសវៈ ដោយអវិជ្ជាសវៈ មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថា មិនមានអាសវៈ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាមិនមានអាសវៈ ។

ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាឆ្លង តើដូចម្តេច ។ កាលបុគ្គលឆ្លងចាកកិលេស ដែលច្រឡំដោយឧទ្ធច្ចៈផង ចាកខន្ធផង ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធជាគោចរ កាលបុគ្គលឆ្លង ចាកកិលេសដែលច្រឡំដោយអវិជ្ជាផង ចាកខន្ធផង វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ក៏មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថាឆ្លង ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាឆ្លង ។

កថំ អនិមិត្តដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ឧទ្ធច្ចំ បជហតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ សព្វនិមិត្តេហិ អនិមិត្តោ ហោតិ និរោធគោចរោ អវិជ្ជំ បជហតោ អនុបស្សនដ្ឋេន វិបស្សនា សព្វនិមិត្តេហិ អនិមិត្តា ហោតិ និរោធគោចរា ឥតិ អនិមិត្តដ្ឋេន សមថវិបស្សនា ឯករសា ហោន្តិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ អនិមិត្តដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

កថំ អប្បណិហិតដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ឧទ្ធច្ចំ បជហតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ សព្វប្បណិធីហិ អប្បណិហិតោ ហោតិ និរោធគោចរោ អវិជ្ជំ បជហតោ អនុបស្សនដ្ឋេន វិបស្សនា សព្វប្បណិធីហិ អប្បណិហិតា ហោតិ និរោធគោចរា ឥតិ អប្បណិហិតដ្ឋេន សមថវិបស្សនា ឯករសា ហោន្តិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ អប្បណិហិតដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាមិនមាននិមិត្ត តើដូចម្តេច ។ កាលបុគ្គលលះនូវឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ ជាធម៌មិនមាននិមិត្តដោយនិមិត្តទាំងពួង មាននិរោធជាគោចរ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ក៏ជាគុណជាតិមិនមាននិមិត្ត ដោយនិមិត្តទាំងពួង មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថាមិនមាននិមិត្ត ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាមិនមាននិមិត្ត ។

ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាមិនមានទីតម្កល់ តើដូចម្តេច ។ កាលបុគ្គលលះនូវឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ ជាធម៌មិនមានទីតម្កល់ដោយទីតម្កល់ទាំងពួង មាននិរោធជាគោចរ កាលបុគ្គលលះនូវអវិជ្ជា វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ក៏ជាគុណជាតិមិនមានទីតម្កល់ដោយទីតម្កល់ទាំងពួង មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថាមិនមានទីតម្កល់ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាមិនមានទីតម្កល់ ។

៣៨

## យុគនទ្ធវគ្គេ យុគនទ្ធកថា

កថំ សុញ្ញតដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ឧទ្ធច្ចំ បជហតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ សព្វាភិនិវេសេហិ សុញ្ញោ ហោតិ និរោធគោចរោ អវិជ្ជំ បជហតោ អនុបស្សនដ្ឋេន វិបស្សនា សព្វាភិនិវេសេហិ សុញ្ញា ហោតិ និរោធគោចរា ឥតិ សុញ្ញតដ្ឋេន សមថវិបស្សនា ឯករសា ហោន្តិ យុគនទ្ធា ហោន្តិ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ សុញ្ញតដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

ភាវេតីតិ ចតស្សោ ភាវនា តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា តទុបគវីរិយវាហនដ្ឋេន ភាវនា អាសេវនដ្ឋេន ភាវនា ។ បេ ។ មគ្គោ សញ្ជាយតីតិ កថំ មគ្គោ សញ្ជាយតិ ។ បេ ។ ឯវំ មគ្គោ សញ្ជាយតិ ។ បេ ។

ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាសូន្យ តើដូចម្ដេច ។ កាលបុគ្គលលះនូវឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ ជាធម៌សូន្យចាកការប្រកាន់ស្អិតទាំងពួង មាននិរោធជាគោចរ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថាឃើញរឿយ ៗ ក៏ជាគុណជាតិសូន្យ ចាកការប្រកាន់ស្អិតទាំងពួង មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថាសូន្យ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានិងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាសូន្យ ។

ពាក្យថា ចម្រើន បានដល់ការចម្រើន ៤ យ៉ាង គឺការចម្រើនដោយអត្ថថាមិនកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ ការចម្រើន ដោយអត្ថថាឥន្ទ្រិយទាំងឡាយមានរសតែមួយ ការចម្រើនដោយអត្ថថានាំទៅដោយវីរិយៈ ដ៏សមគួរដល់ឥន្ទ្រិយនោះ ការចម្រើនដោយអត្ថថាឧស្សាហ៍គប់រក ។ បេ ។ សំណួរត្រង់ពាក្យថា មគ្គកើតឡើង តើមគ្គកើតឡើងដូចម្ដេច ។ បេ ។ មគ្គកើតឡើង យ៉ាងនេះ ។ បេ ។

ឯវំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ឯវំ សុញ្ញតដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ឥមេហិ សោឡសហិ អាការេហិ សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ឯវំ សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

[១៣] កថំ ធម្មុទ្ធច្ចវិគ្គហិតមានសំ ហោតិ ។ អនិច្ចតោ មនសិការោតោ ឱភាសោ ឧប្បជ្ជតិ ឱភាសោ ធម្មោតិ ឱភាសំ អាវជ្ជតិ តតោ វិក្ខេបោ ឧទ្ធច្ចំ តេន ឧទ្ធច្ចេន វិគ្គហិតមានសោ អនិច្ចតោ ឧបដ្ឋានំ យថាភូតំ នប្បជានាតិ ទុក្ខតោ ឧបដ្ឋានំ យថាភូតំ នប្បជានាតិ អនត្តតោ ឧបដ្ឋានំ យថាភូតំ នប្បជានាតិ តេន វុច្ចតិ ធម្មុទ្ធច្ចវិគ្គហិតមានសំ ហោតិ សោ សមយោ យន្តំ ចិត្តំ អជ្ឈត្តញ្ញេវ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិ ហោតិ សមាធិយតិ តស្ស មគ្គោ សញ្ជាយតីតិ កថំ មគ្គោ សញ្ជាយតិ ។ បេ ។ ឯវំ មគ្គោ សញ្ជាយតិ ។ បេ ។ ឯវំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ អនិច្ចតោ មនសិការោតោ ញាណំ ឧប្បជ្ជតិ បីតិ ឧប្បជ្ជតិ

ភិក្ខុនោះ ក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយ ក៏វិនាស យ៉ាងនេះ ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាសូន្យ យ៉ាងនេះ ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអាការ ១៦ យ៉ាងនេះ ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា យ៉ាងនេះឯង ។

[១៣] ចិត្តដែលមិនច្រួលច្រាល់ ដោយឧទ្ធច្ចៈក្នុងធម៌ តើដូចម្ដេច ។ កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាមិនទៀង ពន្លឺក៏កើតឡើង ភិក្ខុនោះ ពិចារណានូវពន្លឺថា ពន្លឺជាធម៌ លំដាប់នោះ សេចក្ដីរាយមាយ សេចក្ដីអណ្ដែតអណ្ដូង (ក៏កើតឡើង) ភិក្ខុមានចិត្តច្រួលច្រាល់ ដោយឧទ្ធច្ចៈនោះ រមែងមិនដឹងតាមពិត នូវការប្រាកដថាមិនទៀង មិនដឹងតាមពិត នូវការប្រាកដថាជាទុក្ខ មិនដឹងតាមពិត នូវការប្រាកដថាមិនមែនខ្លួន ព្រោះហេតុនោះ លោកទើបពោលថា ចិត្តមិនច្រួលច្រាល់ដោយឧទ្ធច្ចៈក្នុងធម៌ មានសម័យដែលចិត្តនោះ ឋិតនៅ សម្ងំនៅ ជាចិត្តខ្ពស់ឯក តាំងនៅនឹងធឹងក្នុងសន្ដាន សំណួរត្រង់ពាក្យថា មគ្គកើតឡើងដល់ភិក្ខុនោះ តើមគ្គកើតឡើងដូចម្ដេច ។ បេ ។ មគ្គកើតឡើង យ៉ាងនេះ ។ បេ ។ ភិក្ខុនោះ ក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស យ៉ាងនេះឯង កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាមិនទៀង ញាណកើតឡើង បីតិកើតឡើង

៣៧

យុគនទ្ធវគ្គេ យុគនទ្ធកថា

បស្សទ្ធិ ឧប្បជ្ជតិ សុខំ ឧប្បជ្ជតិ អធិមោក្ខោ ឧប្បជ្ជតិ បគ្គាហោ ឧប្បជ្ជតិ ឧបដ្ឋានំ ឧប្បជ្ជតិ ឧបេក្ខា ឧប្បជ្ជតិ និកន្តិ ឧប្បជ្ជតិ និកន្តិ ធម្មោតិ និកន្តឹ អាវជ្ជតិ តតោ វិក្ខេបោ ឧទ្ធច្ចន្តេន ឧទ្ធច្ចេន វិគ្គហិត-មានសោ អនិច្ចតោ ឧបដ្ឋានំ យថាភូតំ នប្បជានាតិ ទុក្ខតោ ឧបដ្ឋានំ យថាភូតំ នប្បជានាតិ អនត្តតោ ឧបដ្ឋានំ យថាភូតំ នប្បជានាតិ តេន វុច្ចតិ ធម្មុទ្ធច្ចវិ-គ្គហិតមានសំ ហោតិ សោ សមយោ យំ ចិត្តំ អជ្ឈត្ត-ញ្ញេវ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិ ហោតិ សមាធិយ-តិ តស្ស មគ្គោ សញ្ជាយតីតិ កថំ មគ្គោ សញ្ជាយតិ ។ បេ ។ ឯវំ មគ្គោ សញ្ជាយតិ ។ បេ ។ ឯវំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ទុក្ខតោ មនសិក-រោតោ ។ បេ ។ អនត្តតោ មនសិការោតោ ឱភាសោ ឧប្បជ្ជតិ ញាណំ ឧប្បជ្ជតិ បីតិ ឧប្បជ្ជតិ បស្សទ្ធិ ឧប្បជ្ជតិ សុខំ ឧប្បជ្ជតិ អធិមោក្ខោ ឧប្បជ្ជតិ បគ្គា-ហោ ឧប្បជ្ជតិ ឧបដ្ឋានំ ឧប្បជ្ជតិ ឧបេក្ខា ឧប្បជ្ជតិ និកន្តិ ឧប្បជ្ជតិ និកន្តិ ធម្មោតិ និកន្តឹ អាវជ្ជតិ[១]

១ ឱ. ម. អាបជ្ជតិ ។

បស្សទ្ធិ (សេចក្តីស្ងប់) កើតឡើង សុខ កើតឡើង អធិមោក្ខ (ការជឿស៊ប់) កើតឡើង បគ្គាហៈ (ការព្យាយាម) កើតឡើង ឧបដ្ឋានៈ (សតិដ៏ក្លៀវក្លា) កើតឡើង ឧបេក្ខា កើតឡើង និក្កន្តិ (សេចក្តីត្រេកអរ) ក៏កើតឡើង ភិក្ខុនោះ រមែងពិចារណានូវនិក្កន្តិថា និក្កន្តិជាធម៌លំដាប់នោះ សេចក្តីរាយមាយ សេចក្តីអណ្តែតអណ្តូង (ក៏កើតឡើង) ភិក្ខុមានចិត្តច្រួលច្រាល់ ដោយឧទ្ធច្ចៈនោះ រមែងមិនដឹងតាមពិត នូវការប្រាកដជាមិនទៀង មិនដឹងតាមពិត នូវការប្រាកដជាជាទុក្ខ មិនដឹងតាមពិត នូវការប្រាកដជាមិនមែនខ្លួន ព្រោះហេតុនោះ លោកទើបពោលថា ចិត្តមិនច្រួលច្រាល់ ដោយឧទ្ធច្ចៈក្នុងធម៌ មានសម័យដែលចិត្តនោះ ឋិតនៅ សម្ងំនៅ ជាចិត្តខ្ពស់ឯក តាំងនៅនឹងធឹងក្នុងសន្តាន សំណួរត្រង់ពាក្យថា មគ្គក៏កើតឡើងដល់ភិក្ខុនោះ តើមគ្គកើតឡើង ដូចម្តេច ។ បេ ។ មគ្គកើតឡើង យ៉ាងនេះ ។ បេ ។ ភិក្ខុនោះក៏លះសញ្ញោជនៈទាំង-ឡាយ អនុស័យទាំងឡាយ ក៏វិនាស យ៉ាងនេះ កាលភិក្ខុធ្វើទុកក្នុងចិត្តថាជាទុក្ខ ។ បេ ។ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ពន្លឺកើតឡើង ញាណកើតឡើង បីតិកើតឡើង បស្សទ្ធិកើតឡើង សុខកើតឡើង អធិមោក្ខកើតឡើង បគ្គាហៈកើតឡើង ឧបដ្ឋានៈកើតឡើង ឧបេក្ខាកើតឡើង និក្កន្តិកើតឡើង ភិក្ខុនោះ រមែងពិចារណានូវនិក្កន្តិថា និក្កន្តិ

តតោ វិក្ខេបោ ឧទ្ធច្ចន្តេន ឧទ្ធច្ចេន វិគ្គហិតមានសោ អនត្តតោ ឧបដ្ឋានំ អនិច្ចតោ ឧបដ្ឋានំ ទុក្ខតោ ឧបដ្ឋានំ យថាភូតំ នប្បជានាតិ តេន វុច្ចតិ ធម្មុទ្ធច្ចវិគ្គហិតមានសំ[១] ។ បេ ។ ឯវំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។

[១៤] រូបំ អនិច្ចតោ មនសិការោតោ ។ បេ ។ រូបំ ទុក្ខតោ មនសិការោតោ រូបំ អនត្តតោ មនសិការោតោ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ ចក្ខុំ ។ បេ ។ ជរាមរណំ អនិច្ចតោ មនសិការោតោ ជរាមរណំ ទុក្ខតោ មនសិការោតោ ជរាមរណំ អនត្តតោ មនសិការោតោ ឱភាសោ ឧប្បជ្ជតិ ញាណំ ឧប្បជ្ជតិ បីតិ ឧប្បជ្ជតិ បស្សទ្ធិ ឧប្បជ្ជតិ សុខំ ឧប្បជ្ជតិ អធិមោក្ខោ ឧប្បជ្ជតិ បគ្គាហោ ឧប្បជ្ជតិ ឧបដ្ឋានំ ឧប្បជ្ជតិ ឧបេក្ខា ឧប្បជ្ជតិ និក្កន្តិ ឧប្បជ្ជតិ និក្កន្តិ ធម្មោតិ និក្កន្តឹ អាវជ្ជតិ

១ ឱ. ម. ធម្មុទ្ធច្ចវិគ្គហិតមានសោ ។

ជាធម៌ លំដាប់នោះ សេចក្តីរាយមាយ សេចក្តីអណ្តែតអណ្តូង (ក៏កើតឡើង) ភិក្ខុមានចិត្តច្រួលច្រាល់ដោយឧទ្ធច្ចៈនោះ រមែងមិនដឹងតាមពិតនូវការប្រាកដ ថាមិនមែនខ្លួន នូវការប្រាកដថាមិនទៀង នូវការប្រាកដថាជាទុក្ខ ព្រោះហេតុនោះ លោកទើបពោលថា ចិត្តមិនច្រួលច្រាល់ដោយឧទ្ធច្ចៈក្នុងធម៌ ។ បេ ។ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស យ៉ាងនេះឯង ។

[១៤] កាលភិក្ខុធ្វើទុកក្នុងចិត្តនូវរូប ថាមិនទៀង ។ បេ ។ កាលធ្វើទុកក្នុងចិត្តនូវរូប ថាជាទុក្ខ កាលធ្វើទុកក្នុងចិត្តនូវរូប ថាមិនមែនខ្លួន នូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ កាលភិក្ខុធ្វើទុកក្នុងចិត្ត នូវជរាមរណៈ ថាមិនទៀង កាលធ្វើទុកក្នុងចិត្តនូវជរាមរណៈថាជាទុក្ខ កាលភិក្ខុធ្វើទុកក្នុងចិត្តនូវជរាមរណៈ ថាមិនមែនខ្លួន ពន្លឺកើតឡើង ញាណកើតឡើង បីតិកើតឡើង បស្សទ្ធិកើតឡើង សុខកើតឡើង អធិមោក្ខកើតឡើង បគ្គាហៈកើតឡើង ឧបដ្ឋានៈកើតឡើង ឧបេក្ខាកើតឡើង និកន្តិកើតឡើង ភិក្ខុនោះរមែងពិចារណានូវនិកន្តិថា និកន្តិជាធម៌

៣៩

### យុគនទ្ធវគ្គេ យុគនទ្ធកថា

តតោ វិក្ខេបោ ឧទ្ធច្ចន្តេន ឧទ្ធច្ចេន វិគ្គហិតមានសោ ជរាមរណំ អនត្តតោ ឧបដ្ឋានំ យថាភូតំ នប្ប-ជានាតិ ជរាមរណំ អនិច្ចតោ ឧបដ្ឋានំ យថា-ភូតំ នប្បជានាតិ ជរាមរណំ ទុក្ខតោ ឧបដ្ឋានំ យថា-ភូតំ នប្បជានាតិ តេន វុច្ចតិ ធម្មុទ្ធច្ចវិគ្គហិតមា-នសំ ហោតិ សោ សមយោ យន្តំ ចិត្តំ អនិច្ចតោ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិ ហោតិ សមាធិយតិ តស្ស មគ្គោ សញ្ជាយតីតិ កថំ មគ្គោ សញ្ជាយតិ ។ បេ ។ ឯវំ មគ្គោ សញ្ជាយតិ ។ បេ ។ ឯវំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ឯវំ ធម្មុទ្ធច្ចវិគ្គហិតមានសំ ហោតិ ។

យុគនទ្ធវគ្គ យុគនទ្ធកថា

លំដាប់នោះ សេចក្តីរាយមាយ សេចក្តីអណ្តែតអណ្តូង ក៏កើតឡើង ភិក្ខុមានចិត្តច្រួលច្រាល់ ដោយឧទ្ធច្ចៈនោះ រមែងមិនដឹងតាមពិត នូវការប្រាកដ គឺជរានិងមរណៈ ថាមិនមែនខ្លួន មិនដឹងតាមពិតនូវ ការប្រាកដ គឺជរានិងមរណៈ ថាមិនទៀង មិនដឹងតាមពិត នូវការ ប្រាកដគឺជរានិងមរណៈ ថាជាទុក្ខ ព្រោះហេតុនោះ លោកទើបពោល ថា ចិត្តមិនច្រួលច្រាល់ ដោយឧទ្ធច្ចៈក្នុងធម៌ មានសម័យដែលចិត្តនោះ ឋិតនៅ សម្ងំនៅ ជាចិត្តខ្ពស់ឯក តាំងនៅនឹងធឹង ថាមិនទៀង សំណួរ ត្រង់ពាក្យថា មគ្គកើតឡើងដល់ភិក្ខុនោះ តើមគ្គកើតឡើងដូចម្តេច ។ បេ ។ មគ្គកើតឡើង យ៉ាងនេះ ។ បេ ។ ភិក្ខុនោះ ក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស យ៉ាងនេះ ចិត្តមិនច្រួលច្រាល់ ដោយ ឧទ្ធច្ចៈក្នុងធម៌ យ៉ាងនេះឯង ។

ឱភាសេ ចេវ ញាណេ ច  បីតិយា ច វិកម្បតិ
បស្សទ្ធិយា សុខេ ចេវ  យេហិ ចិត្តំ បវេធតិ
អធិមោក្ខេ ច បគ្គាហេ  ឧបដ្ឋានេ ច វិកម្បតិ
ឧបេក្ខាវជ្ជនា[១] ចេវ  ឧបេក្ខាយ ច និកន្តិយា
ឥមានិ ទស ឋានានិ  បញ្ញាយស្ស បរិចិតា
ធម្មុទ្ធច្ចកុសលោ ហោតិ  ន ច សម្មោហគច្ឆតិ
វិកម្បតិ[២] ចេវ កិលិស្សតិ  ច ចវតិ ចិត្តភាវនា
វិកម្បតិ[៣] កិលិស្សតិ  ភាវនា បរិហាយតិ
វិសុជ្ឈតិ[៤] ន កិលិស្សតិ  ភាវនា ន បរិហាយតិ
ន ច វិក្ខិប្បតេ ចិត្តំ ន កិលិស្សតិ ន ចវតិ ចិត្តភាវនា
ឥមេហិ ចតូហិ ឋានេហិ  ចិត្តស្ស សង្ខេបំ វិក្ខេបំ[៥]
វិគ្គហិតំ[៤] ទសដ្ឋានេហិ[៦]  សម្បជានាតីតិ ។

យុគនទ្ធកថា ។

---

១ ឱ. ម. ឧបេក្ខាវជ្ជនាយ ។ ២-៣ ឱ. ម. វិក្ខិបតិ ។ ៤ ម. វិក្ខិបតិ ។ ៥ ឱ. ចិត្តសង្ខេបវិក្ខេបំ អវិក្ខេបំ វិគ្គហិតន្តិ ទិស្សន្តិ ។ ម. ចិត្តស្ស សង្ខេបវិក្ខេបវិគ្គហិតន្តិ ទិស្សន្តិ ។ ៦ ម. ទសដ្ឋានេ ។

ចិត្តរមែងញាប់ញ័រ ដោយហេតុទាំងឡាយណា ហេតុទាំងនេះមាន ១០ គឺ ចិត្តញាប់ញ័រព្រោះពន្លឺ ១ ញាណ ១ បីតិ ១ បស្សទ្ធិ ១ សុខ ១ ញាប់ញ័រព្រោះអធិមោក្ខ ១ បគ្គាហៈ ១ ឧបដ្ឋានៈ ១ ការពិចារណាដោយឧបេក្ខាក្នុងឧបេក្ខា ១ និកន្តិ ១ ភិក្ខុណា សន្សំបញ្ញាហើយ ភិក្ខុនោះ ឈ្មោះថាជាអ្នកឆ្លៀវឆ្លាស បំពោះឧទ្ធច្ចៈក្នុងធម៌ រមែងមិនដល់នូវសេចក្តីវង្វេង ទាំងដឹងច្បាស់ នូវការប្រមូលចិត្ត និងការរាយមាយដោយហេតុ ៤ នេះ គឺចិត្តភាវនា ញាប់ញ័រ សៅហ្មង ឃ្លាត ១ ចិត្តភាវនា ញាប់ញ័រ សៅហ្មង សាបសូន្យ ១ ចិត្តភាវនា បរិសុទ្ធ មិនសៅហ្មង មិនសាបសូន្យ ១ ចិត្តភាវនា មិនរាយមាយ មិនសៅហ្មង មិនឃ្លាត ១ និងការប្រួលប្រាល់ដោយហេតុ ១០ យ៉ាង ។

ចប់ យុគនទ្ធកថា ។

# យុគនទ្ធវគ្គេ សច្ចកថា

## បរិបុណ្ណកថានិទានំ[១]

[១៥] ចត្តារិមានិ ភិក្ខវេ តថានិ អវិតថានិ អនញ្ញថានិ កតមានិ ចត្តារិ ឥទំ ទុក្ខន្តិ ភិក្ខវេ តថមេតំ អវិតថមេតំ អនញ្ញថមេតំ អយំ ទុក្ខសមុទយោតិ តថមេតំ អវិតថមេតំ អនញ្ញថមេតំ អយំ ទុក្ខនិរោធោតិ តថមេតំ អវិតថមេតំ អនញ្ញថមេតំ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ តថមេតំ អវិតថមេតំ អនញ្ញថមេតំ ឥមានិ ខោ ភិក្ខវេ ចត្តារិ តថានិ អវិតថានិ អនញ្ញថានិ ។

[១៦] កថំ ទុក្ខំ តថដ្ឋេន សច្ចំ ។ ចត្តារោ ទុក្ខស្ស ទុក្ខដ្ឋា តថា អវិតថា អនញ្ញថា ទុក្ខស្ស បីឡនដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ ឥមេ ចត្តារោ ទុក្ខស្ស ទុក្ខដ្ឋា តថា អវិតថា អនញ្ញថា ឯវំ ទុក្ខំ តថដ្ឋេន សច្ចំ ។

---

១ ម. បរិបុណ្ណកថានិទានានិ ។

# យុគនទ្ធវគ្គ សច្ចកថា

# បរិបុណ្ណកថានិទាន

[១៥] ម្នាលភិក្ខុទាំងឡាយ សច្ចៈ ៤ នេះ ជារបស់ពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត សច្ចៈ ៤ តើអ្វីខ្លះ ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះទុក្ខ ទុក្ខសច្ចនុ៎ះ ជារបស់ពិត នុ៎ះជារបស់មិនប្រែប្រួល នុ៎ះជារបស់មិនឃ្លៀងឃ្លាត ពាក្យថា នេះទុក្ខសមុទ័យ ទុក្ខសមុទយសច្ចនុ៎ះ ជារបស់ពិត នុ៎ះជារបស់មិនប្រែប្រួល នុ៎ះជារបស់មិនឃ្លៀងឃ្លាត ពាក្យថា នេះទុក្ខនិរោធ ទុក្ខនិរោធសច្ចនុ៎ះ ជារបស់ពិត នុ៎ះជារបស់មិនប្រែប្រួល នុ៎ះជារបស់មិនឃ្លៀងឃ្លាត ពាក្យថា នេះទុក្ខនិរោធគាមិនីបដិបទា ទុក្ខនិរោធសច្ចនុ៎ះ ជារបស់ពិត នុ៎ះជារបស់មិនប្រែប្រួល នុ៎ះជារបស់មិនឃ្លៀងឃ្លាត ម្នាលភិក្ខុទាំងឡាយ សច្ចៈ ៤ នេះឯង ជារបស់ពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត ។

[១៦] ទុក្ខ ឈ្មោះថាសច្ចៈ ដោយអត្ថថាជារបស់ពិត តើដូចម្តេច ។ អត្ថនៃទុក្ខ របស់ទុក្ខ ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត មាន ៤ យ៉ាង គឺ ទុក្ខ មានអត្ថថាបៀតបៀន ១ មានអត្ថថាបច្ច័យប្រជុំតាក់តែង ១ មានអត្ថថាក្តៅក្រហាយ ១ មានអត្ថថាប្រែប្រួល ១ នេះអត្ថនៃទុក្ខ របស់ទុក្ខ ៤ យ៉ាង ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត ទុក្ខ ឈ្មោះថាសច្ចៈ ដោយអត្ថថាជារបស់ពិត យ៉ាងនេះឯង ។

កថំ សមុទយោ តថដ្ឋេន សច្ចំ ។ ចត្តារោ សមុទយស្ស សមុទយដ្ឋា តថា អវិតថា អនញ្ញថា សមុទយស្ស អាយុហានដ្ឋោ និទានដ្ឋោ សំយោគដ្ឋោ បលិពោធដ្ឋោ ឥមេ ចត្តារោ សមុទយស្ស សមុ-ទយដ្ឋា តថា អវិតថា អនញ្ញថា ឯវំ សមុទយោ តថដ្ឋេន សច្ចំ ។

កថំ និរោធោ តថដ្ឋេន សច្ចំ ។ ចត្តារោ និរោធស្ស និរោធដ្ឋា តថា អវិតថា អនញ្ញថា និរោធស្ស និស្សរណដ្ឋោ វិវេកដ្ឋោ អសង្ខតដ្ឋោ អមតដ្ឋោ ឥមេ ចត្តារោ និរោធស្ស និរោធដ្ឋា តថា អវិតថា អនញ្ញថា ឯវំ និរោធោ តថដ្ឋេន សច្ចំ ។

កថំ មគ្គោ តថដ្ឋេន សច្ចំ ។ ចត្តារោ ម-គ្គស្ស មគ្គដ្ឋា តថា អវិតថា អនញ្ញថា មគ្គស្ស និយ្យានដ្ឋោ ហេតដ្ឋោ[១] ទស្សនដ្ឋោ អាធិបតេយ្យ-ដ្ឋោ ឥមេ ចត្តារោ មគ្គស្ស មគ្គដ្ឋា តថា អវិតថា អនញ្ញថា ឯវំ មគ្គោ តថដ្ឋេន សច្ចំ ។

១ ឱ. ម. ហេតុដ្ឋោ ។

សមុទ័យ ឈ្មោះថាសច្ចៈ ដោយអត្ថថាជារបស់ពិត តើដូចម្តេច ។ អត្ថនៃសមុទ័យ របស់សមុទ័យ ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត មាន ៤ យ៉ាង គឺ សមុទ័យ មានអត្ថថាប្រមូលមក ១ មានអត្ថថាជាហេតុ ១ មានអត្ថថាប្រកបទុក ១ មានអត្ថថាកង្វល់ ១ នេះអត្ថនៃសមុទ័យ របស់សមុទ័យ ៤ យ៉ាង ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត សមុទ័យ ឈ្មោះថាសច្ចៈ ដោយអត្ថថាជារបស់ពិត យ៉ាងនេះឯង ។

និរោធ ឈ្មោះថាសច្ចៈ ដោយអត្ថថាជារបស់ពិត តើដូចម្តេច ។ អត្ថនៃនិរោធ របស់និរោធ ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត មាន ៤ គឺ និរោធ មានអត្ថថារលាស់ខ្លួនចេញ ១ មានអត្ថថាស្ងប់ស្ងាត់ ១ មានអត្ថថាមិនមានបច្ច័យប្រជុំតាក់តែង ១ មានអត្ថថាមិនស្លាប់ ១ នេះអត្ថនៃនិរោធ របស់និរោធ ៤ យ៉ាង ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត និរោធ ឈ្មោះថាសច្ចៈ ដោយអត្ថថាជារបស់ពិត យ៉ាងនេះឯង ។

មគ្គ ឈ្មោះថាសច្ចៈ ដោយអត្ថថាជារបស់ពិត តើដូចម្តេច ។ អត្ថនៃមគ្គ របស់មគ្គ ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត មាន ៤ គឺ មគ្គ មានអត្ថថានាំចេញ ១ មានអត្ថថាជាហេតុ ១ មានអត្ថថាឃើញ ១ មានអត្ថថាជាអធិបតី ១ នេះអត្ថនៃមគ្គ របស់មគ្គ ៤ យ៉ាង ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត មគ្គ ឈ្មោះថាសច្ចៈ ដោយអត្ថថាជារបស់ពិត យ៉ាងនេះឯង ។

[១៧] កតិហាការេហិ(១) ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។ ចតូហាការេហិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ តថដ្ឋេន អនត្តដ្ឋេន សច្ចដ្ឋេន បដិវេធដ្ឋេន ឥមេហិ ចតូហាការេហិ ចត្តារិ សច្ចានិ ឯកសង្គហិតានិ យំ ឯកសង្គហិតំ តំ ឯកត្តំ ឯកត្តំ(២) ឯកេន ញាណេន បដិវិជ្ឈតីតិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។

កថំ តថដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។ ចតូហាការេហិ តថដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ទុក្ខស្ស ទុក្ខដ្ឋោ តថដ្ឋោ សមុទយស្ស សមុទយដ្ឋោ តថដ្ឋោ និរោធស្ស និរោធដ្ឋោ តថដ្ឋោ មគ្គស្ស មគ្គដ្ឋោ តថដ្ឋោ ឥមេហិ ចតូហាការេហិ តថដ្ឋេន ចត្តារិ សច្ចានិ ឯកសង្គហិតានិ យំ ឯកសង្គហិតំ តំ ឯកត្តំ ឯកត្តំ ឯកេន ញាណេន បដិវិជ្ឈតីតិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។

១ ម. កតីហាការេហិ ។ ២ ម. សព្វេសុ ឋានេសុ បច្ឆិមំ ឯកត្តន្តិ បទំ នត្ថិ ។

[១៧] *សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអាការប៉ុន្មានយ៉ាង ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអាការ ៤ យ៉ាង គឺ ដោយអត្ថថាជារបស់ពិត ១ ដោយអត្ថថាមិនមែនខ្លួន ១ ដោយអត្ថថាទៀង ១ ដោយអត្ថថាត្រាស់ដឹង ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអាការ ៤ យ៉ាង សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះ មានសភាពតែមួយ បុគ្គលត្រាស់ដឹងនូវសច្ចៈមានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថាជាទីត្រាស់ដឹងតែមួយ ។*

*សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាជារបស់ពិត តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាជារបស់ពិត ដោយអាការ ៤ យ៉ាង គឺ ទុក្ខ មានអត្ថថាលំបាក ជាអត្ថថាពិត ១ សមុទ័យ មានអត្ថថាជាដែនកើត ជាអត្ថថាពិត ១ និរោធ មានអត្ថថារលត់ ជាអត្ថថាពិត ១ មគ្គ មានអត្ថថាជាផ្លូវ ជាអត្ថថាពិត ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអត្ថថាជារបស់ពិត ដោយអាការ ៤ យ៉ាង សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះមានភាពតែមួយ បុគ្គលត្រាស់ដឹងនូវសច្ចៈ មានភាពតែមួយ ដោយញាណមួយ  ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថាជាទីត្រាស់ដឹងតែមួយ ។*

៤៤



កថំ អនត្តដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។ ចតូហាការេហិ អនត្តដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ទុក្ខស្ស ទុក្ខដ្ឋោ អនត្តដ្ឋោ សមុទយស្ស សមុទយដ្ឋោ អនត្តដ្ឋោ និរោធស្ស និរោធដ្ឋោ អនត្តដ្ឋោ មគ្គស្ស មគ្គដ្ឋោ អនត្តដ្ឋោ ឥមេហិ ចតូហាការេហិ អនត្តដ្ឋេន ចត្តារិ សច្ចានិ ឯកសង្គហិតានិ យំ ឯកសង្គហិតំ តំ ឯកត្តំ ឯកត្តំ ឯកេន ញាណេន បដិវិជ្ឈតីតិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។

កថំ សច្ចដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។ ចតូហាការេហិ សច្ចដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ទុក្ខស្ស ទុក្ខដ្ឋោ សច្ចដ្ឋោ សមុទយស្ស សមុទយដ្ឋោ សច្ចដ្ឋោ និរោធស្ស និរោធដ្ឋោ សច្ចដ្ឋោ មគ្គស្ស មគ្គដ្ឋោ សច្ចដ្ឋោ ឥមេហិ ចតូហាការេហិ សច្ចដ្ឋេន ចត្តារិ សច្ចានិ ឯកសង្គហិតានិ យំ ឯកសង្គហិតំ តំ ឯកត្តំ ឯកត្តំ ឯកេន ញាណេន បដិវិជ្ឈតីតិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាមិនមែនខ្លួន តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាមិនមែនខ្លួន ដោយអាការ ៤ យ៉ាង គឺ ទុក្ខ មានអត្ថថាលំបាក ជាអត្ថថាមិនមែនខ្លួន ១ សមុទ័យ មានអត្ថថាជាដែនកើត ជាអត្ថថាមិនមែនខ្លួន ១ និរោធ មានអត្ថថារលត់ ជាអត្ថថាមិនមែនខ្លួន ១ មគ្គ មានអត្ថថាជាផ្លូវ ជាអត្ថថាមិនមែនខ្លួន ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអត្ថថាមិនមែនខ្លួន ដោយអាការ ៤ យ៉ាង សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះ មានភាពតែមួយ បុគ្គលត្រាស់ដឹងនូវសច្ចៈ មានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថាជាទីត្រាស់ដឹងតែមួយ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាទៀង តើដូចម្តេច។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាទៀង ដោយអាការ ៤ យ៉ាង គឺ ទុក្ខ មានអត្ថថាលំបាក ជាអត្ថថាទៀង ១ សមុទ័យ មានអត្ថថាជាដែនកើត ជាអត្ថថាទៀង ១ និរោធ មានអត្ថថារលត់ ជាអត្ថថាទៀង ១ មគ្គ មានអត្ថថាជាផ្លូវ ជាអត្ថថាទៀង ១ នេះ សច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអត្ថថាទៀង ដោយអាការ ៤ យ៉ាង សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះ មានភាពតែមួយ បុគ្គលត្រាស់ដឹងនូវសច្ចៈ មានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថាជាទីត្រាស់ដឹងតែមួយ ។

កថំ បដិវេធដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។ ចតូហាការេហិ បដិវេធដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ទុក្ខស្ស ទុក្ខដ្ឋោ បដិវេធដ្ឋោ សមុទយស្ស សមុទយដ្ឋោ បដិវេធដ្ឋោ និរោធស្ស និរោធដ្ឋោ បដិវេធដ្ឋោ មគ្គស្ស មគ្គដ្ឋោ បដិវេធដ្ឋោ ឥមេហិ ចតូហាការេហិ បដិវេធដ្ឋេន ចត្តារិ សច្ចានិ ឯកសង្គហិតានិ យំ ឯកសង្គហិតំ តំ ឯកត្តំ ឯកត្តំ ឯកេន ញាណេន បដិវិជ្ឈតីតិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។

[១៨] កតិហាការេហិ[១] ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។ យំ អនិច្ចំ តំ ទុក្ខំ[២] យំ អនិច្ចញ្ច ទុក្ខញ្ច តំ អនត្តា យំ អនិច្ចញ្ច ទុក្ខញ្ច អនត្តា ច តំ តថំ យំ អនិច្ចញ្ច ទុក្ខញ្ច អនត្តា ច[៣] តថញ្ច តំ សច្ចំ យំ អនិច្ចញ្ច ទុក្ខញ្ច អនត្តា ច តថញ្ច សច្ចញ្ច តំ ឯកសង្គហិតំ យំ ឯកសង្គហិតំ តំ ឯកត្តំ ឯកត្តំ ឯកេន ញាណេន បដិវិជ្ឈតីតិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។

១ ឱ. កថំ ។ ២ ម. ឯត្ថន្តរេ យំ ទុក្ខំ តំ អនិច្ចន្តិ ទិស្សន្តិ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាត្រាស់ដឹង តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាត្រាស់ដឹងដោយអាការ ៤ យ៉ាង គឺ ទុក្ខ មានអត្ថថាលំបាក ជាអត្ថថាត្រាស់ដឹង ១ សមុទ័យ មានអត្ថថាជាដែនកើត ជាអត្ថថាត្រាស់ដឹង ១ និរោធ មានអត្ថថារលត់ ជាអត្ថថាត្រាស់ដឹង ១ មគ្គ មានអត្ថថាជាផ្លូវ ជាអត្ថថាត្រាស់ដឹង ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអត្ថថាត្រាស់ដឹង ដោយអាការ ៤ យ៉ាង សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះ មានភាពតែមួយ បុគ្គលត្រាស់ដឹងនូវសច្ចៈមានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថាជាទីត្រាស់ដឹងតែមួយ ។

[១៨] សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអាការប៉ុន្មាន ។ វត្ថុណា មិនទៀង វត្ថុនោះជាទុក្ខ វត្ថុណា មិនទៀងផង ជាទុក្ខផង វត្ថុនោះ មិនមែនរបស់ខ្លួន វត្ថុណា មិនទៀងផង ជាទុក្ខផង មិនមែនរបស់ខ្លួនផង វត្ថុនោះពិត វត្ថុណា មិនទៀងផង ជាទុក្ខផង មិនមែនរបស់ខ្លួនផង ពិតផង វត្ថុនោះទៀង វត្ថុណា មិនទៀងផង ជាទុក្ខផង មិនមែនរបស់ខ្លួនផង ពិតផង ទៀងផង វត្ថុនោះលោកសង្គ្រោះយកតែមួយ វត្ថុណា ដែលលោកសង្គ្រោះយកតែមួយ វត្ថុនោះ ឈ្មោះថាមានភាពតែមួយ បុគ្គលរមែងត្រាស់ដឹងនូវវត្ថុមានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថាជាទីត្រាស់ដឹងតែមួយ ។

កតិហាការេហិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។ នវហាការេហិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ តថដ្ឋេន អនត្តដ្ឋេន សច្ចដ្ឋេន បដិវេធដ្ឋេន អភិញ្ញដ្ឋេន បរិញ្ញដ្ឋេន បហានដ្ឋេន ភាវនដ្ឋេន សច្ឆិកិរិយដ្ឋេន ឥមេហិ នវហាការេហិ ចត្តារិ សច្ចានិ ឯកសង្គហិតានិ យំ ឯកសង្គហិតំ តំ ឯកត្តំ ឯកត្តំ ឯកេន ញាណេន បដិវិជ្ឈតីតិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។

[១៩] កថំ តថដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។ នវហាការេហិ តថដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ទុក្ខស្ស ទុក្ខដ្ឋោ តថដ្ឋោ សមុទយស្ស សមុទយដ្ឋោ តថដ្ឋោ និរោធស្ស និរោធដ្ឋោ តថដ្ឋោ មគ្គស្ស មគ្គដ្ឋោ តថដ្ឋោ អភិញ្ញាយ អភិញ្ញដ្ឋោ តថដ្ឋោ បរិញ្ញាយ បរិញ្ញដ្ឋោ តថដ្ឋោ បហានស្ស បហានដ្ឋោ តថដ្ឋោ ភាវនាយ ភាវនដ្ឋោ តថដ្ឋោ សច្ឆិកិរិយាយ សច្ឆិកិរិយដ្ឋោ

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអាការប៉ុន្មាន ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអាការ ៩ គឺដោយអត្ថថាពិត ១ ដោយអត្ថថាមិនមែនខ្លួន ១ ដោយអត្ថថាទៀង ១ ដោយអត្ថថាត្រាស់ដឹង ១ ដោយអត្ថថាដឹងច្បាស់ ១ ដោយអត្ថថាកំណត់ដឹង ១ ដោយអត្ថថាលះ១ ដោយអត្ថថាចម្រើន ១ ដោយអត្ថថាធ្វើឲ្យជាក់ច្បាស់ ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអាការ ៩ យ៉ាង សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះ មានភាពតែមួយ បុគ្គលរមែងត្រាស់ដឹងនូវសច្ចៈ មានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថាជាទីត្រាស់ដឹងតែមួយ ។

[១៩] សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាពិត តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាពិត ដោយអាការ ៩ គឺ ទុក្ខ មានអត្ថថាលំបាក ជាអត្ថថាពិត ១ សមុទ័យ មានអត្ថថាជាដែនកើត ជាអត្ថថាពិត ១ និរោធ មានអត្ថថារលត់ ជាអត្ថថាពិត ១ មគ្គ មានអត្ថថាជាផ្លូវ ជាអត្ថថាពិត ១ អភិញ្ញា មានអត្ថថាដឹងច្បាស់ ជាអត្ថថាពិត ១ បរិញ្ញា មានអត្ថថាកំណត់ដឹង ជាអត្ថថាពិត ១ បហានៈ មានអត្ថថាលះ ជាអត្ថថាពិត ១ ភាវនា មានអត្ថថាចម្រើន ជាអត្ថថាពិត ១ សច្ឆិកិរិយា មានអត្ថថាធ្វើឲ្យជាក់ច្បាស់

៤៧

## យុគនទ្ធវគ្គេ សច្ចកថា

តថដ្ឋោ ឥមេហិ នវហាការេហិ តថដ្ឋេន ចត្តារិ សច្ចានិ ឯកសង្គហិតានិ យំ ឯកសង្គហិតំ តំ ឯកត្តំ ឯកត្តំ ឯកេន ញាណេន បដិវិជ្ឈតីតិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។

កថំ អនត្តដ្ឋេន សច្ចដ្ឋេន បដិវេធដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។ នវហាការេហិ បដិវេធដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ទុក្ខស្ស ទុក្ខដ្ឋោ បដិវេធដ្ឋោ សមុទយស្ស សមុទយដ្ឋោ បដិវេធដ្ឋោ និរោធស្ស និរោធដ្ឋោ បដិវេធដ្ឋោ មគ្គស្ស មគ្គដ្ឋោ បដិវេធដ្ឋោ អភិញ្ញាយ អភិញ្ញដ្ឋោ បដិវេធដ្ឋោ បរិញ្ញាយ បរិញ្ញដ្ឋោ បដិវេធដ្ឋោ បហានស្ស បហានដ្ឋោ បដិវេធដ្ឋោ ភាវនាយ ភាវនដ្ឋោ បដិវេធដ្ឋោ សច្ឆិកិរិយាយ សច្ឆិកិរិយដ្ឋោ បដិវេធដ្ឋោ ឥមេហិ នវហាការេហិ បដិវេធដ្ឋេន ចត្តារិ សច្ចានិ ឯកសង្គហិតានិ យំ ឯកសង្គហិតំ

ជាអត្ថថាពិត ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអត្ថថាពិត ដោយអាការ ៩ យ៉ាង សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះមានភាពតែមួយ បុគ្គលរមែងត្រាស់ដឹងនូវសច្ចៈ មានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថាជាទីត្រាស់ដឹងតែមួយ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាមិនមែនខ្លួន ដោយអត្ថថាទៀង ដោយអត្ថថាត្រាស់ដឹង តើដូចម្ដេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាត្រាស់ដឹង ដោយអាការ ៩ គឺ ទុក្ខ មានអត្ថថាលំបាក ជាអត្ថថាត្រាស់ដឹង ១ សមុទ័យ មានអត្ថថាជាដែនកើត ជាអត្ថថាត្រាស់ដឹង ១ និរោធ មានអត្ថថារលត់ ជាអត្ថថាត្រាស់ដឹង ១ មគ្គ មានអត្ថថាជាផ្លូវ ជាអត្ថថាត្រាស់ដឹង ១ អភិញ្ញា មានអត្ថថាដឹងច្បាស់ ជាអត្ថថាត្រាស់ដឹង ១ បរិញ្ញា មានអត្ថថាកំណត់ដឹង ជាអត្ថថាត្រាស់ដឹង ១ បហានៈ មានអត្ថថាលះ ជាអត្ថថាត្រាស់ដឹង ១ ភាវនា មានអត្ថថាចម្រើន ជាអត្ថថាត្រាស់ដឹង ១ សច្ឆិកិរិយា មានអត្ថថាធ្វើឲ្យជាក់ច្បាស់ ជាអត្ថថាត្រាស់ដឹង ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអត្ថថាត្រាស់ដឹង ដោយអាការ ៩ យ៉ាង សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ

តំ ឯកត្តំ ឯកត្តំ ឯកេន ញាណេន បដិវិជ្ឈតីតិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។

[២០] កតិហាការេហិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។ ទ្វាទសហាការេហិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ តថដ្ឋេន អនត្តដ្ឋេន សច្ចដ្ឋេន បដិវេធដ្ឋេន អភិជាននដ្ឋេន បរិជាននដ្ឋេន ធម្មដ្ឋេន តថដ្ឋេន ញាតដ្ឋេន សច្ឆិកិរិយដ្ឋេន ផស្សនដ្ឋេន អភិសមយដ្ឋេន ឥមេហិ ទ្វាទសហាការេហិ ចត្តារិ សច្ចានិ ឯកសង្គហិតានិ យំ ឯកសង្គហិតំ តំ ឯកត្តំ ឯកត្តំ ឯកេន ញាណេន បដិវិជ្ឈតីតិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។

កថំ តថដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។ សោឡសហិ អាការេហិ តថដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ទុក្ខស្ស បីឡនដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ តថដ្ឋោ សមុទយស្ស

សច្ចៈនោះ មានភាពតែមួយ បុគ្គលរមែងត្រាស់ដឹងនូវសច្ចៈ មានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថាជាទីត្រាស់ដឹងតែមួយ ។

[២០] សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអាការប៉ុន្មាន ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអាការ ១២ គឺដោយអត្ថថាទៀង ១ ដោយអត្ថថាមិនមែនរបស់ខ្លួន ១ ដោយអត្ថថាពិត ១ ដោយអត្ថថាត្រាស់ដឹង ១ ដោយអត្ថថាដឹងច្បាស់ ១ ដោយអត្ថថាកំណត់ដឹង ១ ដោយអត្ថថាជាធម្មតា ១ ដោយអត្ថថាទៀង ១ ដោយអត្ថថាដឹង ១ ដោយអត្ថថាធ្វើឲ្យជាក់ច្បាស់ ១ ដោយអត្ថថាពាល់ត្រូវ ១ ដោយអត្ថថាយល់ច្បាស់ ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអាការ ១២ សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះមានភាពតែមួយ បុគ្គលរមែងត្រាស់ដឹងនូវសច្ចៈ មានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថាជាទីត្រាស់ដឹងតែមួយ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាទៀង តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាទៀង ដោយអាការ ១៦ គឺ ទុក្ខ មានអត្ថថាបៀតបៀន ១ មានអត្ថថាបច្ច័យប្រជុំតាក់តែង ១ មានអត្ថថាក្តៅក្រហាយ ១ មានអត្ថថាប្រែប្រួល ១ ជាអត្ថថាទៀង សមុទ័យ

៤៩

## យុគនទ្ធវគ្គេ សច្ចកថា

អាយុហនដ្ឋោ និទានដ្ឋោ សញ្ញោគដ្ឋោ បលិពោធដ្ឋោ តថដ្ឋោ និរោធស្ស និស្សរណដ្ឋោ វិវេកដ្ឋោ អសង្ខតដ្ឋោ អមតដ្ឋោ តថដ្ឋោ មគ្គស្ស និយ្យានដ្ឋោ ហេតដ្ឋោ ទស្សនដ្ឋោ អាធិបតេយ្យដ្ឋោ តថដ្ឋោ ឥមេហិ សោឡសហិ អាការេហិ តថដ្ឋេន ចត្តារិ សច្ចានិ ឯកសង្គហិតានិ យំ ឯកសង្គហិតំ តំ ឯកត្តំ ឯកត្តំ ឯកេន ញាណេន បដិវិជ្ឈតីតិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។

កថំ អនត្តដ្ឋេន ។ បេ ។ សច្ចដ្ឋេន បដិវេធដ្ឋេន អភិជាននដ្ឋេន បរិជាននដ្ឋេន ធម្មដ្ឋេន តថដ្ឋេន ញាតដ្ឋេន សច្ឆិកិរិយដ្ឋេន ផស្សនដ្ឋេន អភិសមយដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។ សោឡសហិ អាការេហិ អភិសមយដ្ឋេន ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ទុក្ខស្ស បីឡនដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ អភិសមយដ្ឋោ សមុទយស្ស

មានអត្ថថាប្រមូលមក ១ មានអត្ថថាជាហេតុ ១ មានអត្ថថាប្រកបទុក ១ មានអត្ថថាកង្វល់ ១ ជាអត្ថថាទៀង និរោធ មានអត្ថថារលាស់ចេញ ១ មានអត្ថថាស្ងប់ស្ងាត់ ១ មានអត្ថថាមិនមានបច្ច័យប្រជុំតាក់តែង ១ មានអត្ថថាមិនស្លាប់ ១ ជាអត្ថថាទៀង មគ្គ មានអត្ថថាស្រោចស្រង់ ១ មានអត្ថថាជាហេតុ ១ មានអត្ថថាឃើញ ១ មានអត្ថថាជាអធិបតី ១ ជាអត្ថថាទៀង នេះសច្ចៈទាំង ៤ ដោយអត្ថថាទៀង ដោយអាការ ១៦ យ៉ាង ដែលលោកសង្គ្រោះយកតែមួយ សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះមានភាពតែមួយ បុគ្គលរមែងត្រាស់ដឹងនូវសច្ចៈ មានភាពតែមួយ ដោយញាណមួយ ហេតុនោះសច្ចៈទាំង ៤ ឈ្មោះថាជាទីត្រាស់ដឹងតែមួយ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាមិនមែនរបស់ខ្លួន ។ បេ ។ ដោយអត្ថថាពិត ដោយអត្ថថាត្រាស់ដឹង ដោយអត្ថថាដឹងច្បាស់ ដោយអត្ថថាកំណត់ដឹង ដោយអត្ថថាជាធម្មតា ដោយអត្ថថាទៀង ដោយអត្ថថាដឹង ដោយអត្ថថាធ្វើឲ្យជាក់ច្បាស់ ដោយអត្ថថាពាល់ត្រូវ ដោយអត្ថថាយល់ច្បាស់ តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថាយល់ច្បាស់ ដោយអាការ ១៦ គឺ ទុក្ខ មានអត្ថថាបៀតបៀន ១ មានអត្ថថាបច្ច័យប្រជុំតាក់តែង ១ មានអត្ថថាក្តៅក្រហាយ ១ មានអត្ថថាប្រែប្រួល ១ ជាអត្ថថាយល់ច្បាស់ សមុទ័យ

អាយុហានដ្ឋោ និទានដ្ឋោ សញ្ញោគដ្ឋោ បលិពោធដ្ឋោ អភិសមយដ្ឋោ និរោធស្ស និស្សរណដ្ឋោ វិវេកដ្ឋោ អសង្ខតដ្ឋោ អមតដ្ឋោ អភិសមយដ្ឋោ មគ្គស្ស និយ្យានដ្ឋោ ហេតុដ្ឋោ ទស្សនដ្ឋោ អាធិបតេយ្យដ្ឋោ អភិសមយដ្ឋោ ឥមេហិ សោឡសហិ អាការេហិ អភិសមយដ្ឋេន ចត្តារិ សច្ចានិ ឯកសង្គហិតានិ យំ ឯកសង្គហិតំ តំ ឯកត្តំ ឯកេន ញាណេន បដិវិជ្ឈតីតិ ចត្តារិ សច្ចានិ ឯកប្បដិវេធានិ ។

[២១] សច្ចានំ កតិ លក្ខណានិ ។ សច្ចានំ ទ្វេ លក្ខណានិ សង្ខតលក្ខណញ្ច អសង្ខតលក្ខណញ្ច សច្ចានំ ឥមានិ ទ្វេ លក្ខណានិ ។

សច្ចានំ កតិ លក្ខណានិ ។ សច្ចានំ ឆ លក្ខណានិ សង្ខតានំ សច្ចានំ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតានំ អញ្ញថត្តំ បញ្ញាយតិ ន អសង្ខតស្ស សច្ចស្ស ឧប្បាទោ បញ្ញាយតិ ន វយោ បញ្ញាយតិ ន ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ សច្ចានំ ឥមានិ ឆ លក្ខណានិ ។

មានអត្ថថាប្រមូលមក ១ មានអត្ថថាជាហេតុ ១ មានអត្ថថាប្រកបទុក ១ មានអត្ថថាកង្វល់ ១ ជាអត្ថថាយល់ច្បាស់ និរោធ មានអត្ថថារលាស់ចេញ ១ មានអត្ថថាស្ងប់ស្ងាត់ ១ មានអត្ថថាមិនមានបច្ច័យប្រជុំតាក់តែង ១ មានអត្ថថាមិនស្លាប់ ១ ជាអត្ថថាយល់ច្បាស់ មគ្គ មានអត្ថថាស្រោចស្រង់ ១ មានអត្ថថាជាហេតុ ១ មានអត្ថថាឃើញ ១ មានអត្ថថាជាអធិបតី ១ ជាអត្ថថាយល់ច្បាស់ នេះ សច្ចៈទាំង ៤ ដោយអត្ថថាយល់ច្បាស់ ដោយអាការ ១៦ យ៉ាង ដែលលោកសង្គ្រោះយកតែមួយ សច្ចៈណាដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះ មានភាពតែមួយ បុគ្គលរមែងត្រាស់ដឹងនូវសច្ចៈ មានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថាជាទីត្រាស់ដឹងតែមួយ ។

[២១] លក្ខណៈរបស់សច្ចៈ មានប៉ុន្មាន ។ លក្ខណៈរបស់សច្ចៈ មាន ២ គឺ សង្ខតលក្ខណៈ ១ អសង្ខតលក្ខណៈ ១ នេះលក្ខណៈ ២ របស់សច្ចៈ។

លក្ខណៈរបស់សច្ចៈ មានប៉ុន្មាន ។ លក្ខណៈរបស់សច្ចៈមាន ៦ គឺ សច្ចៈទាំងឡាយជាសង្ខតៈ មានការកើតឡើងប្រាកដ ១ មានការសូន្យប្រាកដ ១ សច្ចៈទាំងឡាយដែលឋិតនៅ មានការប្រែប្រួលប្រាកដ ១ សច្ចៈជាអសង្ខតៈ មានការកើតឡើងមិនប្រាកដ ១ មានការសូន្យមិនប្រាកដ ១ សច្ចៈដែលឋិតនៅ មានការប្រែប្រួលមិនប្រាកដ ១ នេះលក្ខណៈ ៦ របស់សច្ចៈ ។

សច្ចានំ កតិ លក្ខណានិ ។ សច្ចានំ ទ្វាទស លក្ខណានិ ទុក្ខសច្ចស្ស ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ ស-មុទយសច្ចស្ស ឧប្បាទោ បញ្ញាយតិ វយោ បញ្ញា-យតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ មគ្គសច្ចស្ស ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ ន និរោធសច្ចស្ស ឧប្បាទោ បញ្ញាយតិ ន វយោ បញ្ញាយតិ ន ឋិតស្ស អញ្ញថ-ត្តំ បញ្ញាយតិ សច្ចានំ ឥមានិ ទ្វាទស លក្ខណានិ ។

[២២] ចតុន្នំ សច្ចានំ កតិ កុសលា កតិ អកុសលា កតិ អព្យាកតា ។ សមុទ-យសច្ចំ អកុសលំ មគ្គសច្ចំ កុសលំ និរោធ-សច្ចំ អព្យាកតំ ទុក្ខសច្ចំ សិយា កុសលំ សិយា អកុសលំ សិយា អព្យាកតំ តីណិ សច្ចា-និ ឯកសច្ចេន សង្គហិតានិ ឯកំ សច្ចំ តីហិ សច្ចេហិ សង្គហិតំ វត្ថុវសេន បរិយាយេន ។

*លក្ខណៈរបស់សច្ចៈ មានប៉ុន្មាន ។ លក្ខណៈ របស់សច្ចៈ មាន ១២ គឺទុក្ខសច្ចៈ មានការកើតឡើងប្រាកដ ១ មានការសូន្យប្រាកដ ១ ទុក្ខសច្ច ដែលឋិតនៅ មានការប្រែប្រួលប្រាកដ ១ សមុទយសច្ច មានការកើតឡើងប្រាកដ ១ មានការសូន្យប្រាកដ ១ សមុទយសច្ច ដែលឋិតនៅ មានការប្រែប្រួលប្រាកដ ១ មគ្គសច្ច មានការកើតឡើងប្រាកដ ១ មានការសូន្យប្រាកដ ១ មគ្គសច្ច ដែលឋិតនៅ មានការប្រែប្រួលប្រាកដ ១ និរោធសច្ច មានការកើតឡើងមិនប្រាកដ ១ មានការសូន្យមិនប្រាកដ ១ មគ្គសច្ច ដែលឋិតនៅ មានការប្រែប្រួលមិនប្រាកដ ១ នេះលក្ខណៈ ១២ របស់សច្ចៈ ។*

[២២] *បណ្តាសច្ចៈទាំង ៤ សច្ចៈ ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹត ប៉ុន្មាន ។ សមុទយសច្ច ជាអកុសល មគ្គសច្ច ជាកុសល និរោធសច្ច ជាអព្យាក្រឹត ទុក្ខសច្ច ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន សច្ចៈ ៣ លោកសង្គ្រោះដោយសច្ចៈមួយ សច្ចៈមួយ លោកសង្គ្រោះ ដោយសច្ចៈ ៣ តាមបរិយាយដោយអំណាចនៃវត្ថុ ។*

សិយាតិ កថញ្ច សិយា ។ យំ ទុក្ខសច្ចំ អកុសលំ សមុទយសច្ចំ អកុសលំ ឯវំ អកុសលដ្ឋេន ទ្វេ សច្ចានិ ឯកសច្ចេន សង្គហិតានិ ឯកំ សច្ចំ ទ្វីហិ សច្ចេហិ សង្គហិតំ យំ ទុក្ខសច្ចំ កុសលំ មគ្គសច្ចំ កុសលំ ឯវំ កុសលដ្ឋេន ទ្វេ សច្ចានិ ឯកសច្ចេន សង្គហិតានិ ឯកំ សច្ចំ ទ្វីហិ សច្ចេហិ សង្គហិតំ យំ ទុក្ខសច្ចំ អព្យាកតំ និរោធសច្ចំ អព្យាកតំ ឯវំ អព្យាកតដ្ឋេន ទ្វេ សច្ចានិ ឯកសច្ចេន សង្គហិតានិ ឯកំ សច្ចំ ទ្វីហិ សច្ចេហិ សង្គហិតំ ឯវំ សិយា តីណិ សច្ចានិ ឯកសច្ចេន សង្គហិតានិ ឯកំ សច្ចំ តីហិ សច្ចេហិ សង្គហិតំ វត្ថុវសេន បរិយាយេនាតិ ។

[២៣] បុព្វេ មេ ភិក្ខវេ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ កោ នុ ខោ រូបស្ស អស្សាទោ កោ អាទីនវោ កឹ និស្សរណំ កោ វេទនាយ អស្សាទោ កោ អាទីនវោ កឹ និស្សរណំ កោ សញ្ញាយ អស្សាទោ កោ អាទីនវោ កឹ និស្សរណំ កោ សង្ខារានំ អស្សាទោ

សំណួរត្រង់ពាក្យថា ក៏មាន តើមានដូចម្ដេច ។ ចម្លើយថា ត្រង់ថា ទុក្ខសច្ច ជាអកុសល សមុទយសច្ច ជាអកុសល យ៉ាងនេះ ឈ្មោះថា សច្ចៈ ២ ដោយអត្ថថាអកុសល លោកសង្គ្រោះដោយសច្ចៈមួយ សច្ចៈមួយ លោកសង្គ្រោះដោយសច្ចៈពីរ ត្រង់ថា ទុក្ខសច្ច ជាកុសល មគ្គសច្ច ជាកុសល យ៉ាងនេះ ឈ្មោះថាសច្ចៈ ២ ដោយអត្ថថាជាកុសល លោកសង្គ្រោះដោយសច្ចៈមួយ សច្ចៈមួយលោកសង្គ្រោះដោយសច្ចៈពីរ ត្រង់ថា ទុក្ខសច្ច ជាអព្យាក្រឹត និរោធសច្ចៈ ជាអព្យាក្រឹត យ៉ាងនេះ ឈ្មោះថាសច្ចៈ ២ ដោយអត្ថថាជាអព្យាក្រឹត លោកសង្គ្រោះដោយសច្ចៈមួយ សច្ចៈមួយលោកសង្គ្រោះដោយសច្ចៈពីរ សច្ចៈ ៣ លោកសង្គ្រោះដោយសច្ចៈមួយ សច្ចៈមួយលោកសង្គ្រោះដោយសច្ចៈ ៣ តាមបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន យ៉ាងនេះឯង ។

[២៣] ម្នាលភិក្ខុទាំងឡាយ កាលតថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹង មុនអំពីការត្រាស់ដឹងនៅឡើយ មានសេចក្ដីត្រិះរិះថា រូប មានអានិសង្សដូចម្ដេច មានទោសដូចម្ដេច មានការរលាស់ចេញដូចម្ដេច វេទនា មានអានិសង្សដូចម្ដេច មានទោសដូចម្ដេច មានការរលាស់ចេញដូចម្ដេច សញ្ញា មានអានិសង្សដូចម្ដេច មានទោសដូចម្ដេច មានការរលាស់ចេញដូចម្ដេច សង្ខារទាំងឡាយ មានអានិសង្សដូចម្ដេច

កោ អាទីនវោ កឹ និស្សរណំ កោ វិញ្ញាណស្ស អស្សាទោ កោ អាទីនវោ កឹ និស្សរណន្តិ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ យំ ខោ រូបំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ រូបស្ស អស្សា-ទោ យំ រូបំ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អយំ រូបស្ស អាទីនវោ យោ រូបស្មឹ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ រូបស្ស និស្សរណំ យំ វេទនំ បដិច្ច យំ សញ្ញំ បដិច្ច យំ សង្ខារេ បដិច្ច យំ វិញ្ញាណំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ វិញ្ញាណស្ស អស្សាទោ យំ វិញ្ញាណំ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អយំ វិញ្ញាណស្ស អាទីនវោ យោ វិញ្ញាណស្មឹ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ វិញ្ញាណស្ស និស្សរណំ ។

[២៤] យាវកីវញ្ចាហំ ភិក្ខវេ ឥមេសំ បញ្ចន្នំ ឧបា-ទានក្ខន្ធានំ ឯវំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ អព្ភញ្ញាសឹ នេវតាវាហំ ភិក្ខវេ សទេវកេ លោកេ

មានទោសដូចម្ដេច មានការរលាស់ចេញដូចម្ដេច វិញ្ញាណ មានអានិសង្សដូចម្ដេច មានទោស ដូចម្ដេច មានការរលាស់ចេញ ដូចម្ដេច ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្ដីត្រិះរិះដូច្នេះថា សុខ សោមនស្សកើតឡើង ព្រោះអាស្រ័យរូប នេះជាអានិសង្សរបស់រូប រូប មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា នេះជាទោសរបស់រូប ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគ ឯណា ក្នុងរូប នេះជាការ រលាស់ចេញនូវរូប សុខ សោមនស្សកើតឡើង ព្រោះអាស្រ័យវេទនា ព្រោះអាស្រ័យសញ្ញា ព្រោះអាស្រ័យសង្ខារទាំងឡាយ ព្រោះអាស្រ័យវិញ្ញាណ នេះ ជាអានិសង្សរបស់វិញ្ញាណ វិញ្ញាណ មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា នេះ ជាទោសរបស់វិញ្ញាណ ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគ ឯណា ក្នុងវិញ្ញាណ នេះ ជាការរលាស់ចេញ នូវវិញ្ញាណ ។

[២៤] ម្នាលភិក្ខុទាំងឡាយ តថាគត មិនទាន់ដឹងច្បាស់តាមពិត នូវអានិសង្ស ថាជាអានិសង្សផង នូវទោស ថាជាទោសផង នូវការរលាស់ចេញ ថាជាការរលាស់ចេញផង របស់ឧបាទានក្ខន្ធទាំង៥ នេះ យ៉ាងនេះ ដរាបណា ម្នាលភិក្ខុទាំងឡាយ ដរាបនោះ តថាគតក៏មិនទាន់ប្ដេជ្ញាថាជា អ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោកព្រមទាំងទេវលោក

សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ យតោ ច ខ្វាហំ ភិក្ខវេ ឥមេសំ បញ្ចន្នំ ឧបាទានក្ខន្ធានំ ឯវំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ អព្ភញ្ញាសឹ អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ ស-ស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ ចេតោវិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។

[២៨] យំ រូបំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ រូបស្ស អស្សាទោតិ បហានប្បដិវេធោ សមុ-ទយសច្ចំ យំ រូបំ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អ-យំ រូបស្ស អាទីនវោតិ បរិញ្ញាបដិវេធោ ទុក្ខសច្ចំ

មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ម្នាលភិក្ខុទាំងឡាយ លុះតែកាលណា តថាគត បានដឹងច្បាស់តាមពិត នូវអានិសង្ស ថាជាអានិសង្សផង នូវទោស ថាជាទោសផង នូវការរលាស់ចេញ ថាជាការរលាស់ចេញផង របស់ឧបាទានក្ខន្ធ ៥ នេះ យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលណោះ តថាគតទើបប្តេជ្ញាថាជាអ្នកត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស មួយទៀត ញាណជាគ្រឿងឃើញ កើតហើយដល់តថាគតថា ចេតោវិមុត្តិរបស់តថាគត មិនកម្រើកទេ នេះជាជាតិ ទីបំផុត ឥឡូវនេះ ភពថ្មី មិនមានឡើយ ។

[២៥] ការត្រាស់ដឹង ដោយអំណាច នៃការលះថា សុខសោមនស្ស កើតឡើង ព្រោះអាស្រ័យរូប នេះ ជាអានិសង្សរបស់រូប ដូច្នេះ ឈ្មោះថាសមុទយសច្ច ការត្រាស់ដឹង ដោយអំណាចនៃការកំណត់ដឹងថា រូបមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះ ជាទោសរបស់រូប ដូច្នេះ ឈ្មោះថា ទុក្ខសច្ច

យោ រូបស្មឹ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ រូបស្ស និស្សរណន្តិ សច្ចិកិរិយាបដិវេធោ និរោធ-សច្ចំ យា ឥមេសុ តីសុ ឋានេសុ ទិដ្ឋិ សង្កប្បោ វាចា កម្មន្តោ អាជីវោ វាយាមោ សតិ សមាធិ ភាវនាបដិវេធោ មគ្គសច្ចំ យំ វេទនំ បដិច្ច យំ សញ្ញំ បដិច្ច យំ សង្ខារេ បដិច្ច យំ វិញ្ញាណំ បដិច្ច ឧប្ប-ជ្ជតិ សុខំ សោមនស្សំ អយំ វិញ្ញាណស្ស អស្សា-ទោតិ បហានប្បដិវេធោ សមុទយសច្ចំ យំ វិញ្ញាណំ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អយំ វិញ្ញាណស្ស អាទី-នវោតិ បរិញ្ញាបដិវេធោ ទុក្ខសច្ចំ យោ វិញ្ញាណស្មឹ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ វិញ្ញាណស្ស និស្ស-រណន្តិ សច្ចិកិរិយាបដិវេធោ និរោធសច្ចំ យា ឥមេសុ តីសុ ឋានេសុ ទិដ្ឋិ សង្កប្បោ វាចា កម្មន្តោ អាជីវោ វាយាមោ សតិ សមាធិ ភាវនាបដិវេធោ មគ្គសច្ចន្តិ ។

[២៦] កតិហាការេហិ[១] សច្ចំ ។ តីហាការេហិ សច្ចំ ឯសនដ្ឋេន បរិគ្គហដ្ឋេន បដិវេធដ្ឋេន ។

---

១ ឱ. ម. សច្ចន្តិ កតីហាការេហិ សច្ចន្តិ ទិស្សន្តិ ។

ការត្រាស់ដឹង ដោយអំណាចនៃការធ្វើឲ្យជាក់ច្បាស់ថា ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគ ឯណា ក្នុងរូប នេះជាការរលាស់ចេញនូវរូប ដូច្នេះ ឈ្មោះថានិរោធសច្ច ការត្រាស់ដឹងដោយអំណាចនៃការអប់រំ គឺ ទិដ្ឋិ សង្កប្ប: វាចា កម្មន្ត: អាជីវ: វាយាម: សតិ សមាធិ ក្នុងឋាន: ទាំង ៣ នេះ ឈ្មោះថាមគ្គសច្ច ការត្រាស់ដឹងដោយអំណាចនៃការលះថា សុខ សោមនស្សកើតឡើង ព្រោះអាស្រ័យវេទនា ព្រោះអាស្រ័យសញ្ញា ព្រោះអាស្រ័យសង្ខារទាំងឡាយ ព្រោះអាស្រ័យវិញ្ញាណ នេះជាអានិសង្សរបស់វិញ្ញាណ ដូច្នេះ ឈ្មោះថាសមុទយសច្ច ការត្រាស់ដឹងដោយអំណាច នៃការកំណត់ដឹងថា វិញ្ញាណ មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះ ជាទោសរបស់វិញ្ញាណ ដូច្នេះ ឈ្មោះថាទុក្ខសច្ច ការត្រាស់ដឹងដោយអំណាច នៃការធ្វើឲ្យជាក់ច្បាស់ថា ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគ ឯណា ក្នុងវិញ្ញាណ នេះជាការរលាស់ចេញ នូវវិញ្ញាណ ដូច្នេះ ឈ្មោះថានិរោធសច្ច ការត្រាស់ដឹងដោយអំណាចនៃការអប់រំ គឺ ទិដ្ឋិ សង្កប្ប: វាចា កម្មន្ត: អាជីវ: វាយាម: សតិ សមាធិ ក្នុងឋាន: ៣ នេះ ឈ្មោះថាមគ្គសច្ច ។

[២៦] សច្ច: ដោយអាការប៉ុន្មានយ៉ាង ។ សច្ច: ដោយអាការ៣ យ៉ាងគឺ ដោយអត្ថថាស្វែងរក១ ដោយអត្ថថាចំណាំទុក១ ដោយអត្ថថាត្រាស់ដឹង១។

កថំ ឯសនដ្ឋេន សច្ចំ ។ ជរាមរណំ កឹនិទានំ កឹសមុទយំ កឹជាតិកំ កឹបភវន្តិ ឯវំ ឯសនដ្ឋេន សច្ចំ ជរាមរណំ ជាតិនិទានំ ជាតិសមុទយំ ជាតិជាតិកំ ជាតិប្បភវន្តិ ឯវំ បរិគ្គហដ្ឋេន សច្ចំ ជរាមរណញ្ច បជានាតិ ជរាមរណសមុទយញ្ច បជានាតិ ជរាមរណនិរោធញ្ច បជានាតិ ជរាមរណនិរោធគាមិនីបដិបទញ្ច បជានាតិ ឯវំ បដិវេធដ្ឋេន សច្ចំ ។

ជាតិ កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវាតិ ឯវំ ឯសនដ្ឋេន សច្ចំ ជាតិ ភវនិទានា ភវសមុទយា ភវជាតិកា ភវប្បភវាតិ ឯវំ បរិគ្គហដ្ឋេន សច្ចំ ជាតិញ្ច បជានាតិ ជាតិសមុទយញ្ច បជានាតិ ជាតិនិរោធញ្ច បជានាតិ ជាតិនិរោធគាមិនីបដិបទញ្ច បជានាតិ ឯវំ បដិវេធដ្ឋេន សច្ចំ ។

សច្ចៈ ដោយអត្ថថាស្វែងរក តើដូចម្ដេច ។ ជរាមរណៈ មានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះឈ្មោះថាសច្ចៈ ដោយអត្ថថាស្វែងរក ជរាមរណៈ មានជាតិជាហេតុ មានជាតិជាទីប្រជុំកើត មានជាតិជាកំណើត មានជាតិជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាចំណាំទុក បុគ្គលដឹងច្បាស់នូវជរាមរណៈផង ដឹងច្បាស់នូវទីប្រជុំកើតនៃជរាមរណៈផង ដឹងច្បាស់នូវការរលត់នៃជរាមរណៈផង ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ការរលត់នៃជរាមរណៈផង យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាត្រាស់ដឹង ។

ជាតិ មានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាស្វែងរក ជាតិ មានភពជាហេតុ មានភពជាទីប្រជុំកើត មានភពជាកំណើត មានភពជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាចំណាំទុក បុគ្គលដឹងច្បាស់នូវជាតិផង ដឹងច្បាស់នូវទីប្រជុំកើត នៃជាតិផង ដឹងច្បាស់នូវការរលត់នៃជាតិផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់នៃជាតិផង យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាត្រាស់ដឹង ។

៤៧

យុគនទ្ធវគ្គេ សច្ចកថា

ភវោ កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោតិ ឯវំ ឯសនដ្ឋេន សច្ចំ ភវោ ឧបាទាននិទានោ ឧបាទានសមុទយោ ឧបាទានជាតិកោ ឧបាទានប្បភវោតិ ឯវំ បរិគ្គហដ្ឋេន សច្ចំ ភវញ្ច បជានាតិ ភវសមុទយញ្ច បជានាតិ ភវនិរោធញ្ច បជានាតិ ភវនិរោធគាមិនីបដិបទញ្ច បជានាតិ ឯវំ បដិវេធដ្ឋេន សច្ចំ ។

ឧបាទានំ កឹនិទានំ កឹសមុទយំ កឹជាតិកំ កឹបភវន្តិ ឯវំ ឯសនដ្ឋេន សច្ចំ ឧបាទានំ តណ្ហានិទានំ តណ្ហាសមុទយំ តណ្ហាជាតិកំ តណ្ហាបភវន្តិ ឯវំ បរិគ្គហដ្ឋេន សច្ចំ ឧបាទានញ្ច បជានាតិ ឧបាទានសមុទយញ្ច បជានាតិ ឧបាទាននិរោធញ្ច បជានាតិ ឧបាទាននិរោធគាមិនីបដិបទញ្ច បជានាតិ ឯវំ បដិវេធដ្ឋេន សច្ចំ ។

យុគនទ្ធវគ្គ សច្ចកថា

ភព មានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាស្វែងរក ភពមានឧបាទានជាហេតុ មានឧបាទានជាទីប្រជុំកើត មានឧបាទានជាកំណើត មានឧបាទានជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាចំណាំទុក បុគ្គលដឹងច្បាស់នូវភពផង ដឹងច្បាស់នូវទីប្រជុំកើតនៃភពផង ដឹងច្បាស់នូវការរលត់នៃភពផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់នៃភពផង យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាត្រាស់ដឹង ។

ឧបាទាន មានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាស្វែងរក ឧបាទាន មានតណ្ហាជាហេតុ មានតណ្ហាជាទីប្រជុំកើត មានតណ្ហាជាកំណើត មានតណ្ហាជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាចំណាំទុក បុគ្គលដឹងច្បាស់នូវឧបាទានផង ដឹងច្បាស់នូវទីប្រជុំកើតនៃឧបាទានផង ដឹងច្បាស់នូវការរលត់នៃឧបាទានផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់ នៃឧបាទានផង យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាត្រាស់ដឹង ។

តណ្ហា កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវាតិ ឯវំ ឯសនដ្ឋេន សច្ចំ តណ្ហា វេទនានិទានា វេទនាសមុទយា វេទនាជាតិកា វេទនាបភវាតិ ឯវំ បរិគ្គហដ្ឋេន សច្ចំ តណ្ហាញ្ច បជានាតិ តណ្ហាសមុទយញ្ច បជានាតិ តណ្ហានិរោធញ្ច បជានាតិ តណ្ហានិរោធគាមិនីបដិបទញ្ច បជានាតិ ឯវំ បដិវេធដ្ឋេន សច្ចំ ។

វេទនា កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវាតិ ឯវំ ឯសនដ្ឋេន សច្ចំ វេទនា ផស្សនិទានា ផស្សសមុទយា ផស្សជាតិកា ផស្សប្បភវាតិ ឯវំ បរិគ្គហដ្ឋេន សច្ចំ វេទនញ្ច បជានាតិ វេទនាសមុទយញ្ច បជានាតិ វេទនានិរោធញ្ច បជានាតិ វេទនានិរោធគាមិនីបដិបទញ្ច បជានាតិ ឯវំ បដិវេធដ្ឋេន សច្ចំ ។

តណ្ហា មានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាស្វែងរក តណ្ហាមានវេទនាជាហេតុ មានវេទនាជាទីប្រជុំកើត មានវេទនាជាកំណើត មានវេទនាជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាចំណាំទុក បុគ្គលដឹងច្បាស់នូវតណ្ហាផង ដឹងច្បាស់នូវទីប្រជុំកើតនៃតណ្ហាផង ដឹងច្បាស់នូវការរលត់នៃតណ្ហាផង ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ការរលត់ នៃតណ្ហាផង យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាត្រាស់ដឹង ។

វេទនា មានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាស្វែងរក វេទនាមានផស្សៈជាហេតុ មានផស្សៈជាទីប្រជុំកើត មានផស្សៈជាកំណើត មានផស្សៈជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាចំណាំទុក បុគ្គលដឹងច្បាស់នូវវេទនាផង ដឹងច្បាស់នូវទីប្រជុំកើតនៃវេទនាផង ដឹងច្បាស់នូវការរលត់នៃវេទនាផង ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ការរលត់នៃវេទនាផង យ៉ាងនេះឈ្មោះថាសច្ចៈ ដោយអត្ថថាត្រាស់ដឹង។

៤៩

## យុគនទ្ធវគ្គេ សច្ចកថា

ផស្សោ កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោតិ ឯវំ ឯសនដ្ឋេន សច្ចំ ផស្សោ សឡាយតននិទានោ សឡាយតនសមុទយោ សឡាយតនជាតិកោ សឡាយតនប្បភវោតិ ឯវំ បរិគ្គហដ្ឋេន សច្ចំ ផស្សញ្ច បជានាតិ ផស្សសមុទយញ្ច បជានាតិ ផស្សនិរោធញ្ច បជានាតិ ផស្សនិរោធគាមិនីបដិបទញ្ច បជានាតិ ឯវំ បដិវេធដ្ឋេន សច្ចំ ។

សឡាយតនំ កឹនិទានំ កឹសមុទយំ កឹជាតិកំ កឹបភវន្តិ ឯវំ ឯសនដ្ឋេន សច្ចំ សឡាយតនំ នាមរូបនិទានំ នាមរូបសមុទយំ នាមរូបជាតិកំ នាមរូបប្បភវន្តិ ឯវំ បរិគ្គហដ្ឋេន សច្ចំ សឡាយតនញ្ច បជានាតិ សឡាយតនសមុទយញ្ច បជានាតិ សឡាយតននិរោធញ្ច បជានាតិ សឡាយតននិរោធគាមិនីបដិបទញ្ច បជានាតិ ឯវំ បដិវេធដ្ឋេន សច្ចំ ។

យុគនទ្ធវគ្គ សច្ចកថា

ផស្សៈ មានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាស្វែងរក ផស្សៈ មានសឡាយតនៈជាហេតុ មានសឡាយតនៈជាទីប្រជុំកើត មានសឡាយតនៈជាកំណើត មានសឡាយតនៈជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាចំណាំទុក បុគ្គលដឹងច្បាស់នូវផស្សៈផង ដឹងច្បាស់នូវទីប្រជុំកើតនៃផស្សៈផង ដឹងច្បាស់នូវការរលត់ នៃផស្សៈផង ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ការរលត់ នៃផស្សៈផង យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាត្រាស់ដឹង ។

សឡាយតនៈ មានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាស្វែងរក សឡាយតនៈ មាននាមរូបជាហេតុ មាននាមរូបជាទីប្រជុំកើត មាននាមរូបជាកំណើត មាននាមរូបជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាចំណាំទុក បុគ្គលដឹងច្បាស់នូវសឡាយតនៈផង ដឹងច្បាស់នូវទីប្រជុំកើត នៃសឡាយតនៈផង ដឹងច្បាស់នូវការរលត់ នៃសឡាយតនៈផង ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ការរលត់ នៃសឡាយតនៈផង យ៉ាងនេះឈ្មោះថាសច្ចៈ ដោយអត្ថថាត្រាស់ដឹង ។

នាមរូបំ កឹនិទានំ កឹសមុទយំ កឹជាតិកំ កឹបភវន្តិ ឯវំ ឯសនដ្ឋេន សច្ចំ នាមរូបំ វិញ្ញាណនិទានំ វិញ្ញាណសមុទយំ វិញ្ញាណជាតិកំ វិញ្ញាណប្បភវន្តិ ឯវំ បរិគ្គហដ្ឋេន សច្ចំ នាមរូបញ្ច បជានាតិ នាមរូបសមុទយញ្ច បជានាតិ នាមរូបនិរោធញ្ច បជានាតិ នាមរូបនិរោធគាមិនីបដិបទញ្ច បជានាតិ ឯវំ បដិវេធដ្ឋេន សច្ចំ ។

វិញ្ញាណំ កឹនិទានំ កឹសមុទយំ កឹជាតិកំ កឹបភវន្តិ ឯវំ ឯសនដ្ឋេន សច្ចំ វិញ្ញាណំ សង្ខារនិទានំ សង្ខារសមុទយំ សង្ខារជាតិកំ សង្ខារប្បភវន្តិ ឯវំ បរិគ្គហដ្ឋេន សច្ចំ វិញ្ញាណញ្ច បជានាតិ វិញ្ញាណសមុទយញ្ច បជានាតិ វិញ្ញាណនិរោធញ្ច បជានាតិ វិញ្ញាណនិរោធគាមិនីបដិបទញ្ច បជានាតិ ឯវំ បដិវេធដ្ឋេន សច្ចំ ។

នាមរូប មានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាស្វែងរក នាមរូប មានវិញ្ញាណជាហេតុ មានវិញ្ញាណជាទីប្រជុំកើត មានវិញ្ញាណជាកំណើត មានវិញ្ញាណជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាចំណាំទុក បុគ្គលដឹងច្បាស់នូវនាមរូបផង ដឹងច្បាស់នូវទីប្រជុំកើតនៃនាមរូបផង ដឹងច្បាស់នូវការរលត់នៃនាមរូបផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់ នៃនាមរូបផង យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាត្រាស់ដឹង ។

វិញ្ញាណ មានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាស្វែងរក វិញ្ញាណ មានសង្ខារជាហេតុ មានសង្ខារជាទីប្រជុំកើត មានសង្ខារជាកំណើត មានសង្ខារជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាចំណាំទុក បុគ្គលដឹងច្បាស់នូវវិញ្ញាណផង ដឹងច្បាស់នូវទីប្រជុំកើតនៃវិញ្ញាណផង ដឹងច្បាស់នូវការរលត់នៃវិញ្ញាណផង ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ការរលត់នៃវិញ្ញាណផង យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាត្រាស់ដឹង ។

## យុគនទ្ធវគ្គ សច្ចកថា

សង្ខារា កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវាតិ ឯវំ ឯសនដ្ឋេន សច្ចំ សង្ខារា អវិជ្ជានិទានា អវិជ្ជាសមុទយា អវិជ្ជាជាតិកា អវិជ្ជាបភវាតិ ឯវំ បរិគ្គហដ្ឋេន សច្ចំ សង្ខារេ ច បជានាតិ សង្ខារសមុទយញ្ច បជានាតិ សង្ខារនិរោធញ្ច បជានាតិ សង្ខារនិរោធគាមិនីបដិបទញ្ច បជានាតិ ឯវំ បដិវេធដ្ឋេន សច្ចំ ។

[២៧] ជរាមរណំ ទុក្ខសច្ចំ ជាតិ សមុទយសច្ចំ ឧភិន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជាននា មគ្គសច្ចំ ជាតិ ទុក្ខសច្ចំ ភវោ សមុទយសច្ចំ ឧភិន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជាននា មគ្គសច្ចំ ភវោ ទុក្ខសច្ចំ ឧបាទានំ សមុទយសច្ចំ ឧភិន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជាននា មគ្គសច្ចំ ឧបាទានំ ទុក្ខសច្ចំ តណ្ហា សមុទយសច្ចំ ឧភិន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជាននា មគ្គសច្ចំ តណ្ហា ទុក្ខសច្ចំ វេទនា សមុទយសច្ចំ ឧភិន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជាននា មគ្គសច្ចំ

សង្ខារ មានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាស្វែងរក សង្ខារ មានអវិជ្ជាជាហេតុ មានអវិជ្ជាជាទីប្រជុំកើត មានអវិជ្ជាជាកំណើត មានអវិជ្ជាជាដែនកើត យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថថាចំណាំទុក បុគ្គលដឹងច្បាស់នូវសង្ខារទាំងឡាយផង ដឹងច្បាស់នូវទីប្រជុំកើតនៃសង្ខារផង ដឹងច្បាស់នូវការរលត់នៃសង្ខារផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់នៃសង្ខារផង យ៉ាងនេះ ឈ្មោះថាសច្ចៈ ដោយអត្ថជាត្រាស់ដឹង ។

[២៧] ជរាមរណៈ ជាទុក្ខសច្ច ជាតិជាសមុទយសច្ច ការរលាស់ចេញ នូវជរាមរណៈនិងជាតិទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធ ជាមគ្គសច្ច ជាតិជាទុក្ខសច្ច ភពជាសមុទយសច្ច ការរលាស់ចេញនូវជាតិនិងភពទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធជាមគ្គសច្ច ភពជាទុក្ខសច្ច ឧបាទានជាសមុទយសច្ច ការរលាស់ចេញនូវភពនិងឧបាទានទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធ ជាមគ្គ-សច្ច ឧបាទានជាទុក្ខសច្ច តណ្ហាជាសមុទយសច្ច ការរលាស់ចេញនូវឧបាទាននិងតណ្ហាទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធ ជាមគ្គ-សច្ច តណ្ហាជាទុក្ខសច្ច វេទនាជាសមុទយសច្ច ការរលាស់ចេញនូវតណ្ហានិងវេទនាទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធ ជាមគ្គសច្ច

វេទនា ទុក្ខសច្ចំ ផស្សោ សមុទយសច្ចំ ឧភិន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជាននា មគ្គសច្ចំ ផស្សោ ទុក្ខសច្ចំ សឡាយតនំ សមុទយសច្ចំ ឧភិ-ន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជាននា មគ្គសច្ចំ សឡាយតនំ ទុក្ខសច្ចំ នាមរូបំ សមុទយសច្ចំ ឧ-ភិន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជាននា មគ្គសច្ចំ នាមរូបំ ទុក្ខសច្ចំ វិញ្ញាណំ សមុទយ-សច្ចំ ឧភិន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជា-ននា មគ្គសច្ចំ វិញ្ញាណំ ទុក្ខសច្ចំ សង្ខារា សមុទយសច្ចំ ឧភិន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជាននា មគ្គសច្ចំ សង្ខារា ទុក្ខសច្ចំ អវិ-ជ្ជា សមុទយសច្ចំ ឧភិន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជាននា មគ្គសច្ចំ ។ ជរាមរណំ ទុក្ខសច្ចំ

វេទនាជាទុក្ខសច្ច ផស្សៈជាសមុទយសច្ច ការរលាស់ចេញនូវវេទនានិង ផស្សៈទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធ ជាមគ្គសច្ច ផស្សៈ ជាទុក្ខសច្ច សឡាយតនៈជាសមុទយសច្ច ការរលាស់ចេញនូវផស្សៈនិង សឡាយតនៈទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធ ជាមគ្គសច្ច សឡាយតនៈ ជាទុក្ខសច្ច នាមរូបជាសមុទយសច្ច ការរលាស់ចេញ នូវសឡាយតនៈនិងនាមរូបទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវ និរោធ ជាមគ្គសច្ច នាមរូបជាទុក្ខសច្ច វិញ្ញាណជាសមុទយសច្ច ការ រលាស់ចេញនូវនាមរូបនិងវិញ្ញាណទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់ នូវនិរោធ ជាមគ្គសច្ច វិញ្ញាណជាទុក្ខសច្ច សង្ខារជាសមុទយសច្ច ការរលាស់ចេញនូវវិញ្ញាណនិងសង្ខារទាំងពីរ ជានិរោធសច្ច ឯការដឹង ច្បាស់នូវនិរោធ ជាមគ្គសច្ច សង្ខារទាំងឡាយជាទុក្ខសច្ច អវិជ្ជាជា សមុទយសច្ច ការរលាស់ចេញនូវសង្ខារនិងអវិជ្ជាទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធ ជាមគ្គសច្ច ។ ជរាមរណៈ ជាទុក្ខសច្ច

៦៣

យុគនទ្ធវគ្គេ សច្ចកថា

ជាតិ សិយា ទុក្ខសច្ចំ សិយា សមុទយសច្ចំ ឧភិ-ន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជានដា មគ្គសច្ចំ ជាតិ ទុក្ខសច្ចំ ភវោ សិយា ទុក្ខសច្ចំ សិយា សមុទយសច្ចំ ឧភិន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជានដា មគ្គសច្ចំ ។ បេ ។ សង្ខារា ទុក្ខសច្ចំ អវិជ្ជា សិយា ទុក្ខសច្ចំ សិយា សមុទយសច្ចំ ឧភិន្នំបិ និស្សរណំ និរោធសច្ចំ និរោធប្បជានដា មគ្គសច្ចន្តិ ។

សច្ចកថា ។

ភាណវារំ ។

---

យុគនទ្ធវគ្គ សច្ចកថា

ជាតិ ជាទុក្ខសច្ចក៏មាន ជាសមុទយសច្ចក៏មាន ការរលាស់ចេញនូវជរាមរណៈនិងជាតិទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធ ជាមគ្គសច្ច ជាតិ ជាទុក្ខសច្ច ភពជាទុក្ខសច្ចក៏មាន ជាសមុទយសច្ចក៏មាន ការរលាស់ចេញនូវជាតិនិងភពទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធ ជាមគ្គសច្ច ។ បេ ។ សង្ខារទាំងឡាយ ជាទុក្ខសច្ច អវិជ្ជាជាទុក្ខសច្ចក៏មាន ជាសមុទយសច្ចក៏មាន ការរលាស់ចេញនូវសង្ខារនិងអវិជ្ជាទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធ ជាមគ្គសច្ច ។

ចប់ សច្ចកថា ។

ចប់ ភាណវារៈ ។

---

# យុគនទ្ធវគ្គេ ពោជ្ឈង្គកថា

## សាវត្ថិនិទានំ

[២៨] សត្តិមេ ភិក្ខវេ ពោជ្ឈង្គា កតមេ សត្ត សតិសម្ពោជ្ឈង្គោ ធម្មវិចយសម្ពោជ្ឈង្គោ វីរិយសម្ពោជ្ឈង្គោ បីតិសម្ពោជ្ឈង្គោ បស្សទ្ធិសម្ពោជ្ឈង្គោ សមាធិសម្ពោជ្ឈង្គោ ឧបេក្ខាសម្ពោជ្ឈង្គោ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ។

ពោជ្ឈង្គាតិ កេនដ្ឋេន ពោជ្ឈង្គា ។ ពោធិយំ[១] សំវត្តន្តីតិ ពោជ្ឈង្គា ពុជ្ឈន្តីតិ ពោជ្ឈង្គា អនុពុជ្ឈន្តីតិ ពោជ្ឈង្គា បដិពុជ្ឈន្តីតិ ពោជ្ឈង្គា សម្ពុជ្ឈន្តីតិ ពោជ្ឈង្គា ពុជ្ឈនដ្ឋេន ពោជ្ឈង្គា អនុពុជ្ឈនដ្ឋេន ពោជ្ឈង្គា បដិពុជ្ឈនដ្ឋេន ពោជ្ឈង្គា សម្ពុជ្ឈនដ្ឋេន ពោជ្ឈង្គា ពោធេន្តីតិ ពោជ្ឈង្គា អនុពោធេន្តីតិ ពោជ្ឈង្គា បដិពោធេន្តីតិ ពោជ្ឈង្គា សម្ពោធេន្តីតិ ពោជ្ឈង្គា ពោធនដ្ឋេន ពោជ្ឈង្គា អនុពោធនដ្ឋេន ពោជ្ឈង្គា បដិពោធនដ្ឋេន

១ ឱ. ម. ពោធាយាតិ បាឋោ ។

# យុគនទ្ធវគ្គ ពោជ្ឈង្គកថា

## សាវត្ថិនិទាន

[២៨] ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គនេះ មាន ៧ ពោជ្ឈង្គ ៧ តើដូចម្តេច សតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខា-សម្ពោជ្ឈង្គ ១ ម្នាលភិក្ខុទាំងឡាយ នេះឯង ពោជ្ឈង្គ ៧ ។

សំណួរត្រង់ពាក្យថា ពោជ្ឈង្គ តើពោជ្ឈង្គ ដោយអត្ថថាដូចម្តេច ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុប្រព្រឹត្តទៅព្រមក្នុងការត្រាស់ដឹង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងតាម ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងចំពោះ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងព្រម ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថាត្រាស់ដឹង ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាត្រាស់ដឹងតាម ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាត្រាស់ដឹងចំពោះ ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាត្រាស់ដឹងព្រម ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុញុំាងជនឲ្យត្រាស់ដឹង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុញុំាងជនឲ្យត្រាស់ដឹងតាម ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុញុំាងជនឲ្យត្រាស់ដឹងចំពោះ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុញុំាងជនឲ្យត្រាស់ដឹងព្រម ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាញុំាងជនឲ្យត្រាស់ដឹង ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាញុំាងជនឲ្យត្រាស់ដឹងតាម ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាញុំាងជនឲ្យត្រាស់ដឹងចំពោះ

ពោជ្ឈង្គា សម្ពោធដ្ឋេន ពោជ្ឈង្គា ពោធិបក្ខិយដ្ឋេន ពោជ្ឈង្គា អនុពោធិបក្ខិយដ្ឋេន ពោជ្ឈង្គា បដិពោធិបក្ខិយដ្ឋេន ពោជ្ឈង្គា សម្ពោធិបក្ខិយដ្ឋេន ពោជ្ឈង្គា ពុទ្ធិប្បដិលាភដ្ឋេន(១) ពោជ្ឈង្គា ពុទ្ធិរោបនដ្ឋេន ពោជ្ឈង្គា ពុទ្ធិអភិរោបនដ្ឋេន ពោជ្ឈង្គា ពុទ្ធិបាបនដ្ឋេន ពោជ្ឈង្គា ពុទ្ធិសម្បាបនដ្ឋេន ពោជ្ឈង្គា ។

[២៩] មូលដ្ឋេន ពោជ្ឈង្គា មូលចរិយដ្ឋេន ពោជ្ឈង្គា មូលបរិគ្គហដ្ឋេន ពោជ្ឈង្គា មូលបរិវារដ្ឋេន ពោជ្ឈង្គា(២) មូលបរិបូរដ្ឋេន ពោជ្ឈង្គា មូលបរិបាកដ្ឋេន ពោជ្ឈង្គា មូលប្បដិសម្ភិទដ្ឋេន ពោជ្ឈង្គា មូលប្បដិសម្ភិទាបាបនដ្ឋេន ពោជ្ឈង្គា មូលប្បដិសម្ភិទាយ វសីភាវដ្ឋេន ពោជ្ឈង្គា មូលប្បដិសម្ភិទាយ វសីភាវប្បត្តានម្បិ ពោជ្ឈង្គា ហេតដ្ឋេន ពោជ្ឈង្គា ហេតុចរិយដ្ឋេន ពោជ្ឈង្គា ហេតុបរិគ្គហដ្ឋេន

---

១ ម. ឯត្ថន្តរេ ពុទ្ធិលភនដ្ឋេន ពោជ្ឈង្គាតិ ទិស្សន្តិ ។ ២ ម. ឯត្ថន្តរេ មូលហេតុដ្ឋេន ពោជ្ឈង្គាតិ ទិស្សន្តិ ។

ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាញ៉ាំងជនឲ្យត្រាស់ដឹងព្រម ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាប្រព្រឹត្តទៅក្នុងចំណែកនៃការត្រាស់ដឹង ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាប្រព្រឹត្តទៅក្នុងចំណែកនៃការត្រាស់ដឹងតាម ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាប្រព្រឹត្តទៅ ក្នុងចំណែកនៃការត្រាស់ដឹងចំពោះ ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាប្រព្រឹត្តទៅ ក្នុងចំណែកនៃការត្រាស់ដឹងព្រម ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាការបានចំពោះនូវប្រាជ្ញា ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាបណ្តុះនូវប្រាជ្ញា ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាបណ្តុះចំពោះនូវប្រាជ្ញា ឈ្មោះថាពោជ្ឈង្គដោយអត្ថថាញ៉ាំងជនឲ្យដល់នូវប្រាជ្ញា ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាញ៉ាំងជនឲ្យដល់ព្រមនូវប្រាជ្ញា ។

[២៩] ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថាជាមូល ពោជ្ឈង្គ ដោយអត្ថថាទំនុកបម្រុងមូល ពោជ្ឈង្គ ដោយអត្ថថាថែទាំមូល ពោជ្ឈង្គ ដោយអត្ថថាចោមរោមមូល ពោជ្ឈង្គ ដោយអត្ថថាបំពេញមូល ពោជ្ឈង្គ ដោយអត្ថថាធ្វើមូលឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថាធ្វើមូលឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថាញ៉ាំងជនឲ្យដល់នូវមូលប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាចម្រើននូវវសីក្នុងមូលប្បដិសម្ភិទា ពោជ្ឈង្គ របស់ជនអ្នកសម្រេចនូវវសីភាពក្នុងមូលប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាជាហេតុ ពោ-ជ្ឈង្គ ដោយអត្ថថាទំនុកបម្រុងហេតុ ពោជ្ឈង្គ ដោយអត្ថថាថែទាំហេតុ

ពោជ្ឈង្គា ហេតុបរិវារដ្ឋេន ពោជ្ឈង្គា ហេតុបរិបូរដ្ឋេន ពោជ្ឈង្គា ហេតុបរិបាកដ្ឋេន ពោជ្ឈង្គា ហេតុប្បដិសម្ភិទដ្ឋេន ពោជ្ឈង្គា ហេតុប្បដិសម្ភិទាបាបនដ្ឋេន ពោជ្ឈង្គា ហេតុប្បដិសម្ភិទាយ វសីភាវដ្ឋេន ពោជ្ឈង្គា ហេតុប្បដិសម្ភិទាយ វសីភាវប្បត្តានម្បិ ពោជ្ឈង្គា បច្ចយដ្ឋេន ពោជ្ឈង្គា បច្ចយចរិយដ្ឋេន ពោជ្ឈង្គា បច្ចយបរិគ្គហដ្ឋេន ពោជ្ឈង្គា បច្ចយបរិវារដ្ឋេន ពោជ្ឈង្គា បច្ចយបរិបូរដ្ឋេន ពោជ្ឈង្គា បច្ចយបរិបាកដ្ឋេន ពោជ្ឈង្គា បច្ចយប្បដិសម្ភិទដ្ឋេន ពោជ្ឈង្គា បច្ចយប្បដិសម្ភិទាបាបនដ្ឋេន ពោជ្ឈង្គា បច្ចយប្បដិសម្ភិទាយ វសីភាវដ្ឋេន ពោជ្ឈង្គា បច្ចយប្បដិសម្ភិទាយ វសីភាវប្បត្តានម្បិ ពោជ្ឈង្គា វិសុទ្ធដ្ឋេន ពោជ្ឈង្គា វិសុទ្ធិចរិយដ្ឋេន ពោជ្ឈង្គា វិសុទ្ធិបរិគ្គហដ្ឋេន ពោជ្ឈង្គា វិសុទ្ធិបរិវារដ្ឋេន ពោជ្ឈង្គា វិសុទ្ធិបរិបូរដ្ឋេន ពោជ្ឈង្គា វិសុទ្ធិបរិបាកដ្ឋេន ពោជ្ឈង្គា វិសុទ្ធិប្បដិសម្ភិទដ្ឋេន ពោជ្ឈង្គា វិសុទ្ធិប្បដិសម្ភិទាបាបនដ្ឋេន

ពោជ្ឈង្គ ដោយអត្ថថាចោមរោមហេតុ ពោជ្ឈង្គ ដោយអត្ថថាបំពេញហេតុ ពោជ្ឈង្គ ដោយអត្ថថាធ្វើហេតុឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថាធ្វើហេតុឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថាញ៉ាំងជនឲ្យដល់នូវហេតុប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាចម្រើននូវវសីក្នុងហេតុប្បដិសម្ភិទា ពោជ្ឈង្គ របស់ជនអ្នកសម្រេចនូវវសីភាពក្នុងហេតុប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាជាបច្ច័យ ពោជ្ឈង្គ ដោយអត្ថថាទំនុកបម្រុងបច្ច័យ ពោជ្ឈង្គ ដោយអត្ថថាថៃទាំបច្ច័យ ពោជ្ឈង្គ ដោយអត្ថថាចោមរោមបច្ច័យ ពោជ្ឈង្គ ដោយអត្ថថាបំពេញបច្ច័យ ពោជ្ឈង្គ ដោយអត្ថថាធ្វើបច្ច័យឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថាធ្វើបច្ច័យឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថាញ៉ាំងជនឲ្យដល់នូវបច្ចយ-ប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាចម្រើននូវវសីក្នុងបច្ចយប្បដិសម្ភិទា ពោ-ជ្ឈង្គរបស់ជនអ្នកសម្រេចនូវវសីភាពក្នុងបច្ចយប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាបរិសុទ្ធ ពោជ្ឈង្គ ដោយអត្ថថាទំនុកបម្រុងសេចក្តីបរិសុទ្ធ ពោជ្ឈង្គ ដោយអត្ថថាថៃទាំសេចក្តីបរិសុទ្ធ ពោជ្ឈង្គ ដោយអត្ថថាចោមរោមសេចក្តីបរិសុទ្ធ ពោជ្ឈង្គ ដោយអត្ថថាបំពេញសេចក្តីបរិសុទ្ធ ពោជ្ឈង្គ ដោយអត្ថថាធ្វើសេចក្តីបរិសុទ្ធឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថាធ្វើសេចក្តីបរិ-សុទ្ធឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថាញ៉ាំងជនឲ្យដល់នូវវិសុទ្ធិប្បដិសម្ភិទា

## ៦៧

### យុគនទ្ធវគ្គេ ពោជ្ឈង្គកថា

ពោជ្ឈង្គា វិសុទ្ធិប្បដិសម្ភិទាយ វសីភាវដ្ឋេន ពោជ្ឈង្គា វិសុទ្ធិប្បដិសម្ភិទាយ វសីភាវប្បត្តានម្បិ ពោជ្ឈង្គា អនវជ្ជដ្ឋេន ពោជ្ឈង្គា អនវជ្ជចរិយដ្ឋេន ពោជ្ឈង្គា អនវជ្ជបរិគ្គហដ្ឋេន ពោជ្ឈង្គា អនវជ្ជបរិវារដ្ឋេន ពោជ្ឈង្គា អនវជ្ជបរិបូរដ្ឋេន ពោជ្ឈង្គា អនវជ្ជបរិចាគដ្ឋេន ពោជ្ឈង្គា អនវជ្ជប្បដិសម្ភិទដ្ឋេន ពោជ្ឈង្គា អនវជ្ជប្បដិសម្ភិទាចាបនដ្ឋេន ពោជ្ឈង្គា អនវជ្ជប្បដិសម្ភិទាយ វសីភាវដ្ឋេន ពោជ្ឈង្គា អនវជ្ជប្បដិសម្ភិទាយ វសីភាវប្បត្តានម្បិ ពោជ្ឈង្គា នេក្ខម្មដ្ឋេន ពោជ្ឈង្គា នេក្ខម្មចរិយដ្ឋេន ពោជ្ឈង្គា នេក្ខម្មបរិគ្គហដ្ឋេន ពោជ្ឈង្គា នេក្ខម្មបរិវារដ្ឋេន ពោជ្ឈង្គា នេក្ខម្មបរិបូរដ្ឋេន ពោជ្ឈង្គា នេក្ខម្មបរិចាគដ្ឋេន ពោជ្ឈង្គា នេក្ខម្មប្បដិសម្ភិទដ្ឋេន ពោជ្ឈង្គា នេក្ខម្មប្បដិសម្ភិទាចាបនដ្ឋេន ពោជ្ឈង្គា នេក្ខម្មប្បដិសម្ភិទាយ វសីភាវដ្ឋេន ពោជ្ឈង្គា នេក្ខម្មប្បដិសម្ភិទាយ វសីភាវប្បត្តានម្បិ ពោជ្ឈង្គា វិមុត្តដ្ឋេន ពោជ្ឈង្គា វិមុត្តិចរិយដ្ឋេន

ពោជ្ឈង្គ ដោយអត្ថថាចម្រើននូវវសីក្នុងវិសុទ្ធិប្បដិសម្ភិទា ពោជ្ឈង្គ របស់ជនអ្នកសម្រេចនូវវសីភាពក្នុងវិសុទ្ធិប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាជាអំពើមិនមានទោស ពោជ្ឈង្គ ដោយអត្ថថាទំនុកបម្រុងអំពើមិនមានទោស ពោជ្ឈង្គ ដោយអត្ថថាថែទាំអំពើមិនមានទោស ពោជ្ឈង្គ ដោយអត្ថថាចោមរោមអំពើមិនមានទោស ពោជ្ឈង្គ ដោយអត្ថថាបំពេញនូវអំពើមិនមានទោស ពោជ្ឈង្គ ដោយអត្ថថាធ្វើអំពើដែលមិនមានទោសឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថាធ្វើអំពើមិនមានទោសឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថាញុំាងជនឲ្យដល់អនវជ្ជប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាចម្រើននូវវសីក្នុងអនវជ្ជប្បដិសម្ភិទា ពោជ្ឈង្គ របស់ជនអ្នកសម្រេចនូវវសីភាពក្នុងអនវជ្ជប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថានេក្ខម្មៈ (ការចេញចាកកាម) ពោជ្ឈង្គ ដោយអត្ថថាទំនុកបម្រុងនេក្ខម្មៈ ពោជ្ឈង្គ ដោយអត្ថថាថែទាំនេក្ខម្មៈ ពោជ្ឈង្គ ដោយអត្ថថាចោមរោមនេក្ខម្មៈ ពោជ្ឈង្គ ដោយអត្ថថាបំពេញនេក្ខម្មៈ ពោជ្ឈង្គ ដោយអត្ថថាធ្វើនេក្ខម្មៈឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថាធ្វើនេក្ខម្មៈឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថាញុំាងជនឲ្យដល់នូវនេក្ខម្មប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាចម្រើននូវវសីក្នុងនេក្ខម្មប្បដិសម្ភិទា ពោជ្ឈង្គ របស់ជនអ្នកសម្រេចនូវវសីភាពក្នុងនេក្ខម្មប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាវិមុត្តិ ពោជ្ឈង្គ ដោយអត្ថថាទំនុកបម្រុងវិមុត្តិ

ពោជ្ឈង្គា វិមុត្តិបរិគ្គហដ្ឋេន ពោជ្ឈង្គា វិមុត្តិបរិវារដ្ឋេន ពោជ្ឈង្គា វិមុត្តិបរិបូរដ្ឋេន ពោជ្ឈង្គា វិមុត្តិបរិចាក-ដ្ឋេន ពោជ្ឈង្គា វិមុត្តិប្បដិសម្ភិទដ្ឋេន ពោជ្ឈង្គា វិមុ-ត្តិប្បដិសម្ភិទាចាបនដ្ឋេន ពោជ្ឈង្គា វិមុត្តិប្បដិសម្ភិ-ទាយ វសីភាវដ្ឋេន ពោជ្ឈង្គា វិមុត្តិប្បដិសម្ភិទាយ វសីភាវប្បត្តានម្បិ ពោជ្ឈង្គា អនាសវដ្ឋេន ពោជ្ឈង្គា អនាសវចរិយដ្ឋេន ពោជ្ឈង្គា អនាសវបរិគ្គហដ្ឋេន ពោជ្ឈង្គា អនាសវបរិវារដ្ឋេន ពោជ្ឈង្គា អនាសវបរិ-បូរដ្ឋេន ពោជ្ឈង្គា អនាសវបរិចាកដ្ឋេន ពោជ្ឈង្គា អនា-សវប្បដិសម្ភិទដ្ឋេន ពោជ្ឈង្គា អនាសវប្បដិសម្ភិទាចាប-នដ្ឋេន ពោជ្ឈង្គា អនាសវប្បដិសម្ភិទាយ វសីភាវដ្ឋេន ពោជ្ឈង្គា អនាសវប្បដិសម្ភិទាយ វសីភាវប្បត្តានម្បិ ពោជ្ឈង្គា វិវេកដ្ឋេន ពោជ្ឈង្គា វិវេកចរិយដ្ឋេន ពោ-ជ្ឈង្គា វិវេកបរិគ្គហដ្ឋេន ពោជ្ឈង្គា វិវេកបរិវារដ្ឋេន ពោជ្ឈង្គា វិវេកបរិបូរដ្ឋេន ពោជ្ឈង្គា វិវេកបរិចាកដ្ឋេន

ពោជ្ឈង្គ ដោយអត្ថថាថែទាំវិមុត្តិ ពោជ្ឈង្គ ដោយអត្ថថាចោមរោមវិមុត្តិ ពោជ្ឈង្គ ដោយអត្ថថាបំពេញវិមុត្តិ ពោជ្ឈង្គ ដោយអត្ថថាធ្វើវិមុត្តិឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថាធ្វើវិមុត្តិឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថាញុំាងជនឲ្យដល់នូវវិមុត្តិប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាចម្រើននូវវសី ក្នុងវិមុត្តិប្បដិសម្ភិទា ពោជ្ឈង្គ របស់ជនអ្នកសម្រេចនូវវសីភាពក្នុងវិមុត្តិប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាការមិនមានអាសវៈ ពោជ្ឈង្គ ដោយអត្ថថាទំនុកបម្រុងនូវការមិនមានអាសវៈ ពោជ្ឈង្គ ដោយអត្ថថាថែទាំនូវការមិនមានអាសវៈ ពោជ្ឈង្គ ដោយអត្ថថាចោមរោមនូវការមិនមានអាសវៈ ពោជ្ឈង្គ ដោយអត្ថថាបំពេញនូវការមិនមានអាសវៈ ពោជ្ឈង្គ ដោយអត្ថថាធ្វើនូវការមិនមានអាសវៈឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថាធ្វើនូវការមិនមានអាសវៈឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថាញុំាងជនឲ្យដល់នូវអនាសវប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាចម្រើន នូវវសីក្នុងអនាសវប្បដិសម្ភិទា ពោជ្ឈង្គ របស់ជនអ្នកសម្រេចនូវវសីភាពក្នុងអនាសវប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាវិវេក ពោជ្ឈង្គ ដោយអត្ថថាទំនុកបម្រុងវិវេក ពោជ្ឈង្គ ដោយអត្ថថាថែទាំវិវេក ពោជ្ឈង្គ ដោយអត្ថថាចោមរោមវិវេក ពោជ្ឈង្គ ដោយអត្ថថាបំពេញនូវវិវេក ពោជ្ឈង្គ ដោយអត្ថថាធ្វើវិវេកឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថាធ្វើវិវេកឲ្យបែករីក

៦៩

## យុគនទ្ធវគ្គេ ពោជ្ឈង្គកថា

ពោជ្ឈង្គា វិវេកប្បដិសម្ភិទដ្ឋេន ពោជ្ឈង្គា វិវេកប្បដិសម្ភិទាចាបនដ្ឋេន ពោជ្ឈង្គា វិវេកប្បដិសម្ភិទាយ វសីភាវដ្ឋេន ពោជ្ឈង្គា វិវេកប្បដិសម្ភិទាយ វសីភាវប្បត្តានម្បិ ពោជ្ឈង្គា វោស្សគ្គដ្ឋេន ពោជ្ឈង្គា វោស្សគ្គចរិយដ្ឋេន ពោជ្ឈង្គា វោស្សគ្គបរិគ្គហដ្ឋេន ពោជ្ឈង្គា វោស្សគ្គបរិវារដ្ឋេន ពោជ្ឈង្គា វោស្សគ្គបរិបូរដ្ឋេន ពោជ្ឈង្គា វោស្សគ្គបរិចាកដ្ឋេន ពោជ្ឈង្គា វោស្សគ្គប្បដិសម្ភិទដ្ឋេន ពោជ្ឈង្គា វោស្សគ្គប្បដិសម្ភិទាចាបនដ្ឋេន ពោជ្ឈង្គា វោស្សគ្គប្បដិសម្ភិទាយ វសីភាវដ្ឋេន ពោជ្ឈង្គា វោស្សគ្គប្បដិសម្ភិទាយ វសីភាវប្បត្តានម្បិ ពោជ្ឈង្គា ។

[៣០] មូលដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ហេតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បច្ចយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិសុទ្ធដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អនវជ្ជដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា នេក្ខម្មដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិមុត្តដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អនាសវដ្ឋំ ពុជ្ឈន្តីតិ

ពោជ្ឈង្គ ដោយអត្ថថាញុំាងជនឲ្យដល់ នូវវិវេកប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាចម្រើននូវវសីក្នុងវិវេកប្បដិសម្ភិទា ពោជ្ឈង្គ របស់ពួកជនអ្នកសម្រេចនូវវសីភាពក្នុងវិវេកប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាការលះបង់ ពោជ្ឈង្គ ដោយអត្ថថាទំនុកបម្រុងនូវការលះបង់ ពោជ្ឈង្គ ដោយអត្ថថាថៃទាំនូវការលះបង់ ពោជ្ឈង្គ ដោយអត្ថថាចោមរោមនូវការលះបង់ ពោជ្ឈង្គ ដោយអត្ថថាបំពេញនូវការលះបង់ ពោជ្ឈង្គ ដោយអត្ថថាធ្វើនូវការលះបង់ឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថាធ្វើនូវការលះបង់ឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថាញុំាងជនឲ្យដល់នូវវោស្សគ្គប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថាចម្រើននូវវសីក្នុងវោស្សគ្គប្បដិសម្ភិទា ពោជ្ឈង្គ របស់ពួកជនអ្នកសម្រេចនូវវសីភាពក្នុងវោស្សគ្គប្បដិសម្ភិទា ។

[៣០] ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃមូល ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃហេតុ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃបច្ច័យ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបរិសុទ្ធ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃអំពើមិនមានទោស ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃនេក្ខម្មៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃវិមុត្តិ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការមិនមានអាសវៈ

ពោជ្ឈង្គា វិវេកដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វោស្សគ្គដ្ឋំ ពុជ្ឈ-ន្តីតិ ពោជ្ឈង្គា មូលចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ហេតុ-ចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បច្ចយចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិសុទ្ធិចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អនវជ្ជច-រិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា នេក្ខម្មចរិយដ្ឋំ ពុជ្ឈន្តីតិ ពោ-ជ្ឈង្គា វិមុត្តិចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អនាសវចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិវេកចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វោស្សគ្គចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា មូលបរិគ្គហដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។ បេ ។ វោស្សគ្គបរិគ្គហដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា មូលបរិវារដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។ បេ ។

ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃវិវេក ឈ្មោះថាពោ-ជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការលះបង់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការទំនុកបម្រុងមូល ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការទំនុកបម្រុងហេតុ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការទំនុកបម្រុងបច្ច័យ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការទំនុកបម្រុងសេចក្តីបរិសុទ្ធ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទំនុកបម្រុង នូវអំពើមិនមានទោស ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទំនុកបម្រុងនូវនេក្ខម្មៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការទំនុកបម្រុងនូវវិមុត្តិ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទំនុកបម្រុងអំពើមិនមានអាសវៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការទំនុកបម្រុងនូវវិវេក ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការទំនុកបម្រុងនូវការលះបង់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការថែទាំនូវមូល ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការថែទាំការលះបង់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបោមពោមនូវមូល ។ បេ ។

យុគនទុវគ្គេ ពោដ្ឋង្គកថា

ហេស្បុគ្គុបរិភារដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា មូលបរិប្ពូរដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា ។ បេ ។ ហេស្បុគ្គុបរិប្ពូរដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា មូលបរិចាកដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា ។ បេ ។ ហេស្បុគ្គុបរិចាកដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា មូលប្បដិសម្ពិទ-ដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា ។ បេ ។ ហេស្បុគ្គុប្បដិសម្ពិទដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា មូលប្បដិសម្ពិទាចាបនដ្ឋំ ពុ-ដ្ឋន្តីតិ ពោដ្ឋង្គា ។ បេ ។ ហេស្បុគ្គុប្បដិសម្ពិទាចាបនដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា មូលប្បដិសម្ពិទាយ វសីភាវដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា ហេស្បុគ្គុប្បដិសម្ពិទាយ វសីភាវ-ដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា ។ បេ ។

[៣១] បរិគ្គហដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា បរិភារដ្ឋំ ពុដ្ឋ-ន្តីតិ ពោដ្ឋង្គា ។ បេ ។ បរិប្ពូរដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា ឯកគ្គ-ដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា អវិក្ខេបដ្ឋំ ពុដ្ឋន្តីតិ ពោដ្ឋង្គា

ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការចោមរោមនូវការលះបង់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបំពេញមូល ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបំពេញនូវការលះបង់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការធ្វើមូលឲ្យចាស់ក្លា ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការធ្វើនូវការលះបង់ឲ្យចាស់ក្លា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការធ្វើមូលឲ្យបែករីក ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការធ្វើនូវការលះបង់ឲ្យបែករីក ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការញុំាងជនឲ្យដល់នូវមូលប្បដិសម្ភិទា ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការញុំាងជនឲ្យដល់ នូវវោស្សគ្គប្បដិសម្ភិទា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការចម្រើន នូវវសីក្នុងមូលប្បដិសម្ភិទា ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការចម្រើននូវវសីក្នុងវោស្សគ្គប្បដិសម្ភិទា ។ បេ ។

[៣១] ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការថែទាំ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការចោមរោម ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការបំពេញ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃឯកគ្គតាចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការមិនរាយមាយ

៧២



បគ្គហដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អវិសារដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អនាវិលដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អនិញ្ជនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តុបដ្ឋានវសេន ចិត្តស្ស ឋិតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អារម្មណដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា គោចរដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បហានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បរិច្ចាគដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វុដ្ឋានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិវដ្តនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សន្តដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បណីតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិមុត្តដ្ឋំ ពុជ្ឈន្តីតិ ពោ-ជ្ឈង្គា អនាសវដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា តរណដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អនិមិត្តដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា

ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការផ្គងឡើង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការមិនរាយមាយ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃធម៌មិនមានកករល្អក់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការមិនញាប់ញ័រ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃចិត្តតាំងនៅនឹង ដោយអំណាចនៃការប្រុង ដោយភាពនៃចិត្តមានអារម្មណ៍តែមួយ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃអារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃគោចរ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការលះបង់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការបរិច្ចាគ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការចេញ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ប្រាសចាកវដ្តៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ស្ងប់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ដ៏ថ្លៃថ្លា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃវិមុត្តិ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌មិនមានអាសវៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃធម៌ជាគ្រឿងឆ្លង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃព្រះនិព្វានមិនមាននិមិត្ត

យុគនទ្ធវគ្គេ ពោជ្ឈង្គកថា

អប្បណិហិតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សុញ្ញតដ្ឋំ ពុជ្ឈ-
ន្តីតិ ពោជ្ឈង្គា ឯការសដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា
អនតិវត្តនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា យុគនទ្ធដ្ឋំ ពុជ្ឈ-
ន្តីតិ ពោជ្ឈង្គា និយ្យានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា
ហេតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឧស្សនដ្ឋំ ពុជ្ឈន្តីតិ
ពោជ្ឈង្គា អាធិបតេយ្យដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។

[៣២] សមថស្ស អវិក្ខេបដ្ឋំ ពុជ្ឈន្តីតិ ពោ-
ជ្ឈង្គា វិបស្សនាយ អនុបស្សនដ្ឋំ ពុជ្ឈន្តីតិ ពោ-
ជ្ឈង្គា សមថវិបស្សនានំ ឯការសដ្ឋំ ពុជ្ឈន្តីតិ ពោ-
ជ្ឈង្គា យុគនទ្ធស្ស អនតិវត្តនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា
សិក្ខាយ សមាទានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា
អារម្មណស្ស គោចរដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា

ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃព្រះនិព្វានមិនមានគ្រឿងតម្កល់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃព្រះនិព្វានដ៏សូន្យ (ចាកកិលេស) ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌មានរសតែមួយ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនប្រព្រឹត្តលើសគ្នា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ជាប់គ្នាជាគូ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការចេញ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃហេតុ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការយល់ឃើញ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ជាអធិបតី ។

[៣២] ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការមិនរាយមាយរបស់សមថៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការឃើញរឿយ ៗ របស់វិបស្សនា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃសមថៈនិងវិបស្សនាមានរសតែមួយ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌ជាប់គ្នាជាគូ មិនប្រព្រឹត្តលើសគ្នា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការសមាទាននូវសិក្ខា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃគោចររបស់អារម្មណ៍

លីនស្ស ចិត្តស្ស បគ្គហដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឧទ្ធច្ចស្ស ចិត្តស្ស វិនិគ្គហដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឧភោវិសុទ្ធានំ អជ្ឈុបេក្ខនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិសេសាធិគមដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឧត្តរិប្បដិវេធដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សច្ចាភិសមយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា និរោធេ បតិដ្ឋាបកដ្ឋំ[១] ពុជ្ឈន្តីតិ ពោជ្ឈង្គា ។

[៣៣] សទ្ធិន្ទ្រិយស្ស អធិមោក្ខដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។ បេ ។ បញ្ញិន្ទ្រិយស្ស ទស្សនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សទ្ធាពលស្ស អស្សទ្ធិយេ អកម្បិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។ បេ ។ បញ្ញាពលស្ស អវិជ្ជាយ អកម្បិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សតិសម្ពោជ្ឈង្គស្ស ឧបដ្ឋានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គស្ស បដិសង្ខានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សម្មាទិដ្ឋិយា ទស្សនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។ បេ ។

---

១ ឱ. ម. និរោធបតិដ្ឋាបនដ្ឋំ ។

ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការផ្គង់ឡើងនូវចិត្ត រួញរា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការសង្កត់សង្កិននូវចិត្តជាឧទ្ធច្ចៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការព្រងើយរបស់វិសុទ្ធិទាំងពីរ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការបាននូវគុណវិសេស ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការចាក់ធ្លុះដ៏ក្រៃលែង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការត្រាស់ដឹងនូវសច្ចៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃធម៌ញុំាងសត្វឲ្យតាំងនៅក្នុងនិរោធ ។

[៣៣] ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការជឿស៊ប់របស់សទ្ធិន្ទ្រិយ ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការយល់ឃើញរបស់បញ្ញិន្ទ្រិយ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនកម្រើកព្រោះអស្សទ្ធិយៈរបស់សទ្ធាពលៈ ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការមិនកម្រើកព្រោះអវិជ្ជារបស់បញ្ញាពលៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការប្រុងរបស់សតិសម្ពោជ្ឈង្គ ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការពិចារណា របស់ឧបេក្ខាសម្ពោជ្ឈង្គ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការយល់ឃើញ របស់សម្មាទិដ្ឋិ ។ បេ ។

៧៤

យុគនទ្ធវគ្គេ ពោជ្ឈង្គកថា

សម្មាសមាធិស្ស អវិក្ខេបដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈ-ង្គា ឥន្ទ្រិយានំ អាធិបតេយ្យដ្ឋំ ពុជ្ឈន្តីតិ ពោ-ជ្ឈង្គា ពលានំ អកម្បិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈ-ង្គា ពោជ្ឈង្គានំ និយ្យានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា មគ្គស្ស ហេតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សតិប្បដ្ឋានានំ ឧបដ្ឋានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សម្មប្បធានានំ បទ-ហានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឥទ្ធិបាទានំ ឥជ្ឈនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សច្ចានំ តថដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បយោគានំ បដិប្បស្សទ្ធដ្ឋំ ពុជ្ឈន្តីតិ ពោ-ជ្ឈង្គា ផលានំ សច្ឆិកិរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា[១] វិតក្កស្ស អភិរោបនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិចារ-ស្ស ឧបវិចារដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បីតិយា ផរ-ណដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សុខស្ស អភិសន្ទន-ដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តស្ស ឯកគ្គដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។

១ ម. ឯត្ថន្តរេ បញ្ញាយ បជាននដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គាតិ ទិស្សន្តិ ។

ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនរាយមាយ របស់សម្មាសមាធិ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃអធិបតីរបស់ឥន្ទ្រិយ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនកម្រើករបស់ពលៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការចេញ(ចាកវដ្តៈ)របស់ពោជ្ឈង្គ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃហេតុរបស់មគ្គ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការប្រុងរបស់សតិប្បដ្ឋាន ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃគ្រឿងតាំង របស់សម្មប្បធាន ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃគ្រឿងសម្រេចរបស់ឥទ្ធិបាទ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការពិតរបស់សច្ចៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការស្ងប់រម្ងាប់ របស់ធម៌ជាគ្រឿងប្រកប ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការធ្វើឲ្យជាក់ច្បាស់របស់ផលឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃគ្រឿងលើកចិត្តរបស់វិតក្កៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃឧបវិចារៈរបស់វិចារៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការផ្សាយរបស់បីតិ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបង្ហូររបស់សេចក្តីសុខ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃចិត្តមានអារម្មណ៍តែមួយ ។

[៣៤] អាវជ្ជនដ្ឋំ(១) ពុជ្ឈន្តីតិ ពោជ្ឈង្គា វិជ្ជាននដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បជាននដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សញ្ជាននដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកោទដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អភិញ្ញេយ្យដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា(២) បរិញ្ញាយ តីរណដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បហានស្ស បរិច្ចាគដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ភាវនាយ ឯករសដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សច្ឆិកិរិយាយ ផស្សនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ខន្ធានំ ខន្ធដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ធាតូនំ ធាតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អាយតនានំ អាយតនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សង្ខតានំ សង្ខតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អសង្ខតស្ស អសង្ខតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។

---

១ ម. អនវជ្ជនដ្ឋំ ។ ២ ឱ. ម. អភិញ្ញាយ ញាតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គាតិ ទិស្សន្តិ ។

[៣៤] ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការរំពឹង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការដឹងច្បាស់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការដឹងទូទៅ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការដឹងព្រម ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃចិត្តមានអារម្មណ៍តែមួយ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ដែលគប្បីត្រាស់ដឹង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការពិចារណា របស់បរិញ្ញា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការលះរបស់បហានៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃភាវនាមានរសតែមួយ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការពាល់ត្រូវ របស់សច្ឆិកិរិយា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃគំនររបស់ខន្ធ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃគ្រឿងទ្រទ្រង់ របស់ធាតុ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃកន្លែងកើតរបស់អាយតនៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃបច្ច័យតាក់តែង របស់សង្ខតធម៌ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការមិនមានបច្ច័យតាក់តែង របស់អសង្ខតធម៌ ។

### យុគនទ្ធវគ្គេ ពោជ្ឈង្គកថា

[៣៨] ចិត្តដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តានន្តរិកដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តស្ស វុដ្ឋានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តស្ស វិវដ្តនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តស្ស ហេតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តស្ស បច្ចយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តស្ស វត្ថុដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តស្ស ភុម្មដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តស្ស អារម្មណដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តវត្ថុស្ស គោចរដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តស្ស ចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តស្ស គតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តស្ស អភិនីហារដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តស្ស និយ្យានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចិត្តស្ស និស្សរណដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។

យុគនទ្ធវគ្គ ពោជ្ឈង្គកថា

[៣៩] ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃលំដាប់របស់ចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការចេញរបស់ចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការវិលត្រឡប់របស់ចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃហេតុរបស់ចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃបច្ច័យរបស់ចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃទីកើតរបស់ចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃភូមិរបស់ចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃអារម្មណ៍របស់ចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃគោចររបស់ចិត្តវត្ថុ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃចរិយារបស់ចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃដំណើររបស់ចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការប៉ុនប៉ងរបស់ចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការចេញរបស់ចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការរលាស់ចេញរបស់ចិត្ត ។

[៣៦] ឯកត្តេ អាវជ្ជនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ វិជ្ជាននដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ បជាននដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ សញ្ជាននដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ ឯកោទដ្ឋំ ពុជ្ឈ-ន្តីតិ ពោជ្ឈង្គា ឯកត្តេ បក្ខន្ទនដ្ឋំ ពុជ្ឈន្តី-តិ ពោជ្ឈង្គា ឯកត្តេ បសីទនដ្ឋំ[១] ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ សន្តិដ្ឋនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈ-ង្គា ឯកត្តេ វិមុត្តដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯក-ត្តេ ឯតំ សន្តន្តិ បស្សនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ យានីកតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯ-កត្តេ វត្ថុកតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ

---

១ ម. បស្សនដ្ឋំ ។

[៣៦] ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការរំពឹង ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការដឹងច្បាស់ ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការដឹងទូទៅ ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការដឹងព្រម ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃចិត្តមានអារម្មណ៍តែមួយ ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការស្ទុះទៅ ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃសេចក្តីជ្រះថ្លា ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការតម្កល់ព្រម ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃវិមុត្តិ ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការយល់ឃើញ ក្នុងឯកត្តា-រម្មណ៍ថា នេះជាធម្មជាតស្ងប់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃធម៌ធ្វើឲ្យដូចជាយាន ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោ-ជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃធម៌ធ្វើទីកើត ក្នុងឯកត្តារម្មណ៍

៧៩

### យុគនទ្ធវគ្គេ ពោជ្ឈង្គកថា

អនុដ្ឋិតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ បរិចិតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ សុសមារទ្ធដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ បរិគ្គហដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ បរិវារដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ បរិបូរដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ សមោធានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ អធិដ្ឋានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ អាសេវនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ ភាវនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ ពហុលីកម្មដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ សុសមុគ្គតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ សុវិមុត្តដ្ឋំ[១] ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ ពុជ្ឈនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា

---

១ ឱ. ម. សុវិសុទ្ធដ្ឋំ ។

ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនតាំងមាំ ក្នុងឯក-
ត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការសន្សំ
ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការ
ប្រារព្ធដោយប្រពៃ ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុ
ត្រាស់ដឹងនូវអត្ថនៃការកំណត់ ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះ
ហេតុត្រាស់ដឹងនូវអត្ថនៃការចោមរោម ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ
ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបំពេញ ក្នុងឯកត្តារម្មណ៍ ឈ្មោះថា
ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការប្រមូល ក្នុងឯកត្តារម្មណ៍
ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការអធិដ្ឋាន ក្នុង
ឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការ
សេពទូទៅ ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់
ដឹងនូវអត្ថនៃការចម្រើន ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះ
ហេតុត្រាស់ដឹងនូវអត្ថ នៃពហុលីកម្ម ក្នុងឯកត្តារម្មណ៍ ឈ្មោះថា
ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការអណ្តែតឡើងព្រម ក្នុងឯក-
ត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការ
រួចចាកកិលេសដោយប្រពៃ ក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ
ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការត្រាស់ដឹង ក្នុងឯកត្តារម្មណ៍

ឯកត្តេ អនុពុជ្ឈនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ បដិពុជ្ឈនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ សម្ពុជ្ឈនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ ពោធនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ អនុពោធនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ បដិពោធនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ សម្ពោធនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ ពោធិបក្ខិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ អនុពោធិបក្ខិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ បដិពោធិបក្ខិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ សម្ពោធិបក្ខិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ ជោតនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ ឧជ្ជោតនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា

ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការត្រាស់ដឹងតាម ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការត្រាស់ដឹងចំពោះ ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការត្រាស់ដឹងព្រម ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការញុំាងជនឲ្យត្រាស់ដឹង ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការញុំាងជនឲ្យត្រាស់ដឹងតាម ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការញុំាងជន ឲ្យត្រាស់ដឹងចំពោះ ក្នុងឯកត្តាអារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការញុំាងជនឲ្យត្រាស់ដឹងព្រម ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌ជាចំណែកនៃការត្រាស់ដឹង ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌ជាចំណែកនៃការត្រាស់ដឹងតាម ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌ជាចំណែក នៃការត្រាស់ដឹងចំពោះ ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌ជាចំណែកនៃការត្រាស់ដឹងព្រម ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោ-ជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការបំភ្លឺ ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការបំភ្លឺខ្ពស់ឡើង ក្នុង

ឯកត្តេ អនុដោតនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ បដិដោតនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯកត្តេ សញ្ជោតនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។

[៣៧] វីមំសាយ ចាជដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា[១] និពេជដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បតាបនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិពេចនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា កិលេសានំ សន្តាបនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អមលដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិមលដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា និម្មលដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សមដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សមយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិវេកដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិវេកចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា

១ ឱ. ម. បហានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គាតិ ទិស្សតិ ។

ឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការបំភ្លឺតាម ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបំភ្លឺចំពោះ ក្នុងឯកត្តារម្មណ៍ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការបំភ្លឺព្រម ក្នុងឯកត្តារម្មណ៍ ។

[៣៧] ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌ជាជើងរបស់វីមំសា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃនិរោធ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការដុតកម្តៅ (កិលេស) ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការរុងរឿង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការកម្តៅសព្វ នូវកិលេស ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌មិនមានមន្ទិល ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌ប្រាសចាកមន្ទិល ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌ឥតមន្ទិល ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌ដ៏ស្ងប់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌ជាគ្រឿងត្រាស់ដឹង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃវិវេក ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការប្រព្រឹត្តក្នុងវិវេក

វិភាកដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិភាកចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា និរោធដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា និរោធ-ចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វោស្សគ្គដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វោស្សគ្គចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិ-មុត្តដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វិមុត្តិចរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឆន្ទដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឆន្ទស្ស មូល-ដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឆន្ទស្ស បាទដ្ឋំ[១] ពុជ្ឈន្តីតិ ពោជ្ឈង្គា ឆន្ទស្ស បធានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឆន្ទ-ស្ស ឥជ្ឈនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឆន្ទស្ស អធិមោក្ខ-ដ្ឋំ[២] ពុជ្ឈន្តីតិ ពោជ្ឈង្គា ឆន្ទស្ស បគ្គហដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឆន្ទស្ស ឧបដ្ឋានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា

១ ឱ. បទហដ្ឋំ ។ ២ ម. វិមោក្ខដ្ឋំ ។

ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃវិរាគធម៌ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការប្រព្រឹត្ត ក្នុងវិរាគធម៌ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃនិរោធ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការប្រព្រឹត្ត ក្នុងនិរោធ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការលះបង់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការប្រព្រឹត្ត ក្នុងការលះបង់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃវិមុត្តិ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការប្រព្រឹត្តក្នុងវិមុត្តិ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃឆន្ទៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃឫសរបស់ឆន្ទៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃជើងរបស់ឆន្ទៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌ជាប្រធានរបស់ឆន្ទៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការសម្រេចរបស់ឆន្ទៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃអធិមោក្ខ របស់ឆន្ទៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការផ្គងនូវឆន្ទៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការតម្កល់នូវឆន្ទៈ

ឆន្ទស្ស អវិក្ខេបដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា(១) វីរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។ បេ ។ ចិត្តដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វីមំសដ្ឋំ(២) ពុជ្ឈន្តីតិ ពោជ្ឈង្គា វីមំសាយ មូលដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វីមំសាយ ចាទដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វីមំសាយ បធានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វីមំសាយ ឥជ្ឈនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វីមំសាយ អធិមោក្ខដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វីមំសាយ បគ្គហដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វីមំសាយ ឧបដ្ឋានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា វីមំសាយ អវិក្ខេបដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា(៣) ។

[៣៨] ទុក្ខស្ស បីឡនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ទុក្ខស្ស សង្ខតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ទុក្ខស្ស សន្តាបដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ទុក្ខស្ស វិបរិណាមដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សមុទយស្ស អាយុហនដ្ឋំ និទានដ្ឋំ សញ្ញោគដ្ឋំ បលិពោធដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា

---

១ ឱ. ម. ឯត្ថន្តរេ ឆន្ទស្ស ទស្សនដ្ឋំ ពុជ្ឈន្តីតិ ទិស្សតិ ។ ២ ម. វីមំសនដ្ឋំ ។ ៣ ឱ. ម. ឯត្ថ បច្ឆិមេ វីមំសាយ ទស្សនដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គាតិ ឥមេ បាឋា អត្ថិ ។

ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការមិនរាយមាយរបស់ឆន្ទៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃវិរិយៈ ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃចិត្ត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃវីមំសា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃឫសរបស់វីមំសា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃជើងរបស់វីមំសា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌ជាប្រធាន របស់វីមំសា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការសម្រេចរបស់វីមំសា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃអធិមោក្ខ របស់វីមំសា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការផ្គង់របស់វីមំសា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការមិនប្រហែស របស់វីមំសា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការមិនរាយមាយ របស់វីមំសា ។

[៣៨] ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការបៀតបៀនរបស់ទុក្ខ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃទុក្ខត្រូវបច្ច័យតាក់តែង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃទុក្ខជាញុាំងសត្វឲ្យក្តៅ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃទុក្ខមានការប្រែប្រួល ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃសមុទ័យមានការប្រមូលមក នូវអត្ថថាជាហេតុ នូវអត្ថថាសំយោគ នូវអត្ថថាបលិពោធ

ទុក្ខនិរោធស្ស និស្សរណដ្ឋំ វិវេកដ្ឋំ អសង្ខ-
តដ្ឋំ អមតដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា មគ្គស្ស និយ្យានដ្ឋំ
ហេតុដ្ឋំ ទស្សនដ្ឋំ អាធិបតេយ្យដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈ-
ង្គា តថដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា[១] អនត្តដ្ឋំ ពុជ្ឈន្តីតិ
ពោជ្ឈង្គា សច្ចដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បដិវេធដ្ឋំ ពុជ្ឈ-
ន្តីតិ ពោជ្ឈង្គា អភិជាននដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា
បរិជាននដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ធម្មដ្ឋំ ពុជ្ឈន្តីតិ ពោ-
ជ្ឈង្គា ធាតុដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ញាតដ្ឋំ ពុជ្ឈន្តី-
តិ ពោជ្ឈង្គា សច្ឆិកិរិយដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ផស្ស-
នដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អភិសមយដ្ឋំ ពុជ្ឈន្តី-
តិ ពោជ្ឈង្គា នេក្ខម្មំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អព្យាបាទំ
ពុជ្ឈន្តីតិ ពោជ្ឈង្គា អាលោកសញ្ញំ ពុជ្ឈន្តីតិ ពោជ្ឈង្គា

---

១ ឱ. ម. ឯត្ថន្តរេ អនញ្ញថដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គាតិ ទិស្សតិ ។

ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃទុក្ខនិរោធថាជាគ្រឿងរលាស់ចេញ នូវអត្ថថាវិវេក នូវអត្ថថាមិនមានបច្ច័យតាក់តែង នូវអត្ថថាមិនស្លាប់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃមគ្គថាជាគ្រឿងនាំចេញ នូវអត្ថថាជាហេតុ នូវអត្ថថាយល់ឃើញ នូវអត្ថថាជាអធិបតី ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថថាពិត ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថថាជាអនត្តា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថថាទៀង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថថាចាក់ធ្លុះ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថថាដឹងច្បាស់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថថាកំណត់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធម៌ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃធាតុ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃធម៌ដែលដឹងហើយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការពាល់ត្រូវ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវនេក្ខម្មៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអព្យាបាទ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអាលោកសញ្ញា

អវិក្ខេបំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ធម្មវវត្ថានំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ញាណំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ចាមុជ្ជំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បឋមជ្ឈានំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។ បេ ។ អរហត្តមគ្គំ ពុជ្ឈន្តីតិ ពោជ្ឈង្គា[១] ។

[៣៩] អធិមោក្ខដ្ឋេន សទ្ធិន្ទ្រិយំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។ បេ ។ ទស្សនដ្ឋេន បញ្ញិន្ទ្រិយំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អស្សទ្ធិយេ អកម្បិយដ្ឋេន សទ្ធាពលំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។ បេ ។ អវិជ្ជាយ អកម្បិយដ្ឋេន បញ្ញាពលំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឧបដ្ឋានដ្ឋេន សតិសម្ពោជ្ឈង្គំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។ បេ ។ បដិសង្ខានដ្ឋេន ឧបេក្ខាសម្ពោជ្ឈង្គំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ទស្សនដ្ឋេន សម្មាទិដ្ឋឹ ពុជ្ឈន្តីតិ ពោជ្ឈង្គា ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធឹ ពុជ្ឈន្តីតិ ពោជ្ឈង្គា

១ ម. ឯត្ថ បច្ឆិមេ អរហត្តផលសមាបត្តឹ ពុជ្ឈន្តីតិ ពោជ្ឈង្គាតិ ទិស្សតិ ។

ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវការមិនរាយមាយ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវការកំណត់ធម៌ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវញាណ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវបាមុជ្ជៈ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងបឋមជ្ឈាន ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអរហត្តមគ្គ ។

[៣៩] ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវសទ្ធិន្ទ្រិយ ដោយអត្ថថាជឿស៊ប់ ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវបញ្ញិន្ទ្រិយ ដោយអត្ថថាយល់ឃើញ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសទ្ធាពលៈ ដោយអត្ថថាមិនកម្រើក ព្រោះហេតុមិនគួរជឿ ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវបញ្ញាពលៈ ដោយអត្ថថាមិនកម្រើកព្រោះអវិជ្ជា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសតិសម្ពោជ្ឈង្គ ដោយអត្ថថាប្រុង ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវឧបេក្ខាសម្ពោជ្ឈង្គ ដោយអត្ថថាពិចារណា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសម្មាទិដ្ឋិ ដោយអត្ថថាយល់ឃើញ ។ បេ ។ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសម្មាសមាធិ

អាធិបតេយ្យដ្ឋេន ឥន្ទ្រិយំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អកម្បិ-យដ្ឋេន ពលំ ពុជ្ឈន្តីតិ ពោជ្ឈង្គា និយ្យានដ្ឋំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ហេតដ្ឋេន មគ្គំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឧបដ្ឋានដ្ឋេន សតិប្បដ្ឋានំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បទហនដ្ឋេន សម្មប្បធានំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឥជ្ឈន-ដ្ឋេន ឥទ្ធិបាទំ ពុជ្ឈន្តីតិ ពោជ្ឈង្គា តថដ្ឋេន សច្ចំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អវិក្ខេបដ្ឋេន សមថំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អនុបស្សនដ្ឋេន វិបស្សនំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឯករសដ្ឋេន សមថវិបស្សនំ ពុជ្ឈន្តីតិ ពោជ្ឈង្គា អនតិវត្តនដ្ឋេន យុគនទ្ធំ ពុជ្ឈន្តីតិ ពោជ្ឈង្គា សំវរដ្ឋេន សីលវិសុទ្ធឹ ពុជ្ឈន្តីតិ ពោជ្ឈង្គា អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធឹ ពុជ្ឈន្តីតិ ពោជ្ឈង្គា ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធឹ ពុជ្ឈន្តីតិ ពោជ្ឈង្គា

ដោយអត្ថថាមិនរាយមាយ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវឥន្ទ្រិយ ដោយអត្ថថាភាពជាធំ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវពលៈ ដោយអត្ថថាមិនកម្រើក ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថថាចេញ (ចាកវដ្តៈ) ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវមគ្គ ដោយអត្ថថាជាហេតុ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវសតិប្បដ្ឋាន ដោយអត្ថថាប្រុង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសម្មប្បធាន ដោយអត្ថថាតម្កល់ទុក ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវឥទ្ធិបាទ ដោយអត្ថថាសម្រេច ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសច្ចៈ ដោយអត្ថថាទៀង ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសមថៈ ដោយអត្ថថាមិនរាយមាយ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវវិបស្សនាដោយអត្ថថាពិចារណាឃើញរឿយ ៗ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសមថៈនិងវិបស្សនា ដោយអត្ថថាមានរសតែមួយ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវយុគនទ្ធធម៌ ដោយអត្ថថាមិនប្រព្រឹត្តលើសគ្នា ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវចិត្តវិសុទ្ធិ ដោយអត្ថថាមិនរាយមាយ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវទិដ្ឋិវិសុទ្ធិ

៨៧

### យុគនទ្ធវគ្គេ ពោជ្ឈង្គកថា

មុត្តដ្ឋេន វិមោក្ខំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បដិវេធដ្ឋេន វិជ្ជំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បរិច្ចាគដ្ឋេន វិមុត្តឹ ពុជ្ឈន្តីតិ ពោជ្ឈង្គា សមុច្ឆេទដ្ឋេន ខយេ ញាណំ ពុជ្ឈន្តីតិ ពោជ្ឈង្គា បដិប្បស្សទ្ធដ្ឋេន អនុប្បាទេ ញាណំ ពុជ្ឈន្តីតិ ពោជ្ឈង្គា ឆន្ទំ មូលដ្ឋេន ពុជ្ឈន្តីតិ ពោជ្ឈង្គា មនសិការំ សមុដ្ឋានដ្ឋេន ពុជ្ឈន្តីតិ ពោជ្ឈង្គា ផស្សំ សមោធានដ្ឋេន ពុជ្ឈន្តីតិ ពោជ្ឈង្គា វេទនំ សមោសរណដ្ឋេន ពុជ្ឈន្តីតិ ពោជ្ឈង្គា សមាធឹ បមុខដ្ឋេន ពុជ្ឈន្តីតិ ពោជ្ឈង្គា សតឹ អាធិបតេយ្យដ្ឋេន ពុជ្ឈន្តីតិ ពោជ្ឈង្គា បញ្ញំ តទុត្តរដ្ឋេន[១] ពុជ្ឈន្តីតិ ពោជ្ឈង្គា វិមុត្តឹ សារដ្ឋេន ពុជ្ឈន្តីតិ ពោជ្ឈង្គា អមតោគធំ និព្វានំ បរិយោសានដ្ឋេន ពុជ្ឈន្តីតិ ពោជ្ឈង្គា ។

---

១ ឱ. ម. តតុត្តរដ្ឋេន ។

*ដោយអត្ថថាយល់ឃើញ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវវិមោក្ខ ដោយអត្ថថារួច (ចាកកិលេស) ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវវិជ្ជា ដោយអត្ថថាចាក់ធ្លុះចំពោះ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវវិមុត្តិ ដោយអត្ថថាលះបង់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវខយញ្ញាណ ដោយអត្ថថាផ្តាច់ផ្តិល ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអនុប្បាទញ្ញាណ ដោយអត្ថថាស្ងប់រម្ងាប់ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវឆន្ទៈ ដោយអត្ថថាជាឫស ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវមនសិការៈ ដោយអត្ថថាតាំងឡើងព្រម ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវផស្សៈ ដោយអត្ថថាប្រជុំ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវវេទនា ដោយអត្ថថាប្រជុំចុះ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសមាធិ ដោយអត្ថថាជាប្រមុខ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសតិ ដោយអត្ថថាភាពជាធំ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវបញ្ញា ដោយអត្ថថាក្រៃលែងជាងនោះ ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវវិមុត្តិ ដោយអត្ថថាជាខ្លឹម ឈ្មោះថាពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវនិព្វាន ឈ្មោះអមតៈ ជាទីពឹង (របស់សត្វ) ដោយអត្ថថាចប់ស្រេច (នៃកិច្ចក្នុងសាសនា) ។*

# សាវត្ថីនិទានំ

[៤០] តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច សត្តិមេ អាវុសោ ពោជ្ឈង្គា កតមេ សត្ត សតិសម្ពោជ្ឈង្គោ ធម្មវិចយសម្ពោជ្ឈង្គោ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ឥមេ ខោ អាវុសោ សត្ត ពោជ្ឈង្គា ឥមេសំ ខ្វាហំ អាវុសោ សត្តន្នំ ពោជ្ឈង្គានំ យេន យេន ពោជ្ឈង្គេន អាកង្ខាមិ បុព្វណ្ហសមយំ វិហរិតុំ តេន តេន ពោជ្ឈង្គេន បុព្វណ្ហសមយំ វិហរាមិ យេន យេន ពោជ្ឈង្គេន អាកង្ខាមិ មជ្ឈន្តិកសមយំ ។ បេ ។ សាយណ្ហសមយំ វិហរិតុំ តេន តេន ពោជ្ឈង្គេន សាយណ្ហសមយំ វិហរាមិ សតិសម្ពោជ្ឈង្គោ ឥតិ ចេ មេ អាវុសោ ហោតិ អប្បមាណោតិ មេ ហោតិ សុសមារទ្ធោតិ មេ ហោតិ តិដ្ឋន្តំ ចរំ តិដ្ឋតីតិ បជានាមិ សចេបិ មេ ចវតិ ឥទប្បច្ចយា មេ ចវតីតិ បជានាមិ ធម្មវិចយសម្ពោជ្ឈង្គោ ។បេ។

១ ឱ. វចនំ ។ ម. ចវនំ ។

# សារត្ថិនិទាន

[៤០] ព្រះសារីបុត្រមានអាយុ ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលអាវុសោទាំងឡាយ ។ ពួកភិក្ខុទាំងនោះទទួលស្តាប់ព្រះសារីបុត្រមានអាយុថា ករុណាអាវុសោ ។ ព្រះសារីបុត្រមានអាយុបានពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពោជ្ឈង្គនេះ មាន ៧ ពោជ្ឈង្គ ៧ តើដូចម្តេច គឺ សតិសម្ពោជ្ឈង្គ ធម្មវិចយសម្ពោជ្ឈង្គ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ម្នាលអាវុសោទាំងឡាយ នេះឯងពោជ្ឈង្គ ៧ ម្នាលអាវុសោទាំងឡាយ បណ្តាពោជ្ឈង្គទាំង ៧ នេះ ខ្ញុំប្រាថ្នានៅអស់បុព្វណ្ហសម័យ ដោយពោជ្ឈង្គណា ៗ ខ្ញុំក៏នៅ អស់បុព្វណ្ហសម័យដោយពោជ្ឈង្គនោះ ៗ ខ្ញុំប្រាថ្នានៅ អស់មជ្ឈន្តិកសម័យ ដោយពោជ្ឈង្គណា ។ បេ ។ នៅអស់សាយណ្ហសម័យ ខ្ញុំក៏នៅអស់សាយណ្ហសម័យ ដោយពោជ្ឈង្គនោះ ៗ ម្នាលអាវុសោទាំងឡាយ ប្រសិនបើសតិសម្ពោជ្ឈង្គ របស់ខ្ញុំ មានដោយប្រការនោះ ៗ ខ្ញុំក៏មានការដឹងថា និរោធជាធម៌ប្រមាណមិនបាន ទាំងខ្ញុំមានការដឹងថា និរោធជាធម៌ប្រារព្ធសេចក្តីស្ងប់ប្រពៃ ខ្ញុំកាលប្រព្រឹត្ត នូវសតិសម្ពោជ្ឈង្គដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គកំពុងឋិតនៅ បើសតិសម្ពោជ្ឈង្គរបស់ខ្ញុំឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គរបស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ ធម្មវិចយសម្ពោជ្ឈង្គ ។ បេ ។

៨៩

យុគនទ្ធវគ្គេ ពោជ្ឈង្គកថា

ឧបេក្ខាសម្ពោជ្ឈង្គោ ឥតិ ចេ មេ អាវុសោ ហោតិ អប្បមាណោតិ មេ ហោតិ សុសមារទ្ធោតិ មេ ហោតិ តិដ្ឋន្តំ ចរំ តិដ្ឋតីតិ បជានាមិ សចេ-បិ មេ ចវតិ ឥទប្បច្ចយា មេ ចវតីតិ បជានា-មិ សេយ្យថាបិ អាវុសោ រញ្ញោ វា រាជមហា-មត្តស្ស វា នានារត្តានំ ទុស្សានំ ទុស្សករណ្ឌកោ បូរោ អស្ស សោ យញ្ញទេវ ទុស្សយុគំ អាកង្-ខេយ្យ បុព្វណ្ហសមយំ បារុបិតុំ តន្តទេវ ទុស្សយុគំ បុព្វណ្ហសមយំ បារុបេយ្យ យញ្ញទេវ ទុស្សយុគំ អាកង្ខេយ្យ មជ្ឈន្តិកសមយំ សាយណ្ហសមយំ បារុបិតុំ តន្តទេវ ទុស្សយុគំ សាយណ្ហសមយំ បារុបេយ្យ ឯវមេវ ខោ អហំ អាវុសោ ឥមេសំ សត្តន្នំ ពោជ្ឈង្គានំ យេន យេន ពោ-ជ្ឈង្គេន អាកង្ខាមិ បុព្វណ្ហសមយំ វិហរិតុំ តេន តេន ពោជ្ឈង្គេន បុព្វណ្ហសមយំ វិហ-រាមិ យេន យេន ពោជ្ឈង្គេន អាកង្ខាមិ មជ្ឈន្តិកសមយំ សាយណ្ហសមយំ វិហរិតុំ តេន តេន ពោជ្ឈង្គេន សាយណ្ហសមយំ វិហរាមិ

ម្នាលអាវុសោទាំងឡាយ បើឧបេក្ខាសម្ពោជ្ឈង្គ របស់ខ្ញុំមាន ដោយប្រការនោះ ៗ ខ្ញុំក៏មានការដឹងថា និរោធ ជាធម៌ប្រមាណមិនបាន ទាំងខ្ញុំមានការដឹងថា និរោធ ជាធម៌ប្រារព្ធសេចក្តីស្ងប់ប្រពៃ ខ្ញុំកាលប្រព្រឹត្តនូវឧបេក្ខាសម្ពោជ្ឈង្គ ដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គកំពុងឋិតនៅ ប្រសិនបើ ឧបេក្ខាសម្ពោជ្ឈង្គ របស់ខ្ញុំឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គ របស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ ម្នាលអាវុសោទាំងឡាយ ប្រៀបដូចទូសំពត់របស់ព្រះរាជា ឬរបស់រាជមហាមាត្យ ជារបស់ពេញដោយសំពត់ ដែលគេជ្រលក់ ដោយពណ៌ផ្សេង ៗ ព្រះរាជានោះប្រាថ្នានឹងទ្រង់នូវគូនៃព្រះពស្ត្រណា អស់បុព្វណ្ហសម័យ ក៏ទ្រង់នូវគូនៃព្រះពស្ត្រនោះឯង អស់បុព្វណ្ហសម័យ ប្រាថ្នានូវគូនៃព្រះពស្ត្រណា អស់មជ្ឈន្តិកសម័យ អស់សាយណ្ហសម័យ ក៏ទ្រង់នូវគូនៃព្រះពស្ត្រនោះឯង អស់សាយណ្ហសម័យ មានឧបមាដូចម្តេចមិញ ម្នាលអាវុសោទាំងឡាយ មានឧបមេយ្យដូចជា បណ្តាពោជ្ឈង្គទាំង ៧ នេះ ខ្ញុំប្រាថ្នានៅអស់បុព្វណ្ហសម័យ ដោយពោជ្ឈង្គណា ៗ ខ្ញុំក៏នៅអស់បុព្វណ្ហសម័យ ដោយពោជ្ឈង្គនោះ ៗ ខ្ញុំប្រាថ្នានៅអស់មជ្ឈន្តិកសម័យ អស់សាយណ្ហសម័យដោយពោជ្ឈង្គណា ៗ ខ្ញុំក៏នៅអស់សាយណ្ហសម័យ ដោយពោជ្ឈង្គនោះ ៗ

សតិសម្ពោជ្ឈង្គោ ឥតិ ចេ មេ អាវុសោ ហោតិ អប្បមាណោតិ មេ ហោតិ សុសមារទ្ធោតិ មេ ហោតិ តិដ្ឋន្តំ ចវំ តិដ្ឋតីតិ បជានាមិ សចេបិ មេ ចវតិ ឥទប្បច្ចយា មេ ចវតីតិ បជានាមិ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ឥតិ ចេ មេ អាវុសោ ហោតិ អប្បមាណោតិ មេ ហោតិ សុសមារទ្ធោតិ មេ ហោតិ តិដ្ឋន្តំ ចវំ តិដ្ឋ-តីតិ បជានាមិ សចេបិ មេ ចវតិ ឥទប្បច្ចយា មេ ចវតីតិ បជានាមិ ។

[៤១] កថំ សតិសម្ពោជ្ឈង្គោ ឥតិ ចេ មេ[១] ហោ-តីតិ ពោជ្ឈង្គោ ។ យាវតា និរោធុបដ្ឋាតិ តាវតា សតិ-សម្ពោជ្ឈង្គោ ឥតិ ចេ មេ ហោតីតិ ពោជ្ឈង្គោ សេយ្យ-ថាបិ តេលប្បទីបស្ស ឈាយតោ យាវតា អច្ចិ[២] តាវតា វណ្ណោ យាវតា វណ្ណោ តាវតា អច្ចិ ឯវំ យាវតា និរោធុបដ្ឋាតិ តាវតា សតិសម្ពោជ្ឈង្គោ ឥតិ ចេ មេ ហោតីតិ ពោជ្ឈង្គោ ។

---

១ ម. សព្វត្ថ មេតិ នត្ថិ ។ ២ ម. អច្ចិ ។

ម្នាលអាវុសោទាំងឡាយ បើសតិសម្ពោជ្ឈង្គរបស់ខ្ញុំមាន ដោយប្រការនោះៗ ខ្ញុំក៏មានការដឹងថា និរោធ ជាធម៌ប្រមាណមិនបាន ទាំងខ្ញុំមានការដឹងថា និរោធជាធម៌ប្រារព្ធសេចក្តីស្ងប់ប្រពៃ ខ្ញុំកាលប្រព្រឹត្តនូវសតិសម្ពោជ្ឈង្គដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គកំពុងឋិតនៅ បើសតិសម្ពោជ្ឈង្គរបស់ខ្ញុំឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ របស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ ។ បេ ។ ម្នាលអាវុសោទាំងឡាយ បើឧបេក្ខាសម្ពោជ្ឈង្គ របស់ខ្ញុំមានដោយប្រការនោះ ៗ ខ្ញុំក៏មានការដឹងថា និរោធជាធម៌ប្រមាណមិនបាន ទាំងខ្ញុំមានការដឹងថា និរោធជាធម៌ប្រារព្ធសេចក្តីស្ងប់ប្រពៃ ខ្ញុំកាលប្រព្រឹត្តឧបេក្ខាសម្ពោជ្ឈង្គ ដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គកំពុងឋិតនៅ បើឧបេក្ខាសម្ពោជ្ឈង្គរបស់ខ្ញុំឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គ របស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ ។

[៤១] ពោជ្ឈង្គ (អង្គនៃការត្រាស់ដឹង)ថា បើសតិសម្ពោជ្ឈង្គ របស់ខ្ញុំមាន ដោយប្រការនោះ ៗ តើដូចម្តេច ។ និរោធប្រាកដឡើងត្រឹមណា ពោជ្ឈង្គថា បើសតិសម្ពោជ្ឈង្គរបស់ខ្ញុំមានដោយប្រការនោះ ៗ ក៏ត្រឹមណោះ ប្រៀបដូចប្រទីបប្រេងដែលកំពុងឆេះ មានអណ្តាតភ្លើងត្រឹមណា រស្មីក៏ត្រឹមណោះ រស្មីត្រឹមណា អណ្តាតភ្លើងក៏ត្រឹមណោះ មានឧបមាយ៉ាងណា និរោធ ប្រាកដឡើងត្រឹមណា ពោជ្ឈង្គថា បើសតិសម្ពោជ្ឈង្គ របស់ខ្ញុំមានដោយប្រការនោះៗ ក៏ត្រឹមណោះ មានឧបមេយ្យយ៉ាងនោះឯង ។

៩១



កថំ អប្បមាណោ ឥតិ មេ[១] ហោតីតិ ពោជ្ឈង្គោ ។ បមាណវន្តា[២] កិលេសា សព្វេ បរិយុដ្ឋានា យេវ សង្ខារា បោនោព្ភវិកា អប្បមាណោ និរោធោ[៣] អសង្ខតដ្ឋេន យាវតា និរោធុបដ្ឋាតិ តាវតា អប្បមាណោ ឥតិ មេ ហោតីតិ ពោជ្ឈង្គោ ។

កថំ សុសមារទ្ធោ ឥតិ មេ ហោតីតិ ពោជ្ឈង្គោ ។ វិសមា កិលេសា សព្វេ បរិយុដ្ឋានា យេវ សង្ខារា បោនោព្ភវិកា សមធម្មោ និរោធោ សន្តដ្ឋេន បណីតដ្ឋេន យាវតា និរោធុបដ្ឋាតិ តាវតា សុសមារទ្ធោ ឥតិ មេ ហោតីតិ ពោជ្ឈង្គោ ។

[៤២] កថំ តិដ្ឋន្តំ ចរំ តិដ្ឋតីតិ បជានាមិ សចេបិ ចរតិ ឥទប្បច្ចយា មេ ចរតីតិ បជានាមិ កតិហាការេហិ សតិសម្ពោជ្ឈង្គោ តិដ្ឋតិ កតិហាការេហិ សតិសម្ពោជ្ឈង្គោ ចរតិ ។ អដ្ឋហាការេហិ សតិសម្ពោជ្ឈង្គោ តិដ្ឋតិ អដ្ឋហាការេហិ សតិសម្ពោជ្ឈង្គោ ចរតិ ។

១ ម. ចេ ។ ២ ឱ. ម. បមាណពន្ធា ។ ៣ ឱ. ម. ឯត្ថន្តរេ អចលដ្ឋេនាតិ ទិស្សតិ ។

ពោជ្ឈង្គ (អង្គនៃការត្រាស់ដឹង) ថា ខ្ញុំមានការដឹងថា និរោធ ជាធម៌ប្រមាណមិនបាន តើដូចម្តេច ។ កិលេសទាំងឡាយ មានប្រមាណ កិលេសទាំងអស់ ជាគ្រឿងគ្របសង្កត់ សង្ខារទាំងឡាយ ជាធម៌នាំសត្វទៅកើតក្នុងភពថ្មី ឯនិរោធ ជាធម៌ប្រមាណមិនបានទេ ព្រោះអត្ថថាជាអសង្ខតធម៌ និរោធប្រាកដឡើង ត្រឹមណា ពោជ្ឈង្គថា ខ្ញុំមានការដឹងថា និរោធ ជាធម៌ប្រមាណមិនបាន ក៏ត្រឹមណោះដែរ ។

ពោជ្ឈង្គ (អង្គនៃការត្រាស់ដឹង) ថា ខ្ញុំមានការដឹងថា និរោធជាធម៌ប្រារព្ធសេចក្តីស្ងប់ប្រពៃ តើដូចម្តេច ។ កិលេសទាំងឡាយគ្មានការស្ងប់ កិលេសទាំងអស់ ជាគ្រឿងគ្របសង្កត់ចិត្ត សង្ខារទាំងឡាយជាគ្រឿងនាំសត្វទៅកើតក្នុងភពថ្មី ឯនិរោធមានការស្ងប់ជាធម្មតា ព្រោះអត្ថថាជាធម៌ស្ងប់ ព្រោះអត្ថថាជាធម៌ថ្លៃថ្លា និរោធប្រាកដឡើង ត្រឹមណា ពោជ្ឈង្គថា ខ្ញុំមានការដឹងថា និរោធជាធម៌ប្រារព្ធសេចក្តីស្ងប់ប្រពៃ ក៏ត្រឹមណោះ។

[៤២] ខ្ញុំកាលប្រព្រឹត្ត នូវសតិសម្ពោជ្ឈង្គ ដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ កំពុងឋិតនៅ បើសតិសម្ពោជ្ឈង្គឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ របស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ តើដូចម្តេច សតិសម្ពោជ្ឈង្គឋិតនៅ ដោយអាការប៉ុន្មាន សតិសម្ពោជ្ឈង្គឃ្លាត ដោយអាការប៉ុន្មាន សតិសម្ពោជ្ឈង្គឋិតនៅ ដោយអាការ ៨ សតិសម្ពោជ្ឈង្គឃ្លាត ដោយអាការ ៨ ។

កាតមេហិ អដ្ឋហាកាវេហិ សតិសម្ពោជ្ឈង្គោ តិដ្ឋតិ ។ អនុប្បាទំ អាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ តិដ្ឋតិ ឧប្បាទំ អនាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ តិ-ដ្ឋតិ អប្បវត្តំ អាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ តិដ្ឋតិ បវត្តំ អនាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ តិដ្ឋតិ អនិមិ-ត្តំ អាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ តិដ្ឋតិ និមិត្តំ អ-នាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ តិដ្ឋតិ និរោធំ អាវជ្ជិ-តត្តា សតិសម្ពោជ្ឈង្គោ តិដ្ឋតិ សង្ខារេ អនាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ តិដ្ឋតិ ឥមេហិ អដ្ឋហាកាវេហិ សតិសម្ពោជ្ឈង្គោ តិដ្ឋតិ ។

កាតមេហិ អដ្ឋហាកាវេហិ សតិសម្ពោជ្ឈង្គោ ចវតិ ។ ឧប្បាទំ អាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ ចវតិ អនុប្បាទំ អនាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ ចវតិ បវត្តំ អាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ ចវតិ អប្បវត្តំ អនាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ ចវតិ និមិត្តំ អាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ ចវតិ អនិមិត្តំ អនាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ ចវតិ

សតិសម្ពោជ្ឈង្គឋិតនៅ ដោយអាការ ៨ តើដូចម្តេច ។ សតិសម្ពោជ្ឈង្គឋិតនៅ ព្រោះរំពឹងនូវការមិនកើតឡើង ១ សតិសម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវការកើតឡើង ១ សតិសម្ពោជ្ឈង្គឋិតនៅ ព្រោះរំពឹងនូវការមិនប្រព្រឹត្ត ១ សតិសម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវការប្រព្រឹត្ត ១ សតិសម្ពោជ្ឈង្គឋិតនៅ ព្រោះ រំពឹងនូវអនិមិត្ត ១ សតិសម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវនិមិត្ត ១ សតិសម្ពោជ្ឈង្គឋិតនៅ ព្រោះរំពឹងនូវនិរោធ ១ សតិសម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវសង្ខារ ១ នេះសតិសម្ពោជ្ឈង្គឋិតនៅ ដោយអាការ ៨ យ៉ាង ។

សតិសម្ពោជ្ឈង្គឃ្លាត ដោយអាការ ៨ តើដូចម្តេច ។ សតិសម្ពោជ្ឈង្គឃ្លាត ព្រោះរំពឹងនូវការកើតឡើង ១ សតិសម្ពោជ្ឈង្គឃ្លាត ព្រោះមិនរំពឹង នូវការមិនកើតឡើង ១ សតិសម្ពោជ្ឈង្គឃ្លាត ព្រោះរំពឹង នូវការប្រព្រឹត្ត ១ សតិសម្ពោជ្ឈង្គ ឃ្លាត ព្រោះមិនរំពឹង នូវការមិនប្រព្រឹត្ត ១ សតិសម្ពោជ្ឈង្គ ឃ្លាត ព្រោះរំពឹងនូវនិមិត្ត ១ សតិសម្ពោជ្ឈង្គ ឃ្លាត ព្រោះមិនរំពឹង នូវអនិមិត្ត ១

សង្ខារេ អាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ ចរតិ និរោធំ អនាវជ្ជិតត្តា សតិសម្ពោជ្ឈង្គោ ចរតិ ឥមេហិ អដ្ឋហាការេហិ សតិសម្ពោជ្ឈង្គោ ចរតិ ឯវំ តិដ្ឋន្តំ ចរំ តិដ្ឋតីតិ បជានាមិ សចេបិ ចរតិ ឥទប្ប- ច្ចយា មេ ចរតីតិ បជានាមិ ។ បេ ។

[៤៣] កថំ ឧបេក្ខាសម្ពោជ្ឈង្គោ ឥតិ ចេ មេ ហោតីតិ ពោជ្ឈង្គោ ។ យាវតា និរោធុបដ្ឋាតិ តាវតា ឧបេក្ខាសម្ពោជ្ឈង្គោ ឥតិ ចេ មេ ហោតីតិ ពោជ្ឈង្គោ សេយ្យថាបិ តេលប្បទីបស្ស ឈាយតោ យាវតា អច្ចិ តាវតា វណ្ណោ យាវតា វណ្ណោ តាវតា អច្ចិ ឯវមេវ យាវតា និរោធុបដ្ឋាតិ តាវតា ឧបេក្ខា- សម្ពោជ្ឈង្គោ ឥតិ មេ ហោតីតិ ពោជ្ឈង្គោ ។

កថំ អប្បមាណោ ឥតិ មេ ហោតីតិ ពោជ្ឈង្គោ ។ បមាណវន្តា កិលេសា សព្វេ បរិយុដ្ឋានា យេវ សង្ខារា ចោនោព្ភវិកា អប្បមាណោ និរោធោ[១] អ- សង្ខតដ្ឋេន យាវតា និរោធុបដ្ឋាតិ តាវតា អប្បមា- ណោ ឥតិ មេ ហោតីតិ ពោជ្ឈង្គោ ។

---

១ ឱ. ម. ឯត្ថន្តរេ អជលដ្ឋេនាតិ ទិស្សតិ ។

សតិសម្ពោជ្ឈង្គឃ្លាត ព្រោះរំពឹងនូវសង្ខារ ១ សតិសម្ពោជ្ឈង្គឃ្លាត ព្រោះមិនរំពឹងនូវនិពោធ ១ នេះសតិសម្ពោជ្ឈង្គឃ្លាត ដោយអាការ ៨ យ៉ាង ខ្ញុំកាលប្រព្រឹត្ត នូវសតិសម្ពោជ្ឈង្គ ដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គកំពុងឋិតនៅ បើសតិសម្ពោជ្ឈង្គឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គរបស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ យ៉ាងនេះឯង ។ បេ ។

[៤៣] ពោជ្ឈង្គ (អង្គនៃការត្រាស់ដឹង) ថា បើឧបេក្ខាសម្ពោជ្ឈង្គរបស់ខ្ញុំ មានដោយប្រការនោះ ៗ តើដូចម្តេច ។ និរោធប្រាកដ ត្រឹមណា ពោជ្ឈង្គថា បើឧបេក្ខាសម្ពោជ្ឈង្គរបស់ខ្ញុំមានដោយប្រការនោះ ៗ ក៏ត្រឹមណោះដែរ ប្រៀបដូចប្រទីបប្រេង ដែលកំពុងឆេះ មានអណ្តាតភ្លើងត្រឹមណា រស្មីក៏ត្រឹមណោះ រស្មីត្រឹមណា អណ្តាតភ្លើងក៏ត្រឹមណោះ មានឧបមាយ៉ាងណា និរោធប្រាកដត្រឹមណា ពោជ្ឈង្គថា បើឧបេក្ខាសម្ពោ-ជ្ឈង្គ របស់ខ្ញុំមាន ដោយប្រការនោះ ៗ ក៏ត្រឹមណោះដែរ ។

ពោជ្ឈង្គ (អង្គនៃការត្រាស់ដឹង) ថា និរោធជាធម៌ប្រមាណមិនបាន តើដូចម្តេច ។ កិលេសទាំងឡាយ មានប្រមាណ កិលេសទាំងអស់ជាគ្រឿងគ្របសង្កត់ចិត្ត សង្ខារទាំងឡាយ ជាគ្រឿងនាំសត្វទៅកើតក្នុងភពថ្មី ឯនិរោធ ជាធម៌ប្រមាណមិនបានទេ ព្រោះអត្ថថាជាអសង្ខតធម៌ និរោធ ប្រាកដ ត្រឹមណា ពោជ្ឈង្គថា និរោធ ជាធម៌ប្រមាណមិនបាន ត្រឹមណោះដែរ ។

កថំ សុសមារទ្ធោ ឥតិ មេ ហោតីតិ ពោជ្ឈង្គោ ។ វិសមា កិលេសា សព្វេ បរិយុដ្ឋានា យេវ សង្ខារា ចោនោព្ភវិកា សមធម្មោ និរោធោ សន្តដ្ឋេន បណីតដ្ឋេន យាវតា និរោធុបដ្ឋាតិ តាវតា សុសមារទ្ធោ ឥតិ មេ ហោតីតិ ពោជ្ឈង្គោ ។

កថំ តិដ្ឋន្តំ ចរំ តិដ្ឋតីតិ បជានាមិ សចេបិ ចរតិ ឥទប្បច្ចយា មេ ចរតីតិ បជានាមិ កតិហាការេហិ ឧបេក្ខាសម្ពោជ្ឈង្គោ តិដ្ឋតិ កតិហាការេហិ ឧបេក្ខាសម្ពោជ្ឈង្គោ ចរតិ ។

[៨៨] កតមេហិ អដ្ឋហាការេហិ ឧបេក្ខាសម្ពោជ្ឈង្គោ តិដ្ឋតិ ។ អនុប្បាទំ អាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ តិដ្ឋតិ ឧប្បាទំ អនាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ តិដ្ឋតិ អប្បវត្តំ អាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ តិដ្ឋតិ បវត្តំ អនាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ តិដ្ឋតិ អនិមិត្តំ អាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ តិដ្ឋតិ

ពោជ្ឈង្គ (អង្គនៃការត្រាស់ដឹង) ថា និរោធ ជាធម៌ប្រារព្ធសេចក្ដីស្ងប់ប្រពៃ តើដូចម្ដេច ។ កិលេសទាំងឡាយ គ្មានការស្ងប់ កិលេសទាំងអស់ ជាគ្រឿងគ្របសង្កត់ចិត្ត សង្ខារទាំងឡាយ ជាគ្រឿងនាំសត្វទៅកើតក្នុងភពថ្មី ឯនិរោធ មានការស្ងប់ជាធម្មតា ព្រោះអត្ថថាជាធម៌ស្ងប់ ព្រោះអត្ថថាជាធម៌ថ្លៃថ្លា និរោធប្រាកដត្រឹមណា ពោជ្ឈង្គថានិរោធ ជាធម៌ប្រារព្ធសេចក្ដីស្ងប់ប្រពៃ ក៏ត្រឹមណោះដែរ ។

ខ្ញុំកាលប្រព្រឹត្តនូវឧបេក្ខាសម្ពោជ្ឈង្គ ដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គកំពុងឋិតនៅ បើឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គ របស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ តើដូចម្ដេច ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ដោយអាការប៉ុន្មាន ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ដោយអាការប៉ុន្មាន ។ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ដោយអាការ ៨ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ដោយអាការ ៨ ។

[៤៤] ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ដោយអាការ ៨ តើដូចម្ដេច ។ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ព្រោះរំពឹងនូវការមិនកើតឡើង ១ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវការកើតឡើង ១ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ព្រោះរំពឹងនូវការមិនប្រព្រឹត្ត ១ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវការប្រព្រឹត្ត ១ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ព្រោះរំពឹងនូវអនិមិត្ត ១

និមិត្តំ អនាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ តិដ្ឋតិ និរោធំ អាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ តិដ្ឋតិ សង្ខារេ អនាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ តិដ្ឋតិ ឥមេហិ អដ្ឋហាការេហិ ឧបេក្ខាសម្ពោជ្ឈង្គោ តិដ្ឋតិ ។

កតមេហិ អដ្ឋហាការេហិ ឧបេក្ខាសម្ពោជ្ឈង្គោ ចរតិ ។ ឧប្បាទំ អាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ ចរតិ អនុប្បាទំ អនាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ ចរតិ បវត្តំ អាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ ចរតិ អប្បវត្តំ អនាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ ចរតិ និមិត្តំ អាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ ចរតិ អនិមិត្តំ អនាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ ចរតិ សង្ខារេ អាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ ចរតិ និរោធំ អនាវជ្ជិតត្តា ឧបេក្ខាសម្ពោជ្ឈង្គោ ចរតិ ឥមេហិ អដ្ឋហាការេហិ ឧបេក្ខាសម្ពោជ្ឈង្គោ ចរតិ ឯវំ តិដ្ឋន្តំ ចរំ តិដ្ឋតីតិ បជានាមិ សចេបិ ចរតិ ឥទប្បច្ចយា មេ ចរតីតិ បជានាមីតិ ។

ពោជ្ឈង្គកថា ។

ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវនិមិត្ត ១ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ព្រោះរំពឹងនូវនិរោធ ១ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវសង្ខារ ១ នេះ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ដោយអាការ ៨ យ៉ាង ។

ឧបេក្ខាសម្ពោជ្ឈង្គឃ្លាតដោយអាការ ៨ តើដូចម្តេច ។ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះរំពឹងនូវការកើតឡើង ១ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះមិនរំពឹងនូវការមិនកើតឡើង ១ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះរំពឹងនូវការប្រព្រឹត្ត ១ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះមិនរំពឹងនូវការមិនប្រព្រឹត្ត ១ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះរំពឹងនូវនិមិត្ត ១ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះមិនរំពឹង នូវអនិមិត្ត ១ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះរំពឹងនូវសង្ខារ ១ ឧបេក្ខាសម្ពោជ្ឈង្គ ឃ្លាត ព្រោះមិនរំពឹងនូវនិរោធ ១ នេះ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ដោយអាការ ៨ យ៉ាង ខ្ញុំកាលប្រព្រឹត្តនូវឧបេក្ខាសម្ពោជ្ឈង្គ ដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គកំពុងឋិតនៅ បើឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គរបស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ យ៉ាងនេះឯង ។

ចប់ ពោជ្ឈង្គកថា ។

# យុគនទ្ធវគ្គេ មេត្តាកថា

## សាវត្ថីនិទានំ

[៤៩] មេត្តាយ ភិក្ខវេ ចេតោវិមុត្តិយា អាសេវិតាយ ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ ឯកាទសានិសំសា បាដិកង្ខា កតមេ ឯកាទស សុខំ សុបតិ សុខំ បដិពុជ្ឈតិ ន បាបកំ សុបិនំ បស្សតិ មនុស្សានំ បិយោ ហោតិ អមនុស្សានំ បិយោ ហោតិ ទេវតា រក្ខន្តិ នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ តុវដំ ចិត្តំ សមាធិយតិ មុខវណ្ណោ វិប្បសីទតិ អសម្មូឡ្ហោ កាលំ ករោតិ ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ មេត្តាយ ភិក្ខវេ ចេតោវិមុត្តិយា អាសេវិតាយ ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ ឥមេ ឯកាទសានិសំសា បាដិកង្ខា ។

# យុគនទ្ធវគ្គ មេត្តាកថា

## សាវត្ថីនិទាន

[៤៥] ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គល បានសេព អប់រំ ធ្វើឲ្យច្រើន ធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចជាទីតាំង តម្កល់មាំ សន្សំដោយម៉ត់ចត់ ប្រារព្ធល្អហើយ នឹងមានអានិសង្ស ១១ ជាប្រាកដ អានិសង្សទាំង ១១ តើដូចម្តេចខ្លះ គឺមេត្តាវិហារិបុគ្គល រមែងដេកលក់ស្រួល ១ ភ្ញាក់ឡើងស្រួល ១ មិនយល់សប្តអាក្រក់ ១ ជាទីស្រឡាញ់នៃមនុស្សទាំងឡាយ ១ ជាទីស្រឡាញ់នៃអមនុស្សទាំងឡាយ ១ ពួកទេវតាតែងរក្សា ១ ភ្លើងក្តីថ្នាំពិសក្តីសស្ត្រាវុធក្តី រមែងមិនប៉ះពាល់ ១ បុគ្គលនោះតម្កល់ចិត្តនៅនឹងដ៏ឆាប់រហ័ស ១ មានសម្បុរមុខស្រស់បស់ ១ មិនវង្វេងធ្វើមរណកាល ១ កាលបើមិនទាន់បានត្រាស់ដឹងនូវមគ្គផលទេ គង់បានទៅកើតឯព្រហ្មលោក ១ ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គលបានសេព អប់រំ ធ្វើឲ្យច្រើន ធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចជាទីតាំង តម្កល់មាំ សន្សំដោយម៉ត់ចត់ ប្រារព្ធល្អហើយ តែងមានអានិសង្ស ១១ នេះឯង ជាប្រាកដ ។

យុគនទ្ធវគ្គេ មេត្តាកថា

[៤៦] អត្ថិ អនោធិសោ ផរណា មេត្តា ចេតោវិមុត្តិ អត្ថិ ឱធិសោ ផរណា មេត្តា ចេតោវិមុត្តិ អត្ថិ ទិសា ផរណា មេត្តា ចេតោវិមុត្តិ ។ កតិហាការេហិ អនោធិសោ ផរណា មេត្តា ចេតោវិមុត្តិ កតិហាការេហិ ឱធិសោ ផរណា មេត្តា ចេតោវិមុត្តិ កតិហាការេហិ ទិសា ផរណា មេត្តា ចេតោវិមុត្តិ ។ បញ្ចហាការេហិ អនោធិសោ ផរណា មេត្តា ចេតោវិមុត្តិ សត្តហាការេហិ ឱធិសោ ផរណា មេត្តា ចេតោវិមុត្តិ ទសហាការេហិ ទិសា ផរណា មេត្តា ចេតោវិមុត្តិ ។

កតមេហិ បញ្ចហាការេហិ អនោធិសោ ផរណា មេត្តា ចេតោវិមុត្តិ ។ សព្វេ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ សព្វេ បាណា ។ បេ ។ សព្វេ ភូតា សព្វេ បុគ្គលា សព្វេ អត្តភាវបរិយាបន្នា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តូតិ ឥមេហិ បញ្ចហាការេហិ អនោធិសោ ផរណា មេត្តា ចេតោវិមុត្តិ ។

យុគនទ្ធវគ្គ មេត្តាកថា

[៤៦] មេត្តាចេតោវិមុត្តិ ផ្សាយដោយមិនមានចំណែកក៏មាន មេត្តាចេតោវិមុត្តិ ផ្សាយដោយចំណែក ក៏មាន មេត្តាចេតោវិមុត្តិ ផ្សាយកាន់ទិសទាំងឡាយក៏មាន ។ មេត្តាចេតោវិមុត្តិ ផ្សាយដោយមិនមានចំណែក ដោយអាការប៉ុន្មាន មេត្តាចេតោវិមុត្តិ ផ្សាយដោយចំណែក ដោយអាការប៉ុន្មាន មេត្តាចេតោវិមុត្តិ ផ្សាយកាន់ទិសទាំងឡាយ ដោយអាការប៉ុន្មាន ។ មេត្តាចេតោវិមុត្តិ ផ្សាយដោយមិនមានចំណែក ដោយអាការ ៥ មេត្តាចេតោវិមុត្តិ ផ្សាយដោយចំណែក ដោយអាការ ៧ មេត្តាចេតោវិមុត្តិ ផ្សាយកាន់ទិសទាំងឡាយ ដោយអាការ ១០ ។

មេត្តាចេតោវិមុត្តិ ផ្សាយដោយមិនមានចំណែក ដោយអាការ ៥ តើដូចម្តេច ។ ការផ្សាយមេត្តាចិត្តថា សូមសត្វទាំងអស់ កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ ១ សូមសត្វមានជីវិតទាំងអស់ ។ បេ ។ ១ សូមសត្វកើតហើយទាំងអស់ ១ សូមបុគ្គលទាំងអស់ ១ សូមសត្វទាំងអស់ ដែលរាប់ថាមានអត្តភាព កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ ១ នេះមេត្តាចេ-តោវិមុត្តិ ផ្សាយដោយមិនមានចំណែក ដោយអាការ ៥ យ៉ាង ។

កតមេហិ សត្តហាការេហិ ឱធិសោ ផរណា មេត្តា ចេតោវិមុត្តិ ។ សព្វា ឥត្ថិយោ អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ សព្វេ បុរិសា ។ បេ ។ សព្វេ អរិយា សព្វេ អនរិយា សព្វេ ទេវា សព្វេ មនុស្សា សព្វេ វិនិបាតិកា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ ឥមេហិ សត្តហាការេហិ ឱធិសោ ផរណា មេត្តា ចេតោវិមុត្តិ ។

[៤៧] កតមេហិ ទសហាការេហិ ទិសា ផរណា មេត្តា ចេតោវិមុត្តិ ។ សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ សព្វេ បច្ឆិមាយ ទិសាយ សត្តា ។ បេ ។ សព្វេ ឧត្តរាយ ទិសាយ សត្តា សព្វេ ទក្ខិណាយ ទិសាយ សត្តា សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា សព្វេ បច្ឆិមាយ អនុទិសាយ សត្តា សព្វេ ឧត្តរាយ អនុទិសាយ សត្តា សព្វេ ទក្ខិណាយ អនុទិសាយ សត្តា សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា សព្វេ ឧបរិមាយ ទិសាយ សត្តា

មេត្តាចេតោវិមុត្តិ ផ្សាយដោយចំណែក ដោយអាការ ៧ តើដូចម្តេច ។ ការផ្សាយមេត្តាចិត្តថា សូមស្រ្តីទាំងអស់ កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខរក្សាខ្លួនចុះ ១ សូមប្រុសទាំងអស់ ។ បេ ។ ១ សូមព្រះអរិយៈទាំងអស់ ១ សូមបុគ្គលមិនមែនព្រះអរិយៈទាំងអស់ ១ សូមទេវតាទាំងអស់ ១ សូមមនុស្សទាំងអស់ ១ សូមវិនិបាតទាំងអស់ កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខរក្សាខ្លួនចុះ ១ នេះ មេត្តាចេតោវិមុត្តិ ផ្សាយដោយចំណែក ដោយអាការ ៧ យ៉ាង ។

[៤៧] មេត្តាចេតោវិមុត្តិ ផ្សាយកាន់ទិសទាំងឡាយ ដោយអាការ ១០ តើដូចម្តេច ។ ការផ្សាយមេត្តាចិត្តថា សូមសត្វទាំងអស់ ក្នុងទិសខាងកើត កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ សូមសត្វទាំងអស់ ក្នុងទិសខាងលិច ។ បេ ។ សូមសត្វទាំងអស់ ក្នុងទិសខាងជើង សូមសត្វទាំងអស់ ក្នុងទិសខាងត្បូង សូមសត្វទាំងអស់ ក្នុងទិសអគ្នេយ៍ សូមសត្វទាំងអស់ ក្នុងទិសពាយ័ព្យ សូមសត្វទាំងអស់ ក្នុងទិសឦសាន សូមសត្វទាំងអស់ ក្នុងទិសនិរតី សូមសត្វទាំងអស់ ក្នុងទិសខាងក្រោម សូមសត្វទាំងអស់ ក្នុងទិសខាងលើ

យុគនទ្ធវគ្គេ មេត្តាកថា

អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ សព្វេ បុរត្ថិមាយ ទិសាយ បាណា ។ បេ ។ ភូតា បុគ្គលា អត្តភាវបរិយាបន្នា សព្វា ឥត្ថិយោ សព្វេ បុរិសា សព្វេ អរិយា សព្វេ អនរិយា សព្វេ ទេវា សព្វេ មនុស្សា សព្វេ វិនិបាតិកា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ សព្វេ បច្ឆិមាយ ទិសាយ វិនិបាតិកា ។ បេ ។ សព្វេ ឧត្តរាយ ទិសាយ វិនិបាតិកា សព្វេ ទក្ខិណាយ ទិសាយ វិនិបាតិកា សព្វេ បុរត្ថិមាយ អនុទិសាយ វិនិបាតិកា សព្វេ បច្ឆិមាយ អនុទិសាយ វិនិបាតិកា សព្វេ ឧត្តរាយ អនុទិសាយ វិនិបាតិកា សព្វេ ទក្ខិណាយ អនុទិសាយ វិនិបាតិកា សព្វេ ហេដ្ឋិមាយ ទិសាយ វិនិបាតិកា សព្វេ ឧបរិមាយ ទិសាយ វិនិបាតិកា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តូតិ ឥមេហិ ទសហាការេហិ ទិសា ផរណា មេត្តា ចេតោវិមុត្តិ សព្វេសំ សត្តានំ បីឡនំ វជ្ជេត្វា អបីឡនាយ

យុគនទ្ធវគ្គ មេត្តាកថា

កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ សូមសត្វមានជីវិត ។ បេ ។ សត្វកើតហើយ បុគ្គលដែលរាប់ថាមានអត្តភាពទាំងអស់ ស្រីទាំងអស់ ប្រុសទាំងអស់ ព្រះអរិយៈទាំងអស់ បុគ្គលមិនមែនអរិយៈទាំងអស់ ទេវតាទាំងអស់ មនុស្សទាំងអស់ វិនិបាតទាំងអស់ ក្នុងទិសខាងកើត កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ សូមវិនិបាតទាំងអស់ក្នុងទិសខាងលិច ។ បេ ។ សូមវិនិបាតទាំងអស់ក្នុងទិសខាងជើង សូមវិនិបាតទាំងអស់ក្នុងទិសខាងត្បូង សូមវិនិបាតទាំងអស់ក្នុងទិសអគ្នេយ៍ សូមវិនិបាតទាំងអស់ក្នុងទិសពាយ័ព្យ សូមវិនិបាតទាំងអស់ក្នុងទិសឦសាន សូមវិនិបាតទាំងអស់ក្នុងទិសនិរតី សូមវិនិបាតទាំងអស់ក្នុងទិសខាងក្រោម សូមវិនិបាតទាំងអស់ក្នុងទិសខាងលើ កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ នេះមេត្តាចេតោវិមុត្តិ ផ្សាយកាន់ទិសទាំងឡាយដោយអាការ១០យ៉ាង ឈ្មោះថាមេត្តា ព្រោះជាធម្មជាតិប្រព្រឹត្តជាមិត្ត ចំពោះសត្វទាំងអស់ ដោយអាការ ៨ នេះ គឺដោយការវៀរ នូវការបៀតបៀនសត្វទាំងអស់ ហើយមិនបៀតបៀន ១

ឧបឃាតំ វជ្ជេត្វា អនុបឃាតេន សន្តាបំ វជ្ជេត្វា អសន្តាបេន បរិយាទានំ វជ្ជេត្វា អបរិយាទានេន វិហេសំ វជ្ជេត្វា អវិហេសាយ សព្វេ សត្តា អវេរិនោ ហោន្តុ មា វេរិនោ សុខិនោ ហោន្តុ មា ទុក្ខិនោ សុខិតត្តា ហោន្តុ មា ទុក្ខិតត្តាតិ ឥមេហិ អដ្ឋហាការេហិ សព្វេ សត្តេ មេត្តាយតីតិ មេត្តា តំ ធម្មំ ចេតយតីតិ ចេតោ សព្វព្យាបាទបរិយុដ្ឋានេហិ មុច្ចតីតិ វិមុត្តិ មេត្តា ច ចេតោវិមុត្តិ[១] ចាតិ មេត្តា ចេតោវិមុត្តិ ។

[៤៨] សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សទ្ធាយ អធិមុច្ចតិ សទ្ធិន្ទ្រិយបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ វីរិយំ បគ្គណ្ហាតិ វីរិយិន្ទ្រិយបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សតឹ ឧបដ្ឋាបេតិ សតិន្ទ្រិយបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ

---
១ ឱ. ម. ចេតោ ច វិមុត្តី ។

ដោយការវៀរ នូវគំនុំហើយមិនគុំ ១ ដោយការវៀរនូវការដុតកម្តៅហើយមិនដុតកម្តៅ ១ ដោយការវៀរនូវការសង្កត់សង្កិន ហើយមិនសង្កត់សង្កិន ១ ដោយការវៀរ នូវការធ្វើឲ្យលំបាកហើយមិនធ្វើឲ្យលំបាក ១ ដោយការផ្សាយថា សូមសត្វទាំងអស់ជាអ្នកគ្មានពៀរ កុំបីចងពៀរនឹងគ្នា ១ សូមមានសុខ កុំបីមានទុក្ខ ១ សូមមានខ្លួនដល់នូវសុខ កុំបីមានខ្លួនដល់នូវទុក្ខ ១ ឈ្មោះថាចេតោ ព្រោះជាសភាវៈគិតនូវធម៌នោះ ឈ្មោះថាវិមុត្តិ ព្រោះជាធម្មជាតិរួចចាកបរិយុដ្ឋានកិលេស គឺព្យាបាទ ចំពោះសត្វទាំងអស់ ឈ្មោះថាមេត្តាចេតោវិមុត្តិ ព្រោះមេត្តានិងចេតោវិមុត្តិ ។

[៤៨] សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេមសូមមានសុខចុះ បុគ្គលបង្អោនសទ្ធាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះបានអប់រំហើយ ដោយសទ្ធិន្ទ្រិយ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលផ្គង (ព្យាយាម) ដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះបានអប់រំហើយ ដោយវីរិយិន្ទ្រិយ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសេចក្តីសុខចុះ បុគ្គលប្រុងស្មារតីដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះបានអប់រំហើយ ដោយសតិន្ទ្រិយ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម

ហោន្តូតិ ចិត្តំ សមាទហតិ សមាធិន្ទ្រិយបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ បញ្ញាយ បជានាតិ បញ្ញិន្ទ្រិយបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ឥមានិ បញ្ចិន្ទ្រិយានិ មេត្តាយ ចេតោវិមុត្តិយា អាសេវនា ហោន្តិ ឥមេហិ បញ្ចហិន្ទ្រិយេហិ មេត្តា ចេតោវិមុ-ត្តិ អាសេវិយតិ ឥមានិ បញ្ចិន្ទ្រិយានិ មេត្តាយ ចេតោវិមុត្តិយា ភាវនា ហោន្តិ ឥមេហិ បញ្ចហិន្ទ្រិយេ-ហិ មេត្តា ចេតោវិមុត្តិ ភាវិយតិ ឥមានិ បញ្ចិន្ទ្រិយានិ មេត្តាយ ចេតោវិមុត្តិយា ពហុលីកម្មា ហោន្តិ ឥមេហិ បញ្ចហិន្ទ្រិយេហិ មេត្តា ចេតោវិមុត្តិ ពហុលីករិយ-តិ ឥមានិ បញ្ចិន្ទ្រិយានិ មេត្តាយ ចេតោវិមុ-ត្តិយា អលង្ការា ហោន្តិ ឥមេហិ បញ្ចហិន្ទ្រិយេ-ហិ មេត្តា ចេតោវិមុត្តិ ស្វាលង្កតា ហោតិ ឥមានិ បញ្ចិន្ទ្រិយានិ មេត្តាយ ចេតោវិមុត្តិយា បរិក្ខា-រា ហោន្តិ ឥមេហិ បញ្ចហិន្ទ្រិយេហិ មេត្តា ចេតោវិមុត្តិ សុបរិក្ខតា ហោតិ ឥមានិ បញ្ចិន្ទ្រិ-យានិ មេត្តាយ ចេតោវិមុត្តិយា បរិវារា ហោន្តិ

សូមមានសុខចុះ បុគ្គលតម្កល់មាំនូវចិត្តដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះបានអប់រំហើយ ដោយសមាធិន្ទ្រិយ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលដឹងច្បាស់ដោយប្រាជ្ញាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះបានអប់រំហើយ ដោយបញ្ញិន្ទ្រិយ ឥន្ទ្រិយទាំង ៥ នេះ ជាទីសេពរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវឥន្ទ្រិយទាំង ៥ នេះ តែងសេព ឥន្ទ្រិយទាំង ៥ នេះ ជាទីអប់រំរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវឥន្ទ្រិយទាំង ៥ នេះ តែងអប់រំ ឥន្ទ្រិយទាំង ៥ នេះ ជាទីធ្វើឲ្យច្រើន របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវឥន្ទ្រិយទាំង ៥ នេះតែងធ្វើឲ្យច្រើន ឥន្ទ្រិយទាំង ៥ នេះ ជាគ្រឿងប្រដាប់របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវឥន្ទ្រិយទាំង ៥ នេះស្អិតស្អាងល្អហើយ ឥន្ទ្រិយទាំង ៥ នេះ ជាបរិក្ខាររបស់មេត្តា-ចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវឥន្ទ្រិយទាំង ៥ នេះ បិទបាំងហើយដោយប្រពៃ ឥន្ទ្រិយទាំង ៥ នេះ ជាបរិវាររបស់មេត្តាចេតោវិមុត្តិ

ឥមេហិ បញ្ចហិន្ទ្រិយេហិ មេត្តា ចេតោវិមុត្តិ សុបរិវុតា[១] ហោតិ ឥមានិ បញ្ចិន្ទ្រិយានិ មេត្តាយ ចេតោវិមុត្តិយា អាសេវនា ហោន្តិ ភាវនា ហោន្តិ ពហុលីកម្មា[២] ហោន្តិ អលង្ការា ហោន្តិ បរិក្ខារា ហោន្តិ បរិវារា ហោន្តិ ចារិបូរី ហោន្តិ សហគតា ហោន្តិ សហជាតា ហោន្តិ សំសដ្ឋា ហោន្តិ សម្បយុត្តា ហោន្តិ បក្ខន្ទនា ហោន្តិ បសីទនា[៣] ហោន្តិ សន្តិដ្ឋនា ហោន្តិ វិមុច្ចនា ហោន្តិ ឯតំ សន្តន្តិ បស្សនា[៤] ហោន្តិ យានីកតា ហោន្តិ វត្ថុកតា ហោន្តិ អនុដ្ឋិតា ហោន្តិ បរិចិតា ហោន្តិ សុសមារទ្ធា ហោន្តិ សុភាវិតា ហោន្តិ ស្វាធិដ្ឋិតា ហោន្តិ សុសមុគ្គតា ហោន្តិ សុវិមុត្តា ហោន្តិ និព្វត្តេន្តិ ជោតេន្តិ បតាបេន្តិ[៥] ។

[៤៩] សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ អស្សទ្ធិយេ ន កម្បតិ សទ្ធាពលបរិភាវិតា ហោតិ មេត្តាចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ កោសជ្ជេ ន កម្បតិ វីរិយពលបរិភាវិតា ហោតិ

១ ម. បារិបូរី ។ ២ ម. ពហុលីកតា ។ ៣ ម. សំសីទនា ។ ៤ ម. ផុស្សនា ។ ៥ ឱ. បភាសេន្តិ ។ ម. បកាសេន្តិ ។

មេត្តាចេតោវិមុត្តិ ត្រូវឥន្ទ្រិយទាំង ៥ នេះ ចោមរោមហើយ ឥន្ទ្រិយទាំង ៥ នេះ ជាទីសេព ជាទីអប់រំ ជាទីធ្វើឲ្យច្រើន ជាគ្រឿងប្រដាប់ ជាបរិក្ខារ ជាបរិវារ នៃមេត្តាចេតោវិមុត្តិ ជាទីបំពេញ ជាធម៌ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយ ផ្សំ ស្មុះទៅ ជាទីជ្រះថ្លា ជាទីតម្កល់ ជាធម្មជាតរួចចាកកិលេស ជាទីឃើញច្បាស់ថា នេះធម្មជាតស្ងប់ ជាធម្មជាតធ្វើឲ្យដូចជាយាន ធ្វើដូចជាទីតាំង ជាគុណជាតិតម្កល់មាំ សន្សំហើយ ប្រារព្ធល្អហើយ អប់រំល្អហើយ អធិដ្ឋានល្អហើយ អណ្តែតឡើងព្រម ផុតស្រឡះ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

[៤៩] សូមសព្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលមិនញាប់ញ័រ ព្រោះហេតុមិនគួរជឿ ដោយគិតដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសទ្ធាពលៈ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលមិនញាប់ញ័រ ព្រោះកោសជ្ជៈ ដោយគិតដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយវីរិយពលៈ

១០៣

## យុគនទ្ធវគ្គេ មេត្តាកថា

មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ បមាទេ ន កម្បតិ សតិពលបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ ឧទ្ធច្ចេ ន កម្បតិ សមាធិពលបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ អវិជ្ជាយ ន កម្បតិ បញ្ញាពលបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ឥមានិ បញ្ច ពលានិ មេត្តាយ ចេតោវិមុត្តិយា អាសេវនា ហោន្តិ ឥមេហិ បញ្ចហិ ពលេហិ មេត្តា ចេតោវិមុត្តិ អាសេវិយតិ ឥមានិ បញ្ច ពលានិ មេត្តាយ ចេតោវិមុត្តិយា ភាវនា ហោន្តិ ឥមេហិ បញ្ចហិ ពលេហិ មេត្តា ចេតោវិមុត្តិ ភាវិយតិ ឥមានិ បញ្ច ពលានិ មេត្តាយ ចេតោវិមុត្តិយា ពហុលីកម្មា ហោន្តិ ឥមេហិ បញ្ចហិ ពលេហិ មេត្តា ចេតោវិមុត្តិ ពហុលីករិយតិ ឥមានិ បញ្ច ពលានិ មេត្តាយ ចេតោវិមុត្តិយា អលង្ការា ហោន្តិ

យុគនទ្ធវគ្គ មេត្តាកថា

សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលមិនញាប់ញ័រ ព្រោះសេចក្តីប្រហែសដោយគិតដូច្នេះ មេត្តាចេតោ-វិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសតិពលៈ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសេចក្តីសុខចុះ បុគ្គលមិនញាប់ញ័រ ព្រោះឧទ្ធច្ចៈ ដោយគិតដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយដោយសមាធិពលៈ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលមិនញាប់ញ័រ ព្រោះអវិជ្ជា ដោយគិតដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយបញ្ញាពលៈ ពលៈទាំង ៥ នេះ ជាទីសេពរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវពលៈទាំង ៥ នេះ តែងសេព ពលៈទាំង ៥ នេះ ជាទីអប់រំ របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវពលៈទាំង ៥ នេះ តែងអប់រំ ពលៈទាំង ៥ នេះ ជាទីធ្វើឲ្យច្រើន របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវពលៈទាំង ៥ នេះ តែងធ្វើឲ្យច្រើន ពលៈទាំង ៥ នេះ ជាគ្រឿងប្រដាប់ របស់មេត្តាចេតោវិ-មុត្តិ មេត្តាចេតោវិមុត្តិ ត្រូវពលៈទាំង ៥ នេះ ស្អិតស្អាងល្អហើយ

ឥមេហិ បញ្ចហិ ពលេហិ មេត្តា ចេតោវិមុត្តិ ស្វា-
លង្កតា ហោតិ ឥមានិ បញ្ច ពលានិ មេត្តាយ ចេ-
តោវិមុត្តិយា បរិក្ខារា ហោន្តិ ឥមេហិ បញ្ចហិ ពលេហិ
មេត្តា ចេតោវិមុត្តិ សុបរិក្ខតា ហោតិ ឥមានិ បញ្ច ព-
លានិ មេត្តាយ ចេតោវិមុត្តិយា បរិវារា ហោន្តិ ឥមេហិ
បញ្ចហិ ពលេហិ មេត្តា ចេតោវិមុត្តិ សុបរិវុតា ហោតិ
ឥមានិ បញ្ច ពលានិ មេត្តាយ ចេតោវិមុត្តិយា អាសេវនា
ហោន្តិ ភាវនា ហោន្តិ ពហុលីកម្មា ហោន្តិ អលង្ការា
ហោន្តិ បរិក្ខារា ហោន្តិ បរិវារា ហោន្តិ ចារិបូរី
ហោន្តិ សហគតា ហោន្តិ សហជាតា ហោន្តិ
សំសដ្ឋា ហោន្តិ សម្បយុត្តា ហោន្តិ បក្ខន្ទនា ហោន្តិ
បសីទនា ហោន្តិ សន្តិដ្ឋនា ហោន្តិ វិមុច្ចនា
ហោន្តិ ឯតំ សន្តន្តិ បស្សនា ហោន្តិ យានីកតា
ហោន្តិ វត្ថុកតា ហោន្តិ អនុដ្ឋិតា ហោន្តិ បរិចិតា
ហោន្តិ សុសមារទ្ធា ហោន្តិ សុភាវិតា ហោន្តិ
ស្វាធិដ្ឋិតា ហោន្តិ សុសមុគ្គតា ហោន្តិ សុវិមុត្តា
ហោន្តិ និព្វត្តេន្តិ ជោតេន្តិ បតាបេន្តិ ។

ពលៈទាំង ៥ នេះ ជាបរិក្ខាររបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពលៈទាំង ៥ នេះបិទបាំងហើយដោយប្រពៃ ពលៈទាំង ៥ នេះ ជាបរិវារនៃមេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវពលៈទាំង ៥ នេះ ចោមរោមល្អហើយ ពលៈទាំង ៥ នេះ ជាទីសេព ជាទីអប់រំ ជាទីធ្វើឲ្យច្រើន ជាគ្រឿងប្រដាប់ ជាទីបិទបាំង ជាបរិវារនៃមេត្តាចេតោវិមុត្តិ ជាទីបំពេញ ជាធម៌ប្រព្រឹត្តទៅជាមួយ កើតជាមួយ លាយ ផ្សំ ជាទីស្ទុះទៅ ជាទីជ្រះថ្លា ជាធម៌តាំងនៅមាំ ជាធម្មជាតរួចចាកកិលេស ជាទីឃើញច្បាស់ថានេះធម្មជាតស្ងប់ ជាធម្មជាតធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចជាទីតាំង ជាធម្មជាតតម្កល់មាំ សន្សំហើយ ប្រារព្ធល្អហើយ អប់រំល្អហើយ អធិដ្ឋានល្អហើយ អណ្តែតឡើងព្រម ផុតស្រឡះ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

យុគនទ្ធវគ្គេ មេត្តាកថា

[៩០] សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សតី ឧបដ្ឋាបេតិ សតិសម្ពោជ្ឈង្គបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា ។ បេ ។ បញ្ញាយ បវិចិនាតិ[១] ធម្មវិចយសម្ពោជ្ឈង្គបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា ។ បេ ។ វីរិយំ បគ្គណ្ហាតិ វីរិយសម្ពោជ្ឈង្គបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា ។ បេ ។ បរិឡាហំ បដិប្បស្សម្ភេតិ បីតិសម្ពោជ្ឈង្គបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា ។ បេ ។ ទុដ្ឋុល្លំ បដិប្បស្សម្ភេតិ បស្សទ្ធិសម្ពោជ្ឈង្គបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ ចិត្តំ សមាទហាតិ សមាធិសម្ពោជ្ឈង្គបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ ញាណេន កិលេសេ បដិសង្ខាតិ ឧបេក្ខាសម្ពោជ្ឈង្គបរិភាវិតា

---
១ ឱ. បវីចិនាតិ ។

យុគនទ្ធវគ្គ មេត្តាកថា

[៩០] សូមសត្វទាំងអស់កុំបីមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលប្រុងស្មារតីដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយសតិសម្ពោជ្ឈង្គ សូមសត្វទាំងអស់ ។ បេ ។ បុគ្គលពិចារណាដោយប្រាជ្ញាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយធម្មវិចយសម្ពោជ្ឈង្គ សូមសត្វទាំងអស់ ។ បេ ។ បុគ្គលផ្គងព្យាយាមដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយវីរិយសម្ពោជ្ឈង្គ សូមសត្វទាំងអស់ ។ បេ ។ បុគ្គលញុំាងសេចក្ដីក្ដៅក្រហាយឲ្យស្ងប់ដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយបីតិសម្ពោជ្ឈង្គ សូមសត្វទាំងអស់ ។ បេ ។ បុគ្គលញុំាងសេចក្ដីអាក្រក់ឲ្យស្ងប់ដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយបស្សទ្ធិសម្ពោជ្ឈង្គ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលតម្កល់ចិត្តមាំដូច្នេះ មេត្តា-ចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសមាធិសម្ពោជ្ឈង្គ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលពិចារណានូវពួកកិលេស ដោយញាណដូច្នេះ មេត្តា-ចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយឧបេក្ខាសម្ពោជ្ឈង្គ

ហោតិ មេត្តា ចេតោវិមុត្តិ ឥមេ សត្ត ពោជ្ឈង្គា មេត្តាយ ចេតោវិមុត្តិយា អាសេវនា ហោន្តិ ឥមេហិ សត្តហិ ពោជ្ឈង្គេហិ មេត្តា ចេតោវិមុត្តិ អាសេវិយ-តិ ឥមេ សត្ត ពោជ្ឈង្គា មេត្តាយ ចេតោវិមុត្តិយា ភាវនា ហោន្តិ ឥមេហិ សត្តហិ ពោជ្ឈង្គេហិ មេត្តា ចេតោវិមុត្តិ ភាវិយតិ ឥមេ សត្ត ពោជ្ឈង្គា មេត្តាយ ចេតោវិមុត្តិយា ពហុលីកម្មា[១] ហោន្តិ ឥមេហិ សត្តហិ ពោជ្ឈង្គេហិ មេត្តា ចេតោវិមុត្តិ ពហុលីករិយតិ ឥមេ សត្ត ពោជ្ឈង្គា មេត្តាយ ចេតោវិមុត្តិយា អលង្ការា ហោន្តិ ឥមេហិ សត្តហិ ពោជ្ឈង្គេហិ មេត្តា ចេតោវិមុត្តិ ស្វាលង្កតា ហោតិ ឥមេ សត្ត ពោជ្ឈង្គា មេត្តាយ ចេតោវិមុត្តិយា ប-រិក្ខារា ហោន្តិ ឥមេហិ សត្តហិ ពោជ្ឈង្គេហិ មេត្តា ចេតោវិមុត្តិ សុបរិក្ខតា ហោតិ ឥមេ សត្ត ពោជ្ឈង្គា មេត្តាយ ចេតោវិមុត្តិយា បរិវារា ហោន្តិ ឥមេហិ សត្តហិ ពោជ្ឈង្គេហិ មេត្តា ចេតោវិមុត្តិ សុបរិវុតា ហោតិ ឥមេ សត្ត ពោជ្ឈង្គា មេត្តាយ ចេតោវិមុត្តិយា អាសេវនា ហោន្តិ ភាវនា ហោន្តិ

---
១ ម. ពហុលីកតា ។

ពោជ្ឈង្គទាំង ៧ នេះ ជាទីសេពរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវពោជ្ឈង្គទាំង ៧ នេះ តែងសេព ពោជ្ឈង្គទាំង៧ នេះ ជាទីអប់រំរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវពោជ្ឈង្គទាំង ៧ នេះ តែងអប់រំ ពោជ្ឈង្គទាំង ៧ នេះ ជាទីធ្វើឲ្យច្រើន របស់មេត្តាចេតោវិមុត្តិ មេត្តា-ចេតោវិមុត្តិ ត្រូវពោជ្ឈង្គទាំង ៧ នេះ តែងធ្វើឲ្យច្រើន ពោជ្ឈង្គទាំង ៧ នេះ ជាគ្រឿងប្រដាប់ របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវពោជ្ឈង្គទាំង ៧ នេះ ស្អិតស្អាងល្អហើយ ពោជ្ឈង្គទាំង ៧ នេះ ជាបរិក្ខាររបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវពោជ្ឈង្គទាំង ៧ នេះ បិទបាំងហើយ ដោយប្រពៃ ពោជ្ឈង្គទាំង ៧ នេះ ជាបរិវារ របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវពោជ្ឈង្គទាំង ៧ នេះ ចោមរោមល្អហើយ ពោជ្ឈង្គទាំង ៧ នេះ ជាទីសេព ជាទីអប់រំ

ពហុលីកម្មា ហោន្តិ អលង្ការា ហោន្តិ បរិក្ខារា ហោន្តិ បរិវារា ហោន្តិ ចារិបូរី ហោន្តិ សហគតា ហោន្តិ សហជាតា ហោន្តិ សំសដ្ឋា ហោន្តិ សម្បយុត្តា ហោន្តិ បក្ខន្ទនា ហោន្តិ បសីទនា ហោន្តិ សន្តិដ្ឋនា ហោន្តិ វិមុច្ចនា ហោន្តិ ឯតំ សន្តន្តិ បស្សនា ហោន្តិ យានីកតា ហោន្តិ វត្ថុកតា ហោន្តិ អនុដ្ឋិតា ហោន្តិ បរិចិតា ហោន្តិ សុសមារទ្ធា ហោន្តិ សុភាវិតា ហោន្តិ ស្វាធិដ្ឋិតា ហោន្តិ សុសមុគ្គតា ហោន្តិ សុវិមុត្តា ហោន្តិ និព្វត្តេន្តិ ជោតេន្តិ បតាបេន្តិ ។

[៤១] សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សម្មា បស្សតិ សម្មាទិដ្ឋិបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សម្មាអភិនិរោបេតិ សម្មាសង្កប្បបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ

ជាទីធ្វើឲ្យច្រើន ជាគ្រឿងប្រដាប់ ជាបរិក្ខារ ជាបរិវាររបស់មេត្តាចេតោ-វិមុត្តិ ជាទីបំពេញ ជាធម៌ប្រព្រឹត្តជាមួយ កើតជាមួយ លាយ ផ្សំ ជាទីស្មុះទៅ ជាទីជ្រះថ្លា ជាធម៌តាំងនៅមាំ ជាធម៌ធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចទីតាំង ជាធម្មជាតតម្កល់មាំ សន្សំហើយ ប្រារព្ធល្អហើយ អប់រំល្អហើយ អធិដ្ឋានល្អហើយ អណ្តែតឡើងព្រម ផុតស្រឡះ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

[៥១] សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលឃើញដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាទិដ្ឋិ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលលើកចិត្ត (កាន់អារម្មណ៍) ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាសង្កប្បៈ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តី

សុខិនោ ហោន្តូតិ សម្មា បរិគ្គណ្ហាតិ សម្មាវាចាបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សម្មា សមុដ្ឋាបេតិ សម្មាកម្មន្តបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សម្មាវោទាបេតិ សម្មាអាជីវបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សម្មា បគ្គណ្ហាតិ សម្មាវាយាមបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សម្មា ឧបដ្ឋាបេតិ សម្មាសតិបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សម្មា សមាទហាតិ សម្មាសមាធិបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ឥមេ អដ្ឋ មគ្គង្គា មេត្តាយ ចេតោវិមុត្តិយា អាសេវនា ហោន្តិ ឥមេហិ អដ្ឋហិ មគ្គង្គេហិ មេត្តា ចេតោវិមុត្តិ អាសេវិយតិ

ក្សេម សូមមានសុខចុះ បុគ្គលកំណត់វាចា ដោយប្រពៃដូច្នេះ មេត្តា-ចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាវាចា សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលខ្នះខ្នែងដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់-រំហើយ ដោយសម្មាកម្មន្តៈ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គល (ញុំាងការចិញ្ចឹមជីវិត) ឲ្យផូរ-ផង់ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាអាជីវៈ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលផ្គង (ព្យាយាម) ដោយប្រពៃដូច្នេះ មេត្តា-ចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយសម្មាវាយាមៈ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលប្រុងស្មារតី ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាសតិ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលតាំងចិត្តមាំដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាសមាធិ អដ្ឋមគ្គទាំង ៨ នេះ ជាទីសេព របស់មេត្តា-ចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវអដ្ឋមគ្គទាំង ៨ នេះ តែងសេព

១០៩

## យុគនទ្ធវគ្គេ មេត្តាកថា

ឥមេ អដ្ឋ មគ្គង្គា មេត្តាយ ចេតោវិមុត្តិយា ភាវនា ហោន្តិ ឥមេហិ អដ្ឋហិ មគ្គង្គេហិ មេត្តា ចេតោ-វិមុត្តិ ភាវិយតិ ឥមេ អដ្ឋ មគ្គង្គា មេត្តាយ ចេតោវិ-មុត្តិយា ពហុលីកម្មា ហោន្តិ ឥមេហិ អដ្ឋហិ មគ្គង្គេហិ មេត្តា ចេតោវិមុត្តិ ពហុលីករិយតិ ឥមេ អដ្ឋ មគ្គង្គា មេត្តាយ ចេតោវិមុត្តិយា អលង្ការា ហោន្តិ ឥមេហិ អដ្ឋហិ មគ្គង្គេហិ មេត្តា ចេតោវិមុត្តិ ស្វាលង្កតា ហោតិ ឥមេ អដ្ឋ មគ្គង្គា មេត្តាយ ចេតោវិមុត្តិយា បរិក្ខារា ហោន្តិ ឥមេហិ អដ្ឋហិ មគ្គង្គេហិ មេត្តា ចេតោវិមុត្តិ សុបរិក្ខតា ហោតិ ឥមេ អដ្ឋ មគ្គង្គា មេត្តាយ ចេតោវិមុត្តិយា បរិវារា ហោន្តិ ឥមេហិ អដ្ឋហិ មគ្គង្គេហិ មេត្តា ចេតោ-វិមុត្តិ សុបរិវុតា ហោតិ ឥមេ អដ្ឋ មគ្គង្គា មេត្តា-យ ចេតោវិមុត្តិយា អាសេវនា ហោន្តិ ភាវនា ហោ-ន្តិ ពហុលីកម្មា ហោន្តិ អលង្ការា ហោន្តិ បរិក្ខារា ហោន្តិ បរិវារា ហោន្តិ បារិបូរី ហោន្តិ សហគតា ហោន្តិ សហជាតា ហោន្តិ សំសដ្ឋា ហោន្តិ

អដ្ឋមគ្គទាំង ៨ នេះ ជាទីអប់រំ របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវ អដ្ឋមគ្គទាំង ៨ នេះ តែងសេព អដ្ឋមគ្គទាំង ៨នេះ ជាទីចម្រើន របស់មេ-ត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវអដ្ឋមគ្គទាំង ៨ នេះ តែងចម្រើន អដ្ឋមគ្គទាំង ៨ នេះ ជាទីធ្វើឲ្យច្រើន របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវអដ្ឋមគ្គទាំង ៨ នេះ តែងធ្វើឲ្យច្រើន អដ្ឋមគ្គទាំង ៨ នេះ ជាគ្រឿងប្រដាប់ របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវអដ្ឋមគ្គទាំង ៨ នេះ ស្អិតស្អាងល្អហើយ អដ្ឋមគ្គទាំង ៨ នេះ ជាបរិក្ខារ របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវអដ្ឋមគ្គទាំង ៨ នេះ បិទបាំងហើយដោយប្រពៃ អដ្ឋមគ្គទាំង ៨ នេះ ជាបរិវាររបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវអដ្ឋមគ្គទាំង ៨ នេះ ចោមរោមល្អហើយ អដ្ឋមគ្គទាំង ៨ នេះ ជាទីសេព ជាទីអប់រំ ជាទីធ្វើឲ្យច្រើន ជាគ្រឿងប្រដាប់ ជាបរិក្ខារ ជាបរិវារ របស់មេត្តា-ចេតោវិមុត្តិ ជាទីបំពេញ ជាធម៌ប្រព្រឹត្តជាមួយ កើតជាមួយ លាយ ផ្សំ

សម្បយុត្តា ហោន្តិ បគ្ហដ្ឋជា ហោន្តិ បសីទជា ហោន្តិ សន្តិដ្ឋជា ហោន្តិ វិមុច្ចជា ហោន្តិ ឯតំ សន្តន្តិ បស្សជា ហោន្តិ យានីកតា ហោន្តិ វត្ថុកតា ហោន្តិ អនុដ្ឋិតា ហោន្តិ បរិចិតា ហោន្តិ សុសមារទ្ធា ហោន្តិ សុភាវិតា ហោន្តិ ស្វាធិដ្ឋិតា ហោន្តិ សុសមុគ្គតា ហោន្តិ សុវិមុត្តា ហោន្តិ និព្វត្តេន្តិ ជោតេន្តិ បតាបេន្តិ ។

[៨២] សព្វេសំ ចាណានំ... សព្វេសំ ភូតានំ សព្វេសំ បុគ្គលានំ សព្វេសំ អត្តភាវបរិយាបន្នានំ សព្វាសំ ឥត្ថីនំ សព្វេសំ បុរិសានំ សព្វេសំ អរិយានំ សព្វេសំ អនរិយានំ សព្វេសំ ទេវានំ សព្វេសំ មនុស្សានំ សព្វេសំ វិនិបាតិកានំ បីឡនំ វជ្ជេត្វា អបីឡនាយ ឧបឃាតំ វជ្ជេត្វា អនុបឃាតេន សន្តាបំ វជ្ជេត្វា អសន្តាបេន បរិយាទានំ វជ្ជេត្វា អបរិយាទានេន វិហេសំ វជ្ជេត្វា អវិហេសាយ សព្វេ វិនិបាតិកា អវេរិនោ ហោន្តុ មា វេរិនោ សុខិនោ ហោន្តុ មា ទុក្ខិនោ សុខិតត្តា ហោន្តុ

ជាទីស្ទុះទៅ ជាទីជ្រះថ្លា ជាធម៌តាំងនៅមាំ ជាធម៌រួចចាកកិលេស ជាទីឃើញច្បាស់ថា នេះជាធម្មជាតស្ងប់ ជាធម្មជាតធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចជាទីតាំង ជាធម្មជាតតម្កល់មាំ សន្សំហើយ ប្រារព្ធល្អហើយ អប់រំល្អហើយ អធិដ្ឋានល្អហើយ អណ្តែតឡើងព្រម ផុតស្រឡះ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

[៩២] ឈ្មោះថាមេត្តា ព្រោះជាធម្មជាតិប្រព្រឹត្តជាមិត្ត ចំពោះវិនិបាតទាំងអស់ ដោយអាការ ៨ នេះ គឺដោយការវៀរនូវការបៀតបៀន ហើយមិនបៀតបៀន ចំពោះសត្វមានជីវិតទាំងអស់ សត្វកើតហើយទាំងអស់ បុគ្គលទាំងអស់ សត្វដែលរាប់ថាមានអត្តភាពទាំងអស់ ស្រីទាំងអស់ ប្រុសទាំងអស់ អរិយៈទាំងអស់ ជនមិនមែនអរិយៈទាំងអស់ ទេវតាទាំងអស់ មនុស្សទាំងអស់ វិនិបាតទាំងអស់ ១ ដោយការវៀរនូវគំនុំហើយមិនគុំ ១ ដោយការវៀរនូវការផុតកម្តៅ ហើយមិនផុតកម្តៅ ១ ដោយការវៀរនូវការសង្កត់សង្កិន ហើយមិនសង្កត់សង្កិន ១ ដោយការវៀរនូវការធ្វើឲ្យលំបាក ហើយមិនធ្វើឲ្យលំបាក ១ ដោយការផ្សាយមេត្តាចិត្តថា សូមវិនិបាតទាំងអស់ ជាបុគ្គលគ្មានពៀរ កុំបីចងពៀរនឹងគ្នា ១ សូមមានសុខ កុំបីមានទុក្ខ ១ សូមមានខ្លួនដល់នូវសុខ

មា ទុក្ខិតត្តាតិ ឥមេហិ អដ្ឋហាការេហិ សព្វេ វិនិចាតិកោ មេត្តាយតីតិ មេត្តា តំ ធម្មំ ចេតយតីតិ ចេតោ សព្វព្យាចាទបរិយុដ្ឋានេហិ មុច្ចតីតិ វិមុត្តិ មេត្តា ច ចេតោវិមុត្តិ ចាតិ មេត្តា ចេតោវិមុត្តិ សព្វេ វិនិចាតិកា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សទ្ធាយ អធិមុច្ចតិ សទ្ធិន្ទ្រិយ-បរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ និព្វត្តេន្តិ ជោតេន្តិ បតាបេន្តិ ។

[៨៣] សព្វេសំ បុរត្ថិមាយ ទិសាយ សត្តានំ… សព្វេសំ បច្ឆិមាយ ទិសាយ សត្តានំ សព្វេសំ ឧត្តរាយ ទិសាយ សត្តានំ សព្វេសំ ទក្ខិ-ណាយ ទិសាយ សត្តានំ សព្វេសំ បុរត្ថិមាយ អនុទិសាយ សត្តានំ សព្វេសំ បច្ឆិមាយ អនុទិសាយ សត្តានំ សព្វេសំ ឧត្តរាយ អនុទិសាយ សត្តានំ សព្វេសំ ទក្ខិណាយ អនុទិសាយ សត្តានំ សព្វេ-សំ ហេដ្ឋិមាយ ទិសាយ សត្តានំ សព្វេសំ ឧបរិ-មាយ ទិសាយ សត្តានំ បីឡនំ វជ្ជេត្វា អបីឡនាយ ឧបឃាតំ វជ្ជេត្វា អនុបឃាតេន សន្តាបំ វជ្ជេត្វា អសន្តាបេន បរិយាទានំ វជ្ជេត្វា អបរិយាទានេន

កុំបីមានខ្លួនដល់នូវទុក្ខ ១ ឈ្មោះថាចេតោ ព្រោះជាសភាវៈគិតនូវធម៌នោះ ឈ្មោះថាវិមុត្តិ ព្រោះជាធម្មជាតិរួចចាកបរិយុដ្ឋានក្កិលេស គឺព្យាបាទ ចំពោះសត្វទាំងអស់ ឈ្មោះថាមេត្តាចេតោវិមុត្តិ ព្រោះមេត្តានិងចេតោ-វិមុត្តិ សូមវិនិបាតទាំងអស់ កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលជឿស៊ប់ដោយសទ្ធាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសទ្ធិន្ទ្រិយ ។ បេ ។ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្ដៅសព្វ ។

[៨៣] ឈ្មោះថាមេត្តា ព្រោះជាធម្មជាតិប្រព្រឹត្តជាមិត្ត ចំពោះសត្វទាំងអស់ក្នុងទិសខាងលើ ដោយអាការ ៨ នេះ គឺ ដោយការវៀរនូវការបៀតបៀនហើយមិនបៀតបៀន ចំពោះសត្វទាំងអស់ ក្នុងទិសខាងកើត សត្វទាំងអស់ក្នុងទិសខាងលិច សត្វទាំងអស់ក្នុងទិសខាងជើង សត្វទាំងអស់ក្នុងទិសខាងត្បូង សត្វទាំងអស់ក្នុងទិសអគ្នេយ៍ សត្វទាំងអស់ក្នុងទិសពាយ័ព្យ សត្វទាំងអស់ក្នុងទិសឦសាន សត្វទាំងអស់ក្នុងទិសនិរតី សត្វទាំងអស់ក្នុងទិសខាងក្រោម សត្វទាំងអស់ក្នុងទិសខាងលើ ១ ដោយការវៀរនូវគំនុំហើយមិនគុំ ១ ដោយការវៀរនូវការដុតកម្ដៅ ហើយមិនដុតកម្ដៅ ១ ដោយការវៀរនូវការសង្កត់សង្កិនហើយមិនសង្កត់សង្កិន ១

វិហេសំ វជ្ជេត្វា អវិហេសាយ សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរិនោ ហោន្តុ មា វេរិនោ សុខិនោ ហោន្តុ មា ទុក្ខិនោ សុខិតត្តា ហោន្តុ មា ទុក្ខិតត្តាតិ ឥមេហិ អដ្ឋហាការេហិ សព្វេ ឧបរិមាយ ទិសាយ សត្តេ មេត្តាយតីតិ មេត្តា តំ ធម្មំ ចេតយតីតិ ចេតោ សព្វព្យាបាទបរិយុដ្ឋានេហិ មុច្ចតីតិ វិមុត្តិ មេត្តា ច ចេតោវិមុត្តិ ចាតិ មេត្តាចេតោវិមុត្តិ សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សទ្ធាយ អធិមុច្ចតិ សទ្ធិន្ទ្រិយបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ និព្វត្តេន្តិ ជោតេន្តិ បតាបេន្តិ ។

[៥៤] សព្វេសំ បុរត្ថិមាយ ទិសាយ បាណានំ ភូតានំ បុគ្គលានំ អត្តភាវបរិយាបន្នានំ សព្វាសំ ឥត្ថីនំ សព្វេសំ បុរិសានំ សព្វេសំ អរិយានំ សព្វេសំ អនរិយានំ សព្វេសំ ទេវានំ សព្វេសំ មនុស្សានំ សព្វេសំ វិនិបាតិកានំ សព្វេសំ បច្ឆិមាយ ទិសាយ វិនិបាតិកានំ សព្វេសំ ឧត្តរាយ ទិសាយ

ដោយការវៀរនូវការធ្វើឲ្យលំបាក ហើយមិនធ្វើឲ្យលំបាក ១ ដោយការផ្សាយមេត្តាចិត្តថា សូមសត្វទាំងអស់ ក្នុងទិសខាងលើ ជាបុគ្គលគ្មានពៀរ កុំបីចងពៀរនឹងគ្នា ១ សូមមានសុខ កុំបីមានទុក្ខ ១ សូមមានខ្លួនដល់នូវសុខ កុំបីមានខ្លួនដល់នូវទុក្ខ ១ ឈ្មោះថាចេតោ ព្រោះជាសភាវៈគិតនូវធម៌នោះ ឈ្មោះថាវិមុត្តិ ព្រោះជាធម្មជាតិរួចចាកបរិយុដ្ឋានក្កិលេស គឺព្យាបាទចំពោះសត្វទាំងអស់ ឈ្មោះថាមេត្តាចេតោវិមុត្តិ ព្រោះមេត្តានិងចេតោ-វិមុត្តិ សូមសត្វទាំងអស់ ក្នុងទិសខាងលើ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលជឿស៊ប់ដោយសទ្ធាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសទ្ធិន្ទ្រិយ ។ បេ ។ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

[៩២] ឈ្មោះថាមេត្តា ព្រោះជាធម្មជាតិប្រព្រឹត្តជាមិត្ត ចំពោះវិនិបាតទាំងអស់ ក្នុងទិសខាងលើ ដោយអាការ ៨ នេះ គឺ ដោយការវៀរនូវការបៀតបៀនហើយមិនបៀតបៀន ចំពោះសត្វមានជីវិត សត្វកើតហើយ បុគ្គល សត្វដែលរាប់ថាមានអត្តភាពទាំងអស់ ស្រីទាំងអស់ ប្រុសទាំងអស់ ព្រះអរិយៈទាំងអស់ ជនមិនមែនព្រះអរិយៈទាំងអស់ ពួកទេវតាទាំងអស់ មនុស្សទាំងអស់ វិនិបាតទាំងអស់ ក្នុងទិសខាងកើត វិនិបាតទាំងអស់ ក្នុងទិសខាងលិច វិនិបាតទាំងអស់ ក្នុងទិសខាងជើង

១១៣



វិនិបាតិកានំ សព្វេសំ ទក្ខិណាយ ទិសាយ វិនិ-
បាតិកានំ សព្វេសំ បុរត្ថិមាយ អនុទិសាយ វិនិបា-
តិកានំ សព្វេសំ បច្ឆិមាយ អនុទិសាយ វិនិបាតិកានំ
សព្វេសំ ឧត្តរាយ អនុទិសាយ វិនិបាតិកានំ សព្វេ-
សំ ទក្ខិណាយ អនុទិសាយ វិនិបាតិកានំ សព្វេសំ
ហេដ្ឋិមាយ ទិសាយ វិនិបាតិកានំ សព្វេសំ ឧបរិ-
មាយ ទិសាយ វិនិបាតិកានំ បីឡនំ វជ្ជេត្វា អបីឡ-
នាយ ឧបឃាតំ វជ្ជេត្វា អនុបឃាតេន សន្តាបំ វជ្ជេត្វា
អសន្តាបេន បរិយាទានំ វជ្ជេត្វា អបរិយាទានេន វិហេ-
សំ វជ្ជេត្វា អវិហេសាយ សព្វេ ឧបរិមាយ ទិសាយ
វិនិបាតិកា អវេរិនោ ហោន្តុ មា វេរិនោ សុខិនោ
ហោន្តុ មា ទុក្ខិនោ សុខិតត្តា ហោន្តុ មា ទុក្ខិត-
ត្តាតិ ឥមេហិ អដ្ឋហាការេហិ សព្វេ ឧបរិមាយ
ទិសាយ វិនិបាតិកេ មេត្តាយតីតិ មេត្តា តំ ធម្មំ ចេត-
យតីតិ ចេតោ សព្វព្យាបាទបរិយុដ្ឋានេហិ មុច្ចតីតិ
វិមុត្តិ មេត្តា ច ចេតោវិមុត្តិ ចាតិ មេត្តា ចេតោវិមុត្តិ ។

យុគនទ្ធវគ្គ មេត្តាកថា

វិនិបាតទាំងអស់ ក្នុងទិសខាងត្បូង វិនិបាតទាំងអស់ ក្នុងទិសអគ្នេយ៍ វិនិបាតទាំងអស់ ក្នុងទិសពាយ័ព្យ វិនិបាតទាំងអស់ ក្នុងទិសឦសាន វិនិបាតទាំងអស់ ក្នុងទិសនិរតី វិនិបាតទាំងអស់ ក្នុងទិសខាងក្រោម វិនិបាតទាំងអស់ក្នុងទិសខាងលើ ១ ដោយការវៀរនូវគំនុំ ហើយមិនគុំ ១ ដោយការវៀរនូវការដុតកម្តៅ ហើយមិនដុតកម្តៅ ១ ដោយការវៀរនូវការសង្កត់សង្កិន ហើយមិនសង្កត់សង្កិន ១ ដោយការវៀរនូវការធ្វើឲ្យលំបាកហើយមិនធ្វើឲ្យលំបាក ១ ដោយការផ្សាយមេត្តាចិត្តថា សូមវិនិ-បាតទាំងអស់ ក្នុងទិសខាងលើ ជាបុគ្គលគ្មានពៀរ កុំបីចងពៀរនឹងគ្នា ១ សូមមានសុខ កុំបីមានទុក្ខ ១ សូមមានខ្លួនដល់នូវសុខ កុំបីមានខ្លួនដល់នូវទុក្ខ ១ ឈ្មោះថាចេតោ ព្រោះជាសភាវៈគិតនូវធម៌នោះ ឈ្មោះថាវិមុត្តិ ព្រោះជាធម្មជាតិរួចចាកបរិយុដ្ឋានកិលេស គឺព្យាបាទ ចំពោះសត្វទាំងអស់ ឈ្មោះថាមេត្តាចេតោវិមុត្តិ ព្រោះមេត្តានិងចេតោវិមុត្តិ ។

[៥៥] សព្វេ ឧបរិមាយ ទិសាយ វិទិថាតិកា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សទ្ធាយ អធិមុច្ចតិ សទ្ធិន្ទ្រិយបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ សព្វេ ឧបរិមាយ ទិសាយ វិទិថាតិកា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ វីរិយំ បគ្គណ្ហាតិ វីរិយិន្ទ្រិយបរិភាវិតា ហោតិ មេត្តា ចេ-តោវិមុត្តិ ។ បេ ។ សតឹ ឧបដ្ឋាបេតិ សតិន្ទ្រិយបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ ចិត្តំ សមាទ-ហាតិ សមាធិន្ទ្រិយបរិភាវិតា ហោតិ មេត្តា ចេតោ-វិមុត្តិ ។ បេ ។ បញ្ញាយ បជានាតិ បញ្ញិន្ទ្រិយបរិភា-វិតា ហោតិ មេត្តា ចេតោវិមុត្តិ ឥមានិ បញ្ចិ-ន្ទ្រិយានិ មេត្តាយ ចេតោវិមុត្តិយា អាសេវនា ហោន្តិ ឥមេហិ បញ្ចហិន្ទ្រិយេហិ មេត្តា ចេតោវិមុត្តិ អាសេវិយតិ ។ បេ ។ និព្វត្តេន្តិ ជោតេន្តិ បតាបេន្តិ ។

[៥៥] សូមវិនិបាតទាំងអស់ ក្នុងទិសខាងលើ កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលជឿស៊ប់ ដោយសទ្ធាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសទ្ធិន្ទ្រិយ សូមវិនិបាតទាំងអស់ ក្នុងទិសខាងលើ កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលផ្គងព្យាយាមដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយវីរិយិន្ទ្រិយ ។ បេ ។ បុគ្គលប្រុងស្មារតីដូច្នេះ មេត្តា-ចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសតិន្ទ្រិយ ។ បេ ។ បុគ្គលតម្កល់ចិត្តដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសមាធិន្ទ្រិយ ។ បេ ។ បុគ្គលដឹងច្បាស់ដោយប្រាជ្ញាដូច្នេះ មេត្តា-ចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយបញ្ញិន្ទ្រិយ ឥន្ទ្រិយទាំង ៥ នេះ ជាទីសេព របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវឥន្ទ្រិយទាំង ៥ នេះ តែងសេព ។ បេ ។ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

យុគនទ្ធវគ្គេ មេត្តាកថា

[៤៦] សព្វេ ឧបរិមាយ ទិសាយ វិនិបាតិកា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ អស្សទ្ធិយេ ន កម្បតិ សទ្ធាពលបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ កោសជ្ជេ ន កម្បតិ វីរិយពលបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ បមាទេ ន កម្បតិ សតិពលបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ ឧទ្ធច្ចេ ន កម្បតិ សមាធិពលបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ អវិជ្ជាយ ន កម្បតិ បញ្ញាពលបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ឥមានិ បញ្ច ពលានិ មេត្តាយ ចេតោវិមុត្តិយា អាសេវនា ហោន្តិ ឥមេហិ បញ្ចហិ ពលេហិ មេត្តា ចេតោវិមុត្តិ អាសេវិយតិ ។ បេ ។ និព្វត្តេន្តិ ជោតេន្តិ បតាបេន្តិ ។

យុគនទ្ធវគ្គ មេត្តាកថា

[៩៦] សូមវិនិបាតទាំងអស់ ក្នុងទិសខាងលើ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលមិនញាប់ញ័រ ព្រោះហេតុមិនគួរជឿដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសទ្ធាពលៈ ។ បេ ។ បុគ្គលមិនញាប់ញ័រ ព្រោះសេចក្តីខ្ជិលដូច្នេះ មេត្តា-ចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយវីរិយពលៈ ។ បេ ។ បុគ្គលមិនញាប់ញ័រ ព្រោះសេចក្តីប្រហែសដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសតិពលៈ ។ បេ ។ បុគ្គលមិនញាប់ញ័រ ព្រោះឧទ្ធច្ចៈដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសមាធិពលៈ ។ បេ ។ បុគ្គលមិនញាប់ញ័រ ព្រោះអវិជ្ជាដូច្នេះ មេត្តា-ចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយបញ្ញាពលៈ ពលៈទាំង ៥ នេះ ជាទីសេព របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវពលៈទាំង ៥ នេះ តែងសេព ។ បេ ។ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

[៨៧] សព្វេ ឧបរិមាយ ទិសាយ វិនិបាតិកា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សតី ឧបដ្ឋាបេតិ សតិសម្ពោជ្ឈង្គបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ បញ្ញាយ បវិចិនាតិ ធម្មវិចយសម្ពោជ្ឈង្គបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ វិរិយំ បគ្គណ្ហាតិ វិរិយសម្ពោជ្ឈង្គបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ បរិឡាហំ បដិប្បស្សម្ភេតិ បីតិសម្ពោជ្ឈង្គបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ ទុដ្ឋុល្លំ បដិប្បស្សម្ភេតិ បស្សទ្ធិសម្ពោជ្ឈង្គបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ ចិត្តំ សមាទហាតិ សមាធិសម្ពោជ្ឈង្គបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ ញាណេន កិលេសេ បដិសង្ខាតិ ឧបេក្ខាសម្ពោជ្ឈង្គបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ឥមេ សត្ត ពោជ្ឈង្គា មេត្តាយ ចេតោវិមុត្តិយា អាសេវនា ហោន្តិ ឥមេហិ សត្តហិ ពោជ្ឈង្គេហិ មេត្តា ចេតោវិមុត្តិ អាសេវិយតិ ។ បេ ។ និព្វត្តេន្តិ ជោតេន្តិ បតាបេន្តិ ។

[៩៧] សូមវិនិបាតទាំងអស់ ក្នុងទិសខាងលើ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលប្រុងស្មារតីដូច្នេះ មេត្តាចេតោ-វិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសតិសម្ពោជ្ឈង្គ ។ បេ ។ បុ-គ្គលពិចារណាដោយប្រាជ្ញាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយធម្មវិចយសម្ពោជ្ឈង្គ ។ បេ ។ បុគ្គលផ្គងព្យាយាមដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយវីរិយសម្ពោជ្ឈង្គ ។ បេ ។ បុគ្គលរម្ងាប់សេចក្តីក្តៅក្រហាយដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយបីតិសម្ពោជ្ឈង្គ ។ បេ ។ បុគ្គលរម្ងាប់សេចក្តីអាក្រក់ដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយបស្សទ្ធិសម្ពោជ្ឈង្គ ។ បេ ។ បុគ្គលតម្កល់ចិត្តមាំដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសមាធិសម្ពោជ្ឈង្គ ។ បេ ។ បុគ្គលពិចារណានូវកិលេស ដោយញាណដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយឧបេក្ខាសម្ពោជ្ឈង្គ ពោជ្ឈង្គទាំង ៧ នេះ ជាទីសេព របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវពោជ្ឈង្គទាំង ៧ នេះ តែងសេព ។ បេ ។ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

[៤៨] សព្វេ ឧបរិមាយ ទិសាយ វិនិចាតិកា អវេរិនោ ហោន្តុ ខេមិនោ ហោន្តុ សុខិនោ ហោន្តូតិ សម្មា បស្សតិ សម្មាទិដ្ឋិបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ សម្មា អភិនិរោបេតិ សម្មាសង្កប្បបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ សម្មា បរិគ្គណ្ហាតិ សម្មាវាចាបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ សម្មា សមុដ្ឋាបេតិ សម្មាកម្មន្តបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ សម្មា វោទាបេតិ សម្មាអាជីវបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ សម្មា បគ្គណ្ហាតិ សម្មាវាយាមបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ សម្មា ឧបដ្ឋាបេតិ សម្មាសតិបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ។ បេ ។ សម្មា សមាទិយតិ សម្មាសមាធិបរិភាវិតា ហោតិ មេត្តា ចេតោវិមុត្តិ ឥមេ អដ្ឋ មគ្គង្គា មេត្តាយ ចេតោវិមុត្តិយា អាសេវនា ហោន្តិ ឥមេហិ អដ្ឋហិ មគ្គង្គេហិ មេត្តា ចេតោវិមុត្តិ អាសេវិយតិ ។ បេ ។

យុគនទ្ធវគ្គ មេត្តាកថា

[៩៨] សូមវិនិបាតទាំងអស់ ក្នុងទិសខាងលើ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលឃើញ ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាទិដ្ឋិ ។ បេ ។ បុគ្គលលើកចិត្តកាន់អារម្មណ៍ ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាសង្កប្បៈ ។ បេ ។ បុគ្គលកំណាត់វាចា ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាវាចា ។ បេ ។ បុគ្គលខ្ជះខ្ជែងដោយប្រពៃដូច្នេះ មេត្តា-ចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាកម្មន្តៈ ។ បេ ។ បុគ្គល (ញ៉ាំងការចិញ្ចឹមជីវិត) ឲ្យផូរផង់ ដោយប្រពៃដូច្នេះ មេត្តាចេតោ-វិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាអាជីវៈ ។ បេ ។ បុគ្គលផ្គងព្យាយាម ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាវាយាមៈ ។ បេ ។ បុគ្គលប្រុង (ស្មារតី) ដោយប្រពៃ ដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាសតិ ។ បេ ។ បុគ្គលតម្កល់មាំ (នូវចិត្ត) ដោយប្រពៃ ដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះអប់រំហើយ ដោយសម្មាសមាធិ អដ្ឋមគ្គទាំង ៨ នេះ ជាទីសេព របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវអដ្ឋមគ្គទាំង ៨ នេះ តែងសេព ។ បេ ។

ឥមេ អដ្ឋ មគ្គង្គា មេត្តាយ ចេតោវិមុត្តិយា បរិវារា ហោន្តិ ឥមេហិ អដ្ឋហិ មគ្គង្គេហិ មេត្តា ចេតោវិមុត្តិ សុបរិវុតា ហោតិ ឥមេ អដ្ឋ មគ្គង្គា មេត្តាយ ចេតោវិមុត្តិយា អាសេវនា ហោន្តិ ភាវនា ហោន្តិ ពហុលីកម្មា ហោន្តិ អលង្ការា ហោន្តិ បរិក្ខារា ហោន្តិ បរិវារា ហោន្តិ ចារិបូរី ហោន្តិ សហគតា ហោន្តិ សហជា-តា ហោន្តិ សំសដ្ឋា ហោន្តិ សម្បយុត្តា ហោន្តិ បក្ខន្ទ-នា ហោន្តិ បសីទនា ហោន្តិ សន្តិដ្ឋនា ហោន្តិ វិមុច្ចនា ហោន្តិ ឯតំ សន្តន្តិ បស្សនា ហោន្តិ យានីកតា ហោន្តិ វត្ថុកតា ហោន្តិ អនុដ្ឋិតា ហោន្តិ បរិចិតា ហោន្តិ សុសមារទ្ធា ហោន្តិ សុភាវិតា ហោន្តិ ស្វាធិដ្ឋិតា ហោន្តិ សុសមុគ្គតា ហោន្តិ សុវិមុត្តា ហោន្តិ និព្វត្តេន្តិ ជោតេន្តិ បតាបេន្តិ ។

មេត្តាកថា ។

---

*អដ្ឋមគ្គទាំង ៨ នេះ ជាបរិវារ របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវអដ្ឋមគ្គទាំង ៨ នេះ ចោមរោមហើយ អដ្ឋមគ្គទាំង ៨ នេះ ជាទីសេព ជាទីអប់រំ ជាទីធ្វើឲ្យច្រើន ជាគ្រឿងប្រដាប់ ជាបរិក្ខារ ជាបរិវារ របស់មេត្តាចេតោវិមុត្តិ ជាទីបំពេញ ជាធម៌ប្រព្រឹត្តទៅជាមួយ កើតជាមួយ លាយ ផ្សំ ជាទីស្ទុះទៅ ជាទីជ្រះថ្លា ជាធម៌តាំងនៅមាំ ជាធម៌រួច (ចាកកិលេស) ជាគ្រឿងឃើញច្បាស់ថា នេះជាធម្មជាតស្ងប់ ជាធម្មជាតធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចជាទីតាំង ជាទីតម្កល់នៅមាំ សន្សំហើយ ប្រារព្ធល្អហើយ អប់រំល្អហើយ អធិដ្ឋានល្អហើយ អណ្តែតឡើងព្រម ផុតស្រឡះ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។*

ចប់ មេត្តាកថា ។

# យុគនទ្ធវគ្គេ វិរាគកថា

[៤៩] វិរាគោ មគ្គោ វិមុត្តិ ផលំ ។ កថំ វិរាគោ មគ្គោ ។ សោតាបត្តិមគ្គក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ មិច្ឆាទិដ្ឋិយា វិរជ្ជតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វិរជ្ជតិ ពហិទ្ធា ច សព្វនិមិត្តេហិ វិរជ្ជតិ វិរាគោ វិរាគារម្មណោ វិរាគគោចរោ វិរាគេ សមុទាគតោ[១] វិរាគេ ឋិតោ វិរាគេ បតិដ្ឋិតោ ។ វិរាគោតិ ទ្វេ វិរាគា និព្វានញ្ច វិរាគោ យេ ច និព្វានារម្មណាតា ជាតា ធម្មា សព្វេ ច[២] វិរាគា ហោន្តីតិ វិរាគោ[៣] សហជាតានិ សត្តង្គានិ វិរាគំ គច្ឆន្តីតិ វិរាគោ មគ្គោ ឯតេន មគ្គេន ពុទ្ធា ច សាវកា ច អគតំ ទិសំ និព្វានំ គច្ឆន្តីតិ អដ្ឋង្គិកោ មគ្គោ យាវតា បុថុសមណព្រាហ្មណានំ បរប្បវាទានំ មគ្គា អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ អគ្គោ ច សេដ្ឋោ ច វិមោក្ខោ[៤] ច ឧត្តមោ ច បវរោ ចាតិ មគ្គានំ អដ្ឋង្គិកោ សេដ្ឋោ ។

---

១ ឱ. ម. សមុទាគតោ ។ ២ ឱ. ម. ចាតិ បទំ នត្ថិ ។ ៣ ម. សព្វត្ថ វិរាគាតិ ទិស្សតិ ។ ៤ ឱ. ម. សព្វវារេសុ បាមោក្ខោតិ លិខិតំ ។

# យុគនទ្ធវគ្គ វិរាគកថា

[៥៩] វិរាគៈ ជាមគ្គ វិមុត្តិ ជាផល ។ វិរាគៈ ជាមគ្គ តើដូចម្តេច ។ ក្នុងខណៈនៃសោតាបត្តិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ រមែងណាយចាកមិច្ឆាទិដ្ឋិ ណាយចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិនោះផង ចាកខន្ធទាំងឡាយផង ណាយចាកនិមិត្តទាំងពួងខាងក្រៅផង វិរាគៈ មានការណាយជាអារម្មណ៍ មានការណាយជាគោចរ ប្រកបក្នុងការណាយ ឋិតនៅក្នុងការណាយ តម្កល់ស៊ប់ក្នុងការណាយ ។ ពាក្យថា វិរាគៈ បានដល់ វិរាគៈ ២ យ៉ាង វិរាគៈគឺនិព្វាន ១ វិរាគៈ គឺពួកធម៌ណាកើតហើយ ព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះ តែងមានសេចក្តីណាយ ១ វិរាគៈជាមគ្គ ព្រោះអង្គទាំង ៧ ដែលកើតជាមួយគ្នា រមែងដល់នូវការណាយ ផ្លូវប្រកបដោយអង្គ ៨ ឈ្មោះថាមគ្គ ព្រោះព្រះពុទ្ធទាំងឡាយ និងសាវ័កទាំងឡាយ តែងទៅកាន់ទិស ដែលគេមិនធ្លាប់ទៅ គឺនិព្វានដោយសារមគ្គនុ៎ះ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាមគ្គដ៏ខ្ពង់ខ្ពស់ ប្រសើរ វិសេសវិសាល ឧត្តម ថ្លៃថ្លា ជាងមគ្គរបស់ពួកសមណព្រាហ្មណ៍ច្រើននាក់ ដែលប្រកាន់លទ្ធិដទៃ ទាំងអម្បាលម៉ាន ហេតុនោះ មគ្គប្រកបអង្គ ៨ ប្រសើរជាងមគ្គទាំងឡាយ ។

អភិរោបនដ្ឋេន[១] សម្មាសង្កប្បោ មិច្ឆាសង្កប្បា វិមុច្ចតិ បរិគ្គហដ្ឋេន សម្មាវាចា មិច្ឆាវាចាយ វិមុច្ចតិ សមុដ្ឋានដ្ឋេន សម្មាកម្មន្តោ មិច្ឆាកម្មន្តា វិមុច្ចតិ វោទានដ្ឋេន សម្មាអាជីវោ មិច្ឆាអាជីវា វិមុច្ចតិ បគ្គហដ្ឋេន សម្មាវាយាមោ មិច្ឆាវាយាមា វិមុច្ចតិ ឧបដ្ឋានដ្ឋេន សម្មាសតិ មិច្ឆាសតិយា វិមុច្ចតិ អវិក្ខេបដ្ឋេន សម្មាសមាធិ មិច្ឆាសមាធិតោ វិមុច្ចតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វិមុច្ចតិ ពហិទ្ធា ច សព្វនិមិត្តេហិ វិមុច្ចតិ វិមោក្ខោ វិមោក្ខារម្មណោ វិមោក្ខគោចរេ វិមោក្ខេ សមុទាគតោ វិមោក្ខេ ឋិតោ វិមោក្ខេ បតិដ្ឋិតោ ។ វិមោក្ខោតិ ទ្វេ វិមោក្ខា និព្វានញ្ច វិមោក្ខោ យេ ច និព្វានារម្មណា ជាតា ធម្មា សព្វេ ច វិមោក្ខា ហោន្តីតិ វិមោក្ខោ សហជាតានិ សត្តង្គានិ វិមោក្ខំ គច្ឆន្តីតិ វិមោក្ខោ មគ្គោ ឯតេន មគ្គេន ពុទ្ធា ច សាវកា ច អគតំ ទិសំ និព្វានំ គច្ឆន្តីតិ

១ ម. អភិនិរោបនដ្ឋេន ។

សម្មាសង្កប្បៈ ដោយអត្ថថាលើកចិត្តឡើង (កាន់អារម្មណ៍) រមែងណាយចាកមិច្ឆាសង្កប្បៈ សម្មាវាចា ដោយអត្ថថាកំណត់ រមែងណាយចាកមិច្ឆាវាចា សម្មាកម្មន្តៈ ដោយអត្ថថាខ្នះខ្នែង រមែងណាយចាកមិច្ឆា-កម្មន្តៈ សម្មាអាជីវៈ ដោយអត្ថថាផូរផង់ រមែងណាយចាកមិច្ឆាអាជីវៈ សម្មាវាយាមៈ ដោយអត្ថថាផ្គងឡើង រមែងណាយចាកមិច្ឆាវាយាមៈ សម្មាសតិ ដោយអត្ថថាប្រុងប្រយ័ត្ន រមែងណាយចាកមិច្ឆាសតិ សម្មា-សមាធិ ដោយអត្ថថាមិនរាយមាយ រមែងណាយចាកមិច្ឆាសមាធិ រមែងណាយចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាសមាធិនោះផង ចាកខន្ធទាំងឡាយផង រមែងណាយ ចាកនិមិត្តទាំងពួងខាងក្រៅផង វិរាគៈ មានការណាយជាអារម្មណ៍ មានការណាយជាគោចរ ប្រកបក្នុងការណាយ ឋិតនៅក្នុងការណាយ តម្កល់ស៊ប់ក្នុងការណាយ ។ ពាក្យថា វិរាគៈ បានដល់វិរាគៈ ២ យ៉ាង វិរាគៈ គឺនិព្វាន ១ វិរាគៈ គឺពួកធម៌ណាកើតហើយ ព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះ តែងមានសេចក្ដីណាយ ១ វិរាគៈជាមគ្គ ព្រោះអង្គទាំង ៧ ដែលកើតជាមួយគ្នា រមែងដល់នូវការណាយ ផ្លូវប្រកបដោយអង្គ ៨ ឈ្មោះថាមគ្គ ព្រោះព្រះពុទ្ធទាំងឡាយ និងសាវ័កទាំងឡាយ តែងទៅកាន់ទិស ដែលគេមិនធ្លាប់ទៅ គឺព្រះនិព្វាន ដោយសារមគ្គនុ៎ះ

អដ្ឋង្គិកោ មគ្គោ យាវតា បុថុសមណព្រាហ្មណានំ បរប្បវាទានំ មគ្គា អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ អគ្គោ ច សេដ្ឋោ ច វិមោក្ខោ ច ឧត្តមោ ច បវរោ ចាតិ មគ្គានំ អដ្ឋង្គិកោ សេដ្ឋោ ។

[៦០] សកទាគាមិមគ្គក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធិ ឱឡារិកា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា ឱឡារិកា កាមរាគានុសយា បដិឃានុសយា វិរជ្ជតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វិរជ្ជតិ ពហិទ្ធា ច សព្វនិមិត្តេហិ វិរជ្ជតិ វិរាគោ វិរាគារម្មណោ វិរាគគោចរោ វិរាគេ សមុទាគតោ វិរាគេ ឋិតោ វិរាគេ បតិដ្ឋិតោ ។ វិរាគោតិ ទ្វេ វិរាគា និព្វានញ្ច វិរាគោ យេ ច និព្វានារម្មណតា ជាតា ធម្មា សព្វេ ច វិរាគា ហោន្តីតិ វិរាគោ សហជាតានិ សត្តង្គានិ វិរាគំ គច្ឆន្តីតិ វិរាគោ មគ្គោ ឯតេន មគ្គេន ពុទ្ធា ច សាវកា ច អគតំ ទិសំ និព្វានំ គច្ឆន្តីតិ អដ្ឋង្គិកោ មគ្គោ

មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាមគ្គដ៏ខ្ពង់ខ្ពស់ ប្រសើរ វិសេសវិសាល ឧត្តម ថ្លៃថ្លា ជាងមគ្គ របស់ពួកសមណព្រាហ្មណ៍ ច្រើននាក់ ដែលប្រកាន់លទ្ធិដទៃ ទាំងអម្បាលម៉ាន ហេតុនោះ មគ្គប្រកបដោយអង្គ ៨ ប្រសើរជាងមគ្គទាំងឡាយ ។

[៦០] ក្នុងខណៈនៃសកទាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ។ បេ ។ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងណាយ ចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈ ដ៏គ្រោតគ្រាត ចាក កាមរាគានុស័យ ចាកបដិឃានុស័យ ដ៏គ្រោតគ្រាត រមែងណាយចាក កិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមអនុស័យនោះផង ចាកខន្ធ ទាំងឡាយផង រមែងណាយ ចាកនិមិត្តទាំងពួងខាងក្រៅផង វិរាគៈ មានការណាយជាអារម្មណ៍ មានការណាយជាគោចរ ប្រកបក្នុងការ ណាយ ឋិតនៅក្នុងការណាយ តម្កល់ស៊ប់ក្នុងការណាយ ។ ពាក្យថា វិរាគៈ បានដល់វិរាគៈ ២ យ៉ាង វិរាគៈ គឺនិព្វាន ១ វិរាគៈ គឺពួកធម៌ ណាកើតហើយ ព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះ តែង មានសេចក្ដីណាយ ១ វិរាគៈជាមគ្គ ព្រោះអង្គ ៧ ដែលកើតជាមួយគ្នា រមែងដល់នូវការណាយ ផ្លូវប្រកបដោយអង្គ ៨ ឈ្មោះថាមគ្គ ព្រោះ ព្រះពុទ្ធទាំងឡាយ និងសាវ័កទាំងឡាយ តែងទៅកាន់ទិស ដែលគេមិន ធ្លាប់ទៅ គឺព្រះនិព្វាន ដោយសារមគ្គនុ៎ះ មគ្គប្រកបដោយអង្គ ៨ ដ៏

យាវតា បុថុសមណព្រាហ្មណានំ បរប្បវាទានំ មគ្គា អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ អគ្គោ ច សេដ្ឋោ ច វិមោក្ខោ ច ឧត្តមោ ច បវរោ ចាតិ មគ្គានំ អដ្ឋង្គិកោ សេដ្ឋោ ។

[៦១] អនាគាមិមគ្គក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធិ អណុសហគតា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា អណុសហគតា កាមរាគានុសយា បដិឃានុសយា វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ វិរាគោ វិរាគារម្មណោ ។បេ។ មគ្គានំ អដ្ឋង្គិកោ សេដ្ឋោ ។

[៦២] អរហត្តមគ្គក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធិ រូបរាគា អរូបរាគា មានា ឧទ្ធច្ចា អវិជ្ជាយ មានានុសយា ភវរាគានុសយា អវិជ្ជានុសយា វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ

ប្រសើរនេះឯង ជាមគ្គដ៏ខ្ពង់ខ្ពស់ ប្រសើរវិសេសវិសាល ឧត្តម ថ្លៃថ្លា ជាងមគ្គរបស់ពួកសមណព្រាហ្មណ៍ជាច្រើននាក់ ដែលប្រកាន់លទ្ធិដទៃទាំងអម្បាលម៉ាន ហេតុនោះ មគ្គប្រកបដោយអង្គ ៨ ប្រសើរ ជាងមគ្គទាំងឡាយ ។

[៦១] ក្នុងខណៈនៃអនាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ ។ បេ ។ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងណាយចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈដ៏ល្អិត ចាកកាមរាគានុស័យ ចាកបដិឃានុស័យ ដ៏ល្អិត ណាយចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមអនុស័យនោះផង ចាកខន្ធទាំងឡាយផង ណាយចាកនិមិត្តទាំងពួងខាងក្រៅផង វិរាគៈ មានការណាយជាអារម្មណ៍ ។ បេ ។ មគ្គប្រកបដោយអង្គ ៨ ប្រសើរជាងមគ្គទាំងឡាយ ។

[៦២] ក្នុងខណៈនៃអរហត្តមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ ។ បេ ។ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងណាយចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ណាយចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមអនុស័យនោះផង ចាកខន្ធទាំងឡាយផង ណាយចាកនិមិត្តទាំងពួងខាងក្រៅផង

យុគនទ្ធវគ្គេ វិរាគកថា

វិរាគោ វិរាគារម្មណោ វិរាគគោចរោ វិរាគេ សមុទាគតោ វិរាគេ ឋិតោ វិរាគេ បតិដ្ឋិតោ ។ វិរាគោតិ ទ្វេ វិរាគា និព្វានញ្ច វិរាគោ យេ ច និព្វានារម្មណតា ជាតា ធម្មា សព្វេ ច វិរាគា ហោន្តីតិ វិរាគោ សហជាតានិ សត្តង្គានិ វិរាគំ គច្ឆន្តីតិ វិរាគោ មគ្គោ ឯតេន មគ្គេន ពុទ្ធា ច សាវកា ច អគតំ ទិសំ និព្វានំ គច្ឆន្តីតិ អដ្ឋង្គិកោ មគ្គោ យាវតា បុថុសមណព្រាហ្មណានំ បរប្បវាទានំ មគ្គា អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ អគ្គោ ច សេដ្ឋោ ច វិមោក្ខោ ច ឧត្តមោ ច បវរោ ចាតិ មគ្គានំ អដ្ឋង្គិកោ សេដ្ឋោ ។

[៦៣] ទស្សនវិរាគោ សម្មាទិដ្ឋិ អភិរោបនវិរាគោ សម្មាសង្កប្បោ បរិគ្គហវិរាគោ សម្មាវាចា សមុដ្ឋានវិរាគោ សម្មាកម្មន្តោ វោទានវិរាគោ សម្មាអាជីវោ បគ្គហវិរាគោ សម្មាវាយាមោ ឧបដ្ឋានវិរាគោ សម្មាសតិ អវិក្ខេបវិរាគោ សម្មាសមាធិ ឧបដ្ឋានវិរាគោ

វិរាគៈមានការណាយជាអារម្មណ៍ មានការណាយជាគោចរ ប្រកបក្នុងការណាយ ឋិតនៅក្នុងការណាយ តម្កល់ស៊ប់ក្នុងការណាយ ។ ពាក្យថា វិរាគៈ បានដល់វិរាគៈ ២ យ៉ាង វិរាគៈ គឺនិព្វាន ១ វិរាគៈ គឺពួកធម៌ណាកើតហើយ ព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះ តែងមានសេចក្ដីណាយ ១ វិរាគៈជាមគ្គ ព្រោះអង្គទាំង ៧ ដែលកើតជាមួយគ្នា រមែងដល់នូវការណាយ ផ្លូវប្រកបដោយអង្គ ៨ ឈ្មោះថាមគ្គ ព្រោះព្រះពុទ្ធទាំងឡាយនិងសាវ័កទាំងឡាយ រមែងទៅកាន់ទិសដែលគេមិនធ្លាប់ទៅ គឺនិព្វាន ដោយសារមគ្គនុ៎ះ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាមគ្គដ៏ខ្ពង់ខ្ពស់ ប្រសើរ វិសេសវិសាល ឧត្តម ថ្លៃថ្លាជាងមគ្គ របស់ពួកសមណព្រាហ្មណ៍ច្រើននាក់ ដែលប្រកាន់លទ្ធិដទៃទាំងអម្បាលម៉ាន ហេតុនោះ មគ្គប្រកបដោយអង្គ ៨ ប្រសើរ ជាងមគ្គទាំងឡាយ ។

[៦៣] សម្មាទិដ្ឋិ មានការឃើញជាវិរាគៈ សម្មាសង្កប្បៈ មានការលើកចិត្តឡើងជាវិរាគៈ សម្មាវាចា មានការកំណត់ជាវិរាគៈ សម្មាកម្មន្តៈ មានការខ្ជះខ្ជែងជាវិរាគៈ សម្មាអាជីវៈ មានការផូរផង់ជាវិរាគៈ សម្មាវាយាមៈ មានការផ្គងឡើងជាវិរាគៈ សម្មាសតិ មានការប្រុងប្រយ័ត្នជាវិរាគៈ សម្មាសមាធិ មានការមិនរាយមាយជាវិរាគៈ

សតិសម្ពោជ្ឈង្គោ បវិចយវិភគោ ធម្មវិចយសម្ពោជ្ឈង្គោ បគ្គហវិភគោ វីរិយសម្ពោជ្ឈង្គោ ផរណវិភគោ បីតិសម្ពោជ្ឈង្គោ ឧបសមវិភគោ បស្សទ្ធិសម្ពោជ្ឈង្គោ អវិក្ខេបវិភគោ សមាធិសម្ពោជ្ឈង្គោ បដិសង្ខានវិភគោ ឧបេក្ខាសម្ពោជ្ឈង្គោ អស្សទ្ធិយេ អកម្បិយវិភគោ សទ្ធាពលំ កោសជ្ជេ អកម្បិយវិភគោ វីរិយពលំ បមាទេ អកម្បិយវិភគោ សតិពលំ ឧទ្ធច្ចេ អកម្បិយវិភគោ សមាធិពលំ អវិជ្ជាយ អកម្បិយវិភគោ បញ្ញាពលំ អធិមោក្ខវិភគោ សទ្ធិន្ទ្រិយំ បគ្គហវិភគោ វីរិយិន្ទ្រិយំ ឧបដ្ឋានវិភគោ សតិន្ទ្រិយំ អវិក្ខេបវិភគោ សមាធិន្ទ្រិយំ ទស្សនវិភគោ បញ្ញិន្ទ្រិយំ អាធិបតេយ្យដ្ឋេន ឥន្ទ្រិយា វិភគោ អកម្បិយដ្ឋេន ពលា វិភគោ និយ្យានដ្ឋេន ពោជ្ឈង្គា វិភគោ ហេតដ្ឋេន មគ្គោ វិភគោ ឧបដ្ឋានដ្ឋេន សតិប្បដ្ឋានា វិភគោ បធានដ្ឋេន សម្មប្បធានា វិភគោ

សតិសម្ពោជ្ឈង្គ មានការប្រុងប្រយ័ត្នជាវិវេកៈ ធម្មវិចយសម្ពោជ្ឈង្គ មានការពិចារណា ជាវិវេកៈ វីរិយសម្ពោជ្ឈង្គ មានការផ្គងឡើងជាវិវេកៈ បីតិ-សម្ពោជ្ឈង្គ មានការផ្សាយទៅជាវិវេកៈ បស្សទ្ធិសម្ពោជ្ឈង្គ មានការស្ងប់ជាវិវេកៈ សមាធិសម្ពោជ្ឈង្គ មានការមិនរាយមាយជាវិវេកៈ ឧបេ-ក្ខាសម្ពោជ្ឈង្គ មានការពិចារណាជាវិវេកៈ សទ្ធាពលៈ មានការមិនញាប់ញ័រព្រោះការណ៍មិនគួរជឿជាវិវេកៈ វីរិយពលៈ មានការមិនញាប់ញ័រព្រោះសេចក្តីខ្ជិលច្រអូសជាវិវេកៈ សតិពលៈ មានការមិនញាប់ញ័រព្រោះការប្រហែសជាវិវេកៈ សមាធិពលៈ មានការមិនញាប់ញ័រ ព្រោះឧទ្ធច្ចៈជាវិវេកៈ បញ្ញាពលៈ មានការមិនញាប់ញ័រ ព្រោះអវិជ្ជាជាវិវេកៈ សទ្ធិន្ទ្រិយ មានការជឿស៊ប់ជាវិវេកៈ វីរិយិន្ទ្រិយ មានការផ្គងឡើងជាវិវេកៈ សតិន្ទ្រិយ មានការប្រុងប្រយ័ត្នជាវិវេកៈ សមាធិន្ទ្រិយ មានការមិនរាយមាយជាវិវេកៈ បញ្ញិន្ទ្រិយ មានការឃើញជាវិវេកៈ ឥន្ទ្រិយទាំងឡាយដោយអត្ថថាជាអធិបតី ឈ្មោះថាវិវេកៈ ពលៈទាំងឡាយ ដោយអត្ថថាមិនញាប់ញ័រ ឈ្មោះថាវិវេកៈ ពោជ្ឈង្គទាំងឡាយ ដោយអត្ថថាចេញ (ចាកវដ្តៈ) ឈ្មោះថាវិវេកៈ មគ្គ ដោយអត្ថថាជាហេតុ ឈ្មោះថាវិវេកៈ សតិប្បដ្ឋានទាំងឡាយ ដោយអត្ថថាប្រុងប្រយ័ត្ន ឈ្មោះថាវិវេកៈ សម្មប្បធានទាំងឡាយ ដោយអត្ថថាតម្កល់មាំ ឈ្មោះថាវិវេកៈ

ឥជ្ឈនដ្ឋេន ឥទ្ធិបាទា វិរាគោ តថដ្ឋេន សច្ចា វិរាគោ អវិក្ខេបដ្ឋេន សមថោ វិរាគោ អនុបស្សនដ្ឋេន វិបស្សនា វិរាគោ ឯករសដ្ឋេន សមថវិបស្សនា វិរាគោ អនតិវត្តនដ្ឋេន យុគនទ្ធំ វិរាគោ សំវរដ្ឋេន សីលវិសុទ្ធិ វិរាគោ អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ វិរាគោ ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ វិរាគោ វិមុត្តដ្ឋេន វិមោក្ខោ វិរាគោ បដិវេធដ្ឋេន វិជ្ជា វិរាគោ បរិច្ចាគដ្ឋេន វិមុត្តិ វិរាគោ សមុច្ឆេទដ្ឋេន ខយេ ញាណំ វិរាគោ ឆន្ទោ មូលដ្ឋេន វិរាគោ មនសិការោ សមុដ្ឋានដ្ឋេន វិរាគោ ផស្សោ សមោធានដ្ឋេន វិរាគោ វេទនា សមោសរណដ្ឋេន វិរាគោ សមាធិ បមុខដ្ឋេន វិរាគោ សតិ អាធិបតេយ្យដ្ឋេន វិរាគោ បញ្ញា តទុត្តរដ្ឋេន វិរាគោ វិមុត្តិ សារដ្ឋេន វិរាគោ[១] ទស្សនមគ្គោ សម្មាទិដ្ឋិ អភិរោបនមគ្គោ សម្មាសង្កប្បោ ។ បេ ។ អមតោគធំ និព្វានំ បរិយោសានដ្ឋេន មគ្គោ ឯវំ វិរាគោ មគ្គោ ។

---

១ ម. ឯត្ថន្តរេ អមតោគធំ និព្វានំ បរិយោសានដ្ឋេន មគ្គោតិ ទិស្សតិ ។

ឥទ្ធិបាទដោយអត្ថថាសម្រេច ឈ្មោះថាវិរាគៈ សច្ចៈទាំងឡាយ ដោយអត្ថថាទៀងទាត់ ឈ្មោះថាវិរាគៈ សមថៈ ដោយអត្ថថាមិនរាយមាយ ឈ្មោះថាវិរាគៈ វិបស្សនា ដោយអត្ថថាពិចារណាឃើញ ឈ្មោះថាវិរាគៈ សមថៈ និង វិបស្សនា ដោយអត្ថថាមានកិច្ចតែមួយ ឈ្មោះថាវិរាគៈ យុគនទ្ធធម៌ (ធម៌ជាប់គ្នាជាគូ) ដោយអត្ថថាមិនប្រព្រឹត្តកន្លងគ្នា ឈ្មោះថាវិរាគៈ សីលវិសុទ្ធិ ដោយអត្ថថាសង្រួម ឈ្មោះថាវិរាគៈ ចិត្តវិសុទ្ធិ ដោយអត្ថថាមិនរាយមាយ ឈ្មោះថាវិរាគៈ ទិដ្ឋិវិសុទ្ធិ ដោយអត្ថថាឃើញ ឈ្មោះថា វិរាគៈ វិមោក្ខៈ ដោយអត្ថថារួចស្រឡះ ឈ្មោះថាវិរាគៈ វិជ្ជា ដោយអត្ថថាចាក់ធ្លុះ ឈ្មោះថាវិរាគៈ វិមុត្តិ ដោយអត្ថថាលះស្រឡះ ឈ្មោះថាវិរាគៈ ខយញ្ញាណ ដោយអត្ថថាកាត់ផ្តាច់ ឈ្មោះថាវិរាគៈ ឆន្ទៈ ដោយអត្ថថាជាមូល ឈ្មោះថាវិរាគៈ មនសិការៈ ដោយអត្ថថាតាំងឡើងព្រម ឈ្មោះថាវិរាគៈ ផស្សៈ ដោយអត្ថថាចួបជុំ ឈ្មោះថាវិរាគៈ វេទនា ដោយអត្ថថាប្រជុំចុះ ឈ្មោះថាវិរាគៈ សមាធិ ដោយអត្ថថាជាប្រធាន ឈ្មោះថាវិរាគៈ សតិ ដោយអត្ថថាជាអធិបតី ឈ្មោះថាវិរាគៈ បញ្ញា ដោយអត្ថថាក្រៃលែងជាងធម៌ទាំងនោះ ឈ្មោះថាវិរាគៈ វិមុត្តិ ដោយអត្ថថាជាខ្លឹម ឈ្មោះថាវិរាគៈ សម្មាទិដ្ឋិ មានការឃើញជាមគ្គ សម្មាសង្កប្បៈ មានការលើកចិត្តឡើងជាមគ្គ ។ បេ ។ អមតនិព្វាន ដោយអត្ថថាជាទីបំផុត នៃកិច្ចក្នុងសាសនា ឈ្មោះថាមគ្គ វិរាគៈជាមគ្គយ៉ាងនេះឯង ។

[៦៤] កថំ វិមុត្តិ ផលំ ។ សោតាបត្តិផលក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ មិច្ឆាទិដ្ឋិយា វិមុត្តា ហោតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វិមុត្តា ហោតិ ពហិទ្ធា ច សព្វនិមិត្តេហិ វិមុត្តា ហោតិ វិមុត្តិ វិមុត្តារម្មណា វិមុត្តិគោចរា វិមុត្តិយា សមុទាគតា វិមុត្តិយា ឋិតា វិមុត្តិយា បតិដ្ឋិតា ។ វិមុត្តីតិ ទ្វេ វិមុត្តិយោ និព្វានញ្ច វិមុត្តិ យេ ច និព្វានារម្មណតា ជាតា ធម្មា សព្វេ ច វិមុត្តា ហោន្តីតិ វិមុត្តិ ផលំ អភិរោបនដ្ឋេន សម្មាសង្កប្បោ មិច្ឆាសង្កប្បា វិមុត្តោ ហោតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វិមុត្តោ ហោតិ ពហិទ្ធា ច សព្វនិមិត្តេហិ វិមុត្តោ ហោតិ វិមុត្តិ វិមុត្តារម្មណា វិមុត្តិគោចរា វិមុត្តិយា សមុទាគតា វិមុត្តិយា ឋិតា វិមុត្តិយា បតិដ្ឋិតា ។ វិមុត្តីតិ ទ្វេ វិមុត្តិយោ និព្វានញ្ច វិមុត្តិ យេ ច និព្វានារម្មណតា ជាតា ធម្មា សព្វេ ច វិមុត្តា ហោន្តីតិ វិមុត្តិ ផលំ បរិគ្គហដ្ឋេន[១] សម្មាវាចា មិច្ឆាវាចាយ វិមុត្តា ហោតិ ។ បេ ។

---

១ ម. បគ្គហដ្ឋេន ។

[៦៤] វិមុត្តិ ជាផល តើដូចម្ដេច ។ ក្នុងខណៈនៃសោតាបត្តិផល សម្មាទិដ្ឋិ ដោយអត្ថថាឃើញ ជាធម្មជាតិផុតស្រឡះ ចាកមិច្ឆាទិដ្ឋិ ផុតស្រឡះចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិនោះផង ចាកខន្ធទាំងឡាយផង ផុតស្រឡះចាកនិមិត្តទាំងពួងខាងក្រៅផង វិមុត្តិ មានការផុតស្រឡះជាអារម្មណ៍ មានការផុតស្រឡះជាគោចរ ប្រកប ក្នុងការផុតស្រឡះ បិតនៅក្នុងការផុតស្រឡះ តម្កល់ស៊ប់ក្នុងការផុត ស្រឡះ ។ ពាក្យថា វិមុត្តិ បានដល់វិមុត្តិ ២ យ៉ាង វិមុត្តិ គឺនិព្វាន ១ វិមុត្តិ ជាផល គឺពួកធម៌ណាកើតហើយ ព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះតែងរួចស្រឡះ ១ សម្មាសង្កប្បៈ ដោយអត្ថថាលើកចិត្ត ឡើង ជាធម្មជាតផុតស្រឡះចាកមិច្ឆាសង្កប្បៈ ផុតស្រឡះចាកកិលេស ទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាសង្កប្បៈនោះផង ចាកខន្ធទាំង-ឡាយផង ផុតស្រឡះចាកនិមិត្តទាំងពួងខាងក្រៅផង វិមុត្តិ មាន ការផុតស្រឡះជាអារម្មណ៍ មានការផុតស្រឡះជាគោចរ ប្រកប ក្នុងការផុតស្រឡះ បិតនៅក្នុងការផុតស្រឡះ តម្កល់ស៊ប់ក្នុងការ ផុតស្រឡះ ។ ពាក្យថា វិមុត្តិ បានដល់វិមុត្តិ ២ យ៉ាង វិមុត្តិ គឺនិព្វាន ១ វិមុត្តិ ជាផល គឺ ពួកធម៌ណាកើតហើយ ព្រោះមាននិព្វាន ជាអារម្មណ៍ ធម៌ទាំងអស់នោះ តែងរួចស្រឡះ ១ សម្មាវាចា ដោយអត្ថថាកំណត់ ជាធម្មជាតិរួចស្រឡះ ចាកមិច្ឆាវាចា ។ បេ ។

សមុដ្ឋានដ្ឋេន សម្មាកម្មន្តោ មិច្ឆាកម្មន្តា វិមុត្តោ ហោតិ វោទានដ្ឋេន សម្មាអាជីវោ មិច្ឆាអាជីវា វិមុត្តោ ហោតិ បគ្គហដ្ឋេន សម្មាវាយាមោ មិច្ឆាវាយាមា វិមុ-ត្តោ ហោតិ ឧបដ្ឋានដ្ឋេន សម្មាសតិ មិច្ឆាសតិយា វិមុត្តា ហោតិ អវិក្ខេបដ្ឋេន សម្មាសមាធិ មិច្ឆាសមាធិ-តោ វិមុត្តោ ហោតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេ-ហិ ច វិមុត្តោ ហោតិ ពហិទ្ធា ច សព្វនិមិត្តេហិ វិមុត្តោ ហោតិ វិមុត្តិ វិមុត្តារម្មណា វិមុត្តិគោចរា វិមុត្តិយា សមុទាគតា វិមុត្តិយា ឋិតា វិមុត្តិយា បតិដ្ឋិតា ។ វិមុត្តីតិ ទ្វេ វិមុត្តិយោ និព្វានញ្ច វិមុត្តិ យេ ច និព្វានារម្មណា ជាតា ធម្មា សព្វេ ច វិមុត្តា ហោន្តីតិ វិមុត្តិ ផលំ ។

[៦៨] សកទាគាមិផលក្ខណេ ទស្សនដ្ឋេន សម្មា-ទិដ្ឋិ ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធិ ឱឡារិកា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា ឱឡារិកា

សម្មាកម្មន្តៈ ដោយអត្ថថាខ្ទះខ្ទែង ផុតស្រឡះចាកមិច្ឆាកម្មន្តៈ សម្មាអាជីវៈ ដោយអត្ថថាផូរផង់ ផុតស្រឡះចាកមិច្ឆាអាជីវៈ សម្មាវាយាមៈ ដោយអត្ថថាផ្គងឡើង ផុតស្រឡះចាកមិច្ឆាវាយាមៈ សម្មាសតិ ដោយអត្ថថាប្រុងប្រយ័ត្ន ផុតស្រឡះចាកមិច្ឆាសតិ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ ផុតស្រឡះចាកមិច្ឆាសមាធិ ផុតស្រឡះចាកកិលេសទាំង-ឡាយដែលប្រព្រឹត្តទៅតាមមិច្ឆាសមាធិនោះផង ចាកខន្ធទាំងឡាយផង ផុតស្រឡះចាកនិមិត្តទាំងពួងខាងក្រៅផង វិមុត្តិ មានការផុតស្រឡះជាអារម្មណ៍ មានការផុតស្រឡះជាគោចរ ប្រកបក្នុងការផុតស្រឡះ ឋិតនៅក្នុងការផុតស្រឡះ តម្កល់ស៊ប់ ក្នុងការផុតស្រឡះ ។ ពាក្យថា វិមុត្តិ បានដល់វិមុត្តិ ២ យ៉ាង វិមុត្តិ គឺនិព្វាន ១ វិមុត្តិ ជាផល គឺ ពួកធម៌ណាកើតហើយ ព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះ តែងផុតស្រឡះ ១ ។

[៦៥] ក្នុងខណៈនៃសកទាគាមិផល សម្មាទិដ្ឋិ ដោយអត្ថថាឃើញ ។ បេ ។ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងផុតស្រឡះចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈ ដ៏គ្រោតគ្រាត

កាមរាគានុសយា បដិឃានុសយា វិមុត្តោ ហោតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វិមុត្តោ ហោតិ ពហិទ្ធា ច សព្វនិមិត្តេហិ វិមុត្តោ ហោតិ វិមុត្តិ វិមុត្តារម្មណា វិមុត្តិគោចរា វិមុត្តិយា សមុទាគតា វិមុត្តិយា ឋិតា វិមុត្តិយា បតិដ្ឋិតា ។ វិមុត្តីតិ ទ្វេ វិមុត្តិយោ និព្វានញ្ច វិមុត្តិ យេ ច និព្វានារម្មណតា ជាតា ធម្មា សព្វេ ច វិមុត្តា ហោន្តីតិ វិមុត្តិ ផលំ ។

[៦៦] អនាគាមិផលក្ខណេ ទស្សនដ្ឋេន សម្មា-ទិដ្ឋិ ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធិ អណុ-សហគតា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា អណុសហគតា កាមរាគានុសយា បដិឃានុសយា វិមុត្តោ ហោតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វិមុត្តោ ហោតិ ពហិទ្ធា ច សព្វនិមិត្តេហិ វិមុត្តោ ហោតិ វិមុត្តិ វិមុត្តារម្មណា វិមុត្តិគោ-ចរា វិមុត្តិយា សមុទាគតា វិមុត្តិយា ឋិតា វិមុត្តិ-យា បតិដ្ឋិតា ។ បេ ។

ចាកកាមរាគានុស័យ ចាកបដិឃានុស័យ ដ៏គ្រោតគ្រាត ផុតស្រឡះចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមអនុស័យនោះផង ចាកខន្ធទាំងឡាយផង ផុតស្រឡះចាកនិមិត្តទាំងពួងខាងក្រៅផង វិមុត្តិ មានការផុតស្រឡះជាអារម្មណ៍ មានការផុតស្រឡះជាគោចរ ប្រកបក្នុងការផុតស្រឡះ ឋិតនៅក្នុងការផុតស្រឡះ តម្កល់ស៊ប់ក្នុងការផុតស្រឡះ ។ ពាក្យថា វិមុត្តិ បានដល់វិមុត្តិ ២ យ៉ាង វិមុត្តិ គឺនិព្វាន ១ វិមុត្តិ ជាផល គឺពួកធម៌ណាកើតហើយ ព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះ តែងផុតស្រឡះ១ ។

[៦៦] ក្នុងខណៈនៃអនាគាមិផល សម្មាទិដ្ឋិ ដោយអត្ថថាឃើញ ។ បេ ។ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងផុតស្រឡះចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈ ដ៏ល្អិត ចាកកាមរាគានុស័យ ចាកបដិឃានុស័យ ដ៏ល្អិត ផុតស្រឡះចាកកិលេសទាំងឡាយដែលប្រព្រឹត្តទៅតាមអនុស័យនោះផង ចាកខន្ធទាំងឡាយផង ផុតស្រឡះចាកនិមិត្តទាំងពួងខាងក្រៅផង វិមុត្តិ មានការផុតស្រឡះជាអារម្មណ៍ មានការផុតស្រឡះជាគោចរ ប្រកបក្នុងការផុតស្រឡះ ឋិតនៅក្នុងការផុតស្រឡះ តម្កល់ស៊ប់ក្នុងការផុតស្រឡះ ។ បេ ។

១២៩

យុគនទ្ធវគ្គេ វិរាគកថា

[៦៧] អរហត្តផលក្ខណេ ទស្សនដ្ឋេន សម្មា-ទិដ្ឋិ ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធិ រូប-រាគា អរូបរាគា មានា ឧទ្ធច្ចា អវិជ្ជាយ មានានុ-សយា ភវរាគានុសយា អវិជ្ជានុសយា វិមុត្តោ ហោតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វិមុត្តោ ហោតិ ពហិទ្ធា ច សព្វនិមិត្តេហិ វិមុត្តោ ហោតិ វិ-មុត្តិ វិមុត្តារម្មណា វិមុត្តិគោចរា វិមុត្តិយា សមុទាគ-តា វិមុត្តិយា ឋិតា វិមុត្តិយា បតិដ្ឋិតា ។ វិមុត្តីតិ ទ្វេ វិមុត្តិយោ និព្វានញ្ច វិមុត្តិ យេ ច និព្វា-នារម្មណតា ជាតា ធម្មា សព្វេ ច វិមុត្តា ហោ-ន្តីតិ វិមុត្តិ ផលំ ។

[៦៨] ទស្សនវិមុត្តិ សម្មាទិដ្ឋិ ។ បេ ។ អវិក្ខេបវិមុត្តិ សម្មាសមាធិ ឧបដ្ឋានវិមុត្តិ សតិសម្ពោជ្ឈង្គោ ។ បេ ។ បដិសង្ខានវិមុត្តិ ឧបេក្ខាសម្ពោជ្ឈង្គោ អស្សទ្ធិយេ អក-ម្បិយវិមុត្តិ សទ្ធាពលំ ។ បេ ។ អវិជ្ជាយ អកម្បិយ-វិមុត្តិ បញ្ញាពលំ អធិមោក្ខវិមុត្តិ សទ្ធិន្ទ្រិយំ ។ បេ ។

[៦៧] ក្នុងខណៈនៃអរហត្តផល សម្មាទិដ្ឋិ ដោយអត្ថថាឃើញ ។ បេ ។ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងផុតស្រឡះចាករូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ រមែងផុតស្រឡះចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមអនុស័យនោះផង ចាកខន្ធទាំងឡាយផង ផុតស្រឡះចាកនិមិត្តទាំងពួងខាងក្រៅផង វិមុត្តិ មានការផុតស្រឡះជាអារម្មណ៍ មានការផុតស្រឡះជាគោចរ ប្រកបក្នុងការផុតស្រឡះ ឋិតនៅក្នុងការផុតស្រឡះ តម្កល់ស៊ប់ក្នុងការផុតស្រឡះ ។ ពាក្យថា វិមុត្តិ បានដល់វិមុត្តិ ២ យ៉ាង វិមុត្តិ គឺនិព្វាន ១ វិមុត្តិ ជាផល គឺពួកធម៌ណាកើតហើយព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះ តែងរួចស្រឡះ ១ ។

[៦៨] សម្មាទិដ្ឋិ មានការឃើញជាវិមុត្តិ ។ បេ ។ សម្មាសមាធិ មានការមិនរាយមាយជាវិមុត្តិ សតិសម្ពោជ្ឈង្គ មានការប្រុងប្រយ័ត្នជាវិមុត្តិ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ មានការពិចារណាជាវិមុត្តិ សទ្ធាពលៈ មានការមិនញាប់ញ័រព្រោះការណ៍មិនគួរជឿជាវិមុត្តិ ។ បេ ។ បញ្ញាពលៈ មានការមិនញាប់ញ័រព្រោះអវិជ្ជាជាវិមុត្តិ សទ្ធិន្ទ្រិយ មានការជឿស៊ប់ជា

ទស្សនវិមុត្តិ បញ្ញិន្ទ្រិយំ ។ អាធិបតេយ្យដ្ឋេន ឥន្ទ្រិយា វិមុត្តិ អកម្បិយដ្ឋេន ពលា វិមុត្តិ និយ្យានដ្ឋេន ពោជ្ឈង្គា វិមុត្តិ ហេតដ្ឋេន មគ្គោ វិមុត្តិ ឧបដ្ឋានដ្ឋេន សតិប្បដ្ឋានា វិមុត្តិ បទហនដ្ឋេន សម្មប្បធានា វិមុត្តិ ឥជ្ឈនដ្ឋេន ឥទ្ធិបាទា វិមុត្តិ តថដ្ឋេន សច្ចា វិមុត្តិ អវិក្ខេបដ្ឋេន សមថោ វិមុត្តិ អនុបស្សនដ្ឋេន វិបស្សនា វិមុត្តិ ឯករសដ្ឋេន សមថវិបស្សនា វិមុត្តិ អនតិវត្តនដ្ឋេន យុគនទ្ធំ វិមុត្តិ សំវរដ្ឋេន សីលវិសុទ្ធិ វិមុត្តិ អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ វិមុត្តិ ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ វិមុត្តិ វិមុត្តដ្ឋេន វិមោក្ខោ វិមុត្តិ បដិវេធដ្ឋេន វិជ្ជា វិមុត្តិ បរិច្ចាគដ្ឋេន វិមុត្តិ វិមុត្តិ បដិប្បស្សទ្ធដ្ឋេន អនុប្បាទេ ញាណំ វិមុត្តិ[១] ។ ឆន្ទោ មូលដ្ឋេន វិមុត្តិ មនសិការោ សមុដ្ឋានវិមុត្តិ

---

១ ឱ. សមុច្ឆេទដ្ឋេន ខយេ ញាណំ វិមុត្តិ ។ ម. បដិបស្សទ្ធិយដ្ឋេន អនុប្បាទេ ញាណំ វិមុត្តិ ។

វិមុត្តិ ។ បេ ។ បញ្ញិន្ទ្រិយ មានការឃើញជាវិមុត្តិ ឥន្ទ្រិយ ដោយអត្ថថាជាអធិបតី ឈ្មោះថាវិមុត្តិ ពលៈទាំងឡាយ ដោយអត្ថថាមិនញាប់ញ័រ ឈ្មោះថាវិមុត្តិ ពោជ្ឈង្គទាំងឡាយ ដោយអត្ថថាចេញ(ចាកវដ្តៈ) ឈ្មោះថាវិមុត្តិ មគ្គ ដោយអត្ថថាជាហេតុ ឈ្មោះវិមុត្តិ សតិប្បដ្ឋានទាំងឡាយ ដោយអត្ថថាប្រុងប្រយ័ត្ន ឈ្មោះថាវិមុត្តិ សម្មប្បធានទាំងឡាយ ដោយអត្ថថាតម្កល់មាំ ឈ្មោះថាវិមុត្តិ ឥទ្ធិបាទទាំងឡាយ ដោយអត្ថថាសម្រេច ឈ្មោះថាវិមុត្តិ សច្ចៈទាំងឡាយ ដោយអត្ថថាទៀងទាត់ ឈ្មោះថាវិមុត្តិ សមថៈ ដោយអត្ថថាមិនរាយមាយ ឈ្មោះថាវិមុត្តិ វិបស្សនា ដោយអត្ថថាពិចារណាឃើញ ឈ្មោះថាវិមុត្តិ សមថៈនិងវិបស្សនា ដោយអត្ថថាមានកិច្ចតែមួយ ឈ្មោះថាវិមុត្តិ យុគនទ្ធធម៌ ដោយអត្ថថាមិនប្រព្រឹត្តកន្លងគ្នា ឈ្មោះថាវិមុត្តិ សីលវិសុទ្ធិ ដោយអត្ថថាសង្រួម ឈ្មោះថាវិមុត្តិ ចិត្តវិសុទ្ធិ ដោយអត្ថថាមិនរាយមាយ ឈ្មោះថាវិមុត្តិ ទិដ្ឋិវិសុទ្ធិ ដោយអត្ថថាឃើញ ឈ្មោះថាវិមុត្តិ វិមោក្ខៈ ដោយអត្ថថាផុតស្រឡះ ឈ្មោះថាវិមុត្តិ វិជ្ជា ដោយអត្ថថាចាក់ធ្លុះ ឈ្មោះថាវិមុត្តិ វិមុត្តិ ដោយអត្ថថាលះស្រឡះ ឈ្មោះថាវិមុត្តិ អនុប្បាទញ្ញាណ (ការដឹងក្នុងការមិនកើត) ដោយអត្ថថារម្ងាប់ ឈ្មោះថាវិមុត្តិ ។ ឆន្ទៈ ដោយអត្ថថាជាមូល ឈ្មោះថាវិមុត្តិ មនសិការៈ ដោយអត្ថថាតាំងឡើងព្រម ឈ្មោះថាវិមុត្តិ

១៣១

យុគនទ្ធវគ្គេ វិភាគកថា

ផស្សោ សមោធានដ្ឋេន វិមុត្តិ វេទនា សមោសរណដ្ឋេន វិមុត្តិ សមាធិ បមុខដ្ឋេន វិមុត្តិ សតិ អាធិបតេយ្យដ្ឋេន វិមុត្តិ បញ្ញា តទុត្តរដ្ឋេន វិមុត្តិ វិមុត្តិ សារដ្ឋេន វិមុត្តិ អមតោគធំ និព្វានំ បរិយោសានដ្ឋេន វិមុត្តិ ឯវំ វិមុត្តិ ផលំ ឯវំ វិភាគោ មគ្គោ វិមុត្តិ ផលន្តិ ។

វិភាគកថា ។

## ១៣១

យុគនទ្ធវគ្គ វិរាគកថា

ផស្សៈ ដោយអត្ថថាជួបជុំ ឈ្មោះថាវិមុត្តិ វេទនា ដោយអត្ថថាប្រជុំចុះ ឈ្មោះថាវិមុត្តិ សមាធិ ដោយអត្ថថាជាប្រធាន ឈ្មោះថាវិមុត្តិ សតិ ដោយអត្ថថាជាអធិបតី ឈ្មោះថាវិមុត្តិ បញ្ញា ដោយអត្ថថាក្រៃលែងជាងធម៌ទាំងនោះ ឈ្មោះថាវិមុត្តិ វិមុត្តិ ដោយអត្ថថាជាខ្លឹម ឈ្មោះថាវិមុត្តិ អមតនិព្វាន ដោយអត្ថថាជាទីបំផុតនៃកិច្ចក្នុងសាសនា ឈ្មោះថាវិមុត្តិ វិមុត្តិជាផល យ៉ាងនេះឯង វិរាគៈជាមគ្គ វិមុត្តិ ជាផល យ៉ាងនេះឯង ។

ចប់ វិរាគកថា ។

---

# យុគនទ្ធវគ្គេ បដិសម្ភិទាកថា

[៦៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា ។ កតមេ ទ្វេ យោ ចាយំ កាមេសុ កាមសុខល្លិកានុយោគោ ហីនោ គម្មោ ពោថុជ្ជនិកោ អនរិយោ អនត្ថសញ្ហិតោ យោ ចាយំ អត្តកិលមថានុយោគោ ទុក្ខោ អនរិយោ អនត្ថសញ្ហិតោ ឯតេ តេ ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។

# យុគនទ្ធវគ្គ បដិសម្ភិទាកថា

[៦៩] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងបញ្ចវគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អន្តធម៌[១] (ធម៌ជាទីបំផុត ឬធម៌អម) ពីរនេះ បព្វជិតមិនគួរសេពគប់ឡើយ ។ អន្តធម៌ពីរ តើដូចម្តេច សេចក្តីព្យាយាមប្រកបខ្លួនទុកក្នុងកាមសុខ ក្នុងវត្ថុកាមទាំងឡាយ (កាមសុខល្លិកានុយោគ) ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ១ សេចក្តីព្យាយាមប្រកបខ្លួនឲ្យលំបាក (អត្តកិលមថានុយោគ) ជាធម៌នាំមកនូវទុក្ខ មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ១ ម្នាលភិក្ខុទាំងឡាយ ឯមជ្ឈិមាបដិបទា (សេចក្តីប្រតិបត្តិជាកណ្តាល) មិនប៉ះពាល់នូវអន្តធម៌ ទាំងពីរនុ៎ះទេ តថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅ ដើម្បីសេចក្តីរម្ងាប់ (កិលេស) ដើម្បីស្គាល់ (នូវអរិយសច្ច) ដើម្បីត្រាស់ដឹង (នូវអរិយសច្ច) ដើម្បីនិព្វាន ។

---

១ ធម៌ គឺសេចក្តីប្រតិបត្តិធូរពេកនិងតឹងពេក ចាត់ទុកថាជាធម៌ទីបំផុតខាងដើមនិងខាងចុង នៃមជ្ឈិមាបដិបទា ឬចាត់ទុកថាជាធម៌អម នៃមជ្ឈិមាបដិបទា ហេតុនោះ ទើបឈ្មោះថាអន្តធម៌ ។

កាតមា ច សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករ-ណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេ-យ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មា-កម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ អយំ ខោ សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញា-ណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។

[៧០] ឥទំ ខោ បន ភិក្ខវេ ទុក្ខំ អរិយ-សច្ចំ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា ព្យាធិបិ ទុ-ក្ខោ[១] មរណម្បិ ទុក្ខំ អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ ទុក្ខោ យម្បិច្ឆំ ន លភតិ តំបិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា[២] ទុក្ខា ។

១ ឱ. ទុក្ខា ។ ២ ឱ. បញ្ចុបាទានក្ខន្ធាបិ ។

ម្នាលភិក្ខុទាំងឡាយ ចុះមជ្ឈិមាបដិបទានោះ ដែលតថាគតត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ទាំងធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីរម្ងាប់ ដើម្បីស្គាល់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន តើដូចម្តេច អរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង គឺសេចក្តីឃើញត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ ស្មារតីត្រូវ ១ ការតម្កល់ចិត្តត្រូវ ១ (ឈ្មោះថាមជ្ឈិមាបដិបទា) ។ ម្នាលភិក្ខុទាំងឡាយ មជ្ឈិមា-បដិបទានេះឯង ដែលតថាគតត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ទាំងធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីរម្ងាប់ ដើម្បីស្គាល់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។

[៧០] ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាទុក្ខអរិយសច្ច គឺជាតិជាទុក្ខ ១ ជរាជាទុក្ខ ១ ព្យាធិជាទុក្ខ ១ មរណៈជាទុក្ខ ១ ការប្រសព្វចូលនូវសត្វនិងសង្ខារ មិនជាទីស្រឡាញ់ ជាទុក្ខ ១ សេចក្តីព្រាត់ប្រាស ចាកសត្វនិងសង្ខារជាទីស្រឡាញ់ ជាទុក្ខ ១ បុគ្គលប្រាថ្នាវត្ថុណាមិនបាន ការមិនបានវត្ថុនោះតាមសេចក្តីប្រាថ្នា នោះក៏ជាទុក្ខ ១ បើពោលដោយសេចក្តីសង្ខេប ឧបាទានក្ខន្ធទាំង ៥ ជាទុក្ខ ១ ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខសមុទយោ[១] អរិយសច្ចំ
យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រ
តត្រាភិនន្ទិនី សេយ្យថីទំ កាមតណ្ហា ភវតណ្ហា
វិភវតណ្ហា ។ ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធោ[២]
អរិយសច្ចំ យោ តស្សាយេវ តណ្ហាយ អសេសវិ-
រាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាល-
យោ ។ ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធគាមិនី
បដិបទា អរិយសច្ចំ អយមេវ អរិយោ អដ្ឋង្គិកោ
មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។

[៧១] ឥទំ ទុក្ខំ អរិយសច្ចន្តិ មេ ភិក្ខវេ
បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញា-
ណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អា-
លោកោ ឧទបាទិ ។ តំ ខោ បនិទំ ទុក្ខំ អ-
រិយសច្ចំ បរិញ្ញេយ្យន្តិ មេ ភិក្ខវេ ។ បេ ។

១ ឱ. ទុក្ខសមុទយំ ។ ២ ឱ. ទុក្ខនិរោធំ ។

ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាទុក្ខសមុទយអរិយសច្ច គឺតណ្ហា ជាធម្មជាតិនាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីរីករាយ និងសេចក្តីត្រេកត្រអាល ជាធម្មជាតិនាំសត្វឲ្យត្រេកត្រអាល ក្នុងភពនោះ ៗ (ឬក្នុងអារម្មណ៍នោះៗ) បានដល់កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាទុក្ខនិរោធអរិយសច្ច គឺបានខាងនិព្វានធម៌ ជាសភាវៈនឿយណាយនិងការរលត់ មិនមានសេសសល់ ជាសភាវៈលះបង់ គ្រវែងចោល ជម្រុះចោល មិនអាល័យ នូវតណ្ហានុ៎ះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច បានខាងអរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង គឺសេចក្តីឃើញត្រូវ ១ ។ បេ ។ ការតម្កល់ចិត្តត្រូវ ១ ។

[៧១] ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ជាទុក្ខអរិយសច្ច ដែលតថាគតគួរកំណត់ដឹង ។ បេ ។

បរិញ្ញាតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

ឥទំ ទុក្ខសមុទយោ[១] អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វន្តិ មេ ភិក្ខវេ ។ បេ ។ បហីនន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

ឥទំ ទុក្ខនិរោធោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ មេ ភិក្ខវេ ។ បេ ។

១ ឱ. ទុក្ខសមុទយំ ។

ថា នេះ ជាទុក្ខអរិយសច្ច ដែលតថាគតកំណត់ដឹងហើយ ។

ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ជាទុក្ខសមុទយ-អរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ជាទុក្ខសមុទយអរិយសច្ច ដែលតថាគតគួរលះ ។ បេ ។ ថា នេះ ជាទុក្ខសមុទយអរិយសច្ច ដែលតថាគតលះបង់ហើយ ។

ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ជាទុក្ខនិ-រោធអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮ ក្នុងកាលមុន ថា នេះ ជាទុក្ខនិរោធអរិយសច្ច ដែលតថាគតគួរធ្វើឲ្យជាក់ច្បាស់ ។ បេ ។

សច្ឆិកាតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

ឥទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវេតព្វន្តិ មេ ភិក្ខវេ ។ បេ ។ ភាវិតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

ថា នេះ ជាទុក្ខនិរោធអរិយសច្ច ដែលតថាគត បានធ្វើឲ្យជាក់ច្បាស់ហើយ ។

ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះ ជាទុក្ខនិរោធគាមិនីបដិទាអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដែលតថាគតគួរចម្រើន ។ បេ ។ ថា នេះ ជាទុក្ខនិរោធគាមិនីបដិបទា-អរិយសច្ច ដែលតថាគតបានចម្រើនហើយ ។

១៣៧

### យុគនទ្ធវគ្គេ បដិសម្ភិទាកថា

[៧២] យាវកីវញ្ច មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្ដំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ ន សុវិសុទ្ធំ អហោសិ នេវតាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ។ យតោ ច ខោ មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្ដំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ សុវិសុទ្ធំ អហោសិ អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ។

យុគនទ្ធវគ្គ បដិសម្ភិទាកថា

[៧២] ម្នាលភិក្ខុទាំងឡាយ តាមការណ៍ពិត តថាគត មានទស្សនកិច្ច គឺការដឹងតាមពិត ក្នុងអរិយសច្ចទាំង ៤ នេះ ដែលជាញាណមានបរិវដ្ដៈ[១] ៣ មានអាការ[២] ១២ យ៉ាងនេះ បើនៅពុំទាន់បរិសុទ្ធល្អ រហូតកាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ កាលត្រឹមណោះ តថាគតក៏ពុំទាន់ប្ដេជ្ញាខ្លួន ថាជាអ្នកត្រាស់ដឹងចំពោះ នូវសម្មាសម្ពោធិញ្ញាណ ដ៏ប្រសើរ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស នៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែតថាគត មានទស្សនកិច្ចគឺការដឹងតាមពិត ក្នុងអរិយសច្ចទាំង ៤ ដែលជាញាណមានបរិវដ្ដៈ ៣ មានអាការ ១២ យ៉ាងនេះ បរិសុទ្ធល្អហើយ ក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ តថាគត ទើបហ៊ានប្ដេជ្ញាខ្លួន ថាជាអ្នកត្រាស់ដឹងចំពោះ នូវសម្មាសម្ពោធិញ្ញាណ ដ៏ប្រសើរ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ។

---

១- បរិវដ្ដៈ ៣ គឺសច្ចញ្ញាណ ១ កិច្ចញ្ញាណ ១ កតញ្ញាណ ១ ។ ២- បរិវដ្ដៈ ៣ នេះឯង វិលទៅដូចជាចក្រក្នុងសច្ចៈទាំង ៤ គឺក្នុងទុក្ខអរិយសច្ច ៣ ទុក្ខសមុទយអរិយសច្ច ៣ ទុក្ខនិរោធអរិយសច្ច ៣ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ៣ ផ្សំគ្នា ជា ១២ ។

ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ ចេតោវិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុន-ព្ភវោតិ ។ ឥទមវោច ភគវា អត្តមនា បញ្ចវគ្គិយា ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ អាយស្មតោ កោណ្ឌញ្ញស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធ-ធម្មន្តិ ។ បវត្តិតេ ច[១] ភគវតា ធម្មចក្កេ ភុម្មា ទេវា សទ្ទមនុស្សាវេសុំ ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ ។ ភុម្មានំ ទេវានំ សទ្ទំ សុត្វា ចាតុម្មហារាជិកា ។ បេ ។

១ ឱ. ច បនាតិ បទំ ទិស្សតិ ។

មួយទៀត តថាគត មានទស្សនកិច្ចគឺការដឹង កើតឡើងដូច្នេះថា ចេតោ-វិមុត្តិ (អរហត្តផល) របស់តថាគត មិនកម្រើកទេ ជាតិនេះ ផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មី របស់តថាគត មិនមានឡើយ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះហើយ បញ្ចវគ្គិយភិក្ខុ ក៏ត្រេកអររីក-រាយ ចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ក៏កាលដែលព្រះមានព្រះភាគ កំពុងសម្តែងវេយ្យាករណ៍នេះ ធម្មចក្ខុ (សោតាបត្តិមគ្គ) ដ៏ប្រាសចាកធូលី គឺរាគាទិក្កិលេស ប្រាសចាកមន្ទិល គឺទិដ្ឋិនិងវិចិកិច្ឆា បានកើតហើយ ដល់កោណ្ឌញ្ញភិក្ខុមានអាយុថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ សេចក្តីពិសេសថា កាលព្រះធម្មចក្រ ដែលព្រះមានព្រះភាគឲ្យប្រព្រឹត្តទៅ គឺទ្រង់សម្តែងដូចគេបង្វិលកង់យ៉ាងនេះហើយ ភុម្មទេវតាទាំងឡាយ បានញុំាងសំឡេងឲ្យលាន់ឮឡើងដូច្នេះថា ព្រះធម្មចក្រនុ៎ះ មិនមានចក្រដទៃក្រៃលែងជាងទេ ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ជនណានីមួយក្តី ក្នុងលោក មិនអាចនឹងឲ្យប្រព្រឹត្តទៅបានឡើយ (ឥឡូវ) ព្រះមានព្រះភាគទ្រង់ឲ្យប្រព្រឹត្តទៅបានហើយ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ ពួកទេវតានៅក្នុងឋានចាតុម្មហារាជិក ឮសំឡេងរបស់ពួកភុម្មទេវតា ។ បេ ។

១៣៩



តាវត្តឹសា ទេវា យាមា ទេវា តុសិតា ទេវា និម្មានរតី ទេវា បរនិម្មិតវសវត្តី ទេវា ព្រហ្មកាយិកា ទេវា សទ្ទមនុស្សាវេសុំ ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ ។

ឥតិហ តេន ខណេន តេន លយេន តេន មុហុត្តេន យាវ ព្រហ្មលោកា សទ្ទោ អព្ភុគ្គច្ឆិ ។ អយញ្ច ទសសហស្សី លោកធាតុ សង្កម្បិ សម្បកម្បិ សម្បវេធិ អប្បមាណោ ច ឱឡារោ ឱភាសោ លោកេ បាតុរហោសិ អតិក្កម្មេវ ទេវានំ ទេវានុភាវន្តិ ។

អថខោ ភគវា ឧទានំ ឧទានេសិ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោតិ ឥតិហិទំ អាយស្មតោ កោណ្ឌញ្ញស្ស អញ្ញាកោណ្ឌញ្ញោត្វេវ នាមំ(១) អហោសិ ។

១ ឱ. អញ្ញាតកោណ្ឌញ្ញោត្វេវ នាមំ ។ ម. អញ្ញាសិកោណ្ឌញ្ញោត្វេវ នាមំ ។

ពួកទេវតា នៅក្នុងឋានតាវត្តិង្ស ពួកទេវតានៅក្នុងឋានយាមៈ ពួកទេវតានៅក្នុងឋានតុសិតៈ ពួកទេវតានៅក្នុងឋាននិម្មានរតី ពួកទេវតានៅក្នុងឋានបរនិម្មិតវសវត្តី ពួកទេវតាក្នុងព្រហ្ម បានញុំាំងសំឡេងឲ្យលាន់ឮឡើងដូច្នេះថា ព្រះធម្មចក្រនុ៎ះ មិនមានចក្រដទៃ ក្រៃលែងជាងទេ ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ជនណានីមួយក្តី ក្នុងលោក មិនអាចនឹងឲ្យប្រព្រឹត្តទៅបានឡើយ (ឥឡូវ) ព្រះមានព្រះភាគ ទ្រង់ឲ្យប្រព្រឹត្តទៅបានហើយ ក្នុងឥសិបតនមិគទាយវ័នជិតក្រុងពារាណសី ។

ក្នុងខណៈនោះ ក្នុងមួយស្របក់នោះ ក្នុងមួយរំពេចនោះ សំឡេង (កងរំពង) ក៏លាន់ឮឡើងទៅរហូតដល់ព្រហ្មលោក ដោយអាការលាន់ឮតៗគ្នានោះឯង ។ ឯលោកធាតុទាំងមួយហ្មឺននេះ ក៏កក្រើក រំពើកញាប់ញ័រ ទាំងពន្លឺភ្លឺធំទូលាយ ប្រមាណមិនបាន កន្លងលើសទេវានុភាពរបស់ទេវតាទាំងឡាយ បានកើតប្រាកដឡើង ក្នុងលោក ។

លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់បន្លឺនូវឧទានវាចាថា អើហ្ន៎ កោណ្ឌញ្ញៈ បានដឹងហើយ អើហ្ន៎ កោណ្ឌញ្ញៈ បានដឹងហើយ ព្រោះហេតុនោះ ពាក្យថា អញ្ញាកោណ្ឌញ្ញៈ នេះឯង ក៏បានជាប់មកជានាមរបស់ព្រះកោណ្ឌញ្ញភិក្ខុ មានអាយុ ។

[៧៣] ឥទំ ទុក្ខំ អរិយសច្ចន្តិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ ចក្ខុំ ឧទបាទីតិ កេនដ្ឋេន ញាណំ ឧទបាទីតិ កេនដ្ឋេន បញ្ញា ឧទបាទីតិ កេនដ្ឋេន វិជ្ជា ឧទបាទីតិ កេនដ្ឋេន អាលោកោ ឧទបាទីតិ កេនដ្ឋេន ។ ចក្ខុំ ឧទបាទីតិ ទស្សនដ្ឋេន ញាណំ ឧទបាទីតិ ញាតដ្ឋេន បញ្ញា ឧទបាទីតិ បជាននដ្ឋេន វិជ្ជា ឧទបាទីតិ បដិវេធដ្ឋេន អាលោកោ ឧទបាទីតិ ឱភាសដ្ឋេន ។

ចក្ខុំ ធម្មោ ញាណំ ធម្មោ បញ្ញា ធម្មោ វិជ្ជា ធម្មោ អាលោកោ ធម្មោ ឥមេ បញ្ច ធម្មា ធម្មប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្សា អារម្មណា តេ តស្សា គោចរា យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុច្ចតិ ធម្មេសុ ញាណំ ធម្មប្បដិសម្ភិទា ។

[៧៣] ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ជាទុក្ខអរិយសច្ច ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ញាណកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា បញ្ញាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្តេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថាឃើញ ពាក្យថា ញាណកើតហើយ ដោយអត្ថថាដឹង ពាក្យថា បញ្ញាកើតហើយ ដោយអត្ថថាយល់ច្បាស់ ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថថាចាក់ធ្លុះ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថាភ្លឺស្វាង ។

ចក្ខុជាធម៌[១] ញាណជាធម៌ បញ្ញាជាធម៌ វិជ្ជាជាធម៌ ពន្លឺជាធម៌ ធម៌ទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់ធម្មប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍ របស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងធម៌ទាំងឡាយ លោកហៅថា ធម្មប្បដិសម្ភិទា ។

១ ពាក្យថា ជាធម៌ គឺជាហេតុ ។

ទស្សនដ្ឋោ អត្ថោ ញាតដ្ឋោ អត្ថោ បជាននដ្ឋោ អត្ថោ បដិវេធដ្ឋោ អត្ថោ ឱភាសដ្ឋោ អត្ថោ ឥមេ បញ្ច អត្ថា អត្ថប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្សា អារម្មណា តេ តស្សា គោចរា យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុច្ចតិ អត្ថេសុ ញាណំ អត្ថប្បដិសម្ភិទា ។ បញ្ច ធម្មេ សង្កស្សេតុំ ព្យញ្ជននិរុត្តាភិលាបា បញ្ច អត្ថេ សង្កស្សេតុំ ព្យញ្ជននិរុត្តាភិលាបា ឥមា ទស និរុត្តិយោ និរុត្តិប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្សា អារម្មណា តេ តស្សា គោចរា យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុច្ចតិ និរុត្តីសុ ញាណំ និរុត្តិប្បដិសម្ភិទា ។ បញ្ចសុ ធម្មេសុ ញាណានិ បញ្ចសុ អត្ថេសុ ញាណានិ ទសសុ និរុត្តីសុ ញាណានិ ឥមានិ វីសតិ

សេចក្តីនៃការឃើញ ជាអត្ថ[១] សេចក្តីនៃការដឹងជាអត្ថ សេចក្តីនៃការដឹងច្បាស់ជាអត្ថ សេចក្តីនៃការចាក់ធ្លុះ ជាអត្ថ សេចក្តីនៃការភ្លឺស្វាង ជាអត្ថ អត្ថទាំង៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់អត្ថប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះជាអារម្មណ៍ របស់អត្ថប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងអត្ថទាំងឡាយ លោកហៅថា អត្ថប្បដិស-ម្ភិទា ។ ការពោលនិរុត្តិឲ្យប្រាកដ ដើម្បីពន្យល់នូវធម៌ ៥ ការពោលនិរុត្តិឲ្យប្រាកដ ដើម្បីពន្យល់នូវអត្ថ ៥ និរុត្តិទាំង ១០ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់និរុត្តិប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងនោះជាគោចររបស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងនោះជាអារម្មណ៍ របស់និរុត្តិប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងនិរុត្តិទាំងឡាយ លោកហៅថា និរុត្តិប្បដិសម្ភិទា ។ សេចក្តីដឹងក្នុងធម៌ ៥ សេចក្តីដឹងក្នុងអត្ថ ៥ សេចក្តីដឹងក្នុងនិរុត្តិ ១០ សេចក្តីដឹងទាំង ២០

១ ពាក្យថា អត្ថ គឺផល ។ ចក្ខុ ញាណជាដើម គ្រាន់តែជាហេតុ ត្រង់ការឃើញក្តី ការដឹងក្តីជាផល បានមកពីចក្ខុនិងញាណនោះ។ សេចក្តីក្រៅពីនេះ គួរយល់តាមន័យនេះផងចុះ។

ញាណានិ បដិភាណប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្សា អារម្មណា តេ តស្សា គោចរា យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុច្ចតិ បដិភាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។

[៧៤] តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ ។ បេ ។ បរិញ្ញាតន្តិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ ចក្ខុំ ឧទបាទីតិ កេនត្ថេន ញាណំ ឧទបាទីតិ កេនត្ថេន បញ្ញា ឧទបាទីតិ កេនត្ថេន វិជ្ជា ឧទបាទីតិ កេនត្ថេន អាលោកោ ឧទបាទីតិ កេនត្ថេន ។ ចក្ខុំ ឧទបាទីតិ ទស្សនដ្ឋេន ញាណំ ឧទបាទីតិ ញាតដ្ឋេន បញ្ញា ឧទបាទីតិ បជាននដ្ឋេន វិជ្ជា ឧទបាទីតិ បដិវេធដ្ឋេន អាលោកោ ឧទបាទីតិ ឱភាសដ្ឋេន ។

នេះជាអារម្មណ៍ផង ជាគោចរផង របស់បដិភាណប្បដិសម្ភិទា ធម៌ទាំង-ឡាយណា ជាអារម្មណ៍របស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍ របស់បដិភាណប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹង ក្នុងបដិភាណទាំងឡាយ លោកហៅថា បដិភាណប្បដិសម្ភិទា ។

[៧៤] ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ជាទុក្ខអរិយសច្ច ដែលតថាគតគួរកំណត់ដឹង ។ បេ ។ នេះជាទុក្ខអរិយសច្ច ដែលតថាគតកំណត់ដឹងហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ញាណកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា បញ្ញាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្តេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថាឃើញ ពាក្យថា ញាណកើតហើយ ដោយអត្ថថាដឹង ពាក្យថា បញ្ញាកើតហើយ ដោយអត្ថថាយល់ច្បាស់ ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថថាចាក់ធ្លុះ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថាភ្លឺស្វាង ។

១៤៣

## យុគនទ្ធវគ្គេ បដិសម្ភិទាកថា

ចក្ខុំ ធម្មោ ញាណំ ធម្មោ បញ្ញា ធម្មោ វិជ្ជា ធម្មោ អាលោកោ ធម្មោ ឥមេ បញ្ច ធម្មា ធម្មប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្សា អារម្មណា តេ តស្សា គោចរា យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុច្ចតិ ធម្មេសុ ញាណំ ធម្មប្បដិសម្ភិទា ។ ទស្សនដ្ឋោ អត្ថោ ញាតដ្ឋោ អត្ថោ បជាននដ្ឋោ អត្ថោ បដិវេធដ្ឋោ អត្ថោ ឱភាសដ្ឋោ អត្ថោ ឥមេ បញ្ច អត្ថា អត្ថប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្សា អារម្មណា តេ តស្សា គោចរា យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុច្ចតិ អត្ថេសុ ញាណំ អត្ថប្បដិសម្ភិទា ។ បញ្ច ធម្មេ សន្ទស្សេតុំ ព្យញ្ជននិរុត្តាភិលាបា បញ្ច អត្ថេ សន្ទស្សេតុំ ព្យញ្ជននិរុត្តាភិលាបា ឥមា ទស និរុត្តិយោ និរុត្តិប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ

យុគនទ្ធវគ្គ បដិសម្ភិទាកថា

ចក្ខុ ជាធម៌ ញាណជាធម៌ បញ្ញាជាធម៌ វិជ្ជាជាធម៌ ពន្លឺជាធម៌ ធម៌ទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់ធម្មប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងធម៌ទាំងឡាយ លោកហៅថា ធម្មប្បដិសម្ភិទា ។ សេចក្តីនៃការឃើញ ជាអត្ថ សេចក្តីនៃការដឹង ជាអត្ថ សេចក្តីនៃការដឹងច្បាស់ ជាអត្ថ សេចក្តីនៃការចាក់ធ្លុះ ជាអត្ថ សេចក្តីនៃការភ្លឺស្វាង ជាអត្ថ អត្ថទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់អត្ថប្បដិ-សម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់អត្ថប្ប-ដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងអត្ថទាំងឡាយ លោកហៅថា អត្ថប្បដិសម្ភិទា ។ ការពោលនិរុត្តិឲ្យប្រាកដ ដើម្បីពន្យល់នូវធម៌ ៥ ការពោលនិរុត្តិឲ្យប្រាកដ ដើម្បីពន្យល់នូវអត្ថ ៥ និរុត្តិ ទាំង ១០ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់និរុត្តិប្បដិសម្ភិទា

គោចរា ច យេ តស្ស អារម្មណា តេ តស្ស គោចរា យេ តស្ស គោចរា តេ តស្ស អារម្មណា តេន វុច្ចតិ និរុត្តីសុ ញាណំ និរុត្តិប្បដិសម្ភិទា ។ បញ្ចសុ ធម្មេសុ ញាណានិ បញ្ចសុ អត្ថេសុ ញាណានិ ទសសុ និរុត្តីសុ ញាណានិ ឥមានិ វីសតិ ញាណានិ បដិភាណប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្ស អារម្មណា តេ តស្ស គោចរា យេ តស្ស គោចរា តេ តស្ស អារម្មណា តេន វុច្ចតិ បដិភាណេសុ ញាណំ បដិភាណប្បដិស-ម្ភិទា ។ ទុក្ខេ អរិយសច្ចេ បណ្ណរស ធម្មា បណ្ណរស អត្ថា តីស និរុត្តិយោ សដ្ឋី ញាណានិ ។

[៧៤] ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អា-លោកោ ឧទបាទិ ។ បេ ។ តំ ខោ បនិទំ ទុក្ខសមុទ-យោ អរិយសច្ចំ បហាតព្វន្តិ ។ បេ ។ បហីនន្តិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។

ធម៌ទាំងឡាយណា ជាអារម្មណ៍ របស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងនោះជាគោចរ របស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងឡាយណាជាគោចរ របស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់និរុត្តិប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងនិរុត្តិទាំងឡាយ លោកហៅថា និរុត្តិប្បដិសម្ភិទា ។ សេចក្តីដឹងក្នុងធម៌ ៥ សេចក្តីដឹងក្នុងអត្ថ ៥ សេចក្តីដឹងក្នុងនិរុត្តិ ១០ សេចក្តីដឹងទាំង ២០ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់បដិភាណប្បដិសម្ភិទា ធម៌ទាំងឡាយណាជាអារម្មណ៍ របស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់បដិ-ភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់បដិភាណប្ប-ដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងបដិភាណទាំងឡាយ លោកហៅថា បដិភាណប្បដិសម្ភិទា ។ ក្នុងទុក្ខអរិយសច្ច មានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ ។

[៧៥] ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ជាទុក្ខសមុទយអរិយសច្ច ។ បេ ។ ថា នេះជាទុក្ខសមុទយអរិយសច្ច ដែលតថាគតគួរលះ ។ បេ ។ ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ជាទុក្ខសមុទយអរិយសច្ច ដែលតថាគតលះហើយ

អាលោកោ ឧទបាទិ ។ បេ ។ ទុក្ខសមុទយេ អរិយសច្ចេ បណ្ណរស ធម្មា បណ្ណរស អត្ថា តឹស និរុត្តិយោ សដ្ឋី ញាណានិ ។

ឥទំ ទុក្ខនិរោធោ អរិយសច្ចន្តិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ បេ ។ តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ ។ បេ ។ សច្ឆិកតន្តិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ បេ ។ ទុក្ខនិរោធេ អរិយសច្ចេ បណ្ណរស ធម្មា បណ្ណរស អត្ថា តឹស និរុត្តិយោ សដ្ឋី ញាណានិ ។

ឥទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចន្តិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ បេ ។ តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវេតព្វន្តិ ។ បេ ។ ភាវិតន្តិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ បេ ។

។ បេ ។ ក្នុងទុក្ខសមុទយអរិយសច្ច មានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ ។

ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ជាទុក្ខនិរោធអរិយសច្ច ។ បេ ។ ថា នេះ ជាទុក្ខនិរោធអរិយសច្ច ដែលតថាគតគួរធ្វើឲ្យជាក់ច្បាស់ ។ បេ ។ ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ជាទុក្ខនិរោធអរិយសច្ច ដែលតថាគតធ្វើឲ្យជាក់ច្បាស់ហើយ ។ បេ ។ ក្នុងទុក្ខនិរោធអរិយសច្ច មានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ ។

ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះ ជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ បេ ។ ថា នេះ ជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដែលតថាគតគួរចម្រើន ។ បេ ។ ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះ ជាទុក្ខនិរោធ-គាមិនីបដិបទាអរិយសច្ច ដែលតថាគត ចម្រើនហើយ ។ បេ ។

ទុក្ខនិរោធគាមិនិយា បដិបទាយ អរិយសច្ចេ បណ្ណរស ធម្មា បណ្ណរស អត្ថា តឹស និរុត្តិយោ សដ្ឋី ញាណានិ ចតូសុ អរិយសច្ចេសុ សដ្ឋី ធម្មា សដ្ឋី អត្ថា វីសសតា និរុត្តិយោ ចត្តារីសញ្ច ទ្វេ ច ញាណសតានិ ។

[៧៦] អយំ កាយេ កាយានុបស្សនាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ សា ខោ បនាយំ កាយេ កាយានុបស្សនា ភាវេតព្វាតិ មេ ភិក្ខវេ ។ បេ ។ ភាវិតាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ អយំ វេទនាសុ ។ បេ ។ អយំ ចិត្តេ ។ បេ ។ អយំ ធម្មេសុ ធម្មានុបស្សនាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។

ក្នុងទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច មានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ ក្នុងអរិយសច្ចទាំង ៤ មានធម៌ ៦០ មានអត្ថ ៦០ មាននិរុត្តិ ១២០ មានញាណ ២៤០ ។

[៧៦] ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ កាយេកាយានុបស្សនា (ការពិចារណាឃើញថាកាយក្នុងកាយ) ថា នេះ កាយេកាយានុបស្សនា ដែលតថាគតគួរចម្រើន ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ កាយេ-កាយានុបស្សនា ដែលតថាគតចម្រើនហើយ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ វេទនាសុវេទនានុបស្សនា ។ បេ ។ ថា នេះ ចិត្តេចិត្តានុបស្សនា ។ បេ ។ ថា នេះ ធម្មេសុធម្មានុបស្សនា

យុគនទ្ធវគ្គេ បដិសម្ភិទាកថា

អាលោកោ ឧទបាទិ សោ ខោ បនាយំ ធម្មេសុ ធម្មានុបស្សនា ភាវេតព្វាតិ មេ ភិក្ខវេ ។ បេ ។ ភាវិតាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។

អយំ កាយេ កាយានុបស្សនាតិ បុព្វេ អននុស្សុ-តេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោ-កោ ឧទបាទិ សោ ខោ បនាយំ កាយេ កាយានុបស្សនា ភាវេតព្វាតិ ។ បេ ។ ភាវិតាតិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ ចក្ខុំ ឧទបាទីតិ កេនដ្ឋេន ញាណំ ឧទបាទីតិ កេនដ្ឋេន បញ្ញា ឧទបាទីតិ កេនដ្ឋេន វិជ្ជា ឧទបាទីតិ កេនដ្ឋេន អាលោកោ ឧទបាទីតិ កេនដ្ឋេន ។ ចក្ខុំ ឧទបាទីតិ ទស្សនដ្ឋេន ញា-ណំ ឧទបាទីតិ ញាតដ្ឋេន បញ្ញា ឧទបាទីតិ បជាននដ្ឋេន វិជ្ជា ឧទបាទីតិ បដិវេធដ្ឋេន អាលោ-កោ ឧទបាទីតិ ឱភាសដ្ឋេន ។

ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះធម្មេសុធម្មានុបស្សនា ដែលតថាគតគួរចម្រើន ។ បេ ។ ថា នេះធម្មេសុធម្មានុបស្សនា ដែលតថាគត ចម្រើនហើយ ។

ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ កាយេកាយានុបស្សនា ថា នេះ កាយេ-កាយានុបស្សនា ដែលតថាគតគួរចម្រើន ។ បេ ។ ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ កាយេកាយានុប-ស្សនា ដែលតថាគតចម្រើនហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ញាណកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា បញ្ញាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្តេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថាឃើញ ពាក្យថា ញាណកើតហើយ ដោយអត្ថថាដឹង ពាក្យថា បញ្ញាកើតហើយ ដោយអត្ថថាយល់ច្បាស់ ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថថាចាក់ធ្លុះ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថាភ្លឺស្វាង ។

១៤៨

ចក្ខុំ ធម្មោ ញាណំ ធម្មោ បញ្ញា ធម្មោ វិជ្ជា ធម្មោ អាលោកោ ធម្មោ ឥមេ បញ្ច ធម្មា ធម្មប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្សា អារម្មណា តេ តស្សា គោចរា យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុច្ចតិ ធម្មេសុ ញាណំ ធម្ម-ប្បដិសម្ភិទា ។ ទស្សនដ្ឋោ អត្ថោ ញាតដ្ឋោ អត្ថោ បជាននដ្ឋោ អត្ថោ បដិវេធដ្ឋោ អត្ថោ ឱភាសដ្ឋោ អត្ថោ ឥមេ បញ្ច អត្ថា អត្ថប្ប-ដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្សា អារម្មណា តេ តស្សា គោចរា យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុ-ច្ចតិ អត្ថេសុ ញាណំ អត្ថប្បដិសម្ភិទា ។ បញ្ច ធម្មេ សន្ទស្សេតុំ ព្យញ្ជននិរុត្តាភិលាបា បញ្ច អត្ថេ សន្ទស្សេតុំ ព្យញ្ជននិរុត្តាភិលាបា ឥមា ទស និរុត្តិយោ និរុត្តិប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្សា អារម្មណា តេ

ចក្ខុជាធម៌ ញាណជាធម៌ បញ្ញាជាធម៌ វិជ្ជាជាធម៌ ពន្លឺជាធម៌ ធម៌ទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់ធម្មប្បដិសម្ភិទា ធម៌ទាំង-ឡាយណា ជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចរ របស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងធម៌ទាំងឡាយ លោកហៅថា ធម្មប្ប-ដិសម្ភិទា ។ សេចក្តីនៃការឃើញជាអត្ថ សេចក្តីនៃការដឹងជាអត្ថ សេចក្តីនៃការដឹងច្បាស់ជាអត្ថ សេចក្តីនៃការចាក់ធ្លុះជាអត្ថ សេចក្តីនៃការភ្លឺស្វាងជាអត្ថ អត្ថទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់អត្ថ-ប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់អត្ថ-ប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងអត្ថទាំងឡាយ លោកហៅថា អត្ថប្បដិសម្ភិទា ។ ការពោលនិរុត្តិឲ្យប្រាកដ ដើម្បីពន្យល់នូវធម៌ទាំង ៥ ការពោលនិរុត្តិឲ្យប្រាកដ ដើម្បីពន្យល់នូវអត្ថទាំង ៥ និរុត្តិទាំង ១០ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់និរុត្តិប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់

តស្សា គោចរា យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុច្ចតិ និរុត្តីសុ ញាណំ និរុត្តិប្បដិសម្ភិទា ។ បញ្ចសុ ធម្មេសុ ញាណានិ បញ្ចសុ អត្ថេសុ ញាណានិ ទសសុ និរុត្តីសុ ញាណានិ ឥមានិ វីសតិ ញាណានិ បដិភាណប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្សា អារម្មណា តេ តស្សា គោចរា យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុច្ចតិ បដិភាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។ កាយេ កាយានុបស្សនាសតិប្បដ្ឋានេ បណ្ណរស ធម្មា បណ្ណរស អត្ថា តឹស និរុត្តិយោ សដ្ឋី ញាណានិ អយំ វេទនាសុ ។ បេ ។ អយំ ចិត្តេ ។ បេ ។

អយំ ធម្មេសុ ធម្មានុបស្សនាតិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ បេ ។ សា ខោ បនាយំ ធម្មេសុ ធម្មានុបស្សនា ភាវេតព្វាតិ ។ បេ ។ ភាវិតាតិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។

និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់និរុត្តិប្បដិ-សម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់និរុត្តិប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងនិរុត្តិទាំងឡាយ លោកហៅថានិរុត្តិប្បដិសម្ភិទា ។ សេចក្តីដឹងក្នុងធម៌ ៥ សេចក្តីដឹងក្នុងអត្ថ ៥ សេចក្តីដឹងក្នុងនិរុត្តិ ១០ សេចក្តីដឹងទាំង ២០ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់បដិភា-ណប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់បដិភាណប្បដិ-សម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះជាអារម្មណ៍ របស់បដិភាណប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងបដិភាណទាំងឡាយ លោកហៅថា បដិភាណប្បដិសម្ភិទា ។ ក្នុងកាយេកាយានុបស្សនាសតិប្បដ្ឋាន មានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ នេះ វេទនាសុវេទនានុបស្សនា ។ បេ ។ នេះ ចិត្តេចិត្តានុបស្សនា ។បេ។

ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ធម្មេសុធម្មានុបស្សនា ។ បេ ។ ថា នេះ ធម្មេសុធម្មានុបស្សនា ដែលតថាគតគួរចម្រើន ។ បេ ។ ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតឡើងហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ធម្មេសុធម្មានុបស្សនា ដែលតថាគតចម្រើនហើយ ។បេ។

អាលោកោ ឧទបាទិ ។ បេ ។ ធម្មេសុ ធម្មានុបស្សនាសតិប្បដ្ឋានេ បណ្ណរស ធម្មា បណ្ណរស អត្ថា តីស និរុត្តិយោ សដ្ឋី ញាណានិ ចតូសុ សតិប្បដ្ឋានេសុ សដ្ឋី ធម្មា សដ្ឋី អត្ថា វីសសតា និរុត្តិយោ ចត្តារីសញ្ច ទ្វេ ច ញាណសតានិ ។

[៧៧] អយំ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ អយំ វីរិយសមាធិ ។ បេ ។ អយំ ចិត្តសមាធិ ។ បេ ។ អយំ វីមំសាសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ សោ ខោ បនាយំ វីមំសាសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោ ភាវេតព្វោតិ មេ ភិក្ខវេ ។ បេ ។ ភាវិតោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។

ក្នុងធម្មេសុធម្មានុបស្សនាសតិប្បដ្ឋាន មានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ ក្នុងសតិប្បដ្ឋានទាំង ៤ មានធម៌ ៦០ មានអត្ថ ៦០ មាននិរុត្តិ ១២០ មានញាណ ២៤០ ។

[៧៧] ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ថា នេះឥទ្ធិបាទប្រកបដោយវិរិយសមាធិ ។ បេ ។ ថា នេះឥទ្ធិបាទប្រកបដោយចិត្តសមាធិ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ម្នាលភិក្ខុទាំង-ឡាយ តថាគត មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ដែលតថាគតគួរចម្រើន ។ បេ ។ ថា នេះ ឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ដែលតថាគត ចម្រើនហើយ ។

[៧៨] អយំ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោតិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ បេ ។ សោ ខោ បនាយំ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោ ភាវេតព្វោតិ ។ បេ ។ ភាវិតោតិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ ចក្ខុំ ឧទបាទីតិ កេនដ្ឋេន ញាណំ ឧទបាទីតិ កេនដ្ឋេន បញ្ញា ឧទបាទីតិ កេនដ្ឋេន វិជ្ជា ឧទបាទីតិ កេនដ្ឋេន អាលោកោ ឧទបាទីតិ កេនដ្ឋេន ។ ចក្ខុំ ឧទបាទីតិ ទស្សនដ្ឋេន ញាណំ ឧទបាទីតិ ញាតដ្ឋេន បញ្ញា ឧទបាទីតិ បជាននដ្ឋេន វិជ្ជា ឧទបាទីតិ បដិវេធដ្ឋេន អាលោកោ ឧទបាទីតិ ឱភាសដ្ឋេន ។

[៧៨] ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំង-ឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ឥទ្ធិបាទ ប្រកបដោយឆន្ទ-សមាធិនិងបធានសង្ខារ ។ បេ ។ ថា នេះ ឥទ្ធិបាទ ប្រកបដោយឆន្ទ-សមាធិនិងបធានសង្ខារ ដែលតថាគតគួរចម្រើន ។ បេ ។ ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ឥទ្ធិបាទប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ដែលតថាគតចម្រើនហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា ញាណកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា បញ្ញាកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្ដេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថាឃើញ ពាក្យថា ញាណកើតហើយ ដោយអត្ថថាដឹង ពាក្យថា បញ្ញាកើតហើយ ដោយអត្ថថាដឹងច្បាស់ ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថថាចាក់ធ្លុះ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថាភ្លឺស្វាង ។

ចក្ខុំ ធម្មោ ញាណំ ធម្មោ បញ្ញា ធម្មោ វិជ្ជា ធម្មោ អាលោកោ ធម្មោ ឥមេ បញ្ច ធម្មា ធម្មប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្សា អារម្មណា តេ តស្សា គោចរា យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុច្ចតិ ធម្មេសុ ញាណំ ធម្មប្បដិសម្ភិទា ។ ទស្សនដ្ឋោ អត្ថោ ញាតដ្ឋោ អត្ថោ បជាននដ្ឋោ អត្ថោ បដិវេធដ្ឋោ អត្ថោ ឱភាសដ្ឋោ អត្ថោ ឥមេ បញ្ច អត្ថា អត្ថប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្សា អារម្មណា តេ តស្សា គោចរា យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុច្ចតិ អត្ថេសុ ញាណំ អត្ថប្បដិសម្ភិទា ។ បញ្ច ធម្មេ សន្ទស្សេតុំ ព្យញ្ជននិរុត្តាភិលាបា បញ្ច អត្ថេ សន្ទស្សេតុំ ព្យញ្ជននិរុត្តាភិលាបា ឥមា ទស និរុត្តិប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោចរា ច យេ តស្សា អារម្មណា តេ តស្សា គោចរា

ចក្ខុជាធម៌ ញាណជាធម៌ បញ្ញាជាធម៌ វិជ្ជាជាធម៌ ពន្លឺជាធម៌ ធម៌ទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់ធម្មប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងធម៌ទាំងឡាយ លោកហៅថា ធម្មប្បដិសម្ភិទា។ សេចក្តីនៃការឃើញជាអត្ថ សេចក្តីនៃការដឹងជាអត្ថ សេចក្តីនៃការដឹងច្បាស់ជាអត្ថ សេចក្តីនៃការចាក់ធ្លុះជាអត្ថ សេចក្តីនៃការធ្វើស្វាងជាអត្ថ អត្ថទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់អត្ថប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់អត្ថប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងអត្ថទាំងឡាយ លោកហៅថា អត្ថប្បដិសម្ភិទា ។ ការពោលនិរុត្តិឲ្យប្រាកដ ដើម្បីពន្យល់ធម៌ ៥ ការពោលនិរុត្តិឲ្យប្រាកដ ដើម្បីពន្យល់អត្ថ ៥ និរុត្តិទាំង ១០ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់និរុត្តិប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍ របស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចរ របស់និរុត្តិប្បដិសម្ភិទានោះ

យុគនទ្ធវគ្គេ បដិសម្ភិទាកថា

យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុច្ចតិ និរុត្តីសុ ញាណំ និរុត្តិប្បដិសម្ភិទា ។ បញ្ចសុ ធម្មេ-សុ ញាណានិ បញ្ចសុ អត្ថេសុ ញាណានិ ទសសុ និរុត្តីសុ ញាណានិ ឥមានិ វីសតិ ញាណានិ ប-ដិភាណប្បដិសម្ភិទាយ អារម្មណា ចេវ ហោន្តិ គោ-ចរា ច យេ តស្សា អារម្មណា តេ តស្សា គោ-ចរា យេ តស្សា គោចរា តេ តស្សា អារម្មណា តេន វុច្ចតិ បដិភាណេសុ ញាណំ បដិភាណប្បដិ-សម្ភិទា ។ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតេ ឥ-ទ្ធិបាទេ បណ្ណរស ធម្មា បណ្ណរស អត្ថា តឹស និរុត្តិយោ សដ្ឋី ញាណានិ អយំ វីរិយសមាធិ ។ បេ ។ អយំ ចិត្តសមាធិ ។ បេ ។

អយំ វីមំសាសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោតិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ បេ ។ សោ ខោ បនាយំ វីមំសាសមាធិប្បធានសង្ខារ-សមន្នាគតោ ឥទ្ធិបាទោ ភាវេតព្វោតិ ។ បេ ។

ធម៌ទាំងឡាយណា ជាគោចររបស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍ របស់និរុត្តិប្បដិសម្ភិទានោះ ហេតុនោះ សេចក្ដីដឹងក្នុង និរុត្តិទាំងឡាយ លោកហៅថា និរុត្តិប្បដិសម្ភិទា ។ សេចក្ដីដឹងក្នុងធម៌ ៥ សេចក្ដីដឹងក្នុងអត្ថ ៥ សេចក្ដីដឹងក្នុងនិរុត្តិ ១០ សេចក្ដីដឹងទាំង ២០ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់បដិភាណប្បដិសម្ភិទា ធម៌ទាំង-ឡាយណា ជាអារម្មណ៍របស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចរ របស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះជាអារម្មណ៍របស់បដិភាណ-ប្បដិសម្ភិទានោះ ហេតុនោះ សេចក្ដីដឹងក្នុងបដិភាណទាំងឡាយ លោក ហៅថា បដិភាណប្បដិសម្ភិទា ។ ក្នុងឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ មានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ នេះ ឥទ្ធិបាទ ប្រកបដោយវីរិយសមាធិ ។ បេ ។ នេះ ឥទ្ធិបាទ ប្រកបដោយចិត្តសមាធិ ។ បេ ។

ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះ ឥទ្ធិបាទ ប្រកបដោយវីមំសា-សមាធិ និងបធានសង្ខារ ។ បេ ។ នេះ ឥទ្ធិបាទ ប្រកបដោយ វីមំសាសមាធិ និងបធានសង្ខារ ដែលតថាគត គួរចម្រើន ។ បេ ។

ការិតោតិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទ-
បាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ បេ ។ វីមំសាស-
មាធិប្បធានសង្ខារសមន្នាគតេ ឥទ្ធិបាទេ បណ្ណរស
ធម្មា បណ្ណរស អត្ថា តីស និរុត្តិយោ សដ្ឋី ញាណានិ
ចតូសុ ឥទ្ធិបាទេសុ សដ្ឋី ធម្មា សដ្ឋី អត្ថា វីសសតា
និរុត្តិយោ ចត្តារីសញ្ច ទ្វេ ច ញាណសតានិ ។

[៧៩] សមុទយោ សមុទយោតិ ខោ ភិក្ខវេ
វិបស្សិស្ស ពោធិសត្តស្ស បុព្វេ អននុស្សុតេសុ ធ-
ម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ
និរោធោ និរោធោតិ ខោ ភិក្ខវេ វិបស្សិស្ស ពោធិ-
សត្តស្ស បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទ-
បាទិ ។ បេ ។ អាលោកោ ឧទបាទិ វិបស្សិស្ស
ពោធិសត្តស្ស វេយ្យាករណេ ទស ធម្មា ទស
អត្ថា វីសតិ និរុត្តិយោ ចត្តារីសំ ញាណានិ ។

ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះ ឥទ្ធិបាទប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ដែលតថាគតចម្រើនហើយ ។ បេ ។ ក្នុងឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ មានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ ក្នុងឥទ្ធិបាទទាំង ៤ មានធម៌ ៦០ មានអត្ថ ៦០ មាននិរុត្តិ ១២០ មានញាណ ២៤០ ។

[៧៩] ម្នាលភិក្ខុទាំងឡាយ វិបស្សីពោធិសត្វ មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮ ក្នុងកាលមុនថា សមុទ័យ សមុទ័យ (ហេតុជាដែនកើតឡើង ហេតុជាដែនកើតឡើង) ម្នាលភិក្ខុទាំងឡាយ វិបស្សីពោធិសត្វ មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា និរោធ និរោធ (ការរលត់ ការរលត់) ។ ក្នុងវេយ្យាករណ៍ របស់វិបស្សី-ពោធិសត្វ មានធម៌ ១០ មានអត្ថ ១០ មាននិរុត្តិ ២០ មានញាណ ៤០ ។

១៤៤

### យុគនទ្ធវគ្គេ បដិសម្ភិទាកថា

សមុទយោ សមុទយោតិ ខោ ភិក្ខវេ សិខិស្ស
ពោធិសត្តស្ស ។ បេ ។ វេស្សភុស្ស ពោធិសត្តស្ស ។ បេ ។
កកុសន្ធស្ស ពោធិសត្តស្ស ។ បេ ។ កោណាគមនស្ស
ពោធិសត្តស្ស ។ បេ ។ កស្សបស្ស ពោធិសត្តស្ស បុព្វេ
អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោ-
កោ ឧទបាទិ និរោធោ និរោធោតិ ខោ ភិក្ខវេ កស្ស-
បស្ស ពោធិសត្តស្ស បុព្វេ អននុស្សុតេសុ ធម្មេសុ
ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ កស្ស-
បស្ស ពោធិសត្តស្ស វេយ្យាករណេ ទស ធម្មា ទស
អត្ថា វីសតិ និរុត្តិយោ ចត្តារីសំ ញាណានិ ។

សមុទយោ សមុទយោតិ ខោ ភិក្ខវេ គោតមស្ស
ពោធិសត្តស្ស បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ
ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ និរោធោ
និរោធោតិ ខោ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេ-
សុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ
គោតមស្ស ពោធិសត្តស្ស វេយ្យាករណេ ទស ធម្មា
ទស អត្ថា វីសតិ និរុត្តិយោ ចត្តារីសំ ញាណានិ ។

យុគនទ្ធវគ្គ បដិសម្ភិទាកថា

ម្នាលភិក្ខុទាំងឡាយ សិខីពោធិសត្វ ។ បេ ។ វេស្សភូពោធិសត្វ ។ បេ ។ កកុសន្ធពោធិសត្វ ។ បេ ។ កោនាគមនពោធិសត្វ ។ បេ ។ កស្សបពោធិសត្វ មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮ ក្នុងកាលមុន ថា សមុទ័យ សមុទ័យ (ហេតុជាដែនកើត ហេតុជាដែនកើត) ម្នាលភិក្ខុទាំងឡាយ កស្សបពោធិ-សត្វ មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំង-ឡាយ ដែលមិនធ្លាប់ឮ ក្នុងកាលមុនថា និរោធ និរោធ (ការរលត់ ការរលត់) ។ ក្នុងវេយ្យាករណ៍ របស់កស្សបពោធិសត្វ មានធម៌ ១០ មានអត្ថ ១០ មាននិរុត្តិ ២០ មានញាណ ៤០ ។

ម្នាលភិក្ខុទាំងឡាយ គោតមពោធិសត្វ មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮ ក្នុងកាលមុនថា សមុទ័យ សមុទ័យ (ហេតុជាដែនកើត ហេតុជាដែនកើត) ម្នាលភិក្ខុទាំងឡាយ គោតមពោធិសត្វ មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮ ក្នុងកាលមុនថា និរោធ និរោធ (ការរលត់ ការរលត់) ។ ក្នុងវេយ្យាករណ៍ របស់គោតមពោធិ-សត្វ មានធម៌ ១០ មានអត្ថ ១០ មាននិរុត្តិ ២០ មានញាណ ៤០ ។

សត្តន្នំ ពោជ្ឈង្គានំ សត្តសុ វេយ្យាករណេសុ សត្តតិ ធម្មា សត្តតិ អត្ថា ចត្តារីសសតា និរុត្តិយោ អសីតិ ច ទ្វេ ច ញាណសតានិ ។

[៨០] យាវតា អភិញ្ញាយ អភិញ្ញដ្ឋោ ញាតោ ទិដ្ឋោ វិទិតោ សច្ឆិកតោ ផស្សិតោ បញ្ញាយ អផស្សិតោ បញ្ញាយ អភិញ្ញដ្ឋោ ឆត្តឹតិ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ អភិញ្ញាយ អភិញ្ញដ្ឋេ បញ្ចវីសតិ ធម្មា បញ្ចវីសតិ អត្ថា បញ្ញាសំ និរុត្តិយោ សតញ្ញាណានិ យាវតា បរិញ្ញាយ បរិញ្ញដ្ឋោ ។ បេ ។ យាវតា បហានស្ស បហានដ្ឋោ ។ បេ ។ យាវតា ភាវនាយ ភាវនដ្ឋោ ។ បេ ។ យាវតា សច្ឆិកិរិយាយ សច្ឆិកិរិយដ្ឋោ ញាតោ ទិដ្ឋោ វិទិតោ សច្ឆិកតោ ផស្សិតោ បញ្ញាយ អផស្សិតោ បញ្ញាយ សច្ឆិកិរិយដ្ឋោ ឆត្តឹតិ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ សច្ឆិកិរិយាយ សច្ឆិកិរិយដ្ឋេ បញ្ចវីសតិ ធម្មា បញ្ចវីសតិ អត្ថា បញ្ញាសំ និរុត្តិយោ សតញ្ញាណានិ អភិញ្ញាយ អភិញ្ញដ្ឋេ

ក្នុងវេយ្យាករណ៍ទាំង ៧ របស់ពោធិសត្វទាំង ៧ អង្គ មានធម៌ ៧០ មានអត្ថ ៧០ មាននិរុត្តិ ១៤០ មានញាណ ២៨០ ។

[៨០] ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយ ថា អត្ថនៃអភិញ្ញា របស់អភិញ្ញាទាំងប៉ុន្មាន ព្រះមានព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយបញ្ញា អត្ថនៃអភិញ្ញា ព្រះមានព្រះភាគ មិនបានពាល់ត្រូវហើយដោយបញ្ញា មិនមានឡើយ ក្នុងអត្ថនៃអភិញ្ញា របស់អភិញ្ញា មានធម៌ ២៥ មានអត្ថ ២៥ មាននិ-រុត្តិ ៥០ មានញាណ ១០០ ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយថា អត្ថនៃបរិញ្ញា របស់បរិញ្ញាទាំងប៉ុន្មាន ។ បេ ។ អត្ថនៃបហានៈ ទាំងប៉ុន្មាន ។ បេ ។ អត្ថនៃភាវនា របស់ភាវនា ទាំងប៉ុន្មាន ។ បេ ។ អត្ថនៃសច្ឆិកិរិយា របស់សច្ឆិកិរិយា ទាំងប៉ុន្មាន ព្រះមានព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយបញ្ញា អត្ថនៃសច្ឆិកិរិយា ព្រះមានព្រះភាគមិនបានពាល់ត្រូវហើយ ដោយបញ្ញា មិនមានឡើយ ក្នុងអត្ថនៃសច្ឆិកិរិយា របស់សច្ឆិកិរិយា មានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ក្នុងអត្ថនៃអភិញ្ញារបស់អភិញ្ញា

បរិញ្ញាយ បរិញ្ញដ្ឋេ បហានាយ បហានដ្ឋេ ភាវនាយ ភាវនដ្ឋេ សច្ឆិកិរិយាយ សច្ឆិកិរិយដ្ឋេ បញ្ចវីសសតំ ធម្មា បញ្ចវីសសតំ អត្ថា អឌ្ឍតេយ្យនិរុត្តិសតានិ បញ្ចញាណសតានិ ។

[៨១] យាវតា ខន្ធានំ ខន្ធដ្ឋោ ញាតោ ទិដ្ឋោ វិទិតោ សច្ឆិកតោ ផស្សិតោ បញ្ញាយ អផស្សិតោ បញ្ញាយ ខន្ធដ្ឋោ នត្ថីតិ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ខន្ធានំ ខន្ធដ្ឋេ បញ្ចវីសតិ ធម្មា បញ្ចវីសតិ អត្ថា បញ្ញាសំ និរុត្តិយោ សតញ្ញាណានិ យាវតា ធាតូនំ ធាតុដ្ឋោ ។ បេ ។ យាវតា អាយតនានំ អាយតនដ្ឋោ យាវតា សង្ខតានំ សង្ខតដ្ឋោ យាវតា អសង្ខតស្ស អសង្ខតដ្ឋោ ញាតោ ទិដ្ឋោ វិទិតោ សច្ឆិកតោ ផស្សិតោ បញ្ញាយ អផស្សិតោ បញ្ញាយ អសង្ខតដ្ឋោ នត្ថីតិ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ អសង្ខតស្ស អសង្ខតដ្ឋេ បញ្ចវីសតិ ធម្មា បញ្ចវីសតិ អត្ថា បញ្ញាសំ និរុត្តិយោ សតញ្ញាណានិ

ក្នុងអត្ថនៃបរិញ្ញា របស់បរិញ្ញា ក្នុងអត្ថនៃបហានៈ របស់បហានៈ ក្នុងអត្ថនៃភាវនា របស់ភាវនា ក្នុងអត្ថនៃសច្ឆិកិរិយា របស់សច្ឆិកិរិយា មានធម៌ ១២៥ មានអត្ថ ១២៥ មាននិរុត្តិ ២៥០ មានញាណ ៥០០ ។

[៨១] ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយ ថា អត្ថនៃខន្ធ របស់ខន្ធ ទាំងប៉ុន្មាន ព្រះមានព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយបញ្ញា អត្ថនៃខន្ធ ព្រះមានព្រះភាគ មិនបានពាល់ត្រូវហើយដោយបញ្ញា មិនមានឡើយ ក្នុងអត្ថនៃខន្ធ របស់ខន្ធទាំងឡាយ មានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយថា អត្ថនៃធាតុ របស់ធាតុទាំងប៉ុន្មាន ។ បេ ។ អត្ថនៃអាយតនៈ របស់អាយតនៈទាំងប៉ុន្មាន អត្ថនៃសង្ខតៈ របស់សង្ខតៈទាំងប៉ុន្មាន អត្ថនៃអសង្ខតៈ របស់អសង្ខតៈ ទាំងប៉ុន្មាន ព្រះមានព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយបញ្ញា អត្ថនៃអសង្ខតៈ ព្រះមានព្រះភាគ ទ្រង់មិនបានពាល់ត្រូវហើយដោយបញ្ញា មិនមានឡើយ ក្នុងអត្ថនៃអសង្ខតៈ របស់អសង្ខតៈ មានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០

ខន្ធានំ ខន្ធដ្ឋេ ធាតូនំ ធាតដ្ឋេ អាយតនានំ អាយតនដ្ឋេ សង្ខតានំ សង្ខតដ្ឋេ អសង្ខតស្ស អសង្ខតដ្ឋេ បញ្ចវីសសតំ ធម្មា បញ្ចវីសសតំ អត្ថា អឌ្ឍតេយ្យនិរុត្តិសតានិ បញ្ច ញាណសតានិ[១] ។

[៨២] យាវតា ទុក្ខស្ស ទុក្ខដ្ឋោ ញាតោ ទិដ្ឋោ វិទិតោ សច្ឆិកតោ ផស្សិតោ បញ្ញាយ អផស្សិតោ បញ្ញាយ ទុក្ខដ្ឋោ នត្ថីតិ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ទុក្ខស្ស ទុក្ខដ្ឋេ បញ្ចវីសតិ ធម្មា បញ្ចវីសតិ អត្ថា បញ្ញាសំ និរុត្តិយោ សតញ្ញាណានិ យាវតា សមុទយស្ស សមុទយដ្ឋោ ។ បេ ។ យាវតា និរោធស្ស និរោធដ្ឋោ យាវតា មគ្គស្ស មគ្គដ្ឋោ ញាតោ ទិដ្ឋោ វិទិតោ សច្ឆិកតោ ផស្សិតោ បញ្ញាយ អផស្សិតោ បញ្ញាយ មគ្គដ្ឋោ នត្ថីតិ ចក្ខុំ ឧទបាទិ ។បេ។

---

១ ម. អឌ្ឍតេយ្យានិ និរុត្តិសតានិ បញ្ញាស សតានីតិ ទិស្សតិ ។

ក្នុងអត្ថនៃខន្ធ របស់ខន្ធទាំងឡាយ ក្នុងអត្ថនៃធាតុរបស់ធាតុទាំងឡាយ ក្នុងអត្ថនៃអាយតនៈ របស់អាយតនៈទាំងឡាយ ក្នុងអត្ថនៃសង្ខតៈ របស់សង្ខតៈទាំងឡាយ ក្នុងអត្ថនៃអសង្ខតៈ របស់អសង្ខតៈ មានធម៌ ១២៥ មានអត្ថ ១២៥ មាននិរុត្តិ ២៥០ មានញាណ ៥០០ ។

[៨២] ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយថា អត្ថនៃទុក្ខ របស់ទុក្ខសច្ច ព្រះមានព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយបញ្ញា អត្ថនៃទុក្ខ ព្រះមានព្រះភាគមិនបានពាល់ត្រូវហើយ ដោយបញ្ញា មិនមានឡើយ ក្នុងអត្ថនៃទុក្ខ របស់ទុក្ខសច្ច មានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយថា អត្ថនៃសមុទ័យ របស់សមុទយសច្ច ទាំងប៉ុន្មាន ។ បេ ។ អត្ថនៃនិរោធរបស់និរោធសច្ច ទាំងប៉ុន្មាន អត្ថនៃមគ្គ របស់មគ្គសច្ច ទាំងប៉ុន្មាន ព្រះមានព្រះភាគ ទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយបញ្ញា អត្ថនៃមគ្គ ព្រះមានព្រះភាគ មិនបានពាល់ត្រូវហើយ ដោយបញ្ញា មិនមានឡើយ

អាលោកោ ឧទបាទិ មគ្គស្ស មគ្គដ្ឋេ បញ្ចវីសតិ ធម្មា បញ្ចវីសតិ អត្ថា បញ្ញាសំ និរុត្តិយោ សតញ្ញាណានិ ចតូសុ អរិយសច្ចេសុ សតំ ធម្មា សតំ អត្ថា ទ្វេ និរុត្តិសតានិ ចត្តារិ ញាណសតានិ ។

[៨៣] យាវតា អត្ថប្បដិសម្ភិទាយ អត្ថប្បដិស-
ម្ភិទដ្ឋោ ញាតោ ទិដ្ឋោ វិទិតោ សច្ឆិកតោ ផស្សិ-
តោ បញ្ញាយ អផស្សិតោ បញ្ញាយ អត្ថប្បដិស-
ម្ភិទដ្ឋោ នត្ថីតិ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ
ឧទបាទិ អត្ថប្បដិសម្ភិទាយ អត្ថប្បដិសម្ភិទដ្ឋេ បញ្ច-
វីសតិ ធម្មា បញ្ចវីសតិ អត្ថា បញ្ញាសំ និរុត្តិយោ ស-
តញ្ញាណានិ យាវតា ធម្មប្បដិសម្ភិទាយ ធម្មប្បដិស-
ម្ភិទដ្ឋោ ។ បេ ។ យាវតា និរុត្តិប្បដិសម្ភិទាយ និរុត្តិ-
ប្បដិសម្ភិទដ្ឋោ យាវតា បដិភាណប្បដិសម្ភិទាយ
បដិភាណប្បដិសម្ភិទដ្ឋោ ញាតោ ទិដ្ឋោ វិទិតោ ស-
ច្ឆិកតោ ផស្សិតោ បញ្ញាយ អផស្សិតោ បញ្ញាយ
បដិភាណប្បដិសម្ភិទដ្ឋោ នត្ថីតិ ចក្ខុំ ឧទបាទិ ។ បេ ។

យុគនទ្ធវគ្គ បដិសម្ភិទាកថា

ក្នុងអត្ថនៃមគ្គរបស់មគ្គសច្ច មានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ក្នុងអរិយសច្ចទាំង ៤ មានធម៌ ១០០ មានអត្ថ ១០០ មាននិរុត្តិ ២០០ មានញាណ ៤០០ ។

[៨៣] ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយថា អត្ថនៃអត្ថប្បដិសម្ភិទា ព្រះមានព្រះភាគ ទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយបញ្ញា អត្ថនៃអត្ថប្បដិសម្ភិទា ព្រះមានព្រះភាគ មិនបានពាល់ត្រូវហើយ ដោយបញ្ញាមិនមានឡើយ ក្នុងអត្ថនៃអត្ថប្បដិសម្ភិទា របស់អត្ថប្បដិសម្ភិទា មានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយថា អត្ថនៃធម្មប្បដិសម្ភិទា របស់ធម្មប្បដិសម្ភិទា ទាំងប៉ុន្មាន ។ បេ ។ អត្ថនៃនិរុត្តិប្បដិសម្ភិទា របស់និរុត្តិប្បដិសម្ភិទាទាំងប៉ុន្មាន អត្ថនៃបដិភាណប្បដិសម្ភិទា របស់បដិភាណប្បដិសម្ភិទា ទាំងប៉ុន្មាន ព្រះមានព្រះភាគ ទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយបញ្ញា អត្ថ នៃបដិភាណប្បដិសម្ភិទា ព្រះមានព្រះភាគ មិនបានពាល់ត្រូវហើយ ដោយបញ្ញា មិនមានឡើយ

អាលោកោ ឧទបាទិ បដិភាណប្បដិសម្ភិទាយ បដិភាណប្បដិសម្ភិទដ្ឋេ បញ្ចវីសតិ ធម្មា បញ្ចវីសតិ អត្ថា បញ្ញាសំ និរុត្តិយោ សតញ្ញាណានិ ចតូសុ បដិសម្ភិទាសុ សតំ ធម្មា សតំ អត្ថា ទ្វេ និរុត្តិសតានិ ចត្តារិ ញាណសតានិ ។

[៨៤] យាវតា ឥន្ទ្រិយបរោបរិយត្តេ ញាណំ ញាតំ ទិដ្ឋំ វិទិតំ សច្ឆិកតំ ផស្សិតំ បញ្ញាយ អផស្សិតំ បញ្ញាយ ឥន្ទ្រិយបរោបរិយត្តេ ញាណំ នត្ថីតិ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ឥន្ទ្រិយបរោបរិយត្តេ ញាណេ បញ្ចវីសតិ ធម្មា បញ្ចវីសតិ អត្ថា បញ្ញាសំ និរុត្តិយោ សតញ្ញាណានិ យាវតា សត្តានំ អាសយានុសយេ ញាណំ ។ បេ ។ យាវតា យមកប្បាដិហិរេ ញាណំ យាវតា មហាករុណាសមាបត្តិយា ញាណំ យាវតា អនាវរណញាណំ[១] ញាតំ ទិដ្ឋំ វិទិតំ សច្ឆិកតំ ផស្សិតំ បញ្ញាយ អផស្សិតំ បញ្ញាយ អនាវរណញាណំ នត្ថីតិ

១ ម. យាវតា យមកប្បាដិហិរេ ញាណំ ។ បេ ។ យាវតា មហាករុណាសមាបត្តិយា ញាណំ ។ បេ ។ យាវតា សព្វញ្ញុតញ្ញាណំ ។ បេ ។ យាវតា អនាវរណំ ឥតិ ចាលិយានុក្កមោ ។

ក្នុងអត្ថនៃបដិភាណប្បដិសម្ភិទា របស់បដិភាណប្បដិសម្ភិទា មានធម៌២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ក្នុងបដិសម្ភិទាទាំង ៤ មានធម៌ ១០០ មានអត្ថ ១០០ មាននិរុត្តិ ២០០ មានញាណ ៤០០ ។

[៨៤] ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយថា ឥន្ទ្រិយបរោបរិយត្តញ្ញាណទាំងប៉ុន្មាន ព្រះមានព្រះភាគ ទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយប្រាជ្ញា ឥន្ទ្រិយបរោបរិយត្តញ្ញាណ ព្រះមានព្រះភាគ មិនបានពាល់ត្រូវហើយ ដោយប្រាជ្ញា មិនមានឡើយ ក្នុងឥន្ទ្រិយបរោបរិយត្តញ្ញាណ មានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយថា សត្តាសយានុសយញ្ញាណ ទាំងប៉ុន្មាន ។ បេ ។ យមកប្បាដិហិរញ្ញាណ ទាំងប៉ុន្មាន មហាករុណាសមាបត្តិញ្ញាណទាំងប៉ុន្មាន អនាវរណញ្ញាណ ទាំងប៉ុន្មាន ព្រះមានព្រះភាគ ទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយបញ្ញា អនាវរណញ្ញាណ ព្រះមានព្រះភាគមិនពាល់ត្រូវហើយដោយបញ្ញា មិនមានឡើយ

១៦១

យុគនទ្ធវគ្គេ បដិសម្ភិទាកថា

ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ អនាវរណោ ញាណោ បញ្ចវីសតិ ធម្មា បញ្ចវីសតិ អត្ថា បញ្ញាសំ និរុត្តិយោ សតញ្ញាណានិ ឆសុ ពុទ្ធធម្មេសុ ទិយឌ្ឍសតំ ធម្មា ទិយឌ្ឍសតំ អត្ថា តីណិ និរុត្តិសតានិ ឆ ញាណសតានិ បដិសម្ភិទាបករណោ អឌ្ឍនវមានិ ធម្មសតានិ អឌ្ឍនវមានិ អត្ថសតានិ[១] និរុត្តិសហស្សញ្ច សត្ត ច និរុត្តិសតានិ តីណិ ច ញាណសហស្សានិ ចត្តារិ ច ញាណសតានីតិ ។

បដិសម្ភិទាកថា ។

---

១ ឱ. ម. បដិភាណប្បដិសម្ភិទាធិករណោ អឌ្ឍនវមធម្មសតានិ អឌ្ឍនវមអត្ថសតានីតិ បទានុក្កមា ។

យុគនទ្ធវគ្គ បដិសម្ភិទាកថា

*ក្នុងអនាវរណញ្ញាណ មានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ក្នុងធម៌របស់ព្រះពុទ្ធទាំង ៦ មានធម៌ ១៥០ មានអត្ថ ១៥០ មាននិរុត្តិ ៣០០ មានញាណ ៦០០ ក្នុងបដិសម្ភិទាបករណ៍ មានធម៌ ៨៥០ មានអត្ថ ៨៥០ មាននិរុត្តិ ១០០០ ផង មាននិរុត្តិ ៧០០ ផង (និរុត្តិ ១៧០០) មានញាណ ៣០០០ ផង មានញាណ ៤០០ ផង (ញាណ ៣៤០០) ។*

ចប់ បដិសម្ភិទាកថា ។

# យុគនទ្ធវគ្គេ ធម្មចក្កកថា

[៨៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ។ បេ ។ ឥតិ ហិទំ អាយស្មតោ កោណ្ឌញ្ញស្ស អញ្ញាកោណ្ឌញ្ញោត្វេវ នាមំ[១] អហោសិ ។

ឥទំ ទុក្ខំ អរិយសច្ចន្តិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ ចក្ខុំ ឧទបាទីតិ កេនដ្ឋេន ញាណំ ឧទបាទីតិ កេនដ្ឋេន បញ្ញា ឧទបាទីតិ កេនដ្ឋេន វិជ្ជា ឧទបាទីតិ កេនដ្ឋេន អាលោកោ ឧទបាទីតិ កេនដ្ឋេន ។ ចក្ខុំ ឧទបាទីតិ ទស្សនដ្ឋេន ញាណំ ឧទបាទីតិ ញាតដ្ឋេន បញ្ញា ឧទបាទីតិ បជាននដ្ឋេន វិជ្ជា ឧទបាទីតិ បដិវេធដ្ឋេន អាលោកោ ឧទបាទីតិ ឱភាសដ្ឋេន ។

---

១ ម. អញ្ញាសិកោឌញ្ញោត្វេវ នាមន្តិ ទិស្សតិ ។ ឱ. អញ្ញាតកោណ្ឌញ្ញោត្វេវ នាមន្តិបិ ទិស្សតិ ។

# យុគនទ្ធវគ្គ ធម្មចក្កកថា

[៨៥] ខ្ញុំបានស្ដាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ទៀបក្រុងពាពណសី ។ បេ ។ ហេតុនោះ ពាក្យថា អញ្ញា-កោណ្ឌញ្ញៈ នេះ បានមកជាឈ្មោះ របស់ព្រះកោណ្ឌញ្ញៈមានអាយុ ។

ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះ ជាទុក្ខអរិយសច្ច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា ញាណកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា បញ្ញាកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្ដេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថាឃើញ ពាក្យថា ញាណកើតហើយ ដោយអត្ថថាដឹង ពាក្យថា បញ្ញាកើតហើយ ដោយអត្ថថាដឹងច្បាស់ ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថថាចាក់ធ្លុះ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថាភ្លឺស្វាង ។

យុគនទ្ធវគ្គេ ធម្មចក្កកថា

ចក្ខុំ ធម្មោ ធស្សនដ្ឋោ អត្ថោ ញាណំ ធម្មោ ញាតដ្ឋោ អត្ថោ បញ្ញា ធម្មោ បជាននដ្ឋោ អត្ថោ វិជ្ជា ធម្មោ បដិវេធដ្ឋោ អត្ថោ អាលោកោ ធម្មោ ឱភាសដ្ឋោ អត្ថោ ឥមេ បញ្ច ធម្មា បញ្ច អត្ថា ទុក្ខវត្ថុកា សច្ចវត្ថុកា សច្ចារម្មណា សច្ចគោចរា សច្ចសង្គហិតា សច្ចបរិយាបន្នា សច្ចេ សមុទាគតា[១] សច្ចេ ឋិតា សច្ចេ បតិដ្ឋិតា ។

[៨៦] ធម្មចក្កន្តិ កេនដ្ឋេន ធម្មចក្កំ ។ ធម្មញ្ច បវត្តេតិ ចក្កញ្ចាតិ ធម្មចក្កំ ចក្កញ្ច បវត្តេតិ ធម្មញ្ចាតិ ធម្មចក្កំ ធម្មេន បវត្តេតីតិ ធម្មចក្កំ ធម្មចរិយាយ បវត្តេតីតិ ធម្មចក្កំ ធម្មេ ឋិតោ បវត្តេតីតិ ធម្មចក្កំ ធម្មេ បតិដ្ឋិតោ បវត្តេតីតិ ធម្មចក្កំ ធម្មេ បតិដ្ឋាបេន្តោ បវត្តេតីតិ ធម្មចក្កំ ធម្មេ វសិប្បត្តោ បវត្តេតីតិ ធម្មចក្កំ ធម្មេ វសី បាបេន្តោ បវត្តេតីតិ ធម្មចក្កំ ធម្មេ បារមិប្បត្តោ បវត្តេតីតិ

១ ឱ. ម. សមុទាគតា ។

ចក្ខុជាធម៌ សេចក្ដីនៃការឃើញជាអត្ថ ញាណជាធម៌ សេចក្ដីនៃការដឹងជាអត្ថ បញ្ញាជាធម៌ សេចក្ដីនៃការដឹងច្បាស់ជាអត្ថ វិជ្ជាជាធម៌ សេចក្ដីនៃការចាក់ធ្លុះជាអត្ថ ពន្លឺជាធម៌ សេចក្ដីនៃការភ្លឺស្វាងជាអត្ថ នេះឯង ធម៌ទាំង ៥ អត្ថទាំង ៥ ដែលមានទុក្ខជាទីតាំង មានសច្ចៈជាទីតាំង មានសច្ចៈជាអារម្មណ៍ មានសច្ចៈជាគោចរ សង្គ្រោះចូលក្នុងសច្ចៈ រាប់ចូលក្នុងសច្ចៈ រួបរួមចូលក្នុងសច្ចៈ ឋិតនៅក្នុងសច្ចៈ តាំងនៅស៊ប់ក្នុងសច្ចៈ ។

[៨៦] សំណួរត្រង់ពាក្យថា ធម្មចក្រ តើធម្មចក្រ ដោយអត្ថដូចម្ដេច ។ ឈ្មោះថា ធម្មចក្រ ព្រោះព្រះមានព្រះភាគទ្រង់ញ៉ាំងធម៌និងចក្រឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងចក្រនិងធម៌ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម៌ ឈ្មោះថាជាធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម្មចរិយា ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឋិតនៅក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់តាំងនៅស៊ប់ក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វឲ្យតាំងនៅស៊ប់ក្នុងធម៌ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ដល់នូវការស្ទាត់ក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វឲ្យដល់ នូវការស្ទាត់ក្នុងធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ដល់នូវបារមីក្នុងធម៌ហើយ ឲ្យប្រព្រឹត្តទៅ

ធម្មចក្កំ ធម្មេ បារមឹ បាបេន្តោ បវត្តេតីតិ ធម្មចក្កំ ធម្មេ វេសារជ្ជប្បត្តោ បវត្តេតីតិ ធម្មចក្កំ ធម្មេ វេសារជ្ជំ បាបេន្តោ បវត្តេតីតិ ធម្មចក្កំ ធម្មំ សក្ករោន្តោ បវត្តេតីតិ ធម្មចក្កំ ធម្មំ គរុករោន្តោ បវត្តេតីតិ ធម្មចក្កំ ធម្មំ មានេន្តោ បវត្តេតីតិ ធម្មចក្កំ ធម្មំ បូជេន្តោ បវត្តេតីតិ ធម្មចក្កំ ធម្មំ អបចាយមានោ បវត្តេតីតិ ធម្មចក្កំ ធម្មទ្ធជោ បវត្តេតីតិ ធម្មចក្កំ ធម្មកេតុ បវត្តេតីតិ ធម្មចក្កំ ធម្មាធិបតេយ្យោ បវត្តេតីតិ ធម្មចក្កំ តំ ខោ បន ធម្មចក្កំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ ធម្មចក្កំ សទ្ធិន្ទ្រិយំ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ វិរិយិន្ទ្រិយំ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សតិន្ទ្រិយំ ធម្មោ តំ ធម្មំ បវត្តេតីតិ

ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វឲ្យដល់ នូវបារមីក្នុងធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ដល់នូវសេចក្តីក្លាហាន ក្នុងធម៌ ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វឲ្យដល់ នូវសេចក្តីក្លាហានក្នុងធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ធ្វើសក្ការៈចំពោះធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ធ្វើសេចក្តីគោរពចំពោះធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់រាប់អានធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់បូជាធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់កោតក្រែងធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់មានទង់ជ័យគឺធម៌ ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងទង់ជ័យ គឺ ធម៌ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ជាអធិបតីហេតុធម៌ ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះធម្មចក្រនោះ បុគ្គលនីមួយ ក្នុងលោក ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី មិនអាចធ្វើបដិវត្តបានឡើយ ឈ្មោះថាធម្មចក្រ ព្រោះសទ្ធិន្ទ្រិយ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ

យុគនទ្ធវគ្គេ ធម្មចក្កកថា

ធម្មចក្កំ សមាធិន្ទ្រិយំ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្ម-
ចក្កំ បញ្ញិន្ទ្រិយំ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ
សទ្ធាពលំ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ វីរិយ-
ពលំ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សតិពលំ
ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សមាធិពលំ
ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សមាធិពលំ
ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ បញ្ញាពលំ ធ-
ម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សតិសម្ពោជ្ឈង្គោ
ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ ធម្មវិចយស-
ម្ពោជ្ឈង្គោ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ វីរិយ-
សម្ពោជ្ឈង្គោ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ
បីតិសម្ពោជ្ឈង្គោ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ
បស្សទ្ធិសម្ពោជ្ឈង្គោ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្ម-
ចក្កំ សមាធិសម្ពោជ្ឈង្គោ ធម្មោ តំ ធម្មំ បវត្តេតីតិ

ឈ្មោះថាធម្មចក្រ ព្រោះវីរិយិន្ទ្រិយ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសតិន្ទ្រិយ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសមាធិន្ទ្រិយ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះបញ្ញិន្ទ្រិយ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសទ្ធាពលៈ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះវីរិយពលៈ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសតិពលៈ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសមាធិពលៈ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះបញ្ញាពលៈ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសតិសម្ពោជ្ឈង្គ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះធម្មវិចយសម្ពោជ្ឈង្គ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះវីរិយសម្ពោជ្ឈង្គ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះបីតិសម្ពោជ្ឈង្គ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះបស្សទ្ធិសម្ពោជ្ឈង្គ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសមាធិសម្ពោជ្ឈង្គ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ

ធម្មចក្កំ ឧបេក្ខាសម្ពោជ្ឈង្គោ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សម្មាទិដ្ឋិ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សម្មាសង្កប្បោ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សម្មាវាចា ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សម្មាកម្មន្តោ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សម្មាអាជីវោ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សម្មាវាយាមោ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សម្មាសតិ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សម្មាសមាធិ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ អាធិបតេយ្យដ្ឋេន ឥន្ទ្រិយា(១) ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ អកម្បិយដ្ឋេន ពលា(២) ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ និយ្យានដ្ឋេន(៣) ពោជ្ឈង្គោ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ ហេតុដ្ឋេន មគ្គោ ធម្មោ តំ ធម្មំ បវត្តេតីតិ

១ ម. ឥន្ទ្រិយំ ។ ២ ម. ពលំ ។ ៣ ម. និយ្យានិកដ្ឋេន ។

ឈ្មោះថាធម្មចក្រ ព្រោះឧបេក្ខាសម្ពោជ្ឈង្គ ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសម្មាទិដ្ឋិ ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសម្មាសង្កប្បៈ ជាធម៌ ទ្រង់ញុំាងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសម្មាវាចា ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្ម-ចក្រ ព្រោះសម្មាកម្មន្តៈ ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសម្មាអាជីវៈ ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសម្មាវាយាមៈ ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសម្មាសតិ ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសម្មាសមាធិ ជាធម៌ ទ្រង់ញុំាងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះឥន្ទ្រិយ ដោយអត្ថថាជាអធិបតី ជាធម៌ ទ្រង់ញុំាងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះពលៈ ដោយអត្ថថាមិនកម្រើក ជាធម៌ ទ្រង់ញុំាងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះពោជ្ឈង្គៈ ដោយអត្ថថាចេញ (ចាកវដ្តៈ) ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះមគ្គ ដោយអត្ថថាជាហេតុ ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ

១៦៧

### យុគនទ្ធវគ្គេ ធម្មចក្កកថា

ធម្មចក្កំ ឧបដ្ឋានដ្ឋេន សតិប្បដ្ឋានា ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ បធានដ្ឋេន សម្មប្បធានា ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ ឥជ្ឈនដ្ឋេន ឥទ្ធិបាទា ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ តថដ្ឋេន សច្ចា ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ អវិក្ខេបដ្ឋេន សមថោ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ អនុបស្សនដ្ឋេន វិបស្សនា ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ ឯករសដ្ឋេន សមថវិបស្សនា ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ អនតិវត្តនដ្ឋេន យុគនទ្ធំ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សំវរដ្ឋេន សីលវិសុទ្ធិ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ ធម្មោ តំ ធម្មំ បវត្តេតីតិ

ឈ្មោះថាធម្មចក្រ ព្រោះសតិប្បដ្ឋាន ដោយអត្ថថាប្រុងប្រយ័ត្ន ជាធម៌ ទ្រង់ញុំាងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសម្មប្បធាន ដោយអត្ថថាតម្កល់ ជាធម៌ ទ្រង់ញុំាងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះឥទ្ធិបាទ ដោយអត្ថថាសម្រេច ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសច្ចៈ ដោយអត្ថថាពិត ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសមថៈ ដោយអត្ថថាមិនរាយមាយ ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះវិបស្សនា ដោយអត្ថថាពិចារណាឃើញ ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសមថៈ និងវិបស្សនា ដោយអត្ថថា មានរសតែមួយ ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះការជាប់គ្នាជាគូ ដោយអត្ថថាមិនប្រព្រឹត្តលើសគ្នា ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះចិត្តវិសុទ្ធិ ដោយអត្ថថាមិនរាយមាយ ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ

ធម្មចក្កំ ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ មុត្តដ្ឋេន វិមោក្ខោ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ បដិវេធដ្ឋេន វិជ្ជា ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ បរិច្ចាគដ្ឋេន វិមុត្តិ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សមុច្ឆេទដ្ឋេន ខយេ ញាណំ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ បដិប្បស្សទ្ធដ្ឋេន អនុប្បាទេ ញាណំ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ ឆន្ទោ មូលដ្ឋេន ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ មនសិការោ សមុដ្ឋានដ្ឋេន ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ ផស្សោ សមោធានដ្ឋេន ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ វេទនា សមោសរណដ្ឋេន ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សមាធិ បមុខដ្ឋេន ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ សតិ អាធិបតេយ្យដ្ឋេន ធម្មោ តំ ធម្មំ បវត្តេតីតិ

ឈ្មោះថាធម្មចក្រ ព្រោះទិដ្ឋិវិសុទ្ធិ ដោយអត្ថថាឃើញ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះវិមោក្ខ ដោយអត្ថថារួច ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះវិជ្ជា ដោយអត្ថថាចាក់ធ្លុះ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះវិមុត្តិ ដោយអត្ថថាលះបង់ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះខយញ្ញាណ ដោយអត្ថថាកាត់ផ្តាច់ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះអនុប្បាទញ្ញាណ ដោយអត្ថថាស្ងប់ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះឆន្ទៈ ដោយអត្ថថាជាឫស ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះមនសិការៈ ដោយអត្ថថាកើតឡើងព្រម ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះផស្សៈ ដោយអត្ថថារួបរួម ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះវេទនា ដោយអត្ថថាប្រជុំចុះ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសមាធិ ដោយអត្ថថាជាប្រមុខ ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសតិ ដោយអត្ថថាជាអធិបតី ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ

ធម្មចក្កំ បញ្ញា តទុត្តរដ្ឋេន ធម្មោ តំ ធម្មំ បវត្តេ-
តីតិ ធម្មចក្កំ វិមុត្តិ សារដ្ឋេន ធម្មោ តំ ធម្មំ បវត្តេ-
តីតិ ធម្មចក្កំ អមតោគធំ និព្វានំ បរិយោសានដ្ឋេន
ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ ។

[៨៧] តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យ-
ន្តិ ។ បេ ។ បរិញ្ញាតន្តិ បុព្វេ អននុស្សុតេសុ ធម្មេសុ
ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ ចក្ខុំ
ឧទបាទីតិ កេនដ្ឋេន ។ បេ ។ អាលោកោ ឧទបាទីតិ
កេនដ្ឋេន ។ ចក្ខុំ ឧទបាទីតិ ទស្សនដ្ឋេន ។ បេ ។
អាលោកោ ឧទបាទីតិ ឱភាសដ្ឋេន ។

ចក្ខុំ ធម្មោ ទស្សនដ្ឋោ អត្ថោ ។ បេ ។ អាលោ-
កោ ធម្មោ ឱភាសដ្ឋោ អត្ថោ ឥមេ បញ្ច ធម្មា
បញ្ច អត្ថា ទុក្ខវត្ថុកា សច្ចវត្ថុកា សច្ចារម្មណា
សច្ចគោចរា សច្ចសង្គហិតា សច្ចបរិយាបន្នា សច្ចេ
សមុទាគតា សច្ចេ ឋិតា សច្ចេ បតិដ្ឋិតា ។

ឈ្មោះថាធម្មចក្រ ព្រោះបញ្ញា ដោយអត្ថថាក្រៃលែងជាងធម៌ទាំងនោះ ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះវិមុត្តិ ដោយអត្ថថាជាខ្លឹម ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះអមតនិព្វាន ដោយអត្ថថាជាទីបំផុត (នៃកិច្ចក្នុងសាសនា) ជាធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ។

[៨៧] ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំង-ឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ជាទុក្ខអរិយសច្ច ដែលតថាគតគួរកំណត់ដឹង ។ បេ ។ ថា នេះជាទុក្ខអរិយសច្ច ដែលតថាគតកំណត់ដឹងហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្ដេច ។ បេ ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្ដេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថាឃើញ ។ បេ ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថាភ្លឺស្វាង ។

ចក្ខុ ជាធម៌ សេចក្ដីនៃការឃើញ ជាអត្ថ ។ បេ ។ ពន្លឺ ជាធម៌ សេចក្ដីនៃការភ្លឺស្វាង ជាអត្ថ ធម៌ទាំង ៥ អត្ថទាំង ៥ នេះ មានទុក្ខជាទីតាំង មានសច្ចៈជាទីតាំង មានសច្ចៈជាអារម្មណ៍ មានសច្ចៈជាគោចរ សង្គ្រោះចូលក្នុងសច្ចៈ រាប់បញ្ចូលក្នុងសច្ចៈ រួបរួមចូលក្នុងសច្ចៈ ឋិតនៅក្នុងសច្ចៈ តាំងនៅស៊ប់ក្នុងសច្ចៈ ។

ធម្មចក្កន្តិ កេនដ្ឋេន ធម្មចក្កំ ។ ធម្មញ្ច បវត្តេតិ ចក្កញ្ចាតិ ធម្មចក្កំ ចក្កញ្ច បវត្តេតិ ធម្មញ្ចាតិ ធម្មចក្កំ ធម្មេន បវត្តេតីតិ ធម្មចក្កំ ធម្មចរិយាយ បវត្តេតីតិ ធម្មចក្កំ ធម្មេ ឋិតោ បវត្តេតីតិ ធម្មចក្កំ ធម្មេ បតិដ្ឋិតោ បវត្តេតីតិ ធម្មចក្កំ ។ បេ ។ អមតោគធំ និព្វានំ បរិយោសានដ្ឋេន ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ ។

[៨៨] ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វន្តិ ។ បេ ។ បហីនន្តិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ ចក្ខុំ ឧទបាទីតិ កេនដ្ឋេន ។ បេ ។ អាលោកោ ឧទបាទីតិ កេនដ្ឋេន ។ ចក្ខុំ ឧទបាទីតិ ទស្សនដ្ឋេន ។ បេ ។ អាលោកោ ឧទបាទីតិ ឱភាសដ្ឋេន ។

សំណួរត្រង់ពាក្យថា ធម្មចក្រ តើធម្មចក្រ ដោយអត្ថដូចម្តេច ។ ឈ្មោះថាធម្មចក្រ ព្រោះព្រះមានព្រះភាគ ទ្រង់ញ៉ាំងធម៌និងចក្រឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងចក្រនិងធម៌ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម៌ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម្មចរិយា ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឋិតនៅក្នុងធម៌ហើយ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់តាំងនៅស៊ប់ក្នុងធម៌ហើយ ឲ្យប្រព្រឹត្តទៅ ។ បេ ។ ឈ្មោះថាធម្មចក្រ ព្រោះអមតនិព្វាន ដោយអត្ថថាជាទីបំផុត (នៃកិច្ចក្នុងសាសនា) ជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ។

[៨៨] ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះ ជាទុក្ខសមុទយ-អរិយសច្ច ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំង-ឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ជាទុក្ខសមុទយអរិយសច្ចដែលតថាគតគួរលះបង់ ។ បេ ។ ថា នេះ ជាទុក្ខសមុទយអរិយសច្ចដែលតថាគតលះបង់ហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ។ បេ ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្តេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថាឃើញ ។ បេ ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថាភ្លឺស្វាង ។

១៧១



ចក្ខុំ ធម្មោ ទស្សនដ្ឋោ អត្ថោ ។ បេ ។ អាលោកោ ធម្មោ ឱភាសដ្ឋោ អត្ថោ ឥមេ បញ្ច ធម្មា បញ្ច អត្ថា សមុទយវត្ថុកា សច្ចវត្ថុកា ។ បេ ។ និរោធវត្ថុកា មគ្គវត្ថុកា សច្ចវត្ថុកា[១] សច្ចារម្មណា សច្ចគោចរា សច្ចសង្គហិតា សច្ចបរិយាបន្នា សច្ចេ សមុទាគតា សច្ចេ ឋិតា សច្ចេ បតិដ្ឋិតា ។

ធម្មចក្កន្តិ កេនដ្ឋេន ធម្មចក្កំ ។ ធម្មញ្ច បវត្តេតិ ចក្កញ្ចាតិ ធម្មចក្កំ ចក្កញ្ច បវត្តេតិ ធម្មញ្ចាតិ ធម្មចក្កំ ធម្មេន បវត្តេតីតិ ធម្មចក្កំ ធម្មចរិយាយ បវត្តេតីតិ ធម្មចក្កំ ធម្មេ ឋិតោ បវត្តេតីតិ ធម្មចក្កំ ធម្មេ បតិដ្ឋិតោ បវត្តេតីតិ ធម្មចក្កំ ។ បេ ។ អមតោគធំ និព្វានំ បរិយោសានដ្ឋេន ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ ។

[៨៩] អយំ កាយេ កាយានុបស្សនាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ សា ខោ បនាយំ កាយេ

---

១ ឱ. ម. និរោធវត្ថុកា សច្ចវត្ថុកា ។ បេ ។ មគ្គវត្ថុកា សច្ចវត្ថុកាតិ បទានុក្កមោ ។

*ចក្ខុ ជាធម៌ សេចក្ដីនៃការឃើញ ជាអត្ថ ។ បេ ។ ពន្លឺ ជាធម៌ សេចក្ដីនៃការណ៍ភ្លឺស្វាង ជាអត្ថ ធម៌ទាំង ៥ អត្ថទាំង ៥ មាន សមុទ័យជាទីតាំង មានសច្ចៈជាទីតាំង ។ បេ ។ មាននិរោធជាទីតាំង មានមគ្គជាទីតាំង មានសច្ចៈជាទីតាំង មានសច្ចៈជាអារម្មណ៍ មាន សច្ចៈជាគោចរ សង្គ្រោះចូលក្នុងសច្ចៈ រាប់បញ្ចូលក្នុងសច្ចៈ រួបរួម ចូលក្នុងសច្ចៈ ឋិតនៅក្នុងសច្ចៈ តាំងនៅស៊ប់ក្នុងសច្ចៈ ។*

*សំណួរត្រង់ពាក្យថា ធម្មចក្រ តើធម្មចក្រ ដោយអត្ថដូចម្ដេច ។ ឈ្មោះជាធម្មចក្រ ព្រោះព្រះមានព្រះភាគ ទ្រង់ញុំាងធម៌និងចក្រឲ្យ ប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញុំាងចក្រនិងធម៌ ឲ្យប្រព្រឹត្ត ទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម៌ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅ ដោយធម្មចរិយា ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឋិតនៅក្នុងធម៌ហើយ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះ ទ្រង់តាំងនៅស៊ប់ក្នុងធម៌ហើយ ឲ្យប្រព្រឹត្តទៅ ។ បេ ។ ឈ្មោះថាធម្មចក្រ ព្រោះអមតនិព្វាន ដោយអត្ថថាជាទីបំផុត (នៃកិច្ចក្នុងសាសនា) ជា ធម៌ ទ្រង់ញុំាងធម៌នោះ ឲ្យប្រព្រឹត្តទៅ ។*

*[៨៩] ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើត ហើយ ។ បេ ។ មានពន្លឺ កើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះ កាយេកាយានុបស្សនា*

កាយានុបស្សនា ភាវេតព្វាតិ មេ ភិក្ខវេ ។ បេ ។ ភាវិតាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ បេ ។ អយំ វេទនាសុ ។ បេ ។ អយំ ចិត្តេ ។ បេ ។ អយំ ធម្មេសុ ធម្មានុបស្សនាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ សា ខោ បនាយំ ធម្មេសុ ធម្មានុបស្សនា ភាវេតព្វាតិ មេ ភិក្ខវេ ។ បេ ។ ភាវិតាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ អយំ កាយេ កាយានុបស្សនាតិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ សា ខោ បនាយំ កាយេ កាយានុបស្សនា ភាវេតព្វាតិ ។ បេ ។ ភាវិតាតិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។ ចក្ខុំ ឧទបាទីតិ កេនដ្ឋេន ។ បេ ។ អាលោកោ ឧទបាទីតិ កេនដ្ឋេន ។ បេ ។ ចក្ខុំ ឧទបាទីតិ ទស្សនដ្ឋេន ។ បេ ។ អាលោកោ ឧទបាទីតិ ឱភាសដ្ឋេន ។

ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ កាយេកាយានុបស្សនា ដែលតថាគតគួរចម្រើន ។ បេ ។ ថា នេះ កាយេកាយានុបស្សនា ដែលតថាគតចម្រើនហើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុន ថា នេះ វេទនាសុវេទនានុបស្សនា ។ បេ ។ ថា នេះ ចិត្តេចិត្តានុបស្សនា ។ បេ ។ ថា នេះធម្មេសុធម្មានុបស្សនា ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ធម្មេសុធម្មានុបស្សនា ដែលតថាគតគួរចម្រើន ។ បេ ។ ថា នេះ ធម្មេសុធម្មានុបស្សនា ដែលតថាគតចម្រើនហើយ ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ កាយេកាយានុបស្សនា ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុន ថា នេះ កាយេកាយានុបស្សនា ដែលតថាគតគួរចម្រើន ។ បេ ។ ថា នេះកាយេកាយានុបស្សនា ដែលតថាគតចម្រើនហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ។ បេ ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថាដូចម្តេច ។ បេ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថាឃើញ ។ បេ ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថាភ្លឺស្វាង ។

ចក្ខុំ ធម្មោ ទស្សនដ្ឋោ អត្ថោ ។ បេ ។ អាលោកោ ធម្មោ ឱភាសដ្ឋោ អត្ថោ ឥមេ បញ្ច ធម្មា បញ្ច អត្ថា កាយវត្ថុកា សតិប្បដ្ឋានវត្ថុកា ។ បេ ។ វេទនាវត្ថុកា សតិប្បដ្ឋានវត្ថុកា ចិត្តវត្ថុកា សតិប្បដ្ឋានវត្ថុកា ធម្មវត្ថុកា សតិប្បដ្ឋានវត្ថុកា សតិប្បដ្ឋានារម្មណា សតិប្បដ្ឋានគោចរា សតិប្បដ្ឋានសង្គហិតា សតិប្បដ្ឋានបរិយាបន្នា សតិប្បដ្ឋានេ សមុទាគតា សតិប្បដ្ឋានេ ឋិតា សតិប្បដ្ឋានេ បតិដ្ឋិតា ។

ធម្មចក្កន្តិ កេនដ្ឋេន ធម្មចក្កំ ។ ធម្មញ្ច បវត្តេតិ ចក្កញ្ចាតិ ធម្មចក្កំ ចក្កញ្ច បវត្តេតិ ធម្មញ្ចាតិ ធម្មចក្កំ ធម្មេន បវត្តេតីតិ ធម្មចក្កំ ធម្មចរិយាយ បវត្តេតីតិ ធម្មចក្កំ ធម្មេ ឋិតោ បវត្តេតីតិ ធម្មចក្កំ ធម្មេ បតិដ្ឋិតោ បវត្តេតីតិ ធម្មចក្កំ ។ បេ ។ អមតោគធំ និព្វានំ បរិយោសានដ្ឋេន ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ ។

យុគនទ្ធវគ្គ ធម្មចក្កកថា

ចក្ខុ ជាធម៌ សេចក្តីនៃការឃើញ ជាអត្ថ ។ បេ ។ ពន្លឺ ជាធម៌ សេចក្តីនៃការណ៍ភ្លឺស្វាង ជាអត្ថ ធម៌ទាំង ៥ អត្ថទាំង ៥ នេះ មានកាយជាទីតាំង មានសតិប្បដ្ឋានជាទីតាំង ។ បេ ។ មានវេទនាជាទីតាំង មានសតិប្បដ្ឋានជាទីតាំង មានចិត្តជាទីតាំង មានសតិប្បដ្ឋានជាទីតាំង មានធម៌ជាទីតាំង មានសតិប្បដ្ឋានជាទីតាំង មានសតិប្បដ្ឋានជាអារម្មណ៍ មានសតិប្បដ្ឋានជាគោចរ សង្គ្រោះចូលក្នុងសតិប្បដ្ឋាន រាប់បញ្ចូលក្នុងសតិប្បដ្ឋាន រួបរួមចូលក្នុងសតិប្បដ្ឋាន ឋិតនៅក្នុងសតិប្បដ្ឋាន តាំងនៅស៊ប់ក្នុងសតិប្បដ្ឋាន ។

សំណួរត្រង់ពាក្យថា ធម្មចក្រ តើធម្មចក្រ ដោយអត្ថដូចម្តេច ។ ឈ្មោះថាធម្មចក្រ ព្រោះព្រះមានព្រះភាគទ្រង់ញុំាងធម៌និងចក្រឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញុំាងចក្រនិងធម៌ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម៌ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម្មចរិយា ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឋិតនៅក្នុងធម៌ហើយ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់តាំងនៅស៊ប់ក្នុងធម៌ហើយ ឲ្យប្រព្រឹត្តទៅ ។ បេ ។ ឈ្មោះថាធម្មចក្រ ព្រោះអមតនិព្វាន ដោយអត្ថថាជាទីបំផុត (នៃកិច្ចក្នុងសាសនា) ជាធម៌ ទ្រង់ញុំាងធម៌នោះឲ្យប្រព្រឹត្តទៅ ។

[៩០] អយំ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ សោ ខោ បនាយំ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោ ភាវេតព្វោតិ មេ ភិក្ខវេ ។ បេ ។ ភាវិតោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ អយំ វីរិយសមាធិ ។ បេ ។ អយំ ចិត្តសមាធិ ។ បេ ។ អយំ វីមំសាសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ សោ ខោ បនាយំ វីមំសាសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោ ភាវេតព្វោតិ មេ ភិក្ខវេ ។ បេ ។ ភាវិតោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ ។

[៩០] ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ឥទ្ធិបាទ(១) ប្រកបដោយឆន្ទសមាធិ(២) និងបធានសង្ខារ(៣) ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ដែលតថាគតគួរចម្រើន ។ បេ ។ ថា នេះ ឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ដែលតថាគតចម្រើនហើយ ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ឥទ្ធិបាទ ប្រកបដោយវិរិយសមាធិ ។ បេ ។ ថា នេះ ឥទ្ធិបាទ ប្រកបដោយចិត្តសមាធិ ។ បេ ។ ថា នេះ ឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ម្នាលភិក្ខុទាំងឡាយ តថាគត មានចក្ខុកើតហើយ ។ បេ ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ដែលតថាគតគួរចម្រើន ។ បេ ។ ថា នេះ ឥទ្ធិបាទ ប្រកបដោយវីមំសា-សមាធិនិងបធានសង្ខារ ដែលតថាគតចម្រើនហើយ ។

---

១ ធម៌ជាជើងនៃឫទ្ធិ ឬជាទីតាំងនៃឫទ្ធិ ។ ២ សមាធិមានឆន្ទៈជាហេតុ ឬថា សមាធិអាស្រ័យឆន្ទៈ ។ ៣ បានដល់សម្មប្បធានទាំង ៤ ។

១៧៤

យុគនទ្ធវគ្គេ ធម្មចក្កកថា

អយំ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោតិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ សោ ខោ បនាយំ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោ ភាវេតព្វោតិ ។ បេ ។ ភាវិតោតិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ ចក្ខុំ ឧទបាទីតិ កេនដ្ឋេន ញាណំ ឧទបាទីតិ កេនដ្ឋេន បញ្ញា ឧទបាទីតិ កេនដ្ឋេន វិជ្ជា ឧទបាទីតិ កេនដ្ឋេន អាលោកោ ឧទបាទីតិ កេនដ្ឋេន ។ ចក្ខុំ ឧទបាទីតិ ទស្សនដ្ឋេន ញាណំ ឧទបាទីតិ ញាតដ្ឋេន បញ្ញា ឧទបាទីតិ បជាននដ្ឋេន វិជ្ជា ឧទបាទីតិ បដិវេធដ្ឋេន អាលោកោ ឧទបាទីតិ ឱភាសដ្ឋេន ។

ចក្ខុំ ធម្មោ ទស្សនដ្ឋោ អត្ថោ ញាណំ ធម្មោ ញាតដ្ឋោ អត្ថោ បញ្ញា ធម្មោ បជាននដ្ឋោ អត្ថោ

ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារដែលតថាគតគួរចម្រើន ។ បេ ។ ថា នេះ ឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ដែលតថាគតចម្រើនហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា ញាណកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា បញ្ញាកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្ដេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថាឃើញ ពាក្យថា ញាណកើតហើយ ដោយអត្ថថាដឹង ពាក្យថា បញ្ញាកើតហើយ ដោយអត្ថថាដឹងច្បាស់ ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថថាចាក់ធ្លុះ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថាភ្លឺស្វាង ។

ចក្ខុ ជាធម៌ សេចក្ដីនៃការឃើញ ជាអត្ថ ញាណជាធម៌ សេចក្ដីនៃការដឹង ជាអត្ថ បញ្ញា ជាធម៌ សេចក្ដីនៃការដឹងច្បាស់ ជាអត្ថ

វិជ្ជា ធម្មោ បដិវេធដ្ឋោ អត្ថោ អាលោកោ ធម្មោ ឱភាសដ្ឋោ អត្ថោ ឥមេ បញ្ច ធម្មា បញ្ច អត្ថា ឆន្ទវត្ថុកា ឥទ្ធិបាទវត្ថុកា ឥទ្ធិបាទារម្មណា ឥទ្ធិ-បាទគោចរា ឥទ្ធិបាទសង្គហិតា ឥទ្ធិបាទបរិយាបន្នា ឥទ្ធិបាទេ សមុទាគតា ឥទ្ធិបាទេ ឋិតា ឥទ្ធិបាទេ បតិដ្ឋិតា ។

ធម្មចក្កន្តិ កេនដ្ឋេន ធម្មចក្កំ ។ ធម្មញ្ច បវត្តេតិ ចក្កញ្ចាតិ ធម្មចក្កំ ចក្កញ្ច បវត្តេតិ ធម្មញ្ចាតិ ធម្មចក្កំ ធម្មេន បវត្តេតីតិ ធម្មចក្កំ ធម្មចរិយាយ បវត្តេតីតិ ធម្មចក្កំ ធម្មេ ឋិតោ បវត្តេតីតិ ធម្មចក្កំ ធម្មេ បតិដ្ឋិតោ បវត្តេតីតិ ធម្មចក្កំ ធម្មេ បតិដ្ឋាបេន្តោ បវត្តេតីតិ ធម្មចក្កំ ធម្មេ វសិប្បត្តោ បវត្តេតីតិ ធម្មចក្កំ ធម្មេ វសី ចា-បេន្តោ បវត្តេតីតិ ធម្មចក្កំ ធម្មេ បារមិប្បត្តោ បវត្តេតីតិ

វិជ្ជាជាធម៌ សេចក្តីនៃការចាក់ធ្លុះជាអត្ថ ពន្លឺជាធម៌ សេចក្តីនៃការណ៍ភ្លឺស្វាងជាអត្ថ ធម៌ទាំង៥ អត្ថទាំង៥ នេះ មានឆន្ទៈជាទីតាំង មានឥទ្ធិបាទជាទីតាំង មានឥទ្ធិបាទជាអារម្មណ៍ មានឥទ្ធិបាទជាគោចរ សង្គ្រោះចូលក្នុងឥទ្ធិបាទ រាប់បញ្ចូលក្នុងឥទ្ធិបាទ រួបរួមចូលក្នុងឥទ្ធិបាទ ឋិតនៅក្នុងឥទ្ធិបាទ តាំងនៅស៊ប់ក្នុងឥទ្ធិបាទ ។

សំណួរត្រង់ពាក្យថា ធម្មចក្រ តើធម្មចក្រ ដោយអត្ថដូចម្តេច ។ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងធម៌និងចក្រ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងចក្រនិងធម៌ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម៌ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម្មចរិយា ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឋិតនៅក្នុងធម៌ហើយ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់តាំងនៅស៊ប់ក្នុងធម៌ហើយ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វឲ្យតាំងនៅក្នុងធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ដល់នូវការស្ទាត់ក្នុងធម៌ហើយ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វឲ្យដល់ នូវការស្ទាត់ក្នុងធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ដល់នូវបារមីក្នុងធម៌ហើយ ឲ្យប្រព្រឹត្តទៅ

ធម្មចក្កំ ធម្មេ បារមឹ បាបេន្តោ បវត្តេតីតិ ធម្មចក្កំ ធម្មេ អបចាយមានោ បវត្តេតីតិ ធម្មចក្កំ ធម្មទ្ធជោ បវត្តេតីតិ ធម្មចក្កំ ធម្មកោតុំ បវត្តេតីតិ ធម្មចក្កំ ធម្មាធិបតេយ្យោ បវត្តេតីតិ ធម្មចក្កំ តំ ខោ បន ធម្មចក្កំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ ធម្មចក្កំ សទ្ធិន្ទ្រិយំ ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ ។ បេ ។ អមតោគធំ និព្វានំ បរិយោសានដ្ឋេន ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កំ ។

អយំ វីរិយសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោតិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបាទិ សោ ខោ បនាយំ វីរិយសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោ ភាវេតព្វោតិ ។ បេ ។ ភាវិតោតិ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។បេ។ អាលោកោ ឧទបាទិ ។

ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វឲ្យដល់នូវបារមីក្នុងធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់កោតក្រែងចំពោះធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់មានទង់ជ័យគឺធម៌ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងទង់ជ័យគឺធម៌ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់មានធម៌ជាអធិបតី ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះធម្មចក្រ បុគ្គលណានីមួយក្នុងលោក ទោះជាសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី មិនអាចឲ្យប្រព្រឹត្តទៅបានទេ ឈ្មោះថាធម្មចក្រ ព្រោះសទ្ធិន្ទ្រិយជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ។ បេ ។ ឈ្មោះថាធម្មចក្រ ព្រោះអមតនិព្វាន ដោយអត្ថថាជាទីបំផុត (នៃកិច្ចក្នុងសាសនា) ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ។

ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះ ឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ថា នេះ ឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិងបធាន-សង្ខារ ដែលតថាគតគួរចម្រើន ចក្ខុកើតហើយ ។ បេ ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះ ឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ដែលតថាគតចម្រើនហើយ ។

ចក្ខុំ ឧទបាទីតិ កេនដ្ឋេន ។ បេ ។ អាលោកោ ឧទបាទីតិ កេនដ្ឋេន ។ ចក្ខុំ ឧទបាទីតិ ទស្សនដ្ឋេន ។ បេ ។ អាលោកោ ឧទបាទីតិ ឱភាសដ្ឋេន ។

ចក្ខុំ ធម្មោ ទស្សនដ្ឋោ អត្ថោ ។ បេ ។ អាលោកោ ធម្មោ ឱភាសដ្ឋោ អត្ថោ ឥមេ បញ្ច ធម្មា បញ្ច អត្ថា វីរិយវត្ថុកា ឥទ្ធិបាទវត្ថុកា ។ បេ ។ ចិត្តវត្ថុកា ឥទ្ធិបាទវត្ថុកា វីមំសាវត្ថុកា ឥទ្ធិបាទវត្ថុកា ឥទ្ធិបាទារម្មណា ឥទ្ធិបាទគោចរា ឥទ្ធិបាទសង្គហិតា ឥទ្ធិបាទបរិយាបន្នា ឥទ្ធិបាទេ សមុទាគតា ឥទ្ធិបាទេ ឋិតា ឥទ្ធិបាទេ បតិដ្ឋិតា ។

ធម្មចក្កន្តិ កេនដ្ឋេន ធម្មចក្កំ ។ ធម្មញ្ច បវត្តេតិ ចក្កញ្ចាតិ ធម្មចក្កំ ចក្កញ្ច បវត្តេតិ ធម្មញ្ចាតិ ធម្មចក្កំ ធម្មេន បវត្តេតីតិ ធម្មចក្កំ ធម្មចរិយាយ បវត្តេតីតិ ធម្មចក្កំ ធម្មេ ឋិតោ បវត្តេតីតិ ធម្មចក្កំ ធម្មេ បតិដ្ឋិតោ បវត្តេតីតិ ធម្មចក្កំ ។ បេ ។ អមតោគធំ និព្វានំ បរិយោសានដ្ឋេន ធម្មោ តំ ធម្មំ បវត្តេតីតិ ធម្មចក្កន្តិ ។

ធម្មចក្កកថា ។

---

ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ។ បេ ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្តេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថាឃើញ ។ បេ ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថាភ្លឺស្វាង ។

ចក្ខុជាធម៌ សេចក្តីនៃការយល់ឃើញជាអត្ថ ។ បេ ។ ពន្លឺជាធម៌ សេចក្តីនៃការណ៍ភ្លឺស្វាងជាអត្ថ ធម៌ទាំង ៥ អត្ថទាំង ៥ នេះមានវីរិយៈជាទីតាំង មានឥទ្ធិបាទជាទីតាំង ។ បេ ។ មានចិត្តជាទីតាំង មានឥទ្ធិបាទជាទីតាំង មានវីមំសាជាទីតាំង មានឥទ្ធិបាទជាទីតាំង មានឥទ្ធិបាទជាអារម្មណ៍ មានឥទ្ធិបាទជាគោចរ សង្គ្រោះចូលក្នុងឥទ្ធិបាទ រាប់បញ្ចូលក្នុងឥទ្ធិបាទ រួបរួមចូលក្នុងឥទ្ធិបាទ ឋិតនៅក្នុងឥទ្ធិបាទ តាំងនៅស៊ប់ក្នុងឥទ្ធិបាទ ។

សំណួរត្រង់ពាក្យថា ធម្មចក្រ តើធម្មចក្រ ដោយអត្ថដូចម្តេច ។ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងធម៌និងចក្រឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងចក្រនិងធម៌ ឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម៌ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម្មចរិយា ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឋិតនៅក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់តាំងនៅស៊ប់ក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ។ បេ ។ ឈ្មោះថាធម្មចក្រ ព្រោះអមតនិព្វានជាធម៌ ដោយអត្ថថាជាទីបំផុត (នៃកិច្ចក្នុងសាសនា) ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ។

ចប់ ធម្មចក្កកថា ។

---

# យុគនទ្ធវគ្គេ លោកុត្តរកថា

[៩១] កតមេ ធម្មា លោកុត្តរា ។ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិ-ចាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈ-ង្គា[១] អដ្ឋង្គិកោ មគ្គោ ចត្តារោ អរិយមគ្គា ចត្តារិ ច សាមញ្ញផលានិ និព្វានញ្ច ឥមេ ធម្មា លោកុត្តរាតិ ។

លោកុត្តរាតិ កេនដ្ឋេន លោកុត្តរា ។ លោ-កំ ឧត្តរន្តីតិ[២] លោកុត្តរា លោកតោ[៣] ឧត្តរន្តី-តិ លោកុត្តរា លោកា[៤] ឧត្តរន្តីតិ លោកុត្តរា លោកម្ហា ឧត្តរន្តីតិ លោកុត្តរា លោកំ សមតិ-ក្កមន្តីតិ លោកុត្តរា លោកំ សមតិក្កមន្តាតិ[៥] លោកុត្តរា លោកេ[៦] អតិរេកាតិ លោកុត្ត-រា[៧] លោកា និស្សរន្តីតិ លោកុត្តរា លោកតោ និស្សរន្តីតិ លោកុត្តរា លោកម្ហា និស្សរន្តីតិ[៨]

---

១ ម. ឯត្ថន្តរេ អរិយោតិ ទិស្សតិ ។ ២ ឱ. ម. តរន្តីតិ ។ ៣ ឱ. ម. លោកា ។ ៤ ឱ. ម. លោកតោ ។ ៥ ឱ. ម. លោកំ អតិក្កមន្តីតិ លោកុត្តរា លោកំ សមតិក្កមន្តីតិ លោកុត្តរា លោកំ សមតិក្កន្តាតិ ទិស្សន្តិ ។ ៦ ម. លោកេន ។ ៧ ឱ. ម. ឯត្ថន្តរេ លោកន្តំ តរន្តីតិ លោកុត្តរាតិ ទិស្សន្តិ ។ ៨ ម. លោកម្ហា និស្សរន្តីតិ លោកុត្តរា ។

# យុគនទ្ធវគ្គ លោកុត្តរកថា

[៩១] ពួកធម៌ ជាលោកុត្តរៈ តើដូចម្តេច ។ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ អរិយមគ្គ ៤ សាមញ្ញផល ៤ និងនិព្វាន នេះ ពួកធម៌ ជាលោកុត្តរៈ ។

សំណួរត្រង់ពាក្យថា លោកុត្តរៈ តើលោកុត្តរៈ ដោយអត្ថដូចម្តេច ។ ធម៌ទាំងឡាយឆ្លងនូវលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ ឆ្លងអំពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ ឆ្លងចាកលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយឆ្លងពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំង-ឡាយកន្លងនូវលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយកន្លងហើយនូវលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ ដ៏ក្រៃលែងក្នុងលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ រលាស់ចេញចាកលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ រលាស់ចេញអំពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ រលាស់ចេញពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំង-ឡាយលះចេញចាកលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយលះចេញ

លោកុត្តរា លោកា និស្សដ្ឋន្តីតិ លោកុត្តរា[១] លោកតោ និស្សដ្ឋន្តីតិ លោកុត្តរា[២] លោកម្ហា និស្សដ្ឋន្តីតិ លោកុត្តរា[៣] លោកេ ន តិដ្ឋន្តីតិ លោកុត្តរា លោកម្ហិ ន តិដ្ឋន្តីតិ លោកុត្តរា លោកេ ន លិម្បន្តីតិ លោកុត្តរា លោកម្ហិ ន លិម្បន្តីតិ លោកុត្តរា[៤] លោកេ អសំលិត្តាតិ លោកុត្តរា[៥] លោកេន អសំលិត្តាតិ លោកុត្តរា លោកេ អនុបលិត្តាតិ លោកុត្តរា លោកេន អនុបលិត្តាតិ លោកុត្តរា លោកេ វិប្បមុត្តាតិ លោកុត្តរា លោកេន វិប្បមុត្តាតិ លោកុត្តរា លោកា វិប្បមុត្តាតិ លោកុត្តរា លោកតោ វិប្បមុត្តាតិ លោកុត្តរា លោកម្ហា វិប្បមុត្តាតិ លោកុត្តរា លោកេ វិសញ្ញុត្តាតិ លោកុត្តរា លោកេន វិសញ្ញុត្តាតិ លោកុត្តរា លោកា វិសញ្ញុត្តាតិ

១ ឱ. ម. លោកា និស្សដាតិ លោកុត្តរា ។ ២ ឱ. ម. លោកេន និស្សដាតិ លោកុត្តរា ។ ៣ ឱ. ម. លោកម្ហា និស្សដាតិ លោកុត្តរា ។ ៤ ឱ. ម. លោកេន ន លិប្បន្តីតិ លោកុត្តរា ។ ៥ ឱ. លោកេ អសង្គិលិត្តាតិ លោកុត្តរា ។ ៦ ម. លោកស្មឹ ។

អំពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ លះចេញពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនឋិតនៅក្នុងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយ មិនឋិតនៅនាលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយមិនប្រឡាក់ក្នុងលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំង-ឡាយមិនប្រឡាក់ឲ្យដល់លោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិន ជាប់ស្អិតក្នុងលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនជាប់ស្អិត ដោយលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនជាប់ចំពាក់ដោយ លោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនបង្អោនទៅក្នុងលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយមិនបង្អោនទៅតាមលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយរួចស្រឡះចាកលោក ឈ្មោះថាលោកុត្តរៈ ធម៌ ទាំងឡាយ រួចស្រឡះអំពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ រួចស្រឡះពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិន ប្រកបក្នុងលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនប្រកប ដោយលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនប្រកបក្នុងលោក

១៨១



លោកុត្តរា លោកតោ វិសញ្ញុត្តាតិ លោកុត្តរា លោកម្ហា វិសញ្ញុត្តាតិ លោកុត្តរា លោកា សុជ្ឈន្តីតិ លោកុត្តរា លោកតោ សុជ្ឈន្តីតិ លោកុត្តរា លោកម្ហា សុជ្ឈន្តីតិ លោកុត្តរា លោកា វិសុជ្ឈន្តីតិ លោកុត្តរា លោកតោ វិសុជ្ឈន្តីតិ លោកុត្តរា លោកម្ហា វិសុជ្ឈន្តីតិ លោកុត្តរា លោកា វុដ្ឋហន្តីតិ[១] លោកុត្តរា លោកតោ វុដ្ឋហន្តីតិ លោកុត្តរា លោកម្ហា វុដ្ឋហន្តីតិ លោកុត្តរា លោកា វិវដ្ដន្តីតិ[២] លោកុត្តរា លោកតោ វិវដ្ដន្តីតិ លោកុត្តរា លោកម្ហា វិវដ្ដន្តីតិ លោកុត្តរា លោកេ ន សជ្ជន្តីតិ លោកុត្តរា លោកេ ន គយ្ហន្តីតិ លោកុត្តរា លោកេ ន ពជ្ឈន្តីតិ លោកុត្តរា[៣] លោកំ សមុច្ឆិន្ទន្តីតិ លោកុត្តរា លោកំ សមុច្ឆិន្នត្តាតិ

---

១ ម. ឱទ្ធរន្តីតិ ទិស្សតិ ។ ២ ឱ. ម. វិវដ្ដន្តីន្តិ ទិស្សតិ ។ ៣ ម. លោកេ ន វិជ្ជន្តីតិ លោកុត្តរា ។

យុគនទ្ធវគ្គ លោកុត្តរកថា

ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ ឥតប្រកបក្នុងលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ គ្មានប្រកបក្នុងលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយស្អាតចាកលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយស្អាតជាងលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយស្អាតអំពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ ស្អាតវិសេសជាងលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយស្អាតវិសេសអំពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយស្អាតវិសេសក្រៃលែងជាងលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយចេញចាកលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយចេញអំពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ ចេញពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ វៀរចាកលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយវៀរអំពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ វៀរពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនជាប់ក្នុងលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនប្រកាន់ក្នុងលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនចំពាក់ក្នុងលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ ផ្តាច់បង់នូវលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ ឈ្មោះថាលោកុត្តរៈ ព្រោះផ្តាច់បង់នូវលោក

លោកុត្តរា លោកំ បដិប្បស្សម្ភេន្តីតិ លោកុត្តរា លោកំ បដិប្បស្សម្ភិតត្តាតិ លោកុត្តរា លោកស្ស អបច្ចាគតីតិ(១) លោកុត្តរា លោកស្ស អគតីតិ លោកុត្តរា លោកស្ស អវិសយាតិ លោកុត្តរា លោកស្ស អសាធារណាតិ លោកុត្តរា លោកំ វមន្តីតិ លោកុត្តរា លោកំ ន បច្ចាគមន្តីតិ លោកុត្តរា លោកំ ជហន្តីតិ(២) លោកុត្តរា លោកំ ន ឧប្បាទយន្តីតិ លោកុត្តរា លោកំ វិសិនេន្តីតិ លោកុត្តរា លោកំ នយន្តីតិ(៣) លោកុត្តរា លោកំ វិធូបេន្តីតិ លោកុត្តរា លោកំ ន សុធូបេន្តីតិ(៤) លោកុត្តរា លោកំ សមតិក្កម្ម អភិភុយ្យ តិដ្ឋន្តីតិ លោកុត្តរាតិ ។

លោកុត្តរកថា ។

---

១ ឱ. អតីតាតិ ។ ម. អបគ្គាតិ ។ ២ ឱ. ម. បជហន្តីតិ ទិស្សតិ ។ ៣ ឱ. ម. ន ឧស្សិនេន្តីតិ ទិស្សតិ ។ ៤ ឱ. ន សន្ធូបេន្តីតិ ទិស្សតិ ។ ម. សំធូបេន្តីតិ ទិស្សតិ ។

ធម៌ទាំងឡាយ រម្ងាប់បង់នូវលោក ឈ្មោះថាលោកុត្តរៈ ឈ្មោះថាលោកុត្តរៈ ព្រោះរម្ងាប់បង់នូវលោក ធម៌ទាំងឡាយ មានការមិនត្រឡប់មកកាន់លោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ ទៅផុតពីលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនជាវិស័យ នៃលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនសាធារណ៍ដល់លោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ ខ្ជាក់ចោលនូវលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនត្រឡប់មកកាន់លោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ លះបង់នូវលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនញុំាងលោកឲ្យកើត ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនស្រឡាបនូវលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំង-ឡាយ នាំចេញនូវលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយកម្ចាត់បង់នូវលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយ មិនឱបក្រសោបនូវលោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយប្រព្រឹត្តកន្លង គ្របសង្កត់នូវលោក ហើយប្រតិស្ឋាន ឈ្មោះថាលោកុត្តរៈ ។

ចប់ លោកុត្តរកថា ។

---

# យុគនទ្ធវគ្គេ ពលកថា

## សាវត្ថិនិទានំ

[៩២] បញ្ចិមានិ ភិក្ខវេ ពលានិ កតមានិ បញ្ច សទ្ធាពលំ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ឥមានិ ខោ ភិក្ខវេ បញ្ច ពលានិ ។

អបិ ច អដ្ឋសដ្ឋី ពលានិ សទ្ធាពលំ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ហិរិពលំ ឱត្តប្បពលំ បដិសង្ខានពលំ ភាវនាពលំ អនវជ្ជពលំ សង្គាហពលំ[១] ខន្តិពលំ បញ្ញត្តិពលំ និជ្ឈត្តិពលំ[២] ឥស្សរិយពលំ អធិដ្ឋានពលំ សមថពលំ វិបស្សនាពលំ ទស សេក្ខពលានិ ទស អសេក្ខពលានិ ទស ខីណាសវពលានិ ទស ឥទ្ធិពលានិ ទស តថាគតពលានិ ។

[៩៣] កតមំ សទ្ធាពលំ ។ អស្សទ្ធិយេ ន កម្បតីតិ សទ្ធាពលំ សហជាតានំ ធម្មានំ ឧបត្ថម្ភនដ្ឋេន សទ្ធាពលំ កិលេសានំ បរិយាទានដ្ឋេន សទ្ធាពលំ បដិវេធាទិវិសោធនដ្ឋេន

១ ឱ. ម. សង្គហពលំ ។ ២ ឱ. ម. និជ្ឈន្តិពលំ ។

# យុគនទ្ធវគ្គ ពលកថា

## សាវត្ថិនិទាន

[៩២] ម្នាលភិក្ខុទាំងឡាយ ពលៈនេះ មាន ៥ ពលៈ ៥ តើអ្វីខ្លះ សទ្ធាពលៈ វីរិយពលៈ សតិពលៈ សមាធិពលៈ បញ្ញាពលៈ ម្នាលភិក្ខុទាំងឡាយ នេះ ពលៈ ៥ ។

មួយទៀត ពលៈ មាន ៦៨ គឺ សទ្ធាពលៈ ១ វីរិយពលៈ ១ សតិពលៈ ១ សមាធិពលៈ ១ បញ្ញាពលៈ ១ ហិរិពលៈ ១ ឱត្តប្បពលៈ ១ បដិសង្ខានពលៈ ១ ភាវនាពលៈ ១ អនវជ្ជពលៈ ១ សង្គាហពលៈ ១ ខន្តិពលៈ ១ បញ្ញត្តិពលៈ ១ និជ្ឈត្តិពលៈ ១ ឥស្សរិយពលៈ ១ អធិដ្ឋានពលៈ ១ សមថពលៈ ១ វិបស្សនាពលៈ ១ សេក្ខពលៈ ១០ អសេក្ខពលៈ ១០ ខីណាសវពលៈ ១០ ឥទ្ធិពលៈ ១០ តថាគតពលៈ ១០ ។

[៩៣] សទ្ធាពលៈ តើដូចម្ដេច ។ ឈ្មោះថាសទ្ធាពលៈ ព្រោះមិនញាប់ញ័រ ដោយវត្ថុមិនគួរជឿ ឈ្មោះថា សទ្ធាពលៈ ដោយអត្ថថាទំនុកបម្រុង នូវសហជាតធម៌ទាំងឡាយ ឈ្មោះថា សទ្ធាពលៈ ដោយអត្ថថាគ្របសង្កត់ នូវពួកកិលេស ឈ្មោះថា សទ្ធាពលៈ ដោយអត្ថថាជម្រះ នូវគុណមានកិរិយាត្រាស់ដឹងជាដើម

សទ្ធាពលំ ចិត្តស្ស អធិដ្ឋានដ្ឋេន សទ្ធាពលំ ចិត្តស្ស វោទានដ្ឋេន សទ្ធាពលំ វិសេសាធិគមដ្ឋេន[1] សទ្ធាពលំ ឧត្តរិប្បដិវេធដ្ឋេន សទ្ធាពលំ សច្ចាភិសមយដ្ឋេន សទ្ធាពលំ និរោធេ បតិដ្ឋាបកដ្ឋេន សទ្ធាពលំ ឥទំ សទ្ធាពលំ ។

កតមំ វីរិយពលំ ។ កោសជ្ជេ ន កម្បតីតិ វីរិយពលំ សហជាតានំ ធម្មានំ ឧបត្ថម្ភនដ្ឋេន វីរិយពលំ កិលេសានំ បរិយាទានដ្ឋេន វីរិយពលំ បដិវេធាទិវិសោធនដ្ឋេន វីរិយពលំ ចិត្តស្ស អធិដ្ឋានដ្ឋេន វីរិយពលំ ចិត្តស្ស វោទានដ្ឋេន វីរិយពលំ វិសេសាធិគមដ្ឋេន វីរិយពលំ ឧត្តរិប្បដិវេធដ្ឋេន វីរិយពលំ សច្ចាភិសមយដ្ឋេន វីរិយពលំ និរោធេ បតិដ្ឋាបកដ្ឋេន វីរិយពលំ ឥទំ វីរិយពលំ ។

---

១ ឱ. ម. វិសេសាធិកមនដ្ឋេន ។

ឈ្មោះថាសទ្ធាពលៈ ដោយអត្ថថាអធិដ្ឋានចិត្ត ឈ្មោះថាសទ្ធាពលៈ ដោយអត្ថថាញ៉ាំងចិត្តឲ្យផូរផង់ ឈ្មោះថាសទ្ធាពលៈ ដោយអត្ថថាបាននូវគុណវិសេស ឈ្មោះថាសទ្ធាពលៈ ដោយអត្ថថាចាក់ធ្លុះនូវគុណដ៏ក្រៃលែង ឈ្មោះថាសទ្ធាពលៈ ដោយអត្ថថាត្រាស់ដឹងនូវសច្ចៈ ឈ្មោះថាសទ្ធាពលៈ ដោយអត្ថថាឲ្យតាំងនៅស៊ប់ក្នុងនិរោធ នេះ សទ្ធាពលៈ ។

វីរិយពលៈ តើដូចម្តេច ។ ឈ្មោះថាវីរិយពលៈ ព្រោះជាធម្មជាតមិនញាប់ញ័រ ដោយសេចក្តីខ្ជិល ឈ្មោះថាវីរិយពលៈ ដោយអត្ថថាទំនុកបម្រុងនូវសហជាតធម៌ទាំងឡាយ ឈ្មោះថាវីរិយពលៈ ដោយអត្ថថាគ្របសង្កត់នូវកិលេសទាំងឡាយ ឈ្មោះថាវីរិយពលៈ ដោយអត្ថថាជម្រះនូវគុណ មានកិរិយាត្រាស់ដឹងជាដើម ឈ្មោះថាវីរិយពលៈ ដោយអត្ថថាអធិដ្ឋានចិត្ត ឈ្មោះថាវីរិយពលៈ ដោយអត្ថថាញ៉ាំងចិត្តឲ្យផូរផង់ ឈ្មោះថាវីរិយពលៈ ដោយអត្ថថាបាននូវគុណវិសេស ឈ្មោះថាវីរិយពលៈ ដោយអត្ថថាចាក់ធ្លុះនូវគុណដ៏ក្រៃលែង ឈ្មោះថាវីរិយពលៈ ដោយអត្ថថាត្រាស់ដឹងនូវសច្ចៈ ឈ្មោះថាវីរិយពលៈ ដោយអត្ថថាឲ្យតាំងនៅស៊ប់ក្នុងនិរោធ នេះ វីរិយពលៈ ។

កតមំ សតិពលំ ។ បមាទេ ន កម្បតីតិ សតិពលំ សហជាតានំ ធម្មានំ ឧបត្ថម្ភនដ្ឋេន សតិពលំ ។ បេ ។ និរោធេ បតិដ្ឋាបកដ្ឋេន សតិពលំ ឥទំ សតិពលំ ។

កតមំ សមាធិពលំ ។ ឧទ្ធច្ចេ ន កម្បតីតិ សមាធិពលំ សហជាតានំ ធម្មានំ ឧបត្ថម្ភនដ្ឋេន សមាធិពលំ ។ បេ ។ និរោធេ បតិដ្ឋាបកដ្ឋេន សមាធិពលំ ឥទំ សមាធិពលំ ។

កតមំ បញ្ញាពលំ ។ អវិជ្ជាយ ន កម្បតីតិ បញ្ញាពលំ សហជាតានំ ធម្មានំ ឧបត្ថម្ភនដ្ឋេន បញ្ញាពលំ ។ បេ ។ និរោធេ បតិដ្ឋាបកដ្ឋេន បញ្ញាពលំ ឥទំ បញ្ញាពលំ ។

[៩៤] កតមំ ហិរិពលំ ។ នេក្ខម្មេន កាមច្ឆន្ទំ ហិរិយតីតិ ហិរិពលំ អព្យាបាទេន ព្យាបាទំ ហិរិយតីតិ ហិរិពលំ អាលោកសញ្ញាយ ថីនមិទ្ធំ ហិរិយតីតិ ហិរិពលំ អវិក្ខេបេន ឧទ្ធច្ចំ ហិរិយតីតិ

សតិពលៈ តើដូចម្តេច ។ ឈ្មោះថាសតិពលៈ ព្រោះជាធម្មជាតមិនញាប់ញ័រ ដោយសេចក្តីប្រមាទ ឈ្មោះថាសតិពលៈ ដោយអត្ថថាទំនុកបម្រុង នូវសហជាតធម៌ទាំងឡាយ ។ បេ ។ ឈ្មោះថាសតិពលៈ ដោយអត្ថថាឲ្យតាំងនៅស៊ប់ក្នុងនិរោធ នេះ សតិពលៈ ។

សមាធិពលៈ តើដូចម្តេច ។ ឈ្មោះថាសមាធិពលៈ ព្រោះជាធម្មជាតមិនញាប់ញ័រដោយសេចក្តីរាយមាយ ឈ្មោះថាសមាធិពលៈ ដោយអត្ថថាទំនុកបម្រុងនូវសហជាតធម៌ទាំងឡាយ ។ បេ ។ ឈ្មោះថាសមាធិពលៈ ដោយអត្ថថាឲ្យតាំងនៅស៊ប់ក្នុងនិរោធ នេះ សមាធិពលៈ ។

បញ្ញាពលៈ តើដូចម្តេច ។ ឈ្មោះថាបញ្ញាពលៈ ព្រោះជាធម្មជាតមិនញាប់ញ័រដោយអវិជ្ជា ឈ្មោះថាបញ្ញាពលៈ ដោយអត្ថថាទំនុកបម្រុងនូវសហជាតធម៌ទាំងឡាយ ។ បេ។ ឈ្មោះថាបញ្ញាពលៈ ដោយអត្ថថាឲ្យតាំងនៅស៊ប់ក្នុងនិរោធ នេះ បញ្ញាពលៈ ។

[៩៤] ហិរិពលៈ តើដូចម្តេច ។ ឈ្មោះថាហិរិពលៈ ព្រោះជាធម្មជាតខ្មើមកាមច្ឆន្ទៈដោយនេក្ខម្មៈ ឈ្មោះថាហិរិពលៈ ព្រោះខ្មើមព្យាបាទដោយអព្យាបាទ ឈ្មោះថាហិរិពលៈ ព្រោះខ្មើមថីនមិទ្ធៈដោយអាលោកសញ្ញា ឈ្មោះថាហិរិពលៈ ព្រោះខ្មើមឧទ្ធច្ចៈ ដោយសេចក្តីមិនរាយមាយ

ហិរិពលំ ធម្មវវត្ថានេន វិចិកិច្ឆំ ហិរិយតីតិ ហិរិពលំ ញាណេន អវិជ្ជំ ហិរិយតីតិ ហិរិពលំ បាមោជ្ជេន អរតឹ ហិរិយតីតិ ហិរិពលំ បឋមជ្ឈានេន នីវរណេ ហិរិយតីតិ ហិរិពលំ ។ បេ ។ អរហត្តមគ្គេន សព្វក្កិលេសេ ហិរិយតីតិ ហិរិពលំ ឥទំ ហិរិពលំ ។

កតមំ ឱត្តប្បពលំ ។ នេក្ខម្មេន កាមច្ឆន្ទំ ឱត្តប្បតីតិ ឱត្តប្បពលំ អព្យាបាទេន ព្យាបាទំ ឱត្តប្បតីតិ ឱត្តប្បពលំ អាលោកសញ្ញាយ ថីនមិទ្ធំ ឱត្តប្បតីតិ ឱត្តប្បពលំ អវិក្ខេបេន ឧទ្ធច្ចំ ឱត្តប្បតីតិ ឱត្តប្បពលំ ធម្មវវត្ថានេន វិចិកិច្ឆំ ឱត្តប្បតីតិ ឱត្តប្បពលំ ញាណេន អវិជ្ជំ ឱត្តប្បតីតិ ឱត្តប្បពលំ បាមោជ្ជេន អរតឹ ឱត្តប្បតីតិ ឱត្តប្បពលំ បឋមជ្ឈានេន នីវរណេ ឱត្តប្បតីតិ ឱត្តប្បពលំ ។ បេ ។ អរហត្តមគ្គេន សព្វក្កិលេសេ ឱត្តប្បតីតិ ឱត្តប្បពលំ ឥទំ ឱត្តប្បពលំ ។

ឈ្មោះថា ហិរិពលៈ ព្រោះខ្មើមវិចិកិច្ឆា ដោយកិរិយាកំណត់នូវធម៌ ឈ្មោះថាហិរិពលៈ ព្រោះខ្មើមអវិជ្ជាដោយញាណ ឈ្មោះថាហិរិពលៈ ព្រោះខ្មើមសេចក្តីមិនត្រេកអរ ដោយបាមោជ្ជៈ ឈ្មោះថាហិរិពលៈ ព្រោះខ្មើមនីវរណៈ ដោយបឋមជ្ឈាន ។ បេ ។ ឈ្មោះថាហិរិពលៈ ព្រោះខ្មើមកិលេសទាំងពួង ដោយអរហត្តមគ្គ នេះ ហិរិពលៈ ។

ឱត្តប្បពលៈ តើដូចម្តេច ។ ឈ្មោះថាឱត្តប្បពលៈ ព្រោះជាធម្មជាតតក់ស្លុតនឹងកាមច្ឆន្ទៈ ដោយនេក្ខម្មៈ ឈ្មោះថាឱត្តប្បពលៈ ព្រោះតក់ស្លុតនឹងព្យាបាទ ដោយអព្យាបាទ ឈ្មោះថាឱត្តប្បពលៈ ព្រោះតក់ស្លុតនឹងថីនមិទ្ធៈ ដោយអាលោកសញ្ញា ឈ្មោះថាឱត្តប្បពលៈ ព្រោះតក់ស្លុតនឹងឧទ្ធច្ចៈ ដោយសេចក្តីមិនរាយមាយ ឈ្មោះថាឱត្តប្បពលៈ ព្រោះតក់ស្លុតនឹងវិចិកិច្ឆា ដោយកិរិយាកំណត់នូវធម៌ ឈ្មោះថាឱត្តប្បពលៈ ព្រោះតក់ស្លុតនឹងអវិជ្ជា ដោយញាណ ឈ្មោះថាឱត្តប្បពលៈ ព្រោះតក់ស្លុតនឹងសេចក្តីមិនត្រេកអរ ដោយបាមោជ្ជៈ ឈ្មោះថាឱត្តប្បពលៈ ព្រោះតក់ស្លុតនឹងពួកនីវរណៈ ដោយបឋមជ្ឈាន ។ បេ ។ ឈ្មោះថាឱត្តប្បពលៈ ព្រោះតក់ស្លុត នឹងកិលេសទាំងពួង ដោយអរហត្តមគ្គ នេះ ឱត្តប្បពលៈ ។

កតមំ បដិសង្ខានពលំ ។ នេក្ខម្មេន កាមច្ឆន្ទំ បដិសង្ខាតីតិ បដិសង្ខានពលំ អព្យាបាទេន ព្យាបាទំ បដិសង្ខាតីតិ បដិសង្ខានពលំ អាលោកសញ្ញាយ ថីនមិទ្ធំ បដិសង្ខាតីតិ បដិសង្ខានពលំ អវិក្ខេបេន ឧទ្ធច្ចំ បដិសង្ខាតីតិ បដិសង្ខានពលំ ធម្មវវត្ថានេន វិចិកិច្ឆំ បដិសង្ខាតីតិ បដិសង្ខានពលំ ញាណេន អវិជ្ជំ បដិសង្ខាតីតិ បដិសង្ខានពលំ បាមោជ្ជេន អរតឹ បដិសង្ខាតីតិ បដិសង្ខានពលំ បឋមជ្ឈានេន នីវរ-ណេ បដិសង្ខាតីតិ បដិសង្ខានពលំ ។ បេ ។ អរហ-ត្តមគ្គេន សព្វកិលេសេ បដិសង្ខាតីតិ បដិសង្ខាន-ពលំ ឥទំ បដិសង្ខានពលំ ។

[៩៨] កតមំ ភាវនាពលំ ។ កាមច្ឆន្ទំ បជ-ហន្តោ នេក្ខម្មំ ភាវេតីតិ ភាវនាពលំ ។ ព្យា-បាទំ បជហន្តោ អព្យាបាទំ ភាវេតីតិ ភាវនាពលំ ថីនមិទ្ធំ បជហន្តោ អាលោកសញ្ញំ ភាវេតីតិ ភា-វនាពលំ ឧទ្ធច្ចំ បជហន្តោ អវិក្ខេបំ ភាវេតីតិ ភា-វនាពលំ វិចិកិច្ឆំ បជហន្តោ ធម្មវវត្ថានំ ភាវេតីតិ

បដិសង្ខានពលៈ តើដូចម្តេច ។ ឈ្មោះថាបដិសង្ខានពលៈ ព្រោះជាធម្មជាតពិចារណាកាមច្ឆន្ទៈ ដោយនេក្ខម្មៈ ឈ្មោះថាបដិសង្ខានពលៈ ព្រោះពិចារណាព្យាបាទ ដោយអព្យាបាទ ឈ្មោះថាបដិសង្ខានពលៈ ព្រោះពិចារណាថីនមិទ្ធៈ ដោយអាលោកសញ្ញា ឈ្មោះថាបដិសង្ខានពលៈ ព្រោះពិចារណាឧទ្ធច្ចៈ ដោយសេចក្តីមិនរាយមាយ ឈ្មោះថាបដិសង្ខានពលៈ ព្រោះពិចារណាវិចិកិច្ឆា ដោយកិរិយាកំណត់នូវធម៌ ឈ្មោះថាបដិសង្ខានពលៈ ព្រោះពិចារណាអវិជ្ជា ដោយញាណ ឈ្មោះថាបដិសង្ខានពលៈ ព្រោះពិចារណាសេចក្តីមិនត្រេកអរ ដោយបាមោជ្ជៈ ឈ្មោះថាបដិសង្ខានពលៈ ព្រោះពិចារណាពួកនីវរណៈ ដោយបឋមជ្ឈាន ។ បេ ។ ឈ្មោះថាបដិសង្ខានពលៈ ព្រោះពិចារណាពួកកិលេសទាំងពួង ដោយអរហត្តមគ្គ នេះ បដិសង្ខានពលៈ ។

[៩៥] ភាវនាពលៈ តើដូចម្តេច ។ ឈ្មោះថាភាវនាពលៈ ព្រោះលះបង់កាមច្ឆន្ទៈ ចម្រើននេក្ខម្មៈ ឈ្មោះថាភាវនាពលៈ ព្រោះលះបង់ព្យាបាទចម្រើនអព្យាបាទ ឈ្មោះថាភាវនាពលៈ ព្រោះលះបង់ថីនមិទ្ធៈ ចម្រើនអាលោកសញ្ញា ឈ្មោះថាភាវនាពលៈ ព្រោះលះបង់ឧទ្ធច្ចៈចម្រើនអវិក្ខេបៈ ឈ្មោះថាភាវនាពលៈ ព្រោះលះបង់វិចិកិច្ឆាចម្រើននូវកិរិយា

ភាវនាពលំ អវិជ្ជំ បជហន្តោ ញាណំ ភាវេតីតិ ភាវនាពលំ អរតឹ បជហន្តោ ចាមោជ្ជំ ភាវេតីតិ ភាវនាពលំ នីវរណេ បជហន្តោ បឋមជ្ឈានំ ភាវេតីតិ ភាវនាពលំ ។ បេ ។ សព្វកិលេសេ បជហន្តោ អរហត្តមគ្គំ ភាវេតីតិ ភាវនាពលំ ឥទំ ភាវនាពលំ ។

កតមំ អនវជ្ជពលំ ។ កាមច្ឆន្ទស្ស បហីនត្តា នេក្ខម្មេ នត្ថិ កិញ្ចិ វជ្ជន្តិ អនវជ្ជពលំ ព្យាបាទស្ស បហីនត្តា អព្យាបាទេ នត្ថិ កិញ្ចិ វជ្ជន្តិ អនវជ្ជពលំ ថីនមិទ្ធស្ស បហីនត្តា អាលោកសញ្ញាយ នត្ថិ កិញ្ចិ វជ្ជន្តិ អនវជ្ជពលំ ឧទ្ធច្ចស្ស បហីនត្តា អវិក្ខេបេ នត្ថិ កិញ្ចិ វជ្ជន្តិ អនវជ្ជពលំ វិចិកិច្ឆាយ បហីនត្តា ធម្មវវត្ថានេ នត្ថិ កិញ្ចិ វជ្ជន្តិ អនវជ្ជពលំ អវិជ្ជាយ បហីនត្តា ញាណេ នត្ថិ កិញ្ចិ វជ្ជន្តិ អនវជ្ជពលំ អរតិយា បហីនត្តា ចាមុជ្ជេ នត្ថិ កិញ្ចិ វជ្ជន្តិ អនវជ្ជពលំ នីវរណានំ បហីនត្តា បឋមជ្ឈានេ នត្ថិ កិញ្ចិ វជ្ជន្តិ អនវជ្ជពលំ ។ បេ ។ សព្វកិលេសានំ បហីនត្តា អរហត្តមគ្គេ នត្ថិ កិញ្ចិ វជ្ជន្តិ អនវជ្ជពលំ ឥទំ អនវជ្ជពលំ ។

កំណាត់នូវធម៌ ឈ្មោះថាភាវនាពលៈ ព្រោះលះបង់អវិជ្ជាចម្រើនញាណ ឈ្មោះថាភាវនាពលៈ ព្រោះលះបង់សេចក្តីមិនត្រេកអរចម្រើនបាមោជ្ជៈ ឈ្មោះថាភាវនាពលៈ ព្រោះលះបង់ពួកនីវរណៈ ចម្រើនបឋមជ្ឈាន ។ បេ ។ ឈ្មោះថាភាវនាពលៈ ព្រោះលះបង់កិលេសទាំងពួង ចម្រើនអរហត្តមគ្គ នេះ ភាវនាពលៈ ។

អនវជ្ជពលៈ តើដូចម្តេច ។ ឈ្មោះថាអនវជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងនេក្ខម្មៈ ព្រោះលះបង់កាមច្ឆន្ទៈ ឈ្មោះថាអនវជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងអព្យាបាទ ព្រោះលះបង់ព្យាបាទ ឈ្មោះថាអនវជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងអាលោកសញ្ញា ព្រោះលះបង់ថីនមិទ្ធៈ ឈ្មោះថាអនវជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងសេចក្តីមិនរាយមាយ ព្រោះលះបង់ឧទ្ធច្ចៈ ឈ្មោះថាអនវជ្ជពលៈ ព្រោះទោសតិចតួចមិនមាន ក្នុងសេចក្តីកំណាត់នូវធម៌ ព្រោះលះបង់វិចិកិច្ឆា ឈ្មោះថាអនវជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងញាណ ព្រោះលះបង់អវិជ្ជា ឈ្មោះថាអនវជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងបាមោជ្ជៈ ព្រោះលះបង់សេចក្តីមិនត្រេកអរ ឈ្មោះថាអនវជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងបឋមជ្ឈាន ព្រោះលះបង់ពួកនីវរណៈ ។ បេ ។ ឈ្មោះថាអនវជ្ជពលៈ ព្រោះទោសតិចតួចមិនមាន ក្នុងអរហត្តមគ្គ ព្រោះលះបង់កិលេសទាំងពួង នេះ អនវជ្ជពលៈ ។

កតមំ សង្គាហពលំ ។ កាមច្ឆន្ទំ បជហតោ នេក្ខម្មវសេន ចិត្តំ សង្គណ្ហាតីតិ សង្គាហពលំ ព្យាបាទំ បជហតោ អព្យាបាទវសេន ចិត្តំ សង្គ-ណ្ហាតីតិ សង្គាហពលំ ថីនមិទ្ធំ បជហតោ អាលោ-កសញ្ញាវសេន ចិត្តំ សង្គណ្ហាតីតិ សង្គាហពលំ ។ បេ ។ សព្វកិលេសេ បជហតោ អរហត្តមគ្គវសេន ចិត្តំ សង្គណ្ហាតីតិ សង្គាហពលំ ឥទំ សង្គាហពលំ ។

[៩៦] កតមំ ខន្តិពលំ ។ កាមច្ឆន្ទស្ស បហីនត្តា នេក្ខម្មំ ខមតីតិ[១] ខន្តិពលំ ព្យាបាទស្ស បហីនត្តា អព្យាបាទោ ខមតីតិ ខន្តិពលំ ថីនមិទ្ធស្ស បហីនត្តា អាលោកសញ្ញា ខមតីតិ ខន្តិពលំ ឧទ្ធច្ចស្ស បហី-នត្តា អវិក្ខេបោ ខមតីតិ ខន្តិពលំ វិចិកិច្ឆាយ បហី-នត្តា ធម្មវវត្ថានំ ខមតីតិ ខន្តិពលំ អវិជ្ជាយ បហីនត្តា ញាណំ ខមតីតិ ខន្តិពលំ អរតិយា បហីនត្តា បាមុជ្ជំ ខមតីតិ ខន្តិពលំ នីវរណានំ បហីនត្តា បឋមជ្ឈានំ ខមតីតិ ខន្តិពលំ ។ បេ ។ សព្វកិលេសានំ បហីនត្តា អរហត្តមគ្គោ ខមតីតិ ខន្តិពលំ ឥទំ ខន្តិពលំ ។

១ ឱ. ខន្តីតិ ទិស្សតិ ។

សង្គាហពលៈ តើដូចម្ដេច ។ ឈ្មោះថាសង្គាហពលៈ ព្រោះបុគ្គលលះបង់កាមច្ឆន្ទៈសង្គ្រោះចិត្ត ដោយអំណាចនេក្ខម្មៈ ឈ្មោះថាសង្គាហពលៈ ព្រោះលះបង់ព្យាបាទ សង្គ្រោះចិត្តដោយអំណាចអព្យាបាទ ឈ្មោះថាសង្គាហពលៈ ព្រោះលះបង់ថីនមិទ្ធៈ សង្គ្រោះចិត្តដោយអំណាចអាលោកសញ្ញា ។ បេ ។ ឈ្មោះថាសង្គាហពលៈ ព្រោះលះបង់កិលេសទាំងពួង សង្គ្រោះចិត្តដោយអំណាចអរហត្តមគ្គ នេះសង្គាហពលៈ ។

[៩៦] ខន្តិពលៈ តើដូចម្ដេច ។ ឈ្មោះថាខន្តិពលៈ ព្រោះនេក្ខម្មៈអត់ធន់បាន ព្រោះលះបង់កាមច្ឆន្ទៈ ឈ្មោះថាខន្តិពលៈ ព្រោះអព្យាបាទអត់ធន់បាន ព្រោះលះបង់ព្យាបាទ ឈ្មោះថាខន្តិពលៈ ព្រោះអាលោកសញ្ញាអត់ធន់បាន ព្រោះលះបង់ថីនមិទ្ធៈ ឈ្មោះថាខន្តិពលៈ ព្រោះសេចក្ដីមិនរាយមាយអត់ធន់បាន ព្រោះលះបង់ឧទ្ធច្ចៈ ឈ្មោះថាខន្តិពលៈ ព្រោះការកំណត់នូវធម៌អត់ធន់បាន ព្រោះលះបង់វិចិកិច្ឆា ឈ្មោះថា ខន្តិពលៈ ព្រោះញាណអត់ធន់បាន ព្រោះលះបង់នូវអវិជ្ជា ឈ្មោះថាខន្តិពលៈ ព្រោះបាមោជ្ជៈអត់ធន់បាន ព្រោះលះបង់សេចក្ដីមិនត្រេកអរ ឈ្មោះថាខន្តិពលៈ ព្រោះបឋមជ្ឈាន អត់ធន់បាន ព្រោះលះបង់ពួកនីវរណៈ ឈ្មោះថាខន្តិពលៈ ព្រោះអរហត្តមគ្គអត់ធន់បាន ព្រោះលះបង់កិលេសទាំងពួង នេះ ខន្តិពលៈ ។

កតមំ បញ្ញត្តិពលំ ។ កាមច្ឆន្ទំ បជហន្តោ នេក្ខម្មវសេន ចិត្តំ បញ្ញបេតីតិ[១] បញ្ញត្តិពលំ ព្យាបាទំ បជហន្តោ អព្យាបាទវសេន ចិត្តំ បញ្ញបេតីតិ បញ្ញ-ត្តិពលំ ថីនមិទ្ធំ បជហន្តោ អាលោកសញ្ញាវសេន ចិត្តំ បញ្ញបេតីតិ បញ្ញត្តិពលំ ។ បេ ។ សព្វក្កិលេសេ បជហន្តោ អរហត្តមគ្គវសេន ចិត្តំ បញ្ញបេតីតិ បញ្ញត្តិ-ពលំ ឥទំ បញ្ញត្តិពលំ ។

កតមំ និជ្ឈត្តិពលំ ។ កាមច្ឆន្ទំ បជហន្តោ នេក្ខម្មវសេន ចិត្តំ និជ្ឈាបេតីតិ និជ្ឈត្តិពលំ ព្យាបាទំ បជហន្តោ អព្យាបាទវសេន ចិត្តំ និជ្ឈា-បេតីតិ និជ្ឈត្តិពលំ ថីនមិទ្ធំ បជហន្តោ អាលោក-សញ្ញាវសេន ចិត្តំ និជ្ឈាបេតីតិ និជ្ឈត្តិពលំ ។ បេ ។ សព្វក្កិលេសេ បជហន្តោ អរហត្តមគ្គវសេន ចិត្តំ និជ្ឈាបេតីតិ និជ្ឈត្តិពលំ ឥទំ និជ្ឈត្តិពលំ ។

កតមំ ឥស្សរិយពលំ ។ កាមច្ឆន្ទំ បជហន្តោ នេក្ខម្មវសេន ចិត្តំ វសំ វត្តេតីតិ ឥស្សរិយពលំ ព្យាបាទំ បជហន្តោ អព្យាបាទវសេន ចិត្តំ វសំ វត្តេតីតិ

---

១ ឱ. ម. បញ្ញាបេតីតិ ទិស្សតិ ។

បញ្ញត្តិពលៈ តើដូចម្តេច ។ ឈ្មោះថាបញ្ញត្តិពលៈ ព្រោះបុគ្គលលះបង់កាមច្ឆន្ទៈ បញ្ញត្តចិត្ត ដោយអំណាចនេក្ខម្មៈ ឈ្មោះថាបញ្ញត្តិពលៈ ព្រោះលះបង់ព្យាបាទ បញ្ញត្តចិត្តដោយអំណាចអព្យាបាទ ឈ្មោះថាបញ្ញត្តិពលៈ ព្រោះលះបង់ថីនមិទ្ធៈ បញ្ញត្តចិត្ត ដោយអំណាចអាលោកសញ្ញា ។ បេ ។ ឈ្មោះថាបញ្ញត្តិពលៈ ព្រោះបុគ្គលលះបង់កិលេសទាំងពួង បញ្ញត្តចិត្ត ដោយអំណាចអរហត្តមគ្គ នេះ បញ្ញត្តិពលៈ ។

និជ្ឈត្តិពលៈ តើដូចម្តេច ។ ឈ្មោះថានិជ្ឈត្តិពលៈ ព្រោះលះបង់កាមច្ឆន្ទៈសម្លឹងមើលចិត្ត ដោយអំណាចនេក្ខម្មៈ ឈ្មោះថានិជ្ឈត្តិពលៈ ព្រោះលះបង់ព្យាបាទ សម្លឹងមើលចិត្ត ដោយអំណាចអព្យាបាទ ឈ្មោះថានិជ្ឈត្តិពលៈ ព្រោះលះបង់ថីនមិទ្ធៈ សម្លឹងមើលចិត្ត ដោយអំណាចអាលោកសញ្ញា ។ បេ ។ ឈ្មោះថានិជ្ឈត្តិពលៈ ព្រោះបុគ្គលលះបង់កិលេសទាំងពួង សម្លឹងមើលចិត្ត ដោយអំណាចអរហត្តមគ្គ នេះ និជ្ឈត្តិពលៈ ។

ឥស្សរិយពលៈ តើដូចម្តេច ។ ឈ្មោះថា ឥស្សរិយពលៈ ព្រោះបុគ្គលលះបង់កាមច្ឆន្ទៈ ញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាច ដោយអំណាចនៃនេក្ខម្មៈ ឈ្មោះថាឥស្សរិយពលៈ ព្រោះលះបង់ព្យាបាទ ញុំាងចិត្តឲ្យប្រព្រឹត្តទៅ ក្នុងអំណាច ដោយអំណាចនៃអព្យាបាទ

ឥស្សរិយពលំ ថីនមិទ្ធំ បជហតោ អាលោកសញ្ញាវ-សេន ចិត្តំ វសំ វត្តេតីតិ ឥស្សរិយពលំ ។ បេ ។ សព្វ-ក្កិលេសេ បជហតោ អរហត្តមគ្គវសេន ចិត្តំ វសំ វត្តេតីតិ ឥស្សរិយពលំ ឥទំ ឥស្សរិយពលំ ។

កតមំ អធិដ្ឋានពលំ ។ កាមច្ឆន្ទំ បជហតោ នេ-ក្ខម្មវសេន ចិត្តំ អធិដ្ឋាតីតិ អធិដ្ឋានពលំ ព្យាបាទំ បជហតោ អព្យាបាទវសេន ចិត្តំ អធិដ្ឋាតីតិ អធិដ្ឋា-នពលំ ថីនមិទ្ធំ បជហតោ អាលោកសញ្ញាវសេន ចិត្តំ អធិដ្ឋាតីតិ អធិដ្ឋានពលំ ។ បេ ។ សព្វក្កិលេ-សេ បជហតោ អរហត្តមគ្គវសេន ចិត្តំ អធិដ្ឋាតីតិ អធិដ្ឋានពលំ ឥទំ អធិដ្ឋានពលំ ។

[៩៧] កតមំ សមថពលំ ។ នេក្ខម្មវសេន ចិត្ត-ស្ស ឯកគ្គតា អវិក្ខេបោ សមថពលំ អព្យាបា-ទវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមថ-ពលំ អាលោកសញ្ញាវសេន ចិត្តស្ស ឯកគ្គតា អវិ-ក្ខេបោ សមថពលំ ។ បេ ។ បដិនិស្សគ្គានុប-ស្សី អស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ

ឈ្មោះថាឥស្សរិយពលៈ ព្រោះលះបង់ថីនមិទ្ធៈ ញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាច ដោយអំណាចអាលោកសញ្ញា ។ បេ ។ ឈ្មោះថាឥស្សរិយពលៈ ព្រោះលះបង់កិលេសទាំងពួង ញុំាងចិត្តឲ្យប្រព្រឹត្តទៅ ក្នុងអំណាច ដោយអំណាចអរហត្តមគ្គ នេះ ឥស្សរិយពលៈ ។

អធិដ្ឋានពលៈ តើដូចម្តេច ។ ឈ្មោះថាអធិដ្ឋានពលៈ ព្រោះបុគ្គលលះបង់កាមច្ឆន្ទៈ អធិដ្ឋានចិត្តដោយអំណាចនេក្ខម្មៈ ឈ្មោះថាអធិដ្ឋានពលៈ ព្រោះលះបង់ព្យាបាទ អធិដ្ឋានចិត្ត ដោយអំណាចអព្យាបាទ ឈ្មោះថាអធិដ្ឋានពលៈ ព្រោះលះបង់ថីនមិទ្ធៈ អធិដ្ឋានចិត្ត ដោយអំណាចអាលោកសញ្ញា ។ បេ ។ ឈ្មោះថាអធិដ្ឋានពលៈ ព្រោះលះបង់កិលេសទាំងពួង អធិដ្ឋានចិត្ត ដោយអំណាចអរហត្តមគ្គ នេះ អធិដ្ឋានពលៈ ។

[៩៧] សមថពលៈ តើដូចម្តេច ។ ភាពនៃចិត្តមានអារម្មណ៍តែមួយគឺការមិនរាយមាយ ដោយអំណាចនេក្ខម្មៈ ឈ្មោះថាសមថពលៈ ភាពនៃចិត្តមានអារម្មណ៍តែមួយគឺការមិនរាយមាយ ដោយអំណាចអព្យាបាទ ឈ្មោះថាសមថពលៈ ភាពនៃចិត្តមានអារម្មណ៍តែមួយគឺការមិនរាយមាយ ដោយអំណាចអាលោកសញ្ញា ឈ្មោះថាសមថពលៈ ។ បេ ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ គឺការមិនរាយមាយ ដោយអំណាចការដកដង្ហើមចេញ របស់បុគ្គលអ្នកពិចារណាឃើញ នូវអារម្មណ៍ដែលគួរលះ

សមថពលំ បដិនិស្សគ្គានុបស្សី បស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមថពលំ ។

សមថពលន្តិ កេនដ្ឋេន សមថពលំ ។ បឋមជ្ឈានេន នីវរណេ ន កម្បតីតិ សមថពលំ ទុតិយជ្ឈានេន វិតក្កវិចារេ ន កម្បតីតិ សមថពលំ តតិយជ្ឈានេន បីតិយា ន កម្បតីតិ សមថពលំ ចតុត្ថជ្ឈានេន សុខទុក្ខេ ន កម្បតីតិ សមថពលំ អាកាសានញ្ចាយតនសមាបត្តិយា រូបសញ្ញាយ បដិឃសញ្ញាយ នានត្តសញ្ញាយ ន កម្បតីតិ សមថពលំ វិញ្ញាណញ្ចាយតនសមាបត្តិយា អាកាសានញ្ចាយតនសញ្ញាយ ន កម្បតីតិ សមថពលំ អាកិញ្ចញ្ញាយតនសមាបត្តិយា វិញ្ញាណញ្ចាយតនសញ្ញាយ ន កម្បតីតិ សមថពលំ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា អាកិញ្ចញ្ញាយតនសញ្ញាយ ន កម្បតីតិ សមថពលំ ឧទ្ធច្ចេ ច ឧទ្ធច្ចសហគតក្កិលេសេ ច ខន្ធេ ច ន កម្បតិ ន ចលតិ ន វេធតីតិ សមថពលំ ឥទំ សមថពលំ ។

ឈ្មោះថាសមថពលៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ គឺការមិនរាយមាយ ដោយអំណាចខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញនូវអារម្មណ៍ដែលគួរលះ ឈ្មោះថាសមថពលៈ ។

សំណួរត្រង់ពាក្យថា សមថពលៈ តើសមថពលៈ ដោយអត្ថថាដូចម្តេច ។ ឈ្មោះថាសមថពលៈ ព្រោះបុគ្គលមិនញាប់ញ័រ ក្នុងនីវរណៈ ដោយបឋមជ្ឈាន ឈ្មោះថាសមថពលៈ ព្រោះមិនញាប់ញ័រ ក្នុងវិតក្កៈនិងវិចារៈ ដោយទុតិយជ្ឈាន ឈ្មោះថាសមថពលៈ ព្រោះមិនញាប់ញ័រ ក្នុងបីតិ ដោយតតិយជ្ឈាន ឈ្មោះថាសមថពលៈ ព្រោះមិនញាប់ញ័រ ក្នុងសុខនិងទុក្ខ ដោយចតុត្ថជ្ឈាន ឈ្មោះថាសមថពលៈ ព្រោះមិនញាប់ញ័រ ក្នុងរូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ ឈ្មោះថាសមថពលៈ ព្រោះមិនញាប់ញ័រ ក្នុងអាកាសានញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ ឈ្មោះថាសមថពលៈ ព្រោះមិនញាប់ញ័រ ក្នុងវិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ ឈ្មោះថាសមថពលៈ ព្រោះមិនញាប់ញ័រក្នុងអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថាសមថពលៈ ព្រោះមិនញាប់ញ័រ មិនកម្រើក មិនរំភើបក្នុងឧទ្ធច្ចៈផង ក្នុងកិលេសដែលប្រព្រឹត្តទៅតាមឧទ្ធច្ចៈផង ក្នុងខន្ធផង នេះ សមថពលៈ។

[៩៨] កាតមំ វិបស្សនាពលំ ។ អនិច្ចានុបស្សនា វិ-
បស្សនាពលំ ទុក្ខានុបស្សនា វិបស្សនាពលំ ។ បេ ។ បដិ-
និស្សគ្គានុបស្សនា វិបស្សនាពលំ រូបេ អនិច្ចានុបស្ស-
នា វិបស្សនាពលំ រូបេ ទុក្ខានុបស្សនា វិបស្សនាពលំ
។ បេ ។ រូបេ បដិនិស្សគ្គានុបស្សនា វិបស្សនាពលំ
វេទនាយ សញ្ញាយ សង្ខារេសុ វិញ្ញាណេ ចក្ខុស្មឹ
។ បេ ។ ជរាមរណេ អនិច្ចានុបស្សនា វិបស្សនាពលំ
ជរាមរណេ ទុក្ខានុបស្សនា វិបស្សនាពលំ ជរាមរ-
ណេ បដិនិស្សគ្គានុបស្សនា វិបស្សនាពលំ ។

វិបស្សនាពលន្តិ កេនដ្ឋេន វិបស្សនាពលំ ។
អនិច្ចានុបស្សនាយ និច្ចសញ្ញាយ ន កម្បតីតិ
វិបស្សនាពលំ ទុក្ខានុបស្សនាយ សុខសញ្ញាយ
ន កម្បតីតិ វិបស្សនាពលំ អនត្តានុបស្សនាយ
អត្តសញ្ញាយ ន កម្បតីតិ វិបស្សនាពលំ

យុគនទ្ធវគ្គ ពលកថា

[៩៨] វិបស្សនាពលៈ តើដូចម្ដេច ។ ការពិចារណាឃើញ ថាមិនទៀង ឈ្មោះថាវិបស្សនាពលៈ ការពិចារណាឃើញ ថាជាទុក្ខ ឈ្មោះថាវិបស្សនាពលៈ ។ បេ ។ ការពិចារណាឃើញ ថាគួរលះ ឈ្មោះថាវិបស្សនាពលៈ ការពិចារណាឃើញ ថាមិនទៀង ក្នុងរូប ឈ្មោះថាវិបស្សនាពលៈ ការពិចារណាឃើញ ថាជាទុក្ខ ក្នុងរូប ឈ្មោះថាវិបស្សនាពលៈ ។ បេ ។ ការពិចារណាឃើញ ថាគួរលះ ក្នុងរូប ឈ្មោះថាវិបស្សនាពលៈ ការពិចារណាឃើញ ថាមិនទៀង ក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។ បេ ។ ក្នុងជរាមរណៈ ឈ្មោះថាវិបស្សនាពលៈ ការពិចារណាឃើញ ថាជាទុក្ខ ក្នុងជរាមរណៈ ឈ្មោះថាវិបស្សនាពលៈ ការពិចារណាឃើញ ថាគួរលះ ក្នុងជរាមរណៈ ឈ្មោះថាវិបស្សនាពលៈ ។

សំណួរត្រង់ពាក្យថា វិបស្សនាពលៈ តើវិបស្សនាពលៈ ដោយអត្ថថាដូចម្ដេច ។ ឈ្មោះថាវិបស្សនាពលៈ ព្រោះមិនញាប់ញ័រ ក្នុងនិច្ចសញ្ញា ដោយការពិចារណាឃើញ ថាមិនទៀង ឈ្មោះថាវិបស្សនាពលៈ ព្រោះមិនញាប់ញ័រ ក្នុងសុខសញ្ញា ដោយការពិចារណាឃើញ ថាជាទុក្ខ ឈ្មោះថាវិបស្សនាពលៈ ព្រោះមិនញាប់ញ័រ ក្នុងអត្តសញ្ញា ដោយការពិចារណាឃើញ ថាមិនមែនខ្លួន

និព្វិទានុបស្សនាយ នន្ទិយា ន កម្បតីតិ វិបស្សនាពលំ វិរាគានុបស្សនាយ រាគេ ន កម្បតីតិ វិបស្សនាពលំ និរោធានុបស្សនាយ សមុទយេ ន កម្បតីតិ វិបស្សនាពលំ បដិនិស្សគ្គានុបស្សនាយ អាទានេ ន កម្បតីតិ វិបស្សនាពលំ អវិជ្ជាយ ច អវិជ្ជាសហគតកិលេសេ ច ខន្ធេ ច ន កម្បតិ ន ចលតិ ន វេធតីតិ វិបស្សនាពលំ ឥទំ វិបស្សនាពលំ ។

[៩៩] កតមានិ ទស សេក្ខពលានិ ទស អសេក្ខពលានិ ។ សម្មាទិដ្ឋឹ សិក្ខតីតិ សេក្ខពលំ តត្ថ សិក្ខិតត្តា អសេក្ខពលំ សម្មាសង្កប្បំ សិក្ខតីតិ សេក្ខពលំ តត្ថ សិក្ខិតត្តា អសេក្ខពលំ សម្មាវាចំ ។ បេ ។ សម្មាកម្មន្តំ សម្មាអាជីវំ សម្មាវាយាមំ សម្មាសតឹ សម្មាសមាធឹ សម្មាញាណំ ។ បេ ។ សម្មាវិមុត្តឹ[១] សិក្ខតីតិ សេក្ខពលំ តត្ថ សិក្ខិតត្តា អសេក្ខពលំ ឥមានិ ទស សេក្ខពលានិ ទស អសេក្ខពលានិ ។

---

១ ម. សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ សម្មាញាណំ ។ បេ ។ សម្មាវិមុត្តីតិ ទិស្សន្តិ ។

ឈ្មោះថា វិបស្សនាពលៈ ព្រោះមិនញាប់ញ័រ ក្នុងសេចក្តីរីករាយ ដោយការពិចារណាឃើញ ថាគួរនឿយណាយ ឈ្មោះថាវិបស្សនា-ពលៈ ព្រោះមិនញាប់ញ័រ ក្នុងរាគៈ ដោយការពិចារណាឃើញ ថាគួររសាយ ឈ្មោះថាវិបស្សនាពលៈ ព្រោះមិនញាប់ញ័រ ក្នុងការកើតឡើង ដោយការពិចារណាឃើញនូវការរលត់ ឈ្មោះថាវិបស្សនាពលៈ ព្រោះមិនញាប់ញ័រ ក្នុងសេចក្តីប្រកាន់ ដោយការពិចារណាឃើញ ថាគួរលះ ឈ្មោះថាវិបស្សនាពលៈ ព្រោះមិនញាប់ញ័រ មិនកម្រើក មិនរំភើប ក្នុងអវិជ្ជាផង ក្នុងកិលេសដែលកើតរលត់ជាមួយគ្នានឹងអវិជ្ជាផង ក្នុងខន្ធផង នេះវិបស្សនាពលៈ ។

[៩៩] សេក្ខពលៈ ១០ និងអសេក្ខពលៈ ១០ តើដូចម្តេច ។ ឈ្មោះថាសេក្ខពលៈ ព្រោះកំពុងសិក្សានូវសម្មាទិដ្ឋិ ឈ្មោះថាអសេក្ខ-ពលៈ ព្រោះភាពនៃបុគ្គលដែលបានសិក្សាហើយ ក្នុងសម្មាទិដ្ឋិនោះ ឈ្មោះថាសេក្ខពលៈ ព្រោះកំពុងសិក្សានូវសម្មាសង្កប្បៈ ឈ្មោះថាអសេ-ក្ខពលៈ ព្រោះភាពនៃបុគ្គលដែលបានសិក្សាហើយ ក្នុងសម្មាសង្កប្បៈនោះ ឈ្មោះថាសេក្ខពលៈ ព្រោះកំពុងសិក្សា នូវសម្មាវាចា ។ បេ ។ នូវសម្មាកម្មន្តៈ នូវសម្មាអាជីវៈ នូវសម្មាវាយាមៈ នូវសម្មាសតិ នូវសម្មាសមាធិ នូវសម្មាញាណៈ ។ បេ ។ នូវសម្មាវិមុត្តិ ឈ្មោះថាអសេក្ខ-ពលៈ ព្រោះភាពនៃបុគ្គលដែលបានសិក្សាហើយ ក្នុងសម្មាវិមុត្តិ នេះសេក្ខពលៈ ១០ អសេក្ខពលៈ ១០ ។

យុគនទ្ធវគ្គេ ពលកថា

[១០០] កតមានិ ទស វីណាសវពលានិ ។ ឥធ វីណាសវស្ស ភិក្ខុនោ អនិច្ចតោ សព្វេ សង្ខារា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ យម្បិ វីណាសវស្ស ភិក្ខុនោ អនិច្ចតោ សព្វេ សង្ខារា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ឥទម្បិ វីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម វីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ វីណា មេ អាសវាតិ ។

បុន ចបរំ វីណាសវស្ស ភិក្ខុនោ អង្គារកាសូ-បមា កាមា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ យម្បិ វីណាសវស្ស ភិក្ខុនោ អង្គារកាសូបមា កាមា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ឥទម្បិ វីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម វីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ វីណា មេ អាសវាតិ ។

យុគនទ្ធវគ្គ ពលកថា

[១០០] ខីណាសវពលៈ (កម្លាំងព្រះខីណាស្រព) ១០ តើដូចម្តេច ។ ភិក្ខុជាព្រះខីណាស្រពក្នុងសាសនានេះ បានឃើញជាក់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃ នូវសង្ខារទាំងពួង ថាមិនទៀង ត្រង់ដែលភិក្ខុជាព្រះខីណាស្រព បានឃើញជាក់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃ នូវសង្ខារទាំងពួង ថាមិនទៀង នេះឯងជាកម្លាំង របស់ភិក្ខុជាព្រះខីណាស្រព ដែលជាកម្លាំង គឺភិក្ខុជាព្រះខីណាស្រព អាស្រ័យហើយ ទើបដឹងច្បាស់នូវការអស់ នៃអាសវៈទាំងឡាយថា អាត្មាអញអស់អាសវៈហើយ ។

មួយទៀត ភិក្ខុជាព្រះខីណាស្រព បានឃើញជាក់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃ នូវកាមទាំងឡាយ ថាមានឧបមាដោយរណ្តៅរងើកភ្លើង ត្រង់ដែលភិក្ខុជាព្រះខីណាស្រព បានឃើញជាក់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃ នូវកាមទាំងឡាយ ថាមានឧបមាដោយរណ្តៅរងើកភ្លើង នេះឯងជាកម្លាំង របស់ភិក្ខុជាព្រះខីណាស្រព ដែលជាកម្លាំង គឺភិក្ខុជាព្រះខីណាស្រព អាស្រ័យហើយ ទើបដឹងច្បាស់នូវការអស់ នៃអាសវៈទាំងឡាយ ថា អាត្មាអញអស់អាសវៈហើយ ។

បុន ចបរំ ខីណាសវស្ស ភិក្ខុនោ វិវេកនិន្នំ ចិត្តំ ហោតិ វិវេកបោណំ វិវេកបព្ភារំ វិវេកដ្ឋំ នេក្ខម្មាភិរតំ ព្យន្តីភូតំ សព្វសោ អាសវដ្ឋានីយេហិ ធម្មេហិ យម្បិ ខីណាសវស្ស ភិក្ខុនោ វិវេកនិន្នំ ចិត្តំ ហោតិ វិវេកបោណំ វិវេកបព្ភារំ វិវេកដ្ឋំ នេក្ខម្មាភិរតំ ព្យន្តីភូតំ សព្វសោ អាសវដ្ឋានីយេហិ ធម្មេហិ ឥទម្បិ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។

បុន ចបរំ ខីណាសវស្ស ភិក្ខុនោ ចត្តារោ សតិប្បដ្ឋានា ភាវិតា ហោន្តិ សុភាវិតា យម្បិ ខីណាសវស្ស ភិក្ខុនោ ចត្តារោ សតិប្បដ្ឋានា ភាវិតា ហោន្តិ សុភាវិតា ឥទម្បិ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។

មួយទៀត ភិក្ខុជាព្រះខីណាស្រព មានចិត្តឱនទៅរកវិវេក ទោរទៅរកវិវេក ឈមទៅរកវិវេក តាំងនៅក្នុងវិវេក ត្រេកអរក្នុងនេក្ខម្មៈ ឃ្លាតចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងពួង ត្រង់ដែលភិក្ខុជាព្រះខីណាស្រព មានចិត្តឱនទៅរកវិវេក ទោរទៅរកវិវេក ឈមទៅរកវិវេក តាំងនៅក្នុងវិវេក ត្រេកអរក្នុងនេក្ខម្មៈ ឃ្លាតចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងពួង នេះឯងជាកម្លាំង របស់ភិក្ខុជាព្រះខីណាស្រព ដែលជាកម្លាំង គឺភិក្ខុជាព្រះខីណាស្រព អាស្រ័យហើយ ទើបដឹងច្បាស់ នូវការអស់ នៃអាសវៈទាំងឡាយថា អាត្មាអញអស់អាសវៈហើយ ។

មួយទៀត ភិក្ខុជាព្រះខីណាស្រព បានអប់រំ អប់រំល្អហើយ នូវសតិប្បដ្ឋាន ៤ ត្រង់ដែលភិក្ខុជាព្រះខីណាស្រព បានអប់រំ អប់រំល្អហើយ នូវសតិប្បដ្ឋាន ៤ នេះឯងជាកម្លាំង របស់ភិក្ខុជាព្រះខីណាស្រព ដែលជាកម្លាំង គឺភិក្ខុជាព្រះខីណាស្រព អាស្រ័យហើយ ទើបដឹងច្បាស់នូវការអស់ នៃអាសវៈ ទាំងឡាយថា អាត្មាអញអស់អាសវៈហើយ ។

យុគនទ្ធវគ្គេ ពលកថា

បុន ចបរំ វីណាសវស្ស ភិក្ខុនោ ចត្តាពេ សម្មប្បធានា ភាវិតា ហោន្តិ សុភាវិតា ។ បេ ។ ចត្តា-ពេ ឥទ្ធិចាទា ភាវិតា ហោន្តិ សុភាវិតា បញ្ចិន្ទ្រិយា-និ ភាវិតានិ ហោន្តិ សុភាវិតានិ បញ្ចពលានិ ភា-វិតានិ ហោន្តិ សុភាវិតានិ សត្តពោជ្ឈង្គា ភាវិតា ។ បេ ។ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវិតោ ហោតិ សុភាវិតោ យម្បិ វីណាសវស្ស ភិក្ខុនោ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវិតោ ហោតិ សុភាវិតោ ឥទម្បិ វីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អា-គម្ម វីណាសពោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ វីណា មេ អាសវាតិ ឥមានិ ឧស វីណាសវស្ស ពលានិ ។

[១០១] កាតមានិ ឧស ឥទ្ធិពលានិ អធិដ្ឋានា ឥទ្ធិ វិកុព្វនា ឥទ្ធិ មនោមយា ឥទ្ធិ ញាណាវិប្ផារា ឥទ្ធិ ស-មាធិវិប្ផារា ឥទ្ធិ អរិយា ឥទ្ធិ កម្មវិចាកជា ឥទ្ធិ បុញ្ញ-វតោ ឥទ្ធិ វិជ្ជាមយា ឥទ្ធិ តត្ថ តត្ថ សម្មាបយោគ-ប្បច្ចយា ឥជ្ឈានដ្ឋេន ឥទ្ធិ ឥមានិ ឧស ឥទ្ធិពលានិ ។

មួយវិញទៀត ភិក្ខុជាព្រះខីណាស្រព បានអប់រំ អប់រំល្អហើយ នូវសម្មប្បធាន ៤ ។ បេ ។ បានអប់រំ អប់រំល្អហើយ នូវឥទ្ធិបាទ ៤ បានអប់រំ អប់រំល្អហើយ នូវឥន្ទ្រិយ ៥ បានអប់រំ អប់រំល្អហើយ នូវពលៈ ៥ បានអប់រំហើយ នូវពោជ្ឈង្គ ៧ ។ បេ ។ បានអប់រំ អប់រំល្អហើយ នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ត្រង់ដែលភិក្ខុជាព្រះខីណាស្រព បានអប់រំ អប់រំល្អហើយ នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ នេះឯងជាកម្លាំង របស់ភិក្ខុជាព្រះខីណាស្រព ដែលជាកម្លាំង គឺភិក្ខុជាព្រះខីណាស្រព អាស្រ័យហើយ ទើបដឹងច្បាស់នូវការអស់ នៃអាសវៈទាំងឡាយថា អាត្មាអញ អស់អាសវៈហើយ នេះ ខីណាសវពលៈ ១០ ។

[១០១] ឥទ្ធិពលៈ (កម្លាំងឫទ្ធិ) ១០ តើដូចម្តេច ឫទ្ធិ គឺការអធិដ្ឋាន ១ ឫទ្ធិ គឺការធ្វើឲ្យវិសេស ១ ឫទ្ធិ គឺអ្វីដែលសម្រេចដោយចិត្ត ១ ឫទ្ធិ គឺការផ្សាយចេញដោយសារញាណ ១ ឫទ្ធិ គឺការផ្សាយចេញដោយសារសមាធិ ១ ឫទ្ធិ គឺគុណជាតិប្រសើរ ១ ឫទ្ធិកើតអំពីផលកម្ម ១ ឫទ្ធិរបស់បុគ្គលមានបុណ្យ ១ ឫទ្ធិសម្រេចដោយសារវិជ្ជា ១ ឫទ្ធិដោយអត្ថថាសម្រេចព្រោះការប្រកបត្រូវ ក្នុងអំពើនោះៗ ជាបច្ច័យ ១ នេះ ឥទ្ធិពលៈ ១០ ។

[១០៦] កាតមានិ ទស តថាគតពលានិ ។ ឥធ តថាគតោ ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ បជានាតិ យម្បិ តថាគតោ ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ បជានាតិ ឥទម្បិ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឌានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។

បុន ចបរំ តថាគតោ អតីតានាគតបច្ចុប្បន្នា-នំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ បជានាតិ យម្បិ តថាគតោ អតីតានា-គតបច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុ-សោ វិបាកំ យថាភូតំ បជានាតិ ឥទម្បិ តថា-គតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឌានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។

[១០២] *តថាគតពលៈ* (កម្លាំងព្រះតថាគត) ១០ តើដូចម្តេច ។ ព្រះតថាគតក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់តាមពិត នូវហេតុគួរ ថាជាហេតុគួរផង នូវហេតុមិនគួរ ថាជាហេតុមិនគួរផង ត្រង់ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់តាមពិត នូវហេតុគួរ ថាជាហេតុគួរផង នូវហេតុមិនគួរ ថាជាហេតុមិនគួរផង នេះឯងជាតថាគតពលៈ របស់ព្រះតថាគត ដែលជាពលៈ គឺព្រះតថាគតអាស្រ័យហើយ ទើបទ្រង់ប្តេជ្ញា នូវឋានៈដ៏ប្រសើរ ទើបទ្រង់បន្លឺនូវសីហនាទ ក្នុងពួកបរិស័ទ ទើបទ្រង់ញុំាងព្រហ្មចក្រ ឲ្យប្រព្រឹត្តទៅ ។

មួយទៀត ព្រះតថាគត ទ្រង់ជ្រាបច្បាស់តាមពិត នូវផលវិបាកនៃកម្មសមាទាន ដែលជាអតីត អនាគតនិងបច្ចុប្បន្ន តាមឋានៈនិងតាមហេតុ ត្រង់ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់តាមពិត នូវផលវិបាកនៃកម្មសមាទាន ដែលជាអតីត អនាគតនិងបច្ចុប្បន្ន តាមឋានៈនិងតាមហេតុ នេះឯងជាតថាគតពលៈ របស់ព្រះតថាគត ដែលជាពលៈ គឺព្រះតថាគតអាស្រ័យហើយ ទើបទ្រង់ប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបទ្រង់បន្លឺនូវសីហនាទក្នុងពួកបរិស័ទ ទើបទ្រង់ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។

១៩៩

យុគនទ្ធវគ្គេ ពលកថា

បុន ចបរំ តថាគតោ សព្វត្ថគាមិនីបដិបទំ យថាភូតំ បជានាតិ យម្បិ តថាគតោ សព្វត្ថគាមិនី-បដិបទំ យថាភូតំ បជានាតិ ឥទម្បិ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគ-តោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហ-នាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។

បុន ចបរំ តថាគតោ អនេកធាតុនានាធាតុ-លោកំ យថាភូតំ បជានាតិ យម្បិ តថាគតោ អនេកធាតុនានាធាតុលោកំ យថាភូតំ បជានាតិ ឥទម្បិ តថាគតស្ស តថាគតពលំ ហោតិ ។ បេ ។

បុន ចបរំ តថាគតោ សត្តានំ នានាធិមុត្តិកតំ យថាភូតំ បជានាតិ យម្បិ តថាគតោ សត្តានំ នានាធិ-មុត្តិកតំ យថាភូតំ បជានាតិ ឥទម្បិ តថាគតស្ស ។ បេ ។

បុន ចបរំ តថាគតោ បរសត្តានំ បរបុគ្គលានំ ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ បជានាតិ យម្បិ ត-ថាគតោ បរសត្តានំ បរបុគ្គលានំ ឥន្ទ្រិយបរោបរិ-យត្តំ យថាភូតំ បជានាតិ ឥទម្បិ តថាគតស្ស ។ បេ ។

មួយទៀត ព្រះតថាគត ត្រង់ជ្រាបច្បាស់តាមពិត នូវបដិបទាជាដំណើរទៅកាន់ប្រយោជន៍ទាំងពួង ត្រង់ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់ តាមពិត នូវបដិបទាជាដំណើរទៅកាន់ប្រយោជន៍ទាំងពួង នេះឯងជា តថាគតពលៈ របស់ព្រះតថាគត ដែលជាពលៈ គឺព្រះតថាគតអាស្រ័យហើយ ទើបប្ដេជ្ញា នូវឋានៈដ៏ប្រសើរ ទើបទ្រង់បន្លឺនូវសីហនាទក្នុងពួកបរិស័ទ ទើបទ្រង់ញ៉ាំងព្រហ្មចក្រ ឲ្យប្រព្រឹត្តទៅ ។

មួយទៀត ព្រះតថាគតទ្រង់ជ្រាបច្បាស់តាមពិត នូវលោក មានធាតុច្រើន ឬមានធាតុផ្សេង ៗ ត្រង់ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់តាមពិត នូវលោក មានធាតុច្រើន ឬមានធាតុផ្សេង ៗ នេះឯងជាតថាគតពលៈ របស់ព្រះតថាគត ។ បេ ។

មួយទៀត ព្រះតថាគតទ្រង់ជ្រាបច្បាស់តាមពិត នូវអធ្យាស្រ័យផ្សេង ៗ គ្នា របស់ពួកសត្វ ត្រង់ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់តាមពិត នូវអធ្យាស្រ័យផ្សេង ៗ គ្នា របស់ពួកសត្វ នេះឯង ជាតថាគតពលៈ របស់ព្រះតថាគត ។ បេ ។

មួយទៀត ព្រះតថាគតទ្រង់ជ្រាបច្បាស់តាមពិត នូវភាពនៃឥន្ទ្រិយទន់ខ្ចីនិងចាស់ក្លា របស់សត្វដទៃ របស់បុគ្គលដទៃ ត្រង់ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់តាមពិត នូវភាពនៃឥន្ទ្រិយទន់ខ្ចីនិងចាស់ក្លា របស់សត្វដទៃរបស់បុគ្គលដទៃ នេះឯង ជាតថាគតពលៈ របស់ព្រះតថាគត ។ បេ ។

បុន ចបរំ តថាគតោ ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ បជានាតិ យម្បិ តថាគតោ ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ បជានាតិ ឥទម្បិ តថាគតស្ស ។ បេ ។

បុន ចបរំ តថាគតោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកំបិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ យម្បិ តថាគតោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកំបិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥទម្បិ តថាគតស្ស ។ បេ ។

បុន ចបរំ តថាគតោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ យម្បិ តថាគតោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ ឥទម្បិ តថាគតស្ស ។ បេ ។

មួយទៀត ព្រះតថាគត ទ្រង់ជ្រាបច្បាស់តាមពិត នូវសេចក្តីសៅហ្មង នូវសេចក្តីផូរផង់ នូវការចេញ នៃឈាន វិមោក្ខ សមាធិនិងសមាបត្តិ ត្រង់ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់តាមពិត នូវសេចក្តីសៅហ្មង នូវសេចក្តីផូរផង់ នូវការចេញ នៃឈាន វិមោក្ខ សមាធិនិងសមាបត្តិ នេះឯងជាតថាគតពលៈ របស់ព្រះតថាគត ។ បេ ។

មួយទៀត ព្រះតថាគត ទ្រង់រលឹកឃើញ នូវខន្ធបញ្ចកៈ ដែលធ្លាប់អាស្រ័យហើយក្នុងកាលមុន បានច្រើនជាតិ គឺ ទ្រង់រលឹកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ ទ្រង់រលឹកឃើញនូវខន្ធបញ្ចកៈ ដែលធ្លាប់អាស្រ័យហើយក្នុងកាលមុន បានច្រើនជាតិ ព្រមទាំងអាការនិងឧទ្ទេស ដោយប្រការដូច្នេះ ត្រង់ដែលព្រះតថាគត ទ្រង់រលឹកឃើញនូវខន្ធបញ្ចកៈ ដែលធ្លាប់អាស្រ័យនៅហើយក្នុងកាលមុន បានច្រើនជាតិ គឺ ទ្រង់រលឹកឃើញបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ នេះឯង ជាតថាគតពលៈ របស់ព្រះតថាគត ។ បេ ។

មួយទៀត ព្រះតថាគតទ្រង់ឃើញនូវពួកសត្វ ដែលច្យុតនិងកើតឡើង ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងបង់ នូវចក្ខុរបស់មនុស្សធម្មតា ត្រង់ដែលព្រះតថាគត ទ្រង់ឃើញពួកសត្វ ។ បេ ។ ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា នេះឯងជាតថាគតពលៈ របស់ព្រះតថាគត ។ បេ ។

បុន ចបរំ តថាគតោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ យម្បិ តថាគតោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឥទម្បិ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ឥមានិ ទស តថាគតពលានិ ។

[១០៣] កេនដ្ឋេន សទ្ធាពលំ កេនដ្ឋេន វីរិយពលំ កេនដ្ឋេន សតិពលំ កេនដ្ឋេន សមាធិពលំ កេនដ្ឋេន បញ្ញាពលំ កេនដ្ឋេន ហិរិពលំ កេនដ្ឋេន ឱត្តប្បពលំ កេនដ្ឋេន បដិសង្ខានពលំ កេនដ្ឋេន តថាគតពលំ ។ អស្សទ្ធិយេ អកម្បិយដ្ឋេន សទ្ធាពលំ កោសជ្ជេ អកម្បិយដ្ឋេន វីរិយពលំ បមាទេ អកម្បិយដ្ឋេន សតិពលំ ឧទ្ធច្ចេ អកម្បិយដ្ឋេន សមាធិពលំ

មួយទៀត ព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម របស់ព្រះអង្គក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះការអស់អាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ត្រង់ដែលព្រះតថាគត បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម របស់ព្រះអង្គក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះការអស់អាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ នេះឯងជា តថាគតពលៈ របស់ព្រះតថាគត ដែលជាពលៈ គឺព្រះតថាគតអាស្រ័យហើយ ទើបទ្រង់ប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបទ្រង់បន្លឺសីហនាទក្នុងពួកបរិស័ទ ទើបទ្រង់ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ នេះ តថាគតពលៈ ១០ ។

[១០៣] សទ្ធាពលៈ ដោយអត្ថដូចម្តេច វីរិយពលៈ ដោយអត្ថដូចម្តេច សតិពលៈ ដោយអត្ថដូចម្តេច សមាធិពលៈ ដោយអត្ថដូចម្តេច បញ្ញាពលៈ ដោយអត្ថដូចម្តេច ហិរិពលៈ ដោយអត្ថដូចម្តេច ឱត្តប្បពលៈ ដោយអត្ថដូចម្តេច បដិសង្ខានពលៈ ដោយអត្ថដូចម្តេច តថាគតពលៈ ដោយអត្ថដូចម្តេច ។ សទ្ធាពលៈ ដោយអត្ថថាមិនកម្រើក ព្រោះការណ៍មិនគួរជឿ វីរិយពលៈ ដោយអត្ថថាមិនកម្រើក ព្រោះសេចក្តីខ្ជិល សតិពលៈ ដោយអត្ថថាមិនកម្រើក ព្រោះការប្រហែស សមាធិពលៈ ដោយអត្ថថាមិនកម្រើក ព្រោះសេចក្តីរាយមាយ

អវិជ្ជាយ អកម្បិយដ្ឋេន បញ្ញាពលំ ហិរិយតិ ចាបកេ អកុសលេ ធម្មេតិ ហិរិពលំ ឱត្តប្បតិ ចាបកេ អកុសលេ ធម្មេតិ ឱត្តប្បពលំ ញាណេន កិលេសេ បដិសង្ខាតីតិ បដិសង្ខានពលំ តត្ថ ជាតា ធម្មា ឯករសា ហោន្តីតិ ភាវនាពលំ តត្ថ នត្ថិ កិញ្ចិ វជ្ជន្តិ អនវជ្ជពលំ តេន ចិត្តំ សង្គណ្ហាតីតិ សង្គហពលំ តំ តស្ស ខមតីតិ ខន្តិពលំ តេន ចិត្តំ បញ្ញបេតីតិ បញ្ញត្តិពលំ តេន ចិត្តំ និជ្ឈាបេតីតិ និជ្ឈត្តិពលំ តេន ចិត្តំ វសំ វត្តេតីតិ ឥស្សរិយពលំ តេន ចិត្តំ អធិដ្ឋាតីតិ អធិដ្ឋានពលំ តេន ចិត្តំ ឯកគ្គតន្តិ សមថពលំ តត្ថ ជាតេ ធម្មេ អនុបស្សតីតិ វិបស្សនាពលំ តត្ថ សិក្ខតីតិ សេក្ខពលំ តត្ថ សិក្ខិតត្តា អសេក្ខពលំ តេន អាសវា ខីណាតិ ខីណាសវពលំ តំ តស្ស ឥជ្ឈតីតិ ឥទ្ធិពលំ អប្បមេយ្យដ្ឋេន តថាគតពលន្តិ ។

ពលកថា ។

*បញ្ញាពលៈ ដោយអត្ថថាមិនកម្រើក ព្រោះអវិជ្ជា ឈ្មោះថាហិរិពលៈ ព្រោះខ្មាសចំពោះអកុសលធម៌ដ៏លាមក ឈ្មោះថាឱត្តប្បពលៈ ព្រោះខ្លាចចំពោះអកុសលធម៌ដ៏លាមក ឈ្មោះថាបដិសង្ខានពលៈ ព្រោះពិចារណានូវកិលេសដោយញាណ ឈ្មោះថាភាវនាពលៈ ព្រោះធម៌ទាំងឡាយដែលកើតក្នុងទីនោះមានរសតែមួយ ឈ្មោះថាអនវជ្ជពលៈ ព្រោះទោសបន្តិចបន្តួចមិនមានក្នុងធម៌នោះ ឈ្មោះថាសង្គាហពលៈ ព្រោះសង្គ្រោះចិត្តដោយធម៌នោះ ឈ្មោះថាខន្តិពលៈ ព្រោះនេក្ខម្មៈអត់ធន់បានចំពោះធម្មជាតនោះ ឈ្មោះថាបញ្ញត្តិពលៈ ព្រោះបញ្ញត្តចិត្តដោយធម៌នោះ ឈ្មោះថានិជ្ឈត្តិពលៈ ព្រោះសម្លឹងមើលចិត្តដោយធម៌នោះ ឈ្មោះថាឥស្សរិយពលៈ ព្រោះញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចដោយធម៌នោះ ឈ្មោះថាអធិដ្ឋានពលៈ ព្រោះអធិដ្ឋានចិត្តដោយធម៌នោះ ឈ្មោះថាសមថពលៈ ព្រោះចិត្តមានអារម្មណ៍តែមួយ ដោយធម៌នោះ ឈ្មោះថាវិបស្សនាពលៈ ព្រោះពិចារណាឃើញនូវធម៌ ដែលកើតហើយក្នុងធម៌នោះ ឈ្មោះថាសេក្ខពលៈ ព្រោះកំពុងសិក្សាក្នុងធម៌នោះ ឈ្មោះថាអសេក្ខពលៈ ព្រោះភាពនៃបុគ្គលបានសិក្សាហើយ ក្នុងធម៌នោះ ឈ្មោះថាខីណាសវពលៈ ព្រោះលោកអស់អាសវៈហើយ ដោយធម៌នោះ ឈ្មោះថាឥទ្ធិពលៈ ព្រោះធម្មជាតនោះសម្រេចដល់បុគ្គលនោះ ឈ្មោះថា តថាគតពលៈ ដោយអត្ថថាមានគុណរាប់មិនបាន ។*

ចប់ ពលកថា ។

# យុគនទ្ធវគ្គេ សុញ្ញកថា

[១០៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្សារាមេ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សុញ្ញោ លោកោ សុញ្ញោ លោកោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សុញ្ញោ លោកោតិ វុច្ចតីតិ ។ យស្មា ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វា តស្មា សុញ្ញោ លោកោតិ វុច្ចតិ កិញ្ចានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វា ចក្ខុំ ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វា រូបា សុញ្ញា អត្តេន វា អត្តនិយេន វា ចក្ខុវិញ្ញាណំ សុញ្ញំ អត្តេន វា អត្តនិយេន វា ចក្ខុសម្ផស្សោ សុញ្ញោ អត្តេន វា អត្តនិយេន វា យម្បិទំ[១] ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា

១ ម. យទិទំ ។

# យុគនទ្ធវគ្គ សុញ្ញកថា

[១០៤] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ គង់ស៊ប់ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គតែងពោលថា លោកសូន្យ លោកសូន្យ បពិត្រព្រះអង្គដ៏ចម្រើន ដែលព្រះអង្គពោលថា លោកសូន្យ តើដោយហេតុដូចម្តេច ។ ម្នាលអានន្ទ ធម្មជាតដែលសូន្យចាកខ្លួនឬចាកវត្ថុជារបស់ខ្លួន ព្រោះហេតុណាព្រោះហេតុនោះទើបតថាគតពោលថាលោកសូន្យ ម្នាលអានន្ទ ចុះធម្មជាតអ្វីដែលសូន្យចាកខ្លួនឬចាកវត្ថុជារបស់ខ្លួន ម្នាលអានន្ទ ចក្ខុហ្នឹងឯង ជាធម្មជាតសូន្យចាកខ្លួនឬចាកវត្ថុជារបស់ខ្លួន រូបសូន្យ ចាកខ្លួនឬចាកវត្ថុជារបស់ខ្លួន ចក្ខុវិញ្ញាណសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ចក្ខុសម្ផស្ស សូន្យចាកខ្លួនឬចាកវត្ថុជារបស់ខ្លួន វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែន

តម្បិ សុញ្ញំ អត្តេន វា អត្តនិយេន វា សោតំ សុញ្ញំ ។ បេ ។ សទ្ទា សុញ្ញា ឃានំ សុញ្ញំ គន្ធា សុញ្ញា ជិវ្ហា សុញ្ញា រសា សុញ្ញា កាយោ សុញ្ញោ ផោដ្ឋព្វា សុញ្ញា មនោ សុញ្ញោ អត្តេន វា អត្តនិយេន វា ធម្មា សុញ្ញា អត្តេន វា អត្តនិយេន វា មនោវិញ្ញាណំ សុញ្ញំ អត្តេន វា អត្តនិយេន វា មនោសម្ផស្សោ សុញ្ញោ អត្តេន វា អត្តនិយេន វា យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ សុញ្ញំ អត្តេន វា អត្តនិយេន វា យស្មា ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វា តស្មា សុញ្ញោ លោកោតិ វុច្ចតីតិ ។

[១០៥] សុញ្ញំ សុញ្ញំ[១] សង្ខារសុញ្ញំ វិបរិណាមសុញ្ញំ អគ្គសុញ្ញំ លក្ខណសុញ្ញំ វិក្ខម្ភនសុញ្ញំ តទង្គសុញ្ញំ សមុច្ឆេទសុញ្ញំ បដិប្បស្សទ្ធិសុញ្ញំ និស្សរណសុញ្ញំ អជ្ឈត្តសុញ្ញំ ពហិទ្ធាសុញ្ញំ

១ ឱ. ម. សុញ្ញសុញ្ញំ ។

សុខក្តី កើតឡើង ព្រោះចក្ខុសម្ផស្ស ជាបច្ច័យ វេទនានោះក៏សូន្យ ចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ត្រចៀកសូន្យ ។ បេ ។ សំឡេងសូន្យ ច្រមុះសូន្យ ក្លិនសូន្យ អណ្តាតសូន្យ រសសូន្យ កាយសូន្យ ផោ-ដ្ឋព្វៈសូន្យ ចិត្តសូន្យ ចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ធម្មារម្មណ៍សូន្យ ចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន មនោវិញ្ញាណសូន្យ ចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន មនោសម្ផស្សសូន្យ ចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើង ព្រោះមនោសម្ផស្ស ជាបច្ច័យ វេទនានោះក៏សូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ម្នាលអានន្ទ ធម្មជាតដែលសូន្យ ចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ព្រោះហេតុណា ព្រោះហេតុនោះ ទើបតថាគតពោលថា លោកសូន្យ ។

[១០៥] ធម្មជាតត្រូវសូន្យ សូន្យ សង្ខារសូន្យ ធម្មជាតប្រែប្រួលទាំងសូន្យ ធម្មជាតដ៏ប្រសើរសូន្យ លក្ខណៈសូន្យ ធម្មជាតសង្កត់សង្កិនទាំងសូន្យ ធម្ម-ជាតសូន្យដោយអង្គនោះ ធម្មជាតផ្តាច់ផ្តិលទាំងសូន្យ ធម្មជាតស្ងប់រម្ងាប់ទាំងសូន្យ ធម្មជាតរលាស់ចេញទាំងសូន្យ អាយតនៈខាងក្នុងសូន្យ អាយតនៈ

ឧភតោសុញ្ញំ សភាគសុញ្ញំ វិសភាគសុញ្ញំ ឯសនា-
សុញ្ញំ បរិគ្គហសុញ្ញំ បដិលាភសុញ្ញំ បដិវេធសុញ្ញំ
ឯកត្តសុញ្ញំ នានត្តសុញ្ញំ ខន្តិសុញ្ញំ អធិដ្ឋានសុញ្ញំ
បរិយោគាហនសុញ្ញំ សម្បជានស្ស បវត្តបរិយាទានំ
សព្វសុញ្ញតានំ បរមដ្ឋសុញ្ញំ ។

[១០៦] កតមំ សុញ្ញំ សុញ្ញំ ។ ចក្ខុំ សុញ្ញំ អត្តេន
វា អត្តនិយេន វា និច្ចេន វា ធុវេន វា សស្សតេន វា
អវិបរិណាមធម្មេន វា សោតំ សុញ្ញំ ។ បេ ។ ឃានំ សុញ្ញំ
ជិវ្ហា សុញ្ញា កាយោ សុញ្ញោ មនោ សុញ្ញោ អត្តេន
វា អត្តនិយេន វា និច្ចេន វា ធុវេន វា សស្ស-
តេន វា អវិបរិណាមធម្មេន វា ឥទំ សុញ្ញំ សុញ្ញំ ។

[១០៧] កតមំ សង្ខារសុញ្ញំ ។ តយោ សង្ខារា
បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារោ អនេញ្ជាភិសង្ខា-
រោ បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារេន ច អនេញ្ជា-
ភិសង្ខារេន ច សុញ្ញោ អបុញ្ញាភិសង្ខារោ បុញ្ញាភិ-
សង្ខារេន ច អនេញ្ជាភិសង្ខារេន ច សុញ្ញោ អនេ-
ញ្ជាភិសង្ខារោ បុញ្ញាភិសង្ខារេន ច អបុញ្ញាភិសង្ខារេន
ច សុញ្ញោ ឥមេ តយោ សង្ខារា ។

ខាងក្រៅសូន្យ អាយតនៈទាំងពីរសូន្យ ធម្មជាតមានចំណែកស្មើគ្នាទាំងសូន្យ ធម្មជាតមានចំណែកខុសគ្នាទាំងសូន្យ ការស្វែងរកសូន្យ ការកំណាត់សូន្យ ការបានចំពោះទាំងសូន្យ ការចាក់ធ្លុះសូន្យ ធម្មជាតដូចគ្នាទាំងសូន្យ ធម្មជាតផ្សេងគ្នាទាំងសូន្យ ខន្តិសូន្យ ការអធិដ្ឋានសូន្យ ការឈានចុះស៊ប់សូន្យ ការបង្អស់នូវការប្រព្រឹត្ត របស់បុគ្គលអ្នកដឹងទាន់ ឈ្មោះថាសូន្យដ៏ក្រៃលែង ជាងធម្មជាតសូន្យទាំងពួង ។

[១០៦] ធម្មជាតត្រូវសូន្យ សូន្យ តើដូចម្តេច ។ ចក្ខុសូន្យដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការពិតប្រាកដផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង ត្រចៀកសូន្យ ។ បេ ។ ច្រមុះសូន្យ អណ្តាតសូន្យ កាយសូន្យ ចិត្តសូន្យ ដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការពិតប្រាកដផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង នេះ ធម្មជាតត្រូវសូន្យ សូន្យ ។

[១០៧] សង្ខារសូន្យ តើដូចម្តេច ។ សង្ខារ ៣ គឺបុញ្ញាភិសង្ខារ ១ អបុញ្ញាភិសង្ខារ ១ អនេញ្ជាភិសង្ខារ ១ បុញ្ញាភិសង្ខារ សូន្យ ដោយអបុញ្ញាភិសង្ខារផង ដោយអនេញ្ជាភិសង្ខារផង ឯអបុញ្ញាភិសង្ខារ សូន្យដោយបុញ្ញាភិសង្ខារផង ដោយអនេញ្ជាភិសង្ខារផង អនេញ្ជាភិសង្ខារសូន្យដោយបុញ្ញាភិសង្ខារផង ដោយអបុញ្ញាភិសង្ខារផង នេះ សង្ខារ ៣។

អបរេបិ[១] តយោ សង្ខារា កាយសង្ខារោ វចីសង្ខារោ ចិត្តសង្ខារោ កាយសង្ខារោ វចីសង្ខារេន ច ចិត្តសង្ខារេន ច សុញ្ញោ វចីសង្ខារោ កាយសង្ខារេន ច ចិត្តសង្ខារេន ច សុញ្ញោ ចិត្តសង្ខារោ កាយសង្ខារេន ច វចីសង្ខារេន ច សុញ្ញោ ឥមេ តយោ សង្ខារា ។

អបរេបិ[២] តយោ សង្ខារា អតីតា សង្ខារា អនាគតា សង្ខារា បច្ចុប្បន្នា សង្ខារា អតីតា សង្ខារា អនាគតេហិ ច បច្ចុប្បន្នេហិ ច សង្ខារេហិ សុញ្ញា អនាគតា សង្ខារា អតីតេហិ ច បច្ចុប្បន្នេហិ ច សង្ខារេហិ សុញ្ញា បច្ចុប្បន្នា សង្ខារា អតីតេហិ ច អនាគតេហិ ច សង្ខារេហិ សុញ្ញា ឥមេ តយោ សង្ខារា ឥទំ សង្ខារសុញ្ញំ ។

[១០៨] កតមំ វិបរិណាមសុញ្ញំ ។ ជាតំ រូបំ សភាវេន សុញ្ញំ វិគតំ រូបំ វិបរិណតញ្ចេវ សុញ្ញញ្ច ជាតា វេទនា សភាវេន សុញ្ញា វិគតា វេទនា វិបរិណតា ចេវ សុញ្ញា ច ជាតា សញ្ញា[៣]

---

១ ២ ឱ. អបរាបិ ។ ៣ ឱ. ជាតា សញ្ញាតិ នត្ថិ ។

សង្ខារ ៣ ដទៃទៀត គឺកាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ កាយសង្ខារ សូន្យ ដោយវចីសង្ខារផង ដោយចិត្តសង្ខារផង វចីសង្ខារ សូន្យ ដោយកាយសង្ខារផង ដោយចិត្តសង្ខារផង ចិត្តសង្ខារ សូន្យ ដោយកាយសង្ខារផង ដោយវចីសង្ខារផង នេះ សង្ខារ ៣ ។

សង្ខារ ៣ ដទៃទៀត គឺ អតីតសង្ខារ ១ អនាគតសង្ខារ ១ បច្ចុប្បន្នសង្ខារ ១ អតីតសង្ខារ សូន្យ ដោយអនាគតសង្ខារផង ដោយបច្ចុប្បន្នសង្ខារផង ឯអនាគតសង្ខារ សូន្យ ដោយអតីតសង្ខារផង ដោយបច្ចុប្បន្នសង្ខារផង បច្ចុប្បន្នសង្ខារ សូន្យ ដោយអតីតសង្ខារផង ដោយអនាគតសង្ខារផង នេះ សង្ខារ ៣ នេះ សង្ខារសូន្យ ។

[១០៨] ធម្មជាតប្រែប្រួល ទាំងសូន្យ តើដូចម្តេច ។ រូបដែលកើតហើយ ឈ្មោះថាសូន្យ តាមសភាវៈ រូបដែលទៅប្រាសហើយ ឈ្មោះថាប្រែប្រួលផង ឈ្មោះថាសូន្យផង វេទនាដែលកើតហើយ ឈ្មោះថាសូន្យតាមសភាវៈ វេទនាដែលទៅប្រាសហើយ ឈ្មោះថាប្រែប្រួលផង ឈ្មោះថាសូន្យផង សញ្ញាដែលកើតហើយ

ជាតា សង្ខារា ជាតំ វិញ្ញាណំ ជាតំ ចក្ខុំ ។ បេ ។ ជាតោ ភវោ សភាវេន សុញ្ញោ វិគតោ ភវោ វិបរិណតោ ចេវ សុញ្ញោ ច ឥទំ វិបរិណាមសុញ្ញំ ។

[១០៩] កតមំ អគ្គសុញ្ញំ ។ អគ្គមេតំ បទំ សេដ្ឋមេតំ[១] បទំ វិសិដ្ឋមេតំ[២] បទំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ឥទំ អគ្គសុញ្ញំ ។

[១១០] កតមំ លក្ខណសុញ្ញំ ។ ទ្វេ លក្ខណានិ ពាលលក្ខណញ្ច បណ្ឌិតលក្ខណញ្ច ពាលលក្ខណំ បណ្ឌិតលក្ខណេន សុញ្ញំ បណ្ឌិតលក្ខណំ ពាលលក្ខណេន សុញ្ញំ ។ តីណិ លក្ខណានិ ឧប្បាទលក្ខណំ វយលក្ខណំ ឋិតញ្ញថត្តលក្ខណំ ឧប្បាទលក្ខណំ វយលក្ខណេន ច ឋិតញ្ញថត្តលក្ខណេន ច សុញ្ញំ វយលក្ខណំ ឧប្បាទលក្ខណេន ច ឋិតញ្ញថត្តលក្ខណេន ច សុញ្ញំ ឋិតញ្ញថត្តលក្ខណំ ឧប្បាទលក្ខណេន ច វយលក្ខណេន ច

១ ឱ. សេដ្ឋំ ឯតំ ។ ២ ឱ. វិសិដ្ឋំ ឯតំ ។ ម. វិសេដ្ឋមេតំ ។

*សង្ខារទាំងឡាយដែលកើតហើយ វិញ្ញាណដែលកើតហើយ ចក្ខុដែលកើតហើយ ។ បេ ។ ភពដែលកើតហើយ ឈ្មោះថាសូន្យ តាមសភាវៈ ភពដែលទៅប្រាសហើយ ឈ្មោះថាប្រែប្រួលផង ឈ្មោះថាសូន្យផង នេះ ធម្មជាតប្រែប្រួលទាំងសូន្យ ។*

[១០៩] *ធម្មជាតដ៏ប្រសើរសូន្យ តើដូចម្តេច ។ ការរម្ងាប់នូវសង្ខារទាំងពួង ការលះនូវឧបធិទាំងពួង ការអស់នៃតណ្ហា ការប្រាសចាកតម្រេក ការរលត់ ព្រះនិព្វាន ឯណា នុ៎ះជាបទដ៏ខ្ពង់ខ្ពស់ នុ៎ះជាបទដ៏ប្រសើរ នុ៎ះជាបទដ៏វិសេស នេះឯង ធម្មជាតដ៏ប្រសើរសូន្យ ។*

[១១០] *លក្ខណៈសូន្យ តើដូចម្តេច ។ លក្ខណៈ ២ គឺពាលលក្ខណៈ ១ បណ្ឌិតលក្ខណៈ ១ ពាលលក្ខណៈ សូន្យដោយបណ្ឌិតលក្ខណៈ ឯបណ្ឌិតលក្ខណៈ សូន្យដោយពាលលក្ខណៈ ។ លក្ខណៈ ៣ គឺ លក្ខណៈនៃការកើត ១ លក្ខណៈនៃការសូន្យ ១ លក្ខណៈនៃការប្រែប្រួលចាកការតាំងនៅ ១ លក្ខណៈនៃការកើត សូន្យ ដោយលក្ខណៈនៃការសូន្យផង ដោយលក្ខណៈ នៃការប្រែប្រួលចាកការតាំងនៅផង ឯលក្ខណៈនៃការសូន្យ សូន្យ ដោយលក្ខណៈ នៃការកើតផង ដោយលក្ខណៈនៃការប្រែប្រួលចាកការតាំងនៅផង លក្ខណៈនៃការប្រែប្រួលចាកការតាំងនៅសូន្យ ដោយលក្ខណៈនៃការកើតផង ដោយលក្ខណៈនៃការសូន្យផង*

សុញ្ញំ រូបស្ស ឧប្បាទលក្ខណំ វយលក្ខណេន ច ឋិតញ្ញថត្តលក្ខណេន ច សុញ្ញំ រូបស្ស វយ-លក្ខណំ ឧប្បាទលក្ខណេន ច ឋិតញ្ញថត្តលក្ខ-ណេន ច សុញ្ញំ រូបស្ស ឋិតញ្ញថត្តលក្ខណំ ឧ-ប្បាទលក្ខណេន ច វយលក្ខណេន ច សុញ្ញំ វេទ-នាយ សញ្ញាយ សង្ខារានំ វិញ្ញាណស្ស ចក្ខុស្ស ។ បេ ។ ជរាមរណស្ស ឧប្បាទលក្ខណំ វយលក្ខណេន ច ឋិតញ្ញថត្តលក្ខណេន ច សុញ្ញំ ជរាមរណស្ស វយលក្ខណំ ឧប្បាទលក្ខណេន ច ឋិតញ្ញថត្តលក្ខ-ណេន ច សុញ្ញំ ជរាមរណស្ស ឋិតញ្ញថត្តលក្ខណំ ឧប្បាទលក្ខណេន ច វយលក្ខណេន ច សុញ្ញំ ឥទំ លក្ខណសុញ្ញំ ។

[១១១] កតមំ វិក្ខម្ភនសុញ្ញំ ។ នេក្ខម្មេន កាម-ច្ឆន្ទោ វិក្ខម្ភិតោ ចេវ សុញ្ញោ ច អព្យាបាទេន ព្យាបាទោ វិក្ខម្ភិតោ ចេវ សុញ្ញោ ច អាលោកសញ្ញាយ ថីនមិទ្ធំ វិក្ខម្ភិតញ្ចេវ សុញ្ញញ្ច អវិក្ខេបេន ឧទ្ធច្ចំ វិក្ខម្ភិតញ្ចេវ សុញ្ញញ្ច ធម្មវវត្ថានេន វិចិកិច្ឆា វិក្ខម្ភិតា ចេវ សុញ្ញា ច

លក្ខណៈនៃការកើតនៃរូប សូន្យ ដោយលក្ខណៈ នៃការសូន្យផង ដោយលក្ខណៈ នៃការប្រែប្រួលចាកការតាំងនៅផង លក្ខណៈនៃការសូន្យនៃរូប សូន្យ ដោយលក្ខណៈនៃការកើតផង ដោយលក្ខណៈនៃការប្រែប្រួលចាកការតាំងនៅផង លក្ខណៈនៃការប្រែប្រួល ចាកការតាំងនៅនៃរូប សូន្យ ដោយលក្ខណៈនៃការកើតផង ដោយលក្ខណៈនៃការសូន្យផង លក្ខណៈនៃការកើតនៃវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ នៃជរាមរណៈ សូន្យ ដោយលក្ខណៈនៃការសូន្យផង ដោយលក្ខណៈនៃការប្រែប្រួលចាកការតាំងនៅផង លក្ខណៈនៃការសូន្យនៃជរាមរណៈ សូន្យ ដោយលក្ខណៈ នៃការកើតផង ដោយលក្ខណៈនៃការប្រែប្រួលចាកការតាំងនៅផង លក្ខណៈនៃការប្រែប្រួលចាកការតាំងនៅ នៃជរាមរណៈ សូន្យ ដោយលក្ខណៈនៃការកើតផង ដោយលក្ខណៈនៃការសូន្យផង នេះ លក្ខណៈសូន្យ ។

[១១១] ធម្មជាតសង្កត់សង្កិនទាំងសូន្យ តើដូចម្តេច ។ កាមច្ឆន្ទៈ គេសង្កត់សង្កិនផង សូន្យផង ដោយនេក្ខម្មៈ ព្យាបាទ គេសង្កត់សង្កិនផង សូន្យផង ដោយអព្យាបាទ ថីនមិទ្ធៈ គេសង្កត់សង្កិនផង សូន្យផង ដោយអាលោកសញ្ញា ឧទ្ធច្ចៈ គេសង្កត់សង្កិនផង សូន្យផងដោយការមិនរាយមាយ វិចិកិច្ឆា គេសង្កត់សង្កិនផង សូន្យផង ដោយការកំណត់នូវធម៌

ញាណេន អវិជ្ជា វិក្ខម្ភិតា ចេវ សុញ្ញា ច បាមុជ្ជេន អរតិ វិក្ខម្ភិតា ចេវ សុញ្ញា ច បឋមជ្ឈានេន នីវរណា វិក្ខម្ភិតា ចេវ សុញ្ញា ច ។ បេ ។ អរហត្តមគ្គេន សព្វក្កិលេសា វិក្ខម្ភិតា ចេវ សុញ្ញា ច ឥទំ វិក្ខម្ភនសុញ្ញំ ។

[១១២] កតមំ តទង្គសុញ្ញំ ។ នេក្ខម្មេន កាមច្ឆន្ទោ តទង្គសុញ្ញោ អព្យាបាទេន ព្យាបាទោ តទង្គសុញ្ញោ អាលោកសញ្ញាយ ថីនមិទ្ធំ តទង្គសុញ្ញំ អវិក្ខេបេន ឧទ្ធច្ចំ តទង្គសុញ្ញំ ធម្មវវត្ថានេន វិចិកិច្ឆា តទង្គសុញ្ញា ញាណេន អវិជ្ជា តទង្គសុញ្ញា បាមុជ្ជេន អរតិ តទង្គសុញ្ញា បឋមជ្ឈានេន នីវរណា តទង្គសុញ្ញា ។ បេ ។ វិវដ្ដនានុបស្សនាយ សញ្ញោគាភិនិវេសោ តទង្គសុញ្ញោ ឥទំ តទង្គសុញ្ញំ ។

[១១៣] កតមំ សមុច្ឆេទសុញ្ញំ ។ នេក្ខម្មេន កាមច្ឆន្ទោ សមុច្ឆិន្នោ ចេវ សុញ្ញោ ច អព្យាបាទេន ព្យាបាទោ សមុច្ឆិន្នោ ចេវ សុញ្ញោ ច អាលោកសញ្ញាយ ថីនមិទ្ធំ សមុច្ឆិន្នញ្ចេវ សុញ្ញញ្ច អវិក្ខេបេន ឧទ្ធច្ចំ សមុច្ឆិន្នញ្ចេវ សុញ្ញញ្ច

អវិជ្ជា គេសង្កត់សង្កិនផង សូន្យផង ដោយញាណ អរតិ (សេចក្តីមិនត្រេកអរ) គេសង្កត់សង្កិនផង សូន្យផង ដោយបាមុជ្ជៈ នីវរណៈ គេសង្កត់សង្កិនផង សូន្យផង ដោយបឋមជ្ឈាន ។ បេ ។ កិលេសទាំងអស់ គេសង្កត់សង្កិនផង សូន្យផង ដោយអរហត្តមគ្គ នេះ ធម្មជាតសង្កត់សង្កិនទាំងសូន្យ ។

[១១២] ធម្មជាតសូន្យដោយអង្គនោះ តើដូចម្តេច ។ កាមច្ឆន្ទៈ សូន្យដោយអង្គនោះ គឺដោយនេក្ខម្មៈ ព្យាបាទ សូន្យដោយអង្គនោះ គឺដោយអព្យាបាទ ថីនមិទ្ធៈ សូន្យដោយអង្គនោះ គឺដោយអាលោកសញ្ញា ឧទ្ធច្ចៈ សូន្យដោយអង្គនោះ គឺដោយការមិនរាយមាយ វិចិកិច្ឆា សូន្យដោយអង្គនោះ គឺដោយការកំណត់នូវធម៌ អវិជ្ជា សូន្យដោយអង្គនោះ គឺដោយញាណ អរតិ សូន្យដោយអង្គនោះ គឺដោយបាមុជ្ជៈ ពួកនីវរណៈ សូន្យដោយអង្គនោះ គឺដោយបឋមជ្ឈាន ។ បេ ។ ការប្រកាន់មាំដោយសំយោគ សូន្យដោយអង្គនោះ គឺដោយវិវដ្ដនានុបស្សនា នេះ ធម្មជាតសូន្យដោយអង្គនោះ ។

[១១៣] ធម្មជាតផ្តាច់ផ្តិលទាំងសូន្យ តើដូចម្តេច ។ កាមច្ឆន្ទៈ គេផ្តាច់ផ្តិលផង សូន្យផង ដោយនេក្ខម្មៈ ព្យាបាទ គេផ្តាច់ផ្តិលផង សូន្យផង ដោយអព្យាបាទ ថីនមិទ្ធ គេផ្តាច់ផ្តិលផង សូន្យផង ដោយអាលោកសញ្ញា ឧទ្ធច្ចៈ គេផ្តាច់ផ្តិលផង សូន្យផង ដោយការមិនរាយមាយ

ធម្មវវត្ថានេន វិចិកិច្ឆា សមុច្ឆិន្នា ចេវ សុញ្ញា ច ញាណេន អវិជ្ជា សមុច្ឆិន្នា ចេវ សុញ្ញា ច បាមុជ្ជេន អរតិ សមុច្ឆិន្នា ចេវ សុញ្ញា ច បឋមជ្ឈានេន នីវរណា សមុច្ឆិន្នា ចេវ សុញ្ញា ច ។ បេ ។ អរហត្តមគ្គេន សព្វកិលេសា សមុច្ឆិន្នា ចេវ សុញ្ញា ច ឥទំ សមុច្ឆេទសុញ្ញំ ។

[១១៤] កតមំ បដិប្បស្សទ្ធិសុញ្ញំ ។ នេក្ខម្មេន កាមច្ឆន្ទោ បដិប្បស្សទ្ធោ ចេវ សុញ្ញោ ច អព្យាបាទេន ព្យាបាទោ បដិប្បស្សទ្ធោ ចេវ សុញ្ញោ ច អាលោកសញ្ញាយ ថីនមិទ្ធំ បដិប្បស្សទ្ធញ្ចេវ សុញ្ញញ្ច អវិក្ខេបេន ឧទ្ធច្ចំ បដិប្បស្សទ្ធញ្ចេវ សុញ្ញញ្ច ធម្មវវត្ថានេន វិចិកិច្ឆា បដិប្បស្សទ្ធា ចេវ សុញ្ញា ច ញាណេន អវិជ្ជា បដិប្បស្សទ្ធា ចេវ សុញ្ញា ច បាមុជ្ជេន អរតិ បដិប្បស្សទ្ធា ចេវ សុញ្ញា ច បឋមជ្ឈានេន នីវរណា បដិប្បស្សទ្ធា ចេវ សុញ្ញា ច ។ បេ ។ អរហត្តមគ្គេន សព្វកិលេសា បដិប្បស្សទ្ធា ចេវ សុញ្ញា ច ឥទំ បដិប្បស្សទ្ធិសុញ្ញំ ។

វិចិកិច្ឆា គេផ្តាច់ផ្តិលផង សូន្យផង ដោយការកំណត់នូវធម៌ អវិជ្ជា គេផ្តាច់ផ្តិលផង សូន្យផង ដោយញាណ អរតិ គេផ្តាច់ផ្តិលផង សូន្យផង ដោយបាមុជ្ជៈ នីវរណៈទាំងឡាយ គេផ្តាច់ផ្តិលផង សូន្យផង ដោយបឋមជ្ឈាន ។ បេ ។ កិលេសទាំងអស់ គេផ្តាច់ផ្តិលផង សូន្យផង ដោយអរហត្តមគ្គ នេះ ធម្មជាតផ្តាច់ផ្តិលទាំងសូន្យ ។

[១១៤] ធម្មជាតស្ងប់រម្ងាប់ទាំងសូន្យ តើដូចម្តេច ។ កាមច្ឆន្ទៈ ស្ងប់រម្ងាប់ផង សូន្យផង ដោយនេក្ខម្មៈ ព្យាបាទ ស្ងប់រម្ងាប់ផង សូន្យផង ដោយអព្យាបាទ ថីនមិទ្ធ ស្ងប់រម្ងាប់ផង សូន្យផង ដោយអាលោកសញ្ញា ឧទ្ធច្ចៈ ស្ងប់រម្ងាប់ផង សូន្យផង ដោយការមិនរាយមាយ វិចិកិច្ឆា ស្ងប់រម្ងាប់ផង សូន្យផង ដោយការកំណត់នូវធម៌ អវិជ្ជា ស្ងប់រម្ងាប់ផង សូន្យផង ដោយញាណ អរតិ ស្ងប់រម្ងាប់ផង សូន្យផង ដោយបាមុជ្ជៈ ពួកនីវរណៈ ស្ងប់រម្ងាប់ផង សូន្យផង ដោយបឋមជ្ឈាន ។ បេ ។ កិលេសទាំងអស់ ស្ងប់រម្ងាប់ផង សូន្យផង ដោយអរហត្តមគ្គ នេះ ធម្មជាតស្ងប់រម្ងាប់ទាំងសូន្យ ។

២១១

## យុគនទ្ធវគ្គេ សុញ្ញកថា

[១១៥] កតមំ និស្សរណសុញ្ញំ ។ នេក្ខម្មេន កាមច្ឆន្ទោ និស្សដោ ចេវ សុញ្ញោ ច អព្យាបាទេន ព្យាបាទោ និស្សដោ ចេវ សុញ្ញោ ច អាលោកសញ្ញាយ ថីនមិទ្ធំ និស្សដញ្ចេវ សុញ្ញញ្ច អវិក្ខេបេន ឧទ្ធច្ចំ និស្សដញ្ចេវ សុញ្ញញ្ច ធម្មវវត្ថានេន វិចិកិច្ឆា និស្សដា ចេវ សុញ្ញា ច ញាណេន អវិជ្ជា និស្សដា ចេវ សុញ្ញា ច បាមុជ្ជេន អរតិ និស្សដា ចេវ សុញ្ញា ច បឋមជ្ឈានេន នីវរណា និស្សដា ចេវ សុញ្ញា ច ។ បេ ។ អរហត្តមគ្គេន សព្វកិលេសា និស្សដា ចេវ សុញ្ញា ច ឥទំ និស្សរណសុញ្ញំ ។

[១១៦] កតមំ អជ្ឈត្តសុញ្ញំ ។ អជ្ឈត្តំ ចក្ខុ សុញ្ញំ អត្តេន វា អត្តនិយេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វា អជ្ឈត្តំ សោតំ សុញ្ញំ ។ បេ ។ អជ្ឈត្តំ ឃានំ សុញ្ញំ អជ្ឈត្តំ ជិវ្ហា សុញ្ញា អជ្ឈត្តំ កាយោ សុញ្ញោ អជ្ឈត្តំ មនោ សុញ្ញោ អត្តេន វា អត្តនិយេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វា ឥទំ អជ្ឈត្តសុញ្ញំ ។

យុគនទ្ធវគ្គ សុញ្ញកថា

[១១៥] ធម្មជាតរលាស់ចេញទាំងសូន្យ តើដូចម្ដេច ។ កាមច្ឆន្ទៈ គេរលាស់ចេញផង សូន្យផង ដោយនេក្ខម្មៈ ព្យាបាទ គេរលាស់ចេញផង សូន្យផង ដោយអព្យាបាទ ថីនមិទ្ធ គេរលាស់ចេញផង សូន្យផង ដោយអាលោកសញ្ញា ឧទ្ធច្ចៈ គេរលាស់ចេញផង សូន្យផង ដោយការមិនរាយមាយ វិចិកិច្ឆា គេរលាស់ចេញផង សូន្យផង ដោយការកំណត់នូវធម៌ អវិជ្ជា គេរលាស់ចេញផង សូន្យផង ដោយញាណ អរតិ គេរលាស់ចេញផង សូន្យផង ដោយបាមុជ្ជៈ ពួកនីវរណៈ គេរលាស់ចេញផង សូន្យផង ដោយបឋមជ្ឈាន ។ បេ ។ កិលេសទាំងអស់ គេរលាស់ចេញផង សូន្យផង ដោយអរហត្តមគ្គ នេះ ធម្មជាតរលាស់ចេញទាំងសូន្យ ។

[១១៦] អាយតនៈខាងក្នុងសូន្យ តើដូចម្ដេច ។ ចក្ខុខាងក្នុងសូន្យ ដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការឋិតថេរផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង ត្រចៀកខាងក្នុង សូន្យ ។ បេ ។ ច្រមុះខាងក្នុង សូន្យ អណ្ដាតខាងក្នុង សូន្យ កាយខាងក្នុង សូន្យ ចិត្តខាងក្នុង សូន្យ ដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការឋិតថេរផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង នេះ អាយតនៈខាងក្នុងសូន្យ ។

[១១៧] កតមំ ពហិទ្ធា សុញ្ញំ ។ ពហិទ្ធា រូបា សុ-ញ្ញា ។ បេ ។ ពហិទ្ធា ធម្មា សុញ្ញា អត្តេន វា អត្ត-និយេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិ-បរិណាមធម្មេន វា ឥទំ ពហិទ្ធាសុញ្ញំ ។

[១១៨] កតមំ ទុភតោសុញ្ញំ ។ យញ្ច អជ្ឈ-ត្តំ ចក្ខុំ[១] យេ ច ពហិទ្ធា រូបា ឧភយតោ តំ[២] សុញ្ញំ អត្តេន វា អត្តនិយេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វា យញ្ច អជ្ឈត្តំ សោតំ យេ ច ពហិទ្ធា សទ្ទា ។ បេ ។ យញ្ច អជ្ឈ-ត្តំ ឃានំ យេ ច ពហិទ្ធា គន្ធា យា ច អជ្ឈត្តំ ជិ-វ្ហា យេ ច ពហិទ្ធា រសា យោច អជ្ឈត្តំ កាយោ យេ ច ពហិទ្ធា ផោដ្ឋព្វា យោ ច អជ្ឈត្តំ មនោ យេ ច ពហិទ្ធា ធម្មា ឧភយតោ តំ សុញ្ញំ អត្តេន វា អត្តនិយេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វា ឥទំ ទុភតោសុញ្ញំ ។

---

១ ម. ចក្ខុ ។ ២ ឱ. ម. ឧភយមេតំ ។

[១១៧] អាយតនៈខាងក្រៅសូន្យ តើដូចម្តេច ។ រូបខាងក្រៅ សូន្យ ។ បេ ។ ធម្មារម្មណ៍ខាងក្រៅ សូន្យ ដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការឋិតថេរផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង នេះ អាយតនៈខាងក្រៅសូន្យ ។

[១១៨] អាយតនៈទាំងពីរសូន្យ តើដូចម្តេច ។ ចក្ខុខាងក្នុងណា និងរូបខាងក្រៅណា ធម្មជាតទាំងពីរនោះ សូន្យ ដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការឋិតថេរផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង ត្រចៀកខាងក្នុងណា និងសំឡេងខាងក្រៅណា ។ បេ ។ ច្រមុះខាងក្នុងណា និងក្លិនខាងក្រៅណា អណ្តាតខាងក្នុងណា និងរសខាងក្រៅណា កាយខាងក្នុងណា និងផោដ្ឋព្វៈខាងក្រៅណា ចិត្តខាងក្នុងណា និងធម្មារម្មណ៍ខាងក្រៅណា ធម្មជាតទាំងពីរនោះ សូន្យដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការឋិតថេរផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង នេះអាយតនៈទាំងពីរសូន្យ ។

យុគនទ្ធវគ្គេ សុញ្ញកថា

[១១៩] កតមំ សភាគសុញ្ញំ ។ ឆ អជ្ឈត្តិកានិ អាយតនានិ សភាគានិ ចេវ សុញ្ញានិ ច ឆ ពាហិរានិ អាយតនានិ សភាគានិ ចេវ សុញ្ញានិ ច ឆ វិញ្ញាណកាយា សភាគា ចេវ សុញ្ញា ច ឆ ផស្សកាយា សភាគា ចេវ សុញ្ញា ច ឆ វេទនាកាយា សភាគា ចេវ សុញ្ញា ច ឆ សញ្ញាកាយា សភាគា ចេវ សុញ្ញា ច ឆ ចេតនាកាយា សភាគា ចេវ សុញ្ញា ច ឥទំ សភាគសុញ្ញំ ។

[១២០] កតមំ វិសភាគសុញ្ញំ ។ ឆ អជ្ឈត្តិកានិ អាយតនានិ ឆហិ ពាហិរាយតនេហិ វិសភាគានិ ចេវ សុញ្ញានិ ច ឆ ពាហិរាយតនានិ ឆហិ វិញ្ញាណកាយេហិ វិសភាគានិ ចេវ សុញ្ញានិ ច ឆ វិញ្ញាណកាយា ឆហិ ផស្សកាយេហិ វិសភាគា ចេវ សុញ្ញា ច ឆ ផស្សកាយា ឆហិ វេទនាកាយេហិ វិសភាគា ចេវ សុញ្ញា ច ឆ វេទនាកាយា ឆហិ សញ្ញាកាយេហិ វិសភាគា ចេវ សុញ្ញា ច ឆ សញ្ញាកាយា ឆហិ ចេតនាកាយេហិ វិសភាគា ចេវ សុញ្ញា ច ឥទំ វិសភាគសុញ្ញំ ។

យុគនទ្ធវគ្គ សុញ្ញកថា

[១១៩] ធម្មជាតមានចំណែកស្មើគ្នាទាំងសូន្យ តើដូចម្ដេច ។ អាយតនៈ ខាងក្នុង ៦ មានចំណែកស្មើគ្នាផង សូន្យផង អាយតនៈ ខាងក្រៅ ៦ មានចំណែកស្មើគ្នាផង សូន្យផង ពួកនៃវិញ្ញាណ ៦ មានចំណែកស្មើគ្នាផង សូន្យផង ពួកនៃផស្សៈ ៦ មានចំណែក ស្មើគ្នាផង សូន្យផង ពួកនៃវេទនា ៦ មានចំណែកស្មើគ្នាផង សូន្យ ផង ពួកនៃសញ្ញា ៦ មានចំណែកស្មើគ្នាផង សូន្យផង ពួកនៃ ចេតនា ៦ មានចំណែកស្មើគ្នាផង សូន្យផង នេះ ធម្មជាតមាន ចំណែកស្មើគ្នាទាំងសូន្យ ។

[១២០] ធម្មជាតមានចំណែកខុសគ្នាទាំងសូន្យ តើដូចម្ដេច ។ អាយតនៈ ខាងក្នុង ៦ មានចំណែកខុសគ្នា ពីអាយតនៈខាងក្រៅ ៦ ផង សូន្យផង អាយតនៈខាងក្រៅ ៦ មានចំណែខុសគ្នា ពីពួកនៃ វិញ្ញាណ ៦ ផង សូន្យផង ពួកនៃវិញ្ញាណ ៦ មានចំណែកខុសគ្នាពីពួក នៃផស្សៈ ៦ ផង សូន្យផង ពួកនៃផស្សៈ ៦ មានចំណែកខុសគ្នា ពីពួក នៃវេទនា ៦ ផង សូន្យផង ពួកនៃវេទនា ៦ មានចំណែកខុសគ្នាពីពួកនៃ សញ្ញា ៦ ផង សូន្យផង ពួកនៃសញ្ញា ៦ មានចំណែកខុសគ្នាពីពួកនៃ ចេតនា ៦ ផង សូន្យផង នេះ ធម្មជាតមានចំណែកខុសគ្នាទាំងសូន្យ ។

[១២១] កតមំ ឯសនាសុញ្ញំ ។ នេក្ខម្មេសនា កាមច្ឆន្ទេន សុញ្ញា អព្យាបាទេសនា ព្យាបាទេន សុញ្ញា អាលោកសញ្ញេសនា ថីនមិទ្ធេន សុញ្ញា អវិក្ខេបេសនា ឧទ្ធច្ចេន សុញ្ញា ធម្មវវត្ថានេសនា វិចិកិច្ឆាយ សុញ្ញា ញាណេសនា អវិជ្ជាយ សុញ្ញា បាមុជ្ជេសនា អរតិយា សុញ្ញា បឋមជ្ឈានេសនា នីវរណេហិ សុញ្ញា ។ បេ ។ អរហត្តមគ្គេសនា សព្វកិលេសេហិ សុញ្ញា ឥទំ ឯសនាសុញ្ញំ ។

[១២២] កតមំ បរិគ្គហសុញ្ញំ ។ នេក្ខម្មបរិគ្គហោ កាមច្ឆន្ទេន សុញ្ញោ អព្យាបាទបរិគ្គហោ ព្យាបាទេន សុញ្ញោ អាលោកសញ្ញាបរិគ្គហោ ថីនមិទ្ធេន សុញ្ញោ អវិក្ខេបបរិគ្គហោ ឧទ្ធច្ចេន សុញ្ញោ ធម្មវវត្ថានបរិគ្គហោ វិចិកិច្ឆាយ សុញ្ញោ ញាណបរិគ្គហោ អវិជ្ជាយ សុញ្ញោ បាមុជ្ជបរិគ្គហោ អរតិយា សុញ្ញោ បឋមជ្ឈានបរិគ្គហោ នីវរណេហិ សុញ្ញោ ។ បេ ។ អរហត្តមគ្គបរិគ្គហោ សព្វកិលេសេហិ សុញ្ញោ ឥទំ បរិគ្គហសុញ្ញំ ។

[១២១] ការស្វែងរកសូន្យ តើដូចម្តេច ។ ការស្វែងរកនេក្ខម្មៈ សូន្យដោយកាមច្ឆន្ទៈ ការស្វែងរកអព្យាបាទ សូន្យដោយព្យាបាទ ការស្វែងរកអាលោកសញ្ញា សូន្យដោយថីនមិទ្ធ ការស្វែងរកសេចក្តីមិនរាយមាយ សូន្យ ដោយឧទ្ធច្ចៈ ការស្វែងរកសេចក្តីកំណត់នូវធម៌ សូន្យដោយវិចិកិច្ឆា ការស្វែងរកញាណ សូន្យដោយអវិជ្ជា ការស្វែងរកបាមុជ្ជៈ សូន្យដោយអរតិ ការស្វែងរកបឋមជ្ឈាន សូន្យដោយនីវរណៈ ។ បេ ។ ការស្វែងរកអរហត្តមគ្គ សូន្យដោយកិលេសទាំងអស់ នេះ ការស្វែងរកសូន្យ ។

[១២២] ការកំណត់សូន្យ តើដូចម្តេច ។ ការកំណត់នូវនេក្ខម្មៈ សូន្យដោយកាមច្ឆន្ទៈ ការកំណត់នូវអព្យាបាទ សូន្យដោយព្យាបាទ ការកំណត់នូវអាលោកសញ្ញា សូន្យដោយថីនមិទ្ធ ការកំណត់នូវសេចក្តីមិនរាយមាយ សូន្យដោយឧទ្ធច្ចៈ ការកំណត់នូវសេចក្តីកំណត់នូវធម៌ សូន្យដោយវិចិកិច្ឆា ការកំណត់នូវញាណ សូន្យដោយអវិជ្ជា ការកំណត់នូវបាមុជ្ជៈ សូន្យដោយអរតិ ការកំណត់នូវបឋមជ្ឈាន សូន្យដោយពួកនីវរណៈ ។ បេ ។ ការកំណត់នូវអរហត្តមគ្គ សូន្យដោយកិលេសទាំងអស់ នេះ ការកំណត់សូន្យ ។

យុគនទ្ធវគ្គេ សុញ្ញកថា

[១២៣] កតមំ បដិលាភសុញ្ញំ ។ នេក្ខម្មបដិលាភោ កាមច្ឆន្ទេន សុញ្ញោ អព្យាបាទបដិលាភោ ព្យាបាទេន សុញ្ញោ អាលោកសញ្ញាបដិលាភោ ថីនមិទ្ធេន សុញ្ញោ អវិក្ខេបប្បដិលាភោ ឧទ្ធច្ចេន សុញ្ញោ ធម្មវវត្ថានប្បដិលាភោ វិចិកិច្ឆាយ សុញ្ញោ ញាណប្បដិលាភោ អវិជ្ជាយ សុញ្ញោ បាមុជ្ជប្បដិលាភោ អរតិយា សុញ្ញោ បឋមជ្ឈានប្បដិលាភោ នីវរណេហិ សុញ្ញោ ។ បេ ។ អរហត្តមគ្គប្បដិលាភោ សព្វក្កិលេសេហិ សុញ្ញោ ឥទំ បដិលាភសុញ្ញំ ។

[១២៤] កតមំ បដិវេធសុញ្ញំ ។ នេក្ខម្មបដិវេធោ កាមច្ឆន្ទេន សុញ្ញោ អព្យាបាទប្បដិវេធោ ព្យាបាទេន សុញ្ញោ អាលោកសញ្ញាបដិវេធោ ថីនមិទ្ធេន សុញ្ញោ អវិក្ខេបប្បដិវេធោ ឧទ្ធច្ចេន សុញ្ញោ ធម្មវវត្ថានប្បដិវេធោ វិចិកិច្ឆាយ សុញ្ញោ ញាណប្បដិវេធោ អវិជ្ជាយ សុញ្ញោ បាមុជ្ជប្បដិវេធោ អរតិយា សុញ្ញោ បឋមជ្ឈានប្បដិវេធោ នីវរណេហិ សុញ្ញោ ។ បេ ។ អរហត្តមគ្គប្បដិវេធោ សព្វក្កិលេសេហិ សុញ្ញោ ឥទំ បដិវេធសុញ្ញំ ។

យុគនទ្ធវគ្គ សុញ្ញកថា

[១២៣] ការបានចំពោះសូន្យ តើដូចម្ដេច ។ ការបានចំពោះនូវនេក្ខម្មៈ សូន្យដោយកាមច្ឆន្ទៈ ការបានចំពោះនូវអព្យាបាទ សូន្យដោយព្យាបាទ ការបានចំពោះនូវអាលោកសញ្ញា សូន្យដោយថីនមិទ្ធៈ ការបានចំពោះនូវសេចក្ដីមិនរាយមាយ សូន្យដោយឧទ្ធច្ចៈ ការបានចំ-ពោះនូវសេចក្ដីកំណត់នូវធម៌ សូន្យ ដោយវិចិកិច្ឆា ការបានចំពោះនូវញាណ សូន្យដោយអវិជ្ជា ការបានចំពោះនូវបាមុជ្ជៈ សូន្យដោយអរតិ ការបានចំពោះនូវបឋមជ្ឈាន សូន្យដោយពួកនីវរណៈ ។ បេ ។ ការបានចំពោះនូវអរហត្តមគ្គ សូន្យដោយកិលេសទាំងអស់ នេះ ការបានចំពោះសូន្យ ។

[១២៤] ការចាក់ធ្លុះសូន្យ តើដូចម្ដេច ។ ការចាក់ធ្លុះនូវនេក្ខម្មៈ សូន្យដោយកាមច្ឆន្ទៈ ការចាក់ធ្លុះនូវអព្យាបាទ សូន្យដោយព្យាបាទ ការចាក់ធ្លុះនូវអាលោកសញ្ញា សូន្យ ដោយថីនមិទ្ធៈ ការចាក់ធ្លុះនូវសេចក្ដីមិនរាយមាយ សូន្យដោយឧទ្ធច្ចៈ ការចាក់ធ្លុះនូវសេចក្ដីកំណត់នូវធម៌ សូន្យដោយវិចិកិច្ឆា ការចាក់ធ្លុះនូវញាណ សូន្យដោយអវិជ្ជា ការចាក់ធ្លុះនូវបាមុជ្ជៈ សូន្យដោយអរតិ ការចាក់ធ្លុះនូវបឋមជ្ឈាន សូន្យដោយនីវរណៈ ។ បេ ។ ការចាក់ធ្លុះនូវអរហត្តមគ្គ សូន្យដោយកិលេសទាំងអស់ នេះ ការចាក់ធ្លុះសូន្យ ។

[១២៥] កតមំ ឯកត្តសុញ្ញំ នានត្តសុញ្ញំ ។ កាមច្ឆន្ទោ នានត្តំ នេក្ខម្មំ ឯកត្តំ នេក្ខម្មេកត្តំ ចេតយតោ កាមច្ឆន្ទេន សុញ្ញំ ព្យាបាទោ នានត្តំ អព្យាបាទោ ឯកត្តំ អព្យាបាទេកត្តំ ចេតយតោ ព្យាបាទេន សុញ្ញំ ថីនមិទ្ធំ នានត្តំ អាលោកសញ្ញា ឯកត្តំ អាលោកសញ្ញេកត្តំ ចេតយតោ ថីនមិទ្ធេន សុញ្ញំ ឧទ្ធច្ចំ នានត្តំ វិចិកិច្ឆា នានត្តំ អវិជ្ជា នានត្តំ អរតិ នានត្តំ នីវរណា នានត្តំ[១] បឋមជ្ឈានំ ឯកត្តំ បឋមជ្ឈានេកត្តំ ចេតយតោ នីវរណេហិ សុញ្ញំ ។ បេ ។ សព្វក្កិលេសា នានត្តំ អរហត្តមគ្គោ ឯកត្តំ អរហត្តមគ្គេកត្តំ ចេតយតោ សព្វក្កិលេសេហិ សុញ្ញំ ឥទំ ឯកត្តសុញ្ញំ នានត្តសុញ្ញំ ។

[១២៦] កតមំ ខន្តិសុញ្ញំ ។ នេក្ខម្មខន្តិ កាមច្ឆន្ទេន សុញ្ញា អព្យាបាទខន្តិ ព្យាបាទេន សុញ្ញា អាលោកសញ្ញាខន្តិ ថីនមិទ្ធេន សុញ្ញា អវិក្ខេបខន្តិ ឧទ្ធច្ចេន សុញ្ញា ធម្មវវត្ថានខន្តិ វិចិកិច្ឆាយ សុញ្ញា

១ ម. ឧទ្ធច្ចំ នានត្តំ អវិក្ខេបោ ឯកត្តំ អវិក្ខេបេកត្តំ ចេតយតោ ឧទ្ធច្ចេន សុញ្ញំ វិចិកិច្ឆា នានត្តំ ធម្មវវត្ថានំ ឯកត្តំ ធម្មវវត្ថានេកត្តំ ចេតយតោ វិចិកិច្ឆាយ សុញ្ញំ អវិជ្ជា នានត្តំ ញាណំ ឯកត្តំ ញាណេកត្តំ ចេតយតោ អវិជ្ជាយ សុញ្ញំ អរតិ នានត្តំ បាមោជ្ជំ ឯកត្តំ បាមោជ្ជេកត្តំ ចេតយតោ អរតិយា សុញ្ញំ នីវរណា នានត្តន្តិ បទានុក្កមោ ។

[១២៥] ធម្មជាតដូចគ្នាសូន្យ ធម្មជាតផ្សេងគ្នាសូន្យ តើដូចម្តេច ។ កាមច្ឆន្ទៈ ជាសភាពផ្សេងគ្នា នេក្ខម្មៈ ជាសភាពដូចគ្នា នេក្ខម្មៈ ជាសភាពដូចគ្នា សូន្យដោយកាមច្ឆន្ទៈ របស់បុគ្គលកាលគិត ព្យាបាទ ជាសភាពផ្សេងគ្នា អព្យាបាទ ជាសភាពដូចគ្នា អព្យាបាទ ជាសភាពដូចគ្នា សូន្យដោយព្យាបាទ របស់បុគ្គលកាលគិត ថីនមិទ្ធ ជាសភាពផ្សេងគ្នា អាលោកសញ្ញា ជាសភាពដូចគ្នា អាលោកសញ្ញា ជាសភាពដូចគ្នា សូន្យដោយថីនមិទ្ធ របស់បុគ្គលកាលគិត ឧទ្ធច្ចៈ ជាសភាពផ្សេងគ្នា វិចិកិច្ឆា ជាសភាពផ្សេងគ្នា អវិជ្ជា ជាសភាពផ្សេងគ្នា អរតិ ជាសភាពផ្សេងគ្នា ពួកនីវរណៈ ជាសភាពផ្សេងគ្នា បឋមជ្ឈាន ជាសភាពដូចគ្នា បឋមជ្ឈាន ជាសភាពដូចគ្នា សូន្យដោយពួកនីវរណៈ របស់បុគ្គលកាលគិត ។ បេ ។ កិលេសទាំងអស់ ជាសភាពផ្សេងគ្នា អរហត្តមគ្គ ជាសភាពដូចគ្នា អរហត្តមគ្គ ជាសភាពដូចគ្នា សូន្យដោយកិលេសទាំងអស់ របស់បុគ្គលកាលគិត នេះ ធម្មជាតដូចគ្នាសូន្យ ធម្មជាតផ្សេងគ្នាសូន្យ ។

[១២៦] ខន្តិ សូន្យ តើដូចម្តេច ។ ខន្តិ ក្នុងនេក្ខម្មៈ សូន្យដោយកាមច្ឆន្ទៈ ខន្តិ ក្នុងអព្យាបាទ សូន្យដោយព្យាបាទ ខន្តិ ក្នុងអាលោកសញ្ញា សូន្យ ដោយថីនមិទ្ធ ខន្តិ ក្នុងការមិនរាយមាយ សូន្យដោយឧទ្ធច្ចៈ ខន្តិ ក្នុងការកំណត់នូវធម៌ សូន្យ ដោយវិចិកិច្ឆា

ញាណខន្តិ អវិជ្ជាយ សុញ្ញា ចាមុជ្ជខន្តិ អរតិយា សុញ្ញា បឋមជ្ឈានខន្តិ នីវរណេហិ សុញ្ញា ។ បេ ។ អរហត្តមគ្គខន្តិ សព្វកិលេសេហិ សុញ្ញា ឥទំ ខន្តិសុញ្ញំ ។

[១២៧] កតមំ អធិដ្ឋានសុញ្ញំ ។ នេក្ខម្មាធិដ្ឋានំ កាមច្ឆន្ទេន សុញ្ញំ អព្យាបាទាធិដ្ឋានំ ព្យាបាទេន សុញ្ញំ អាលោកសញ្ញាធិដ្ឋានំ ថីនមិទ្ធេន សុញ្ញំ អវិក្ខេបាធិដ្ឋានំ ឧទ្ធច្ចេន សុញ្ញំ ធម្មវវត្ថានាធិដ្ឋានំ វិចិកិច្ឆាយ សុញ្ញំ ញាណាធិដ្ឋានំ អវិជ្ជាយ សុញ្ញំ ចាមុជ្ជាធិដ្ឋានំ អរតិយា សុញ្ញំ បឋមជ្ឈានាធិដ្ឋានំ នីវរណេហិ សុញ្ញំ ។ បេ ។ អរហត្តមគ្គាធិដ្ឋានំ សព្វកិលេសេហិ សុញ្ញំ ឥទំ អធិដ្ឋានសុញ្ញំ ។

[១២៨] កតមំ បរិយោគាហនសុញ្ញំ ។ នេក្ខម្មបរិយោគាហនំ កាមច្ឆន្ទេន សុញ្ញំ អព្យាបាទបរិយោគាហនំ ព្យាបាទេន សុញ្ញំ អាលោកសញ្ញាបរិយោគាហនំ ថីនមិទ្ធេន សុញ្ញំ អវិក្ខេបបរិយោគាហនំ ឧទ្ធច្ចេន សុញ្ញំ ធម្មវវត្ថានបរិយោគាហនំ វិចិកិច្ឆាយ សុញ្ញំ

ខន្តិ ក្នុងញាណ សូន្យដោយអវិជ្ជា ខន្តិ ក្នុងបាមុជ្ជៈ សូន្យដោយអរតិ ខន្តិ ក្នុងបឋមជ្ឈាន សូន្យដោយនីវរណៈ ។ បេ ។ ខន្តិ ក្នុងអរហត្តមគ្គ សូន្យដោយកិលេសទាំងអស់ នេះ ខន្តិសូន្យ ។

[១២៧] អធិដ្ឋានសូន្យ តើដូចម្តេច ។ អធិដ្ឋាននូវនេក្ខម្មៈ សូន្យដោយកាមច្ឆន្ទៈ អធិដ្ឋាននូវអព្យាបាទ សូន្យដោយព្យាបាទ អធិដ្ឋាននូវអាលោកសញ្ញា សូន្យដោយថីនមិទ្ធ អធិដ្ឋាននូវការមិនរាយមាយ សូន្យដោយឧទ្ធច្ចៈ អធិដ្ឋាននូវការកំណត់នូវធម៌ សូន្យដោយវិចិកិច្ឆា អធិដ្ឋាននូវញាណ សូន្យដោយអវិជ្ជា អធិដ្ឋាននូវបាមុជ្ជៈ សូន្យដោយអរតិ អធិដ្ឋាននូវបឋមជ្ឈាន សូន្យដោយពួកនីវរណៈ ។ បេ ។ អធិដ្ឋាននូវអរហត្តមគ្គ សូន្យដោយកិលេសទាំងអស់ នេះ អធិដ្ឋានសូន្យ ។

[១២៨] ការឈានចុះស៊ប់សូន្យ តើដូចម្តេច ។ ការឈានចុះស៊ប់ក្នុងនេក្ខម្មៈ សូន្យដោយកាមច្ឆន្ទៈ ការឈានចុះស៊ប់ក្នុងអព្យាបាទ សូន្យដោយព្យាបាទ ការឈានចុះស៊ប់ ក្នុងអាលោកសញ្ញា សូន្យដោយថីនមិទ្ធ ការឈានចុះស៊ប់ក្នុងសេចក្តីមិនរាយមាយ សូន្យដោយឧទ្ធច្ចៈ ការឈានចុះស៊ប់ ក្នុងសេចក្តីកំណត់នូវធម៌ សូន្យ ដោយវិចិកិច្ឆា

ញាណបរិយោគាហនំ អវិជ្ជាយ សុញ្ញំ បាមុជ្ជបរិយោគាហនំ អរតិយា សុញ្ញំ បឋមជ្ឈានបរិយោគាហនំ នីវរណេហិ សុញ្ញំ ។ បេ ។ អរហត្តមគ្គបរិយោគាហនំ សព្វក្កិលេសេហិ សុញ្ញំ ឥទំ បរិយោគាហនសុញ្ញំ ។

[១២៩] កតមំ សម្បជានស្ស បវត្តបរិយាទានំ សព្វសុញ្ញតានំ បរមត្ថសុញ្ញំ ។ សម្បជានោ[១] នេក្ខម្មេន កាមច្ឆន្ទស្ស បវត្តំ បរិយាទិយតិ អព្យាបាទេន ព្យាបាទស្ស បវត្តំ បរិយាទិយតិ អាលោកសញ្ញាយ ថីនមិទ្ធស្ស បវត្តំ បរិយាទិយតិ អវិក្ខេបេន ឧទ្ធច្ចស្ស បវត្តំ បរិយាទិយតិ ធម្មវវត្ថានេន វិចិកិច្ឆាយ បវត្តំ បរិយាទិយតិ ញាណេន អវិជ្ជាយ បវត្តំ បរិយាទិយតិ បាមុជ្ជេន អរតិយា បវត្តំ បរិយាទិយតិ បឋមជ្ឈានេន នីវរណានំ បវត្តំ បរិយាទិយតិ ។ បេ ។ អរហត្តមគ្គេន សព្វក្កិលេសានំ បវត្តំ បរិយាទិយតិ អថ វា បន សម្បជានស្ស អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយន្តស្ស ឥទញ្ចេវ ចក្ខុប្បវត្តំ បរិយាទិយតិ

១ ឱ.ម. ឯត្ថន្តរេ ឥធាតិ អត្ថិ ។

ការឈានចុះស៊ប់ក្នុងញាណ សូន្យដោយអវិជ្ជា ការឈានចុះស៊ប់ក្នុងបាមុជ្ជៈ សូន្យដោយអរតិ ការឈានចុះស៊ប់ក្នុងបឋមជ្ឈាន សូន្យដោយនីវរណៈ ។ បេ ។ ការឈានចុះស៊ប់ ក្នុងអរហត្តមគ្គ សូន្យដោយកិលេសទាំងអស់ នេះ ការឈានចុះស៊ប់សូន្យ ។

[១២៩] ការបង្អស់នូវការប្រព្រឹត្ត របស់បុគ្គលអ្នកដឹងច្បាស់ ឈ្មោះថាសូន្យដ៏ក្រៃលែង ជាងធម្មជាតសូន្យទាំងអស់ តើដូចម្តេច ។ បុគ្គលអ្នកដឹងច្បាស់ រមែងបង្អស់នូវការប្រព្រឹត្ត នៃកាមច្ឆន្ទៈ ដោយនេក្ខម្មៈ បង្អស់នូវការប្រព្រឹត្ត នៃព្យាបាទ ដោយអព្យាបាទ បង្អស់នូវការប្រព្រឹត្តនៃថីនមិទ្ធៈ ដោយអាលោកសញ្ញា បង្អស់នូវការប្រព្រឹត្តនៃឧទ្ធច្ចៈ ដោយការមិនរាយមាយ បង្អស់នូវការប្រព្រឹត្ត នៃវិចិកិច្ឆា ដោយការកំណត់នូវធម៌ បង្អស់នូវការប្រព្រឹត្តនៃអវិជ្ជា ដោយញាណ បង្អស់នូវការប្រព្រឹត្តនៃអរតិ ដោយបាមុជ្ជៈ បង្អស់នូវការប្រព្រឹត្តនៃពួកនីវរណៈ ដោយបឋមជ្ឈាន ។ បេ ។ បង្អស់នូវការប្រព្រឹត្ត នៃកិលេសទាំងអស់ ដោយអរហត្តមគ្គ មួយវិញទៀត កាលបុគ្គលអ្នកដឹងច្បាស់ បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ការប្រព្រឹត្តនៃចក្ខុនេះឯង

អញ្ញញ្ច ចក្ខុប្បវត្តំ ន ឧប្បជ្ជតិ ឥទញ្ចេវ សោតប្បវត្តំ ។ បេ ។ ឃានប្បវត្តំ ជិវ្ហាបវត្តំ កាយប្បវត្តំ មនោបវត្តំ បរិយាទិយតិ អញ្ញញ្ច មនោបវត្តំ ន ឧប្បជ្ជតិ ឥទំ សម្បជានស្ស បវត្តបរិយាទានំ សព្វសុញ្ញតានំ បរមត្ថសុញ្ញន្តិ ។

សុញ្ញកថា ។

យុគនទ្ធវគ្គោ ទុតិយោ ។

## តស្ស វគ្គស្ស ឧទ្ទានំ ភវតិ

យុគនទ្ធា សច្ចពោជ្ឈង្គា
មេត្តា វិរាគបញ្ចមំ[១]
បដិសម្ភិទា ធម្មចក្កំ
លោកុត្តរពលា[២] សុញ្ញា តេ ទសាតិ ។
ឯស និកាយវរោ[៣] ឋបិតោ
អសមោ ទុតិយោ បវរោ[៤] វរមគ្គោតិ ។

១ ម. មេត្តា វិរាគបញ្ចមា ។ ២ ម. លោកុត្តរពលសុញ្ញតាតិ ។ ៣ ម. និកាយធរេហិ ។ ៤ ម. បវរេ ។

រមែងអស់ទៅ ទាំងការប្រព្រឹត្ត នៃចក្ខុដទៃ ក៏មិនកើតឡើង ការប្រព្រឹត្ត នៃសោតៈនេះឯង ។ បេ ។ ការប្រព្រឹត្ត នៃឃានៈ ការប្រព្រឹត្ត នៃជិវ្ហា ការប្រព្រឹត្ត នៃកាយ ការប្រព្រឹត្ត នៃមនោ នេះឯង រមែងអស់ទៅ ទាំងការប្រព្រឹត្ត នៃមនោដទៃ ក៏មិនកើតឡើង នេះ ការបង្អស់ នូវការប្រព្រឹត្ត របស់បុគ្គលអ្នកដឹងច្បាស់ ឈ្មោះថាសូន្យដ៏ក្រៃលែង ជាងធម្មជាតសូន្យទាំងអស់ ។

ចប់ សុញ្ញកថា ។

ចប់ យុគនទ្ធវគ្គ ទី ២ ។

## ឧទ្ទាន នៃវគ្គនោះ គឺ

យុគនទ្ធកថា ១ សច្ចកថា ១ ពោជ្ឈង្គកថា ១ មេត្តាកថា ១ វិរាគកថា ១ ជាគម្រប់ ៥ បដិសម្ភិទាកថា ១ ធម្មចក្កកថា ១ លោកុត្តរកថា ១ ពលកថា ១ សុញ្ញកថា ១ ត្រូវជា ១០ ។ វគ្គទីពីរនុ៎ះ ជាពួកដ៏ប្រសើរ ឥតមានពួកដទៃស្មើឡើយ ជាមគ្គដ៏ប្រសើរ ថ្ងៃថ្លា ដែលព្រះសង្គីតិកាចារ្យរចនាទុកហើយ ។

# បញ្ញាវគ្គេ មហាបញ្ញាកថា

[១៣០] អនិច្ចានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ ទុក្ខានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ អនត្តានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ និព្វិទានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ វិរាគានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ និរោធានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ បដិនិស្សគ្គានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ ។ អនិច្ចានុបស្សនា ភាវិតា ពហុលីកតា ជវនប្បញ្ញំ បរិបូរេតិ ទុក្ខានុបស្សនា ភាវិតា ពហុលីកតា និព្វេធិកប្បញ្ញំ បរិបូរេតិ អនត្តានុបស្សនា ភាវិតា ពហុលីកតា មហាបញ្ញំ បរិបូរេតិ និព្វិទានុបស្សនា ភាវិតា ពហុលីកតា តិក្ខប្បញ្ញំ បរិបូរេតិ វិរាគានុបស្សនា ភាវិតា ពហុលីកតា វិបុលប្បញ្ញំ បរិបូរេតិ និរោធានុបស្សនា ភាវិតា ពហុលីកតា

# បញ្ញាវគ្គ មហាបញ្ញាកថា

[១៣០] *អនិច្ចានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ទុក្ខានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច អនត្តានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច និព្វិទានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច វិរាគានុបស្សនាដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច និរោធានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច បដិនិស្សគ្គានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ។*

*អនិច្ចានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនបញ្ញា ទុក្ខានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវនិព្វេធិកបញ្ញា អនត្តានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវមហាបញ្ញា និព្វិទានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវតិក្ខបញ្ញា វិរាគានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវវិបុលបញ្ញា និរោធានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ*

២២១



គម្ភីរប្បញ្ញំ បរិបូរេតិ បដិនិស្សគ្គានុបស្សនា ភាវិតា ពហុលីកតា អស្សាមន្តប្បញ្ញំ បរិបូរេតិ ។ ឥមា សត្ត បញ្ញា ភាវិតា ពហុលីកតា បណ្ឌិច្ចំ បរិបូរេន្តិ ឥមា អដ្ឋ បញ្ញា ភាវិតា ពហុលីកតា បុថុប្បញ្ញំ បរិបូរេន្តិ ឥមា នវ បញ្ញា ភាវិតា ពហុលីកតា ហាសប្បញ្ញំ បរិបូរេន្តិ ។ ហាសប្បញ្ញា បដិភាណប្បដិសម្ភិទា[១] តស្សា អត្ថវវត្ថានតោ អត្ថប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ ធម្មវវត្ថានតោ ធម្មប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ និរុត្តិវវត្ថានតោ និរុត្តិប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ បដិភាណវវត្ថានតោ បដិភាណប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ តស្សិមា ចតស្សោ បដិសម្ភិទាយោ អធិគតា ហោន្តិ សច្ឆិកតា ផស្សិតា បញ្ញាយ ។

---

១ បដិសម្ភិទាតិ ភវិស្សតិ មញ្ញេ ។

តែងបំពេញនូវគម្ភីរប្បញ្ញា បដិនិស្សគ្គានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវអស្សាមន្តប្បញ្ញា ។ បញ្ញាទាំង ៧ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវភាពជាបណ្ឌិត បញ្ញាទាំង ៨ នេះដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបុថុប្បញ្ញា បញ្ញាទាំង ៩ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវហាសប្បញ្ញា ។ ហាសប្បញ្ញា ជាតួបដិភាណប្បដិសម្ភិទា[១] (ព្រោះថា) ហាសប្បញ្ញានោះ តែងមានអត្ថប្បដិសម្ភិទា ព្រោះការកំណត់នូវអត្ថ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា តែងមានធម្មប្បដិសម្ភិទា ព្រោះការកំណត់នូវធម៌ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា តែងមាននិរុត្តិប្បដិសម្ភិទា ព្រោះការកំណត់នូវនិរុត្តិ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា តែងមានបដិភាណប្បដិសម្ភិទា ព្រោះការកំណត់នូវបដិភាណ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា នេះឯងហាសប្បញ្ញានោះ ដែលតែងមានបដិសម្ភិទាទាំង ៤ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា។

១ តាមមតិយើងថា "ជាតួបដិសម្ភិទា" ។

[១៣១] រូបេ អនិច្ចានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ ។ បេ ។ រូបេ បដិនិស្សគ្គានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ ។ រូបេ អនិច្ចានុបស្សនា ភាវិតា ពហុលីកតា ជវនបញ្ញំ បរិបូរេតិ ។ បេ ។ រូបេ បដិនិស្សគ្គានុបស្សនា ភាវិតា ពហុលីកតា អស្សាមន្តបញ្ញំ បរិបូរេតិ ។ ឥមា សត្ត បញ្ញា ភាវិតា ពហុលីកតា បណ្ឌិច្ចំ បរិបូរេន្តិ ឥមា អដ្ឋ បញ្ញា ភាវិតា ពហុលីកតា បុថុបញ្ញំ បរិបូរេន្តិ ឥមា នវ បញ្ញា ភាវិតា ពហុលីកតា ហាសបញ្ញា បរិបូរេន្តិ ។ ហាសបញ្ញា បដិភាណបដិសម្ភិទា[១] តស្សា អត្ថវវត្ថានតោ អត្ថបដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ ធម្មវវត្ថានតោ ធម្មបដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ និរុត្តិវវត្ថានតោ និរុត្តិបដិ-

១ បដិសម្ភិទាតិ ភវិស្សតិ មញ្ញេ ។

[១៣១] ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការមិនទៀងក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ។ បេ ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការលះក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការមិនទៀងក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនប្បញ្ញា ។ បេ ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការលះក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវអេស្សាមន្តប្បញ្ញា ។ ប្រាជ្ញាទាំង ៧ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវភាពជាបណ្ឌិត ប្រាជ្ញាទាំង ៨ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបុថុប្បញ្ញា ប្រាជ្ញាទាំង ៩ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវហាសប្បញ្ញា ។ ហាសប្បញ្ញា ជាតួបដិភាណប្បដិសម្ភិទា (ព្រោះថា) ហាសប្បញ្ញានោះ តែងមានអត្ថប្បដិសម្ភិទា ព្រោះការកំណត់នូវអត្ថ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា តែងមានធម្មប្បដិសម្ភិទា ព្រោះការកំណត់នូវធម៌ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា តែងមាននិរុត្តិប្បដិសម្ភិទា ព្រោះការកំណត់នូវនិរុត្តិ

សម្ភិតា អធិកតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ បដិភាណាវវត្ថានតោ បដិភាណប្បដិសម្ភិតា អធិកតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ តស្សិមា ចតស្សោ បដិសម្ភិតាយោ អធិកតា ហោន្តិ សច្ឆិកតា ផស្សិតា បញ្ញាយ ។ វេទនាយ សញ្ញាយ សង្ខារេសុ វិញ្ញាណេ ចក្ខុស្មឹ ។ បេ ។ ជរាមរណេ អនិច្ចានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ ។ បេ ។ ជរា-មរណេ បដិនិស្សគ្គានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ ។ ជរាមរណេ អនិច្ចានុបស្ស-នា ភាវិតា ពហុលីកតា ជវនបញ្ញំ បរិបូរេតិ ។ បេ ។ ជរាមរណេ បដិនិស្សគ្គានុបស្សនា ភាវិតា ពហុលីក-តា អស្សាមន្តប្បញ្ញំ បរិបូរេតិ ។ ឥមា សត្ត បញ្ញា ភាវិតា ពហុលីកតា បណ្ឌិច្ចំ បរិបូរេន្តិ ឥមា អដ្ឋ បញ្ញា ភាវិតា ពហុលីកតា បុថុប្បញ្ញំ បរិបូរេន្តិ

ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា តែងមានបដិភាណប្បដិសម្ភិទា ព្រោះការកំណត់នូវបដិភាណ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញានេះឯង ហាសបញ្ញានោះ ដែលតែងមានបដិសម្ភិទា ទាំង ៤ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា ។ ប្រាជ្ញា ជាគ្រឿងពិចារណាឃើញនូវការមិនទៀង ក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។ បេ ។ ក្នុងជរាមរណៈ ជាធម្មជាតដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ។ បេ ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការលះបង់ជរាមរណៈ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការមិនទៀង ក្នុងជរាមរណៈ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនប្បញ្ញា ។ បេ ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការលះក្នុងជរាមរណៈ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវអស្សាមន្តប្បញ្ញា ។ ប្រាជ្ញាទាំង ៧ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវភាពជាបណ្ឌិត ប្រាជ្ញាទាំង ៨ នេះ ដែលបុគ្គលបានអប់រំ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបុថុប្បញ្ញា

ឥមា ៨វ បញ្ញា ភាវិតា ពហុលីកតា ហាសបញ្ញំ បរិបូ-
រេន្តិ ។ ហាសបញ្ញា បដិភាណប្បដិសម្ភិទា តស្មា អត្ថ-
វវត្ថានតោ អត្ថប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិក-
តា ផស្សិតា បញ្ញាយ ធម្មវវត្ថានតោ ធម្មប្បដិសម្ភិទា
អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ និរុត្តិ-
វវត្ថានតោ និរុត្តិប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិ-
កតា ផស្សិតា បញ្ញាយ បដិភាណវវត្ថានតោ បដិ-
ភាណប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផ-
ស្សិតា បញ្ញាយ តស្សិមា ចតស្សោ បដិសម្ភិទាយោ
អធិគតា ហោន្តិ សច្ឆិកតា ផស្សិតា បញ្ញាយ ។

[១៣២] រូបេ អនិច្ចានុបស្សនា ភាវិតា ពហុលីកតា
កតមំ បញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ រូបេ អនិ-
ច្ចានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ

ប្រាជ្ញាទាំង ៩ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវហាសប្បញ្ញា ។ ហាសប្បញ្ញា ជាតួបដិភាណប្បដិសម្ភិទា (ព្រោះថា) ហាសប្បញ្ញានោះ តែងមានអត្ថប្បដិសម្ភិទា ព្រោះការកំណត់នូវអត្ថ ជាធម្មជាតិដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា តែងមានធម្មប្បដិសម្ភិទា ព្រោះការកំណត់នូវធម៌ ជាធម្មជាតិដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា តែងមាននិរុត្តិប្បដិសម្ភិទា ព្រោះការកំណត់នូវនិរុត្តិ ជាធម្មជាតិដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា តែងមានបដិភាណប្បដិសម្ភិទា ព្រោះការកំណត់នូវបដិភាណ ជាធម្មជាតិដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា នេះឯងហាសប្បញ្ញានោះ ដែលតែងមានបដិសម្ភិទា ទាំង ៤ ជាធម្មជាតិដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា ។

[១៣២] ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាមិនទៀងក្នុងរូប ដែលបុគ្គលអប់រំហើយធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាមិនទៀងក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច

២២៥



រូបេ ទុក្ខានុបស្សនា ភាវិតា ពហុលីកតា កាតមំ បញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ រូបេ ទុក្ខា-នុបស្សនា ភាវិតា ពហុលីកតា កាតមំ បញ្ញំ បរិបូរេតិ រូបេ អនត្តានុបស្សនា ភាវិតា ពហុលីក-តា កាតមំ បញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ រូបេ អនត្តានុបស្សនា ភាវិតា ពហុលីកតា កា-តមំ បញ្ញំ បរិបូរេតិ រូបេ និព្វិទានុបស្សនា ភាវិតា ពហុលីកតា កាតមំ បញ្ញំ បរិបូរេតិ អតីតានា-គតប្បច្ចុប្បន្នេ រូបេ និព្វិទានុបស្សនា ភាវិតា ពហុ-លីកតា កាតមំ បញ្ញំ បរិបូរេតិ រូបេ វិរាគានុប-ស្សនា ភាវិតា ពហុលីកតា កាតមំ បញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ រូបេ វិរាគានុបស្សនា ភាវិតា ពហុលីកតា កាតមំ បញ្ញំ បរិបូរេតិ រូបេ និរោធានុ-បស្សនា ភាវិតា ពហុលីកតា កាតមំ បញ្ញំ បរិបូរេតិ

ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាជាទុក្ខក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារ-ណាឃើញ ថាជាទុក្ខក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាមិនមែនខ្លួនក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាមិនមែនខ្លួនក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវសេចក្ដីនឿយណាយក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវសេចក្ដីនឿយណាយក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការប្រាសចាកតម្រេក ក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការប្រាសចាកតម្រេកក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវសេចក្ដីរលត់ក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច

អតីតានាគតប្បច្ចុប្បន្នេ រូបេ និព្វេទានុបស្សនា ភាវិតា ពហុលីកតា គតមំ បញ្ញំ បរិបូរេតិ រូបេ បដិនិស្សគ្គានុបស្សនា ភាវិតា ពហុលីកតា គតមំ បញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ រូបេ បដិនិស្សគ្គានុបស្សនា ភាវិតា ពហុលីកតា គតមំ បញ្ញំ បរិបូរេតិ ។ រូបេ អនិច្ចានុបស្សនា ភាវិតា ពហុលីកតា ជវនប្បញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ រូបេ អនិច្ចានុបស្សនា ភាវិតា ពហុលីកតា ជវនប្បញ្ញំ បរិបូរេតិ រូបេ ទុក្ខានុបស្សនា ភាវិតា ពហុលីកតា និព្វេធិកប្បញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ រូបេ ទុក្ខានុបស្សនា ភាវិតា ពហុលីកតា ជវនប្បញ្ញំ បរិបូរេតិ រូបេ អនត្តានុបស្សនា ភាវិតា ពហុលីកតា មហាបញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ រូបេ អនត្តានុបស្សនា ភាវិតា ពហុលីកតា ជវនប្បញ្ញំ បរិបូរេតិ

ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការរលត់ក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការលះក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការលះក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាមិនទៀងក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនប្បញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាមិនទៀងក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនប្បញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាជាទុក្ខក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវនិព្វេធិកប្បញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាជាទុក្ខក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនប្បញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាមិនមែនខ្លួនក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវមហាបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាមិនមែនខ្លួនក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវ

## ២២៧



រូបេ និព្ពិទានុបស្សនា ភាវិតា ពហុលីកតា តិក្ខប្បញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ រូបេ និព្ពិទានុបស្សនា ភាវិតា ពហុលីកតា ជវនប្បញ្ញំ បរិបូរេតិ រូបេ វិរាគានុបស្សនា ភាវិតា ពហុលីកតា វិបុលប្បញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ រូបេ វិរាគានុបស្សនា ភាវិតា ពហុលីកតា ជវនប្បញ្ញំ បរិបូរេតិ រូបេ និរោធានុបស្សនា ភាវិតា ពហុលីកតា គម្ភីរប្បញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ រូបេ និរោធានុបស្សនា ភាវិតា ពហុលីកតា ជវនប្បញ្ញំ បរិបូរេតិ រូបេ បដិនិស្សគ្គានុបស្សនា ភាវិតា ពហុលីកតា អសាមន្តប្បញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ រូបេ បដិនិស្សគ្គានុបស្សនា ភាវិតា ពហុលីកតា ជវនប្បញ្ញំ បរិបូរេតិ ។ ឥមា សត្ត បញ្ញា ភាវិតា ពហុលីកតា បណ្ឌិច្ចំ បរិបូរេន្តិ ឥមា អដ្ឋ បញ្ញា ភាវិតា ពហុលីកតា បុថុប្បញ្ញំ បរិបូរេន្តិ ឥមា នវ បញ្ញា

ជវនបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការនឿយណាយក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវតិក្ខបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវសេចក្តីនឿយណាយក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការប្រាសចាកតម្រេក ក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវវិបុលបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការប្រាសចាកតម្រេកក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវសេចក្តីរលត់ក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវគម្ភីរបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវសេចក្តីរលត់ក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការលះក្នុងរូប ដែលបុគ្គលអប់រំហើយធ្វើឲ្យច្រើនហើយ តែងបំពេញនូវអស្សាមន្តបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការលះក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនបញ្ញា ។ ប្រាជ្ញាទាំង ៧ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវភាពជាបណ្ឌិត ប្រាជ្ញាទាំង ៨ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបុថុបញ្ញា ប្រាជ្ញាទាំង ៩ នេះ

ភាវិតា ពហុលីកតា ហាសប្បញ្ញំ បរិបូរេន្តិ ។ ហាសប្បញ្ញា បដិភាណប្បដិសម្ភិទា តស្សា អត្ថវវត្ថានតោ អត្ថប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ ធម្មវវត្ថានតោ ធម្មប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ និរុត្តិវវត្ថានតោ និរុត្តិប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ បដិភាណវវត្ថានតោ បដិភាណប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ តស្សិមា ចតស្សោ បដិសម្ភិទាយោ អធិគតា ហោន្តិ សច្ឆិកតា ផស្សិតា បញ្ញាយ ។ វេទនាយ សញ្ញាយ សង្ខារេសុ វិញ្ញាណេ ចក្ខុស្មឹ ។ បេ ។ ជរាមរណេ អនិច្ចានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ ជរាមរណេ អនិច្ចានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ ។ បេ ។

ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវហាសបញ្ញា ។ ហាសបញ្ញា ជាតួបដិភាណប្បដិសម្ភិទា(ព្រោះថា)ហាសបញ្ញានោះ តែងមានអត្ថប្បដិសម្ភិទា ព្រោះការកំណត់នូវអត្ថ ជាធម្មជាតិដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា តែងមានធម្មប្បដិសម្ភិទា ព្រោះការកំណត់នូវធម៌ ជាធម្មជាតិដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា តែងមាននិរុត្តិប្បដិសម្ភិទា ព្រោះការកំណត់នូវនិរុត្តិ ជាធម្មជាតិដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា តែងមានបដិភាណប្បដិសម្ភិទា ព្រោះការកំណត់នូវបដិភាណ ជាធម្មជាតិដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា នេះឯងហាសបញ្ញានោះ ដែលតែងមានបដិសម្ភិទាទាំង ៤ ជាធម្មជាតិដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាមិនទៀង ក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ ក្នុងជរាមរណៈ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាមិនទៀង ក្នុងជរាមរណៈ ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គល អប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញ នូវបញ្ញាដូចម្តេច ។ បេ ។

ជរាមរណេ បដិនិស្សគ្គានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ អតីតានាគតប្បច្ចុប្បន្នេ ជរាមរណេ បដិនិស្សគ្គានុបស្សនា ភាវិតា ពហុលីកតា កតមំ បញ្ញំ បរិបូរេតិ ។ ជរាមរណេ អធិដ្ឋានុបស្សនា ភាវិតា ពហុលីកតា ជវនប្បញ្ញំ បរិបូរេតិ អតីតានាគតបច្ចុប្បន្នេ ជរាមរណេ អធិដ្ឋានុបស្សនា ភាវិតា ពហុលីកតា ជវនប្បញ្ញំ បរិបូរេតិ ។ បេ ។ តស្សិមា ចតស្សោ បដិសម្ភិទាយោ អធិគតា ហោន្តិ សច្ឆិកតា ផស្សិតា បញ្ញាយ ។

[១៣៣] ចត្តារោមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា សោតាបត្តិផលសច្ឆិកិរិយាយ សំវត្តន្តិ កតមេ ចត្តារោ សប្បុរិសសំសេវោ សទ្ធម្មស្សវនំ យោនិសោមនសិការោ ធម្មានុធម្មប្បដិបត្តិ ឥមេ ខោ ភិក្ខវេ ចត្តារោ ធម្មា ភាវិតា ពហុលីកតា សោតាបត្តិផលសច្ឆិកិរិយាយ សំវត្តន្តិ ។

ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការលះក្នុងជរាមរណៈ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញ នូវការលះក្នុងជរាមរណៈ ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាមិនទៀង ក្នុងជរាមរណៈ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាមិនទៀងក្នុងជរាមរណៈ ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនបញ្ញា ។ បេ ។ នេះឯង ហាសបញ្ញានោះ ដែលតែងមានបដិសម្ភិទាទាំង ៤ ជាធម្មជាតិដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា ។

[១៣៣] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ធម៌ទាំង ៤ តើដូចម្តេចខ្លះ គឺការគប់រកសប្បុរស ១ ការស្តាប់ព្រះសទ្ធម្ម ១ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ១ ការប្រតិបត្តិនូវធម៌ដ៏សមគួរតាមធម៌ ១ ម្នាលភិក្ខុទាំងឡាយ នេះឯងធម៌ទាំង ៤ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ។

ចត្តារោមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា សកទាគាមិផលសច្ឆិកិរិយាយ សំវត្តន្តិ ។ បេ ។ អនាគាមិផលសច្ឆិកិរិយាយ សំវត្តន្តិ ។ បេ ។ អរហត្តផលសច្ឆិកិរិយាយ សំវត្តន្តិ កតមេ ចត្តារោ សប្បុរិសសំសេវោ សទ្ធម្មស្សវនំ យោនិសោមនសិ-ការោ ធម្មានុធម្មប្បដិបត្តិ ឥមេ ខោ ភិក្ខវេ ចត្តារោ ធម្មា ភាវិតា ពហុលីកតា អរហត្តផលសច្ឆិកិរិយាយ សំវត្តន្តិ ។

[១៣៤] ចត្តារោមេ ភិក្ខវេ ធម្មា ភាវិតា ពហុលី-កតា បញ្ញាបដិលាភាយ សំវត្តន្តិ បញ្ញាវុឌ្ឍិយា សំវត្តន្តិ បញ្ញាវេបុល្លាយ សំវត្តន្តិ មហាបញ្ញតាយ សំវត្តន្តិ បុថុប្បញ្ញតាយ សំវត្តន្តិ វិបុលប្បញ្ញតាយ សំវត្តន្តិ គម្ភីរប្បញ្ញតាយ សំវត្តន្តិ អស្សាមន្តប្បញ្ញតាយ សំវត្តន្តិ ភូរិប្បញ្ញតាយ សំវត្តន្តិ បញ្ញាពាហុល្លាយ

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ ប្រការនេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល ។ បេ ។

តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ។ បេ ។ តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តផល ធម៌ទាំង ៤ តើដូចម្តេចខ្លះ គឺការគប់រកសប្បុរស ១ ការស្តាប់ព្រះសទ្ធម្ម ១ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ១ ការប្រតិបត្តិនូវធម៌ដ៏សមគួរតាមធម៌ ១ ម្នាលភិក្ខុទាំងឡាយ នេះឯង ធម៌ ៤ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តផល ។

[១៣៤] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីបាននូវប្រាជ្ញា ប្រ-ព្រឹត្តទៅដើម្បីលូតលាស់ប្រាជ្ញា ប្រព្រឹត្តទៅដើម្បីភាពធំទូលាយនៃប្រាជ្ញា ប្រព្រឹត្តទៅដើម្បីភាព នៃប្រាជ្ញាជាធំ ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាដ៏ក្រាស់ ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាដ៏ទូលាយ ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាដ៏ជ្រាលជ្រៅ ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាមិនជិត ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាដូចផែនដី ប្រព្រឹត្តទៅ ដើម្បីភាពនៃប្រាជ្ញាដ៏ច្រើន

សំវត្តន្តិ សីឃប្បញ្ញតាយ សំវត្តន្តិ លហុប្បញ្ញតាយ សំវត្តន្តិ ហាសប្បញ្ញតាយ សំវត្តន្តិ ជវនប្បញ្ញតាយ សំវត្តន្តិ តិក្ខប្បញ្ញតាយ សំវត្តន្តិ និព្វេធិកប្បញ្ញតាយ សំវត្តន្តិ កតមេ ចត្តារោ សប្បុរិសសំសេវោ សទ្ធម្មស្សវនំ យោនិសោមនសិការោ ធម្មានុធម្មប្បដិបត្តិ ឥមេ ខោ ភិក្ខវេ ចត្តារោ ធម្មា ភាវិតា ពហុលីកតា បញ្ញាបដិលាភាយ សំវត្តន្តិ បញ្ញាពុឌ្ឍិយា[១] សំវត្តន្តិ ។ បេ ។ និព្វេធិកប្បញ្ញតាយ សំវត្តន្តិ ។

[១៣៤] បញ្ញាបដិលាភាយ សំវត្តន្តីតិ កតមោ បញ្ញាបដិលាភោ ។ ចតុន្នំ មគ្គញ្ញាណានំ ចតុន្នំ ផលញ្ញាណានំ ចតុន្នំ បដិសម្ភិទាញាណានំ ឆន្នំ អភិញ្ញានំ[២] តេសត្តតីនំ ញាណានំ សត្តសត្តតីនំ ញាណានំ លាភោ បដិលាភោ បត្តិ សម្បត្តិ ផស្សនា សច្ឆិកិរិយា ឧបសម្បទា បញ្ញាបដិលាភាយ សំវត្តន្តីតិ អយំ បញ្ញាបដិលាភោ ។

---

១ ឱ. ម. បញ្ញាពុទ្ធិយា ។ ២ ឱ. ម. អភិញ្ញាញាណានំ ។

ប្រព្រឹត្តទៅ ដើម្បីភាពនៃ ប្រាជ្ញាដ៏ធាប់ ប្រព្រឹត្តទៅ ដើម្បីភាពនៃប្រាជ្ញាដ៏រហ័ស ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញានាំឲ្យរីករាយ ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាជាគ្រឿងស្ទុះស្ទា ប្រព្រឹត្តទៅ ដើម្បីភាពនៃប្រាជ្ញាដ៏មុត ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញា ជាគ្រឿងទម្លុះទម្លាយ នូវកិលេស ធម៌ទាំង ៤ តើដូចម្តេចខ្លះ គឺ ការសេពគប់សប្បុរស ១ ការស្តាប់ព្រះសទ្ធម្ម ១ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ១ ការប្រតិបត្តិនូវធម៌ដ៏សមគួរតាមធម៌ ១ ម្នាលភិក្ខុទាំងឡាយ នេះឯង ធម៌ ៤ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីបាននូវប្រាជ្ញា ប្រព្រឹត្តទៅដើម្បីលូតលាស់ប្រាជ្ញា ។ បេ ។ ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញា ជាគ្រឿងទម្លុះទម្លាយនូវកិលេស ។

[១៣៥] សំណួរត្រង់ពាក្យថា ប្រព្រឹត្តទៅដើម្បីបាន នូវប្រាជ្ញា តើការបាននូវប្រាជ្ញា ដូចម្តេច ។ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការចូលទៅជិតព្រម នូវមគ្គញ្ញាណ ៤ ផលញ្ញាណ ៤ បដិសម្ភិទាញាណ ៤ អភិញ្ញា ៦ ញាណ ៧៣ ញាណ ៧៧ នេះឯង ការបាននូវប្រាជ្ញា ក្នុងពាក្យថា ប្រព្រឹត្តទៅ ដើម្បីបាននូវប្រាជ្ញា ។

បញ្ញាពុឌ្ឍិយា សំវត្តន្តីតិ កតមា បញ្ញាពុឌ្ឍិ ។ សត្តន្នញ្ច សេក្ខានំ បុថុជ្ជនកល្យាណកស្ស ច បញ្ញា វឌ្ឍតិ អរហតោ បញ្ញា វឌ្ឍតិ វឌ្ឍនា[១] បញ្ញាពុឌ្ឍិយា សំវត្តន្តីតិ អយំ បញ្ញាពុឌ្ឍិ ។

បញ្ញាវេបុល្លាយ សំវត្តន្តីតិ កតមំ បញ្ញាវេបុល្លំ ។ សត្តន្នញ្ច សេក្ខានំ បុថុជ្ជនកល្យាណកស្ស ច បញ្ញា វេបុល្លំ គច្ឆតិ អរហតោ បញ្ញា វេបុល្លតា[២] បញ្ញាវេបុល្លាយ សំវត្តន្តីតិ ឥទំ បញ្ញាវេបុល្លំ ។

[១៣៦] មហាបញ្ញតាយ សំវត្តន្តីតិ កតមា មហាបញ្ញា ។ មហន្តេ អត្ថេ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តេ ធម្មេ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តា និរុត្តិយោ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តានិ បដិភាណានិ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តេ សីលក្ខន្ធេ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តេ សមាធិក្ខន្ធេ បរិគ្គណ្ហាតីតិ មហាបញ្ញា

---

១ ម. វឌ្ឍិតវឌ្ឍនា ។ ២ វេបុល្លន្តិ យុត្តតរមេវ ។

ពាក្យថា ប្រព្រឹត្តទៅដើម្បីលូតលាស់ប្រាជ្ញា តើការលូតលាស់ប្រាជ្ញា ដូចម្តេច ។ ប្រាជ្ញារបស់សេក្ខបុគ្គល ៧ ពួក និងរបស់កល្យាណបុថុជ្ជន រមែងលូតលាស់ ប្រាជ្ញារបស់ព្រះអរហន្ត រមែងលូតលាស់ នេះឯងការលូតលាស់ប្រាជ្ញា ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីសេចក្តីលូតលាស់ប្រាជ្ញា។

ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពធំទូលាយនៃប្រាជ្ញា តើភាពធំទូ-លាយនៃប្រាជ្ញា ដូចម្តេច ។ ប្រាជ្ញារបស់សេក្ខបុគ្គល ៧ ពួក និងរបស់កល្យាណបុថុជ្ជន រមែងដល់នូវភាពធំទូលាយ ប្រាជ្ញារបស់ព្រះអរហន្ត ក៏ដល់នូវភាពធំទូលាយ នេះឯងភាពធំទូលាយនៃប្រាជ្ញា ក្នុងពាក្យថា ប្រព្រឹត្តទៅ ដើម្បីភាពធំទូលាយនៃប្រាជ្ញា ។

[១៣៦] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាជាធំ តើប្រាជ្ញាជាធំ ដូចម្តេច ។ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវអត្ថជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវធម៌ជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវនិរុត្តិជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវបដិភាណជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសីល-ក្ខន្ធជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសមាធិក្ខន្ធជាធំ

មហន្តេ វិមុត្តិក្ខន្ធេ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តេ វិមុត្តិញាណទស្សនក្ខន្ធេ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តានិ ឋានាឋានានិ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តា វិហារសមាបត្តិយោ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តានិ អរិយសច្ចានិ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តេ សតិប្បដ្ឋានេ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តេ សម្មប្បធានេ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តេ ឥទ្ធិបាទេ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តានិ ឥន្ទ្រិយានិ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តានិ ពលានិ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តេ ពោជ្ឈង្គេ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តំ អរិយមគ្គំ[១] បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តានិ សាមញ្ញផលានិ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តា អភិញ្ញាយោ បរិគ្គណ្ហាតីតិ មហាបញ្ញា មហន្តំ បរមត្ថំ និព្វានំ បរិគ្គណ្ហាតីតិ មហាបញ្ញា មហាបញ្ញតាយ សំវត្តន្តីតិ អយំ មហាបញ្ញា ។

១ ម. មហន្តេ អរិយមគ្គេ ។

ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវបញ្ញាខន្ធជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវវិមុត្តិក្ខន្ធជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវវិមុត្តិញ្ញាណទស្សនក្ខន្ធជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវឋានាឋានៈជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវវិហារសមាបត្តិជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវអរិយសច្ចជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសតិប្បដ្ឋានជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសម្មប្បធានជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវឥទ្ធិបាទជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវឥន្ទ្រិយជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវពលៈជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវពោជ្ឈង្គជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវអរិយមគ្គជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យក នូវសាមញ្ញផលជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យក នូវអភិញ្ញាជាធំ ឈ្មោះថាប្រាជ្ញាជាធំ ព្រោះកំណត់យកនូវព្រះនិព្វាន ដែលមានអត្ថដ៏ឧត្តមជាធំ នេះឯងប្រាជ្ញាជាធំ ក្នុងពាក្យថា ប្រព្រឹត្តទៅ ដើម្បីភាពនៃប្រាជ្ញាជាធំ ។

[១៣៧] បុថុប្បញ្ញតាយ សំវត្តន្តីតិ កតមា បុថុប្បញ្ញា ។ បុថុនានាខន្ធេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាធាតូសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាអាយតនេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាបដិច្ចសមុប្បាទេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាសុញ្ញតមនុលព្ភេសុ[១] ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាអត្ថេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាធម្មេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានានិរុត្តីសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាបដិភាណេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាសីលក្ខន្ធេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាសមាធិក្ខន្ធេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាបញ្ញាខន្ធេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាវិមុត្តិក្ខន្ធេសុ ញាណំ បវត្តតីតិ

---
១ ឱ. ម. បុថុនានាសុញ្ញតមនុបលព្ភេសុ ។

[១៣៧] ពាក្យថា ប្រព្រឹត្តទៅ ដើម្បីភាពនៃបញ្ញាដ៏ក្រាស់ តើបញ្ញាដ៏ក្រាស់ ដូចម្ដេច ។ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងខន្ធផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងធាតុផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងអាយតនៈ ផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងបដិច្ចសមុប្បាទ ផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងធម៌ដ៏សូន្យ និងធម៌ដែលបណ្ឌិតគប្បីបាន ផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងអត្ថ ផ្សេង ៗ ក៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងធម៌ផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងនិរុត្តិ ផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងបដិភាណផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងសីលក្ខន្ធផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងសមាធិក្ខន្ធ ផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងបញ្ញាខន្ធផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងវិមុត្តិក្ខន្ធផ្សេង ៗ ដ៏ក្រាស់

បុថុប្បញ្ញា បុថុនានាវិមុត្តិញាណទស្សនក្ខន្ធេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាឋានាឋានេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាវិហារសមាបត្តីសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាអរិយសច្ចេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាសតិប្បដ្ឋានេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាសម្មប្បធា-នេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានាឥទ្ធិ-បាទេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានា-ឥន្ទ្រិយេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនា-នាពលេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានា-ពោជ្ឈង្គេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានា-អរិយមគ្គេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនានា-សាមញ្ញផលេសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុនា-នាអភិញ្ញាសុ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុ-ជ្ជនសាធារណេ ធម្មេ សមតិក្កម្ម[១] បរមត្ថេ និព្វា-នេ ញាណំ បវត្តតីតិ បុថុប្បញ្ញា បុថុប្បញ្ញតាយ សំវត្តន្តីតិ អយំ បុថុប្បញ្ញា ។

១ ម. អតិក្កម្ម ។

ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងវិមុត្តិញ្ញាណទស្សនក្ខន្ធផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងហេតុនិងមិនមែនហេតុ ផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងវិហារសមាបត្តិផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងអរិយសច្ចផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងសតិប្បដ្ឋានផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងសម្មប្បធានផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងឥទ្ធិបាទផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងឥន្ទ្រិយផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងពលៈ ផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងពោជ្ឈង្គផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងអរិយមគ្គផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងសាមញ្ញផលផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងអភិញ្ញាផ្សេង ៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងប្រយោជន៍ដ៏ក្រៃលែង គឺព្រះនិព្វាន កន្លងនូវធម៌ដែលទូទៅដល់បុថុជ្ជន នេះឯងបញ្ញាដ៏ក្រាស់ ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏ក្រាស់ ។

[១៣៨] វិបុលប្បញ្ញតាយ សំវត្តន្តីតិ កាតមា វិបុលប្បញ្ញា ។ វិបុលេ អត្ថេ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលេ ធម្មេ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលា និរុត្តិយោ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលានិ បដិភាណានិ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលេ សីលក្ខន្ធេ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលេ សមាធិក្ខន្ធេ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលេ បញ្ញាខន្ធេ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលេ វិមុត្តិក្ខន្ធេ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលេ វិមុត្តិញ្ញាណទស្សនក្ខន្ធេ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលានិ ឋានាឋានានិ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលា វិហារសមាបត្តិយោ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលានិ អរិយសច្ចានិ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលេ សតិប្បដ្ឋានេ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលេ សម្មប្បធានេ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុលេ ឥទ្ធិបាទេ បរិគ្គណ្ហាតីតិ

[១៣៨] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏ទូលាយ តើបញ្ញាដ៏ទូលាយ ដូចម្តេច ។ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវអត្ថដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវធម៌ដ៏ទូ-លាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវនិរុត្តិ ដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវបដិភាណ ដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវសីលក្ខន្ធដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវសមាធិក្ខន្ធដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវបញ្ញាខន្ធ ដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវវិមុត្តិក្ខន្ធដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវវិមុត្តិញ្ញាណទស្សនក្ខន្ធដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យក នូវហេតុនិងមិនមែនហេតុ ដ៏ទូ-លាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវវិហារសមាបត្តិ ដ៏ទូ-លាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវអរិយសច្ចដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវសតិប្បដ្ឋាន ដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវសម្មប្បធាន ដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យក នូវឥទ្ធិបាទដ៏ទូលាយ

វិបុលប្បញ្ញា វិបុលានិ ឥន្ទ្រិយានិ បរិគ្គណ្ហាតីតិ វិបុ-
លប្បញ្ញា វិបុលានិ ពលានិ បរិគ្គណ្ហាតីតិ វិបុល-
ប្បញ្ញា វិបុលេ ពោជ្ឈង្គេ បរិគ្គណ្ហាតីតិ វិបុលប្ប-
ញ្ញា វិបុលេ អរិយមគ្គេ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា
វិបុលានិ សាមញ្ញផលានិ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា
វិបុលា អភិញ្ញាយោ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា វិបុ-
លំ បរមដ្ឋំ និព្វានំ បរិគ្គណ្ហាតីតិ វិបុលប្បញ្ញា
វិបុលប្បញ្ញតាយ សំវត្តន្តីតិ អយំ វិបុលប្បញ្ញា ។

[១៣៩] គម្ភីរប្បញ្ញតាយ សំវត្តន្តីតិ កាតមា គម្ភី-
រប្បញ្ញា ។ គម្ភីរេសុ ខន្ធេសុ ញាណំ បវត្តតីតិ គម្ភីរ-
ប្បញ្ញា គម្ភីរាសុ ធាតូសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា
គម្ភីរេសុ អាយតនេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា
គម្ភីរេសុ បដិច្ចសមុប្បាទេសុ ញាណំ បវត្តតីតិ គម្ភីរ-
ប្បញ្ញា គម្ភីរេសុ សុញ្ញតមនុលព្ភេសុ ញាណំ បវត្តតីតិ

ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវឥន្ទ្រិយ ដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវពលៈដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវពោជ្ឈង្គៈ ដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវអរិយមគ្គដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវសាមញ្ញផលដ៏ទូលាយ ឈ្មោះថាបញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវអភិញ្ញា ដ៏ទូលាយ ឈ្មោះបញ្ញាដ៏ទូលាយ ព្រោះកំណត់យក នូវប្រយោជន៍ដ៏ក្រៃលែង គឺនិព្វាន ដ៏ទូលាយ នេះឯងបញ្ញាដ៏ទូលាយ ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏ទូលាយ ។

[១៣៩] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាព នៃបញ្ញាដ៏ជ្រាលជ្រៅ តើបញ្ញាដ៏ជ្រាលជ្រៅ ដូចម្តេច ។ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងខន្ធដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងធាតុដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងអាយតនៈដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងបដិច្ចសមុប្បាទដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងធម៌ដ៏សូន្យ និងធម៌គឺបណ្ឌិតគប្បីបាន ដ៏ជ្រាលជ្រៅ

គម្ភីរប្បញ្ញា គម្ភីរេសុ អត្ថេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ ធម្មេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរាសុ និរុត្តីសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ បដិភាណេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ សីលក្ខន្ធេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ សមាធិក្ខន្ធេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ បញ្ញាខន្ធេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ វិមុត្តិក្ខន្ធេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ វិមុត្តិញាណទស្សនក្ខន្ធេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ ឋានាឋានេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរាសុ វិហារសមាបត្តីសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ អរិយសច្ចេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ សតិបដ្ឋានេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ សម្មប្បធានេសុ ញាណំ បវត្តតីតិ

ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងអត្ថដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងធម៌ដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងនិរុត្តិដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងបដិភាណដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងសីលក្ខន្ធដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងសមាធិក្ខន្ធដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងបញ្ញាខន្ធដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងវិមុត្តិក្ខន្ធដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងវិមុត្តិញ្ញាណទស្សនក្ខន្ធដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងហេតុនិងមិនមែនហេតុដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងវិហារសមាបត្តិដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងអរិយសច្ចដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាល-ជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងសតិប្បដ្ឋានដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងសម្មប្បធានដ៏ជ្រាលជ្រៅ

គម្ភីរប្បញ្ញា គម្ភីរេសុ ឥទ្ធិបាទេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ ឥន្ទ្រិយេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ ពលេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ ពោជ្ឈង្គេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ អរិយមគ្គេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ សាមញ្ញផលេសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេសុ អភិញ្ញាសុ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរេ បរមត្ថេ និព្វានេ ញាណំ បវត្តតីតិ គម្ភីរប្បញ្ញា គម្ភីរប្បញ្ញតាយ សំវត្តន្តីតិ អយំ គម្ភីរប្បញ្ញា ។

[១៤០] អស្សាមន្តប្បញ្ញតាយ សំវត្តន្តីតិ កតមា អស្សាមន្តប្បញ្ញា ។ យស្ស បុគ្គលស្ស អត្ថវវត្ថានតោ អត្ថប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ ធម្មវវត្ថានតោ ធម្មប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ និរុត្តិវវត្ថានតោ និរុត្តិប្បដិសម្ភិទា អធិគតា ហោតិ

ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងឥទ្ធិបាទដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងឥន្ទ្រិយដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងពលៈដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងពោជ្ឈង្គដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងអរិយមគ្គដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងសាមញ្ញផលដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងអភិញ្ញាដ៏ជ្រាលជ្រៅ ឈ្មោះថាបញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងប្រយោជន៍ដ៏ក្រៃលែង គឺនិព្វានដ៏ជ្រាលជ្រៅ នេះឯងបញ្ញាដ៏ជ្រាលជ្រៅ ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏ជ្រាលជ្រៅ ។

[១៨០] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាមិនជិត តើបញ្ញាមិនជិត ដូចម្ដេច ។ បុគ្គលណា ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវហើយ នូវអត្ថប្បដិសម្ភិទា ព្រោះការកំណត់នូវអត្ថដោយសារប្រាជ្ញា ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវហើយ នូវធម្មប្បដិសម្ភិទា ព្រោះការកំណត់នូវធម៌ ដោយសារប្រាជ្ញា ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវហើយ នូវនិរុត្តិប្បដិសម្ភិទា ព្រោះការកំណត់នូវនិរុត្តិ ដោយសារប្រាជ្ញា

សច្ឆិកតា ផស្សិតា បញ្ញាយ បដិភាណវវត្ថានតោ បដិភាណប្បដិសម្ភិទា អធិគតា ហោតិ សច្ឆិកតា ផស្សិតា បញ្ញាយ តស្ស[១] អត្ថេ ច ធម្មេ ច និរុត្តិយា ច បដិភាណេ ច ន អញ្ញោ កោចិ សក្កោតិ អភិសម្ភវិតុំ អនភិសម្ភាវនីយោ ច សោ អញ្ញោតិ[២] អស្សាមន្តប្បញ្ញា បុថុជ្ជនកល្យាណកស្ស បញ្ញា អដ្ឋមកស្ស បញ្ញាយ ទូរេ វិទូរេ សុវិទូរេ ន សន្តិ-កេ ន សាមន្តា បុថុជ្ជនកល្យាណកំ ឧបាទាយ អដ្ឋមកោ អស្សាមន្តប្បញ្ញោ អដ្ឋមកស្ស បញ្ញា សោតាបន្នស្ស បញ្ញាយ ទូរេ វិទូរេ សុវិទូរេ ន សន្តិកេ ន សាមន្តា អដ្ឋមកំ ឧបាទាយ សោតា-បន្នោ អស្សាមន្តប្បញ្ញោ សោតាបន្នស្ស បញ្ញា ស-កទាគាមិស្ស បញ្ញាយ ទូរេ វិទូរេ សុវិទូរេ ន សន្តិកេ ន សាមន្តា សោតាបន្នំ ឧបាទាយ

---

១ ម. តស្សា ។ ២ ឱ.ម. អនភិសម្ភវនីយោ ច យោ អញ្ញេហីតិ ។

ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវហើយ នូវបដិភាណប្បដិសម្ភិទា ព្រោះការកំណត់នូវបដិភាណដោយសារប្រាជ្ញា បុគ្គលដទៃណាមួយមិនអាចដើម្បីយល់ច្បាស់ក្នុងអត្ថផង ធម៌ផង និរុត្តិផង បដិភាណផង របស់បុគ្គលនោះឡើយ មួយទៀត បុគ្គលដទៃនោះ គេមិនគួរបំភ្លឺឲ្យយល់បានទេ ហេតុនោះ ឈ្មោះថាបញ្ញាមិនជិត ។ (មែនពិត)ប្រាជ្ញារបស់កល្យាណ-បុថុជ្ជន ឆ្ងាយ ឆ្ងាយកន្លង ឆ្ងាយដាច់ស្រយាល មិនជិត មិននៅក្បែរនឹងប្រាជ្ញារបស់អដ្ឋមកបុគ្គលឡើយ អដ្ឋមកបុគ្គល ឈ្មោះថាអ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹងកល្យាណបុថុជ្ជន; ឯប្រាជ្ញារបស់អដ្ឋមកបុគ្គល ឆ្ងាយ ឆ្ងាយកន្លង ឆ្ងាយដាច់ស្រយាល មិនជិត មិននៅក្បែរនឹងប្រាជ្ញារបស់សោតាបន្នបុគ្គលឡើយ សោតាបន្នបុគ្គល ឈ្មោះថាអ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹងអដ្ឋមកបុគ្គល; ឯប្រាជ្ញារបស់សោតាបន្នបុគ្គល ឆ្ងាយ ឆ្ងាយកន្លង ឆ្ងាយដាច់ស្រយាល មិនជិត មិននៅក្បែរនឹងប្រាជ្ញារបស់សកទាគាមិបុគ្គលឡើយ សកទាគាមិបុគ្គល ឈ្មោះថាអ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹងសោតាបន្នបុគ្គល; ឯប្រាជ្ញារបស់សកទា-គាមិបុគ្គលឆ្ងាយ ឆ្ងាយកន្លង ឆ្ងាយដាច់ស្រយាល មិនជិត មិននៅក្បែរ

២៤១



សកទាគាមិ អស្សាមគ្គប្បញ្ញោ សកទាគាមិស្ស បញ្ញា អនាគាមិស្ស បញ្ញាយ ទូរេ វិទូរេ សុវិទូរេ ន សន្តិកេ ន សាមន្តា សកទាគាមឹ ឧបាទាយ អនាគាមី អស្សាមគ្គប្បញ្ញោ អនាគាមិស្ស បញ្ញា អរហតោ បញ្ញាយ ទូរេ វិទូរេ សុវិទូរេ ន សន្តិកេ ន សាមន្តា អនាគាមឹ ឧបាទាយ អរហា អស្សាមគ្គប្បញ្ញោ អរហតោ បញ្ញា បច្ចេកពុទ្ធស្ស បញ្ញាយ ទូរេ វិទូរេ សុវិទូរេ ន សន្តិកេ ន សាមន្តា អរហន្តំ ឧបាទាយ បច្ចេកពុទ្ធោ អស្សាមគ្គប្បញ្ញោ បច្ចេកពុទ្ធញ្ច សទេវកញ្ច លោកំ ឧបាទាយ តថាគតោ អរហំ សម្មាសម្ពុទ្ធោ អគ្គោ អស្សាមគ្គប្បញ្ញោ បញ្ញាបភេទកុសលោ បភិន្នញាណោ អធិគតប្បដិសម្ភិទោ ចតុវេសារជ្ជប្បត្តោ ទសពលធារី បុរិសាសភោ បុរិសសីហោ បុរិសនាគោ បុរិសាជញ្ញោ បុរិសធោរយ្ហោ អនន្តញាណោ អនន្តតេជោ អនន្តយសោ

នឹងប្រាជ្ញារបស់អនាគាមិបុគ្គលឡើយ អនាគាមិបុគ្គល ឈ្មោះថាអ្នកមាន បញ្ញាមិនជិត បើប្រៀបធៀបនឹងសកទាគាមិបុគ្គល ឯប្រាជ្ញារបស់អនាគា-មិបុគ្គល ឆ្ងាយ ឆ្ងាយកន្លង ឆ្ងាយដាច់ស្រយាល មិនជិត មិននៅក្បែរនឹង ប្រាជ្ញារបស់អរហន្តឡើយ អរហន្ត ឈ្មោះថាអ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹងអនាគាមិបុគ្គល ឯប្រាជ្ញារបស់អរហន្ត ឆ្ងាយ ឆ្ងាយកន្លង ឆ្ងាយដាច់ស្រយាល មិនជិត មិននៅក្បែរនឹងប្រាជ្ញារបស់ព្រះបច្ចេកពុទ្ធ ឡើយ ព្រះបច្ចេកពុទ្ធ ឈ្មោះថាអ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹង ព្រះអរហន្ត ចំណែកព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គប្រសើរផុត ឈ្មោះថាអ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹងព្រះបច្ចេកពុទ្ធផង និង មនុស្សលោកព្រមទាំងទេវលោកផង ទ្រង់ឈ្លាសក្នុងប្រភេទនៃប្រាជ្ញា មានញាណបែកធ្លាយហើយ ចាក់ធ្លុះនូវបដិសម្ភិទា សម្រេចនូវចតុវេសា-រជ្ជញ្ញាណ ទ្រទ្រង់នូវកម្លាំង ១០ ជាបុរសអាសភៈ ជាបុរសសីហៈ ជា បុរសនាគៈ ជាបុរសអាជានេយ្យ ជាបុរសគួរដើម្បីនាំនូវធុរៈ មានញាណ មិនមានទីបំផុត មានតេជៈមិនមានទីបំផុត មានយសមិនមានទីបំផុត

អញ្ញោ មហន្តោ ជនវា នេតា វិនេតា អនុនេតា បញ្ញបេតា និជ្ឈាបេតា បេក្ខតា បសាទេតា សោ ហិ ភគវា អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា អនក្ខាតស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិទូ មគ្គានុគា[1] ច បន ឯតរហិ សាវកា វិហរន្តិ បច្ឆាគតា សោ ហិ ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមី តថាគតោ នត្ថិ តស្ស ភគវតោ អញ្ញាតំ អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផស្សិតំ បញ្ញាយ អតីតានាគតបច្ចុប្បន្នំ ឧបាទាយ សព្វេ ធម្មា សព្វាការេន ពុទ្ធស្ស ភគវតោ ញាណមុខេ អាបាថំ អាគច្ឆន្តិ

---

១ ឱ. ម. មគ្គានុគាមី ។

ព្រះអង្គស្តុកស្តម្ភ មានទ្រព្យច្រើន មានធនធានច្រើន ទ្រង់ជាអ្នកណែនាំ ពន្យល់ ដឹកនាំ ប្រញ៉ប្ត ពិនិត្យមើល សម្លឹងមើល ញ៉ាំងបុគ្គលដទៃឲ្យជ្រះថ្លា ព្រោះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ញ៉ាំងមគ្គដែលមិនទាន់កើត ឲ្យកើតឡើង ញ៉ាំងមគ្គដែលមិនទាន់ដុះដាល ឲ្យដុះដាលឡើង ទ្រង់ជាអ្នកប្រាប់ផ្លូវ ដែលគេមិនដែលប្រាប់ ទ្រង់ជ្រាបផ្លូវ យល់ផ្លូវ ឈ្លាសក្នុងផ្លូវ ឯពួកសាវ័ក ក្នុងកាលឥឡូវនេះ គ្រាន់តែដើរទៅតាមផ្លូវ ជាអ្នកដើរទៅតាមក្រោយទេ ព្រះមានព្រះភាគ អង្គនោះ ទ្រង់ជ្រាបហេតុដែលគួរជ្រាប ទ្រង់ឃើញហេតុដែលគួរឃើញ ទ្រង់មានចក្ខុ មានញាណ មានធម៌ ជាបុគ្គលដ៏ប្រសើរ ទ្រង់ពោល ទ្រង់បង្ហើប ទ្រង់បង្ហាញនូវប្រយោជន៍ ទ្រង់ប្រទាននូវអមតនិព្វាន ជាម្ចាស់ហេតុធម៌ ជាព្រះតថាគត ។ ធម្មជាតដែលព្រះមានព្រះភាគនោះ មិនបានដឹង មិនបានឃើញ មិនបានជ្រាប មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានប៉ះពាល់ហើយ ដោយប្រាជ្ញា មិនមានឡើយ ធម៌ទាំងពួងដែលអាស្រ័យនូវហេតុ ជាអតីត អនាគត និងបច្ចុប្បន្ន រមែងមកកាន់គន្លង ចំមុខព្រះញាណរបស់ព្រះពុទ្ធមានជោគ ដោយអាការទាំងពួង ។

យំ កិញ្ចិ នេយ្យំ នាម អត្ថធម្មំ ជានិតព្វំ[១] អត្តត្ថោ វា បរត្ថោ វា ឧភយត្ថោ វា ទិដ្ឋធម្មិកោ វា អត្ថោ សម្បរាយិកោ វា អត្ថោ ឧត្តានោ វា អត្ថោ គម្ភីរោ វា អត្ថោ គុឡ្ហោ វា អត្ថោ បដិច្ឆន្នោ វា អត្ថោ នេយ្យោ វា អត្ថោ នីតោ វា អត្ថោ អនវជ្ជោ វា អត្ថោ និក្កិលេសោ វា អត្ថោ វោទានោ វា អត្ថោ បរមត្ថោ វា អត្ថោ សព្វន្តំ អន្តោពុទ្ធញ្ញាណេ បរិវត្តតិ សព្វំ កាយកម្មំ ពុទ្ធស្ស ញាណានុបរិវត្តតិ សព្វំ វចីកម្មំ ពុទ្ធស្ស ញាណានុបរិវត្តតិ សព្វំ មនោកម្មំ ពុទ្ធស្ស ញាណានុបរិវត្តតិ អតីតេ ពុទ្ធស្ស អប្បដិហតំ ញាណំ អនាគតេ ពុទ្ធស្ស អប្បដិហតំ ញាណំ បច្ចុប្បន្នេ ពុទ្ធស្ស អប្បដិហតំ ញាណំ យាវតកំ នេយ្យំ តាវតកំ ញាណំ យាវតកំ ញាណំ តាវតកំ នេយ្យំ នេយ្យបរិយន្តិកំ ញាណំ ញាណបរិយន្តិកំ

១ ម. យំ កិញ្ចិ នេយ្យំ នាម អត្ថិ តំ សព្វំ ជានិតព្វន្តិ យុត្តតរំ ។ បស្វរសុត្តនិទ្ទេសេ ហិ យំ កិញ្ចិ នេយ្យំ នាម អត្ថិ ជានិតព្វន្តិ ទិស្សតិ ។

ធម្មជាតណាមួយ ឈ្មោះថាគួរដឹង ព្រោះអាស្រ័យអត្ថនឹងធម៌ ដែលគេគប្បីដឹង គឺប្រយោជន៍ខ្លួន ប្រយោជន៍បុគ្គលដទៃ ឬប្រយោជន៍ទាំងពីរ ប្រយោជន៍ក្នុងបច្ចុប្បន្ន ឬប្រយោជន៍ក្នុងបរលោក ប្រយោជន៍រាក់ ឬប្រយោជន៍ជ្រាលជ្រៅ ប្រយោជន៍ដែលគេលាក់ ឬប្រយោជន៍កំបាំង ប្រយោជន៍គួរណែនាំ ឬប្រយោជន៍ដែលត្រូវទូន្មាន ប្រយោជន៍ឥតទោស ប្រយោជន៍មិនមានកិលេស ប្រយោជន៍ផូរផង់ ឬប្រយោជន៍ដ៏ក្រៃលែង ធម្មជាតទាំងអស់នោះ ប្រព្រឹត្តទៅខាងក្នុងនៃពុទ្ធញ្ញាណ ។ កាយកម្មទាំងអស់ ប្រព្រឹត្តទៅតាមញាណរបស់ព្រះពុទ្ធ វចីកម្មទាំងអស់ ប្រព្រឹត្តទៅតាមញាណ របស់ព្រះពុទ្ធ មនោកម្មទាំងអស់ ប្រព្រឹត្តទៅតាមញាណរបស់ព្រះពុទ្ធ ញាណរបស់ព្រះពុទ្ធ មិនមានអ្វីរារាំងក្នុងអតីតកាល ញាណរបស់ព្រះពុទ្ធ មិនមានអ្វីរារាំងក្នុងអនាគតកាល ញាណរបស់ព្រះពុទ្ធមិនមានអ្វីរារាំងក្នុងបច្ចុប្បន្នកាល ហេតុការណ៍ដែលត្រូវដឹង មានកំណត់ត្រឹមណា ញាណក៏មានកំណត់ត្រឹមនោះ ញាណមានកំណត់ត្រឹមណា ហេតុការណ៍ដែលត្រូវដឹង ក៏មានកំណត់ត្រឹមនោះ ញាណមានហេតុដែលត្រូវដឹងជាទីបំផុត ហេតុដែលត្រូវដឹង ក៏មានញាណជាទីបំផុត

ណេយ្យំ ណេយ្យំ អតិក្កមិត្វា ញាណំ នប្បវត្តតិ ញាណំ អតិក្កមិត្វា ណេយ្យបថោ នត្ថិ អញ្ញមញ្ញំ បរិយន្តដ្ឋាយិនោ[១] តេ ធម្មា យថា ទ្វិន្នំ សមុគ្គបដលានំ សុផស្សិតានំ ហេដ្ឋិមសមុគ្គបដលំ ឧបរិមំ នាតិវត្តតិ ឧបរិមសមុគ្គបដលំ ហេដ្ឋិមំ នាតិវត្តតិ អញ្ញមញ្ញំ បរិយន្តដ្ឋាយិនោ ឯវមេវំ[២] ពុទ្ធស្ស ភគវតោ ណេយ្យញ្ច ញាណញ្ច អញ្ញមញ្ញំ បរិយន្តដ្ឋាយិនោ តេ ធម្មា យាវតកំ ណេយ្យំ តាវតកំ ញាណំ យាវតកំ ញាណំ តាវតកំ ណេយ្យំ ណេយ្យបរិយន្តិកំ ញាណំ ញាណបរិយន្តិកំ ណេយ្យំ ណេយ្យំ អតិក្កមិត្វា ញាណំ នប្បវត្តតិ ញាណំ អតិក្កមិត្វា ណេយ្យបថោ នត្ថិ អញ្ញមញ្ញំ បរិយន្តដ្ឋាយិនោ តេ ធម្មា សព្វធម្មេសុ ពុទ្ធស្ស ញាណំ បវត្តតិ សព្វេ ធម្មា ពុទ្ធស្ស ភគវតោ អាវជ្ជនប្បដិពទ្ធា អាកង្ខាបដិពទ្ធា មនសិការប្បដិពទ្ធា ចិត្តុប្បាទប្បដិពទ្ធា សព្វសត្តេសុ ពុទ្ធស្ស ញាណំ បវត្តតិ សព្វេសំ សត្តានំ ពុទ្ធោ អាសយំ ជានាតិ

១ ឱ. សព្វត្ថ បរិយន្តដ្ឋានិយោតិ ។ ២ ម. សព្វត្ថ ឯវមេវសទ្ទោ ទិស្សតិ ។

ញាណមិនប្រព្រឹត្តកន្លង នូវហេតុដែលត្រូវដឹង ទាំងគន្លងនៃហេតុដែលត្រូវដឹង ក៏មិនកន្លងនូវញាណ ធម៌ទាំងនោះ ឋិតនៅក្នុងទីបំផុតនៃគ្នានិងគ្នា បាតស្មុគ្រទាំងពីរខាង ដែលជិតស្និទ្ធល្អ បាតស្មុគ្រខាងក្រោមមិនប្រព្រឹត្តកន្លងបាតស្មុគ្រខាងលើ បាតស្មុគ្រខាងលើ មិនប្រព្រឹត្តកន្លងនូវបាតស្មុគ្រខាងក្រោម បាតស្មុគ្រទាំងនោះ ឋិតនៅត្រឹមទីបំផុតនៃគ្នានិងគ្នា យ៉ាងណាមិញ របស់ដែលត្រូវដឹង និងញាណនៃព្រះពុទ្ធដ៏មានជោគឋិតនៅត្រឹមទីបំផុតនៃគ្នានិងគ្នា ក៏យ៉ាងនោះដែរ គឺ របស់ដែលត្រូវដឹងមានកំណត់ត្រឹមណា ញាណក៏មានកំណត់ត្រឹមនោះ ញាណមានកំណត់ត្រឹមណា របស់ដែលត្រូវដឹង ក៏មានកំណត់ត្រឹមនោះ ញាណមានរបស់ដែលត្រូវដឹងជាទីបំផុត របស់ដែលត្រូវដឹង ក៏មានញាណជាទីបំផុត ញាណមិនប្រព្រឹត្តកន្លងនូវរបស់ដែលត្រូវដឹង គន្លងដែលត្រូវដឹងក៏មិនកន្លងនូវញាណ ធម៌ទាំងនោះ ឋិតនៅត្រឹមទីបំផុតនៃគ្នានិងគ្នា ។ ញាណរបស់ព្រះពុទ្ធ ប្រព្រឹត្តទៅក្នុងធម៌ទាំងអស់ គឺ ធម៌ទាំងអស់ជាប់ចំពោះដោយការនឹក ជាប់ចំពោះដោយបំណង ជាប់ចំពោះដោយការធ្វើទុកក្នុងចិត្ត ជាប់ចំពោះដោយចិត្តុប្បាទ របស់ព្រះពុទ្ធមានជោគ ។ ញាណរបស់ព្រះពុទ្ធ ប្រព្រឹត្តទៅក្នុងសត្វទាំងអស់ គឺ ព្រះពុទ្ធទ្រង់ជ្រាបនូវអាសយធម៌

អនុសយំ ជានាតិ ចរិយំ[១] ជានាតិ អធិមុត្តឹ ជានាតិ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ ភព្វាភព្វេ សត្តេ បជានាតិ សទេវកោ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា អន្តោពុទ្ធញ្ញាណេ បរិវត្តតិ យថា យេ កេចិ មច្ឆកច្ឆបា អន្តមសោ តិមិតិមិង្គលំ ឧបាទាយ អន្តោ មហាសមុទ្ទេ បរិវត្តន្តិ ឯវមេវំ សទេវកោ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា អន្តោពុទ្ធញ្ញាណេ បរិវត្តតិ យថា យេ កេចិ បក្ខិនោ អន្តមសោ គរុឡំ វេនតេយ្យំ ឧបាទាយ អាកាសស្ស បទេសេ បរិវត្តន្តិ ឯវមេវំ យេបិ តេ សារីបុត្តសមប្បញ្ញា តេបិ ពុទ្ធញ្ញាណស្ស បទេសេ បរិវត្តន្តិ

---
១ ឱ. ម. ចរិតំ ។

ជ្រាបនូវអនុសយធម៌ ជ្រាបនូវចរិយា ជ្រាបនូវអធ្យាស្រ័យ របស់ពួកសត្វទាំងអស់ ជ្រាបច្បាស់នូវពួកសត្វដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយចាស់ក្លា មានឥន្ទ្រិយទន់ខ្សោយ មានអាការល្អ មានអាការអាក្រក់ គួរឲ្យត្រាស់ដឹងបានដោយងាយ គួរឲ្យត្រាស់ដឹងបានដោយក្រ មានភ័ព្វនិងឥតភ័ព្វ ។ លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពពួកសត្វព្រមទាំងសមណនិងព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស រមែងប្រព្រឹត្តទៅខាងក្នុងនៃពុទ្ធញ្ញាណ ពួកត្រីនិងអណ្ដើកណាមួយ ដោយហោចទៅ រាប់យកទាំងត្រីឈ្មោះតិមិតិមិង្គលៈ រមែងប្រព្រឹត្តទៅក្នុងខាងក្នុងនៃមហាសមុទ្រ យ៉ាងណាមិញ លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពួកសត្វព្រមទាំងសមណៈនិងព្រាហ្មណ៍ មនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស រមែងប្រព្រឹត្តទៅខាងក្នុងនៃពុទ្ធញ្ញាណ ក៏យ៉ាងនោះដែរ ពុំនោះសោតពួកសត្វស្លាបណាមួយ ដោយទីបំផុតទៅ រាប់យកទាំងសត្វគ្រុឌឈ្មោះវេនតេយ្យ រមែងវិលវល់នៅ ក្នុងប្រទេស នៃអាកាស យ៉ាងណាមិញ ជនទាំងឡាយណា មានប្រាជ្ញា ស្មើនឹងព្រះសារីបុត្ត ជនទាំងនោះ រមែងប្រព្រឹត្តទៅ ក្នុងប្រទេសនៃពុទ្ធញ្ញាណ ក៏យ៉ាងនោះឯង។

ពុទ្ធញាណំ ទេវមនុស្សានំ បញ្ញំ ជវិត្វា អតិឃំសិត្វា តិដ្ឋតិ យេបិ តេ ខត្តិយបណ្ឌិតា ព្រាហ្មណបណ្ឌិតា គហបតិបណ្ឌិតា សមណបណ្ឌិតា និបុណា កតបរប្បវាទា វាលវេធិរូបា តេ ភិន្ទន្តា មញ្ញេ ចរន្តិ[១] បញ្ញាគតេន ទិដ្ឋិគតានិ តេ បញ្ហំ[២] អភិសង្ខរិត្វា តថាគតំ ឧបសង្កមិត្វា បុច្ឆន្តិ គុឡ្ហានិ ច បដិច្ឆន្នានិ ច កថិតា វិស្សជ្ជិតា ច តេ បញ្ហា ច ភគវតា ហោន្តិ និទ្ទិដ្ឋការណា ឧបក្ខិត្តកា ច តេ ភគវតោ សម្បជ្ជន្តិ អថខោ ភគវា តត្ថ អតិរោចតិ យទិទំ បញ្ញាយាតិ អគ្គោ អស្សាមន្តប្បញ្ញោ អស្សាមន្តប្បញ្ញតាយ សំវត្តន្តីតិ អយំ អស្សាមន្តប្បញ្ញា ។

[១៤១] ភូរិប្បញ្ញតាយ សំវត្តន្តីតិ កតមា ភូរិប្បញ្ញា ។ រាគំ អភិភុយ្យតីតិ ភូរិប្បញ្ញា អភិភវិតាតិ[៣]

---

១ ម. មញ្ញេ វទន្តិ ។ ២ ឱ. ម. ចសទ្ទោ នត្ថិ ។ ៣ ម. សព្វត្ថ អតិភវិកាតិ ទិស្សតិ ។

ពុទ្ធញ្ញាណ ផ្សាយទៅរហ័សណាស់ កន្ទង់បញ្ញា នៃទេវតានិងមនុស្សទាំង-ឡាយ ពួកជនណា ជាខត្តិយបណ្ឌិត ព្រាហ្មណបណ្ឌិត គហបតិ-បណ្ឌិត ឬសមណបណ្ឌិត មានប្រាជ្ញាល្អិត ស្គាល់បរប្បវាទ ដូចនាយខ្មាន់ធ្នូអ្នកបាញ់នូវរោម ពួកជនទាំងនោះ ប្រព្រឹត្តហាក់ដូចជាទម្លាយនូវទិដ្ឋិ (របស់ជនដទៃ) ដោយប្រាជ្ញា (របស់ខ្លួន) ពួកជនទាំងនោះឯង បានចង់ក្រងនូវប្រស្នា ហើយចូលទៅគាល់ព្រះតថាគត ហើយសួរនូវអាថ៌ដែលគេលាក់ផង ដែលកំបាំងផង ប្រស្នាទាំងនោះ ព្រះមានព្រះភាគបានសម្តែង ដោះស្រាយហើយផង ជាប្រស្នាមានហេតុដែលព្រះអង្គអធិប្បាយហើយផង ជាប្រស្នាដែលព្រះអង្គលើកបង្ហាញហើយផង ពួកជនទាំងនោះបានសម្រេច (សម្បត្តិជាសាវ័ក ឬជាឧបាសក ដោយការដោះស្រាយ) របស់ព្រះមានព្រះភាគ លំដាប់នោះ ព្រះមានព្រះភាគទ្រង់រុងរឿងក្រៃលែងក្នុងទីនោះ ដោយប្រាជ្ញា ហេតុនោះ ព្រះមានព្រះភាគ ទ្រង់ប្រសើរលើស ឈ្មោះថាទ្រង់មានបញ្ញាមិនជិត ។ នេះឯងបញ្ញាមិនជិត ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាមិនជិត ។

[១៤១] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដូចផែនដី តើបញ្ញាដូចផែនដី ដូចម្តេច ។ ឈ្មោះថាបញ្ញាដូចផែនដី ព្រោះគ្របសង្កត់នូវរាគៈ ឈ្មោះថាបញ្ញាដូចផែនដី ព្រោះគ្របសង្កត់ហើយ (នូវរាគៈ)

ភូរិប្បញ្ញា ទោសំ អភិកុយ្យតីតិ ភូរិប្បញ្ញា អភិ-
ភវិតាតិ ភូរិប្បញ្ញា មោហំ អភិកុយ្យតីតិ ភូរិប្ប-
ញ្ញា អភិភវិតាតិ ភូរិប្បញ្ញា កោធំ ។ បេ ។ ឧប-
នាហំ មក្ខំ បឡាសំ ឥស្សំ មច្ឆរិយំ មាយំ សា-
ឋេយ្យំ ថម្ភំ សារម្ភំ មានំ អតិមានំ មទំ បមាទំ
សព្វេ កិលេសេ សព្វេ ទុច្ចរិតេ សព្វេ អភិសង្ខា-
រេ ។ បេ ។ សព្វេ ភវគាមិកម្មេ អភិកុយ្យតីតិ ភូ-
រិប្បញ្ញា អភិភវិតាតិ ភូរិប្បញ្ញា រាគោ អរិ តំ អរឹ
មទ្ទនិប្បញ្ញាតិ ភូរិប្បញ្ញា ទោសោ អរិ តំ អរឹ
មទ្ទនិប្បញ្ញាតិ ភូរិប្បញ្ញា មោហោ អរិ តំ អរឹ
មទ្ទនិប្បញ្ញាតិ ភូរិប្បញ្ញា កោធោ ។ បេ ។ ឧបនាហោ
មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ
ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ ស-
ព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ សង្ខារា[១] ។ បេ ។

១ ម. អភិសង្ខារា ។

ឈ្មោះថាបញ្ញាដូចផែនដី ព្រោះគ្របសង្កត់នូវទោសៈ ឈ្មោះថាបញ្ញាដូចផែនដី ព្រោះគ្របសង្កត់ហើយនូវ(ទោសៈ) ឈ្មោះថាបញ្ញាដូចផែនដី ព្រោះគ្របសង្កត់នូវមោហៈ ឈ្មោះថាបញ្ញាដូចផែនដី ព្រោះគ្របសង្កត់ហើយ (នូវមោហៈ) ឈ្មោះថាបញ្ញាដូចផែនដី ព្រោះគ្របសង្កត់នូវក្រោធ ។ បេ ។ នូវការចងគំនុំ ការលុបគុណគេ ការវាយឫកស្មើ ឫស្យា កំណាញ់ មាយា ការអួតអាង ការរឹងត្អឹង ការប្រណាំងប្រជែង ការប្រកាន់ ការមើលងាយ ការស្រវឹង ការធ្វេសប្រហែស កិលេសទាំងអស់ ទុច្ចរិតទាំងអស់ អភិសង្ខារទាំងអស់ ។ បេ ។ នូវភវគាមិកម្មទាំងអស់ ឈ្មោះថាបញ្ញាដូចផែនដី ព្រោះគ្របសង្កត់ហើយ ឈ្មោះថាបញ្ញាដូចផែនដី ព្រោះរាគៈជាសត្រូវ ប្រាជ្ញាជាគ្រឿងញាំញី នូវរាគៈជាសត្រូវនោះ ឈ្មោះថាបញ្ញាដូចផែនដី ព្រោះទោសៈជាសត្រូវ ប្រាជ្ញាជាគ្រឿងញាំញី នូវទោសៈជាសត្រូវនោះ ឈ្មោះថា បញ្ញាដូចផែនដី ព្រោះមោហៈជាសត្រូវ ប្រាជ្ញាជាគ្រឿងញាំញី នូវមោហៈជាសត្រូវនោះ ឈ្មោះថា បញ្ញាដូចផែនដី ព្រោះក្រោធ ។ បេ ។ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សង្ខារទាំងអស់ ។បេ។

សព្វេ ភវគាមិកម្មា អភិ តំ អភី មទ្ទនិប្បញ្ញាតិ ភូរិប្បញ្ញា ភូរិ វុច្ចតិ បថវី តាយ[១] បថវីសមាយ វិត្ថតាយ វិបុលាយ បញ្ញាយ សមន្នាគតោតិ ភូរិប្បញ្ញា អបិ ច បញ្ញាយ មេតំ អធិវចនំ ភូរិ មេធាបរិណាយិកាតិ ភូរិប្បញ្ញា ភូរិប្បញ្ញតាយ សំវត្តន្តីតិ អយំ ភូរិប្បញ្ញា ។

[១៤២] បញ្ញាពាហុល្លាយ សំវត្តន្តីតិ កតមំ បញ្ញាពាហុល្លំ ។ ឥធេកច្ចោ បញ្ញាគរុកោ ហោតិ បញ្ញាចរិតោ បញ្ញាសយោ បញ្ញាធិមុត្តោ បញ្ញាធជោ បញ្ញាកេតុ បញ្ញាធិបតេយ្យោ វិចយពហុលោ បវិចយពហុលោ ឱក្ខាយនពហុលោ សម្បេក្ខាយនពហុលោ សម្បេក្ខាយនធម្មោ វិភូតវិហារិតច្ចរិតោ[២] តគ្គរុកោ តព្វហុលោ តន្និន្នោ តំចោណោ តំបព្ភារោ[៣] តទធិមុត្តោ តទាធិបតេយ្យោ យថា

---

១ ឱ. ម. តាយសទ្ទោ នត្ថិ ។ ២ ឱ. ម. វិភូតវិហារីតច្ចរិតោ ។ ៣ ឱ. ម. តប្បោណោ តប្បព្ភារោ ។

ភវគាមិកម្មទាំងអស់ជាសត្រូវ ប្រាជ្ញាជាគ្រឿងញាំញី នូវភវគាមិកម្មជាសត្រូវនោះ ។ ប្រឹថពី លោកហៅថា ផែនដី ឈ្មោះថាបញ្ញាដូចផែនដី ព្រោះបុគ្គលប្រកបព្រមដោយប្រាជ្ញា ផ្សាយចេញ ទូលាយ ស្មើដោយផែនដីនោះ ម្យ៉ាងទៀត ពាក្យថា ផែនដី នេះ ជាឈ្មោះនៃប្រាជ្ញា ឈ្មោះថាបញ្ញាដូចផែនដី ព្រោះបញ្ញាជាគ្រឿងទម្លាយនូវកិលេស ជាគ្រឿងណែនាំ ។ នេះឯង បញ្ញាដូចផែនដី ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដូចផែនដី ។

[១៤២] ពាក្យថា ប្រព្រឹត្តទៅ ដើម្បីភាពច្រើនដោយប្រាជ្ញា តើភាពច្រើនដោយប្រាជ្ញា ដូចម្ដេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកធ្ងន់ដោយប្រាជ្ញា មានប្រាជ្ញាជាចរិត មានប្រាជ្ញាជាអជ្ឈាស្រ័យ មានប្រាជ្ញាជាអធិមុត្តិ មានប្រាជ្ញាជាទង់ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិនិត្យ ច្រើនដោយការស្ទាបស្ទង់មើល ច្រើនដោយការរិះរេមើល មានការរិះរេមើលជាធម្មតា មានធម៌ជាគ្រឿងនៅប្រាកដជាចរិត ធ្ងន់ដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ឱនទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ ចុះចិត្តស៊ប់ក្នុងប្រាជ្ញានោះ មានប្រាជ្ញានោះជាអធិបតី

គណកុរោ វុច្ចតិ គណពាហុលិកោតិ ចីវរក-
រុកោ វុច្ចតិ ចីវរពាហុលិកោតិ បត្តករុកោ វុច្ចតិ
បត្តពាហុលិកោតិ សេនាសនករុកោ វុច្ចតិ សេនា-
សនពាហុលិកោតិ ឯវមេវំ ឥធេកច្ចោ បញ្ញា-
ករុកោ ហោតិ បញ្ញាចរិតោ បញ្ញាសយោ បញ្ញា-
ធិមុត្តោ បញ្ញាធជោ បញ្ញាកេតុ បញ្ញាធិបតេយ្យោ
វិចយពហុលោ បវិចយពហុលោ ឱក្ខាយនពហុលោ
សម្បេក្ខាយនពហុលោ សម្បេក្ខាយនធម្មោ វិភូតវិហា-
រិតច្ចរិតោ តគ្គរុកោ តព្វហុលោ តន្និន្នោ តំបោណោ
តំបព្ភារោ តទធិមុត្តោ តទាធិបតេយ្យោ បញ្ញាពាហុ-
ល្លាយ សំវត្តន្តីតិ ឥទំ បញ្ញាពាហុល្លំ ។

[១៤៣] សីឃប្បញ្ញតាយ សំវត្តន្តីតិ កាតមា
សីឃប្បញ្ញា ។ សីឃំ សីឃំ សីលានិ បរិបូរេតីតិ សី-
ឃប្បញ្ញា សីឃំ សីឃំ ឥន្ទ្រិយសំវរំ បរិបូរេតីតិ សីឃ-
ប្បញ្ញា សីឃំ សីឃំ ភោជនេ មត្តញ្ញុតំ បរិបូរេតីតិ

បុគ្គលអ្នកធ្ងន់ក្នុងពួក គេហៅថា អ្នកច្រើនដោយពួក បុគ្គលអ្នកធ្ងន់ក្នុងចីវរ គេហៅថា អ្នកច្រើនដោយចីវរ បុគ្គលអ្នកធ្ងន់ក្នុងបាត្រ គេហៅថា អ្នកច្រើនដោយបាត្រ បុគ្គលអ្នកធ្ងន់ក្នុងសេនាសនៈ គេហៅថា អ្នកច្រើនដោយសេនាសនៈ យ៉ាងណា បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកធ្ងន់ដោយប្រាជ្ញា មានប្រាជ្ញាជាចរិត មានប្រាជ្ញាជាអធ្យាស្រ័យ មានប្រាជ្ញាជាអធិមុត្តិ មានប្រាជ្ញាជាទង់ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការរិះរមើល មានការរិះរមើលជាធម្មតា មានធម៌ជាគ្រឿងនៅប្រាកដជាចរិត ធ្ងន់ក្នុងប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ឱនទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ ចុះចិត្តស៊ប់ ក្នុងប្រាជ្ញានោះ មានប្រាជ្ញានោះជាអធិបតី ក៏យ៉ាងនោះដែរ ។ នេះឯង ភាពច្រើនដោយបញ្ញា ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពច្រើនដោយប្រាជ្ញា ។

[១៤៣] ពាក្យថាប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏ធាប់ តើបញ្ញាដ៏ធាប់ដូចម្តេច ។ ឈ្មោះថាបញ្ញាដ៏ធាប់ព្រោះញុំាងសីលឲ្យពេញលេញធាប់ៗ ឈ្មោះថាបញ្ញាដ៏ធាប់ ព្រោះញុំាងឥន្ទ្រិយសំវរៈឲ្យពេញលេញធាប់ ៗ ឈ្មោះថាបញ្ញាដ៏ធាប់ ព្រោះញុំាងសេចក្តីដឹងប្រមាណក្នុងភោជនឲ្យពេញលេញធាប់ ៗ

សីឃប្បញ្ញា សីឃំ សីឃំ ជាតរិយាធុយោកំ ប-
រិបូរេតីតិ សីឃប្បញ្ញា សីឃំ សីឃំ សីលក្ខន្ធំ
បរិបូរេតីតិ សីឃប្បញ្ញា សីឃំ សីឃំ សមាធិ-
ក្ខន្ធំ បរិបូរេតីតិ សីឃប្បញ្ញា សីឃំ សីឃំ ប-
ញ្ញាខន្ធំ បរិបូរេតីតិ សីឃប្បញ្ញា សីឃំ សីឃំ វិមុត្តិ-
ក្ខន្ធំ បរិបូរេតីតិ សីឃប្បញ្ញា សីឃំ សីឃំ វិមុត្តិ-
ញ្ញាណទស្សនក្ខន្ធំ បរិបូរេតីតិ សីឃប្បញ្ញា សីឃំ
សីឃំ ឋានាឋានានិ បដិវិជ្ឈតីតិ សីឃប្បញ្ញា សីឃំ
សីឃំ វិហារសមាបត្តិយោ បរិបូរេតីតិ សីឃប្បញ្ញា សីឃំ
សីឃំ អរិយសច្ចានិ បដិវិជ្ឈតីតិ សីឃប្បញ្ញា សីឃំ
សីឃំ សតិប្បដ្ឋានេ ភាវេតីតិ សីឃប្បញ្ញា សីឃំ
សីឃំ សម្មប្បធានេ ភាវេតីតិ សីឃប្បញ្ញា សីឃំ
សីឃំ ឥទ្ធិបាទេ ភាវេតីតិ សីឃប្បញ្ញា សីឃំ សីឃំ
ឥន្ទ្រិយានិ ភាវេតីតិ សីឃប្បញ្ញា សីឃំ សីឃំ ពលា-
និ ភាវេតីតិ សីឃប្បញ្ញា សីឃំ សីឃំ ពោជ្ឈង្គេ

ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងការប្រកបរឿយ ៗ ក្នុងសេចក្តីភ្ញាក់រលឹកឲ្យពេញលេញឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងសីលក្ខន្ធឲ្យពេញលេញឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងសមាធិក្ខន្ធឲ្យពេញលេញឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងបញ្ញាខន្ធឲ្យពេញលេញឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងវិមុត្តិក្ខន្ធឲ្យពេញលេញឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងវិមុត្តិញ្ញាណទស្សនក្ខន្ធឲ្យពេញលេញឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះចាក់ធ្លុះនូវហេតុនិងមិនមែនហេតុឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងវិហារសមាបត្តិឲ្យពេញលេញឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះចាក់ធ្លុះនូវអរិយសច្ចឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងសតិប្បដ្ឋានឲ្យចម្រើនឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងសម្មប្បធានឲ្យចម្រើនឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងឥទ្ធិបាទឲ្យចម្រើនឆាប់ ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងឥន្ទ្រិយឲ្យចម្រើនឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងពលៈឲ្យចម្រើនឆាប់ ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងពោជ្ឈង្គឲ្យចម្រើនឆាប់ ៗ

ភាវេតីតិ សីឃប្បញ្ញា សីឃំ សីឃំ អរិយមគ្គំ ភាវេតីតិ សីឃប្បញ្ញា សីឃំ សីឃំ សាមញ្ញផលានិ សច្ឆិ-ករោតីតិ សីឃប្បញ្ញា សីឃំ សីឃំ អភិញ្ញាយោ បដិវិជ្ឈតីតិ សីឃប្បញ្ញា សីឃំ សីឃំ បរមត្ថំ និព្វានំ សច្ឆិករោតីតិ សីឃប្បញ្ញា សីឃប្បញ្ញតាយ សំវត្តន្តីតិ អយំ សីឃប្បញ្ញា ។

[១៤៤] លហុប្បញ្ញតាយ សំវត្តន្តីតិ កតមា លហុប្បញ្ញា ។ លហុំ លហុំ សីលានិ បរិបូរេ-តីតិ លហុប្បញ្ញា លហុំ លហុំ ឥន្ទ្រិយសំវរំ បរិ-បូរេតីតិ លហុប្បញ្ញា លហុំ លហុំ ភោជនេ មត្ត-ញ្ញុតំ បរិបូរេតីតិ លហុប្បញ្ញា លហុំ លហុំ ជាគរិ-យានុយោគំ បរិបូរេតីតិ លហុប្បញ្ញា លហុំ លហុំ សីលក្ខន្ធំ ។ បេ ។ សមាធិក្ខន្ធំ បញ្ញាខន្ធំ វិមុត្តិ-ក្ខន្ធំ វិមុត្តិញ្ញាណទស្សនក្ខន្ធំ បរិបូរេតីតិ លហុប្បញ្ញា លហុំ លហុំ ឋានាឋានានិ បដិវិជ្ឈតីតិ លហុប្ប-ញ្ញា លហុំ លហុំ វិហារសមាបត្តិយោ បរិបូរេតីតិ

ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះញ៉ាំងអរិយមគ្គឲ្យចម្រើនឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះធ្វើឲ្យជាក់ច្បាស់ នូវសាមញ្ញផលឆាប់ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះចាក់ធ្លុះនូវអភិញ្ញា ឆាប់ ៗ ឈ្មោះថាបញ្ញាដ៏ឆាប់ ព្រោះធ្វើឲ្យជាក់ច្បាស់ នូវប្រយោជន៍ក្រៃលែង គឺនិព្វាន ឆាប់ៗ ។ នេះបញ្ញាដ៏ឆាប់ ក្នុងពាក្យថា ប្រព្រឹត្តទៅ ដើម្បីភាពនៃប្រាជ្ញាដ៏ឆាប់ ។

[១៤៤] ពាក្យថា ប្រព្រឹត្តទៅ ដើម្បីភាពនៃបញ្ញារហ័ស តើបញ្ញារហ័ស ដូចម្តេច ។ ឈ្មោះថាបញ្ញារហ័ស ព្រោះញ៉ាំងសីលឲ្យពេញលេញរហ័ស ៗ ឈ្មោះថាបញ្ញារហ័ស ព្រោះញ៉ាំងឥន្ទ្រិយសំវរៈឲ្យពេញលេញរហ័ស ៗ ឈ្មោះថាបញ្ញារហ័ស ព្រោះញ៉ាំងសេចក្តីដឹងប្រមាណក្នុងភោជន ឲ្យពេញលេញរហ័ស ៗ ឈ្មោះថាបញ្ញារហ័ស ព្រោះញ៉ាំងការប្រកបរឿយ ៗ ក្នុងសេចក្តីភ្ញាក់រលឹក ឲ្យពេញលេញរហ័ស ៗ ឈ្មោះថាបញ្ញារហ័ស ព្រោះញ៉ាំងសីលក្ខន្ធ ។ បេ ។ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញ្ញាណទស្សនក្ខន្ធ ឲ្យពេញលេញរហ័ស ៗ ឈ្មោះថាបញ្ញារហ័ស ព្រោះចាក់ធ្លុះនូវហេតុនិងមិនមែនហេតុ រហ័ស ៗ ឈ្មោះថាបញ្ញារហ័ស ព្រោះញ៉ាំងវិហារសមាបត្តិឲ្យពេញលេញរហ័សៗ

លហុប្បញ្ញា លហុំ លហុំ អរិយសច្ចានិ បដិវិជ្ឈតីតិ លហុប្បញ្ញា លហុំ លហុំ សតិប្បដ្ឋានេ ភាវេតីតិ លហុប្បញ្ញា លហុំ លហុំ សម្មប្បធានេ ភាវេតីតិ លហុប្បញ្ញា លហុំ លហុំ ឥទ្ធិបាទេ ភាវេតីតិ លហុប្បញ្ញា លហុំ លហុំ ឥន្ទ្រិយានិ ភាវេតីតិ លហុប្បញ្ញា លហុំ លហុំ ពលានិ ភាវេតីតិ លហុប្បញ្ញា លហុំ លហុំ ពោជ្ឈង្គេ ភាវេតីតិ លហុប្បញ្ញា លហុំ លហុំ អរិយមគ្គំ ភាវេតីតិ លហុប្បញ្ញា លហុំ លហុំ សាមញ្ញផលានិ សច្ឆិករោតីតិ លហុប្បញ្ញា លហុំ លហុំ អភិញ្ញាយោ បដិវិជ្ឈតីតិ លហុប្បញ្ញា លហុំ លហុំ បរមដ្ឋំ និព្វានំ សច្ឆិករោតីតិ លហុប្បញ្ញា លហុប្បញ្ញតាយ សំវត្តន្តីតិ អយំ លហុប្បញ្ញា ។

[១៤៥] ហាសប្បញ្ញតាយ សំវត្តន្តីតិ កតមា ហាសប្បញ្ញា ។ ឥធេកច្ចោ ហាសពហុលោ វេទពហុលោ តុដ្ឋិពហុលោ បាមុជ្ជពហុលោ

ឈ្មោះថាបញ្ញារហ័ស ព្រោះចាក់ធ្លុះនូវអរិយសច្ច រហ័ស ។ ឈ្មោះថាបញ្ញារហ័ស ព្រោះញ៉ាំងសតិប្បដ្ឋានឲ្យចម្រើនរហ័ស ។ ឈ្មោះថាបញ្ញារហ័ស ព្រោះញ៉ាំងសម្មប្បធានឲ្យចម្រើនរហ័ស ។ ឈ្មោះថាបញ្ញារហ័ស ព្រោះញ៉ាំងឥទ្ធិបាទឲ្យចម្រើនរហ័ស ។ ឈ្មោះថាបញ្ញារហ័ស ព្រោះញ៉ាំងឥន្ទ្រិយឲ្យចម្រើនរហ័ស ។ ឈ្មោះថាបញ្ញារហ័ស ព្រោះញ៉ាំងពលៈឲ្យចម្រើនរហ័ស ។ ឈ្មោះថាបញ្ញារហ័ស ព្រោះញ៉ាំងពោជ្ឈង្គឲ្យចម្រើនរហ័ស ។ ឈ្មោះថាបញ្ញារហ័ស ព្រោះញ៉ាំងអរិយមគ្គ ឲ្យចម្រើនរហ័ស ។ ឈ្មោះថាបញ្ញារហ័ស ព្រោះធ្វើឲ្យជាក់ច្បាស់ នូវសាមញ្ញផល រហ័ស ។ ឈ្មោះថាបញ្ញារហ័ស ព្រោះចាក់ធ្លុះនូវអភិញ្ញា រហ័ស ។ ឈ្មោះថាបញ្ញារហ័ស ព្រោះធ្វើឲ្យជាក់ច្បាស់ នូវប្រយោជន៍ដ៏ក្រៃលែង គឺព្រះនិព្វានរហ័ស ។ ។ នេះឯង បញ្ញារហ័ស ក្នុងពាក្យថា ប្រព្រឹត្តទៅ ដើម្បីភាពនៃប្រាជ្ញារហ័ស ។

[១៤៩] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញានាំឲ្យរីករាយ តើបញ្ញានាំឲ្យរីករាយ ដូចម្តេច ។ ឈ្មោះថាបញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលពួកខ្លះ ក្នុងលោកនេះ ច្រើនដោយសេចក្តីរីករាយ ច្រើនដោយសេចក្តីស្រស់ស្រាយ ច្រើនដោយសេចក្តីត្រេកអរ ច្រើនដោយសេចក្តីស្រួលចិត្ត

សីលានិ បរិបូរេតីតិ ហាសបញ្ញា ហាសពហុ-
លោ វេទពហុលោ តុដ្ឋិពហុលោ ចាមុជ្ជពហុលោ
ឥន្ទ្រិយសំវរំ បរិបូរេតីតិ ហាសបញ្ញា ហាសពហុ-
លោ វេទពហុលោ តុដ្ឋិពហុលោ ចាមុជ្ជពហុលោ
ភោជនេ មត្តញ្ញុតំ បរិបូរេតីតិ ហាសបញ្ញា
ហាសពហុលោ វេទពហុលោ តុដ្ឋិពហុលោ ចា-
មុជ្ជពហុលោ ជាគរិយានុយោគំ បរិបូរេតីតិ ហា-
សបញ្ញា ហាសពហុលោ វេទពហុលោ តុដ្ឋិ-
ពហុលោ ចាមុជ្ជពហុលោ សីលក្ខន្ធំ ។ បេ ។
សមាធិក្ខន្ធំ បញ្ញាខន្ធំ វិមុត្តិក្ខន្ធំ វិមុត្តិញ្ញាណទ-
ស្សនក្ខន្ធំ បរិបូរេតីតិ ហាសបញ្ញា ហានាហានានិ
បដិវិជ្ឈតីតិ វិហារសមាបត្តិយោ បរិបូរេតីតិ អរិយ-
សច្ចានិ បដិវិជ្ឈតីតិ សតិប្បដ្ឋានេ ភាវេតីតិ

រមែងញុំាងសីលឲ្យពេញលេញ ឈ្មោះថាបញ្ញា នាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្តីរីករាយ ច្រើនដោយសេចក្តីស្រស់ស្រាយ ច្រើនដោយសេចក្តីត្រេកអរ ច្រើនដោយសេចក្តីស្រួលចិត្ត រមែងញុំាងឥន្ទ្រិយសំវរៈឲ្យពេញលេញ ឈ្មោះថាបញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្តីរីករាយ ច្រើនដោយសេចក្តីស្រស់ស្រាយ ច្រើនដោយការត្រេកអរ ច្រើនដោយការស្រួលចិត្ត រមែងញុំាងសេចក្តីដឹងប្រមាណក្នុងភោជនឲ្យពេញលេញ ឈ្មោះថាបញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្តីរីករាយ ច្រើនដោយសេចក្តីស្រស់ស្រាយ ច្រើនដោយសេចក្តីត្រេកអរ ច្រើនដោយសេចក្តីស្រួលចិត្ត រមែងញុំាងសេចក្តីប្រកបរឿយ ៗ ក្នុងសេចក្តីភ្ញាក់រលឹកឲ្យពេញលេញ ឈ្មោះថាបញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយការរីករាយ ច្រើនដោយការស្រស់ស្រាយ ច្រើនដោយការត្រេកអរ ច្រើនដោយការស្រួលចិត្ត រមែងញុំាងសីលក្ខន្ធ ។ បេ ។ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញ្ញាណទស្សនក្ខន្ធឲ្យពេញលេញ ឈ្មោះថាបញ្ញានាំឲ្យរីករាយ ព្រោះចាក់ធ្លុះចំពោះនូវហេតុនិងមិនមែនហេតុ ព្រោះញុំាងវិហារសមាបត្តិ ឲ្យពេញលេញ ព្រោះចាក់ធ្លុះនូវអរិយសច្ច ព្រោះញុំាងសតិប្បដ្ឋានឲ្យចម្រើន

សម្មប្បធានេ ភាវេតីតិ ឥទ្ធិបាទេ ភាវេតីតិ ឥន្ទ្រិយានិ ភាវេតីតិ ពលានិ ភាវេតីតិ ពោជ្ឈង្គេ ភាវេតីតិ អរិយមគ្គំ ភាវេតីតិ សាមញ្ញផលានិ សច្ឆិករោតីតិ ហាសប្បញ្ញា ហាសពហុលោ វេទ-ពហុលោ តុដ្ឋិពហុលោ បាមុជ្ជពហុលោ អភិញ្ញាយោ បដិវិជ្ឈតីតិ ហាសប្បញ្ញា ហាសពហុលោ វេទ-ពហុលោ តុដ្ឋិពហុលោ បាមុជ្ជពហុលោ បរមដ្ឋំ និព្វានំ សច្ឆិករោតីតិ ហាសប្បញ្ញា ហាសប្បញ្ញ-តាយ សំវត្តន្តីតិ អយំ ហាសប្បញ្ញា ។

[១៤៦] ជវនប្បញ្ញតាយ សំវត្តន្តីតិ កតមា ជវន-ប្បញ្ញា ។ យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យន្ទូរេ សន្តិកេ វា សព្វំ រូបំ អនិច្ចតោ ខិប្បំ ជវតីតិ ជវនប្បញ្ញា ទុក្ខតោ ខិប្បំ ជវតីតិ

ព្រោះញ៉ាំងសម្មប្បធានឲ្យបម្រើន ព្រោះញ៉ាំងឥទ្ធិបាទឲ្យបម្រើន ព្រោះញ៉ាំងឥន្ទ្រិយឲ្យបម្រើន ព្រោះញ៉ាំងពលៈ ឲ្យបម្រើន ព្រោះញ៉ាំងពោជ្ឈង្គឲ្យបម្រើន ព្រោះញ៉ាំងអរិយមគ្គឲ្យបម្រើន ព្រោះធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផល ឈ្មោះថាបញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្តីរីករាយ ច្រើនដោយសេចក្តីស្រស់ស្រាយ ច្រើនដោយសេចក្តីត្រេកអរ ច្រើនដោយសេចក្តីស្រួលចិត្ត រមែងចាក់ធ្លុះនូវអភិញ្ញា ឈ្មោះថាបញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្តីរីករាយ ច្រើនដោយសេចក្តីស្រស់ស្រាយ ច្រើនដោយសេចក្តីត្រេកអរ ច្រើនដោយសេចក្តីស្រួលចិត្ត រមែងធ្វើឲ្យជាក់ច្បាស់នូវប្រយោជន៍ដ៏ក្រៃលែង គឺនិព្វាន ។ នេះឯង បញ្ញានាំឲ្យរីករាយ ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញានាំឲ្យរីករាយ ។

[១៨៦] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញា ជាគ្រឿងស្ទុះទៅ តើបញ្ញាជាគ្រឿងស្ទុះទៅ ដូចម្តេច ។ ឈ្មោះថាបញ្ញាជាគ្រឿងស្ទុះទៅ ព្រោះរូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបណាក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី បញ្ញាស្ទុះទៅឆាប់ កាន់រូបទាំងអស់នោះ ថាមិនទៀង ឈ្មោះថាបញ្ញា ជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅឆាប់ ថាជាទុក្ខ

ជវនប្បញ្ញា អនត្តតោ ខិប្បំ ជវតីតិ ជវន-
ប្បញ្ញា យា កាចិ វេទនា ។ បេ ។ យា កាចិ
សញ្ញា យេ កេចិ សង្ខារា យំ កិញ្ចិ វិញ្ញាណំ អ-
តីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ
វា សុខុមំ វា ហីនំ វា បណីតំ វា យន្ទូរេ សន្តិកេ វា
សព្វំ វិញ្ញាណំ អនិច្ចតោ ខិប្បំ ជវតីតិ ជវនប្បញ្ញា
ទុក្ខតោ ខិប្បំ ជវតីតិ ជវនប្បញ្ញា អនត្តតោ ខិ-
ប្បំ ជវតីតិ ជវនប្បញ្ញា ចក្ខុំ ។ បេ ។ ជរាមរណំ
អតីតានាគតប្បច្ចុប្បន្នំ អនិច្ចតោ ខិប្បំ ជវតីតិ ជវ-
នប្បញ្ញា ទុក្ខតោ ខិប្បំ ជវតីតិ ជវនប្បញ្ញា អនត្ត-
តោ ខិប្បំ ជវតីតិ ជវនប្បញ្ញា រូបំ អតីតានាគត-
ប្បច្ចុប្បន្នំ អនិច្ចំ ខយដ្ឋេន ទុក្ខំ ភយដ្ឋេន អនត្តា
អសារកដ្ឋេនាតិ តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ
កត្វា រូបនិរោធេ និព្វានេ ខិប្បំ ជវតីតិ ជវនប្បញ្ញា
វេទនា សញ្ញា សង្ខារា វិញ្ញាណំ ចក្ខុំ ។ បេ ។

ឈ្មោះថាបញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅឆាប់ ថាមិនមែនជារបស់ខ្លួន ឈ្មោះថាបញ្ញាជាគ្រឿងស្ទុះទៅ ព្រោះវេទនាណាមួយ ។ បេ ។ សញ្ញាណាមួយ សង្ខារទាំងឡាយណាមួយ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វិញ្ញាណណាមួយ ក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី បញ្ញាស្ទុះទៅឆាប់កាន់វិញ្ញាណទាំងអស់ (នោះ) ថាមិនទៀង ឈ្មោះថាបញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅឆាប់ ថាជាទុក្ខ ឈ្មោះថាបញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅឆាប់ ថាមិនមែនជារបស់ខ្លួន ឈ្មោះថាបញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅឆាប់ កាន់ចក្ខុ ។ បេ ។ កាន់ជរាមរណៈជាអតីត អនាគត បច្ចុប្បន្ន ថាមិនទៀង ឈ្មោះថាបញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅឆាប់ ថាជាទុក្ខ ឈ្មោះថាបញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅឆាប់ ថាមិនមែនជារបស់ខ្លួន ឈ្មោះថាបញ្ញាជាគ្រឿងស្ទុះទៅ ព្រោះថ្លឹងពិចារណា អប់រំ ធ្វើឲ្យជាក់ច្បាស់ថា រូបជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថាមិនទៀង ដោយអត្ថថាអស់ទៅ ឈ្មោះថាជាទុក្ខ ដោយអត្ថថាជាភ័យ ឈ្មោះថាជាអនត្តា ដោយអត្ថថាគ្មានខ្លឹម ហើយស្ទុះទៅឆាប់ ក្នុងទីជាទីរលត់រូប គឺព្រះនិព្វាន ឈ្មោះថាបញ្ញាជាគ្រឿងស្ទុះទៅ ព្រោះថ្លឹង ពិចារណា អប់រំ ធ្វើឲ្យជាក់ច្បាស់ថា វេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។

ជរាមរណំ អតីតានាគតប្បច្ចុប្បន្នំ អនិច្ចំ ខយដ្ឋេន ទុក្ខំ ភយដ្ឋេន អនត្តា អសារកដ្ឋេនាតិ តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ជរាមរណនិរោធេ និព្វានេ ខិប្បំ ជវតីតិ ជវនបញ្ញា រូបំ អតីតានាគតប្បច្ចុប្បន្នំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មន្តិ តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា រូបនិរោធេ និព្វានេ ខិប្បំ ជវតីតិ ជវនបញ្ញា វេទនា សញ្ញា សង្ខារា វិញ្ញាណំ ចក្ខុំ ។ បេ ។ ជរាមរណំ អតីតានាគតប្បច្ចុប្បន្នំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មន្តិ តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ជរាមរណនិរោធេ និព្វានេ ខិប្បំ ជវតីតិ ជវនបញ្ញា ជវនបញ្ញតាយ សំវត្តន្តីតិ អយំ ជវនបញ្ញា ។

ជរាមរណៈ ជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថាមិនទៀង ដោយអត្ថថាអស់ទៅ ឈ្មោះថាជាទុក្ខ ដោយអត្ថថាជាភ័យ ឈ្មោះថាជាអនត្តា ដោយអត្ថថាមិនមានខ្លឹម ហើយស្ទុះទៅឆាប់ ក្នុងទីជាទីរលត់នូវជរាមរណៈ គឺព្រះនិព្វាន ឈ្មោះថាបញ្ញាជាគ្រឿងស្ទុះទៅ ព្រោះថ្លឹង ពិចារណា អប់រំ ធ្វើឲ្យជាក់ច្បាស់ថា រូបជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថាមិនទៀង មានបច្ច័យតាក់តែង អាស្រ័យនូវបច្ច័យហើយកើតឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការប្រាសចាករាគៈជាធម្មតា មានការរលត់ជាធម្មតា ហើយស្ទុះទៅឆាប់ក្នុងទីជាទីរលត់រូប គឺព្រះនិព្វាន ឈ្មោះថាបញ្ញាជាគ្រឿងស្ទុះទៅ ព្រោះថ្លឹង ពិចារណា អប់រំ ធ្វើឲ្យជាក់ច្បាស់ថា វេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ ជរាមរណៈ ជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថាមិនទៀង មានបច្ច័យប្រជុំតាក់តែង អាស្រ័យនូវបច្ច័យហើយកើតឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការប្រាសចាករាគៈជាធម្មតា មានការរលត់ជាធម្មតា ហើយស្ទុះឆាប់ក្នុងទីជាទីរលត់ជរាមរណៈ គឺព្រះនិព្វាន នេះឯង បញ្ញាជាគ្រឿងស្ទុះទៅ ក្នុងពាក្យថា ប្រព្រឹត្តទៅ ដើម្បីភាពនៃបញ្ញាជាគ្រឿងស្ទុះទៅ ។

[១៤៧] តិក្ខប្បញ្ញាតាយ សំវត្តន្តីតិ កាតមា តិក្ខប្បញ្ញា ។ ខិប្បំ កិលេសេ ភិន្ទតីតិ[១] តិក្ខប្បញ្ញា ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ[២] អនភាវង្គមេតីតិ តិក្ខប្បញ្ញា ឧប្បន្នំ ព្យាបាទវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតីតិ តិក្ខប្បញ្ញា ឧប្បន្នំ វិហឹសាវិតក្កំ នាធិវាសេតិ ។ បេ ។ ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតីតិ តិក្ខប្បញ្ញា ឧប្បន្នំ រាគំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតីតិ តិក្ខប្បញ្ញា ឧប្បន្នំ ទោសំ ។ បេ ។ ឧប្បន្នំ មោហំ ឧប្បន្នំ កោធំ ឧបនាហំ មក្ខំ បឡាសំ ឥស្សំ មច្ឆរិយំ មាយំ សាឋេយ្យំ ថម្ភំ សារម្ភំ មានំ អតិមានំ មទំ

១ ឱ.ម. ឆិន្ទតីតិ ។ ២ ម. ព្យន្តីករោតិ ។

[១៤៧] ពាក្យថា ប្រព្រឹត្តទៅ ដើម្បីភាពនៃបញ្ញាដ៏មុត តើបញ្ញាដ៏មុត ដូចម្តេច ។ ឈ្មោះថា បញ្ញាដ៏មុត ព្រោះទម្លាយនូវកិលេសរហ័ស ឈ្មោះថាបញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកាមវិតក្កៈដែលកើតឡើងហើយ ឈ្មោះថាបញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវព្យាបាទវិតក្កៈ ដែលកើតឡើងហើយ ឈ្មោះថាបញ្ញាដ៏មុត ព្រោះមិនទទួល នូវវិហឹសាវិតក្កៈ ដែលកើតឡើងហើយ ។ បេ ។ ឈ្មោះថាបញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវអកុសលធម៌ ដ៏លាមកដែលកើតឡើងហើយ ឈ្មោះថាបញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវរាគៈដែលកើតឡើងហើយ ឈ្មោះថាបញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវទោសៈ ដែលកើតឡើងហើយ ។ បេ ។ នូវមោហៈ ដែលកើតឡើងហើយ នូវសេចក្តីក្រោធដែលកើតឡើងហើយ នូវការចងសេចក្តីក្រោធទុក ការលុបគុណគេ ការវាយឫកស្មើ ឫស្យា ការកំណាញ់ ការលាក់ពុត ការអួតអាង ការរឹងត្អឹង ការប្រណាំងប្រជែង ការប្រកាន់ ការមើលងាយ ការស្រវឹង

បមាទំ សព្វេ កិលេសេ សព្វេ ទុច្ចរិតេ សព្វេ អភិសង្ខារេ ។ បេ ។ សព្វេ ភវគាមិកម្មេ ជាជិវា-សេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គ-មេតីតិ តិក្ខប្បញ្ញា ឯកម្ហិ អាសនេ ចត្តារោ ច អ-រិយមគ្គា ចត្តារិ ច សាមញ្ញផលានិ ចតស្សោ ច បដិសម្ភិទាយោ ច ឆ អភិញ្ញាយោ អធិគតា ហោន្តិ សច្ឆិកតា ផស្សិតា បញ្ញាយាតិ តិក្ខប្បញ្ញា តិក្ខ-ប្បញ្ញតាយ សំវត្តន្តីតិ អយំ តិក្ខប្បញ្ញា ។

[១៤៨] និព្វេធិកប្បញ្ញតាយ សំវត្តន្តីតិ កតមា និព្វេធិកប្បញ្ញា ។ ឥធេកច្ចោ សព្វសង្ខារេសុ ឧព្វេគពហុលោ ហោតិ ឧត្តាសពហុលោ ឧក្ក-ណ្ឋានពហុលោ ហោតិ អរតិពហុលោ អនភិរ-តិពហុលោ ពហិមុខោ ន រមតិ សព្វសង្ខារេ អនិព្វិទ្ធបុព្វំ អប្បទាលិតបុព្វំ លោភក្ខន្ធំ និព្វិ-ជ្ឈតិ បទាលេតីតិ និព្វេធិកប្បញ្ញា អនិព្វិទ្ធបុព្វំ អប្បទាលិតបុព្វំ ទោសក្ខន្ធំ និព្វិជ្ឈតិ បទាលេតីតិ

ការប្រហែសធ្វេស កិលេសទាំងអស់ ទុច្ចរិតទាំងអស់ អភិសង្ខារទាំងអស់ ។ បេ ។ ភវគាមិកម្មទាំងអស់ ដែលកើតឡើងហើយ ឈ្មោះថាបញ្ញាដ៏មុត ព្រោះអរិយមគ្គ ៤ សាមញ្ញផល ៤ បដិសម្ភិទា ៤ និង អភិញ្ញា ៦ ជាគុណជាតិដែលបុគ្គលចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវហើយដោយប្រាជ្ញា ក្នុងអាសនៈមួយ នេះឯង បញ្ញាដ៏មុត ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏មុត ។

[១៤៨] ពាក្យថា ប្រព្រឹត្តទៅ ដើម្បីភាពនៃបញ្ញាជាគ្រឿងទម្លុះទម្លាយ តើបញ្ញាជាគ្រឿងទម្លុះទម្លាយ ដូចម្តេច ។ ឈ្មោះថាបញ្ញាជាគ្រឿងទម្លុះទម្លាយ ព្រោះបុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកច្រើនដោយសេចក្តីរន្ធត់ ច្រើនដោយសេចក្តីតក់ស្លុត ច្រើនដោយសេចក្តីអផ្សុក ច្រើនដោយសេចក្តីមិនត្រេកអរ ច្រើនដោយសេចក្តីនឿយណាយក្នុងសង្ខារទាំងពួង មានមុខងាកចេញក្រៅ មិនត្រេកអរក្នុងសង្ខារទាំង-ពួង រមែងទម្លុះទម្លាយនូវគំនរលោភៈ ដែលខ្លួនមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយហើយ ឈ្មោះថាបញ្ញាជាគ្រឿងទម្លុះទម្លាយ ព្រោះទម្លុះទម្លាយ នូវគំនរទោសៈ ដែលខ្លួនមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយហើយ

និព្វេធិកប្បញ្ញា អនិព្វិទ្ធបុព្វំ អប្បទាលិតបុព្វំ មោហក្ខន្ធំ និព្វិជ្ឈតិ បទាលេតីតិ និព្វេធិកប្បញ្ញា អនិព្វិទ្ធបុព្វំ អប្បទាលិតបុព្វំ កោធំ ។ បេ ។ ឧបនាហំ មក្ខំ បឡាសំ ឥស្សំ មច្ឆរិយំ មាយំ សាថេយ្យំ ថម្ភំ សារម្ភំ មានំ អតិមានំ មទំ បមាទំ សព្វេ កិលេសេ សព្វេ ទុច្ចរិតេ សព្វេ អភិសង្ខារេ ។ បេ ។ សព្វេ ភវគាមិកម្មេ និព្វិជ្ឈតិ បទាលេតីតិ និព្វេធិកប្បញ្ញា និព្វេធិកប្បញ្ញតាយ សំវត្តន្តីតិ អយំ និព្វេធិកប្បញ្ញា ឥមា សោឡស បញ្ញាយោ ។

[១៨៩] ឥមាហិ សោឡសហិ បញ្ញាហិ សមន្នាគតោ បុគ្គលោ បដិសម្ភិទប្បត្តោ ។ ទ្វេ បុគ្គលា បដិសម្ភិទប្បត្តា ឯកោ បុព្វយោគសម្បន្នោ ឯកោ ន បុព្វយោគសម្បន្នោ យោ បុព្វយោគសម្បន្នោ សោ តេន អតិរេកោ ហោតិ អធិកោ ហោតិ វិសេសោ ហោតិ តស្ស ញាណំ បភិជ្ជតីតិ ទ្វេ បុគ្គលា បដិសម្ភិទប្បត្តា ទ្វេបិ បុព្វយោគសម្បន្នា

ឈ្មោះថាបញ្ញាជាគ្រឿងទម្លុះទម្លាយ ព្រោះទម្លុះទម្លាយ នូវគំនរមោហៈ ដែលខ្លួនមិនធ្លាប់ទម្លុះមិនធ្លាប់ទម្លាយហើយ ឈ្មោះថាបញ្ញាជាគ្រឿងទម្លុះទម្លាយ ព្រោះទម្លុះទម្លាយនូវក្រោធ ។ បេ ។ នូវការចងក្រោធទុក ការលុបគុណគេ ការវាយឫកស្មើ ឫស្យា កំណាញ់ ការលាក់ពុត ការអួតអាង ការរឹងត្អឹង ការប្រណាំងប្រជែង ការប្រកាន់ ការមើលងាយ ការស្រវឹង ការប្រហែសធ្វេស កិលេសទាំងអស់ ទុច្ចរិតទាំងអស់ អភិសង្ខារទាំងអស់ ។ បេ ។ ភវគាមិកម្មទាំងអស់ ដែលខ្លួនមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយហើយ នេះបញ្ញាជាគ្រឿងទម្លុះទម្លាយ ក្នុងពាក្យថា ប្រព្រឹត្តទៅ ដើម្បីភាពនៃបញ្ញាជាគ្រឿងទម្លុះទម្លាយ នេះ បញ្ញា ១៦ ។

[១៤៩] បុគ្គលប្រកបដោយប្រាជ្ញាទាំង ១៦ នេះ ឈ្មោះថាអ្នកដល់នូវបដិសម្ភិទា ។ បុគ្គលអ្នកដល់នូវបដិសម្ភិទា មាន២ ពួក គឺពួកមួយ បរិបូណ៌ដោយបុព្វយោគ (ការប្រកបក្នុងកាលមុន) ពួកមួយ មិនបរិបូណ៌ដោយបុព្វយោគ បុគ្គលណា បរិបូណ៌ដោយបុព្វយោគ បុគ្គលនោះ ជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេស ជាងបុគ្គលមួយពួកនោះ ញាណរបស់បុគ្គលនោះ បែកធ្លាយជាង នេះបុគ្គលអ្នកដល់នូវបដិសម្ភិទា ពីរពួក ។ ឯបុគ្គលអ្នកបរិបូណ៌ដោយបុព្វយោគ មាន ២ ពួក

ឯកោ ពហុស្សុតោ ឯកោ ន ពហុស្សុតោ យោ ពហុ-
ស្សុតោ សោ តេន អតិរេកោ ហោតិ អធិកោ ហោ-
តិ វិសេសោ ហោតិ តស្ស ញាណំ បភិជ្ជតីតិ ទ្វេ
បុគ្គលា បដិសម្ភិទប្បត្តា ទ្វេបិ បុព្វយោគសម្បន្នា ទ្វេបិ
ពហុស្សុតា ឯកោ ទេសនាពហុលោ ឯកោ ន
ទេសនាពហុលោ យោ ទេសនាពហុលោ សោ តេន
អតិរេកោ ហោតិ អធិកោ ហោតិ វិសេសោ ហោ-
តិ តស្ស ញាណំ បភិជ្ជតីតិ ទ្វេ បុគ្គលា បដិស-
ម្ភិទប្បត្តា ទ្វេបិ បុព្វយោគសម្បន្នា ទ្វេបិ ពហុស្សុ-
តា ទ្វេបិ ទេសនាពហុលា ឯកោ គរូបនិស្សិតោ
ឯកោ ន គរូបនិស្សិតោ យោ គរូបនិស្សិតោ សោ
តេន អតិរេកោ ហោតិ អធិកោ ហោតិ វិសេ-
សោ ហោតិ តស្ស ញាណំ បភិជ្ជតីតិ ទ្វេ
បុគ្គលា បដិសម្ភិទប្បត្តា ទ្វេបិ បុព្វយោគស-
ម្បន្នា ទ្វេបិ ពហុស្សុតា ទ្វេបិ ទេសនាពហុលា

គឺបុគ្គលពួកមួយជាពហុស្សូត ពួកមួយមិនមែនជាពហុស្សូត បុគ្គលណា ជាពហុស្សូត បុគ្គលនោះ ជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេស ជាង់បុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះ បែកធ្លាយជាង់ នេះបុគ្គលអ្នកដល់នូវបដិសម្ភិទាពីរពួក បុគ្គលអ្នកបរិបូណ៌ដោយបុព្វយោគពីរពួក ។ ឯបុគ្គលជាពហុស្សូតមាន ២ ពួក គឺបុគ្គលពួកមួយ ជាអ្នកច្រើនដោយទេសនា ពួកមួយ ជាអ្នកមិនច្រើនដោយទេសនា បុគ្គលណា ច្រើនដោយទេសនា បុគ្គលនោះ ជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេស ជាង់បុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះ បែកធ្លាយជាង់ នេះបុគ្គលអ្នកដល់នូវបដិសម្ភិទាពីរពួក បុគ្គលអ្នកបរិបូណ៌ដោយបុព្វយោគពីរពួក បុគ្គលជាពហុស្សូតពីរពួក ។ ឯបុគ្គលអ្នកច្រើនដោយទេសនា មាន ២ ពួក គឺបុគ្គលពួកមួយ ជាអ្នកចូលទៅអាស្រ័យនឹងគ្រូ ពួកមួយ ជាអ្នកមិនចូលទៅ អាស្រ័យនឹងគ្រូ បុគ្គលណា ដែលចូលទៅអាស្រ័យនឹងគ្រូ បុគ្គលនោះ ជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេស ជាង់បុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះ បែកធ្លាយជាង់ នេះបុគ្គលអ្នកដល់នូវបដិ-សម្ភិទា ពីរពួក បុគ្គលអ្នកបរិបូណ៌ ដោយបុព្វយោគ ពីរពួក បុគ្គលជាពហុស្សូត ពីរពួក បុគ្គលអ្នកច្រើនដោយទេសនា ពីរពួក ។

ទ្វេបិ គរូបនិស្សិតា ឯកោ វិហារពហុលោ ឯកោ ន វិហារពហុលោ យោ វិហារពហុលោ សោ តេន អតិរេ-កោ ហោតិ អធិកោ ហោតិ វិសេសោ ហោតិ តស្ស ញាណំ បភិជ្ជតីតិ ទ្វេ បុគ្គលា បដិសម្ភិទប្បត្តា ទ្វេបិ បុព្វយោគសម្បន្នា ទ្វេបិ ពហុស្សុតា ទ្វេបិ ទេសនាពហុលា ទ្វេបិ គរូបនិស្សិតា ទ្វេបិ វិហារព-ហុលា ឯកោ បច្ចវេក្ខណាពហុលោ ឯកោ ន បច្ច-វេក្ខណាពហុលោ យោ បច្ចវេក្ខណាពហុលោ សោ តេន អតិរេកោ ហោតិ អធិកោ ហោតិ វិសេ-សោ ហោតិ តស្ស ញាណំ បភិជ្ជតីតិ ទ្វេ បុ-គ្គលា បដិសម្ភិទប្បត្តា ទ្វេបិ បុព្វយោគសម្បន្នា ទ្វេបិ ពហុស្សុតា ទ្វេបិ ទេសនាពហុលា ទ្វេបិ គរូបនិស្សិតា ទ្វេបិ វិហារពហុលា ទ្វេបិ បច្ច-វេក្ខណាពហុលា ឯកោ សេក្ខប្បដិសម្ភិទប្បត្តោ

ឯបុគ្គលអ្នកចូលទៅអាស្រ័យនឹងគ្រូ ក៏មាន ២ ពួក គឺ បុគ្គលពួកមួយ ជាអ្នកច្រើនដោយវិហារធម៌ ពួកមួយ ជាអ្នកមិនច្រើនដោយវិហារធម៌ បុគ្គលណា ដែលច្រើនដោយវិហារធម៌ បុគ្គលនោះ ជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេស ជាងបុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះ បែកធ្លាយជាង នេះបុគ្គលអ្នកដល់នូវបដិសម្ភិទាពីរពួក បុគ្គលអ្នកបរិបូណ៌ដោយបុព្វយោគពីរពួក បុគ្គលជាពហុស្សូត ពីរពួក បុគ្គលអ្នកច្រើនដោយទេសនាពីរពួក បុគ្គលអ្នកចូលទៅអាស្រ័យនឹងគ្រូពីរពួក ។ ឯបុគ្គលអ្នកច្រើនដោយវិហារធម៌ ក៏មាន ២ ពួក គឺពួកមួយជាអ្នកច្រើនដោយការពិចារណា ពួកមួយ ជាអ្នកមិនច្រើនដោយការពិចា-រណា បុគ្គលណាច្រើនដោយការពិចារណា បុគ្គលនោះ ជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេស ជាងបុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះ បែកធ្លាយជាង នេះបុគ្គលអ្នកដល់នូវបដិសម្ភិទាពីរពួក បុគ្គលអ្នកបរិបូណ៌ ដោយបុព្វយោគពីរពួក បុគ្គលជាពហុស្សូតពីរពួក បុគ្គលអ្នកច្រើនដោយទេសនាពីរពួក បុគ្គលចូលទៅអាស្រ័យនឹងគ្រូពីរពួក បុគ្គលច្រើនដោយវិហារធម៌ពីរពួក ។ ឯបុគ្គលច្រើនដោយការពិចារណាក៏មាន ២ ពួក គឺពួកមួយ ជាអ្នកដល់នូវសេក្ខប្បដិសម្ភិទា

ឯកោ អសេក្ខប្បដិសម្ភិទប្បត្តោ យោ អសេក្ខប្ប-
ដិសម្ភិទប្បត្តោ សោ តេន អតិរេកោ ហោតិ អធិកោ
ហោតិ វិសេសោ ហោតិ តស្ស ញាណំ បភិជ្ជតីតិ ទ្វេ
បុគ្គលា បដិសម្ភិទប្បត្តា ទ្វេបិ បុព្វយោគសម្បន្នា
ទ្វេបិ ពហុស្សុតា ទ្វេបិ ទេសនាពហុលា ទ្វេបិ គរុបនិ-
ស្សិតា ទ្វេបិ វិហារពហុលា ទ្វេបិ បច្ចវេក្ខណាពហុ-
លា ទ្វេបិ អសេក្ខប្បដិសម្ភិទប្បត្តា ឯកោ សាវក-
ចារមិប្បត្តោ ឯកោ ន សាវកចារមិប្បត្តោ យោ សា-
វកចារមិប្បត្តោ សោ តេន អតិរេកោ ហោតិ អធិ-
កោ ហោតិ វិសេសោ ហោតិ តស្ស ញាណំ បភិជ្ជ-
តីតិ ទ្វេ បុគ្គលា បដិសម្ភិទប្បត្តា ទ្វេបិ បុព្វយោគ-
សម្បន្នា ទ្វេបិ ពហុស្សុតា ទ្វេបិ ទេសនាពហុលា
ទ្វេបិ គរុបនិស្សិតា ទ្វេបិ វិហារពហុលា ទ្វេបិ
បច្ចវេក្ខណាពហុលា ទ្វេបិ អសេក្ខប្បដិសម្ភិទប្បត្តា
ឯកោ សាវកចារមិប្បត្តោ ឯកោ បច្ចេកសម្ពុទ្ធោ

ពួកមួយ ជាអ្នកដល់នូវអសេក្ខប្បដិសម្ភិទា បុគ្គលណាដែលដល់នូវអសេ-ក្ខប្បដិសម្ភិទា បុគ្គលពួកនោះ ជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេស ជាធំបុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះ បែកធ្លាយជាធំ នេះបុគ្គលអ្នកដល់នូវបដិសម្ភិទាពីរពួក បុគ្គលបរិបូណ៌ ដោយបុព្វយោគពីរពួក បុគ្គលជាពហុស្សូតពីរពួក បុគ្គលអ្នកច្រើនដោយទេសនាពីរពួក បុគ្គលអ្នកចូលទៅអាស្រ័យនឹងគ្រូពីរពួក បុគ្គលអ្នកច្រើនដោយវិហារធម៌ពីរពួក បុគ្គលអ្នកច្រើនដោយការពិចារណាពីរពួក ។ ឯបុគ្គលដែលដល់នូវអសេក្ខប្បដិសម្ភិទាមាន ២ ពួក គឺពួកមួយ ដល់នូវសាវកបារមី ពួកមួយមិនដល់នូវសាវកបារមី បុគ្គលណាដល់នូវសាវកបារមី បុគ្គលនោះ ជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេស ជាធំបុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះ បែកធ្លាយជាធំ នេះបុគ្គលអ្នកដល់នូវបដិសម្ភិទាពីរពួក បុគ្គលអ្នកបរិបូណ៌ ដោយបុព្វយោគពីរពួក បុគ្គលជាពហុស្សូតពីរពួក បុគ្គលអ្នកច្រើនដោយទេសនាពីរពួក បុគ្គលអ្នកចូលទៅអាស្រ័យនឹងគ្រូពីរពួក បុគ្គលអ្នកច្រើនដោយវិហារធម៌ពីរពួក បុគ្គលអ្នកច្រើនដោយការពិចារណាពីរពួក ។ ឯបុគ្គលអ្នកដល់នូវអសេក្ខប្បដិសម្ភិទាមាន ២ ពួក គឺពួកមួយ ជាអ្នកដល់នូវសាវកបារមី ពួកមួយជាបច្ចេកសម្ពុទ្ធ

យោ បច្ចេកសម្ពុទ្ធោ សោ តេន អតិរេកោ ហោតិ អធិកោ ហោតិ វិសេសោ ហោតិ តស្ស ញាណំ បភិន្នំ តីតិ បច្ចេកពុទ្ធញ្ច សទេវកញ្ច លោកំ ឧបាទាយ តថាគតោ អរហំ សម្មាសម្ពុទ្ធោ អគ្គោ បដិសម្ភិទប្បត្តោ បញ្ញាបភេទកុសលោ បភិន្ន-ញាណោ អធិគតប្បដិសម្ភិទោ ចតុវេសារជ្ជប្បត្តោ ទសពលធារី បុរិសាសភោ បុរិសសីហោ ។ បេ ។ យេបិ តេ ខត្តិយបណ្ឌិតា ព្រាហ្មណបណ្ឌិតា គហ-បតិបណ្ឌិតា សមណបណ្ឌិតា និបុណា កតបរប្ប-វាទា វាលវេធិរូបា តេ ភិន្ទន្តា មញ្ញេ ចរន្តិ បញ្ញាគ-តេន ទិដ្ឋិគតានិ តេ បញ្ហញ្ច អភិសង្ខរិត្វា តថា-គតំ ឧបសង្កមិត្វា បុច្ឆន្តិ គុឡ្ហានិ ច បដិច្ឆន្នានិ ច កថិតា វិស្សជ្ជិតា ច តេ បញ្ហា ភគវតា ហោន្តិ និទ្ទិដ្ឋការណា ឧបក្ខិត្តកា ច តេ ភគវតោ សម្ប-ជ្ជន្តិ អថ ខោ ភគវា តត្ថ អតិរោចតិ យទិទំ បញ្ញា-យាតិ អគ្គោ បដិសម្ភិទប្បត្តោតិ ។

មហាបញ្ញាកថា ។

---

បុគ្គលណាជាបច្ចេកសម្ពុទ្ធ បុគ្គលនោះ ជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេស ជាងបុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះ បែកធ្លាយជាង ហេតុនោះ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ប្រៀបធៀបនឹងព្រះបច្ចេកពុទ្ធផង នឹងមនុស្សលោកព្រមទាំងទេវលោកផង ព្រះអង្គជាបុគ្គលប្រសើរ ដល់នូវបដិសម្ភិទា ឈ្លាសក្នុងប្រភេទនៃប្រាជ្ញា មានព្រះញាណបែកធ្លាយហើយ បានសម្រេចនូវបដិសម្ភិទា ដល់នូវចតុវេសារជ្ជញ្ញាណ ទ្រទ្រង់នូវកម្លាំង ១០ ជាបុរសអាសភៈ ជាបុរសសីហៈ ។ បេ ។ ពួកជនណា ជាខត្តិយបណ្ឌិត ជាព្រាហ្មណបណ្ឌិត ជាគហបតិបណ្ឌិត ជាសមណបណ្ឌិតដែលមានប្រាជ្ញាល្អិត ស្គាល់បរប្បវាទ មានសភាពដូចនាយខ្មាន់ធ្នូអ្នកបាញ់នូវរោម ពួកជនទាំងនោះហាក់ដូចជាទម្លាយនូវទិដ្ឋិ (របស់ជនដទៃ) ដោយប្រាជ្ញា (របស់ខ្លួន) ពួកជនទាំងនោះ បានចងក្រងនូវប្រស្នាហើយ ចូលទៅគាល់ព្រះតថាគត ហើយសួរនូវអាថ៌ដែលគេលាក់ផង ដែលកំបាំងផង ប្រស្នាទាំងនោះ ព្រះតថាគតក៏បានសម្តែងដោះស្រាយហើយផង ជាប្រស្នាមានហេតុដែលព្រះអង្គអធិប្បាយហើយផង ជាប្រស្នាដែលព្រះអង្គលើកបង្ហាញហើយផង ពួកជនទាំងនោះ បានសម្រេច (សម្បត្តិជា សាវ័កឬជាឧបាសក ដោយការដោះស្រាយ) របស់ព្រះមានព្រះភាគ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់រុងរឿងក្រៃលែងក្នុងទីនោះ ដោយប្រាជ្ញា ហេតុនោះ ព្រះមានព្រះភាគព្រះអង្គប្រសើរ ទ្រង់ដល់នូវបដិសម្ភិទា ។

ចប់ មហាបញ្ញាកថា ។

# បញ្ញាវគ្គេ ឥទ្ធិកថា

[១៨០] កា ឥទ្ធិ កតិ ឥទ្ធិយោ ឥទ្ធិយា កតិ ភូមិយោ កតិ បាទា កតិ បទានិ កតិ មូលានិ ។

កា ឥទ្ធីតិ ឥជ្ឈនដ្ឋេន ឥទ្ធិ ។ កតិ ឥទ្ធិយោតិ ទស ឥទ្ធិយោ ។ ឥទ្ធិយា ចតស្សោ ភូមិយោ ចត្តារោ បាទា អដ្ឋ បទានិ សោឡស មូលានិ ។

[១៨១] កតមា ទស ឥទ្ធិយោ ។ អធិដ្ឋានា ឥទ្ធិ វិកុព្វនា ឥទ្ធិ មនោមយា ឥទ្ធិ ញាណវិប្ផារា ឥទ្ធិ សមាធិវិប្ផារា ឥទ្ធិ អរិយា ឥទ្ធិ កម្មវិបាកជា ឥទ្ធិ បុញ្ញវតោ ឥទ្ធិ វិជ្ជាមយា ឥទ្ធិ តត្ថ តត្ថ សម្មប្បយោគប្បច្ចយា[១] ឥជ្ឈនដ្ឋេន ឥទ្ធិ ។

[១៨២] ឥទ្ធិយា កតមា ចតស្សោ ភូមិយោ ។ វិវេកជា ភូមិ បឋមជ្ឈានំ បីតិសុខភូមិ ទុតិយជ្ឈានំ ឧបេក្ខាសុខភូមិ តតិយជ្ឈានំ អទុក្ខមសុខភូមិ

---

១ ឱ. ម. សម្មាបយោគប្បច្ចយា ។

# បញ្ញាវគ្គ ឥទ្ធិកថា

[១៥០] ឫទ្ធិ ប្រែថាដូចម្តេច ឫទ្ធិ មានប៉ុន្មាន ឫទ្ធិ មានភូមិប៉ុន្មាន មានបាទប៉ុន្មាន មានបទប៉ុន្មាន មានមូលប៉ុន្មាន ។

ត្រង់សំណួរថា ឫទ្ធិ ប្រែថាដូចម្តេច ចម្លើយថា ឫទ្ធិ ប្រែថាការសម្រេច ។ ត្រង់សំណួរថា ឫទ្ធិ មានប៉ុន្មាន ចម្លើយថា ឫទ្ធិ មាន ១០ ។ ឫទ្ធិ មានភូមិ ៤ មានបាទ ៤ មានបទ ៨ មានមូល ១៦ ។

[១៥១] ឫទ្ធិ ១០ តើដូចម្តេច ។ ឫទ្ធិ គឺការអធិដ្ឋាន (អធិដ្ឋានឥទ្ធិ) ១ ឫទ្ធិ គឺការធ្វើឲ្យប្លែក (វិកុព្វនឥទ្ធិ) ១ ឫទ្ធិ សម្រេចអំពីចិត្ត (មនោមយឥទ្ធិ) ១ ឫទ្ធិ គឺការផ្សាយចេញនៃញាណ (ញាណវិប្ផារឥទ្ធិ) ១ ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ (សមាធិវិប្ផារឥទ្ធិ) ១ ឫទ្ធិ គឺភាពអ្នកខ្ពង់ខ្ពស់ (អរិយឥទ្ធិ) ១ ឫទ្ធិ កើតអំពីផលកម្ម (កម្មវិបាកជឥទ្ធិ) ១ ឫទ្ធិរបស់បុគ្គលអ្នកមានបុណ្យ (បុញ្ញវន្តឥទ្ធិ) ១ ឫទ្ធិសម្រេចអំពីវិជ្ជា (វិជ្ជាមយឥទ្ធិ) ១ ឫទ្ធិ ដោយអត្ថថាសម្រេច ព្រោះបច្ច័យនៃការប្រកបត្រូវក្នុងកិច្ចនោះៗ (ឥជ្ឈនដ្ឋឥទ្ធិ) ១ ។

[១៥២] ឫទ្ធិមានភូមិ ៤ តើដូចម្តេច ។ ភូមិជាទីកើតនៃវិវេក គឺបឋមជ្ឈាន ១ ភូមិជាទីកើតនៃបីតិនិងសុខៈ គឺទុតិយជ្ឈាន ១ ភូមិជាទីកើតនៃឧបេក្ខានិងសុខៈ គឺតតិយជ្ឈាន ១ ភូមិជាទីកើតនៃវេទនាមិនទុក្ខមិនសុខ

ចតុត្ថជ្ឈានំ ឥទ្ធិយា ឥមា ចតស្សោ ភូមិយោ ឥទ្ធិ-
លាភាយ ឥទ្ធិប្បដិលាភាយ ឥទ្ធិវិកុព្វនាយ ឥទ្ធិវិ-
សវិតាយ ឥទ្ធិវសីភាវាយ ឥទ្ធិវេសារជ្ជាយ សំវត្តន្តីតិ ។

[១៨៣] ឥទ្ធិយា កតមេ ចត្តារោ បាទា ។
ឥធ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបា-
ទំ ភាវេតិ វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិ-
បាទំ ភាវេតិ ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥ-
ទ្ធិបាទំ ភាវេតិ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ
ឥទ្ធិបាទំ ភាវេតិ ឥទ្ធិយា ឥមេ ចត្តារោ បាទា ឥទ្ធិ-
លាភាយ ឥទ្ធិប្បដិលាភាយ ឥទ្ធិវិកុព្វនាយ ឥទ្ធិវិស-
វិតាយ ឥទ្ធិវសីភាវាយ ឥទ្ធិវេសារជ្ជាយ សំវត្តន្តីតិ ។

[១៨៤] ឥទ្ធិយា កតមានិ អដ្ឋ បទានិ ។ ឆន្ទ-
ញ្ចេ ភិក្ខុ និស្សាយ លភតិ សមាធឹ លភតិ
ចិត្តស្ស ឯកគ្គតំ ឆន្ទោ ន សមាធិ សមាធិ
ន ឆន្ទោ អញ្ញោ ឆន្ទោ អញ្ញោ សមាធិ វីរិយ-
ញ្ចេ ភិក្ខុ និស្សាយ លភតិ សមាធឹ លភតិ

គឺចតុត្ថជ្ឈាន ១ នេះឯងភូមិទាំង ៤ របស់ឫទ្ធិ ប្រព្រឹត្តទៅ ដើម្បីបាននូវឫទ្ធិ ដើម្បីបានចំពោះនូវឫទ្ធិ ដើម្បីការធ្វើឲ្យប្លែកនៃឫទ្ធិ ដើម្បីបង្វែរទៅនៃឫទ្ធិ ដើម្បីភាពនៃការស្ទាត់ក្នុងឫទ្ធិ ដើម្បីសេចក្តីក្លៀវក្លាក្នុងឫទ្ធិ ។

[១៩៣] ឫទ្ធិ មានបាទ ៤ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើន នូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ១ ចម្រើនឥទ្ធិ-បាទ ប្រកបដោយចិត្តសមាធិនិងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ នេះឯងបាទទាំង ៤ របស់ឫទ្ធិ ប្រព្រឹត្តទៅ ដើម្បីបាននូវឫទ្ធិ ដើម្បីបានចំពោះនូវឫទ្ធិ ដើម្បីការធ្វើឲ្យប្លែកនៃឫទ្ធិ ដើម្បីបង្វែរទៅនៃឫទ្ធិ ដើម្បីភាពនៃការស្ទាត់ក្នុងឫទ្ធិ ដើម្បីសេចក្តីក្លៀវក្លាក្នុងឫទ្ធិ ។

[១៩៤] ឫទ្ធិ មានបទ ៨ តើដូចម្តេច ។ បើភិក្ខុអាស្រ័យនូវឆន្ទៈ ហើយបានសមាធិ គឺបាននូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ១ ឆន្ទៈមិនមែនសមាធិ សមាធិមិនមែនឆន្ទៈ ឆន្ទៈដោយឡែកសមាធិដោយឡែក ១ បើភិក្ខុអាស្រ័យ នូវវីរិយៈ ហើយបានសមាធិ

ចិត្តស្ស ឯកគ្គតំ វិរិយំ ន សមាធិ សមាធិ ន វិរិយំ អញ្ញំ វិរិយំ អញ្ញោ សមាធិ ចិត្តញ្ចេ ភិក្ខុ និស្សាយ លភតិ សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ ចិត្តំ ន សមាធិ សមាធិ ន ចិត្តំ អញ្ញំ ចិត្តំ អញ្ញោ សមាធិ វីមំសញ្ចេ ភិក្ខុ និស្សាយ លភតិ សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ វីមំសា ន សមាធិ សមាធិ ន វីមំសា អញ្ញា វីមំសា អញ្ញោ សមាធិ ឥទ្ធិយា ឥមានិ អដ្ឋបទានិ ឥទ្ធិលាភាយ ឥទ្ធិប្បដិលាភាយ ឥទ្ធិវិកុព្វនាយ ឥទ្ធិវិសវិតាយ ឥទ្ធិវសីភាវាយ ឥទ្ធិវេសារជ្ជាយ សំវត្តន្តីតិ ។

[១៤៤] ឥទ្ធិយា កតមានិ សោឡស មូលានិ ។ អនោនតំ ចិត្តំ កោសជ្ជេ ន ឥញ្ជតីតិ អានេញ្ជំ អនុន្នតំ ចិត្តំ ឧទ្ធច្ចេ ន ឥញ្ជតីតិ[១] អានេញ្ជំ អនភិនតំ ចិត្តំ រាគេ ន ឥញ្ជតីតិ

១ ឱ. សព្វត្ថ ន ឥជ្ឈតីតិ ទិស្សតិ ។

គឺបាននូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ១ វិរិយៈ មិនមែនសមាធិ សមាធិមិនមែនវិរិយៈ វិរិយៈដោយឡែក សមាធិដោយឡែក ១ បើភិក្ខុអាស្រ័យចិត្ត ហើយបានសមាធិ គឺបាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ ១ ចិត្តមិនមែនសមាធិ សមាធិមិនមែនចិត្ត ចិត្តដោយឡែក សមាធិដោយឡែក ១ បើភិក្ខុអាស្រ័យនូវវីមំសា ហើយបានសមាធិ គឺបាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ ១ វីមំសា មិនមែនសមាធិ សមាធិមិនមែនវីមំសា វីមំសា ដោយឡែក សមាធិដោយឡែក ១ នេះឯង បទ ៨ របស់ឫទ្ធិ ប្រព្រឹត្តទៅដើម្បីបាននូវឫទ្ធិ ដើម្បីបានចំពោះនូវឫទ្ធិ ដើម្បីការធ្វើឲ្យប្លែកនៃឫទ្ធិ ដើម្បីបង្ហូរទៅនៃឫទ្ធិ ដើម្បីភាពនៃការស្ទាត់ក្នុងឫទ្ធិ ដើម្បីសេចក្ដីក្លៀវក្លាក្នុងឫទ្ធិ ។

[១៥៥] ឫទ្ធិ មានមូល ១៦ តើដូចម្ដេច ។ ចិត្តដែលមិនទ្រោមរមែងមិនញាប់ញ័រ ក្នុងការខ្ជិលច្រអូស ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ (ទុកជាមូល) ១ ចិត្តដែលមិនប៉ោងឡើង រមែងមិនញាប់ញ័រ ក្នុងសេចក្ដីរវើរវាយ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ (ទុកជាមូល) ១ ចិត្តដែលមិនទន់ទោរ រមែងមិនញាប់ញ័រ ក្នុងរាគៈ

អានេញ្ជំ អនបនតំ ចិត្តំ ព្យាបាទេ ន ឥញ្ជតីតិ អានេ-
ញ្ជំ អនិស្សិតំ ចិត្តំ ទិដ្ឋិយា ន ឥញ្ជតីតិ អានេញ្ជំ
អប្បដិពទ្ធំ ចិត្តំ ឆន្ទរាគេ ន ឥញ្ជតីតិ អានេញ្ជំ វិប្បមុត្តំ
ចិត្តំ កាមរាគេ ន ឥញ្ជតីតិ អានេញ្ជំ វិសញ្ញុត្តំ ចិត្តំ
កិលេសេ ន ឥញ្ជតីតិ អានេញ្ជំ វិមរិយាទិកតំ ចិត្តំ
កិលេសមរិយាទេ ន ឥញ្ជតីតិ អានេញ្ជំ ឯកគ្គតំ
ចិត្តំ នានត្តក្កិលេសេ ន ឥញ្ជតីតិ អានេញ្ជំ សទ្ធាយ
បរិគ្គហិតំ ចិត្តំ អស្សទ្ធិយេ ន ឥញ្ជតីតិ អានេញ្ជំ
វីរិយេន បរិគ្គហិតំ ចិត្តំ កោសជ្ជេ ន ឥញ្ជតីតិ អា-
នេញ្ជំ សតិយា បរិគ្គហិតំ ចិត្តំ បមាទេ ន ឥញ្ជតីតិ
អានេញ្ជំ សមាធិនា បរិគ្គហិតំ ចិត្តំ ឧទ្ធច្ចេ ន ឥញ្ជតីតិ
អានេញ្ជំ បញ្ញាយ បរិគ្គហិតំ ចិត្តំ អវិជ្ជាយ ន ឥញ្ជតីតិ

ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ ១ ចិត្តដែលមិនបង្អោន រមែងមិនញាប់ញ័រក្នុងព្យាបាទ ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ ១ ចិត្តដែលមិនអាស្រ័យ រមែងមិនញាប់ញ័រក្នុងទិដ្ឋិ ហេតុនោះ ឈ្មោះថាជាចិត្តមិនញាប់ញ័រ ១ ចិត្តដែលមិនជាប់ចំពាក់ រមែងមិនញាប់ញ័រក្នុងឆន្ទរាគ ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ ១ ចិត្តដែលផុតស្រឡះ រមែងមិនញាប់ញ័រក្នុងកាមរាគ ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ ១ ចិត្តដែលគ្មានគ្រឿងប្រកប រមែងមិនញាប់ញ័រក្នុងកិលេស ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ ១ ចិត្តដែលគ្មានភ្ជឹគឹកិលេស រមែងមិនញាប់ញ័រក្នុងភ្ជឹគឹកិលេស ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានអារម្មណ៍តែមួយ រមែងមិនញាប់ញ័រ ក្នុងកិលេសមានសភាពផ្សេង ៗ ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានសទ្ធាថែរក្សា រមែងមិនញាប់ញ័រ ក្នុងវត្ថុមិនគួរជឿ ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានវីរិយៈថែរក្សា រមែងមិនញាប់ញ័រក្នុងការខ្ជិលច្រអូស ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានសតិថែរក្សា រមែងមិនញាប់ញ័រក្នុងប្រមាទ ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានសមាធិថែរក្សា រមែងមិនញាប់ញ័រ ក្នុងសេចក្តីរាយមាយ ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានបញ្ញាថែរក្សា រមែងមិនញាប់ញ័រ ក្នុងអវិជ្ជា

អានេញ្ជំ ឱភាសគតំ ចិត្តំ អវិជ្ជន្ធការេ ន ឥញ្ជតីតិ អានេញ្ជំ ឥទ្ធិយា ឥមានិ សោឡស មូលានិ ឥទ្ធិលាភាយ ឥទ្ធិប្បដិលាភាយ ឥទ្ធិវិកុព្វនាយ ឥទ្ធិវិសវិតាយ ឥទ្ធិវសីភាវាយ ឥទ្ធិវេសារជ្ជាយ សំវត្តន្តីតិ ។

[១៨៦] កតមា អធិដ្ឋានា ឥទ្ធិ ។ ឥធ ភិក្ខុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ បថវិយា ឧម្មុជ្ជនិម្មុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆតិ សេយ្យថាបិ បថវិយំ អាកាសេ[១] បល្លង្កេន កមតិ[២] សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរាមសតិ បរិមជ្ជតិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ[៣] ។

---

១ ឱ. ម. អាកាសេបិ ។ ២ ឱ. ម. ចង្កមតិ ។ ៣ ម. វត្តេតីតិ ។

ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ ១ ចិត្តដែលភ្លឺស្វាង រមែងមិនញាប់ញ័រក្នុងងងឹតគឺអវិជ្ជា ហេតុនោះ ឈ្មោះថាចិត្តមិនញាប់ញ័រ ១ នេះមូល ១៦ របស់ឫទ្ធិ ប្រព្រឹត្តទៅ ដើម្បីបាននូវឫទ្ធិ ដើម្បីបានចំពោះនូវឫទ្ធិ ដើម្បីធ្វើឲ្យប្លែកនូវឫទ្ធិ ដើម្បីបង្ហូរទៅនៃឫទ្ធិ ដើម្បីភាពនៃការស្ទាត់ជំនាញក្នុងឫទ្ធិ ដើម្បីសេចក្តីក្លៀវក្លាក្នុងឫទ្ធិ ។

[១៩៦] ឫទ្ធិ គឺការអធិដ្ឋាន តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះតាក់តែងនូវឫទ្ធិបានច្រើនប្រការ គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជាម្នាក់វិញក៏បាន ដើរ (ទម្លុះ) ទៅកាន់ទីវាល ទីខាងក្រៅ ទីក្រៅជញ្ជាំង ទីក្រៅកំពែង ទីក្រៅភ្នំ ឥតមានទើសទាក់ ដូចគេដើរក្នុងអាកាសក៏បាន ធ្វើនូវការងើបមុជក្នុងផែនដី ដូចគេងើបមុជក្នុងទឹកក៏បាន ដើរលើទឹកឥតមានបែកធ្លាយ ដូចគេដើរលើផែនដីក៏បាន ទៅទាំងភ្នែនក្នុងអាកាស ដូចបក្សីសកុណជាតិក៏បាន យកដៃស្ទាបអង្អែល នូវព្រះចន្ទ្រនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ញុំាងអំណាចឲ្យប្រព្រឹត្តទៅទាំងកាយ រហូតដល់ព្រហ្មលោកក៏បាន ។

ឥជាតិ ឥមិស្សា ទិដ្ឋិយា ឥមិស្សា ខន្តិយា ឥមិស្សា រុចិយា ឥមស្មឹ អាទាយេ ឥមស្មឹ ធម្មេ ឥមស្មឹ វិនយេ[១] ឥមស្មឹ ធាវចនេ ឥមស្មឹ ព្រហ្មចរិយេ ឥមស្មឹ សត្ថុសាសនេ តេន វុច្ចតិ ឥជាតិ ។

ភិក្ខូតិ បុថុជ្ជនកល្យាណកោ វា ហោតិ ភិក្ខុ សេក្ខោ វា អរហា វា អកុប្បធម្មោ ។

អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតីតិ នានប្បការ-កំ ឥទ្ធិវិធំ បច្ចនុភោតិ ។

ឯកោបិ ហុត្វា ពហុធា ហោតីតិ បកតិយា ឯកោ ពហុកំ[២] អាវជ្ជតិ សតំ វា សហស្សំ វា សតសហស្សំ វា អាវជ្ជតិ អាវជ្ជិត្វា ញាណេន អធិដ្ឋាតិ ពហុកោ ហោមីតិ ពហុកោ ហោតិ[៤] យថាយស្មា ចុល្លបន្ថកោ ឯកោបិ ហុត្វា ពហុធា ហោតិ ឯវមេវ សោ ឥទ្ធិមា ចេតោវសិប្បត្តោ ឯកោ-បិ ហុត្វា ពហុធា ហោតិ ។

---

១ ម. ឯត្តន្តរេ ឥមស្មឹ ធម្មវិនយេតិ ទិស្សតិ ។ ២ ឱ. ពហុលំ ។ ៤ ម. ពហុលោ ហោតូតិ ពហុលោ ហោតិ ។

បញ្ញាវគ្គ ឥទ្ធិកថា

ពាក្យថា ក្នុងសាសនានេះ គឺ ក្នុងទិដ្ឋិនេះ ក្នុងចំណង់នេះ ក្នុងសេចក្តីគាប់ចិត្តនេះ ក្នុងសេចក្តីពេញចិត្តនេះ ក្នុងធម៌នេះ ក្នុងវិន័យនេះ ក្នុងពាក្យជាប្រធាននេះ ក្នុងព្រហ្មចរិយៈនេះ ក្នុងសាសនានៃសាស្តានេះ ហេតុនោះ លោកពោលថា ក្នុងសាសនានេះ ។

ពាក្យថា ភិក្ខុ បានដល់ភិក្ខុ ជាកល្យាណបុថុជ្ជនក្តី ភិក្ខុជាសេក្ខៈក្តី ជាព្រះអរហន្ត មានធម៌មិនកម្រើកក្តី ។

ពាក្យថា តាក់តែងនូវឫទ្ធិ បានច្រើនប្រការ គឺតាក់តែងនូវឫទ្ធិមានប្រការផ្សេងៗ ។

ត្រង់ពាក្យថា មនុស្សម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ គឺ ភិក្ខុតែមួយរូបទេដោយប្រក្រតី តែនឹកចង់ឲ្យបានច្រើនរូប គឺនឹកចង់ឲ្យទៅជាមួយរយរូបក្តី មួយពាន់រូបក្តី មួយម៉ឺនរូបក្តី លុះនឹកចប់ហើយ ក៏អធិដ្ឋានដោយញាណថា សូមឲ្យអាត្មាអញមានរូបច្រើន ក៏បានរូបច្រើន ដូចព្រះចុល្លបន្ថកមានអាយុ សូម្បីមានរូបតែមួយ ក៏ធ្វើឲ្យបានច្រើនរូប ឯភិក្ខុដែលមានឫទ្ធិដល់នូវការស្ទាត់ជំនាញក្នុងចិត្តនោះ សូម្បីមានរូបតែមួយ ក៏ធ្វើឲ្យទៅជាច្រើនរូបបាន យ៉ាងនោះឯង ។

ពហុធាបិ ហុត្វា ឯកោ ហោតីតិ បកតិយា ពហុកោ ឯកំ អាវជ្ជតិ អាវជ្ជិត្វា ញាណេន អធិ-ដ្ឋាតិ ឯកោ ហោមីតិ(២) ឯកោ ហោតិ យថា-យស្មា ចុល្លបន្ថកោ ពហុធាបិ ហុត្វា ឯកោ ហោតិ ឯវមេវ សោ ឥទ្ធិមា ចេតោវសិប្បត្តោ ពហុធាបិ ហុត្វា ឯកោ ហោតិ ។

អាវិភាវន្តិ កេនចិ អនាវដំ ហោតិ អប្ប-ដិច្ឆន្នំ វិវដំ(៣) ។

តិរោភាវន្តិ កេនចិ អាវដំ ហោតិ បដិច្ឆន្នំ បិហិតំ បដិកុជ្ជិតំ ។

តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេតិ បកតិយា អាកា-សកសិណសមាបត្តិយា លាភី ហោតិ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អាវជ្ជតិ អាវជ្ជិត្វា ញាណេន អធិដ្ឋាតិ អាកាសោ ហោតូតិ អាកាសោ ហោតិ

២ ម. ហោតូតិ ។ ៣ ឱ.ម. ឯត្ថន្តរេ បាកដន្តិ ទិស្សតិ ។

ត្រង់ពាក្យថា មនុស្សច្រើននាក់ ធ្វើឲ្យទៅជាម្នាក់វិញ គឺ ភិក្ខុច្រើនរូប ដោយប្រក្រតី តែនឹកចង់ឲ្យទៅជាម្នាក់វិញ លុះនឹកចង់ហើយក៏អធិដ្ឋាន ដោយញាណថា សូមឲ្យអាត្មាអញមានរូបតែមួយវិញ ក៏បានរូបតែមួយ ដូចព្រះចុល្លបន្ថកមានអាយុ សូម្បីមានរូបច្រើន ក៏រួមមកតែរូបមួយវិញ ឯភិក្ខុដែលមានឫទ្ធិ ដល់នូវការស្ទាត់ជំនាញ ក្នុងចិត្តនោះ សូម្បីមានរូបច្រើន ក៏រួមមកតែរូបមួយវិញបាន យ៉ាងនោះឯង ។

ពាក្យថា ទីវាល បានដល់ទី ដែលវត្ថុអ្វីមួយមិនរាំង មិនបិទបាំងជាទីវាល ។

ពាក្យថា ទីខាងក្រៅ បានដល់ទី ដែលមានវត្ថុអ្វីមួយ រាំងបាំងបិទ គ្រប ។

ពាក្យថា ដើរ (ទម្លុះ) ទៅកាន់ទីក្រៅជញ្ជាំង ទីក្រៅកំពែងទីក្រៅភ្នំ មិនទើសទាក់ ដូចគេដើរក្នុងអាកាស គឺ ភិក្ខុអ្នកបាននូវសមាបត្តិ មានអាកាសកសិណជាអារម្មណ៍ ដោយប្រក្រតី តែងនឹកចង់ទៅ កាន់ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង ទីខាងក្រៅភ្នំ លុះនឹងចង់ហើយ ក៏អធិដ្ឋាន ដោយញាណថា សូមឲ្យប្រទេសទ្រុំះទៅជាអាកាស ទីនោះ ក៏បានទៅជាអាកាស ភិក្ខុនោះ ក៏ដើរ

សោ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ យថា មនុស្សា បកតិយា អនិទ្ធិមន្តោ កេនចិ អនាវដេ អបរិក្ខិត្តេ អសជ្ជមានា គច្ឆន្តិ ឯវមេវ សោ ឥទ្ធិមា ចេតោវសិប្បត្តោ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ ។

បឋវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ ករោតិ សេយ្យថាបិ ឧទកេតិ បកតិយា អាបោកសិណសមាបត្តិយា លាភី ហោតិ បឋវឹ អាវជ្ជតិ អាវជ្ជិត្វា ញាណេន អធិដ្ឋាតិ ឧទកំ ហោតូតិ ឧទកំ ហោតិ សោ បឋវិយា ឧម្មុជ្ជនិម្មុជ្ជំ ករោតិ យថា មនុស្សា បកតិយា អនិទ្ធិមន្តោ ឧទកេ ឧម្មុជ្ជនិម្មុជ្ជំ ករោន្តិ ឯវមេវ សោ ឥទ្ធិមា ចេតោវសិប្បត្តោ បឋវិយា ឧម្មុជ្ជនិម្មុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ ។

(ទម្លុះ) ទៅកាន់ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង ទីខាងក្រៅភ្នំ មិនទើសទាក់ ដូចពួកមនុស្សដែលមិនមានឫទ្ធិ ដោយប្រក្រតី កាលដើរទៅមិនជាប់ចំពាក់ ក្នុងទីដែលមិនមានវត្ថុអ្វីមួយ រាំង បិទបាំងឡើយ ឯភិក្ខុ ដែលមានឫទ្ធិ ដល់ហើយនូវការស្ទាត់ជំនាញ ក្នុងចិត្តនោះ តែងដើ (ទម្លុះ) ទៅកាន់ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង ទីខាងក្រៅភ្នំ មិនទើសទាក់ ដូចគេដើរទៅក្នុងអាកាស យ៉ាងនោះឯង ។

ពាក្យថា ធ្វើនូវការងើបមុជក្នុងផែនដី ដូចគេងើបមុជក្នុងទឹក គឺភិក្ខុដែលបាននូវសមាបត្តិ មានអាបោកសិណជាអារម្មណ៍ ដោយប្រក្រតីតែងនឹកចង់ដើរក្នុងដី លុះនឹកចង់ហើយក៏អធិដ្ឋាន ដោយញាណថា សូមឲ្យ (ផែនដីត្រង់ទីនេះ) ទៅជាទឹក ទីនោះក៏បានទៅជាទឹក ភិក្ខុនោះ ក៏ធ្វើនូវការងើបមុជក្នុងផែនដី ដូចពួកមនុស្សដែលមិនមានឫទ្ធិ ដោយប្រក្រតីធ្វើនូវការងើបមុជក្នុងទឹក ឯភិក្ខុដែលមានឫទ្ធិ បានដល់ហើយនូវការស្ទាត់ជំនាញក្នុងចិត្តនោះ តែងធ្វើនូវការងើបមុជក្នុងផែនដី ដូចគេងើបមុជក្នុងទឹកបាន យ៉ាងនោះឯង ។

ឧទកេបិ អភិជ្ជមានេ គច្ឆតិ សេយ្យថាបិ បឋវិយ- ន្តិ បកតិយា បឋវីកសិណសមាបត្តិយា លាភី ហោតិ ឧទកំ អាវជ្ជតិ អាវជ្ជិត្វា ញាណេន អធិដ្ឋាតិ បឋវី ហោតូតិ បឋវី ហោតិ សោ អភិជ្ជមានេ ឧទកេ គច្ឆតិ យថា មនុស្សា បកតិយា អនិទ្ធិមន្តោ អភិជ្ជមានាយ បឋវិយា គច្ឆន្តិ ឯវមេវ សោ ឥទ្ធិមា ចេតោវសិប្បត្តោ អភិជ្ជមានេ ឧទកេ គច្ឆតិ សេយ្យថាបិ បឋវិយំ ។

អាកាសេបិ បល្លង្កេន កមតិ[១] សេយ្យថាបិ បក្ខី សកុណោតិ បកតិយា បឋវីកសិណសមាបត្តិយា លាភី ហោតិ អាកាសេ អាវជ្ជតិ អាវជ្ជិត្វា ញា- ណេន អធិដ្ឋាតិ បឋវី ហោតូតិ បឋវី ហោតិ សោ អាកាសេ អន្តលិក្ខេ ចង្កមតិបិ តិដ្ឋតិបិ និសីទតិបិ សេយ្យម្បិ កប្បេតិ យថា មនុស្សា បកតិយា អនិទ្ធិម- ន្តោ បឋវិយា ចង្កមន្តិបិ តិដ្ឋន្តិបិ និសីទន្តិបិ សេយ្យម្បិ កប្បេន្តិ ឯវមេវ សោ ឥទ្ធិមា ចេតោវសិប្បត្តោ អាកាសេ អន្តលិក្ខេ ចង្កមតិបិ តិដ្ឋតិបិ និសីទតិបិ សេយ្យម្បិ កប្បេតិ សេយ្យថាបិ បក្ខី សកុណោ ។

១ ឱ. ម. ចង្កមតិ ។

ពាក្យថា ដើរលើទឹកមិនបែកធ្លាយ ដូចគេដើរលើផែនដី គឺភិក្ខុបាននូវសមាបត្តិមានបឋវីកសិណជាអារម្មណ៍ ដោយប្រក្រតី តែងនឹកចង់ដើរលើទឹក លុះនឹកចង់ហើយ ក៏អធិដ្ឋានដោយញាណថា សូមឲ្យ (ទឹកត្រង់ទីនេះ) ទៅជាផែនដី ដូច្នេះ ទឹកក៏ទៅជាផែនដី ភិក្ខុនោះ ដើទៅលើទឹកមិនបែកធ្លាយ ដូចពួកមនុស្សមិនមានឫទ្ធិ ដោយប្រក្រតី ដើរលើផែនដីមិនបែកធ្លាយ យ៉ាងណា ឯភិក្ខុដែលមានឫទ្ធិ ដល់ហើយនូវការស្ទាត់ជំនាញក្នុងចិត្តនោះ ដើរទៅលើទឹកមិនបែកធ្លាយ ដូចគេដើរលើផែនដី យ៉ាងនោះឯង ។

ពាក្យថា ទៅទាំងភ្នែនក្នុងអាកាស ដូចបក្សីសកុណជាតិ គឺ ភិក្ខុដែលបាននូវសមាបត្តិ មានបឋវីកសិណជាអារម្មណ៍ ដោយប្រក្រតី តែងនឹកចង់ដើរក្នុងអាកាស លុះនឹកចង់ហើយ ក៏អធិដ្ឋានដោយញាណថា សូមឲ្យអាកាសទៅជាផែនដី ដូច្នេះ អាកាសក៏ទៅជាផែនដី ភិក្ខុនោះ ដើរក្តី ឈរក្តី អង្គុយក្តី សិងក្តី ក្នុងអាកាសទទេបាន ដូចពួកមនុស្សដែលមិនមានឫទ្ធិ ដោយប្រក្រតី ដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី លើផែនដី យ៉ាងណា ឯភិក្ខុដែលមានឫទ្ធិ បានដល់ហើយនូវការស្ទាត់ជំនាញក្នុងចិត្តនោះ ដើរក្តី ឈរក្តី អង្គុយក្តី សិងក្តី ក្នុងអាកាសទទេ ដូចបក្សីសកុណជាតិ យ៉ាងនោះឯង ។

២៧៣



ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរាមសតិ បរិមជ្ជតីតិ ឥធ សោ ឥទ្ធិមា ចេតោវសិប្បត្តោ និសិន្នកោ វា និបន្នកោ វា ចន្ទិមសុរិយេ អាវជ្ជតិ អាវជ្ជិត្វា ញាណេន អធិដ្ឋាតិ ហត្ថបាសេ ហោតូតិ ហត្ថបាសេ ហោតិ សោ និសិន្នកោ វា និបន្នកោ វា ចន្ទិមសុរិយេ បាណិនា អាមសតិ បរាមសតិ បរិមជ្ជតិ យថា មនុស្សា បកតិយា អនិទ្ធិមន្តោ កិញ្ចិ ទេវ រូបគតំ ហត្ថបាសេ អាមសន្តិ បរាមសន្តិ បរិមជ្ជន្តិ ឯវមេវ សោ ឥទ្ធិមា ចេតោវសិប្បត្តោ និសិន្នកោ វា និបន្នកោ វា ចន្ទិមសុរិយេ បាណិនា អាមសតិ បរាមសតិ បរិមជ្ជតិ ។

យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតីតិ សចេ សោ ឥទ្ធិមា ចេតោវសិប្បត្តោ ព្រហ្មលោកំ គន្តុកាមោ ហោតិ ទូរេបិ សន្តិកេ អធិដ្ឋាតិ សន្តិកេ ហោតូតិ

ពាក្យថា យកដៃស្ទាបអង្អែល នូវព្រះចន្ទ្រនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ គឺ ភិក្ខុដែលមានឫទ្ធិក្នុងសាសនានេះ ដែលបានដល់ហើយ នូវការស្ទាត់ជំនាញក្នុងចិត្តនោះ ជាអ្នកអង្គុយ ឬសិង នឹកចង់ស្ទាបអង្អែលនូវព្រះចន្ទ្រនិងព្រះអាទិត្យ លុះនឹកចង់ហើយ ក៏អធិដ្ឋានដោយញាណថា សូមឲ្យ (ព្រះចន្ទ្រឬព្រះអាទិត្យ) មកនៅក្នុងហត្ថបាស (ព្រះចន្ទ្រឬព្រះអាទិត្យ) ក៏បានមកនៅក្នុងហត្ថបាស ភិក្ខុនោះ ជាអ្នកអង្គុយ ឬសិង យកដៃទៅពាល់ស្ទាបអង្អែល នូវព្រះចន្ទ្រនិងព្រះអាទិត្យបាន ដូចពួកមនុស្សដែលមិនមានឫទ្ធិដោយប្រក្រតី ពាល់ស្ទាបអង្អែល នូវវត្ថុអ្វីនីមួយ ជារបស់មានរូបតាំងនៅក្នុងហត្ថបាស យ៉ាងណា ឯភិក្ខុដែលមានឫទ្ធិ បានដល់ហើយនូវការស្ទាត់ជំនាញក្នុងចិត្តនោះ ជាអ្នកអង្គុយ ឬសិង យកដៃទៅពាល់ស្ទាបអង្អែល នូវព្រះចន្ទ្រនិងព្រះអាទិត្យ យ៉ាងនោះឯង ។

ពាក្យថា ញុំាងអំណាចឲ្យប្រព្រឹត្តទៅទាំងកាយ រហូតដល់ព្រហ្មលោក គឺបើភិក្ខុមានឫទ្ធិ ដែលបានសម្រេចហើយនូវការស្ទាត់ជំនាញក្នុងចិត្តនោះ មានប្រាថ្នាដើម្បីទៅកាន់ព្រហ្មលោក ក៏អធិដ្ឋាន (នូវវត្ថុ) ក្នុងទីឆ្ងាយ ឲ្យមកក្នុងទីជិតថា សូមឲ្យ (វត្ថុនោះ) មកតាំងនៅក្នុងទីជិត

សន្តិកេ ហោតិ សន្តិកេបិ ទូរេ អធិដ្ឋាតិ ទូរេ ហោតូតិ ទូរេ ហោតិ ពហុកំបិ ថោកំ[១] អធិដ្ឋាតិ ថោកំ ហោតូតិ ថោកំ ហោតិ ថោកម្បិ ពហុកំ[២] អធិដ្ឋាតិ ពហុកំ ហោតូតិ ពហុកំ ហោតិ ទិព្វេន ចក្ខុនា តស្ស ព្រហ្មុនោ រូបំ បស្សតិ ទិព្វាយ សោតធាតុយា តស្ស ព្រហ្មុនោ សទ្ទំ សុណាតិ ចេតោបរិយញ្ញាណេន តស្ស ព្រហ្មុនោ ចិត្តំ បជានាតិ សចេ សោ ឥទ្ធិមា ចេតោវសិប្បត្តោ ទិស្សមានេន កាយេន ព្រហ្មលោកំ គន្តុកាមោ ហោតិ កាយវសេន ចិត្តំ បរិណាមេតិ កាយវសេន ចិត្តំ អធិដ្ឋាតិ កាយវសេន ចិត្តំ បរិណាមេត្វា កាយវសេន ចិត្តំ អធិដ្ឋហិត្វា សុខសញ្ញញ្ច លហុសញ្ញញ្ច ឱក្កមិត្វា ទិស្សមានេន កាយេន ព្រហ្មលោកំ គច្ឆតិ សចេ សោ ឥទ្ធិមា ចេតោវសិប្បត្តោ អទិស្សមានេន កាយេន ព្រហ្មលោកំ គន្តុកាមោ ហោតិ ចិត្តវសេន កាយំ បរិណាមេតិ ចិត្តវសេន កាយំ អធិដ្ឋាតិ

---

១ ម. ថោកន្តិ ។ ២ ម. ពហុកន្តិ ។

(វត្ថុនោះ) ក៏មកតាំងនៅក្នុងទីជិតក៏បាន អធិដ្ឋាន (នូវវត្ថុ) ក្នុងទីជិតឲ្យទៅក្នុងទីឆ្ងាយថា សូមឲ្យ (វត្ថុនេះ) តាំងនៅក្នុងទីឆ្ងាយ (វត្ថុនោះ) ក៏តាំងនៅក្នុងទីឆ្ងាយក៏បាន អធិដ្ឋាននូវវត្ថុច្រើន ឲ្យទៅជាវត្ថុតិចថា សូមឲ្យវត្ថុនេះមានចំនួនតិច វត្ថុនោះក៏ទៅជាតិចក៏បាន អធិដ្ឋាននូវវត្ថុតិច ឲ្យទៅជាវត្ថុច្រើនថា សូមឲ្យវត្ថុនេះទៅជាវត្ថុច្រើន វត្ថុនោះក៏ទៅជាច្រើនក៏បាន (ភិក្ខុនោះ) ឃើញច្បាស់នូវរូបនៃព្រហ្មនោះ ដោយចក្ខុដូចជាទិព្យ ឮសំឡេងនៃព្រហ្មនោះ ដោយសោតធាតុដូចជាទិព្យ ដឹងច្បាស់នូវចិត្ត នៃព្រហ្មនោះ ដោយញាណជាគ្រឿងកំណត់នូវចិត្ត បើភិក្ខុមានឫទ្ធិ ដែលបានសម្រេចនូវការស្ទាត់ជំនាញ ក្នុងចិត្តនោះ មានប្រាថ្នាដើម្បីទៅ កាន់ព្រហ្មលោក ដោយកាយដ៏ប្រាកដ ក៏បង្អោនចិត្តទៅដោយអំណាចនៃកាយ អធិដ្ឋានចិត្ត ដោយអំណាចនៃកាយ លុះបង្អោនចិត្តទៅ ដោយអំណាចនៃកាយ អធិដ្ឋានចិត្តដោយអំណាចនៃកាយហើយ ទើបចុះទៅកាន់សុខសញ្ញាផង កាន់លហុសញ្ញាផង ហើយទៅកាន់ព្រហ្មលោក ដោយកាយដ៏ប្រាកដបាន បើភិក្ខុមានឫទ្ធិបានសម្រេច នូវការស្ទាត់ជំនាញ ក្នុងចិត្តនោះ ជាអ្នកមានប្រាថ្នាដើម្បីទៅ កាន់ព្រហ្មលោក ដោយកាយមិនប្រាកដ ក៏បង្អោនកាយទៅ ដោយអំណាចនៃចិត្ត អធិដ្ឋាននូវកាយ ដោយអំណាចនៃចិត្ត

ចិត្តវសេន កាយំ បរិណាមេត្វា ចិត្តវសេន កាយំ អធិដ្ឋហិត្វា សុខសញ្ញញ្ច លហុសញ្ញញ្ច ឱក្កមិត្វា អទិស្សមានេន កាយេន ព្រហ្មលោកំ គច្ឆតិ សោ តស្ស ព្រហ្មុនោ បុរតោ រូបំ អភិនិម្មិនាតិ មនោមយំ សព្វង្គប្បច្ចង្គំ អហីនិន្ទ្រិយំ សចេ សោ ឥទ្ធិមា ចង្កមតិ និម្មិតោបិ តត្ថ ចង្កមតិ សចេ សោ ឥទ្ធិមា តិដ្ឋតិ និម្មិតោបិ តត្ថ តិដ្ឋតិ សចេ សោ ឥទ្ធិមា និសីទតិ និម្មិតោបិ តត្ថ និសីទតិ សចេ សោ ឥទ្ធិមា សេយ្យំ កប្បេតិ និម្មិតោបិ តត្ថ សេយ្យំ កប្បេតិ សចេ សោ ឥទ្ធិមា ធូមាយតិ និម្មិតោបិ តត្ថ ធូមាយតិ សចេ សោ ឥទ្ធិមា បជ្ជលតិ និម្មិតោបិ តត្ថ បជ្ជលតិ សចេ សោ ឥទ្ធិមា ធម្មំ ភាសតិ និម្មិតោបិ តត្ថ ធម្មំ ភាសតិ សចេ សោ ឥទ្ធិមា បញ្ហំ បុច្ឆតិ និម្មិតោបិ តត្ថ បញ្ហំ បុច្ឆតិ សចេ សោ ឥទ្ធិមា បញ្ហំ បុដ្ឋោ វិស្សជ្ជេតិ និម្មិតោបិ តត្ថ បញ្ហំ បុដ្ឋោ វិស្សជ្ជេតិ

លុះបង្អោនកាយទៅ ដោយអំណាចនៃចិត្ត អធិដ្ឋាននូវកាយ ដោយអំណាចនៃចិត្តហើយ ទើបចុះកាន់សុខសញ្ញាផង កាន់លហុសញ្ញាផង ហើយទៅកាន់ព្រហ្មលោក ដោយកាយមិនប្រាកដ ភិក្ខុនោះ និម្មិតរូបខ្លួន ដែលសម្រេចអំពីចិត្ត មានអវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រិយមិនថោក ទាបនៅខាងមុខនៃព្រហ្មនោះ បើភិក្ខុមានឫទ្ធិនោះចង្ក្រម រូបនិម្មិតក៏ចង្ក្រម ក្នុងទីនោះដែរ បើភិក្ខុមានឫទ្ធិនោះឈរ រូបនិម្មិតក៏ឈរក្នុងទីនោះដែរ បើ ភិក្ខុមានឫទ្ធិនោះអង្គុយ រូបនិម្មិតនោះ ក៏អង្គុយក្នុងទីនោះដែរ បើភិក្ខុមាន ឫទ្ធិនោះសិង រូបនិម្មិតក៏សិងក្នុងទីនោះដែរ បើភិក្ខុមានឫទ្ធិនោះ បញ្ចេញ ផ្សែង រូបនិម្មិត ក៏បញ្ចេញផ្សែង ក្នុងទីនោះដែរ បើភិក្ខុមានឫទ្ធិនោះ ឆេះទៅជាភ្លើង រូបនិម្មិតក៏ឆេះទៅជាភ្លើង ក្នុងទីនោះដែរ បើភិក្ខុមាន ឫទ្ធិនោះសម្ដែងធម៌ រូបនិម្មិតក៏សម្ដែងធម៌ ក្នុងទីនោះដែរ បើភិក្ខុមាន ឫទ្ធិនោះសួរនូវប្រស្នា រូបនិម្មិតក៏សួរនូវប្រស្នា ក្នុងទីនោះដែរ បើ ភិក្ខុមានឫទ្ធិនោះ ត្រូវគេសួរប្រស្នាហើយកំពុងដោះស្រាយ រូបនិម្មិត នោះ ក៏ត្រូវគេសួរប្រស្នា ហើយកំពុងដោះស្រាយ ក្នុងទីនោះដែរ

សចេ សោ ឥទ្ធិមា តេន ព្រហ្មុនា សទ្ធឹ សន្តិដ្ឋតិ សល្លបតិ សាកច្ឆំ សមាបជ្ជតិ និម្មិតោបិ តត្ថ តេន ព្រហ្មុនា សទ្ធឹ សន្តិដ្ឋតិ សល្លបតិ សាកច្ឆំ សមាបជ្ជតិ យញ្ញទេវ(១) សោ ឥទ្ធិមា ករោតិ តន្តទេវ ហិ សោ និម្មិតោ ករោតីតិ អយំ អធិដ្ឋានា ឥទ្ធិ ។

[១៨៧] កតមា វិកុព្វនា ឥទ្ធិ ។ សិខិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អភិភូ នាម សាវកោ ព្រហ្មលោកេ ឋិតោ សហស្សីលោកធាតុំ សរេន វិញ្ញាបេសិ(២) សោ ទិស្សមានេនបិ កាយេន ធម្មំ ទេសេសិ(៣) អទិស្សមានេនបិ កាយេន ធម្មំ ទេសេសិ ទិស្សមានេនបិ ហេដ្ឋិមេន ឧបឌ្ឍកាយេន អទិស្សមានេនបិ ឧបរិមេន ឧបឌ្ឍកាយេន ធម្មំ ទេសេសិ ទិស្សមានេនបិ ឧបរិមេន ឧបឌ្ឍកាយេន អទិស្សមានេនបិ ហេដ្ឋិមេន ឧបឌ្ឍកាយេន ធម្មំ ទេសេសិ

១ ឱ. ម. ឯត្ថន្តរេ ហិសទ្ទោ ទិស្សតិ ។ ២ ឱ. វិញ្ញាបេតិ ។ ៣ ឱ. សព្វត្ថ ទេសេតីតិ ទិស្សតិ ។

បើភិក្ខុមានឫទ្ធិនោះ កំពុងឈរចរចា ធ្វើសាកច្ឆា ជាមួយព្រហ្មនោះ រូបនិម្មិតក៏ឈរចរចាធ្វើសាកច្ឆា ជាមួយនឹងព្រហ្មនោះ ក្នុងទីនោះដែរ ភិក្ខុមានឫទ្ធិនោះ ធ្វើនូវការណាបាន រូបនិម្មិតក៏ធ្វើនូវការនោះបានដែរ នេះ ឫទ្ធិ គឺការអធិដ្ឋាន ដូចសេចក្តីដែលពោលមកនេះឯង ។

[១៥៧] ឫទ្ធិ គឺការធ្វើឲ្យប្លែក តើដូចម្តេច ។ ភិក្ខុនាម អភិភូ ជាសាវ័ករបស់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមសិខី លោកឋិតនៅឰដ៏ព្រហ្មលោក អាចញ៉ាំងលោកធាតុទាំងមួយពាន់ឲ្យដឹងច្បាស់ដោយសំឡេងបាន ព្រះអភិភូនោះ មានកាយប្រាកដ សម្តែងធម៌ក៏បាន មានកាយមិនប្រាកដ សម្តែងធម៌ក៏បាន មានកាយពាក់កណ្តាលខាងក្រោមប្រាកដ សម្តែងធម៌ក៏បាន មានកាយពាក់កណ្តាលខាងលើមិនប្រាកដ សម្តែងធម៌ក៏បាន មានកាយពាក់កណ្តាលខាងលើប្រាកដ សម្តែងធម៌ក៏បាន មានកាយពាក់កណ្តាលខាងក្រោមមិនប្រាកដ សម្តែងធម៌ក៏

សោ បកតិវណ្ណំ វិជហិត្វា កុមារកវណ្ណំ វា ទស្សេតិ នាគវណ្ណំ វា ទស្សេតិ សុបណ្ណវណ្ណំ វា ទស្សេតិ យក្ខវណ្ណំ វា ទស្សេតិ អសុរវណ្ណំ វា ទស្សេតិ ឥន្ទវណ្ណំ វា ទស្សេតិ ទេវវណ្ណំ វា ទស្សេតិ ព្រហ្មវណ្ណំ វា ទស្សេតិ សមុទ្ទវណ្ណំ វា ទស្សេតិ បព្វតវណ្ណំ វា ទស្សេតិ វនវណ្ណំ វា ទស្សេតិ សីហវណ្ណំ វា ទស្សេតិ ព្យគ្ឃវណ្ណំ វា ទស្សេតិ ទីបិវណ្ណំ វា ទស្សេតិ ហត្ថឹបិ ទស្សេតិ អស្សំបិ ទស្សេតិ រថំបិ ទស្សេតិ បត្តឹបិ ទស្សេតិ វិវិធំបិ សេនាព្យូហំ ទស្សេតិ អយំ វិកុព្វនា ឥទ្ធិ ។

[១៥៨] កតមា មនោមយា ឥទ្ធិ ។ ឥធ ភិក្ខុ ឥមម្ហា កាយា អញ្ញំ កាយំ អភិនិម្មិនាតិ រូបឹ មនោមយំ សព្វង្គប្បច្ចង្គំ អហីនិន្ទ្រិយំ សេយ្យថាបិ បុរិសោ មុញ្ជម្ហា ឥសិកំ បវាហេយ្យ តស្ស ឯវមស្ស អយំ មុញ្ជោ អយំ ឥសិកា អញ្ញោ មុញ្ជោ អញ្ញា ឥសិកា មុញ្ជម្ហា ត្វេវ ឥសិកា បវាឡ្ហាតិ

បាន ព្រះអភិក្ខុនោះ លះបង់ភេទជាប្រក្រតី ហើយសំដែងភេទជាកុមារខ្លះ សម្ដែងភេទជានាគខ្លះ សម្ដែងភេទជាគ្រុឌខ្លះ សម្ដែងភេទជាយក្ខខ្លះ សម្ដែងភេទជាអសុរខ្លះ សម្ដែងភេទជាព្រះឥន្ទ្រខ្លះ សម្ដែងភេទជាទេវតាខ្លះ សម្ដែងភេទជាព្រហ្មខ្លះ សម្ដែងភេទជាសមុទ្រខ្លះ សម្ដែងភេទជាភ្នំខ្លះ សម្ដែងភេទជាព្រៃខ្លះ សម្ដែងភេទជាសីហៈខ្លះ សម្ដែងភេទជាខ្លាធំខ្លះ សម្ដែងភេទជាខ្លាដំបង់ខ្លះ សម្ដែងភេទជាដំរីខ្លះ សម្ដែងភេទជាសេះខ្លះ សម្ដែងភេទជារថខ្លះ សម្ដែងភេទជាពលថ្មើរជើងខ្លះ សម្ដែងភេទជាកងទាហានប្លែក ៗ គ្នាខ្លះ នេះ ឫទ្ធិ គឺការធ្វើឲ្យប្លែក ។

[១៥៨] ឫទ្ធិ សម្រេចអំពីចិត្ត តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ និម្មិតនូវកាយ មានរូបដែលសម្រេចអំពីចិត្ត មានអវយវៈធំតូចសព្វគ្រប់ មានឥន្ទ្រិយមិនថោកថយ ជាកាយដទៃអំពីកាយនេះ ប្រៀបដូចបុរសដកចេញ នូវបណ្ដូល អំពីស្មៅយាប្លង់ បុរសនោះ មានសេចក្ដីដឹងយ៉ាងនេះថា នេះឯងស្មៅយាប្លង់ នេះបណ្ដូល ឯស្មៅយាប្លង់ដោយឡែក បណ្ដូលដោយឡែក បណ្ដូលគេដកចេញមក អំពីស្មៅយាប្លង់ហ្នឹងឯង

សេយ្យថាបិ វា បន បុរិសោ អសឹ កោសិយា បវាហេយ្យ តស្ស ឯវមស្ស អយំ អសិ អយំ កោសិ អញ្ញោ អសិ អញ្ញា កោសិ កោសិយា ត្វេវ អសិ បវាឡ្ហតិ សេយ្យថាបិ វា បន បុរិសោ អហឹ ករណ្ឌា ឧទ្ធរេយ្យ តស្ស ឯវមស្ស អយំ អហិ(១) អយំ ករណ្ឌោ អញ្ញោ អហិ(២) អញ្ញោ ករណ្ឌោ ករណ្ឌា ត្វេវ អហិ ឧព្ភតោតិ ឯវមេវ ភិក្ខុ ឥមម្ហា កាយា អញ្ញំ កាយំ អភិនិម្មិនាតិ រូបឹ មនោមយំ សព្វង្គបច្ចង្គំ អហីនិន្ទ្រិយំ អយំ មនោមយា ឥទ្ធិ ។

[១៨៩] កតមា ញាណវិប្ផារា ឥទ្ធិ ។ អនិច្ចានុបស្សនាយ និច្ចសញ្ញាយ បហានដ្ឋោ ឥជ្ឈតីតិ ញាណវិប្ផារា ឥទ្ធិ ទុក្ខានុបស្សនាយ សុខសញ្ញាយ

---

១-២ ឱ. អសិ ។

មួយទៀត ប្រៀបដូចបុរស ហូតដាវចេញ អំពីស្រោម បុរសនោះ មានសេចក្តីដឹង យ៉ាងនេះថា នេះដាវ នេះស្រោម ឯដាវដោយឡែក ស្រោមដោយឡែក ដាវគេហូតចេញមកអំពីស្រោមហ្នឹងឯង ពុំនោះសោត ប្រៀបដូចបុរស ទាញយកពស់ចេញអំពីត្រុក បុរសនោះមានសេចក្តីដឹងយ៉ាងនេះថា នេះពស់ នេះត្រុក ឯពស់ដោយឡែក ត្រុកដោយឡែក ពស់គេទាញចេញមកអំពីត្រុកហ្នឹងឯង យ៉ាងណាមិញ ភិក្ខុនិម្មិតនូវកាយ មានរូបដែលសម្រេចអំពីចិត្ត មានអវយវៈធំតូចសព្វគ្រប់ មានឥន្ទ្រិយមិនថោកថយ ជាកាយដទៃអំពីកាយនេះ ក៏យ៉ាងនោះដែរ នេះ ឫទ្ធិសម្រេចអំពីចិត្ត ។

[១៨៩] ឫទ្ធិ គឺការផ្សាយចេញនៃញាណ តើដូចម្តេច ។ ឈ្មោះថាឫទ្ធិ គឺការផ្សាយចេញនៃញាណ ព្រោះសម្រេចអត្ថនៃការលះបង់នូវសេចក្តីសម្គាល់ថាទៀង ដោយការពិចារណាឃើញថា មិនទៀង ឈ្មោះថាឫទ្ធិ គឺការផ្សាយចេញនៃញាណ ព្រោះសម្រេចអត្ថនៃការលះបង់ នូវសេចក្តីសម្គាល់ថាជាសុខ ដោយការពិចារណាឃើញ ថាជាទុក្ខ

អនត្តានុបស្សនាយ អត្តសញ្ញាយ និព្វិទានុបស្សនាយ នន្ទិយា វិរាគានុបស្សនាយ រាគស្ស និរោធានុបស្សនាយ សមុទយស្ស បដិនិស្សគ្គានុបស្សនាយ អាទានស្ស បហានដ្ឋោ ឥជ្ឈតីតិ ញាណវិប្ផារា ឥទ្ធិ អាយស្មតោ ពក្កុលស្ស[១] ញាណវិប្ផារា ឥទ្ធិ អាយស្មតោ សំកិច្ចស្ស ញាណវិប្ផារា ឥទ្ធិ អាយស្មតោ ភូតបាលស្ស ញាណវិប្ផារា ឥទ្ធិ អយំ ញាណវិប្ផារា ឥទ្ធិ ។

[១៦០] កតមា សមាធិវិប្ផារា ឥទ្ធិ ។ បឋមជ្ឈានេន នីវរណានំ បហានដ្ឋោ ឥជ្ឈតីតិ សមាធិវិប្ផារា ឥទ្ធិ ទុតិយជ្ឈានេន វិតក្កវិចារានំ បហានដ្ឋោ ឥជ្ឈតីតិ សមាធិវិប្ផារា ឥទ្ធិ តតិយជ្ឈានេន បីតិយា បហានដ្ឋោ ឥជ្ឈតីតិ ។ បេ ។ ចតុត្ថជ្ឈានេន សុខទុក្ខានំ បហានដ្ឋោ ឥជ្ឈតីតិ ។ បេ ។

១ ម. ពាកុលស្ស ។

នូវសេចក្តីសម្គាល់ថាខ្លួន ដោយការពិចារណាឃើញ ថាមិនមែនខ្លួន នូវសេចក្តីត្រេកត្រអាល ដោយការពិចារណាឃើញថាជាសេចក្តីនឿយណាយ នូវតម្រេក ដោយការពិចារណាឃើញ នូវវិរាគធម៌ នូវហេតុជាទីកើត ដោយការពិចារណាឃើញ នូវការរំលត់ នូវសេចក្តីប្រកាន់ ដោយការពិចារណាឃើញ នូវការលះបង់ (ដូចជា) ឫទ្ធិគឺការផ្សាយចេញនៃញាណ របស់ព្រះពក្កុលៈមានអាយុ ឫទ្ធិគឺការផ្សាយចេញនៃញាណរបស់ព្រះសំកិច្ចៈមានអាយុ និងឫទ្ធិគឺការផ្សាយចេញនៃញាណ របស់ព្រះភូតបាលមានអាយុ នេះឫទ្ធិ គឺការផ្សាយចេញនៃញាណ ។

[១៦០] ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ តើដូចម្តេច ។ ឈ្មោះថាឫទ្ធិ គឺការផ្សាយចេញនៃសមាធិ ព្រោះសម្រេចអត្ថនៃការលះបង់នូវនីវរណៈ ដោយបឋមជ្ឈាន ឈ្មោះថាឫទ្ធិ គឺការផ្សាយចេញសមាធិ ព្រោះសម្រេចអត្ថនៃការលះបង់ នូវវិតក្កៈនិងវិចារៈ ដោយទុតិយជ្ឈាន ព្រោះសម្រេចអត្ថនៃការលះបង់នូវបីតិ ដោយតតិយជ្ឈាន ។ បេ ។ ព្រោះសម្រេចអត្ថនៃការលះបង់ នូវសុខនិងទុក្ខ ដោយចតុត្ថជ្ឈាន ។ បេ ។

អាកាសានញ្ចាយតនសមាបត្តិយា រូបសញ្ញាយ បដិឃសញ្ញាយ នានត្តសញ្ញាយ បហានដ្ឋោ ឥជ្ឈតីតិ ។ បេ ។ វិញ្ញាណញ្ចាយតនសមាបត្តិយា អាកាសានញ្ចាយតនសញ្ញាយ បហានដ្ឋោ ឥជ្ឈតីតិ ។ បេ ។ អាកិញ្ចញ្ញាយតនសមាបត្តិយា វិញ្ញាណញ្ចាយតនសញ្ញាយ បហានដ្ឋោ ឥជ្ឈតីតិ ។ បេ ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា អាកិញ្ចញ្ញាយតនសញ្ញាយ បហានដ្ឋោ ឥជ្ឈតីតិ សមាធិវិប្ផារា ឥទ្ធិ អាយស្មតោ សារីបុត្តស្ស សមាធិវិប្ផារា ឥទ្ធិ អាយស្មតោ សញ្ជីវស្ស សមាធិវិប្ផារា ឥទ្ធិ អាយស្មតោ ខាណុកោណ្ឌញ្ញស្ស សមាធិវិប្ផារា ឥទ្ធិ ឧត្តរាយ ឧបាសិកាយ សមាធិវិប្ផារា ឥទ្ធិ សាមាវតិយា ឧបាសិកាយ សមាធិវិប្ផារា ឥទ្ធិ អយំ សមាធិវិប្ផារា ឥទ្ធិ ។

ព្រោះសម្រេចអត្ថនៃការលះបង់ នូវរូបសញ្ញា នូវបដិឃសញ្ញា នូវនានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ ។ បេ ។ ព្រោះសម្រេចអត្ថនៃការលះបង់ នូវអាកាសានញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ ។ បេ ។ ព្រោះសម្រេចអត្ថនៃការលះបង់ នូវវិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ ។ បេ ។ ឈ្មោះថាឫទ្ធិគឺការផ្សាយចេញនៃសមាធិ ព្រោះសម្រេចអត្ថនៃការលះបង់ នូវអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ (ដូចជា) ឫទ្ធិគឺការផ្សាយចេញនៃសមាធិ របស់ព្រះសារីបុត្តមានអាយុ ឫទ្ធិគឺការផ្សាយចេញនៃសមាធិ របស់ព្រះសញ្ជីវៈមានអាយុ ឫទ្ធិគឺការផ្សាយចេញនៃសមាធិ របស់ព្រះខាណុកោណ្ឌញ្ញៈ មានអាយុ ឫទ្ធិគឺការផ្សាយចេញនៃសមាធិ របស់ឧបាសិកាឈ្មោះឧត្តរា ឫទ្ធិគឺការផ្សាយចេញនៃសមាធិ របស់ឧបាសិកា ឈ្មោះសាមាវតី នេះឫទ្ធិ គឺការផ្សាយចេញនៃសមាធិ។

បញ្ញាវគ្គេ ឥទ្ធិកថា

[១៦១] កាតមា អរិយា ឥទ្ធិ ។ ឥធ ភិក្ខុ សចេ អាកង្ខតិ បដិក្កូលេ អប្បដិក្កូលសញ្ញី វិហរេយ្យន្តិ អប្បដិក្កូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ អប្បដិក្កូលេ បដិក្កូលសញ្ញី វិហរេយ្យន្តិ បដិក្កូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ បដិក្កូលេ ច អប្បដិក្កូលេ ច អប្បដិក្កូលសញ្ញី វិហរេយ្យន្តិ អប្បដិក្កូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ អប្បដិក្កូលេ ច បដិក្កូលេ ច បដិក្កូលស-ញ្ញី វិហរេយ្យន្តិ បដិក្កូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ បដិក្កូលេ ច អប្បដិក្កូលេ ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យំ សតោ សម្បជា-នោតិ ឧបេក្ខកោ តត្ថ វិហរតិ សតោ សម្បជានោ ។

កថំ បដិក្កូលេ អប្បដិក្កូលសញ្ញី វិហរតិ ។ អនិដ្ឋស្មឹ វត្ថុស្មឹ មេត្តាយ វា ផរតិ ធាតុតោ វា ឧ-បសំហរតិ ឯវំ បដិក្កូលេ អប្បដិក្កូលសញ្ញី វិហរតិ ។

បញ្ញាវគ្គ ឥទ្ធិកថា

[១៦១] ឫទ្ធិ គឺភាពអ្នកខ្ពង់ខ្ពស់ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ បើប្រាថ្នាថា អាត្មាអញ គប្បីមានសេចក្តីសម្គាល់ថាមិនគួរខ្ពើម ក្នុងរបស់គួរខ្ពើម លោកក៏ជាអ្នកសម្គាល់ថាមិនគួរខ្ពើម ក្នុងរបស់នោះ បើប្រាថ្នាថា អាត្មាអញ គប្បីមានសេចក្តីសម្គាល់ថាគួរខ្ពើម ក្នុងរបស់មិនគួរខ្ពើម លោកក៏ជាអ្នកសម្គាល់ថាគួរខ្ពើម ក្នុងរបស់នោះ បើប្រាថ្នាថា អាត្មាអញ គប្បីមានសេចក្តីសម្គាល់ថាមិនគួរខ្ពើម ក្នុងរបស់គួរខ្ពើមផង ក្នុងរបស់មិនគួរខ្ពើមផង លោកក៏ជាអ្នកសម្គាល់ថាមិនគួរខ្ពើម ក្នុងរបស់នោះ បើប្រាថ្នាថា អាត្មាអញគប្បីមានសេចក្តីសម្គាល់ថាគួរខ្ពើម ក្នុងរបស់មិនគួរខ្ពើមផង ក្នុងរបស់គួរខ្ពើមផង លោកក៏ជាអ្នកសម្គាល់ថាគួរខ្ពើម ក្នុងរបស់នោះ បើប្រាថ្នាថា អាត្មាអញគប្បីវៀរបង់នូវបទ ទាំង ២ នោះ គឺក្នុងរបស់គួរខ្ពើម និងមិនគួរខ្ពើម ហើយជាអ្នកមានស្មារតី ដឹងខ្លួន ប្រកបដោយឧបេក្ខា លោកក៏ជាអ្នកមានស្មារតីដឹងខ្លួន មានចិត្តប្រកបដោយឧបេក្ខា ក្នុងរបស់នោះ ។

ភិក្ខុមានសេចក្តីសម្គាល់ថាមិនគួរខ្ពើម ក្នុងរបស់គួរខ្ពើម តើដូចម្តេច ។ ភិក្ខុផ្សាយមេត្តាចិត្ត ឬពិចារណាថាជាធាតុ ក្នុងវត្ថុមិនជាទីប្រាថ្នា យ៉ាងនេះ ឈ្មោះថាអ្នកមានសេចក្តីសម្គាល់ថាមិនគួរខ្ពើម ក្នុងវត្ថុគួរខ្ពើម ។

កថំ អប្បដិក្កូលេ បដិក្កូលសញ្ញី វិហរតិ ។ ឥដ្ឋស្មឹ វត្ថុស្មឹ អសុភាយ វា ផរតិ អនិច្ចតោ វា ឧ-បសំហរតិ ឯវំ អប្បដិក្កូលេ បដិក្កូលសញ្ញី វិហរតិ ។

កថំ បដិក្កូលេ ច អប្បដិក្កូលេ ច អប្បដិក្កូ-លសញ្ញី វិហរតិ ។ អនិដ្ឋស្មឹ ច ឥដ្ឋស្មឹ ច វត្ថុស្មឹ មេត្តាយ វា ផរតិ ធាតុតោ វា ឧបសំហរតិ ឯវំ បដិក្កូលេ ច អប្បដិក្កូលេ ច អប្បដិក្កូលសញ្ញី វិហរតិ ។

កថំ អប្បដិក្កូលេ ច បដិក្កូលេ ច បដិក្កូល-សញ្ញី វិហរតិ ។ ឥដ្ឋស្មឹ ច អនិដ្ឋស្មឹ ច វត្ថុស្មឹ អសុភា-យ វា ផរតិ អនិច្ចតោ វា ឧបសំហរតិ ឯវំ អប្បដិ-ក្កូលេ ច បដិក្កូលេ ច បដិក្កូលសញ្ញី វិហរតិ ។

កថំ បដិក្កូលេ ច អប្បដិក្កូលេ ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរតិ សតោ សម្បជានោ ។

ភិក្ខុមានសេចក្តីសម្គាល់ថាគួរខ្ពើម ក្នុងរបស់មិនគួរខ្ពើម តើដូចម្តេច ។ ភិក្ខុផ្សាយចិត្ត ថាជាអសុភ ឬពិចារណា ថាជារបស់មិនទៀង ក្នុងវត្ថុជាទីប្រាថ្នា យ៉ាងនេះ ឈ្មោះថាអ្នកមានសេចក្តីសម្គាល់ថាគួរខ្ពើម ក្នុងរបស់មិនគួរខ្ពើម ។

ភិក្ខុមានសេចក្តីសម្គាល់ថាមិនគួរខ្ពើម ក្នុងរបស់គួរខ្ពើមផង ក្នុងរបស់មិនគួរខ្ពើមផង តើដូចម្តេច ។ ភិក្ខុផ្សាយមេត្តាចិត្ត ឬពិចារណាថាជាធាតុ ក្នុងវត្ថុមិនជាទីប្រាថ្នាផង ក្នុងវត្ថុជាទីប្រាថ្នាផង យ៉ាងនេះ ឈ្មោះថាអ្នកមានសេចក្តីសម្គាល់ថាមិនគួរខ្ពើម ក្នុងរបស់គួរខ្ពើមផង ក្នុងរបស់មិនគួរខ្ពើមផង ។

ភិក្ខុមានសេចក្តីសម្គាល់ថាគួរខ្ពើម ក្នុងរបស់មិនគួរខ្ពើមផង ក្នុងរបស់គួរខ្ពើមផង តើដូចម្តេច ។ ភិក្ខុផ្សាយចិត្តថាជាអសុភ ឬពិចារណាថាជារបស់មិនទៀង ក្នុងវត្ថុជាទីប្រាថ្នាផង ក្នុងវត្ថុមិនជាទីប្រាថ្នាផង យ៉ាងនេះ ឈ្មោះថាអ្នកមានសេចក្តីសម្គាល់ថាគួរខ្ពើម ក្នុងរបស់មិនគួរខ្ពើមផង ក្នុងរបស់គួរខ្ពើមផង ។

ភិក្ខុអ្នកវៀរបង់នូវបទទាំងពីរនោះ គឺក្នុងរបស់គួរខ្ពើម និងមិនគួរខ្ពើម ហើយជាអ្នកមានស្មារតីដឹងខ្លួន មានចិត្តប្រកបដោយឧបេក្ខា តើដូចម្តេច ។

ឥធ ភិក្ខុ ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ សោតេន សទ្ទំ សុត្វា ឃានេន គន្ធំ ឃាយិត្វា ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្វំ ផុសិត្វា មនសា ធម្មំ វិញ្ញាយ នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ ឯវំ បដិ-កូលេ ច អប្បដិកូលេ ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរតិ សតោ សម្បជានោ អយំ អរិយា ឥទ្ធិ ។

[១៦២] កតមា កម្មវិបាកជា ឥទ្ធិ ។ សព្វេសំ បក្ខីនំ សព្វេសំ ទេវានំ ឯកច្ចានំ មនុស្សានំ ឯក-ច្ចានំ វិនិបាតិកានំ អយំ កម្មវិបាកជា ឥទ្ធិ ។

ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែក ជាអ្នកមិនសោមនស្ស មិនទោមនស្ស មានស្មារតីដឹងខ្លួន មានចិត្តប្រកបដោយឧបេក្ខា ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សរសដោយអណ្ដាត ពាល់ត្រូវនូវផោដ្ឋព្វារម្មណ៍ ដោយកាយ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ជាអ្នកមិនសោមនស្ស មិនទោមនស្ស មានស្មារតីដឹងខ្លួន មានចិត្តប្រកបដោយឧបេក្ខា យ៉ាងនេះ ឈ្មោះថាភិក្ខុវៀរបង់នូវបទទាំងពីរនោះ គឺក្នុងរបស់គួរខ្ពើម និងមិនគួរខ្ពើម ហើយជាអ្នកមានស្មារតីដឹងខ្លួន មានចិត្តប្រកបដោយឧបេក្ខា នេះ ឫទ្ធិ គឺភាពអ្នកខ្ពង់ខ្ពស់ ។

[១៦២] ឫទ្ធិកើតអំពីផលកម្ម តើដូចម្ដេច ។ ឫទ្ធិរបស់សត្វស្លាបទាំងអស់ របស់ទេវតាទាំងអស់ របស់ពួកមនុស្សខ្លះ របស់សត្វជាវិនិបាតិកៈកំណើតពួកខ្លះ នេះ ឫទ្ធិកើតអំពីផលកម្ម ។

[១៦៣] កតមា បុញ្ញវតោ ឥទ្ធិ ។ រាជា ចក្កវត្តិ វេហាសំ គច្ឆតិ សទ្ធឹ ចតុរង្គិនិយា សេនាយ អន្តមសោ អស្សពន្ធគោបកេ បុរិសេ ឧបាទាយ ជោតិយស្ស(១) គហបតិស្ស បុញ្ញវតោ ឥទ្ធិ ជដិលស្ស គហបតិស្ស បុញ្ញវតោ ឥទ្ធិ មេណ្ឌកស្ស គហបតិស្ស បុញ្ញវតោ ឥទ្ធិ ឃោសិតស្ស គហបតិស្ស បុញ្ញវតោ ឥទ្ធិ(២) បញ្ចន្នំ មហាបុញ្ញានំ បុញ្ញវតោ ឥទ្ធិ អយំ បុញ្ញវតោ ឥទ្ធិ ។

[១៦៤] កតមា វិជ្ជាមយា ឥទ្ធិ ។ វិជ្ជាធរា វិជ្ជំ បរិជបេត្វា វេហាសំ គច្ឆន្តិ អាកាសេ អន្តលិក្ខេ ហត្ថិម្បិ ទស្សេន្តិ អស្សម្បិ ទស្សេន្តិ រថម្បិ ទស្សេន្តិ បត្តិម្បិ ទស្សេន្តិ វិវិធម្បិ សេនាព្យូហំ ទស្សេន្តិ អយំ វិជ្ជាមយា ឥទ្ធិ ។

---

១ ឱ. ម. ជោតិកស្ស ។ ២ ម. ឯត្ថន្តរេ យេសន្តិ ទិស្សតិ ។

[១៦៣] ឫទ្ធិរបស់បុគ្គលមានបុណ្យ តើដូចម្តេច ។ ព្រះរាជាចក្រពត្តិ ទ្រង់ស្តេចទៅកាន់អាកាសបាន មួយអន្លើដោយសេនា ប្រកបដោយអង្គ ៤ ដោយហោចទៅ រាប់តាំងអំពីបុរស អ្នកចង់និងអ្នករក្សាសេះ ឫទ្ធិរបស់បុគ្គលមានបុណ្យ ឈ្មោះជោតិយគហបតី ឫទ្ធិរបស់បុគ្គលមានបុណ្យ ឈ្មោះជដិលគហបតី ឫទ្ធិរបស់បុគ្គលមានបុណ្យ ឈ្មោះមេណ្ឌកគហបតី ឫទ្ធិរបស់បុគ្គលមានបុណ្យ ឈ្មោះឃោសិតគហបតី ឫទ្ធិរបស់បុគ្គល អ្នកមានបុណ្យធំ ទាំង ៥ នាក់ ឈ្មោះថាអ្នកមានបុណ្យនេះ ឫទ្ធិ របស់បុគ្គលមានបុណ្យ ។

[១៦៤] ឫទ្ធិសម្រេចដោយវិជ្ជា តើដូចម្តេច ។ ពួកវិជ្ជាធររាយ (ឬជប់) នូវវិជ្ជា ហោះទៅកាន់អាកាសទទេ តំណែងខ្លួនជាដំរីខ្លះ តំណែងខ្លួនជាសេះខ្លះ តំណែងខ្លួនជារថខ្លះ តំណែងខ្លួនជាពលថ្មើរជើងខ្លះ តំណែងខ្លួនជាកងទាហានផ្សេង ៗ ខ្លះ នេះ ឫទ្ធិសម្រេចដោយវិជ្ជា ។

[១៦៤] កថំ តត្ថ តត្ថ សម្មប្បយោគប្បច្ចយា ឥជ្ឈនដ្ឋេន ឥទ្ធិ ។ នេក្ខម្មេន កាមច្ឆន្ទស្ស បហានដ្ឋោ ឥជ្ឈតីតិ តត្ថ តត្ថ សម្មប្បយោគប្បច្ចយា ឥជ្ឈនដ្ឋេន ឥទ្ធិ អព្យាចាទេន ព្យាចាទស្ស បហានដ្ឋោ ឥជ្ឈតីតិ ។ បេ ។ អាលោកសញ្ញាយ ថីនមិទ្ធស្ស ។ បេ ។ អរហត្តមគ្គេន សព្វកិលេសានំ បហានដ្ឋោ ឥជ្ឈតីតិ តត្ថ តត្ថ សម្មប្បយោគប្បច្ចយា ឥជ្ឈនដ្ឋេន ឥទ្ធិ ឯវំ តត្ថ តត្ថ សម្មប្បយោគប្បច្ចយា ឥជ្ឈនដ្ឋេន ឥទ្ធិ ឥមា ទស ឥទ្ធិយោតិ ។

ឥទ្ធិកថា និដ្ឋិតា ។

[១៦៥] ឫទ្ធិដោយអត្ថថាសម្រេច ព្រោះការប្រកបត្រូវក្នុងអំពើនោះៗ ជាបច្ច័យ តើដូចម្ដេច ។ ឈ្មោះថាឫទ្ធិដោយអត្ថថាសម្រេច ព្រោះការប្រកបត្រូវក្នុងអំពើនោះៗ ជាបច្ច័យ ព្រោះសម្រេចអត្ថនៃការលះបង់ នូវកាមច្ឆន្ទៈ ដោយនេក្ខម្មៈ ។ បេ ។ ព្រោះសម្រេចអត្ថនៃការលះបង់នូវព្យាបាទ ដោយអព្យាបាទ ។ បេ ។ នូវថីនមិទ្ធៈ ដោយអាលោកសញ្ញា ។ បេ ។ ឈ្មោះថាឫទ្ធិដោយអត្ថថាសម្រេច ព្រោះការប្រកបត្រូវក្នុងអំពើនោះៗ ជាបច្ច័យ ព្រោះសម្រេចអត្ថនៃការលះបង់ នូវកិលេសទាំងពួង យ៉ាងនេះឯង ឈ្មោះថាឫទ្ធិ ដោយអត្ថថាសម្រេច ព្រោះការប្រកបត្រូវក្នុងអំពើនោះ ៗ ជាបច្ច័យ នេះ ឫទ្ធិទាំង ១០ ។

ចប់ ឥទ្ធិកថា ។

# បញ្ញាវគ្គេ អភិសមយកថា

[១៦៦] អភិសមយោតិ កេន អភិសមេតិ ។ ចិត្តេន អភិសមេតិ[១] ។ ហញ្ចិ ចិត្តេន អភិសមេតិ ។ តេនហិ អញ្ញាណី អភិសមេតិ ។ ន អញ្ញាណី អភិសមេតិ ញាណេន អភិសមេតិ ។ ហញ្ចិ ញាណេន អភិសមេតិ តេនហិ អចិត្តកោ អភិសមេតិ[២] ។ ន អចិត្តកោ អភិសមេតិ ចិត្តេន ច ញាណេន ច អភិសមេតិ[៣] ។ ហញ្ចិ ចិត្តេន ច ញាណេន ច អភិសមេតិ តេនហិ កាមាវចរចិត្តេន ច ញាណេន ច អភិសមេតិ ។ ន កាមាវចរចិត្តេន ច ញាណេន ច អភិសមេតិ ។ តេនហិ រូបាវចរចិត្តេន ច ញាណេន ច អភិសមេតិ ។ ន រូបាវចរចិត្តេន ច ញាណេន ច អភិសមេតិ ។ តេនហិ អរូបាវចរចិត្តេន ច ញាណេន ច អភិសមេតិ ។ ន អរូបាវចរចិត្តេន ច ញាណេន ច អភិសមេតិ ។

---

១ ឱ. ចិត្តេន អភិសមេតីតិ ឥមេ បាឋា នត្ថិ ។ ២ ម. ហញ្ចិ ញាណេន អភិសមេតិ តេនហិ អចិត្តេន ច ញាណេន ច អចិត្តកោ អភិសមេតិ ។ ៣ ម. ចិត្តេន ច ញាណេន ច អភិសមេតីតិ ទិស្សន្តិ ។

# បញ្ញាវគ្គ អភិសមយកថា

[១៦៦] សំណួរត្រង់ ពាក្យថា ការត្រាស់ដឹង តើបុគ្គលត្រាស់ដឹងដោយធម្មជាតអ្វី ។ បុគ្គលត្រាស់ដឹងដោយចិត្ត ។ បើបុគ្គលត្រាស់ដឹងដោយចិត្ត ដូច្នេះ បុគ្គលមិនមានញាណក៏ត្រាស់ដឹង ។ បុគ្គលមិនមានញាណមិនត្រាស់ដឹងទេ ត្រាស់ដឹងតែដោយញាណ ។ បើបុគ្គលត្រាស់ដឹងដោយញាណ ដូច្នោះ បុគ្គលមិនមានចិត្ត ក៏ត្រាស់ដឹង ។ បុគ្គលមិនមានចិត្តមិនត្រាស់ដឹងទេ ត្រាស់ដឹងដោយចិត្តផង ដោយញាណផង ។ បើបុគ្គលត្រាស់ដឹងដោយចិត្តផង ដោយញាណផង ដូច្នោះ បុគ្គលត្រាស់ដឹង ដោយកាមាវចរចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹង ដោយកាមាវចរចិត្តផង ដោយញាណផងទេ ។ ដូច្នោះ បុគ្គលត្រាស់ដឹង ដោយរូបាវចរចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹង ដោយរូបាវចរចិត្តផង ដោយញាណផងទេ ។ ដូច្នោះ បុគ្គលត្រាស់ដឹង ដោយអរូបាវចរចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹង ដោយអរូបាវចរចិត្តផង ដោយញាណផងទេ ។

តេនហិ កម្មស្សកតាចិត្តេន ច ញាណេន ច អភិស-
មេតិ ។ ន កម្មស្សកតាចិត្តេន ច ញាណេន ច អភិ-
សមេតិ ។ តេនហិ សច្ចានុលោមិកចិត្តេន ច ញាណេន
ច អភិសមេតិ ។ ន សច្ចានុលោមិកចិត្តេន ច
ញាណេន ច អភិសមេតិ ។ តេនហិ អតីតចិត្តេន ច ញា-
ណេន ច អភិសមេតិ ។ ន អតីតចិត្តេន ច ញា-
ណេន ច អភិសមេតិ ។ តេនហិ អនាគតចិត្តេន ច
ញាណេន ច អភិសមេតិ ។ ន អនាគតចិត្តេន ច ញា-
ណេន ច អភិសមេតិ ។ តេនហិ បច្ចុប្បន្នលោកិយចិ-
ត្តេន ច ញាណេន ច អភិសមេតិ ។ ន បច្ចុប្បន្នលោ-
កិយចិត្តេន ច ញាណេន ច អភិសមេតិ លោកុត្តរមគ្គ-
ក្ខណេ បច្ចុប្បន្នចិត្តេន ច ញាណេន ច អភិសមេតិ ។

[១៦៧] កថំ លោកុត្តរមគ្គក្ខណេ បច្ចុប្បន្នចិ-
ត្តេន ច ញាណេន ច អភិសមេតិ ។ លោកុត្តរ-
មគ្គក្ខណេ ឧប្បាទាធិបតេយ្យំ ចិត្តំ ញាណស្ស ហេ-
តុ បច្ចយោ ច តំសម្បយុត្តំ ចិត្តំ និរោធគោចរំ

ដូច្នោះ បុគ្គលត្រាស់ដឹង ដោយកម្មស្សកតាចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹង ដោយកម្មស្សកតាចិត្តផង ដោយញាណផងទេ ។ ដូច្នោះ បុគ្គលត្រាស់ដឹង ដោយសច្ចានុលោមិកចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹង ដោយសច្ចានុលោមិកចិត្តផង ដោយញាណផងទេ។ ដូច្នោះ បុគ្គលត្រាស់ដឹងដោយអតីតចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹង ដោយអតីតចិត្តផង ដោយញាណផងទេ ។ ដូច្នោះ បុគ្គលត្រាស់ដឹង ដោយអនាគតចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹង ដោយអនាគតចិត្តផង ដោយញាណផងទេ ។ ដូច្នោះ បុគ្គលត្រាស់ដឹង ដោយបច្ចុប្បន្នលោកិយចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹង ដោយបច្ចុប្បន្នលោកិយចិត្តផង ដោយញាណផងទេ ត្រាស់ដឹងដោយបច្ចុប្បន្នចិត្តផង ដោយញាណផង ក្នុងខណៈនៃលោកុត្តរមគ្គ ។

[១៦៧] បុគ្គលត្រាស់ដឹង ដោយបច្ចុប្បន្នចិត្តផង ដោយញាណផង ក្នុងខណៈនៃលោកុត្តរមគ្គ តើដូចម្តេច ។ ក្នុងខណៈនៃលោកុត្តរមគ្គ ចិត្តមានកិរិយាកើតឡើងជាអធិបតី ជាហេតុ ជាបច្ច័យនៃញាណ ចិត្តដែលប្រកបដោយញាណនោះ មានព្រះនិព្វានជាអារម្មណ៍

ធម្មាធិបតេយ្យំ ញាណំ ចិត្តស្ស ហេតុ បច្ចយោ ច តំសម្បយុត្តំ ញាណំ និរោធគោចរំ ឯវំ លោ-កុត្តរមគ្គក្ខណេ បច្ចុប្បន្នចិត្តេន ច ញាណេន ច អភិសមេតិ ។

[១៦៨] កិន្នុ ឯត្តកោ យេវ អភិសមយោតិ ។ ន ហិ លោកុត្តរមគ្គក្ខណេ ធម្មាភិសមយោ សម្មាទិដ្ឋិ អភិនិរោបនាភិសមយោ សម្មាសង្កប្បោ បរិគ្គហាភិសមយោ សម្មាវាចា សមុដ្ឋានាភិសមយោ សម្មាកម្មន្តោ វោទានាភិសមយោ សម្មាអាជីវោ បគ្គហាភិសមយោ សម្មាវាយាមោ ឧបដ្ឋានាភិសម-យោ សម្មាសតិ អវិក្ខេបាភិសមយោ សម្មាសមាធិ ឧបដ្ឋានាភិសមយោ សតិសម្ពោជ្ឈង្គោ ។ បេ ។

ញាណមានកិរិយាឃើញជាអធិបតី ជាហេតុជាបច្ច័យនៃចិត្ត ញាណដែលប្រកបដោយចិត្តនោះ មាននិរោធជាអារម្មណ៍ យ៉ាងនេះ ឈ្មោះថាបុគ្គលត្រាស់ដឹង ដោយបច្ចុប្បន្នចិត្តផង ដោយញាណផង ក្នុងខណៈនៃលោកុត្តរមគ្គ ។

[១៦៨] ការត្រាស់ដឹង មានត្រឹមតែប៉ុណ្ណោះទេឬ ។ មិនមែនមានតែប៉ុណ្ណោះទេ ក្នុងខណៈនៃលោកុត្តរមគ្គ មានការត្រាស់ដឹងដោយការឃើញ គឺសម្មាទិដ្ឋិ មានការត្រាស់ដឹង ដោយកិរិយាលើកចិត្តកាន់អារម្មណ៍ គឺសម្មាសង្កប្បៈ ការត្រាស់ដឹង ដោយកិរិយាកំណត់ គឺសម្មាវាចា ការត្រាស់ដឹង ដោយការខ្នះខ្នែង គឺសម្មាកម្មន្តៈ ការត្រាស់ដឹង ដោយកិរិយាផូរផង់ គឺសម្មាអាជីវៈ ការត្រាស់ដឹង ដោយកិរិយាផ្គងឡើង គឺសម្មាវាយាមៈ ការត្រាស់ដឹងដោយការប្រុង គឺសម្មាសតិ ការត្រាស់ដឹង ដោយកិរិយាមិនរាយមាយ គឺសម្មាសមាធិ ការត្រាស់ដឹង ដោយការប្រុង គឺសតិសម្ពោជ្ឈង្គ ។ បេ ។

២៨៩



បដិសង្ខានាភិសមយោ ឧបេក្ខាសម្ពោជ្ឈង្គោ អស្ស-
ទ្ធិយេ អកម្បិយាភិសមយោ សទ្ធាពលំ កោសជ្ជេ
អកម្បិយាភិសមយោ វីរិយពលំ បមាទេ អកម្បិ-
យាភិសមយោ សតិពលំ ឧទ្ធច្ចេ អកម្បិយាភិស-
មយោ សមាធិពលំ អវិជ្ជាយ អកម្បិយាភិសម-
យោ បញ្ញាពលំ អធិមោក្ខាភិសមយោ សទ្ធិ-
ន្ទ្រិយំ បគ្គហាភិសមយោ វីរិយិន្ទ្រិយំ ឧបដ្ឋានាភិស-
មយោ សតិន្ទ្រិយំ អវិក្ខេបាភិសមយោ សមាធិន្ទ្រិ-
យំ ទស្សនាភិសមយោ បញ្ញិន្ទ្រិយំ អាធិបតេយ្យដ្ឋេន
ឥន្ទ្រិយាភិសមយោ អកម្បិយដ្ឋេន ពលាភិសមយោ
និយ្យានដ្ឋេន ពោជ្ឈង្គាភិសមយោ ហេតុដ្ឋេន មគ្គាភិ-
សមយោ ឧបដ្ឋានដ្ឋេន សតិប្បដ្ឋានាភិសមយោ បទហ-
នដ្ឋេន[១] សម្មប្បធានាភិសមយោ ឥជ្ឈនដ្ឋេន ឥទ្ធិបា-
ទាភិសមយោ តថដ្ឋេន សច្ចាភិសមយោ អវិក្ខេបដ្ឋេន

---

១ ម. បគ្គហដ្ឋេន ។

ការត្រាស់ដឹងដោយការពិចារណា គឺឧបេក្ខាសម្ពោជ្ឈង្គ ការត្រាស់ដឹង ដោយការមិនញាប់ញ័រ ចំពោះហេតុមិនគួរជឿ គឺសទ្ធាពលៈ ការត្រាស់ ដឹងដោយកិរិយាមិនញាប់ញ័រ ចំពោះសេចក្ដីខ្ជិលច្រអូស គឺវីរិយពលៈ ការត្រាស់ដឹងដោយកិរិយាមិនញាប់ញ័រ ចំពោះសេចក្ដីប្រហែស គឺសតិ-ពលៈ ការត្រាស់ដឹងដោយកិរិយាមិនញាប់ញ័រ ចំពោះសេចក្ដីរាយមាយ គឺសមាធិពលៈ ការត្រាស់ដឹង ដោយកិរិយាមិនញាប់ញ័រ ចំពោះអវិជ្ជា គឺបញ្ញាពលៈ ការត្រាស់ដឹងដោយសេចក្ដីជឿស៊ប់ គឺសទ្ធិន្ទ្រិយ ការត្រាស់ដឹងដោយការផ្គងឡើង គឺវីរិយិន្ទ្រិយ ការត្រាស់ដឹងដោយកិរិយាប្រុង គឺសតិន្ទ្រិយ ការត្រាស់ដឹងដោយការមិនរាយមាយ គឺសមាធិន្ទ្រិយ ការត្រាស់ដឹងដោយកិរិយាយល់ គឺបញ្ញិន្ទ្រិយ ការត្រាស់ដឹង គឺឥន្ទ្រិយ ដោយអត្ថថាជាអធិបតី ការត្រាស់ដឹង គឺពលៈ ដោយអត្ថថាមិនញាប់ញ័រ ការត្រាស់ដឹងគឺពោជ្ឈង្គ ដោយអត្ថថាចេញចាកវដ្ដៈ ការត្រាស់ដឹងគឺមគ្គ ដោយអត្ថថាជាហេតុ ការត្រាស់ដឹង គឺសតិប្បដ្ឋាន ដោយអត្ថថាប្រុង ការត្រាស់ដឹង គឺសម្មប្បធាន ដោយអត្ថថាតម្កល់ ការត្រាស់ដឹង គឺឥទ្ធិ-បាទ ដោយអត្ថថាសម្រេច ការត្រាស់ដឹងគឺសច្ចៈ ដោយអត្ថថាទៀងទាត់

សមថាភិសមយោ អនុបស្សនដ្ឋេន វិបស្សនាភិសមយោ ឯករសដ្ឋេន សមថវិបស្សនាភិសមយោ អនតិវត្តនដ្ឋេន យុគនទ្ធាភិសមយោ សំវរដ្ឋេន សីលវិសុទ្ធិ អភិសមយោ អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ អភិសមយោ ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ អភិសមយោ មុត្តដ្ឋេន អធិមោក្ខាភិសមយោ[១] បដិវេធដ្ឋេន វិជ្ជាភិសមយោ បរិច្ចាគដ្ឋេន វិមុត្តិ អភិសមយោ សមុច្ឆេទនដ្ឋេន ខយេ ញាណំ អភិសមយោ ឆន្ទោ មូលដ្ឋេន អភិសមយោ មនសិការោ សមុដ្ឋានដ្ឋេន អភិសមយោ ផស្សោ សមោធានដ្ឋេន អភិសមយោ វេទនា សមោសរណដ្ឋេន អភិសមយោ សមាធិ បមុខដ្ឋេន អភិសមយោ សតិ អាធិបតេយ្យដ្ឋេន អភិសមយោ បញ្ញា តទុត្តរដ្ឋេន អភិសមយោ វិមុត្តិ សារដ្ឋេន អភិសមយោ អមតោគធំ និព្វានំ បរិយោសានដ្ឋេន អភិសមយោ ។

១ ម. វិមុត្តដ្ឋេន វិមោក្ខាភិសមយោ ។

ការត្រាស់ដឹងគឺសមថៈ ដោយអត្ថថាមិនរាយមាយ ការត្រាស់ដឹងគឺវិបស្សនា ដោយអត្ថថាពិចារណាឃើញ ការត្រាស់ដឹង គឺសមថៈនិងវិបស្សនា ដោយអត្ថថាមានរសតែមួយ ការត្រាស់ដឹង គឺធម៌ជាប់គ្នាជាគូ ដោយអត្ថថាមិនប្រព្រឹត្តលើសគ្នា ការត្រាស់ដឹង គឺសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ការត្រាស់ដឹង គឺចិត្តវិសុទ្ធិ ដោយអត្ថថាមិនរាយមាយ ការត្រាស់ដឹង គឺទិដ្ឋិវិសុទ្ធិ ដោយអត្ថថាឃើញ ការត្រាស់ដឹង គឺអធិមោក្ខ ដោយអត្ថថារួច ការត្រាស់ដឹងគឺវិជ្ជា ដោយអត្ថថាចាក់ធ្លុះ ការត្រាស់ដឹងគឺវិមុត្តិ ដោយអត្ថថាលះបង់ ការត្រាស់ដឹងគឺខយញ្ញាណ ដោយអត្ថថាកាត់ដាច់ស្រឡះ ការត្រាស់ដឹងគឺឆន្ទៈ ដោយអត្ថថាជាឫស ការត្រាស់ដឹង គឺមនសិការៈ ដោយអត្ថថាតាំងឡើងព្រម ការត្រាស់ដឹង គឺផស្សៈ ដោយអត្ថថាប្រមូល ការត្រាស់ដឹង គឺវេទនា ដោយអត្ថថាជាទីប្រជុំចុះ ការត្រាស់ដឹង គឺសមាធិ ដោយអត្ថថាជាប្រធាន ការត្រាស់ដឹង គឺសតិ ដោយអត្ថថាជាអធិបតី ការត្រាស់ដឹង គឺបញ្ញា ដោយអត្ថថាប្រសើរជាងធម៌ទាំងនោះ ការត្រាស់ដឹង គឺវិមុត្តិ ដោយអត្ថថាជាខ្លឹម ការត្រាស់ដឹង គឺអមតនិព្វាន ដោយអត្ថថាជាទីបំផុត (នៃកិច្ចក្នុងសាសនា) ។

[១៦៩] កិន្នុ ឯត្តកោ យេវ អភិសមយោតិ ។ ន ហិ សោតាបត្តិមគ្គក្ខណេ ធម្មាភិសមយោ សម្មា-ទិដ្ឋិ ។ បេ ។ អមតោគធំ និព្វានំ បរិយោសានដ្ឋេន អភិសមយោ ។

កិន្នុ ឯត្តកោ យេវ អភិសមយោតិ ។ ន ហិ សោតាបត្តិផលក្ខណេ ធម្មាភិសមយោ សម្មាទិដ្ឋិ ។ បេ ។ បដិប្បស្សទ្ធដ្ឋេន អនុប្បាទេ ញាណំ អភិ-សមយោ ឆន្ទោ មូលដ្ឋេន អភិសមយោ ។ បេ ។ អមតោគធំ និព្វានំ បរិយោសានដ្ឋេន អភិសមយោ ។

កិន្នុ ឯត្តកោ យេវ អភិសមយោតិ ។ ន ហិ ស-កទាគាមិមគ្គក្ខណេ ។ បេ ។ សកទាគាមិផលក្ខណេ អនាគាមិមគ្គក្ខណេ អនាគាមិផលក្ខណេ អរហត្តមគ្គ-ក្ខណេ អរហត្តផលក្ខណេ ធម្មាភិសមយោ ស-ម្មាទិដ្ឋិ អភិនិរោបនាភិសមយោ សម្មាសង្កប្បោ ។ បេ ។

[១៦៩] ការត្រាស់ដឹង មានត្រឹមតែប៉ុណ្ណោះទេឬ ។ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ ក្នុងខណៈនៃសោតាបត្តិមគ្គ មានការត្រាស់ដឹងដោយកិរិយាយល់ គឺសម្មាទិដ្ឋិ ។ បេ ។ មានការត្រាស់ដឹង គឺអមតនិព្វាន ដោយអត្ថថាជាទីបំផុត (នៃកិច្ចក្នុងសាសនា) ។

ការត្រាស់ដឹងមានត្រឹមតែប៉ុណ្ណោះទេឬ ។ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ ក្នុងខណៈនៃសោតាបត្តិផល មានការត្រាស់ដឹងដោយកិរិយាយល់ គឺសម្មាទិដ្ឋិ ។ បេ ។ ការត្រាស់ដឹង គឺអនុប្បាទញ្ញាណ ដោយអត្ថថារម្ងាប់ ការត្រាស់ដឹងគឺឆន្ទៈ ដោយអត្ថថាជាឫស ។ បេ ។ ការត្រាស់ដឹង គឺអមតនិព្វាន ដោយអត្ថថាជាទីបំផុត (នៃកិច្ចក្នុងសាសនា) ។

ការត្រាស់ដឹង មានតែប៉ុណ្ណោះទេឬ ។ មិនមែនមានតែប៉ុណ្ណោះទេ ក្នុងខណៈនៃសកទាគាមិមគ្គ ។ បេ ។ ក្នុងខណៈនៃសកទាគាមិផល ក្នុងខណៈនៃអនាគាមិមគ្គ ក្នុងខណៈនៃអនាគាមិផល ក្នុងខណៈនៃអរហត្តមគ្គ ក្នុងខណៈនៃអរហត្តផល មានការត្រាស់ដឹងដោយការយល់ គឺសម្មាទិដ្ឋិ ការត្រាស់ដឹងដោយការលើកចិត្តកាន់អារម្មណ៍ គឺសម្មាសង្កប្បៈ ។ បេ ។

បដិប្បស្សទ្ធដ្ឋេន អនុប្បាទេ ញាណំ អភិសមយោ ឆន្ទោ មូលដ្ឋេន អភិសមយោ ។ បេ ។ អមតោគធំ និព្វានំ បរិយោសានដ្ឋេន អភិសមយោ ។ ស្វាយំ អតីតេ កិលេសេ បជហតិ អនាគតេ កិលេសេ បជហតិ បច្ចុប្បន្នេ កិលេសេ បជហតិ ។

[១៧០] អតីតេ កិលេសេ បជហតីតិ ហញ្ចិ អតីតេ កិលេសេ បជហតិ តេនហិ ខីណំ ខេបេតិ និរុទ្ធំ និរោធេតិ វិគតំ វិគមេតិ អត្ថង្គតំ អត្ថង្គមេតិ អតីតំ យំ នត្ថិ តំ បជហតីតិ ។ ន អតីតេ កិលេសេ បជហតិ[១] ។

អនាគតេ កិលេសេ បជហតីតិ ហញ្ចិ អនាគតេ កិលេសេ បជហតិ តេនហិ អជាតំ បជហតិ អនិព្វត្តំ បជហតិ អនុប្បន្នំ បជហតិ អបាតុភូតំ បជហតិ អនាគតំ យំ នត្ថិ តំ បជហតីតិ ។ ន អនាគតេ កិលេសេ បជហតិ ។

១ ឱ. ម. បជហតីតិ ។

ការត្រាស់ដឹង គឺអនុប្បាទញ្ញាណ ដោយអត្ថថាស្ងប់ ការត្រាស់ដឹង គឺឆន្ទៈ ដោយអត្ថថាជាឫស ។ បេ ។ ការត្រាស់ដឹង គឺអមតនិព្វាន ដោយអត្ថថាជាទីបំផុត (នៃកិច្ចក្នុងសាសនា) ។ ភិក្ខុនោះ តែងលះកិលេសដែលកន្លងហើយ លះកិលេសដែលមិនទាន់មានមក លះកិលេសដែលកើតចំពោះមុខ ។

[១៧០] ពាក្យថា លះកិលេសដែលកន្លងហើយ សំណួរថា បើលះកិលេសដែលកន្លងហើយ មានតែ ញុំាងកិលេសដែលអស់ហើយឲ្យអស់ ញុំាងកិលេសដែលរលត់ហើយឲ្យរលត់ ញុំាងកិលេសដែលសាបសូន្យហើយឲ្យសាបសូន្យ ញុំាងកិលេសដែលវិនាសហើយឲ្យវិនាស គឺថា កិលេសជាតណាកន្លងហើយ មិនមានទេ លះកិលេសជាតនោះឬ ។ ចម្លើយថា មិនមែនលះកិលេស ដែលកន្លងហើយទេ ។

ពាក្យថា លះកិលេសដែលមិនទាន់មក សំណួរថា បើលះកិលេសដែលមិនទាន់មក មានតែ លះកិលេស ដែលមិនទាន់កើត លះកិលេសដែលមិនទាន់ដុះ លះកិលេស ដែលមិនទាន់ផុសឡើង លះកិលេសដែលមិនទាន់កើតប្រាកដ គឺថា កិលេសជាតណា ដែលមិនទាន់មកមិនមានទេ លះកិលេសជាតនោះឬ ។ ចម្លើយថា មិនមែនលះកិលេសដែលមិនទាន់មកទេ ។

បញ្ញាវគ្គេ អភិសមយកថា

បច្ចុប្បន្នេ កិលេសេ បជហាតីតិ ហញ្ចិ បច្ចុប្បន្នេ កិលេសេ បជហាតិ តេនហិ រត្តោ រាគំ បជហាតិ ទុដ្ឋោ ទោសំ បជហាតិ មូឡ្ហោ មោហំ បជហាតិ វិនិពន្ធោ មានំ បជហាតិ បរាមដ្ឋោ ទិដ្ឋឹ បជហាតិ វិក្ខេបគតោ[១] ឧទ្ធច្ចំ បជហាតិ អនិដ្ឋង្គតោ វិចិកិច្ឆំ បជហាតិ ថាមគតោ អនុសយំ បជហាតិ កណ្ហាសុក្កធម្មា យុគនទ្ធា បវត្តន្តិ សំកិលេសិកា មគ្គភាវនា ហោតីតិ ។ ន អតីតេ កិលេសេ បជហាតិ ន អនាគតេ កិលេសេ បជហាតិ ន បច្ចុប្បន្នេ កិលេសេ បជហាតីតិ ។

[១៧១] ហញ្ចិ ន អតីតេ កិលេសេ បជហាតិ ន អនាគតេ កិលេសេ បជហាតិ ន បច្ចុប្បន្នេ កិលេសេ បជហាតិ តេនហិ នត្ថិ មគ្គភាវនា នត្ថិ ផលសច្ឆិកិរិយា នត្ថិ កិលេសប្បហានំ នត្ថិ ធម្មាភិសមយោ ។

---

១ ឱ. អវិក្ខេបគតោ ។

ពាក្យថា លះកិលេសដែលកើតចំពោះមុខ សំណួរថា បើលះកិលេស ដែលកើតចំពោះមុខ មានតែ ភិក្ខុអ្នកត្រេកអរ លះរាគៈ អ្នកប្រទូស្ត លះទោសៈ អ្នកវង្វេង លះមោហៈ អ្នកប្រកួតប្រកាន់ លះមានះ អ្នកស្ទាបអង្អែល លះទិដ្ឋិ អ្នកមានចិត្តរាយមាយ លះឧទ្ធច្ចៈ អ្នកដល់នូវការមិនដាច់ស្រេច លះវិចិកិច្ឆា អ្នកមានព្យាយាម លះអនុស័យ គឺជាធម៌ខ្មៅនិងធម៌ស តែងជាប់គ្នាជាគូប្រព្រឹត្តទៅ មគ្គភាវនា ប្រកបដោយសេចក្តីសៅហ្មង ដោយធម៌ទាំងពីរនោះឬ ។ ចម្លើយថា មិនមែនលះកិលេសដែលកន្លងហើយ មិនមែនលះកិលេសដែលមិនទាន់មក មិនមែនលះកិលេស ដែលកើតចំពោះមុខទេ ។

[១៧១] បើមិនមែនលះកិលេសដែលកន្លងហើយ មិនមែនលះកិលេសដែលមិនទាន់មក មិនមែនលះកិលេសដែលកើតចំពោះមុខទេ បើដូច្នោះមានតែ មគ្គភាវនាមិនមាន ការធ្វើឲ្យជាក់ច្បាស់នូវផលមិនមាន ការលះកិលេសមិនមាន ការត្រាស់ដឹងធម៌ មិនមានឬ ។

ន ហិ អត្ថិ មគ្គភាវនា អត្ថិ ផលសច្ឆិកិរិយា អត្ថិ កិលេសប្បហានំ អត្ថិ ធម្មាភិសមយោ យថា កថំ វិយ យថាបិ[១] តរុណោ រុក្ខោ អជាតផលោ តមេនំ បុរិសោ មូលេ ឆិន្ទេយ្យ យេ[២] តស្ស រុក្ខស្ស អជាតផលា[៣] អជាតា យេវ ន ជាយន្តិ អនិព្វត្តា យេវ ន និព្វត្តន្តិ អនុប្បន្នា យេវ ន ឧប្បជ្ជន្តិ អបាតុភូតា យេវ ន បាតុភវន្តិ ឯវមេវ ឧប្បាទោ ហេតុ ឧប្បាទោ បច្ចយោ កិលេសានំ និព្វត្តិយា ឧប្បាទេ អាទីនវំ ទិស្វា អនុប្បាទេ ចិត្តំ បក្ខន្ទតិ អនុប្បាទេ ចិត្តស្ស បក្ខន្ទនត្តា យេ ឧប្បាទប្បច្ចយា កិលេសា និព្វត្តេយ្យុំ តេ អជាតា យេវ ន ជាយន្តិ អនិព្វត្តា យេវ ន និព្វត្តន្តិ អនុប្បន្នា យេវ ន ឧប្បជ្ជន្តិ អបាតុភូតា យេវ ន បាតុភវន្តិ ។ ឯវំ ហេតុនិរោធា ទុក្ខនិរោធោ បវត្តហេតុ និមិត្តហេតុ អាយូហនហេតុ[៤] អាយូហនា បច្ចយោ កិលេសានំ និព្វត្តិយា អាយូហនេ អាទីនវំ ទិស្វា

---

១ ឱ. ម. សេយ្យថាបិ ។ ២ ម. យេន ។ ៣ ឱ. ឯត្ថន្តរេ តេតិ ទិស្សតិ ។ ម. តេនាតិ ទិស្សតិ ។ ៤ ម. បវត្តំហេតុ និមិត្តំហេតុ អាយូហនាហេតុ ។

មិនមែនដូច្នោះទេ មគ្គភាវនាមាន ការធ្វើឲ្យជាក់ច្បាស់នូវផលមាន ការលះកិលេសមាន ការត្រាស់ដឹងនូវធម៌មាន ឧបមាដូចជាអ្វី ដូចជាដើមឈើចំទង់ មិនទាន់មានផ្លែ បុរសកាត់ផ្តាច់ឈើនុ៎ះត្រង់គល់ ឯអជាតផលណារបស់ឈើនោះ ដែលមិនទាន់ចេញ ក៏លែងចេញ ដែលមិនទាន់កើត ក៏លែងកើត ដែលមិនទាន់ពក ក៏លែងពក ដែលមិនទាន់កើតប្រាកដ ក៏លែងកើតប្រាកដ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូច ការកើតជាហេតុ ការកើតជាបច្ច័យ នៃការកើតកិលេស ចិត្តតែងស្ទុះទៅក្នុងការមិនកើត ព្រោះឃើញទោសក្នុងការកើត ព្រោះតែចិត្តស្ទុះទៅក្នុងការមិនកើត បានជា កិលេសទាំងឡាយណា ដែលមានការកើតឡើងជាបច្ច័យគប្បីកើតឡើង កិលេសទាំងនោះ ដែលមិនទាន់កើត ក៏លែងកើត ដែលមិនទាន់ដុះ ក៏លែងដុះ ដែលមិនទាន់ផុស ក៏លែងផុស ដែលមិនទាន់កើតប្រាកដ ក៏លែងកើតប្រាកដ ។ ការរលត់ទុក្ខ ព្រោះការរលត់នៃហេតុ យ៉ាងនេះឯង ហេតុគឺការប្រព្រឹត្តទៅ ហេតុគឺនិមិត្ត ហេតុគឺការប្រមូលមក ឯការប្រមូលមក ជាបច្ច័យ នៃការកើតនូវកិលេស ចិត្តតែងស្ទុះទៅ ក្នុងការមិនប្រមូល ព្រោះឃើញទោស

អនាយុហានេ ចិត្តំ បក្ខន្ទតិ អនាយុហានេ ចិត្តស្ស បក្ខន្ទនត្តា យេ អាយុហានប្បច្ចយា កិលេសា និព្វត្តេយ្យុំ តេ អជាតា យេវ ន ជាយន្តិ អនិព្វត្តា យេវ ន និព្វត្តន្តិ អនុប្បន្នា យេវ ន ឧប្បជ្ជន្តិ អបាតុភូតា យេវ ន បាតុភវន្តិ ។ ឯវំ ហេតុនិរោធា ទុក្ខនិរោធោ ។ ឯវំ អត្ថិ មគ្គភាវនា អត្ថិ ផលសច្ឆិកិរិយា អត្ថិ កិលេសប្បហានំ អត្ថិ ធម្មាភិសមយោតិ ។

អភិសមយកថា និដ្ឋិតា ។

---

ក្នុងការប្រមូល ព្រោះតែចិត្តស្ទុះទៅ ក្នុងការមិនប្រមូល បានជាកិលេសទាំងឡាយណា ដែលមានការប្រមូលជាបច្ច័យ គប្បីកើតឡើង កិលេសទាំងនោះ ដែលមិនទាន់កើត ក៏លែងកើត ដែលមិនទាន់ដុះ ក៏លែងដុះ ដែលមិនទាន់ផុសឡើង ក៏លែងផុសឡើង ដែលមិនទាន់កើតប្រាកដ ក៏លែងកើតប្រាកដ ។ ការរលត់ទុក្ខ ព្រោះរលត់ហេតុ យ៉ាងនេះ ។ មគ្គភាវនាមាន ការធ្វើឲ្យជាក់ច្បាស់នូវផលមាន ការលះកិលេសមាន ការត្រាស់ដឹងធម៌មាន យ៉ាងនេះឯង ។

ចប់ អភិសមយកថា ។

# បញ្ញាវគ្គេ វិវេកកថា

## សាវត្ថីនិទានំ[១]

[១៧២] សេយ្យថាបិ ភិក្ខវេ យេ កេចិ ពលករណីយា[២] កម្មន្តា ករីយន្តិ សព្វេ តេ បឋវឹ និស្សាយ បឋវិយំ បតិដ្ឋាយ ឯវមេតេ ពលករណីយា[២] កម្មន្តា ករីយន្តិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។

[១៧៣] កថញ្ច ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ សម្មាសង្កប្បំ ភាវេតិ សម្មាវាចំ ភាវេតិ សម្មាកម្មន្តំ ភាវេតិ

---

១ ឱ. ម. បរិបុណ្ណនិទានំ ។ ២ ឱ. ពហុលករណីយា ។

# បញ្ញាវគ្គ វិវេកកថា

## សាវត្ថីនិទាន

[១៧២] ម្នាលភិក្ខុទាំងឡាយ ការងារទាំងឡាយ ណាមួយ ដែលត្រូវធ្វើដោយកម្លាំង ការងារទាំងអស់នោះ បុគ្គលលុះតែអាស្រ័យផែនដី ឈរលើផែនដី ទើបធ្វើបាន ការងារទាំងឡាយ ដែលត្រូវធ្វើដោយកម្លាំងទាំងនុ៎ះ បុគ្គលតែងធ្វើយ៉ាងនេះ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូច ភិក្ខុលុះតែអាស្រ័យនូវសីល តាំងនៅក្នុងសីលហើយ ទើបចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន ទើបធ្វើឲ្យច្រើន នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន ។

[១៧៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុលុះតែអាស្រ័យនូវសីល តាំងនៅក្នុងសីលហើយ ទើបចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន ទើបធ្វើឲ្យច្រើន នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសម្មាទិដ្ឋិ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះ ចម្រើនសម្មាសង្កប្បៈ ចម្រើនសម្មាវាចា ចម្រើនសម្មាកម្មន្តៈ

សម្មាអាជីវំ ភាវេតិ សម្មាវាយាមំ ភាវេតិ សម្មាសតឹ ភាវេតិ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ឯវំ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។

សេយ្យថាបិ ភិក្ខវេ យេ កេចិ វីជគាមភូតគាមា វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តិ សព្វេ តេ បឋវឹ និស្សាយ បឋវិយំ បតិដ្ឋាយ ឯវមេតេ វីជគាមភូតគាមា វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ បាបុណាតិ ធម្មេសុ ។

ចម្រើនសម្មាអាជីវៈ ចម្រើនសម្មាវាយាមៈ ចម្រើនសម្មាសតិ ចម្រើនសម្មាសមាធិ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុលុះតែអាស្រ័យសីល តាំងនៅក្នុងសីលហើយ ទើបចម្រើន នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន ទើបធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ៨ ដ៏ប្រសើរបាន យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ពីជគាមនិងភូតគាមទាំងឡាយណាមួយ ពីជគាមនិងភូតគាមទាំងអស់នោះ តែងអាស្រ័យផែនដី តាំងស៊ប់លើផែនដីហើយ ទើបដល់នូវការចម្រើន លូតលាស់ ធំទូលាយបាន ពីជគាមនិងភូតគាមទាំងនុ៎ះ តែងដល់នូវការចម្រើន លូតលាស់ ធំទូលាយ ដោយហេតុយ៉ាងនេះ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចភិក្ខុកាលអាស្រ័យសីល តាំងនៅក្នុងសីល ហើយចម្រើននូវមគ្គប្រកបដោយអង្គ៨ ដ៏ប្រសើរ ហើយធ្វើឲ្យច្រើន នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ទើបដល់នូវការចម្រើន លូតលាស់ ធំទូលាយ ក្នុងធម៌ទាំងឡាយបាន។

[១៧៤] កថញ្ច ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ បាបុណាតិ ធម្មេសុ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ សម្មាសង្កប្បំ ភាវេតិ សម្មាវាចំ ភាវេតិ សម្មាកម្មន្តំ ភាវេតិ សម្មាអាជីវំ ភាវេតិ សម្មាវាយាមំ ភាវេតិ សម្មាសតឹ ភាវេតិ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ សម្មាទិដ្ឋិយា បញ្ច វិវេកា បញ្ច វិរាគា បញ្ច និរោធា បញ្ច វោស្សគ្គា ទ្វាទស និស្សយា សម្មាសង្កប្បស្ស ។ បេ ។ សម្មាវាចាយ សម្មាកម្មន្តស្ស សម្មាអាជីវស្ស សម្មាវាយាមស្ស សម្មាសតិយា សម្មាសមាធិស្ស បញ្ច វិវេកា បញ្ច វិរាគា បញ្ច និរោធា បញ្ច វោស្សគ្គា ទ្វាទស និស្សយា ។

[១៧២] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលអាស្រ័យសីល តាំងនៅក្នុងសីល ហើយចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ហើយធ្វើឲ្យច្រើន នូវមគ្គប្រកបដោយអង្គ៨ ដ៏ប្រសើរ ទើបដល់នូវការចម្រើនលូតលាស់ធំទូលាយក្នុងធម៌ទាំងឡាយបាន តើដូចម្តេចខ្វះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសម្មាទិដ្ឋិ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះ ចម្រើនសម្មាសង្កប្បៈ ចម្រើនសម្មាវាចា ចម្រើនសម្មាកម្មន្តៈ ចម្រើនសម្មាអាជីវៈ ចម្រើនសម្មាវាយាមៈ ចម្រើនសម្មាសតិ ចម្រើនសម្មាសមាធិ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះ ។ សម្មាទិដ្ឋិ មានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ សម្មាសង្កប្បៈ ។ បេ ។ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ មានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ ។

[១៧៥] សម្មាទិដ្ឋិយា កតមេ បញ្ច វិវេកា ។ វិក្ខម្ភនវិវេកោ តទង្គវិវេកោ សមុច្ឆេទវិវេកោ បដិប្បស្សទ្ធិវិវេកោ និស្សរណវិវេកោ ។ វិក្ខម្ភនវិវេកោ ច នីវរណានំ បឋមជ្ឈានំ ភាវយតោ តទង្គវិវេកោ ច និព្វេធភាគិយំ សមាធឹ ភាវយតោ សមុច្ឆេទវិវេកោ ច លោកុត្តរំ ខយគាមឹ មគ្គំ ភាវយតោ បដិប្បស្សទ្ធិវិវេកោ ច ផលក្ខណេ និស្សរណវិវេកោ ច និរោធោ និព្វានំ សម្មាទិដ្ឋិយា ឥមេ បញ្ច វិវេកា ។ ឥមេសុ បញ្ចសុ វិវេកេសុ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស ស្វាធិដ្ឋិតំ ។

[១៧៦] សម្មាទិដ្ឋិយា កតមេ បញ្ច វិរាគា ។ វិក្ខម្ភនវិរាគោ តទង្គវិរាគោ សមុច្ឆេទវិរាគោ បដិប្បស្សទ្ធិវិរាគោ និស្សរណវិរាគោ ។ វិក្ខម្ភនវិរាគោ ច នីវរណានំ បឋមជ្ឈានំ ភាវយតោ តទង្គវិរាគោ ច និព្វេធភាគិយំ សមាធឹ ភាវយតោ

បញ្ញាវគ្គ វិវេកកថា

[១៧៥] សម្មាទិដ្ឋិ មានវិវេក ៥ តើដូចម្តេច ។ វិក្ខម្ភនវិវេក ១ តទង្គវិវេក ១ សមុច្ឆេទវិវេក ១ បដិប្បស្សទ្ធិវិវេក ១ និស្សរណវិវេក ១ ។ ឯវិក្ខម្ភនវិវេក សម្រាប់បុគ្គល (កាលលះបង់) នូវនីវរណៈទាំងឡាយ ហើយចម្រើនបឋមជ្ឈាន តទង្គវិវេក សម្រាប់បុគ្គល (កាលលះបង់) នូវទិដ្ឋិទាំងឡាយ ហើយចម្រើនសមាធិ ដែលជាចំណែកនៃសេចក្តីទម្លុះទម្លាយ សមុច្ឆេទវិវេក សម្រាប់បុគ្គល កាលចម្រើនមគ្គ ជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវិវេក មានក្នុងខណៈនៃផល និស្សរណវិវេក គឺជានិរោធ និព្វាន ។ នេះសម្មាទិដ្ឋិ មានវិវេក ៥ ។ បុគ្គលណា មានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ហើយ ក្នុងវិវេកទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថាអធិដ្ឋានល្អហើយ ។

[១៧៦] សម្មាទិដ្ឋិ មានវិរាគៈ ៥ តើដូចម្តេច ។ វិក្ខម្ភនវិរាគៈ ១ តទង្គវិរាគៈ ១ សមុច្ឆេទវិរាគៈ ១ បដិប្បស្សទ្ធិវិរាគៈ ១ និស្សរណវិរាគៈ ១ ។ វិក្ខម្ភនវិរាគៈ សម្រាប់បុគ្គល (កាលលះបង់) នូវនីវរណៈ ហើយចម្រើននូវបឋមជ្ឈាន តទង្គវិរាគៈ សម្រាប់បុគ្គល (កាលលះបង់) នូវទិដ្ឋិ ហើយចម្រើនសមាធិ ដែលជាចំណែកនៃសេចក្តីទម្លុះទម្លាយ

សមុច្ឆេទវិវេកោ ច លោកុត្តរំ ខយគាមឹ មគ្គំ ភាវយតោ បដិប្បស្សទ្ធិវិវេកោ ច ផលក្ខណេ និស្សរណវិវេកោ ច និរោធោ និព្វានំ សម្មាទិដ្ឋិយា ឥមេ បញ្ច វិវេកា ។ ឥមេសុ បញ្ចសុ វិវេកេសុ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស ស្វាធិដ្ឋិតំ ។

[១៧៧] សម្មាទិដ្ឋិយា កតមេ បញ្ច និរោធា ។ វិក្ខម្ភននិរោធោ តទង្គនិរោធោ សមុច្ឆេទនិរោធោ បដិប្បស្សទ្ធិនិរោធោ និស្សរណនិរោធោ ។ វិក្ខម្ភននិរោធោ ច នីវរណានំ បឋមជ្ឈានំ ភាវយតោ តទង្គនិរោធោ ច ទិដ្ឋិគតានំ និព្វេធភាគិយំ សមាធឹ ភាវយតោ សមុច្ឆេទនិរោធោ ច លោកុត្តរំ ខយគាមឹ មគ្គំ ភាវយតោ បដិប្បស្សទ្ធិនិរោធោ ច ផលក្ខណេ និស្សរណនិរោធោ ច អមតា ធាតុ[១] សម្មាទិដ្ឋិយា ឥមេ បញ្ច និរោធា ។ ឥមេសុ បញ្ចសុ និរោធេសុ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស ស្វាធិដ្ឋិតំ ។

---

១ ឱ. និរោធោ និព្វានំ ។

សមុច្ឆេទវិវេក: សម្រាប់បុគ្គល កាលចម្រើនមគ្គ ជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវិវេក: មានក្នុងខណៈនៃផល និស្សរណវិវេក: គឺជានិរោធ និព្វាន នេះ សម្មាទិដ្ឋិ មានវិវេក: ៥ ។ បុគ្គលណា មានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ ក្នុងវិវេកៈទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថាអធិដ្ឋានល្អហើយ ។

[១៧៧] សម្មាទិដ្ឋិ មាននិរោធ ៥ តើដូចម្តេច ។ វិក្ខម្ភននិរោធ ១ តទង្គនិរោធ ១ សមុច្ឆេទនិរោធ ១ បដិប្បស្សទ្ធិនិរោធ ១ និស្សរណនិរោធ ១ ។ ឯវិក្ខម្ភននិរោធ សម្រាប់បុគ្គល (កាលលះបង់) នូវនីវរណៈ ហើយចម្រើនបឋមជ្ឈាន តទង្គនិរោធ សម្រាប់បុគ្គល (កាលលះបង់) នូវទិដ្ឋិ ហើយចម្រើននូវសមាធិ ដែលជាចំណែក នៃសេចក្តីទម្លុះទម្លាយ សមុច្ឆេទនិរោធ សម្រាប់បុគ្គល កាលចម្រើនមគ្គជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិនិរោធ មានក្នុងខណៈនៃផល និស្សរណនិរោធ គឺជាអមតធាតុ នេះសម្មាទិដ្ឋិ មាននិរោធ ៥ ។ បុគ្គលណា មានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ ក្នុងនិរោធទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថាអធិដ្ឋានល្អហើយ ។

[១៧៨] សម្មាទិដ្ឋិយា កតមេ បញ្ច វោស្សគ្គា ។ វិក្ខម្ភនវោស្សគ្គោ តទង្គវោស្សគ្គោ សមុច្ឆេទវោស្ស-គ្គោ បដិប្បស្សទ្ធិវោស្សគ្គោ និស្សរណវោស្សគ្គោ ។ វិក្ខម្ភនវោស្សគ្គោ ច នីវរណានំ បឋមជ្ឈានំ ភាវ-យតោ តទង្គវោស្សគ្គោ ច ទិដ្ឋិគតានំ និព្វេធភាគិយំ សមាធឹ ភាវយតោ សមុច្ឆេទវោស្សគ្គោ ច លោកុត្តរំ ខយគាមឹ មគ្គំ ភាវយតោ បដិប្បស្សទ្ធិវោស្សគ្គោ ច ផលក្ខណេ និស្សរណវោស្សគ្គោ ច និរោធោ និព្វានំ សម្មាទិដ្ឋិយា ឥមេ បញ្ច វោស្សគ្គា ។ ឥមេសុ បញ្ចសុ វោស្សគ្គេសុ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស ស្វាធិដ្ឋិតំ ។

សម្មាទិដ្ឋិយា ឥមេ បញ្ច វិវេកា បញ្ច វិរាគា បញ្ច និរោធា បញ្ច វោស្សគ្គា ទ្វាទស និស្សយា ។

[១៧៩] សម្មាសង្កប្បស្ស ។ បេ ។ សម្មាវាចាយ ។ បេ ។ សម្មាកម្មន្តស្ស ។ បេ ។ សម្មាអាជីវស្ស ។ បេ ។ សម្មាវាយាមស្ស ។ បេ ។ សម្មាសតិយា ។ បេ ។

បញ្ញាវគ្គ វិវេកកថា

[១៧៨] សម្មាទិដ្ឋិមានវោស្សគ្គៈ ៥ តើដូចម្តេច ។ វិក្ខម្ភនវោស្សគ្គៈ ១ តទង្គវោស្សគ្គៈ ១ សមុច្ឆេទវោស្សគ្គៈ ១ បដិប្បស្សទ្ធិវោស្សគ្គៈ ១ និស្សរណវោស្សគ្គៈ ១ ។ ឯវិក្ខម្ភនវោស្សគ្គៈ សម្រាប់បុគ្គល (កាលលះបង់) នូវនីវរណៈទាំងឡាយ ហើយចម្រើនបឋមជ្ឈាន តទង្គវោស្សគ្គៈ សម្រាប់បុគ្គល (កាលលះបង់) នូវទិដ្ឋិទាំងឡាយ ហើយចម្រើនសមាធិ ដែលជាចំណែកនៃសេចក្តីទម្លុះទម្លាយ សមុច្ឆេទវោស្សគ្គៈ សម្រាប់បុគ្គលកាលចម្រើនមគ្គជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវោស្សគ្គៈ មានក្នុងខណៈនៃផល និរោធវោស្សគ្គៈ គឺជានិរោធ និព្វាន នេះសម្មាទិដ្ឋិមានវោស្សគ្គៈ ៥ ។ បុគ្គលណា មានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ ក្នុងវោស្សគ្គៈទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថាអធិដ្ឋានល្អហើយ ។

នេះសម្មាទិដ្ឋិ មានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ ។

[១៧៩] សម្មាសង្កប្បៈ ។ បេ ។ សម្មាវាចា ។ បេ ។ សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ។ បេ ។ សម្មាវាយាមៈ ។ បេ ។ សម្មាសតិ ។ បេ ។

សម្មាសមាធិស្ស កតមេ បញ្ច វិវេកា ។ វិក្ខម្ភនវិវេកោ តទង្គវិវេកោ សមុច្ឆេទវិវេកោ បដិប្បស្សទ្ធិវិវេកោ និស្សរណវិវេកោ ។ វិក្ខម្ភនវិវេកោ ច នីវរណានំ បឋមជ្ឈានំ ភាវយតោ តទង្គវិវេកោ ច ទិដ្ឋិគតានំ និព្វេធភាគិយំ សមាធឹ ភាវយតោ សមុច្ឆេទវិវេកោ ច លោកុត្តរំ ខយគាមឹ មគ្គំ ភាវយតោ បដិប្បស្សទ្ធិវិវេកោ ច ផលក្ខណេ និស្សរណវិវេកោ ច និរោធោ និព្វានំ សម្មាសមាធិស្ស ឥមេ បញ្ច វិវេកា ។ ឥមេសុ បញ្ចសុ វិវេកេសុ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស ស្វាធិដ្ឋិតំ ។

[១៨០] សម្មាសមាធិស្ស កតមេ បញ្ច វិរាគា ។ វិក្ខម្ភនវិរាគោ តទង្គវិរាគោ សមុច្ឆេទវិរាគោ បដិប្បស្សទ្ធិវិរាគោ និស្សរណវិរាគោ ។ វិក្ខម្ភនវិរាគោ ច នីវរណានំ បឋមជ្ឈានំ ភាវយតោ តទង្គវិរាគោ ច ទិដ្ឋិគតានំ និព្វេធភាគិយំ សមាធឹ ភាវយតោ

*សម្មាសមាធិ មានវិវេក ៥ តើដូចម្តេច ។ វិក្ខម្ភនវិវេក ១ តទង្គ-វិវេក ១ សមុច្ឆេទវិវេក ១ បដិប្បស្សទ្ធិវិវេក ១ និស្សរណវិវេក ១ ។ ឯវិក្ខម្ភនវិវេក សម្រាប់បុគ្គល* (*កាលលះបង់*) *នូវនីវរណៈទាំងឡាយហើយ ចម្រើននូវបឋមជ្ឈាន តទង្គវិវេក សម្រាប់បុគ្គល* (*កាលលះបង់*) *នូវទិដ្ឋិទាំង-ឡាយ ហើយចម្រើនសមាធិ ដែលជាចំណែកនៃសេចក្តីទម្លុះទម្លាយ សមុច្ឆេទវិវេក សម្រាប់បុគ្គល កាលចម្រើនមគ្គជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវិវេក មានក្នុងខណៈនៃផល និរោធវិវេក គឺជានិរោធ និព្វាន នេះសម្មាសមាធិ មានវិវេក ៥ ។ បុគ្គលណា មានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ ក្នុងវិវេកទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថាអធិដ្ឋានល្អហើយ ។*

[១៨០] *សម្មាសមាធិ មានវិរាគៈ ៥ តើដូចម្តេច ។ វិក្ខម្ភនវិរាគៈ ១ តទង្គវិរាគៈ ១ សមុច្ឆេទវិរាគៈ ១ បដិប្បស្សទ្ធិវិរាគៈ ១ និស្សរណវិរាគៈ ១ ។ វិក្ខម្ភនវិរាគៈ សម្រាប់បុគ្គល* (*កាលលះបង់*) *នូវនីវរណៈទាំងឡាយ ហើយចម្រើនបឋមជ្ឈាន តទង្គវិរាគៈ សម្រាប់បុគ្គល* (*កាលលះបង់*) *នូវទិដ្ឋិទាំងឡាយ ហើយចម្រើនសមាធិ ដែលជាចំណែក នៃសេចក្តី*

សមុច្ឆេទវិរាគោ ច លោកុត្តរំ ខយគាមី មគ្គំ ភាវ-
យតោ បដិប្បស្សទ្ធិវិរាគោ ច ផលក្ខណេ និស្ស-
រណវិរាគោ ច និរោធោ និព្វានំ សម្មាសមាធិស្ស
ឥមេ បញ្ច វិរាគា ។ ឥមេសុ បញ្ចសុ វិរាគេសុ
ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស
ស្វាធិដ្ឋិតំ ។

[១៨១] សម្មាសមាធិស្ស កតមេ បញ្ច និរោ-
ធា ។ វិក្ខម្ភននិរោធោ តទង្គនិរោធោ សមុច្ឆេទនិរោធោ
បដិប្បស្សទ្ធិនិរោធោ និស្សរណនិរោធោ ។ វិក្ខម្ភន-
និរោធោ ច នីវរណានំ បឋមជ្ឈានំ ភាវយតោ
តទង្គនិរោធោ ច ទិដ្ឋិគតានំ និព្វេធភាគិយំ សមាធឹ
ភាវយតោ សមុច្ឆេទនិរោធោ ច លោកុត្តរំ ខយ-
គាមី មគ្គំ ភាវយតោ បដិប្បស្សទ្ធិនិរោធោ ច ផ-
លក្ខណេ និស្សរណនិរោធោ ច អមតា ធាតុ[១]
សម្មាសមាធិស្ស ឥមេ បញ្ច និរោធា ។ ឥមេសុ
បញ្ចសុ និរោធេសុ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ
ចិត្តំ ចស្ស ស្វាធិដ្ឋិតំ ។

---

១ ឱ. និរោធោ និព្វានំ ។

ទម្ងុះទម្លាយ សមុច្ឆេទវិវេកៈ សម្រាប់បុគ្គល កាលចម្រើនមគ្គជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវិវេកៈ មានក្នុងខណៈនៃផល និស្សរណវិវេកៈ គឺជានិរោធ និព្វាន នេះសម្មាសមាធិ មានវិវេកៈ ៥ ។ បុគ្គលណា មានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ ក្នុងវិវេកៈទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថាអធិដ្ឋានល្អហើយ ។

[១៨១] សម្មាសមាធិ មាននិរោធ ៥ តើដូចម្ដេច ។ វិក្ខម្ភននិរោធ ១ តទង្គនិរោធ ១ សមុច្ឆេទនិរោធ ១ បដិប្បស្សទ្ធិនិរោធ ១ និស្សរណនិរោធ ១ ។ ឯវិក្ខម្ភននិរោធ សម្រាប់បុគ្គល (កាលលះបង់) នូវនីវរណៈទាំងឡាយ ហើយចម្រើននូវបឋមជ្ឈាន តទង្គនិរោធ សម្រាប់បុគ្គល (កាលលះបង់) នូវទិដ្ឋិទាំងឡាយ ហើយចម្រើនសមាធិ ដែលជាចំណែកនៃសេចក្ដីទម្ងុះទម្លាយ សមុច្ឆេទនិរោធ សម្រាប់បុគ្គលកាលចម្រើនមគ្គជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិនិរោធ មានក្នុងខណៈនៃផល និស្សរណនិរោធ គឺជានិរោធ និព្វាន នេះ សម្មាសមាធិ មាននិរោធ ៥ ។ បុគ្គលណា មានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ ក្នុងនិរោធទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថាអធិដ្ឋានល្អហើយ ។

[១៨២] សម្មាសមាធិស្ស កតមេ បញ្ច វោស្សគ្គា ។ វិក្ខម្ភនវោស្សគ្គោ តទង្គវោស្សគ្គោ សមុច្ឆេទវោស្សគ្គោ បដិប្បស្សទ្ធិវោស្សគ្គោ និស្សរណវោស្សគ្គោ ។ វិក្ខម្ភនវោស្សគ្គោ ច នីវរណានំ បឋមជ្ឈានំ ភាវយតោ តទង្គវោស្សគ្គោ ច ទិដ្ឋិគតានំ និព្វេធភាគិយំ សមាធឹ ភាវយតោ សមុច្ឆេទវោស្សគ្គោ ច លោកុត្តរំ ខយគាមឹ មគ្គំ ភាវយតោ បដិប្បស្សទ្ធិវោស្សគ្គោ ច ផលក្ខណេ និស្សរណវោស្សគ្គោ ច និរោធោ និព្វានំ សម្មាសមាធិស្ស ឥមេ បញ្ច វោស្សគ្គា ឥមេសុ បញ្ចសុ វោស្សគ្គេសុ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស ស្វាធិដ្ឋិតំ ។

សម្មាសមាធិស្ស ឥមេ បញ្ច វិវេកា បញ្ច វិរាគា បញ្ច និរោធា បញ្ច វោស្សគ្គា ទ្វាទស និស្សយា ។

[១៨២] សម្មាសមាធិ មានវោស្សគ្គៈ ៥ តើដូចម្តេច ។ វិក្ខម្ភនវោស្សគ្គៈ ១ តទង្គវោស្សគ្គៈ ១ សមុច្ឆេទវោស្សគ្គៈ ១ បដិប្បស្សទ្ធិវោស្សគ្គៈ ១ និស្សរណវោស្សគ្គៈ ១ ។ ឯវិក្ខម្ភនវោស្សគ្គៈ សម្រាប់បុគ្គល (កាលលះបង់) នូវនីវរណៈ ហើយចម្រើនបឋមជ្ឈាន តទង្គវោស្សគ្គៈ សម្រាប់បុគ្គល (កាលលះបង់) នូវទិដ្ឋិ ហើយចម្រើនសមាធិ ដែលជាចំណែកនៃសេចក្តីទម្លុះទម្លាយ សមុច្ឆេទវោស្សគ្គៈ សម្រាប់បុគ្គលកាលចម្រើនមគ្គជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវោស្សគ្គៈ មានក្នុងខណៈនៃផល និរោធវោស្សគ្គៈ គឺជានិរោធ និព្វាន នេះ សម្មាសមាធិ មានវោស្សគ្គៈ ៥ ។ បុគ្គលណា មានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ ក្នុងវោស្សគ្គៈទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថាអធិដ្ឋានល្អហើយ ។

នេះ សម្មាសមាធិ មានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ ។

[១៨៣] សេយ្យថាបិ ភិក្ខវេ យេ កេចិ ពលករណីយា[១] កម្មន្តា ករីយន្តិ សព្វេ តេ បឋវឹ និស្សាយ បឋវិយំ បតិដ្ឋាយ ឯវមេតេ ពលករណីយា កម្មន្តា ករីយន្តិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតិ ។ បេ ។ សត្ត ពោជ្ឈង្គេ ភាវេន្តោ សត្ត ពោជ្ឈង្គេ ពហុលីករោន្តោ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ បាបុណាតិ ធម្មេសុ ។ បេ ។ បញ្ច ពលានិ ភាវេតិ បញ្ច ពលានិ ពហុលីករោតិ ។ បេ ។ បញ្ច ពលានិ ភាវេន្តោ បញ្ច ពលានិ ពហុលីករោន្តោ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ បាបុណាតិ ធម្មេសុ ។ បេ ។ បញ្ចិន្ទ្រិយានិ ភាវេតិ បញ្ចិន្ទ្រិយានិ ពហុលីករោតិ ។ បេ ។

---

១ ឱ. ពហុលករណីយា ។

[១៨៣] ម្នាលភិក្ខុទាំងឡាយ ការងារទាំងឡាយណាមួយ ដែលត្រូវធ្វើដោយកម្លាំង ការងារទាំងអស់នោះ បុគ្គលលុះតែអាស្រ័យផែនដី ឈរលើផែនដី ទើបធ្វើបាន ការងារទាំងឡាយ ដែលត្រូវធ្វើដោយកម្លាំងនុ៎ះ បុគ្គលតែងធ្វើ យ៉ាងនេះ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូច ភិក្ខុលុះតែអាស្រ័យសីល តាំងនៅក្នុងសីលហើយ ទើបចម្រើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ បាន ។ បេ ។ ភិក្ខុកាលចម្រើននូវពោជ្ឈង្គទាំង ៧ កាលធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ រមែងដល់នូវការចម្រើន លូតលាស់ ធំទូលាយក្នុងធម៌ទាំងឡាយ ។ បេ ។ ភិក្ខុចម្រើន នូវពលៈ ៥ ធ្វើឲ្យច្រើននូវពលៈ ៥ ។ បេ ។ ភិក្ខុកាលចម្រើន នូវពលៈ ៥ កាលធ្វើឲ្យច្រើននូវពលៈ ៥ រមែងដល់នូវការចម្រើន លូតលាស់ ធំទូលាយ ក្នុងធម៌ទាំងឡាយ ។ បេ ។ ភិក្ខុចម្រើននូវឥន្ទ្រិយ ៥ ធ្វើឲ្យច្រើន នូវឥន្ទ្រិយ ៥ ។ បេ ។

សេយ្យថាបិ ភិក្ខវេ យេ កេចិ វីជគាមភូត-
គាមា វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តិ សព្វេ តេ
បឋវឹ និស្សាយ បឋវិយំ បតិដ្ឋាយ ឯវមេតេ វីជ-
គាមភូតគាមា វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តិ ឯវ-
មេវ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ
បតិដ្ឋាយ បញ្ចិន្ទ្រិយានិ ភាវេន្តោ បញ្ចិន្ទ្រិយានិ
ពហុលីករោន្តោ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ បាបុណាតិ
ធម្មេសុ ។

[១៨៤] កថញ្ច ភិក្ខវេ ភិក្ខុ សីលំ និស្សា-
យ សីលេ បតិដ្ឋាយ បញ្ចិន្ទ្រិយានិ ភាវេន្តោ បញ្ចិ-
ន្ទ្រិយានិ ពហុលីករោន្តោ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ
បាបុណាតិ ធម្មេសុ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធិន្ទ្រិ-
យំ ភាវេតិ វិវេកនិស្សិតំ និរោធនិស្សិតំ វោស្ស-
គ្គបរិណាមឹ វីរិយិន្ទ្រិយំ ភាវេតិ ។ បេ ។ សតិន្ទ្រិយំ
ភាវេតិ សមាធិន្ទ្រិយំ ភាវេតិ បញ្ញិន្ទ្រិយំ ភាវេតិ

ម្នាលភិក្ខុទាំងឡាយ ពីជគាមនិងភូតគាម ឯណាមួយ ពីជគាមនិងភូតគាម ទាំងអស់នោះ តែងអាស្រ័យនូវផែនដី តាំងនៅលើផែនដី ទើបដល់នូវការចម្រើន លូតលាស់ ធំទូលាយបាន ពីជគាមនិងភូតគាមនុ៎ះ តែងដល់នូវការចម្រើន លូតលាស់ ធំទូលាយ ដោយហេតុយ៉ាងនេះ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូច ភិក្ខុកាលអាស្រ័យសីល តាំងនៅក្នុងសីល ហើយចម្រើន នូវឥន្ទ្រិយ ៥ ហើយធ្វើឲ្យច្រើន នូវឥន្ទ្រិយ ៥ ទើបដល់នូវការចម្រើន លូតលាស់ ធំទូលាយ ក្នុងធម៌ទាំងឡាយបាន ។

[១៨៤] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលអាស្រ័យសីល តាំងនៅក្នុងសីល ហើយចម្រើននូវឥន្ទ្រិយ ៥ ហើយធ្វើឲ្យច្រើន នូវឥន្ទ្រិយ ៥ ទើបដល់នូវការចម្រើន លូតលាស់ ធំទូលាយ ក្នុងធម៌ទាំងឡាយបាន តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសទ្ធិន្ទ្រិយ ដែលអាស្រ័យវិវេក អាស្រ័យនិរោធ បង្អោនទៅដើម្បីលះ ចម្រើនវីរិយិន្ទ្រិយ ។ បេ ។ ចម្រើនសតិន្ទ្រិយ ចម្រើនសមាធិន្ទ្រិយ ចម្រើនបញ្ញិន្ទ្រិយ

វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ សទ្ធិន្ទ្រិយស្ស បញ្ច វិវេកា បញ្ច វិរាគា បញ្ច និរោធា បញ្ច វោស្សគ្គា ទ្វាទស និស្សយា ។ បេ ។ វីរិយិន្ទ្រិយស្ស ។ បេ ។ សតិន្ទ្រិយស្ស ។ បេ ។ សមាធិន្ទ្រិយស្ស បញ្ញិន្ទ្រិយស្ស បញ្ច វិវេកា បញ្ច វិរាគា បញ្ច និរោធា បញ្ច វោស្សគ្គា ទ្វាទស និស្សយា ។

[១៨៥] សទ្ធិន្ទ្រិយស្ស កតមេ បញ្ច វិវេកា វិក្ខម្ភនវិវេកោ តទង្គវិវេកោ សមុច្ឆេទវិវេកោ បដិប្បស្សទ្ធិវិវេកោ និស្សរណវិវេកោ វិក្ខម្ភនវិវេកោ ច នីវរណានំ បឋមជ្ឈានំ ភាវយតោ តទង្គវិវេកោ ច ទិដ្ឋិគតានំ និព្វេធភាគិយំ សមាធឹ ភាវយតោ សមុច្ឆេទវិវេកោ ច លោកុត្តរំ ខយគាមឹ មគ្គំ ភាវយតោ បដិប្បស្សទ្ធិវិវេកោ ច ផលក្ខណេ

ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះ ។ សទ្ធិន្ទ្រិយ មានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ ។ បេ ។ វីរិយិន្ទ្រិយ ។ បេ ។ សតិន្ទ្រិយ ។ បេ ។ សមាធិន្ទ្រិយ ។ បេ ។ បញ្ញិន្ទ្រិយ មានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ ។

[១៨៥] សទ្ធិន្ទ្រិយ មានវិវេក ៥ តើដូចម្តេច ។ វិក្ខម្ភនវិវេក ១ តទង្គវិវេក ១ សមុច្ឆេទវិវេក ១ បដិប្បស្សទ្ធិវិវេក ១ និស្សរណវិវេក ១ ។ ឯវិក្ខម្ភនវិវេក សម្រាប់បុគ្គល (កាលលះបង់) នូវនីវរណៈ ទាំងឡាយ ហើយចម្រើនបឋមជ្ឈាន តទង្គវិវេក សម្រាប់បុគ្គល (កាលលះបង់) នូវទិដ្ឋិទាំងឡាយ ហើយចម្រើនសមាធិ ដែលជាចំណែកនៃសេចក្តីទម្លុះទម្លាយ សមុច្ឆេទវិវេក សម្រាប់បុគ្គល កាលចម្រើនមគ្គជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវិវេក មានក្នុងខណៈនៃផល

និស្សរណវិវេកោ ច និរោធោ និព្វានំ សទ្ធិន្ទ្រិយស្ស ឥមេ បញ្ច វិវេកា ឥមេសុ បញ្ចសុ វិវេកេសុ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស ស្វាធិដ្ឋិតំ ។ សទ្ធិន្ទ្រិយស្ស ឥមេ បញ្ច វិវេកា បញ្ច វិរាគា បញ្ច និរោធា បញ្ច វោស្សគ្គា ទ្វាទស និស្សយា វីរិយិន្ទ្រិយស្ស ។ បេ ។ សតិន្ទ្រិយស្ស ។ បេ ។ សមាធិន្ទ្រិយស្ស ។ បេ ។

បញ្ញិន្ទ្រិយស្ស កតមេ បញ្ច វិវេកា ។ វិក្ខម្ភនវិវេកោ តទង្គវិវេកោ សមុច្ឆេទវិវេកោ បដិប្បស្សទ្ធិវិវេកោ និស្សរណវិវេកោ ។ បេ ។ បញ្ញិន្ទ្រិយស្ស ឥមេ បញ្ច វិវេកា បញ្ច វិរាគា បញ្ច និរោធា បញ្ច វោស្សគ្គា ទ្វាទស និស្សយាតិ ។

វិវេកកថា និដ្ឋិតា ។

---

និស្សរណវិវេក គឺជានិរោធ និព្វាន នេះ សទ្ធិន្ទ្រិយ មានវិវេក ៥ ។ បុគ្គលណា មានឆន្ទៈ កើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ ក្នុងវិវេកទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថាអធិដ្ឋានល្អហើយ ។ នេះ សទ្ធិន្ទ្រិយ មានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ ។ វីរិយិន្ទ្រិយ ។ បេ ។ សតិន្ទ្រិយ ។ បេ ។ សមាធិន្ទ្រិយ ។ បេ ។

បញ្ញិន្ទ្រិយ មានវិវេក ៥ តើដូចម្តេច ។ វិក្ខម្ភនវិវេក ១ តទង្គ-វិវេក ១ សមុច្ឆេទវិវេក ១ បដិប្បស្សទ្ធិវិវេក ១ និស្សរណវិវេក ១ ។ បេ ។ នេះ បញ្ញិន្ទ្រិយ មានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មាននិស្ស័យ ១២ ។

ចប់ វិវេកកថា ។

---

# បញ្ញាវគ្គេ ចរិយាកថា

[១៨៦] ចរិយាតិ អដ្ឋ ចរិយាយោ ឥរិយាបថចរិយា អាយតនចរិយា សតិចរិយា សមាធិចរិយា ញាណចរិយា មគ្គចរិយា បត្តិចរិយា លោកត្ថចរិយា ។

ឥរិយាបថចរិយាតិ ចតូសុ ឥរិយាបថេសុ ។ អាយតនចរិយាតិ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ ។ សតិចរិយាតិ ចតូសុ សតិប្បដ្ឋានេសុ ។ សមាធិចរិយាតិ ចតូសុ ឈានេសុ ។ ញាណចរិយាតិ ចតូសុ អរិយសច្ចេសុ ។ មគ្គចរិយាតិ ចតូសុ អរិយមគ្គេសុ ។ បត្តិចរិយាតិ ចតូសុ សាមញ្ញផលេសុ ។ លោកត្ថចរិយាតិ តថាគតេសុ អរហន្តេសុ សម្មាសម្ពុទ្ធេសុ បទេសោ[១] បច្ចេកពុទ្ធេសុ បទេសោ[១] សាវកេសុ ។

---

១ ម. បទេសេ ។

# បញ្ញាវគ្គ ចរិយាកថា

[១៨៦] ពាក្យថា ចរិយា បានដល់ចរិយា ៨ គឺ ឥរិយាបថ-ចរិយា ១ អាយតនចរិយា ១ សតិចរិយា ១ សមាធិចរិយា ១ ញាណ-ចរិយា ១ មគ្គចរិយា ១ បត្តិចរិយា ១ លោកត្ថចរិយា ១ ។

ការប្រព្រឹត្ត ក្នុងឥរិយាបថ ទាំង ៤ ឈ្មោះថាឥរិយាបថចរិយា ។ ការប្រព្រឹត្ត ក្នុងអាយតនៈ ៦ ទាំងខាងក្នុងនិងខាងក្រៅ ឈ្មោះថា អាយតនចរិយា ។ ការប្រព្រឹត្ត ក្នុងសតិប្បដ្ឋាន ៤ ឈ្មោះថា សតិចរិយា ។ ការប្រព្រឹត្ត ក្នុងឈាន ៤ ឈ្មោះថា សមាធិ-ចរិយា ។ ការប្រព្រឹត្ត ក្នុងអរិយសច្ច ៤ ឈ្មោះថាញាណចរិយា ។ ការប្រព្រឹត្ត ក្នុងអរិយមគ្គ ៤ ឈ្មោះថាមគ្គចរិយា ។ ការប្រព្រឹត្តក្នុង សាមញ្ញផល ៤ ឈ្មោះថាបត្តិចរិយា ។ ការប្រព្រឹត្តក្នុងព្រះតថាគត អរហន្តសម្មាសម្ពុទ្ធទាំងឡាយ ក្នុងព្រះបច្ចេកពុទ្ធ ដោយចំណែកខ្លះ ក្នុងសាវ័កទាំងឡាយ ដោយចំណែកខ្លះ ឈ្មោះថាលោកត្ថចរិយា ។

ឥរិយាបថចរិយា ច បណិធិសម្បន្នានំ អាយតនចរិយា ច ឥន្ទ្រិយេសុ គុត្តទ្វារានំ សតិចរិយា ច អប្បមាទវិហារីនំ សមាធិចរិយា ច អធិចិត្តមនុយុត្តានំ ញាណចរិយា ច ពុទ្ធិសម្បន្នានំ មគ្គចរិយា ច សម្មាបដិបន្នានំ បត្តិចរិយា ច អធិគតផលានំ លោកត្ថចរិយា ច តថាគតានំ អរហន្តានំ សម្មាសម្ពុទ្ធានំ បទេសោ បច្ចេកពុទ្ធានំ បទេសោ សាវកានំ ឥមា អដ្ឋ ចរិយាយោ ។

[១៨៧] អបរាបិ អដ្ឋ ចរិយាយោ អធិមុច្ចន្តោ សទ្ធាយ ចរតិ បគ្គណ្ហន្តោ វីរិយេន ចរតិ ឧបដ្ឋាបេន្តោ សតិយា ចរតិ អវិក្ខេបំ ករោន្តោ សមាធិនា ចរតិ បជានន្តោ បញ្ញាយ ចរតិ វិជានន្តោ វិញ្ញាណេន ចរតិ ឯវំ បដិបន្នោ វិសេសមធិគច្ឆតីតិ វិសេសចរិយាយ ចរតិ ឯវំ បដិបន្នស្ស កុសលា ធម្មា អាយាបេន្តីតិ អាយតនចរិយាយ ចរតិ ឥមា អដ្ឋ ចរិយាយោ ។

ឯឥរិយាបថចរិយា សម្រាប់បុគ្គលអ្នកបរិបូណ៌ដោយបណិធិ (ការប្រាថ្នា) អាយតនចរិយា សម្រាប់បុគ្គលអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំង-ឡាយ សតិចរិយា សម្រាប់បុគ្គលអ្នកមានកិរិយានៅដោយមិនប្រមាទ សមាធិចរិយា សម្រាប់បុគ្គលអ្នកប្រកបក្នុងអធិចិត្ត ញាណចរិយា សម្រាប់បុគ្គលអ្នកបរិបូណ៌ដោយប្រាជ្ញា មគ្គចរិយា សម្រាប់បុគ្គលអ្នកប្រតិបត្តិត្រូវ បត្តិចរិយា សម្រាប់បុគ្គលអ្នកបានសម្រេចផលហើយ លោកត្ថចរិយា សម្រាប់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធទាំងឡាយ សម្រាប់ព្រះបច្ចេកពុទ្ធទាំងឡាយ ដោយចំណែកខ្លះ សម្រាប់សាវ័កទាំងឡាយ ដោយចំណែកខ្លះ នេះចរិយា ៨ ។

[១៨៧] ចរិយា មាន ៨ ដទៃទៀត គឺ បុគ្គលកាលជឿស៊ប់ ប្រព្រឹត្តដោយសទ្ធា ១ កាលផ្គង ប្រព្រឹត្តដោយព្យាយាម ១ កាលប្រុង ប្រព្រឹត្តដោយសតិ ១ កាលធ្វើនូវការមិនរាយមាយ ប្រព្រឹត្តដោយ សមាធិ ១ កាលដឹង ប្រព្រឹត្តដោយបញ្ញា ១ កាលដឹងច្បាស់ ប្រព្រឹត្ត ដោយវិញ្ញាណ ១ ប្រព្រឹត្តដោយវិសេសចរិយា ព្រោះគិតថា បុគ្គល ប្រតិបត្តិយ៉ាងនេះ រមែងបាននូវគុណវិសេស ១ ប្រព្រឹត្តដោយអាយ-តនចរិយា ព្រោះគិតថា កុសលធម៌ទាំងឡាយ តែងចម្រើនដល់ បុគ្គល អ្នកប្រតិបត្តិយ៉ាងនេះ ១ នេះ ចរិយាទាំង ៨ ។

[១៨៨] អបរាបិ អដ្ឋ ចរិយាយោ ឧស្សនចរិយា ច សម្មាទិដ្ឋិយា អភិរោបនចរិយា ច សម្មាសង្កប្បស្ស បរិគ្គហចរិយា ច សម្មាវាចាយ សមុដ្ឋានចរិយា ច សម្មាកម្មន្តស្ស វោទានចរិយា ច សម្មាអាជីវស្ស បគ្គហចរិយា ច សម្មាវាយាមស្ស ឧបដ្ឋានចរិយា ច សម្មាសតិយា អវិក្ខេបចរិយា ច សម្មាសមាធិស្ស ឥមា អដ្ឋ ចរិយាយោតិ ។

ចរិយាកថា និដ្ឋិតា ។

---

[១៨៨] ចរិយា មាន ៨ ដទៃទៀត គឺ ទស្សនចរិយា នៃ សម្មាទិដ្ឋិ ១ អភិរោបនចរិយា នៃសម្មាសង្កប្បៈ ១ បរិគ្គហចរិយា នៃ សម្មាវាចា ១ សមុដ្ឋានចរិយា នៃសម្មាកម្មន្តៈ ១ វោទានចរិយា នៃ សម្មាអាជីវៈ ១ បគ្គហចរិយា នៃសម្មាវាយាមៈ ១ ឧបដ្ឋានចរិយា នៃ សម្មាសតិ ១ អវិក្ខេបចរិយា នៃសម្មាសមាធិ ១ នេះ ចរិយា ៨ ។

ចប់ ចរិយាកថា ។

# បញ្ញាវគ្គេ បាដិហារិយកថា

[១៨៩] តីណិមានិ ភិក្ខវេ បាដិហារិយានិ កតមានិ តីណិ ឥទ្ធិប្បាដិហារិយំ អាទេសនាបាដិ-ហារិយំ អនុសាសនីបាដិហារិយំ ។

[១៩០] កតមញ្ច ភិក្ខវេ ឥទ្ធិប្បាដិហារិយំ ឥធ ភិក្ខវេ ឯកច្ចោ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ឥទំ វុច្ចតិ ភិក្ខវេ ឥទ្ធិប្បាដិហារិយំ ។

[១៩១] កតមញ្ច ភិក្ខវេ អាទេសនាបាដិហារិ-យំ ឥធ ភិក្ខវេ ឯកច្ចោ និមិត្តេន អាទិសតិ ឯវម្បិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ សោ ពហុញ្ចេបិ អាទិសតិ តថេវ តំ ហោតិ

# បញ្ញាវគ្គ បាដិហារិយកថា

[១៨៩] ម្នាលភិក្ខុទាំងឡាយ បាដិហារ្យ នេះ មាន ៣ ។ បាដិហារ្យ ៣ គឺអ្វីខ្លះ គឺ ឥទ្ធិប្បាដិហារ្យ ១ អាទេសនាបាដិហារិយ៍ ១ អនុសាសនីបាដិហារ្យ ។

[១៩០] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិប្បាដិហារ្យ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ សម្ដែងនូវឫទ្ធិបានច្រើនប្រការ គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជាម្នាក់វិញក៏បាន ដើរទម្លុះទៅកាន់ទីវាល ទីខាងក្រៅ ។ បេ ។ ញុំាងអំណាចឲ្យប្រព្រឹត្តទៅទាំងកាយ រហូតដល់ព្រហ្មលោកក៏បាន ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា ឥទ្ធិប្បាដិហារ្យ ។

[១៩១] ម្នាលភិក្ខុទាំងឡាយ អាទេសនាបាដិហារ្យ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ទាយដោយនិមិត្តថា មនោរបស់អ្នក យ៉ាងនេះខ្លះ មនោរបស់អ្នក មានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ បើបុគ្គលនោះទាយឲ្យច្រើន ការទាយនោះ ក៏នៅតែយ៉ាង

នោ អញ្ញថា ឥធ បន ភិក្ខុវេ ឯកច្ចោ ន ហេវ ខោ និមិត្តេន អាទិសតិ អបិ ច ខោ មនុស្សានំ វា អមនុស្សានំ វា ទេវានំ វា សទ្ទំ សុត្វា អាទិសតិ ឯវម្បិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ សោ ពហុញ្ចេបិ អាទិសតិ តថេវ តំ ហោតិ នោ អញ្ញថា ឥធ បន ភិក្ខុវេ ឯកច្ចោ ន ហេវ ខោ និមិត្តេន អាទិសតិ នបិ មនុស្សានំ វា អមនុស្សានំ វា ទេវានំ វា សទ្ទំ សុត្វា អាទិសតិ អបិ ច ខោ វិតក្កយតោ វិចារយតោ វិតក្កវិចារសទ្ទំ សុត្វា អាទិសតិ ឯវម្បិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ សោ ពហុញ្ចេបិ អាទិសតិ តថេវ តំ ហោតិ នោ អញ្ញថា ឥធ បន ភិក្ខុវេ ឯកច្ចោ ន ហេវ ខោ និមិត្តេន អាទិសតិ នបិ មនុស្សានំ វា អមនុស្សានំ វា ទេវានំ វា សទ្ទំ សុត្វា អាទិសតិ

នោះដដែល គ្មានប្លែកទេ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកមួយ ក្នុងលោកនេះ មិនទាយដោយនិមិត្តទេ គ្រាន់តែឮសំឡេងមនុស្ស ឬអមនុ-ស្ស ឬទេវតាហើយ ក៏ទាយថា មនោរបស់អ្នក យ៉ាងនេះខ្លះ មនោរបស់អ្នក មានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នក ដូច្នេះខ្លះ បើទុកជាបុគ្គលនោះទាយឲ្យច្រើន ការទាយនោះ ក៏នៅតែយ៉ាងនោះដដែល គ្មានប្លែកទេ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកមួយ ក្នុងលោកនេះ មិនទាយដោយនិមិត្តទេ ទាំងមិនបានឮសំឡេងមនុស្ស ឬអមនុស្ស ឬទេវតាហើយទាយទេ តែបានឮសំឡេងនៃការត្រិះរិះឬការពិចារណា របស់បុគ្គលកំពុងត្រិះរិះ ឬកំពុងពិចារណាហើយ ក៏ទាយថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នកមានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ប្រសិនបើបុគ្គលនោះទាយឲ្យច្រើន ការទាយនោះ ក៏នៅតែយ៉ាងនោះដដែល គ្មានប្លែកទេ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលពួកមួយ ក្នុងលោកនេះ មិនទាយដោយនិមិត្តទេ មិនឮសំឡេងមនុស្ស ឬអមនុស្ស ឬទេវតា ហើយ

ន វិតក្កយតោ វិចារយតោ វិតក្កវិចារសទ្ទំ សុត្វា អាទិសតិ អបិ ច ខោ អវិតក្កំ អវិចារំ សមាធឹ សមាបន្នស្ស ចេតសា ចេតោ បរិច្ច បជានាតិ យថា ឥមស្ស ភោតោ មនោសង្ខារា បណិហិតា តថា ឥមស្ស ចិត្តស្ស អនន្តរា អមុន្នាម[១] វិតក្កំ វិតក្កេស្សតីតិ សោ ពហុញ្ចេបិ អាទិសតិ តថេវ តំ ហោតិ នោ អញ្ញថា ឥទំ វុច្ចតិ ភិក្ខវេ អាទេសនាបាដិហារិយំ ។

[១៩២] កតមញ្ច ភិក្ខវេ អនុសាសនីបាដិហារិយំ ឥធ បន ភិក្ខវេ ឯកច្ចោ ឯវំ អនុសាសតិ ឯវំ វិតក្កេថ មា ឯវំ វិតក្កយិត្ថ ឯវំ មនសិករោថ មា ឯវំ មនសាការិត្ថ ឥទំ បជហថ ឥទំ ឧបសម្បជ្ជ វិហរថាតិ ឥទំ វុច្ចតិ ភិក្ខវេ អនុសាសនីបាដិហារិយំ ឥមានិ ខោ ភិក្ខវេ តីណិ បាដិហារិយានិ ។

---

១ ឱ. អមុកំ នាម ។

ទាយទេ មិនឮសំឡេងនៃការត្រិះរិះ ឬការពិចារណា របស់បុគ្គលកំពុងត្រិះរិះ ឬពិចារណាហើយទាយទេ គ្រាន់តែកំណត់ដឹងដោយចិត្ត នូវចិត្តរបស់បុគ្គល ដែលចូលកាន់សមាធិ មិនមានវិតក្កៈ មិនមានវិចារៈថា មនោសង្ខារទាំងឡាយ ដែលលោកដ៏ចម្រើននេះ បានតាំងទុកហើយដោយប្រការណា លោកដ៏ចម្រើននោះ នឹងត្រិះរិះនូវវិតក្កៈ បែបនេះ ក្នុងលំដាប់នៃចិត្តនេះ ដោយប្រការនោះ បើបុគ្គលនោះ ទាយឲ្យច្រើនការទាយនោះ ក៏នៅតែយ៉ាងនោះដដែល គ្មានប្លែកទេ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា អាទេសនាបាដិហារ្យ ។

[១៩២] ម្នាលភិក្ខុទាំងឡាយ អនុសាសនីបាដិហារ្យ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ តែងប្រៀនប្រដៅយ៉ាងនេះថា អ្នកទាំងឡាយ ចូរត្រិះរិះយ៉ាងនេះចុះ កុំត្រិះរិះយ៉ាងនេះឡើយ ចូរធ្វើទុកក្នុងចិត្តយ៉ាងនេះចុះ កុំធ្វើទុកក្នុងចិត្តយ៉ាងនេះឡើយ ចូរលះបង់អំពើនេះ ចូរចូលឈាននេះទៅ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនុសាសនីបាដិហារ្យ ម្នាលភិក្ខុទាំងឡាយ នេះឯង បាដិហារ្យ ៣ យ៉ាង ។

[១៩៣] នេក្ខម្មំ ឥជ្ឈតីតិ ឥទ្ធិ កាមច្ឆន្ទំ ប-
ដិហរតីតិ ចាដិហារិយំ យេ តេន នេក្ខម្មេន
សមន្នាគតា សព្វេ តេ វិសុទ្ធិចិត្តា អនាវិល-
សង្កប្បាតិ អាទេសនាចាដិហារិយំ តំ ខោ បន
នេក្ខម្មំ ឃរំ អាសេវិតព្វំ ឃរំ ភាវេតព្វំ ឃរំ ពហុ-
លីកាតព្វំ ឃរំ តទនុធម្មតាសតិ ឧបដ្ឋាបេតព្វាតិ
អនុសាសនីចាដិហារិយំ អព្យាចាទោ ឥជ្ឈតីតិ ឥទ្ធិ
ព្យាចាទំ បដិហរតីតិ ចាដិហារិយំ យេ តេន
អព្យាចាទេន សមន្នាគតា សព្វេ តេ វិសុទ្ធិចិត្តា
អនាវិលសង្កប្បាតិ អាទេសនាចាដិហារិយំ សោ
ខោ បន អព្យាចាទោ ឃរំ អាសេវិតព្វោ ឃរំ
ភាវេតព្វោ ឃរំ ពហុលីកាតព្វោ ឃរំ តទនុធម្មតា-
សតិ ឧបដ្ឋាបេតព្វាតិ អនុសាសនីចាដិហារិយំ អា-
លោកសញ្ញា ឥជ្ឈតីតិ ឥទ្ធិ ថីនមិទ្ធំ បដិហរតីតិ

[១៩៣] ឈ្មោះថាឥទ្ធិ ព្រោះនេក្ខម្មៈសម្រេច ឈ្មោះថាបាដិហារ្យ ព្រោះកម្ចាត់បង់នូវកាមច្ឆន្ទៈ ឈ្មោះថាអាទេសនាបាដិហារ្យ ព្រោះជនទាំងឡាយណា ប្រកបដោយនេក្ខម្មៈនោះ ពួកជនទាំងអស់នោះ ជាអ្នកមានចិត្តបរិសុទ្ធ មានតម្រិះមិនល្អក់ ឈ្មោះថា អនុសាសនីបាដិហារ្យ ព្រោះនេក្ខម្មៈនោះឯង បណ្ឌិតត្រូវសេពយ៉ាងនេះ ត្រូវចម្រើនយ៉ាងនេះ ត្រូវធ្វើឲ្យច្រើនយ៉ាងនេះ ត្រូវតម្កល់ទុកនូវសតិ ដ៏សមគួរដល់នេក្ខម្មៈនោះយ៉ាងនេះ ឈ្មោះថាឥទ្ធិ ព្រោះការមិនមានព្យាបាទសម្រេច ឈ្មោះថាបាដិហារ្យ ព្រោះកម្ចាត់បង់នូវព្យាបាទ ឈ្មោះថាអាទេសនាបាដិហារ្យ ព្រោះជនទាំងឡាយណា ប្រកបដោយការមិនមានព្យាបាទនោះ ពួកជនទាំងអស់នោះ ជាអ្នកមានចិត្តបរិសុទ្ធ មានតម្រិះមិនល្អក់ ឈ្មោះថា អនុសាសនីបាដិហារ្យ ព្រោះការមិនមានព្យាបាទនោះ បណ្ឌិតត្រូវសេពយ៉ាងនេះ ត្រូវចម្រើនយ៉ាងនេះ ត្រូវធ្វើឲ្យច្រើនយ៉ាងនេះ ត្រូវតម្កល់ទុកនូវសតិដ៏សមគួរដល់ការមិនមានព្យាបាទនោះយ៉ាងនេះ ឈ្មោះថាឥទ្ធិ ព្រោះអាលោកសញ្ញាសម្រេច ឈ្មោះថាបាដិហារ្យ ព្រោះកម្ចាត់បង់នូវថីនមិទ្ធៈ

ចាដិហារិយំ យេ តាយ អាលោកសញ្ញាយ សមន្នាគតា សព្វេ តេ វិសុទ្ធិចិត្តា អនាវិលសង្ក-ប្បាតិ អាទេសនាចាដិហារិយំ សា ខោ បន អាលោកសញ្ញា ឯវំ អាសេវិតត្តា ឯវំ ភាវេ-តត្តា ឯវំ ពហុលីកាតត្តា ឯវំ តទនុធម្មតាសតិ ឧបដ្ឋាបេតត្តាតិ អនុសាសនីចាដិហារិយំ អវិក្ខេបោ ឥជ្ឈតីតិ ឥទ្ធិ ឧទ្ធច្ចំ បដិហរតីតិ ចាដិហារិយំ យេ តេន អវិក្ខេបេន សមន្នាគតា សព្វេ តេ វិសុទ្ធិចិត្តា អនាវិលសង្កប្បាតិ អាទេសនាចាដិហារិយំ សោ ខោ បន អវិក្ខេបោ ឯវំ អាសេវិតព្វោ ឯវំ ភាវេតព្វោ ឯវំ ពហុលីកាតព្វោ ឯវំ តទនុធម្មតាសតិ ឧបដ្ឋា-បេតព្វាតិ អនុសាសនីចាដិហារិយំ ។ បេ ។ អរហត្ត-មគ្គោ ឥជ្ឈតីតិ ឥទ្ធិ សព្វកិលេសេ បដិហរតីតិ

ឈ្មោះថាអាទេសនាបាដិហារ្យ ព្រោះជនទាំងឡាយណា ប្រកបដោយអាលោកសញ្ញានោះ ពួកជនទាំងអស់នោះ ជាអ្នកមានចិត្តបរិសុទ្ធ មានតម្រិះមិនល្អក់ ឈ្មោះថាអនុសាសនីបាដិហារ្យ ព្រោះអាលោកសញ្ញានោះឯង បណ្ឌិតត្រូវសេពយ៉ាងនេះ ត្រូវចម្រើនយ៉ាងនេះ ត្រូវធ្វើឲ្យច្រើនយ៉ាងនេះ ត្រូវតម្កល់ទុកនូវសតិ ដ៏សមគួរដល់អាលោកសញ្ញានោះយ៉ាងនេះ ឈ្មោះថាឥទ្ធិ ព្រោះការមិនរាយមាយសម្រេច ឈ្មោះថាបាដិហារ្យ ព្រោះកម្ចាត់បង់ឧទ្ធច្ចៈ ឈ្មោះថាអាទេសនាបាដិហារ្យ ព្រោះជនទាំងឡាយណា ប្រកបដោយការមិនរាយមាយនោះ ពួកជនទាំងអស់នោះ ជាអ្នកមានចិត្តបរិសុទ្ធ មានតម្រិះមិនល្អក់ ឈ្មោះថាអានុសាសនីបាដិហារ្យ ព្រោះការមិនរាយមាយនោះ បណ្ឌិតត្រូវសេពយ៉ាងនេះ ត្រូវចម្រើនយ៉ាងនេះ ត្រូវធ្វើឲ្យច្រើនយ៉ាងនេះ ត្រូវតម្កល់ទុកនូវសតិដ៏សមគួរដល់ការមិនរាយមាយនោះយ៉ាងនេះ ។ បេ ។ ឈ្មោះថាឥទ្ធិ ព្រោះអរហត្តមគ្គសម្រេច ឈ្មោះថាបាដិហារ្យ ព្រោះកម្ចាត់បង់នូវកិលេសទាំងពួង

បាដិហារិយំ យេ តេន អរហត្តមគ្គេន សមន្នាគតា សព្វេ តេ វិសុទ្ធិចិត្តា អនាវិលសង្កប្បាតិ អាទេសនាបាដិហារិយំ សោ ខោ បន អរហត្តមគ្គោ ឯវំ អាសេវិតព្វោ ឯវំ ភាវេតព្វោ ឯវំ ពហុលីកាតព្វោ ឯវំ តទនុធម្មតាសតិ ឧបដ្ឋាបេតព្វាតិ អនុសាសនីបាដិហារិយំ នេក្ខម្មំ ឥជ្ឈតីតិ ឥទ្ធិ កាមច្ឆន្ទំ បដិហរតីតិ បាដិហារិយំ យា ច ឥទ្ធិ យញ្ច បាដិហារិយំ ឥទំ វុច្ចតិ ឥទ្ធិបាដិហារិយំ អព្យាបាទោ ឥជ្ឈតីតិ ឥទ្ធិ ព្យាបាទំ បដិហរតីតិ បាដិហារិយំ យា ច ឥទ្ធិ យញ្ច បាដិហារិយំ ឥទំ វុច្ចតិ ឥទ្ធិបាដិហារិយំ អាលោកសញ្ញា ឥជ្ឈតីតិ ឥទ្ធិ ថីនមិទ្ធំ បដិហរតីតិ បាដិហារិយំ ។ បេ ។ អរហត្តមគ្គោ ឥជ្ឈតីតិ ឥទ្ធិ សព្វេ កិលេសេ បដិហរតីតិ បាដិហារិយំ យា ច ឥទ្ធិ យញ្ច បាដិហារិយំ ឥទំ វុច្ចតិ ឥទ្ធិបាដិហារិយំ ។

បាដិហារិយកថា និដ្ឋិតា ។

ឈ្មោះថាអាទេសនាបាដិហារ្យ ព្រោះជនទាំងឡាយណា ប្រកបដោយអរហត្តមគ្គនោះ ពួកជនទាំងអស់នោះ ជាអ្នកមានចិត្តបរិសុទ្ធ មានតម្រិះមិនល្អក់ ឈ្មោះថាអនុសាសនីបាដិហារ្យ ព្រោះអរហត្តមគ្គនោះ បណ្ឌិតត្រូវសេព យ៉ាងនេះ ត្រូវចម្រើន យ៉ាងនេះ ត្រូវធ្វើឲ្យច្រើនយ៉ាងនេះ ត្រូវតម្កល់ទុកនូវសតិដ៏សមគួរ ដល់អរហត្តមគ្គនោះយ៉ាងនេះ ឈ្មោះថាឥទ្ធិ ព្រោះនេក្ខម្មៈសម្រេច ឈ្មោះថាបាដិហារ្យ ព្រោះកម្ចាត់បង់នូវកាមច្ឆន្ទៈ ឫទ្ធិនិងបាដិហារ្យ នេះ ហៅថា ឥទ្ធិប្បាដិហារ្យ ឈ្មោះថាឫទ្ធិ ព្រោះការមិនមានព្យាបាទសម្រេច ឈ្មោះថាបាដិហារ្យ ព្រោះកម្ចាត់បង់នូវព្យាបាទ ឫទ្ធិនិងបាដិហារ្យ នេះ ហៅថា ឥទ្ធិប្បាដិហារ្យ ឈ្មោះថា ឫទ្ធិ ព្រោះអាលោកសញ្ញាសម្រេច ឈ្មោះថាបាដិហារ្យ ព្រោះកម្ចាត់បង់នូវថីនមិទ្ធៈ ។ បេ ។ ឈ្មោះថាឫទ្ធិ ព្រោះអរហត្តមគ្គសម្រេច ឈ្មោះថាបាដិហារ្យ ព្រោះកម្ចាត់បង់នូវកិលេសទាំងពួង ឫទ្ធិនិងបាដិហារ្យ នេះ ហៅថា ឥទ្ធិប្បាដិហារ្យ ។

ចប់ បាដិហារិយកថា ។

---

## បញ្ញាវគ្គេ សមសីសកថា

[១៩៤] សព្វធម្មានំ សម្មាសមុច្ឆេទេ និរោធេ ច អនុបដ្ឋានតា បញ្ញា សមសីសដ្ឋេ ញាណំ ។

សព្វធម្មានន្តិ បញ្ចក្ខន្ធា ទ្វាទសាយតនានិ អដ្ឋារស ធាតុយោ កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា កាមាវចរា ធម្មា រូបាវចរា ធម្មា អរូបាវចរា ធម្មា អបរិយាបន្នា ធម្មា ។

សម្មាសមុច្ឆេទេតិ នេក្ខម្មេន កាមច្ឆន្ទំ សម្មា សមុច្ឆិន្ទតិ អព្យាបាទេន ព្យាបាទំ សម្មា សមុច្ឆិន្ទតិ អាលោកសញ្ញាយ ថីនមិទ្ធំ សម្មា សមុច្ឆិន្ទតិ អវិក្ខេបេន ឧទ្ធច្ចំ សម្មា សមុច្ឆិន្ទតិ ធម្មវវត្ថានេន វិចិកិច្ឆំ សម្មា សមុច្ឆិន្ទតិ ញាណេន អវិជ្ជំ សម្មា សមុច្ឆិន្ទតិ បាមុជ្ជេន អរតឹ សម្មា សមុច្ឆិន្ទតិ បឋមជ្ឈានេន នីវរណេ សម្មា សមុច្ឆិន្ទតិ ។ បេ ។ អរហត្តមគ្គេន សព្វកិលេសេ សម្មា សមុច្ឆិន្ទតិ ។

# បញ្ញាវគ្គ សមសីសកថា

[១៩៤] បញ្ញា គឺការមិនតាំងឡើង ព្រោះការផ្តាច់ផ្តិល ដោយប្រពៃ ព្រោះការរលត់នៃធម៌ទាំងពួង ឈ្មោះថា សមសីសដ្ឋញ្ញាណ (ញាណក្នុងអត្ថថាស្ងប់និងជាប្រធាន) ។

ពាក្យថា ធម៌ទាំងពួង បានដល់ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ កុសលធម៌ អកុសលធម៌ អព្យាកតធម៌ កាមាវចរធម៌ រូបាវចរធម៌ អរូបាវចរធម៌ អបរិយាបន្នធម៌ ។

ពាក្យថា ការផ្តាច់ផ្តិលដោយប្រពៃ អធិប្បាយថា ផ្តាច់ផ្តិលដោយប្រពៃ នូវកាមច្ឆន្ទៈ ដោយនេក្ខម្មៈ ផ្តាច់ផ្តិលដោយប្រពៃ នូវព្យាបាទ ដោយមិនមានព្យាបាទ ផ្តាច់ផ្តិលដោយប្រពៃ នូវថីនមិទ្ធៈ ដោយអាលោកសញ្ញា ផ្តាច់ផ្តិលដោយប្រពៃ នូវឧទ្ធច្ចៈ ដោយការមិនរាយមាយ ផ្តាច់ផ្តិលដោយប្រពៃ នូវវិចិកិច្ឆា ដោយការកំណត់នូវធម៌ ផ្តាច់ផ្តិលដោយប្រពៃ នូវអវិជ្ជា ដោយញាណ ផ្តាច់ផ្តិលដោយប្រពៃ នូវសេចក្តីមិនត្រេកអរ ដោយបាមុជ្ជៈ ផ្តាច់ផ្តិលដោយប្រពៃ នូវនីវរណៈទាំងឡាយ ដោយបឋមជ្ឈាន ។ បេ ។ ផ្តាច់ផ្តិលដោយប្រពៃ នូវកិលេសទាំងពួង ដោយអរហត្តមគ្គ ។

៣១៩

បញ្ញាវគ្គេ សមសីសកថា

[១៩៤] និរោធេតិ នេក្ខម្មេន កាមច្ឆន្ទំ និរោធេតិ អព្យាបាទេន ព្យាបាទំ និរោធេតិ អាលោកសញ្ញាយ ថីនមិទ្ធំ និរោធេតិ អវិក្ខេបេន ឧទ្ធច្ចំ និរោធេតិ ធម្មវវត្ថានេន វិចិកិច្ឆំ និរោធេតិ ញាណេន អវិជ្ជំ និរោធេតិ បាមុជ្ជេន អរតឹ និរោធេតិ បឋមជ្ឈានេន នីវរណេ និរោធេតិ ។ បេ ។ អរហត្តមគ្គេន សព្វកិលេសេ និរោធេតិ ។

អនុបដ្ឋានតាតិ នេក្ខម្មំ បដិលទ្ធស្ស កាមច្ឆន្ទោ ន ឧបដ្ឋាតិ អព្យាបាទំ បដិលទ្ធស្ស ព្យាបាទោ ន ឧបដ្ឋាតិ អាលោកសញ្ញំ បដិលទ្ធស្ស ថីនមិទ្ធំ ន ឧបដ្ឋាតិ អវិក្ខេបំ បដិលទ្ធស្ស ឧទ្ធច្ចំ ន ឧបដ្ឋាតិ ធម្មវវត្ថានំ បដិលទ្ធស្ស វិចិកិច្ឆា ន ឧបដ្ឋាតិ ញាណំ បដិលទ្ធស្ស អវិជ្ជា ន ឧបដ្ឋាតិ បាមុជ្ជំ បដិលទ្ធស្ស អរតិ ន ឧបដ្ឋាតិ បឋមជ្ឈានំ បដិលទ្ធស្ស នីវរណា ន ឧបដ្ឋហន្តិ[១] ។ បេ ។ អរហត្តមគ្គំ បដិលទ្ធស្ស សព្វកិលេសា ន ឧបដ្ឋហន្តិ[១] ។

---

១ ឱ. ម. ន ឧបដ្ឋន្តិ ។

[១៩៥] ពាក្យថា ការរលត់ អធិប្បាយថា រំលត់កាមច្ឆន្ទៈ ដោយនេក្ខម្មៈ រំលត់ព្យាបាទ ដោយអព្យាបាទ រំលត់ថីនមិទ្ធៈ ដោយអាលោកសញ្ញា រំលត់ឧទ្ធច្ចៈ ដោយការមិនរាយមាយ រំលត់វិចិកិច្ឆា ដោយការកំណត់នូវធម៌ រំលត់អវិជ្ជា ដោយញាណ រំលត់នូវសេចក្តីមិនត្រេកអរ ដោយបាមុជ្ជៈ រំលត់នូវនីវរណៈទាំងឡាយ ដោយបឋមជ្ឈាន ។ បេ ។ រំលត់នូវកិលេសទាំងពួង ដោយអរហត្តមគ្គ ។

ពាក្យថា ការមិនតាំងឡើង អធិប្បាយថា កាលបុគ្គលបាននូវនេក្ខម្មៈ កាមច្ឆន្ទៈតាំងឡើងមិនបាន កាលបុគ្គលបាន នូវអព្យាបាទ ព្យាបាទតាំងឡើងមិនបាន កាលបុគ្គលបាននូវអាលោកសញ្ញា ថីនមិទ្ធៈតាំងឡើងមិនបាន កាលបុគ្គលបាន នូវសេចក្តីមិនរាយមាយ ឧទ្ធច្ចៈតាំងឡើងមិនបាន កាលបុគ្គលបាន នូវការកំណត់ធម៌ វិចិកិច្ឆាតាំងឡើងមិនបាន កាលបុគ្គលបាន នូវញាណ អវិជ្ជាតាំងឡើងមិនបាន កាលបុគ្គលបាន នូវបាមុជ្ជៈ ការមិនត្រេកអរ តាំងឡើងមិនបាន កាលបុគ្គលបាន នូវបឋមជ្ឈាន នីវរណៈទាំងឡាយ តាំងឡើងមិនបាន ។ បេ ។ កាលបុគ្គលបាន នូវអរហត្តមគ្គ កិលេសទាំងពួងតាំងឡើងមិនបាន ។

[១៩៦] សមន្តិ កាមច្ឆន្ទស្ស បហីនត្តា នេក្ខម្មំ សមំ ព្យាបាទស្ស បហីនត្តា អព្យាបាទោ សមំ ថីនមិទ្ធស្ស បហីនត្តា អាលោកសញ្ញា សមំ ឧទ្ធច្ចស្ស បហីនត្តា អវិក្ខេបោ សមំ វិចិកិច្ឆាយ បហីនត្តា ធម្មវវត្ថានំ សមំ អវិជ្ជាយ បហីនត្តា ញាណំ សមំ អរតិយា បហីនត្តា បាមុជ្ជំ សមំ នីវរណានំ បហីនត្តា បឋមជ្ឈានំ សមំ ។ បេ ។ សព្វកិលេសានំ បហីនត្តា អរហត្តមគ្គោ សមំ ។

សីសន្តិ តេរស សីសានិ បលិពោធសីសញ្ច តណ្ហា ពន្ធនសីសញ្ច[១] មានោ បរាមាសសីសញ្ច ទិដ្ឋិ វិក្ខេបសីសញ្ច ឧទ្ធច្ចំ កិលេសសីសញ្ច អវិជ្ជា អធិមោក្ខសីសញ្ច សទ្ធា បគ្គហសីសញ្ច វីរិយំ ឧបដ្ឋានសីសញ្ច សតិ អវិក្ខេបសីសញ្ច សមាធិ ទស្សនសីសញ្ច បញ្ញា បវត្តសីសញ្ច ជីវិតិន្ទ្រិយំ គោចរសីសញ្ច វិមោក្ខោ សង្ខារសីសញ្ច និរោធោតិ ។

សមសីសកថា និដ្ឋិតា ។

---

១ ឱ. ម. វិនិពន្ធសីសញ្ច ។

[១៩៦] ពាក្យថា ស្ងប់ គឺ នេក្ខម្មៈ ឈ្មោះថាស្ងប់ ព្រោះបាន លះបង់កាមច្ឆន្ទៈ អព្យាបាទ ឈ្មោះថាស្ងប់ ព្រោះបានលះបង់ព្យាបាទ អាលោកសញ្ញា ឈ្មោះថាស្ងប់ ព្រោះបានលះបង់នូវថីនមិទ្ធ ការមិន រាយមាយ ឈ្មោះថាស្ងប់ ព្រោះបានលះបង់ឧទ្ធច្ចៈ ការកំណត់ធម៌ ឈ្មោះថាស្ងប់ ព្រោះបានលះបង់វិចិកិច្ឆា ញាណ ឈ្មោះថាស្ងប់ ព្រោះ បានលះបង់អវិជ្ជា បាមុជ្ជៈ ឈ្មោះថាស្ងប់ ព្រោះបានលះបង់អរតិ បឋ-មជ្ឈាន ឈ្មោះថាស្ងប់ ព្រោះបានលះបង់នីវរណៈទាំងឡាយ ។ បេ ។ អរហត្តមគ្គ ឈ្មោះថាស្ងប់ ព្រោះបានលះបង់កិលេសទាំងពួង ។

ពាក្យថា ជាប្រធាន បានដល់ប្រធាន ១៣ យ៉ាង គឺ ប្រធាន ខាងកង្វល់ បានដល់តណ្ហា ១ ប្រធានខាងចំណង បានដល់មានះ ១ ប្រធានខាងការស្ទាបអង្អែល បានដល់ទិដ្ឋិ ១ ប្រធានខាងការរាយមាយ បានដល់ឧទ្ធច្ចៈ ១ ប្រធានខាងការសៅហ្មង បានដល់អវិជ្ជា ១ ប្រធាន ខាងការជឿ បានដល់សទ្ធា ១ ប្រធានខាងការផ្គងឡើង បានដល់វីរិយៈ ១ ប្រធានខាងការប្រុង បានដល់សតិ ១ ប្រធានខាងការមិនរាយមាយ បានដល់សមាធិ ១ ប្រធានខាងការយល់ បានដល់បញ្ញា ១ ប្រធាន ខាងការប្រព្រឹត្តទៅ បានដល់ជីវិតិន្ទ្រិយ ១ ប្រធានខាងគោចរ បាន ដល់វិមោក្ខ ១ ប្រធានខាងសង្ខារ បានដល់និរោធ ១ ។

ចប់ សមសីសកថា ។

---

# បញ្ញាវគ្គេ សតិប្បដ្ឋានកថា

## សាវត្ថីបរិបុណ្ណនិទានំ

[១៩៧] ចត្តារោមេ ភិក្ខវេ សតិប្បដ្ឋានា កតមេ ចត្តារោ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ ។ បេ ។ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ឥមេ ខោ ភិក្ខវេ ចត្តារោ សតិប្បដ្ឋានាតិ ។

[១៩៨] កថំ កាយេ កាយានុបស្សី វិហរតិ ។ ឥធេកច្ចោ បឋវីកាយំ អនិច្ចតោ អនុបស្សតិ នោ និច្ចតោ ទុក្ខតោ អនុបស្សតិ នោ សុខតោ អនត្ត-តោ អនុបស្សតិ នោ អត្តតោ និព្វិន្ទតិ នោ នន្ទតិ

# បញ្ញាវគ្គ សតិប្បដ្ឋានកថា

## សាវត្ថីបរិបុណ្ណនិទាន

[១៩៧] ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន នេះ មាន ៤ សតិប្បដ្ឋាន ៤ តើអ្វីខ្លះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញ នូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ១ ជាអ្នកពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយ ។ បេ ។ ១ នូវចិត្តក្នុងចិត្ត ១ នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី គប្បីកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ម្នាលភិក្ខុទាំងឡាយ នេះឯង សតិប្បដ្ឋាន ៤ ។

[១៩៨] ជាអ្នកពិចារណាឃើញ នូវកាយ ក្នុងកាយ តើដូចម្តេច ។ បុគ្គលពួកមួយ ក្នុងលោកនេះ ពិចារណាឃើញ នូវពួកដីថាមិនទៀង មិនមែនថាទៀងទេ ពិចារណាឃើញ នូវពួកដី ថាជាទុក្ខ មិនមែនថាជាសុខទេ ពិចារណាឃើញ នូវពួកដី ថាមិនមែនខ្លួន មិនមែនថាជាខ្លួនទេ រមែងនឿយណាយ មិនរីករាយទេ

វិរជ្ជតិ នោ រជ្ជតិ និរោធេតិ នោ សមុទេតិ បដិនិស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហាតិ ទុក្ខតោ អនុបស្សន្តោ សុខសញ្ញំ បជហាតិ អនត្តតោ អនុបស្សន្តោ អត្តសញ្ញំ បជហាតិ និព្វិន្ទន្តោ នន្ទឹ បជហាតិ វិរជ្ជន្តោ រាគំ បជហាតិ និរោធេន្តោ សមុទយំ បជហាតិ បដិនិស្សជ្ជន្តោ អាទានំ បជហាតិ ឥមេហិ សត្តហាការេហិ កាយំ អនុបស្សតិ កាយោ ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តំ កាយំ អនុបស្សតីតិ តេន វុច្ចតិ កាយេ កាយានុបស្សនា សតិប្បដ្ឋានភាវនា[១] ។

ភាវនាតិ ចតស្សោ ភាវនា តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា

---

១ ម. សតិប្បដ្ឋានា ។

រមែងជិនណាយ មិនត្រេកអរទេ រមែងរំលត់ មិនឲ្យកើតទេ រមែងលះបង់ មិនប្រកាន់ទេ កាលពិចារណាឃើញថាមិនទៀង រមែងលះបង់សេចក្តីសម្គាល់ថាទៀង កាលពិចារណាឃើញថាជាទុក្ខ រមែងលះបង់នូវសេចក្តីសម្គាល់ថាជាសុខ កាលពិចារណាឃើញ ថាមិនមែនខ្លួន រមែងលះបង់នូវសេចក្តីសម្គាល់ថាខ្លួន កាលនឿយណាយ រមែងលះបង់នូវសេចក្តីរីករាយ កាលជិនណាយ រមែងលះបង់តម្រេក កាលរំលត់ រមែងលះបង់នូវការកើត កាលលះបង់ រមែងលះបង់នូវការប្រកាន់ បុគ្គលពិចារណាឃើញនូវកាយ ដោយអាការទាំង ៧ នេះ កាយ ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ឯសតិ ឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញ នូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះ លោកពោលថា កាយេកាយានុបស្សនា សតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ គឺ ភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លង នូវពួកធម៌ ដែលកើតហើយ ក្នុងទីនោះ ១ ភាវនា ដោយអត្ថថាឥន្ទ្រិយទាំងឡាយ មានរសតែមួយ ១ ភាវនា

៣២៣



តទុបគវីរិយវាហនដ្ឋេន ភាវនា អាសេវនដ្ឋេន ភាវនា
ឥធេកច្ចោ អាបោកាយំ តេជោកាយំ វាយោ-
កាយំ កេសកាយំ លោមកាយំ ឆវិកាយំ
ចម្មកាយំ មំសកាយំ[១] នហារុកាយំ អដ្ឋិកាយំ
អដ្ឋិមិញ្ជកាយំ អនិច្ចតោ អនុបស្សតិ នោ និច្ច-
តោ ទុក្ខតោ អនុបស្សតិ នោ សុខតោ អន-
ត្តតោ អនុបស្សតិ នោ អត្តតោ និព្វិន្ទតិ នោ
នន្ទតិ វិរជ្ជតិ នោ រជ្ជតិ និរោធេតិ នោ សមុទេតិ
បដិនិស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ អនុបស្ស-
ន្តោ និច្ចសញ្ញំ បជហតិ ទុក្ខតោ អនុបស្សន្តោ
សុខសញ្ញំ បជហតិ អនត្តតោ អនុបស្សន្តោ
អត្តសញ្ញំ បជហតិ និព្វិន្ទន្តោ នន្ទឹ បជហតិ វិរជ្ជន្តោ
រាគំ បជហតិ និរោធេន្តោ សមុទយំ បជហតិ

១ ឱ. ម. ឯត្ថន្តរេ រុធិរកាយន្តិ ទិស្សតិ ។

ដោយអត្ថថាដឹកនាំ នូវសេចក្តីព្យាយាម ដ៏សមគួរដល់ធម៌នោះ ១ ភាវនា ដោយអត្ថថាជាគ្រឿងសេពរឿយ ៗ ១ បុគ្គលពួកមួយ ក្នុងលោកនេះ ពិចារណាឃើញ នូវពួកទឹក ពួកភ្លើង ពួកខ្យល់ ពួកសក់ ពួករោម ពួកសម្បុរថ្ងៃ ពួកស្បែក ពួកសាច់ ពួកសរសៃ ពួកឆ្អឹង ពួកខួរក្នុងឆ្អឹង ថាមិនទៀង មិនមែនថាទៀងទេ ពិចារណាឃើញថាជាទុក្ខ មិនមែនថាជាសុខទេ ពិចារណាឃើញថាមិនមែនខ្លួន មិនមែនថាជាខ្លួនទេ រមែងនឿយណាយ មិនរីករាយទេ រមែងជិនណាយ មិនត្រេកអរទេ រមែងរំលត់ មិនឲ្យកើតទេ រមែងលះបង់ មិនប្រកាន់ទេ កាលពិចារណាឃើញថាមិនទៀង រមែងលះបង់នូវសេចក្តីសម្គាល់ថាទៀង កាលពិចារណាឃើញថាជាទុក្ខ រមែងលះបង់នូវសេចក្តីសម្គាល់ថាជាសុខ កាលពិចារណាឃើញ ថាមិនមែនខ្លួន រមែងលះបង់នូវសេចក្តីសម្គាល់ ថាជាខ្លួន កាលនឿយណាយ រមែងលះបង់ នូវសេចក្តីរីករាយ កាលជិនណាយ រមែងលះបង់តម្រេក កាលរំលត់ រមែងលះបង់នូវការកើត

បដិនិស្សជ្ជន្តោ អាទានំ បជហតិ ឥមេហិ សត្ត-
ហាការេហិ កាយំ អនុបស្សតិ កាយោ ឧបដ្ឋានំ
នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ
សតិយា តេន ញាណេន តំ កាយំ អនុប-
ស្សតីតិ តេន វុច្ចតិ កាយេ កាយានុបស្សនា
សតិប្បដ្ឋានភាវនា[១] ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន
ភាវនា ។ បេ ។ ឯវំ កាយេ កាយានុបស្សី វិហរតិ ។

[១៩៩] កថំ វេទនាសុ វេទនានុបស្សី វិហរតិ ។
ឥធេកច្ចោ សុខំ វេទនំ អនិច្ចតោ អនុបស្សតិ
នោ និច្ចតោ ។ បេ ។ បដិនិស្សជ្ជតិ នោ អាទិយ-
តិ អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហតិ
។ បេ ។ បដិនិស្សជ្ជន្តោ អាទានំ បជហតិ ឥមេហិ
សត្តហាការេហិ វេទនំ អនុបស្សតិ វេទនា ឧប-
ដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ
សតិយា តេន ញាណេន តំ វេទនំ អនុបស្សតីតិ
តេន វុច្ចតិ វេទនាសុ វេទនានុបស្សនា សតិប្ប-
ដ្ឋានភាវនា[២] ។

១-២ ម. សតិប្បដ្ឋានា ។

កាលលះបង់ រមែងលះបង់នូវការប្រកាន់ បុគ្គលពិចារណាឃើញនូវកាយ ដោយអាការទាំង ៧ នេះ កាយ ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ឯសតិ ឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះ លោកពាក្យថា កាយេកាយានុបស្សនា សតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ ។ បេ ។ ភាវនា ដោយអត្ថថាសេពរឿយ ៗ ។ បេ ។ ភិក្ខុជាអ្នកពិចារណាឃើញ នូវកាយក្នុងកាយ យ៉ាងនេះឯង ។

[១៩៩] ជាអ្នកពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយ តើដូចម្ដេច ។ បុគ្គលពួកមួយ ក្នុងលោកនេះ ពិចារណាឃើញនូវសុខ-វេទនាថាមិនទៀង មិនមែនថាទៀងទេ ។ បេ ។ រមែងលះបង់ មិនប្រកាន់ទេ កាលពិចារណាឃើញថាមិនទៀង រមែងលះបង់នូវសេចក្ដីសម្គាល់ថាទៀង ។ បេ ។ កាលលះបង់ រមែងលះបង់នូវការប្រកាន់ បុគ្គលពិចារណាឃើញនូវវេទនា ដោយអាការទាំង ៧ នេះ វេទនា ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ឯសតិ ឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញ នូវវេទនានោះ ដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះ លោកពោលថា វេទនាសុវេទនានុបស្សនាសតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

ភាវេតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ បេ ។ ឥធេកច្ចោ ទុក្ខំ វេទនំ ។ បេ ។ អទុក្ខមសុខំ វេទនំ[១] ចក្ខុសម្ផស្សជំ វេទនំ សោតសម្ផស្សជំ វេទនំ ឃានសម្ផស្សជំ វេទនំ ។ បេ ។ បដិនិស្សជ្ជន្តោ អាទានំ បជហតិ ឥមេហិ សត្តហាការេហិ វេទនំ អនុបស្សតិ វេទនា ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តំ វេទនំ អនុបស្សតីតិ តេន វុច្ចតិ វេទនាសុ វេទនានុបស្សនា សតិប្បដ្ឋានភាវនា ។

ភាវេតិ ចតស្សោ ភាវនា ។ បេ ។ ឯវំ វេទនាសុ វេទនានុបស្សី វិហរតិ ។

[២០០] កថំ ចិត្តេ ចិត្តានុបស្សី វិហរតិ ។ ឥធេកច្ចោ សរាគំ ចិត្តំ អនិច្ចតោ អនុបស្សតិ នោ និច្ចតោ ។ បេ ។ បដិនិស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហតិ ។ បេ ។

---

១ ម. ឯត្តន្តរេ សាមិសំ សុខំ វេទនំ និរាមិសំ សុខំ វេទនំ សាមិសំ ទុក្ខំ វេទនំ និរាមិសំ ទុក្ខំ វេទនំ សាមិសំ អទុក្ខមសុខំ វេទនំ និរាមិសំ អទុក្ខមសុខំ វេទនន្តិ ទិស្សន្តិ ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ ។ បេ ។ ភាវនា ដោយអត្ថថាសេពរឿយ ៗ ។ បេ ។ បុគ្គលពួកមួយ ក្នុងលោកនេះ ពិចារណាឃើញនូវទុក្ខវេទនា ។ បេ ។ នូវអទុក្ខមសុខវេទនា នូវវេទនាដែលកើតអំពីចក្ខុ-សម្ផស្ស នូវវេទនាដែលកើតអំពីសោតសម្ផស្ស នូវវេទនាដែលកើតអំពីឃានសម្ផស្ស ។ បេ ។ កាលលះបង់ រមែងលះបង់ នូវការប្រកាន់ បុគ្គលពិចារណាឃើញនូវវេទនា ដោយអាការទាំង ៧ នេះ វេទនា ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ឯសតិ ឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញ នូវវេទនានោះ ដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះ លោកពោលថា វេទនាសុ វេទនានុបស្សនា សតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ ។ បេ ។ ភាវនា ដោយអត្ថថាសេពរឿយ ៗ ។ បេ ។ ភិក្ខុជាអ្នកពិចារណាឃើញ នូវវេទនាក្នុងវេទនាទាំងឡាយ យ៉ាងនេះឯង ។

[២០០] ជាអ្នកពិចារណាឃើញនូវចិត្តក្នុងចិត្ត តើដូចម្តេច ។ បុគ្គលពួកមួយ ក្នុងលោកនេះ ពិចារណាឃើញចិត្ត ដែលប្រកបដោយរាគៈ ថាមិនទៀង មិនមែនថាទៀងទេ ។ បេ ។ រមែងលះបង់ មិនប្រកាន់ទេ កាលពិ-ចារណាឃើញថាមិនទៀង រមែងលះបង់សេចក្តីសម្គាល់ថាទៀង ។ បេ ។

បដិនិស្សជ្ជន្តោ អាទានំ បជហាតិ ឥមេហិ សត្តហាការេហិ ចិត្តំ អនុបស្សតិ ចិត្តំ ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តំ ចិត្តំ អនុបស្សតីតិ តេន វុច្ចតិ ចិត្តេ ចិត្តានុបស្សនា សតិប្បដ្ឋានភាវនា ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ បេ ។ ឥធេកច្ចោ សរាគំ ចិត្តំ[១] វីតរាគំ ចិត្តំ សទោសំ ចិត្តំ វីតទោសំ ចិត្តំ សមោហំ ចិត្តំ វីតមោហំ ចិត្តំ សំខិត្តំ ចិត្តំ វិក្ខិត្តំ ចិត្តំ មហគ្គតំ ចិត្តំ អមហគ្គតំ ចិត្តំ សឧត្តរំ ចិត្តំ អនុត្តរំ ចិត្តំ សមាហិតំ ចិត្តំ អសមាហិតំ ចិត្តំ វិមុត្តំ ចិត្តំ អវិមុត្តំ ចិត្តំ ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនោវិញ្ញាណំ អនិច្ចតោ អនុបស្សតិ នោ និច្ចតោ ។ បេ ។

---

១ ឱ. សរាគំ ចិត្តន្តិ ន ទិស្សតិ ។

កាលលះបង់ រមែងលះបង់នូវការប្រកាន់ បុគ្គលពិចារណាឃើញចិត្ត ដោយអាការទាំង ៧ នេះ ចិត្ត ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ឯសតិ ឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញ ចិត្តនោះ ដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះ លោក ពោលថា ចិត្តេចិត្តានុបស្សនាសតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ ។ បេ ។ ភាវនា ដោយ អត្ថថាសេពរឿយ ៗ ។ បេ ។ បុគ្គលពួកមួយ ក្នុងលោកនេះ ពិចារណា ឃើញចិត្តប្រកបដោយរាគៈ ចិត្តប្រាសចាករាគៈ ចិត្តប្រកបដោយទោសៈ ចិត្តប្រាសចាកទោសៈ ចិត្តប្រកបដោយមោហៈ ចិត្តប្រាសចាកមោហៈ ចិត្តរួញរា ចិត្តរាយមាយ ចិត្តដល់នូវភាពជាធំ គឺរូបាវចរនិងអរូបាវចរ ចិត្តមិនដល់នូវភាពជាធំ គឺជាកាមាវចរ ចិត្តនៅមានចិត្តដទៃប្រសើរ ជាង គឺនៅជាកាមាវចរ ចិត្តមិនមានចិត្តដទៃប្រសើរជាង គឺជារូបាវចរ និងអរូបាវចរ ចិត្តតាំងនៅមាំ គឺជាអប្បនាសមាធិ និងឧបចារសមាធិ ចិត្តមិនតាំងនៅមាំ គឺប្រាសចាកសមាធិទាំងពីរ ចិត្តរួចស្រឡះ ចិត្តមិន ទាន់រួចស្រឡះ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ ថាមិនទៀង មិនមែនថាទៀងទេ ។ បេ ។

បដិនិស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហតិ ។ បេ ។ បដិនិស្សជ្ជន្តោ អាទានំ បជហតិ ឥមេហិ សត្តហាការេហិ ចិត្តំ អនុបស្សតិ ចិត្តំ ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តំ ចិត្តំ អនុបស្សតីតិ តេន វុច្ចតិ ចិត្តេ ចិត្តានុបស្សនា សតិប្បដ្ឋានភាវនា ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ បេ ។ ឯវំ ចិត្តេ ចិត្តានុបស្សី វិហរតិ ។

[២០១] កថំ ធម្មេសុ ធម្មានុបស្សី វិហរតិ ។ ឥធេកច្ចោ ឋបេត្វា កាយំ ឋបេត្វា វេទនំ ឋបេត្វា ចិត្តំ តទវសេសេ[១] ធម្មេ អនិច្ចតោ អនុបស្សតិ នោ និច្ចតោ ទុក្ខតោ អនុបស្សតិ នោ សុខតោ អនត្តតោ អនុបស្សតិ នោ អត្តតោ និព្វិន្ទតិ នោ នន្ទតិ វិរជ្ជតិ នោ រជ្ជតិ និរោធេតិ នោ សមុទេតិ

១ ម. អវសេសេ ។

រមែងលះបង់ មិនប្រកាន់ទេ កាលពិចារណាឃើញថាមិនទៀង រមែងលះបង់នូវសេចក្ដីសម្គាល់ថាទៀង ។ បេ ។ កាលលះបង់ រមែងលះបង់នូវការប្រកាន់ បុគ្គលពិចារណាឃើញចិត្ត ដោយអាការទាំង ៧ នេះ ចិត្ត ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ឯសតិ ឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញ នូវចិត្តនោះ ដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះ លោកពោលថា ចិត្តេចិត្តានុបស្សនាសតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

ពាក្យថាភាវនា បានដល់ភាវនា ៤ ។ បេ ។ ភាវនាដោយអត្ថថាសេព ។ បេ ។ ភិក្ខុជាអ្នកពិចារណាឃើញនូវចិត្តក្នុងចិត្តយ៉ាងនេះឯង ។

[២០១] ជាអ្នកពិចារណាឃើញ នូវធម៌ក្នុងធម៌ទាំងឡាយ តើដូចម្ដេច ។ បុគ្គលពួកមួយ ក្នុងលោកនេះ លើកទុកកាយ លើកទុកវេទនា លើកទុកចិត្ត ហើយពិចារណាឃើញនូវធម៌ដ៏សេសសល់អំពីកាយ វេទនា និងចិត្តនោះ ថាមិនទៀង មិនមែនថាទៀងទេ ពិចារណាឃើញថាជាទុក្ខ មិនមែនថាជាសុខទេ ពិចារណាឃើញថាមិនមែនខ្លួន មិនមែនថាជាខ្លួនទេ រមែងនឿយណាយ មិនរីករាយទេ រមែងជិនណាយ មិនត្រេកអរទេ រមែងរំលត់ មិនឲ្យកើតទេ

៣២៨



បដិនិស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហតិ ទុក្ខតោ អនុបស្សន្តោ សុខសញ្ញំ បជហតិ អនត្តតោ អនុបស្សន្តោ អត្តសញ្ញំ បជហតិ និព្វិន្ទន្តោ នន្ទឹ បជហតិ វិរជ្ជន្តោ រាគំ បជហតិ និរោធេន្តោ សមុទយំ បជហតិ បដិនិស្សជ្ជន្តោ អាទានំ បជហតិ ឥមេហិ សត្តហាការេហិ ធម្មេ អនុបស្សតិ ធម្មា ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តេ ធម្មេ អនុបស្សតីតិ តេន វុច្ចតិ ធម្មេសុ ធម្មានុបស្សនា សតិប្បដ្ឋានភាវនា ។

ភាវនាតិ ចតស្សោ ភាវនា តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា តទុបគវីរិយវាហនដ្ឋេន ភាវនា អាសេវនដ្ឋេន ភាវនា ។ បេ ។ ឯវំ ធម្មេសុ ធម្មានុបស្សី វិហរតីតិ ។

សតិប្បដ្ឋានកថា និដ្ឋិតា ។

រមែងលះបង់ មិនប្រកាន់ទេ កាលពិចារណាឃើញថាមិនទៀង រមែងលះបង់សេចក្តីសម្គាល់ថាទៀង កាលពិចារណាឃើញថាជាទុក្ខ រមែងលះបង់សេចក្តីសម្គាល់ថាជាសុខ កាលពិចារណាឃើញថា មិនមែនខ្លួន រមែងលះបង់សេចក្តីសម្គាល់ថាជាខ្លួន កាលនឿយណាយ រមែងលះបង់នូវសេចក្តីរីករាយ កាលជិនណាយ រមែងលះបង់តម្រេក កាលរំលត់ រមែងលះបង់ការកើត កាលលះបង់ រមែងលះបង់ការប្រកាន់ បុគ្គលពិចារណាឃើញធម៌ ដោយអាការទាំង ៧ នេះ ធម៌ ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ឯសតិ ឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញនូវធម៌នោះ ដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះ លោកពោលថា ធម្មេសុ ធម្មានុបស្សនា សតិប្បដ្ឋាន-ភាវនា ដោយប្រការដូច្នេះ ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង គឺភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវពួកធម៌ ដែលកើតហើយក្នុងទីនោះ ភាវនា ដោយអត្ថថាឥន្ទ្រិយទាំងឡាយ មានរសតែមួយ ភាវនា ដោយអត្ថថាដឹកនាំនូវព្យាយាមដ៏សមគួរដល់ធម៌នោះ ភាវនា ដោយអត្ថថាសេពរឿយ ៗ ។ បេ ។ ភិក្ខុជាអ្នកពិចារណាឃើញ នូវធម៌ក្នុងធម៌ទាំងឡាយ យ៉ាងនេះឯង ។

ចប់ សតិប្បដ្ឋានកថា ។

---

# បញ្ញាវគ្គេ វិបស្សនាកថា

## សាវត្ថីបរិបុណ្ណនិទានំ

[២០២] ។ បេ ។ សោ វត ភិក្ខវេ ភិក្ខុ កញ្ចិ សង្ខារំ និច្ចតោ សមនុបស្សន្តោ អនុលោមិកាយ ខន្តិយា សមន្នាគតោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ អនុលោមិកាយ ខន្តិយា អសមន្នាគតោ សម្មត្តនិយាមំ ឱក្កមិស្សតីតិ នេតំ ឋានំ វិជ្ជតិ សម្មត្តនិយាមំ អនោក្កមមានោ សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តផលំ វា សច្ឆិករិស្សតីតិ នេតំ ឋានំ វិជ្ជតិ សោ វត ភិក្ខវេ ភិក្ខុ សព្វសង្ខារេ អនិច្ចតោ សមនុបស្សន្តោ អនុលោមិកាយ ខន្តិយា សមន្នាគតោ ភវិស្សតីតិ ឋានមេតំ វិជ្ជតិ អនុលោមិកាយ ខន្តិយា សមន្នាគតោ សម្មត្តនិយាមំ ឱក្កមិស្សតីតិ ឋានមេតំ វិជ្ជតិ សម្មត្តនិយាមំ ឱក្កមមានោ សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តផលំ វា សច្ឆិករិស្សតីតិ ឋានមេតំ វិជ្ជតិ ។

# បញ្ញាវគ្គ វិបស្សនាកថា

## សារត្ថីបរិបុណ្ណនិទាន

[២០២] ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង កាលពិចារណាឃើញ នូវសង្ខារនីមួយ ថាទៀង នឹងប្រកបដោយអនុលោមិកខន្តី ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះ មិនប្រកបដោយអនុលោមិកខន្តី នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះកាលមិនចុះ កាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឬ សកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង កាលពិចារណាឃើញ នូវសង្ខារទាំងពួង ថាមិនទៀង នឹងប្រកបដោយអនុលោមិកខន្តី ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ភិក្ខុនោះប្រកបដោយអនុលោមិកខន្តី នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ភិក្ខុនោះ កាលចុះកាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ។

[២០៣] សោ វត ភិក្ខវេ ភិក្ខុ កញ្ចិ សង្ខារំ សុខតោ សមនុបស្សន្តោ អនុលោមិកាយ ខន្តិយា សមន្នាគតោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ អនុលោមិកាយ ខន្តិយា អសមន្នាគតោ សម្មត្តនិយាមំ ឱក្កមិស្សតីតិ នេតំ ឋានំ វិជ្ជតិ សម្មត្តនិយាមំ អនោក្កមមានោ សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តផលំ វា សច្ឆិករិស្សតីតិ នេតំ ឋានំ វិជ្ជតិ សោ វត ភិក្ខវេ ភិក្ខុ សព្វសង្ខារេ ទុក្ខតោ សមនុបស្សន្តោ អនុលោមិកាយ ខន្តិយា សមន្នាគតោ ភវិស្សតីតិ ឋានមេតំ វិជ្ជតិ អនុលោមិកាយ ខន្តិយា សមន្នាគតោ សម្មត្តនិយាមំ ឱក្កមិស្សតីតិ ឋានមេតំ វិជ្ជតិ សម្មត្តនិយាមំ ឱក្កមមានោ សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តផលំ វា សច្ឆិករិស្សតីតិ ឋានមេតំ វិជ្ជតិ ។

[២០៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង កាលពិចារណាឃើញ នូវសង្ខារនីមួយ ថាជាសុខ នឹងប្រកបដោយអនុលោមិកខន្តិ ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះមិនប្រកបដោយអនុលោមិ-កខន្តិ នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះ កាលមិនចុះកាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឬ សកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង កាលពិចារណាឃើញ នូវសង្ខារទាំងពួង ថាជាទុក្ខ នឹងប្រកបដោយអនុលោមិកខន្តិ ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ភិក្ខុនោះប្រកបដោយអនុលោមិកខន្តិ នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ភិក្ខុនោះ កាលចុះកាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឬ សកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ។

[២០៤] សោ វត ភិក្ខវេ ភិក្ខុ កញ្ចិ ធម្មំ អត្តតោ សមនុបស្សន្តោ អនុលោមិកាយ ខន្តិយា សមន្នាគតោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ អនុលោមិកាយ ខន្តិយា អសមន្នាគតោ សម្មត្តនិ-យាមំ ឱក្កមិស្សតីតិ នេតំ ឋានំ វិជ្ជតិ សម្មត្តនិយាមំ អនោក្កមមានោ សោតាបត្តិផលំ វា សកទាគាមិផ-លំ វា អនាគាមិផលំ វា អរហត្តផលំ វា សច្ឆិ-ករិស្សតីតិ នេតំ ឋានំ វិជ្ជតិ សោ វត ភិក្ខវេ ភិក្ខុ កញ្ចិ ធម្មំ អនត្តតោ សមនុបស្សន្តោ អនុលោមិកាយ ខន្តិយា សមន្នាគតោ ភវិស្សតីតិ ឋានមេតំ វិជ្ជតិ អនុលោមិកាយ ខន្តិយា សម-ន្នាគតោ សម្មត្តនិយាមំ ឱក្កមិស្សតីតិ ឋានមេតំ វិជ្ជតិ សម្មត្តនិយាមំ ឱក្កមមានោ សោតាបត្តិ-ផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តផលំ វា សច្ឆិករិស្សតីតិ ឋានមេតំ វិជ្ជតិ ។

បញ្ញាវគ្គ វិបស្សនាកថា

[២០៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង កាលពិចារណាឃើញធម៌នីមួយថាជាខ្លួន នឹងប្រកបដោយអនុលោមិកខន្តិ ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះមិនប្រកបដោយអនុលោមិកខន្តិ នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះកាលមិនចុះកាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង កាលពិចារណាឃើញធម៌នីមួយ ថាមិនមែនខ្លួន នឹងប្រកបដោយអនុលោមិកខន្តិ ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ភិក្ខុប្រកបដោយអនុលោមិកខន្តិ នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ភិក្ខុនោះកាលចុះកាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ។

[២០៨] សោ វត ភិក្ខវេ ភិក្ខុ និព្វានំ ទុក្ខ-តោ សមនុបស្សន្តោ អនុលោមិកាយ ខន្តិយា សមន្នាគតោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ អនុ-លោមិកាយ ខន្តិយា អសមន្នាគតោ សម្មត្តនិយាមំ ឱក្កមិស្សតីតិ នេតំ ឋានំ វិជ្ជតិ សម្មត្តនិយាមំ អនោក្កមមានោ សោតាបត្តិផលំ វា សកទាគា-មិផលំ វា អនាគាមិផលំ វា អរហត្តផលំ វា សច្ឆិ-ករិស្សតីតិ នេតំ ឋានំ វិជ្ជតិ សោ វត ភិក្ខវេ ភិក្ខុ និព្វានំ សុខតោ សមនុបស្សន្តោ អនុលោមិ-កាយ ខន្តិយា សមន្នាគតោ ភវិស្សតីតិ ឋានមេតំ វិជ្ជតិ អនុលោមិកាយ ខន្តិយា សមន្នាគតោ សម្មត្តនិយាមំ ឱក្កមិស្សតីតិ ឋានមេតំ វិជ្ជតិ សម្មត្តនិយាមំ ឱក្កមមានោ សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តផលំ វា សច្ឆិករិស្សតីតិ ឋានមេតំ វិជ្ជតិ ។

[២០៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង កាលពិចារណាឃើញព្រះនិព្វានថាជាទុក្ខ នឹងប្រកបដោយអនុលោមិកខន្តិ ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះមិនប្រកបដោយអនុលោមិកខន្តិ នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះកាលមិនចុះកាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬ សកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង កាលពិចារណាឃើញព្រះនិព្វានថាជាសុខ នឹងប្រកបដោយអនុលោមិកខន្តិ ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ភិក្ខុនោះប្រកបដោយអនុលោមិកខន្តិ នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នោះនុ៎ះ ទើបសមហេតុ ភិក្ខុនោះចុះកាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិ-ផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ។

៣៣៣



[២០៦] កតិហាការេហិ អនុលោមិកំ ខន្តឹ បដិលភតិ កតិហាការេហិ សម្មត្តនិយាមំ ឱក្កមតិ ។ ចត្តារីសាយ អាការេហិ អនុលោមិកំ ខន្តឹ បដិលភតិ ចត្តារីសាយ អាការេហិ សម្មត្តនិយាមំ ឱក្កមតិ ។

កតមេហិ ចត្តារីសាយ អាការេហិ អនុលោមិកំ ខន្តឹ បដិលភតិ កតមេហិ ចត្តារីសាយ អាការេហិ សម្មត្តនិយាមំ ឱក្កមតិ ។ បញ្ចក្ខន្ធេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ ឦតិតោ ឧបទ្ទវតោ ភយតោ ឧបសគ្គតោ ចលតោ បភង្គុតោ អទ្ធុវតោ អត្តាណតោ អលេណតោ អសរណតោ រិត្តតោ តុច្ឆតោ សុញ្ញតោ អនត្តតោ អាទីនវតោ វិបរិណាមធម្មតោ អសារកតោ អឃមូលតោ វធកតោ វិភវតោ សាសវតោ

[២០៦] ភិក្ខុបាននូវអនុលោមិកខន្តី ដោយអាការប៉ុន្មាន ចុះកាន់សម្មត្តនិយាមធម៌ ដោយអាការប៉ុន្មាន ។ ភិក្ខុបាននូវអនុលោមិកខន្តី ដោយអាការ ៤០ ចុះកាន់សម្មត្តនិយាមធម៌ ក៏ដោយអាការ ៤០ ដែរ ។

ភិក្ខុបាននូវអនុលោមិកខន្តី ដោយអាការ ៤០ តើដូចម្ដេចខ្លះ ចុះកាន់សម្មត្តនិយាមធម៌ ដោយអាការ ៤០ តើដូចម្ដេចខ្លះ ។ ភិក្ខុពិចារណាឃើញនូវខន្ធ ៥ ថាមិនទៀង ១ ថាជាទុក្ខ ១ ជារោគ ១ ជាបូស ១ ជាសរ ១ ជារបស់លំបាក ១ ជាអាពាធ ១ ជារបស់ដទៃ ១ ជារបស់វិនាស ១ ជាចង្រៃ ១ ជាឧបទ្រព ១ ជាភ័យ ១ ជាឧបសគ្គ ១ ជាគ្រឿងញាប់ញ័រ ១ ជាគ្រឿងបែកធ្លាយ ១ ថាមិនទៀង ១ ថាមិនមានទីជ្រកកោន ១ ថាមិនមានទីពួន ១ ថាមិនមានទីពឹង ១ ថាជាវាល ១ ថាទទេ ១ ថាសោះសូន្យ ១ ថាមិនមែនខ្លួន ១ ថាជាទោស ១ ថាមានសេចក្ដីប្រែប្រួលជាធម្មតា ១ ថាគ្មានខ្លឹម ១ ថាជាឫសគល់នៃសេចក្ដីលំបាក ១ ថាជាអ្នកសម្លាប់ ១ ថាមិនមានសេចក្ដីចម្រើន ១ ថាប្រកបដោយអាសវៈ ១

សង្ខតតោ មាភាមិសតោ ជាតិធម្មតោ ជរាធម្មតោ ព្យាធិធម្មតោ មរណធម្មតោ សោកធម្មតោ បរិទេវ-ធម្មតោ ឧបាយាសធម្មតោ សំកិលេសិកធម្មតោ បញ្ចក្ខន្ធេ អនិច្ចតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ និច្ចំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ ទុក្ខតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ សុខំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ រោគតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អារោគ្យំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ គណ្ឌតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ និគណ្ឌោ[១] និព្វានន្តិ បស្សន្តោ

១ ឱ. ម. អគណ្ឌំ ។

ថាជារបស់ដែលបច្ច័យប្រជុំតាក់តែង ១ ថាជាអាមិសៈនៃមារ ១ ថាមានការកើតជាធម្មតា ១ មានជរាជាធម្មតា ១ មានព្យាធិជាធម្មតា ១ មានមរៈណៈជាធម្មតា១ មានសោកជាធម្មតា១ មានការខ្សឹកខ្សួលជាធម្មតា១ មានសេចក្តីចង្អៀតចង្អល់ជាធម្មតា ១ មានសេចក្តីសៅហ្មងជាធម្មតា ១ គឺថាកាលពិចារណាឃើញថា ខន្ធ ៥ មិនទៀង រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វានដ៏ទៀង រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញថាខន្ធ ៥ ជាទុក្ខ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានសុខ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញថាខន្ធ ៥ ជារោគ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថាការរំលត់ខន្ធ៥ គឺព្រះនិព្វាន ជាឋានមិនមានរោគ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញថាខន្ធ ៥ ជាបូស រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមាន

សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ សល្លតោ បស្ស-
ន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ
និរោធោ និសល្លំ និព្វានន្តិ បស្សន្តោ សម្មត្ត-
និយាមំ ឱក្កមតិ បញ្ចក្ខន្ធេ អឃតោ បស្សន្តោ
អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និ-
រោធោ អនឃោ និព្វានន្តិ បស្សន្តោ សម្មត្តនិយា-
មំ ឱក្កមតិ បញ្ចក្ខន្ធេ អាពាធតោ បស្សន្តោ
អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ
និរោធោ អនាពាធោ និព្វានន្តិ បស្សន្តោ សម្មត្ត-
និយាមំ ឱក្កមតិ បញ្ចក្ខន្ធេ បរតោ បស្សន្តោ
អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ
និរោធោ អបរប្បច្ចយំ និព្វានន្តិ បស្សន្តោ សម្មត្ត-
និយាមំ ឱក្កមតិ បញ្ចក្ខន្ធេ បលោកតោ បស្ស-
ន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធា-
នំ និរោធោ អប្បលោកធម្មោ និព្វានន្តិ បស្សន្តោ

បូស រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថា ជាសរ រមែងបានអនុលោមិកខន្តិ កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានសរ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាខន្ធលំបាក រមែងបានអនុលោមិកខន្តិ កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានទុក្ខ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញ នូវខន្ធ ៥ ថាជាអាពាធ រមែងបានអនុលោមិកខន្តិ កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានអាពាធ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជារបស់ដទៃ រមែងបានអនុលោមិកខន្តិ កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនជាបច្ច័យរបស់អ្នកដទៃ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាវិនាស រមែងបានអនុលោមិកខន្តិ កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាសភាវៈមិនវិនាស

សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ ឡុតិតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អជីតិកំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ ឧបទ្ទវតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អនុបទ្ទវំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ ភយតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អភយំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ ឧបសគ្គតោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អនុបសគ្គំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ ចលតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អចលំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ បភង្គុតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អប្បភង្គុំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ

រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាចង្រៃ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានចង្រៃ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាឧបទ្រព រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានឧបទ្រព រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាភ័យ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វានជាឋានមិនមានភ័យ រមែងចុះកាន់សម្មត្តនិយាម-ធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាឧបសគ្គ រមែងបានអនុ-លោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានឧបសគ្គ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាគ្រឿងញាប់ញ័រ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានការញាប់ញ័រ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជារបស់បែកធ្លាយ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានការបែកធ្លាយ

៣៣៧



ឱក្កមតិ បញ្ចក្ខន្ធេ អទ្ធុវតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ ធុវំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ អត្តាណតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ តាណំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ អលេណតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ លេណំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ អសរណតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ សរណំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ រិត្តតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អរិត្តំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ តុច្ឆតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អតុច្ឆំ និព្វានន្តិ បស្សន្តោ

រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមិនទៀង រមែងបានអនុលោមិកខន្តិ កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វានជាឋានទៀង រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមិនមានទីជ្រកកោន រមែងបានអនុលោមិកខន្តិ កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វានជាឋានមានទីជ្រកកោន រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមិនមានទីពួន រមែងបានអនុលោមិកខន្តិ កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វានជាឋានមានទីពួន រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមិនមានទីពឹង រមែងបានអនុលោមិកខន្តិ កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមានទីពឹង រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាវាល រមែងបានអនុលោមិកខន្តិ កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានទីវាល រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជារបស់ទទេ រមែងបានអនុលោមិកខន្តិ កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនទទេ

សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ សុញ្ញតោ
បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ
ខន្ធានំ និរោធោ បរមំ សុញ្ញំ និព្វានន្តិ បស្សន្តោ សម្ម-
ត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ អនត្តតោ បស្សន្តោ
អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ
និរោធោ បរមត្ថំ និព្វានន្តិ បស្សន្តោ សម្មត្តនិ-
យាមំ ឱក្កមតិ បញ្ចក្ខន្ធេ អាទីនវតោ បស្សន្តោ
អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ
និរោធោ អនាទីនវំ និព្វានន្តិ បស្សន្តោ សម្មត្តនិ-
យាមំ ឱក្កមតិ បញ្ចក្ខន្ធេ វិបរិណាមធម្មតោ បស្ស-
ន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធា-
នំ និរោធោ អវិបរិណាមធម្មំ និព្វានន្តិ បស្សន្តោ
សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ អសារកតោ
បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ
ខន្ធានំ និរោធោ សារំ និព្វានន្តិ បស្សន្តោ

រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាសូន្យ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វានជាឋានសូន្យ (ចាកកិលេស) ដ៏ក្រៃលែង រមែងចុះកាន់សម្មត្ត-និយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមិនមែនខ្លួន រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមានអត្ថដ៏ឧត្តម រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញ នូវខន្ធ ៥ ថាជាទោស រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានទោស រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានការប្រែប្រួលជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារ-ណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានការប្រែប្រួលជាធម្មតា រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមិនមានខ្លឹម រមែងបាន នូវអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមានខ្លឹម

សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ អឃម្ពលតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អនឃម្ពលំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ វធកតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិ-លភតិ បញ្ចន្នំ ខន្ធានំ និរោធោ អវធកំ និ-ព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ច-ក្ខន្ធេ វិភវតោ បស្សន្តោ អនុលោមិកំ ខន្តឹ ប-ដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អវិភវំ និព្វាន-ន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ សាសវតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អនាសវំ និព្វានន្តិ ប-ស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ សង្ខ-តោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អសង្ខតំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ មារាមិសតោ ប-ស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ

រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាឫស គល់នៃការលំបាក រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានឫសគល់នៃសេចក្តីលំបាក រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ៥ថាជាអ្នកសម្លាប់ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វានមិនជាទីសម្លាប់ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាប្រាសចាកសេចក្តីចម្រើន រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមែនជាទីប្រាសចាកសេចក្តីចម្រើន រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាប្រកបដោយអាសវៈ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានអាសវៈ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាបច្ច័យប្រជុំតាក់តែង រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានបច្ច័យប្រជុំតាក់តែង រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាអាមិសៈនៃមារ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ

និរោធោ និរាមិសំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ ជាតិធម្មតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អជាតំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ ជរាធម្មតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អជរំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ ព្យាធិធម្មតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អព្យាធិធម្មំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ មរណធម្មតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អមតំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ សោកធម្មតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អសោកំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ បរិទេវធម្មតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិលភតិ

៥ គឺព្រះនិព្វានមិនមានអាមិសៈ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិ-ចារណាឃើញខន្ធ ៥ ថាមានការកើតជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានឈប់កើត រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានជរាជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានជរា រមែងចុះកាន់សម្មត្តនិយាម-ធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានព្យាធិជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានព្យាធិជាធម្មតា រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានសេចក្តីស្លាប់ជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនស្លាប់ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានសេចក្តីសោកជាធម្មតា រមែងបាន នូវអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានសេចក្តីសោក រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានសេចក្តីខ្សឹកខ្សួលជាធម្មតា រមែងបានអនុលោមិកខន្តី

បញ្ចន្នំ ខន្ធានំ និរោធោ អបរិនេវំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ចក្ខន្ធេ ឧចា-យាសធម្មតោ បស្សន្តោ អនុលោមិកំ ខន្តឹ បដិ-លភតិ បញ្ចន្នំ ខន្ធានំ និរោធោ អនុចាយាសំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ បញ្ច-ក្ខន្ធេ សំកិលេសិកធម្មតោ បស្សន្តោ អនុលោមិ-កំ ខន្តឹ បដិលភតិ បញ្ចន្នំ ខន្ធានំ និរោធោ អសំ-កិលិដ្ឋំ និព្វានន្តិ បស្សន្តោ សម្មត្តនិយាមំ ឱក្កមតិ ។

[២០៧] អនិច្ចតោតិ អនិច្ចានុបស្សនា ។

ទុក្ខតោតិ ទុក្ខានុបស្សនា ។

រោគតោតិ ទុក្ខានុបស្សនា ។

គណ្ឌតោតិ ទុក្ខានុបស្សនា ។

សល្លតោតិ ទុក្ខានុបស្សនា ។

អឃតោតិ ទុក្ខានុបស្សនា ។

កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានសេចក្តីខ្សឹកខ្សួល រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានសេចក្តីចង្អៀតចង្អល់ជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានសេចក្តីចង្អៀតចង្អល់ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានសេចក្តីសៅហ្មងជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានសេចក្តីសៅហ្មង រមែងចុះកាន់សម្មត្តនិយាមធម៌ ។

[២០៧] ពាក្យថាមិនទៀង បានដល់អនិច្ចានុបស្សនា ។

ពាក្យថាទុក្ខ បានដល់ទុក្ខានុបស្សនា ។

ពាក្យថារោគ បានដល់ទុក្ខានុបស្សនា ។

ពាក្យថាបូស បានដល់ទុក្ខានុបស្សនា ។

ពាក្យថាសរ បានដល់ទុក្ខានុបស្សនា ។

ពាក្យថាលំបាក បានដល់ទុក្ខានុបស្សនា ។

អាពាធតោតិ ទុក្ខានុបស្សនា ។

បរតោតិ អនត្តានុបស្សនា ។

បលោកតោតិ អនត្តានុបស្សនា[១]។

ឦតិតោតិ ទុក្ខានុបស្សនា ។

ឧបទ្ទវតោតិ ទុក្ខានុបស្សនា ។

ភយតោតិ ទុក្ខានុបស្សនា ។

ឧបសគ្គតោតិ ទុក្ខានុបស្សនា ។

ចលតោតិ អនិច្ចានុបស្សនា ។

បភង្គុតោតិ អនិច្ចានុបស្សនា ។

អទ្ធុវតោតិ អនិច្ចានុបស្សនា ។

អត្តាណតោតិ ទុក្ខានុបស្សនា ។

អលេណតោតិ ទុក្ខានុបស្សនា ។

អសរណតោតិ ទុក្ខានុបស្សនា ។

រិត្តតោតិ ទុក្ខានុបស្សនា[២]។

តុច្ឆតោតិ អនត្តានុបស្សនា ។

---

១ ម. អនិច្ចានុបស្សនា ។ ២ ម. រិត្តតោតិ អនត្តានុបស្សនា ។

ពាក្យថាអាពាធ បានដល់ទុក្ខានុបស្សនា ។

ពាក្យថាជារបស់អ្នកដទៃ បានដល់អនត្តានុបស្សនា ។

ពាក្យថាវិនាស បានដល់អនត្តានុបស្សនា ។

ពាក្យថាចង្រៃ បានដល់ទុក្ខានុបស្សនា ។

ពាក្យថាឧបទ្រព បានដល់ទុក្ខានុបស្សនា ។

ពាក្យថាភ័យ បានដល់ទុក្ខានុបស្សនា ។

ពាក្យថាឧបសគ្គ បានដល់ទុក្ខានុបស្សនា ។

ពាក្យថាញាប់ញ័រ បានដល់អនិច្ចានុបស្សនា ។

ពាក្យថាបែកធ្លាយ បានដល់អនិច្ចានុបស្សនា ។

ពាក្យថាមិនទៀង បានដល់អនិច្ចានុបស្សនា ។

ពាក្យថាមិនមានទីជ្រកកោន បានដល់ទុក្ខានុបស្សនា ។

ពាក្យថាមិនមានទីពួន បានដល់ទុក្ខានុបស្សនា ។

ពាក្យថាមិនមានទីពឹង បានដល់ទុក្ខានុបស្សនា ។

ពាក្យថាទីវាល បានដល់ទុក្ខានុបស្សនា ។

ពាក្យថាទទេ បានដល់អនត្តានុបស្សនា ។

៣៤៣

## បញ្ញាវគ្គេ វិបស្សនាកថា

| | |
|---|---|
| សុញ្ញតោតិ | អនត្តានុបស្សនា ។ |
| អនត្តតោតិ | អនត្តានុបស្សនា ។ |
| អាទីនវតោតិ | ទុក្ខានុបស្សនា ។ |
| វិបរិណាមធម្មតោតិ | អនិច្ចានុបស្សនា ។ |
| អសារកតោតិ | អនត្តានុបស្សនា ។ |
| អឃមូលតោតិ | ទុក្ខានុបស្សនា ។ |
| វធកតោតិ | ទុក្ខានុបស្សនា ។ |
| វិភវតោតិ | អនិច្ចានុបស្សនា ។ |
| សាសវតោតិ | ទុក្ខានុបស្សនា ។ |
| សង្ខតតោតិ | អនិច្ចានុបស្សនា ។ |
| មារាមិសតោតិ | ទុក្ខានុបស្សនា ។ |
| ជាតិធម្មតោតិ | ទុក្ខានុបស្សនា ។ |
| ជរាធម្មតោតិ | ទុក្ខានុបស្សនា ។ |
| ព្យាធិធម្មតោតិ | ទុក្ខានុបស្សនា ។ |
| មរណធម្មតោតិ | អនិច្ចានុបស្សនា ។ |

ពាក្យថាសោះសូន្យ បានដល់អនត្តានុបស្សនា ។

ពាក្យថាមិនមែនខ្លួន បានដល់អនត្តានុបស្សនា ។

ពាក្យថាទោស បានដល់ទុក្ខានុបស្សនា ។

ពាក្យថាមានការប្រែប្រួលជាធម្មតា បានដល់អនិច្ចានុបស្សនា ។

ពាក្យថាមិនមានខ្លឹម បានដល់អនត្តានុបស្សនា ។

ពាក្យថាជាមានការលំបាកជាឫសគល់ បានដល់ទុក្ខានុបស្សនា ។

ពាក្យថាអ្នកសម្លាប់ បានដល់ទុក្ខានុបស្សនា ។

ពាក្យថាប្រាសចាកសេចក្តីចម្រើន បានដល់អនិច្ចានុបស្សនា ។

ពាក្យថាប្រកបដោយអាសវៈ បានដល់ទុក្ខានុបស្សនា ។

ពាក្យថាមានបច្ច័យប្រជុំតាក់តែង បានដល់អនិច្ចានុបស្សនា ។

ពាក្យថាជាអាមិសៈនៃមារ បានដល់ទុក្ខានុបស្សនា ។

ពាក្យថាមានការកើតជាធម្មតា បានដល់ទុក្ខានុបស្សនា ។

ពាក្យថាមានជរាជាធម្មតា បានដល់ទុក្ខានុបស្សនា ។

ពាក្យថាមានព្យាធិជាធម្មតា បានដល់ទុក្ខានុបស្សនា ។

ពាក្យថាមានសេចក្តីស្លាប់ជាធម្មតា បានដល់អនិច្ចានុបស្សនា ។

សោកធម្មតោតិ ទុក្ខានុបស្សនា ។
បរិទេវធម្មតោតិ ទុក្ខានុបស្សនា ។
ឧបាយាសធម្មតោតិ ទុក្ខានុបស្សនា ។
សំកិលេសិកធម្មតោតិ ទុក្ខានុបស្សនា ។

ឥមេហិ ចត្តារីសាយ អាការេហិ អនុលោមិកំ ខន្តឹ បដិលភតិ ឥមេហិ ចត្តារីសាយ អាការេហិ សម្មត្តនិយាមំ ឱក្កមតិ ។

ឥមេហិ ចត្តារីសាយ អាការេហិ អនុលោមិកំ ខន្តឹ បដិលភន្តស្ស ឥមេហិ ចត្តារីសាយ អាការេហិ សម្មត្តនិយាមំ ឱក្កមន្តស្ស កាតិ អនិច្ចានុបស្សនា កាតិ ទុក្ខានុបស្សនា កាតិ អនត្តានុបស្សនា ។

បញ្ចវីសតិ អនត្តានុបស្សនា
បញ្ញាសំ អនិច្ចានុបស្សនា
សតំ បញ្ចវីសតិញ្ចេវ
យានិ ទុក្ខេ បវុច្ចរេតិ[១] ។

វិបស្សនាកថា និដ្ឋិតា ។

១ ម. យានិ ទុក្ខានុបស្សនានិ បវុច្ចរេតិ ។

ពាក្យថា មានសោកជាធម្មតា បានដល់ទុក្ខានុបស្សនា ។

ពាក្យថាមានសេចក្តីខ្សឹកខ្សួលជាធម្មតា បានដល់ទុក្ខានុបស្សនា ។

ពាក្យថាមានសេចក្តីចង្អៀតចង្អល់ជាធម្មតា បានដល់ទុក្ខានុបស្សនា។

ពាក្យថា មានសេចក្តីសៅហ្មងជាធម្មតា បានដល់ទុក្ខានុបស្សនា។

ភិក្ខុបានអនុលោមិកខន្តី ដោយអាការ ៤០ នេះ ចុះកាន់សម្មត្តនិយាមធម៌ ដោយអាការ ៤០ នេះ ។

កាលភិក្ខុបានអនុលោមិកខន្តី ដោយអាការ ៤០ នេះ ចុះកាន់សម្មត្តនិយាមធម៌ ដោយអាការ ៤០ នេះ តើអនិច្ចានុបស្សនា មានប៉ុន្មាន ទុក្ខានុបស្សនា មានប៉ុន្មាន អនត្តានុបស្សនា មានប៉ុន្មាន ។

អនត្តានុបស្សនា មាន ២៥ អនិច្ចានុបស្សនា មាន ៥០

វិបស្សនាទាំងឡាយណា ដែលព្រះមានព្រះភាគ សម្តែង

ចំពោះទុក្ខានុបស្សនា វិបស្សនានោះ មាន ១២៥ ។

ចប់ វិបស្សនាកថា ។

# បញ្ញាវគ្គេ មាតិកកថា

[២០៨] និច្ឆាតោ មុច្ចតីតិ វិមោក្ខោ វិជ្ជាវិមុត្តិ[១] អធិសីលំ អធិចិត្តំ អធិប្បញ្ញា បស្សទ្ធិ ញាណំ ទស្សនំ សុទ្ធិ[២] នេក្ខម្មំ និស្សរណំ បវិវេកោ វោស្សគ្គោ ចរិយា ឈានវិមោក្ខោ ភាវនាធិដ្ឋានជីវិតំ[៣] ។

និច្ឆាតោតិ នេក្ខម្មេន កាមច្ឆន្ទតោ និច្ឆាតោ អព្យាបាទេន ព្យាបាទតោ និច្ឆាតោ ។ បេ ។ បឋមជ្ឈានេន នីវរណេហិ និច្ឆាតោ ។ បេ ។ អរហត្តមគ្គេន សព្វក្កិលេសេហិ និច្ឆាតោ មុច្ចតិ ។

វិមោក្ខោតិ[៤] នេក្ខម្មេន កាមច្ឆន្ទតោ មុច្ចតីតិ វិមោក្ខោ អព្យាបាទេន ព្យាបាទតោ មុច្ចតីតិ វិមោក្ខោ ។ បេ ។ បឋមជ្ឈានេន នីវរណេហិ មុច្ចតីតិ វិមោក្ខោ ។ បេ ។ អរហត្តមគ្គេន សព្វក្កិលេសេហិ មុច្ចតីតិ វិមោក្ខោ ។

---

១ ម. និច្ឆាតោ មោក្ខោ វិមោក្ខោ វិជ្ជាវិមុត្តីតិ ទិស្សន្តិ ។ ២ ឱ. ម. វិសុទ្ធិ ។ ៣ ឱ. ម. ភាវនា អធិដ្ឋានំ ជីវិតំ ។ ៤ ម. សព្វក្កិលេសេហិ និច្ឆាតោ ។ មោក្ខោ វិមោក្ខោតិ ទិស្សន្តិ ។

# បញ្ញាវគ្គ មាតិកកថា

[២០៨] ពាក្យថា បុគ្គលមិនមានសេចក្តីស្រេកឃ្លាន រមែងរួច បានដល់ វិមោក្ខ វិជ្ជាវិមុត្តិ អធិសីល អធិចិត្ត អធិប្បញ្ញា បស្សទ្ធិ ញាណ ទស្សនៈ សុទ្ធិ នេក្ខម្មៈ និស្សរណៈ បវិវេក វោស្សគ្គៈ ចរិយា ឈាន វិមោក្ខ ភាវនា អធិដ្ឋាន និងការរស់នៅ ។

ពាក្យថា មិនមានសេចក្តីស្រេកឃ្លាន គឺ មិនមានសេចក្តីស្រេកឃ្លាន រមែងរួច ចាកកាមច្ឆន្ទៈ ដោយនេក្ខម្មៈ មិនមានសេចក្តីស្រេកឃ្លាន រមែងរួច ចាកព្យាបាទ ដោយមិនមានព្យាបាទ ។ បេ ។ មិនមានសេចក្តីស្រេកឃ្លាន រមែងរួច ចាកនីវរណៈ ដោយបឋមជ្ឈាន ។ បេ ។ មិនមានសេចក្តីស្រេកឃ្លាន រមែងរួច ចាកកិលេសទាំងពួង ដោយអរហត្តមគ្គ ។

ពាក្យថា វិមោក្ខ សេចក្តីថា សភាវៈរួចចាកកាមច្ឆន្ទៈ ដោយនេក្ខម្មៈ ហេតុនោះ ឈ្មោះថាវិមោក្ខ សភាវៈរួចចាកព្យាបាទ ដោយមិនមានព្យាបាទ ហេតុនោះ ឈ្មោះថាវិមោក្ខ ។ បេ ។ សភាវៈរួច ចាកនីវ-រណៈ ដោយបឋមជ្ឈាន ហេតុនោះ ឈ្មោះថាវិមោក្ខ ។ បេ ។ សភាវៈរួច ចាកកិលេសទាំងពួង ដោយអរហត្តមគ្គ ហេតុនោះ ឈ្មោះថាវិមោក្ខ ។

វិជ្ជាវិមុត្តីតិ នេក្ខម្មំ វិជ្ជតីតិ វិជ្ជា កាមច្ឆន្ទតោ មុច្ចតីតិ វិមុត្តិ វិជ្ជន្តោ មុច្ចតិ មុច្ចន្តោ វិជ្ជតីតិ វិជ្ជាវិមុត្តិ អព្យាបាទំ(១) វិជ្ជតីតិ វិជ្ជា ព្យាបាទតោ មុច្ចតីតិ វិមុត្តិ វិជ្ជន្តោ មុច្ចតិ មុច្ចន្តោ វិជ្ជតីតិ វិជ្ជាវិមុត្តិ ។ បេ ។ អរហត្តមគ្គោ វិជ្ជតីតិ វិជ្ជា សព្វក្កិលេសេហិ មុច្ចតីតិ វិមុត្តិ វិជ្ជន្តោ មុច្ចតិ មុច្ចន្តោ វិជ្ជតីតិ វិជ្ជាវិមុត្តិ ។

[២០៩] អធិសីលំ អធិចិត្តំ អធិប្បញ្ញាតិ នេក្ខម្មេន កាមច្ឆន្ទំ សំវរដ្ឋេន សីលវិសុទ្ធិ អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ យោ តត្ថ សំវរដ្ឋោ អយំ អធិសីលសិក្ខា យោ តត្ថ អវិក្ខេបដ្ឋោ អយំ អធិចិត្តសិក្ខា យោ តត្ថ ទស្សនដ្ឋោ អយំ អធិប្បញ្ញាសិក្ខា អព្យាបាទេន ព្យាបាទំ សំវរដ្ឋេន សីលវិសុទ្ធិ ។ បេ ។ អរហត្តមគ្គេន សព្វក្កិលេសេ សំវរដ្ឋេន សីលវិសុទ្ធិ អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ

១ ឱ. ម. អព្យាបាទោ ។

ពាក្យថា វិជ្ជាវិមុត្តិ គឺ ឈ្មោះថាវិជ្ជា ព្រោះដឹងនេក្ខម្មៈ ឈ្មោះថាវិមុត្តិ ព្រោះរួចចាកកាមច្ឆន្ទៈ ឈ្មោះថាវិជ្ជាវិមុត្តិ ព្រោះបុគ្គលកាលដឹង រមែងរួច កាលរួច រមែងដឹង ឈ្មោះថាវិជ្ជា ព្រោះដឹង អព្យាបាទ ឈ្មោះថាវិមុត្តិ ព្រោះរួចចាកព្យាបាទ ឈ្មោះថាវិជ្ជាវិមុត្តិ ព្រោះបុគ្គលកាលដឹង រមែងរួច កាលរួច រមែងដឹង ។ បេ ។ ឈ្មោះថាវិជ្ជា ព្រោះដឹង អរហត្តមគ្គ ឈ្មោះថាវិមុត្តិ ព្រោះរួចចាកកិលេសទាំងពួង ឈ្មោះថាវិជ្ជាវិមុត្តិ ព្រោះបុគ្គលកាលដឹង រមែងរួច កាលរួច រមែងដឹង ។

[២០៩] ពាក្យថា អធិសីល អធិចិត្ត អធិប្បញ្ញា សេចក្តីថា សីលវិសុទ្ធិ ដោយអត្ថថារវាំងនូវកាមច្ឆន្ទៈ ដោយនេក្ខម្មៈ ចិត្តវិសុទ្ធិ ដោយអត្ថថាមិនរាយមាយ ទិដ្ឋិវិសុទ្ធិ ដោយអត្ថថាឃើញ អត្ថនៃសេចក្តីសង្រួមណា ក្នុងសីលវិសុទ្ធិនោះ នេះឈ្មោះថាអធិសីលសិក្ខា អត្ថនៃសេចក្តីមិនរាយមាយណា ក្នុងចិត្តវិសុទ្ធិនោះ នេះ ឈ្មោះថាអធិចិត្តសិក្ខា អត្ថនៃសេចក្តីឃើញណា ក្នុងទិដ្ឋិវិសុទ្ធិនោះ នេះឈ្មោះថាអធិប្បញ្ញាសិក្ខា សីលវិសុទ្ធិ ដោយអត្ថថារវាំងនូវព្យាបាទ ដោយមិនមានព្យាបាទ ។ បេ ។ សីលវិសុទ្ធិ ដោយអត្ថថារវាំងនូវកិលេសទាំងពួង ដោយអរហត្តមគ្គ ចិត្តវិសុទ្ធិ ដោយអត្ថថាមិនរាយមាយ

ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ យោ តត្ថ សំវរដ្ឋោ អយំ អធិសីលសិក្ខា យោ តត្ថ អវិក្ខេបដ្ឋោ អយំ អធិ-ចិត្តសិក្ខា យោ តត្ថ ទស្សនដ្ឋោ អយំ អធិប្ប-ញ្ញាសិក្ខា ។

[២១០] បស្សទ្ធីតិ នេក្ខម្មេន កាមច្ឆន្ទំ បដិ-ប្បស្សម្ភេតិ អព្យាបាទេន ព្យាបាទំ បដិប្បស្សម្ភេ-តិ ។ បេ ។ អរហត្តមគ្គេន សព្វក្កិលេសេ បដិ-ប្បស្សម្ភេតិ ។

ញាណន្តិ កាមច្ឆន្ទស្ស បហីនត្តា នេក្ខម្មំ ញាតដ្ឋេន ញាណំ ព្យាបាទស្ស បហីនត្តា អព្យា-បាទោ ញាតដ្ឋេន ញាណំ ។ បេ ។ សព្វក្កិលេសា-នំ បហីនត្តា អរហត្តមគ្គោ ញាតដ្ឋេន ញាណំ ។

ទស្សនន្តិ កាមច្ឆន្ទស្ស បហីនត្តា នេក្ខម្មំ ទិដ្ឋត្តា ទស្សនំ ព្យាបាទស្ស បហីនត្តា អព្យាបាទោ ទិដ្ឋត្តា ទស្សនំ ។ បេ ។ សព្វក្កិលេសានំ បហីន-ត្តា អរហត្តមគ្គោ ទិដ្ឋត្តា ទស្សនំ ។

ទិដ្ឋិវិសុទ្ធិ ដោយអត្ថថាឃើញ អត្ថនៃសេចក្តីសង្រួមណា ក្នុងសីលវិសុទ្ធិនោះ នេះឈ្មោះថាអធិសីលសិក្ខា អត្ថនៃសេចក្តីមិនរាយមាយណា ក្នុងចិត្តវិសុទ្ធិនោះ នេះឈ្មោះថាអធិចិត្តសិក្ខា អត្ថនៃសេចក្តីឃើញណា ក្នុងទិដ្ឋិវិសុទ្ធិនោះ នេះឈ្មោះថាអធិប្បញ្ញាសិក្ខា ។

[២១០] ពាក្យថា បស្សទ្ធិ សេចក្តីថា បុគ្គលរម្ងាប់កាមច្ឆន្ទៈ ដោយនេក្ខម្មៈ រម្ងាប់ព្យាបាទ ដោយមិនមានព្យាបាទ ។ បេ ។ រម្ងាប់កិលេសទាំងពួង ដោយអរហត្តមគ្គ ។

ពាក្យថា ញាណ សេចក្តីថា ឈ្មោះថានេក្ខម្មៈ ព្រោះលះកាមច្ឆន្ទៈ ឈ្មោះថាញាណ ព្រោះអត្ថថាដឹង ឈ្មោះថាអព្យាបាទ ព្រោះលះព្យាបាទ ។ បេ ។ ឈ្មោះថាញាណ ព្រោះអត្ថថាដឹង ឈ្មោះថាអរហត្តមគ្គ ព្រោះលះកិលេសទាំងពួង ឈ្មោះថាញាណ ព្រោះអត្ថថាដឹង ។

ពាក្យថា ទស្សនៈ សេចក្តីថា ឈ្មោះថានេក្ខម្មៈ ព្រោះលះកាមច្ឆន្ទៈ ឈ្មោះថាទស្សនៈ ព្រោះឃើញ ឈ្មោះថាអព្យាបាទ ព្រោះលះព្យាបាទ ឈ្មោះថាទស្សនៈ ព្រោះឃើញ ។ បេ ។ ឈ្មោះថាអរហត្តមគ្គ ព្រោះលះកិលេសទាំងពួង ឈ្មោះថាទស្សនៈ ព្រោះឃើញ ។

វិសុទ្ធីតិ កាមច្ឆន្ទំ បជហន្តោ នេក្ខម្មេន វិសុជ្ឈតិ ព្យាបាទំ បជហន្តោ អព្យាបាទេន វិសុជ្ឈតិ ។ បេ ។ សព្វកិលេសេ បជហន្តោ អរហត្តមគ្គេន វិសុជ្ឈតិ ។

[២១១] នេក្ខម្មន្តិ កាមានមេតំ និស្សរណំ យទិទំ នេក្ខម្មំ រូបានមេតំ និស្សរណំ យទិទំ អារុប្បំ យំ ខោ បន កិញ្ចិ ភូតំ សង្ខតំ បដិច្ចសមុប្បន្នំ និរោធោ តស្ស នេក្ខម្មំ ព្យាបាទស្ស អព្យាបាទោ នេក្ខម្មំ ថីនមិទ្ធស្ស អាលោកសញ្ញា នេក្ខម្មំ ។ បេ ។

និស្សរណន្តិ កាមានមេតំ និស្សរណំ យទិទំ នេក្ខម្មំ រូបានមេតំ និស្សរណំ យទិទំ អារុប្បំ យំ ខោ បន កិញ្ចិ ភូតំ សង្ខតំ បដិច្ចសមុប្បន្នំ និរោធោ តស្ស និស្សរណំ កាមច្ឆន្ទស្ស នេក្ខម្មំ និស្សរណំ ព្យាបាទស្ស អព្យាបាទោ និស្សរណំ ។ បេ ។ សព្វកិលេសានំ អរហត្តមគ្គោ និស្សរណំ ។

ពាក្យថា វិសុទ្ធិ សេចក្តីថា បុគ្គលកាលលះកាមច្ឆន្ទៈ រមែងបរិសុទ្ធ ដោយនេក្ខម្មៈ កាលលះព្យាបាទ រមែងបរិសុទ្ធ ដោយអព្យាបាទ ។ បេ ។ កាលលះកិលេសទាំងពួង រមែងបរិសុទ្ធ ដោយអរហត្តមគ្គ ។

[២១១] ពាក្យថា នេក្ខម្មៈ សេចក្តីថា ការរលាស់ចេញនូវកាម គឺនេក្ខម្មៈ ការរលាស់ចេញនូវរូប គឺអារុប្បៈ ធម្មជាតណានីមួយ កើតហើយ ដែលបច្ច័យប្រជុំតាក់តែង កើតព្រោះបច្ច័យ និងការរលត់វិញ ឈ្មោះថានេក្ខម្មៈ នៃធម្មជាតនោះ អព្យាបាទ ឈ្មោះថានេក្ខម្មៈ នៃព្យាបាទ អាលោកសញ្ញា ឈ្មោះថានេក្ខម្មៈ នៃថីនមិទ្ធៈ ។ បេ ។

ពាក្យថា និស្សរណៈ សេចក្តីថា ការរលាស់ចេញនូវកាម គឺនេក្ខម្មៈ ការរលាស់ចេញនូវរូប គឺអារុប្បៈ ធម្មជាតណានីមួយ កើតហើយ ដែលបច្ច័យប្រជុំតាក់តែង កើតព្រោះបច្ច័យ និងការរលត់វិញ ឈ្មោះថានិស្សរណៈ នៃធម្មជាតនោះ នេក្ខម្មៈ ឈ្មោះថានិស្សរណៈ នៃកាមច្ឆន្ទៈ អព្យាបាទ ឈ្មោះថានិស្សរណៈ នៃព្យាបាទ ។ បេ ។ អរហត្តមគ្គ ឈ្មោះថានិស្សរណៈ នៃកិលេសទាំងពួង ។

បរិវេកោតិ កាមច្ឆន្ទស្ស នេក្ខម្មំ បរិវេកោ ព្យាបាទស្ស អព្យាបាទោ បរិវេកោ ។ បេ ។ សព្វក្កិលេសានំ អរហត្តមគ្គោ បរិវេកោ ។

វោស្សគ្គោតិ នេក្ខម្មេន កាមច្ឆន្ទំ វោស្សជ្ជតិ អព្យាបាទេន ព្យាបាទំ វោស្សជ្ជតិ ។ បេ ។ អរហត្តមគ្គេន សព្វក្កិលេសេ វោស្សជ្ជតិ[១] ។

ចរិយាតិ កាមច្ឆន្ទំ[២] បជហន្តោ នេក្ខម្មេន ចរតិ ព្យាបាទំ បជហន្តោ អព្យាបាទេន ចរតិ ។ បេ ។ សព្វក្កិលេសេ បជហន្តោ អរហត្តមគ្គេន ចរតិ ។

ឈានវិមោក្ខោតិ នេក្ខម្មំ ជាយតីតិ[៣] ឈានំ កាមច្ឆន្ទំ ឈាបេតីតិ ឈានំ ជាយន្តោ[៤] មុច្ចតីតិ ឈានវិមោក្ខោ ឈាបេន្តោ មុច្ចតីតិ ឈានវិមោក្ខោ ជាយន្តីតិ ធម្មា ឈាបេន្តីតិ កិលេសេ ជាតេ ច[៥] ឈាបេ ច ជានាតីតិ ឈានវិមោក្ខោ[៦] អព្យាបាទោ ជាយតីតិ[៧] ឈានំ ព្យាបាទំ ឈាបេតីតិ

---

១ ម. វោស្សគ្គោតិ នេក្ខម្មេន កាមច្ឆន្ទំ វោស្សជ្ជតីតិ វោស្សគ្គោ អព្យាបាទេន ព្យាបាទំ វោស្សជ្ជតីតិ វោស្សគ្គោ ។ បេ ។ អរហត្តមគ្គេន សព្វក្កិលេសានំ វោស្សជ្ជតីតិ វោស្សគ្គោតិ ទិស្សន្តិ ។ ២ ម. កាមច្ឆន្ទស្ស ។ ៣ ឱ.ម. ឈាយតីតិ ។ ៤ ឱ.ម. ឈាយន្តោ ។ ៥ ឱ.ម. ឈាតេ ច ។ ៦ ម. យានឈាយី ។ ៧ ឱ.ម. ឈាយតីតិ ។

ពាក្យថា បរិវេក សេចក្តីថា នេក្ខម្មៈ ជាបរិវេក (ការស្ងប់ស្ងាត់) នៃកាមច្ឆន្ទៈ អព្យាបាទ ជាបរិវេក នៃព្យាបាទ ។ បេ ។ អរហត្តមគ្គ ជាបរិវេក នៃកិលេសទាំងពួង ។

ពាក្យថា វោស្សគ្គៈ សេចក្តីថា បុគ្គលលះកាមច្ឆន្ទៈ ដោយនេក្ខម្មៈ លះព្យាបាទ ដោយមិនមានព្យាបាទ ។ បេ ។ លះកិលេសទាំងពួង ដោយអរហត្តមគ្គ ។

ពាក្យថា ចរិយា (ការប្រព្រឹត្ត) សេចក្តីថា បុគ្គលកាលលះកាមច្ឆន្ទៈ ប្រព្រឹត្តដោយនេក្ខម្មៈ កាលលះព្យាបាទ ប្រព្រឹត្តដោយមិនមានព្យាបាទ ។ បេ ។ កាលលះកិលេសទាំងពួង ប្រព្រឹត្ត ដោយអរហត្តមគ្គ ។

ពាក្យថា ឈានវិមោក្ខ សេចក្តីថា ឈ្មោះថាឈាន ព្រោះនេក្ខម្មៈកើត ឈ្មោះថាឈាន ព្រោះដុតកាមច្ឆន្ទៈ ឈ្មោះថាឈានវិមោក្ខ ព្រោះកាលកើត រមែងរួច ឈ្មោះថាឈានវិមោក្ខ ព្រោះកាលដុត រមែងរួច ឈ្មោះថាធម៌ ព្រោះកើត ព្រោះដុត ឈ្មោះថាឈានវិមោក្ខ ព្រោះដឹងនូវកិលេសទាំងឡាយ ដែលកើតហើយផង ដែលឆេះហើយផង ឈ្មោះថាឈាន ព្រោះអព្យាបាទកើត ឈ្មោះថាឈាន ព្រោះដុតព្យាបាទ

ឈានំ អាលោកសញ្ញា ឋាយតីតិ[១] ឈានំ ។ បេ ។ ថីនមិទ្ធំ ឈាបេតីតិ ឈានំ ។ បេ ។ អរហត្តមគ្គោ ឋាយតីតិ[១] ឈានំ សព្វកិលេសេ ឈាបេតីតិ ឈានំ ឋាយន្តោ[២] មុច្ចតីតិ ឈានវិមោក្ខោ ឈាបេន្តោ មុច្ចតីតិ ឈានវិមោក្ខោ ឋាយន្តីតិ[៣] ធម្មា ឈាបេន្តីតិ កិលេសេ ឋាតេ ច[៤] ឈាបេ ច ជានាតីតិ ឈានវិមោក្ខោ ។

[២១២] ការោធិដ្ឋានជីវិតន្តិ កាមច្ឆន្ទំ បជហន្តោ នេក្ខម្មំ ការេតីតិ ការោសម្បន្នោ នេក្ខម្មវសេន ចិត្តំ អធិដ្ឋាតីតិ អធិដ្ឋានសម្បន្នោ ស្វាយំ ឯវំ ការោសម្បន្នោ អធិដ្ឋានសម្បន្នោ សមំ ជីវតិ នោ វិសមំ សម្មា ជីវតិ នោ មិច្ឆា វិសុទ្ធំ ជីវតិ នោ កិលិដ្ឋន្តិ អាជីវសម្បន្នោ ស្វាយំ ឯវំ ការោសម្បន្នោ អធិដ្ឋានសម្បន្នោ អាជីវសម្បន្នោ

---

១ ឱ.ម. ឈាយតីតិ ។ ២ ឱ.ម. ឈាយន្តោ ។ ៣ ឱ.ម. ឈាយន្តីតិ ។ ៤ ឱ.ម. ឈាតេ ច ។

ឈ្មោះថាឈាន ព្រោះអាលោកសញ្ញាកើត ។ បេ ។ ឈ្មោះថាឈាន ព្រោះដុតថីនមិទ្ធៈ ។ បេ ។ ឈ្មោះថា ឈាន ព្រោះអរហត្តមគ្គកើត ឈ្មោះថាឈាន ព្រោះដុតកិលេសទាំងពួង ឈ្មោះថាឈានវិមោក្ខ ព្រោះកាលកើត រមែងរួច ឈ្មោះថាឈានវិមោក្ខ ព្រោះកាលដុត រមែងរួច ឈ្មោះថាធម៌ ព្រោះកើត ព្រោះដុត ឈ្មោះថាឈានវិមោក្ខ ព្រោះដឹងកិលេសទាំងឡាយ ដែលកើតហើយផង ដែលឆេះហើយផង ។

[២១២] ពាក្យថា ភាវនា អធិដ្ឋាននិងការរស់នៅ សេចក្តីថា បុគ្គល ឈ្មោះថាអ្នកបរិបូណ៌ដោយភាវនា ព្រោះលះកាមច្ឆន្ទៈ ចម្រើននេក្ខម្មៈ ឈ្មោះថាអ្នកបរិបូណ៌ដោយអធិដ្ឋាន ព្រោះអធិដ្ឋានចិត្ត ដោយអំណាចនេក្ខម្មៈ ឈ្មោះថាអ្នកបរិបូណ៌ដោយអាជីវៈ ព្រោះបុគ្គលដែលបរិបូណ៌ដោយភាវនា បរិបូណ៌ដោយអធិដ្ឋាន យ៉ាងនេះនោះឯង រមែងរស់នៅស្មើ មិនមែនមិនស្មើទេ រស់នៅដោយត្រឹមត្រូវ មិនមែនដោយខុសទេ រស់នៅបរិសុទ្ធ មិនមែនសៅហ្មងទេ បុគ្គលដែលបរិបូណ៌ដោយភាវនា បរិបូណ៌ដោយអធិដ្ឋាន បរិបូណ៌ដោយអាជីវៈយ៉ាងនេះ

យញ្ញទេវ បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមតិ អមង្កុភូតោ តំ កិស្សហេតុ តថា ហិ សោ ភាវនាសម្បន្នោ អធិដ្ឋានសម្បន្នោ អាជីវសម្បន្នោ ព្យាបាទំ បជហន្តោ អព្យាបាទំ ភាវេតីតិ ភាវនាសម្បន្នោ ថីនមិទ្ធំ បជហន្តោ អាលោកសញ្ញំ ភាវេតីតិ ភាវនាសម្បន្នោ ឧទ្ធច្ចំ បជហន្តោ អវិក្ខេបំ ភាវេតីតិ ភាវនាសម្បន្នោ វិចិកិច្ឆំ បជហន្តោ ធម្មវវត្ថានំ ភាវេតីតិ ភាវនាសម្បន្នោ អវិជ្ជំ បជហន្តោ ញាណំ(១) ភាវេតីតិ ភាវនាសម្បន្នោ អរតឹ បជហន្តោ បាមុជ្ជំ ភាវេតីតិ ភាវនាសម្បន្នោ នីវរណំ បជហន្តោ បឋមជ្ឈានំ ភាវេតីតិ ភាវនាសម្បន្នោ ។ បេ ។ សព្វកិលេសេ បជហន្តោ អរហត្តមគ្គំ ភាវេតីតិ ភាវនាសម្បន្នោ អរហត្តមគ្គវសេន ចិត្តំ អធិដ្ឋាតីតិ អធិដ្ឋានសម្បន្នោ ស្វាយំ ឯវំ ភាវនាសម្បន្នោ អធិដ្ឋានសម្បន្នោ សមំ ជីវតិ នោ វិសមំ

---

១ ម. វិជ្ជំ ។

នោះឯង ចូលទៅរកបរិសទ្យណា ទោះខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី ក៏ជាអ្នកក្លាហាន ចូលទៅរក មិនមានអៀនអន់ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា បុគ្គលនោះបរិបូណ៌ដោយភាវនា បរិបូណ៌ដោយអធិដ្ឋាន បរិបូណ៌ដោយអាជីវៈ ឈ្មោះថាអ្នកបរិបូណ៌ដោយភាវនា ព្រោះលះព្យាបាទ ចម្រើនអព្យាបាទ ឈ្មោះថាអ្នកបរិបូណ៌ដោយភាវនា ព្រោះលះថីនមិទ្ធៈ ចម្រើនអាលោកសញ្ញា ឈ្មោះថា អ្នកបរិបូណ៌ដោយភាវនា ព្រោះលះឧទ្ធច្ចៈ ចម្រើនសេចក្តីមិនរាយមាយ ឈ្មោះថាអ្នកបរិបូណ៌ដោយភាវនា ព្រោះលះវិចិកិច្ឆា ចម្រើនការកំណត់នូវធម៌ ឈ្មោះថា អ្នកបរិបូណ៌ដោយភាវនា ព្រោះលះអវិជ្ជា ចម្រើនញាណ ឈ្មោះថាអ្នកបរិបូណ៌ដោយភាវនា ព្រោះលះអរតិ ចម្រើនបាមុជ្ជៈ ឈ្មោះថាអ្នកបរិបូណ៌ដោយភាវនា ព្រោះលះនីវរណៈ ចម្រើនបឋមជ្ឈាន ។ បេ ។ ឈ្មោះថាអ្នកបរិបូណ៌ដោយភាវនា ព្រោះលះកិលេសទាំងពួង ចម្រើនអរហត្តមគ្គ ឈ្មោះថាអ្នកបរិបូណ៌ដោយអធិដ្ឋាន ព្រោះអធិដ្ឋានចិត្តដោយអំណាចអរហត្តមគ្គ ឈ្មោះថាអ្នកបរិបូណ៌ដោយអាជីវៈ ព្រោះបុគ្គលដែលបរិបូណ៌ដោយភាវនា បរិបូណ៌ដោយអធិដ្ឋានយ៉ាងនេះនោះឯង តែងរស់នៅស្មើ មិនមែនមិនស្មើទេ

សម្មា ជីវតិ នោ មិច្ឆា វិសុទ្ធំ ជីវតិ នោ កិលិដ្ឋន្តិ អាជីវសម្បន្នោ ស្វាយំ ឃរំ ការជាសម្បន្នោ អជិដ្ឋានសម្បន្នោ អាជីវសម្បន្នោ យញ្ញទេវ បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមតិ អមង្កុភូតោ តំ កិស្សហេតុ តថា ហិ សោ ការជាសម្បន្នោ អជិដ្ឋានសម្បន្នោ អាជីវសម្បន្នោតិ ។

មាតិកកថា និដ្ឋិតា ។

បដិសម្ភិទាបករណំ សមត្តំ ។

---

*រស់នៅដោយត្រឹមត្រូវ មិនមែនដោយខុសទេ រស់នៅបរិសុទ្ធ មិនមែនសៅហ្មងទេ បុគ្គលដែលបរិបូណ៌ដោយភាវនា បរិបូណ៌ដោយអធិដ្ឋាន បរិបូណ៌ដោយអាជីវៈ យ៉ាងនេះនោះឯង ចូលទៅរកបរិសទ្យណា ទោះខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណ-បរិសទ្យក្តី ក៏ជាអ្នកក្លាហាន ចូលទៅរក មិនមានអៀនអន់ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា បុគ្គលនោះ បរិបូណ៌ដោយភាវនា បរិបូណ៌ដោយអធិដ្ឋាន បរិបូណ៌ដោយអាជីវៈ ។*

ចប់ មាតិកកថា ។

ចប់ បដិសម្ភិទាបករណៈ ។

---

# តត្រុទ្ទានំ ភវតិ

ញាណំ ទិដ្ឋិ ច អស្សាសំ
ឥន្ទ្រិយំ វិមោក្ខេន បញ្ចមំ[១]
គតិកម្មំ វិបល្លាសោ
មគ្គោ មណ្ឌេន[២] តេ ទស
យុគនទ្ធំ សច្ចពោជ្ឈង្គា[៣]
មេត្តា វិរាគេន បញ្ចមំ[៤]
បដិសម្ភិទា ធម្មចក្កំ
លោកុត្តរំ ពលំ សុញ្ញតោ តេ ទស[៥]
បញ្ញា ឥទ្ធិ អភិសមយោ
វិវេកំ ចរិយេន បញ្ចមំ[៦]
ចាដិហិរិយញ្ច សមសីសញ្ច
សតិប្បដ្ឋានំ វិបស្សនា
មាតិកាយ ច តេ ទសាតិ[៧] ។

---

១ ឱ. ម. ញាណំ ទិដ្ឋិ អានាបានំ ឥន្ទ្រិយំ វិមោក្ខបញ្ចមំ ។ ២ ឱ. ម. មណ្ឌោតិ ។ ៣ ឱ. ម. យុគនន្ធសច្ចពោជ្ឈង្គា ។ ៤ ឱ. វិរាគបញ្ចមា ។ ម. វិរាគបញ្ចមំ ។ ៥ ម. លោកុត្តរពលសុញ្ញតាតិ ទិស្សន្តិ ។ ៦ ឱ. ម. វិវេកោ ចរិយបញ្ចមោ ។ ៧ ម. បាដិហារិយសមសីសំ សតិប្បដ្ឋានំ វិបស្សនា មាតិកាតីតិ ទិស្សន្តិ ។ ឱ. បាតិហារិយញ្ច សមសីសញ្ច សតិ វិបស្សនាមាតិកាតីតិ ទិស្សន្តិ ។

ឧទ្ទានក្នុងបដិសម្ភិទាបករណៈនោះ គឺ

*ញាណ ១ ទិដ្ឋិ ១ អស្សាសៈ ១ ឥន្ទ្រិយ ១ ជាគម្រប់ ៥ នឹងវិមោក្ខ គតិ ១ កម្ម ១ វិបល្លាស ១ មគ្គ ១ ជាគម្រប់ ១០ នឹងមណ្ឌៈ យុគនទ្ធៈ ១ សច្ចៈ ១ ពោជ្ឈង្គ ១ មេត្តា ១ ជាគម្រប់ ៥ នឹងវិរាគៈ បដិសម្ភិទា ១ ធម្មចក្ក ១ លោកុត្តរៈ ១ ពលៈ ១ ជាគម្រប់ ១០ នឹងសុញ្ញៈ បញ្ញា ១ ឥទ្ធិ ១ អភិសមយៈ ១ វិវេក ១ ជាគម្រប់ ៥ នឹងចរិយា បាដិហារិយៈ ១ សមសីសៈ ១ សតិប្បដ្ឋាន ១ វិបស្សនា ១ ជាគម្រប់ ១០ នឹងមាតិកា ។ វគ្គទាំង ៣*

តិវគ្គោ យស្ស វិក្ខោចោ
បដិសម្ភិទាបករណោ
អនន្តនយមគ្គេសុ
គម្ភីរេ សាគរូបមោ
នភំ ច តារកាកិណ្ណំ
ថូលោ ជាតស្សរោ យថា
កជិកានំ វិលាសាយ
យោគិនំ ញាណជោតនន្តិ ។

ឥតិ បដិសម្ភិទា និដ្ឋិតា ។

*ដែលមាន ក្នុងបដិសម្ភិទាបករណៈ ជាវគ្គដ៏ទូលាយ ជ្រាលជ្រៅ ក្នុងផ្លូវមានន័យមិនមានទីបំផុត មានឧ-បមាដោយសាគរ ឬដូចពពកដែលដេរដាសដោយផ្កាយ ឬក៏ដូចជាតស្រះដ៏ទូលាយ ជាវគ្គបំភ្លឺញាណរបស់ពួកព្រះយោគី ទាំងដើម្បីទូលាយ* (គំនិតប្រាជ្ញាស្មារតី) *របស់ពួកលោកអ្នកសម្តែងធម៌ ។*

ចប់ បដិសម្ភិទា តែប៉ុណ្ណេះ ។

---

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស បដិសម្ភិទាមគ្គោ

# តតិយោ ភាគោ

## មាតិកា អង្កេ


| | | |
|---|---|---|
| មហាវគ្គេ | មណ្ឌបេយ្យកថា | ១ |
| យុគនទ្ធវគ្គេ | យុគនទ្ធកថា | ១៥ |
| | សច្ចកថា | ៤១ |
| | ពោជ្ឈង្គកថា | ៦៤ |
| | មេត្តាកថា | ៩៦ |
| | វិរាគកថា | ១១៩ |
| | បដិសម្ភិទាកថា | ១៣២ |
| | ធម្មចក្កកថា | ១៦២ |
| | លោកុត្តរកថា | ១៧៩ |
| | ពលកថា | ១៨៣ |
| | សុញ្ញកថា | ២០៣ |
| បញ្ញាវគ្គេ | មហាបញ្ញាកថា | ២២០ |
| | ឥទ្ធិកថា | ២៦៤ |

# សុត្តន្តបិដក

# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

# តតិយភាគ

## មាតិកា ទំព័រ


| | | |
|---|---|---|
| មហាវគ្គ | មណ្ឌបេយ្យកថា | ១ |
| យុគនទ្ធវគ្គ | យុគនទ្ធកថា | ១៥ |
| | សច្ចកថា | ៤១ |
| | ពោជ្ឈង្គកថា | ៦៤ |
| | មេត្តាកថា | ៩៦ |
| | វិរាគកថា | ១១៩ |
| | បដិសម្ភិទាកថា | ១៣២ |
| | ធម្មចក្កកថា | ១៦២ |
| | លោកុត្តរកថា | ១៧៩ |
| | ពលកថា | ១៨៣ |
| | សុញ្ញកថា | ២០៣ |
| បញ្ញាវគ្គ | មហាបញ្ញាកថា | ២២០ |
| | ឥទ្ធិកថា | ២៦៤ |

# មាតិកាបត្តានិ

| មាតិកា | | អង្កេ |
|---|---|---|

បញ្ញាវគ្គ អភិសមយកថា........................................................ ២៨៦
វិវេកកថា ................................................................. ២៩៦
ចរិយាកថា ..............................................................៣០៩
បាដិហារិយកថា .......................................................៣១២
សមសីសកថា...........................................................៣១៨
សតិប្បដ្ឋានកថា .......................................................៣២១
វិបស្សនាកថា...........................................................៣២៩
មាតិកកថា...............................................................៣៤៥
ឧទ្ទានំ.................................................................... ៣៥៣

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ

បញ្ញាវគ្គ អភិសមយកថា ........................................ ២៨៦
វិវេកកថា ........................................ ២៩៦
ចរិយាកថា ........................................ ៣០៩
បាដិហារិយកថា ........................................ ៣១២
សមសីសកថា ........................................ ៣១៨
សតិប្បដ្ឋានកថា ........................................ ៣២១
វិបស្សនាកថា ........................................ ៣២៩
មាតិកកថា ........................................ ៣៤៥
ឧទ្ទាន ........................................ ៣៥៣

---

